Layout Histor.qxd 2/10/07 10:08 AM Page 1

# ប្រវត្តិ

# ព្រះសហគមន៍គ្រីស្តបរិស័ទ

រៀបរៀងដោយលោកបូជាចារ្យ F. Ponchaud

Layout Histor.qxd 2/10/07 10:08 AM Page 2

# មាតិកា


| | | | |
|---|---|---|---|
| | ពាក្យលំនាំ | ទំព័រ | 3 - 5 |
| ជំពូក ១ : | កំណើតព្រះសហគមន៍ | - | 6 - 17 |
| ជំពូក ២ : | គ្រីស្តបរិស័ទរស់នៅក្នុងសង្គមដែលមិនយល់ចិត្តគេ | - | 18 - 41 |
| ជំពូក ៣ : | ការរស់នៅជាគ្រីស្តបរិស័ទសតវត្សដើមដំបូង | - | 42 - 69 |
| ជំពូក ៤ : | ព្រះសហគមន៍នៅក្នុងសម័យគ្រីស្តបរិស័ទ | - | 70 - 91 |
| ជំពូក ៥ : | កំណើតនៃធម៌ប្រកាសជំនឿ | - | 92 - 113 |
| ជំពូក ៦ : | គ្រូបាធ្យាយនៃព្រះសហគមន៍ | - | 114 - 127 |
| ជំពូក ៧ : | មជ្ឈិមវ័យនៅទ្វីបអឺរ៉ុប | - | 128 - 139 |
| ជំពូក ៨ : | សង្គមដែលសុទ្ធតែជាគ្រីស្តបរិស័ទ | - | 140 - 159 |
| ជំពូក ៩ : | ការកែទម្រង់ព្រះសហគមន៍ | - | 160 - 169 |
| ជំពូក ១០ : | ព្រះសហគមន៍កាតូលិកកែទម្រង់ខ្លួនឯង | - | 170 - 181 |
| ជំពូក ១១ : | ការប្រកាសដំណឹងល្អនៅលើពិភពលោកទាំងមូល | - | 182 - 197 |
| ជំពូក ១២ : | បដិវត្តន៍នៅទ្វីបអឺរ៉ុប និង ឧស្សាហូបនីយកម្ម | - | 198 - 207 |
| ជំពូក ១៣ : | ព្រះសហគមន៍ និង សង្គមថ្មី | - | 208 - 219 |
| ជំពូក ១៤ : | គ្រីស្តសាសនាលាតសន្ធឹងលើពិភពលោក | - | 220 - 233 |
| ជំពូក ១៥ : | ព្រះសហគមន៍តាមមហាសន្និបាតវ៉ាទីកង់ទី ២ | - | 234 - 248 |

Layout Histor.qxd 2/10/07 10:08 AM Page 3

# ពាក្យលំនាំ

គ្រីស្ដបរិស័ទគឺអ្នកផ្ញើជីវិតទាំងស្រុងលើលោកយេស៊ូ ដោយប្រកាសថា លោកជា «ព្រះគ្រីស្ដ» គឺព្រះអង្គដែលប្រទានសុភមង្គលម៉្យាងមកឲ្យខ្លួន ព្រះអង្គធ្វើឲ្យព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់តាំងពីដើមរៀងមក កើតជារូបរាង ។ គេក៏ប្រកាសទៀតថា លោកជា «ព្រះអម្ចាស់» គឺមានឋានៈស្មើនឹងព្រះជាម្ចាស់ (កក ២,៣៦) និងគ្រប់គ្រងលើអ្វីៗទាំងអស់ ។

លោក**យេស៊ូ**ជាជនជាតិយូដា រស់នៅដើមគ្រីស្ដសករាជ ។ លោកមិនសរសេរគម្ពីរណាមួយសោះ គឺសាវ័កនិងអ្នកជឿលើលោក បានបញ្ជូនបន្ដសេចក្ដីដែលលោកប្រៀនប្រដៅមកយើងតៗគ្នារហូតដល់សព្វថ្ងៃ ។ គ្រីស្ដបរិស័ទដើមដំបូងចែងសៀវភៅស្ដីអំពីសេចក្ដីដែលគេនឹកចាំពីលោកយេស៊ូ និងសេចក្ដីដែលគេជឿនោះ ។ សៀវភៅទាំងនោះនិពន្ធនៅដើមគ្រីស្ដសករាជ មានចំណងជើងថា «គម្ពីរសម្ពន្ធមេត្រីថ្មី» ។ មុនដំបូង អ្នកជឿពន្យល់ជំនឿរបស់គេទៅតាមអរិយធម៌របស់ខ្លួន គឺតាមអរិយធម៌ជនជាតិយូដាដែលនិយាយនិងសរសេរភាសាអារ៉ាមេអាំង ហើយយោងសេចក្ដី និងនិមិត្តរូបជាច្រើនពីគម្ពីរសម្ពន្ធមេត្រីរបស់ជនជាតិយូដា ដែលគ្រីស្ដបរិស័ទសន្មតហៅថា «គម្ពីរសម្ពន្ធមេត្រីចាស់» ។

រីឯលោកប៉ូលវិញ លោកសរសេរលិខិតផ្ញើជូនគ្រីស្ដបរិស័ទជាតិក្រិក ជាឯកសារនិពន្ធមុនគេអំពីជំនឿនៃគ្រីស្ដសាសនា (គ.ស ៥១-៦៣) លោកនិពន្ធតាមអរិយធម៌ក្រិក ។ បន្ទាប់មកអ្នកនិពន្ធគម្ពីរសម្ពន្ធមេត្រីថ្មីសុទ្ធតែសរសេរជាភាសាក្រិក តាមអរិយធម៌យូដានិងក្រិកខ្លះ ។ ជួនកាលយើងពិបាកយល់អត្ថន័យសៀវភៅដែលគេសរសេរនោះណាស់ មកពីយើងមិនសូវស្គាល់គម្ពីរសម្ពន្ធមេត្រីចាស់និងអរិយធម៌របស់គេ ។

បន្ទាប់មក គ្រីស្ដសាសនាសាយភាយទៅស្រុកដែលនៅជុំវិញសមុទ្រមេឌីទែរ៉ាណេ ហើយអ្នកជឿបកស្រាយគម្ពីរ និងរិះគិតអំពីជំនឿរបស់ខ្លួនតាមរបៀបនិងតាមអរិយធម៌របស់គេ ។ ក្រោយមកទៀត គ្រីស្ដសាសនាសាយភាយនៅទ្វីបអឺរ៉ុប ហើយជនជាតិអឺរ៉ុបបង្កើតអរិយធម៌ម៉្យាង គឺគេលាយអរិយធម៌របស់ខ្លួនជាមួយនឹងជំនឿនៃគ្រីស្ដសាសនា បង្កើតទៅជា «អរិយធម៌នៃគ្រីស្ដសាសនា» ។ តាំងពីសតវត្សទី ១៦ មក គ្រីស្ដបរិស័ទអឺរ៉ុបចេញទៅផ្សព្វផ្សាយគ្រីស្ដសាសនាក្នុងពិភពលោកទាំងមូល ។

ហេតុដូចនេះហើយ បានជាគ្រីស្ដបរិស័ទខ្លះរស់នៅសព្វថ្ងៃនេះ នាំគ្នាសួរថា តើគ្រីស្ដសាសនាដែលយើងកាន់នេះ ស្របតាមជំនឿរបស់គ្រីស្ដទូតពីដើម ឬយ៉ាងណា? ប្រហែលគ្រីស្ដសាសនាលាយជាមួយអរិយធម៌អឺរ៉ុបទេដឹង? ដូច្នេះ ទើបគ្រីស្ដបរិស័ទសម័យឥឡូវ យកចិត្តទុកដាក់រៀនប្រវត្តិនៃព្រះសហគមន៍យ៉ាងល្អិតល្អន់ ដើម្បីឲ្យដឹងថា គ្រប់សម័យ តើគ្រីស្ដបរិស័ទអនុវត្តតាមព្រះឱវាទព្រះយេស៊ូយ៉ាងណា? តើគេប្រកាសជំនឿចំពោះព្រះគ្រីស្ដតែមួយព្រះអង្គ តាមអរិយធម៌របស់គេយ៉ាងណា? តើយើងជាគ្រីស្ដបរិស័ទនៅប្រទេសកម្ពុជានាសតវត្សទី ២១ នេះ អាចប្រកាសជំនឿរបស់ខ្លួនឲ្យប្រជាជនកម្ពុជាងាយជឿ តាមអរិយធម៌របស់ខ្លួនបានយ៉ាងណាដែរ?

ព្រះយេស៊ូក៏មិនបាត់ចែងព្រះសហគមន៍តាមរចនាសម្ពន្ធសព្វថ្ងៃដែរ គឺសាវ័កនិងអ្នកជឿលើព្រះអង្គ បានបាត់ចែងរចនាសម្ពន្ធព្រះសហគមន៍តាមសម័យនីមួយៗ ឲ្យត្រូវតាមរបៀបចាត់ចែងរចនាសម្ពន្ធក្នុងសង្គមនៃប្រទេសរបស់គេ ។ ឧប. ព្រះយេស៊ូជ្រើសរើសសាវ័ក ១២ នាក់ ទុកជាតំណាងប្រជាជនអ៊ីស្រាអែល ឲ្យធ្វើជាគ្រីស្ដទូត និងដាក់លោកសិលាធ្វើជាអ្នកណែនាំ ។

Layout Histor.qxd 2/10/07 10:08 AM Page 4

ក្រោយមក គ្រីស្តទូតជ្រើសរើសនិងតែងតាំង ៧ នាក់ទៀតឲ្យទទួលខុសត្រូវលើការប្រកាសដំណឹងល្អទៅសាសន៍ដទៃ ។ នៅសម័យក្រោយ គេបាត់បែងរចនាសម្ពន្ធនៃព្រះសហគមន៍តាមរចនាសម្ពន្ធចក្រភពរ៉ូម៉ាំង បន្ទាប់គេបាត់បែងតាមរបៀបរាជានិយម និងបន្ទាប់មកទៀតគេបាត់បែងឲ្យស្របតាមរបបប្រជាធិបតេយ្យ ។ ដូច្នេះ យើងជាគ្រីស្តបរិស័ទនៅសតវត្សទី ២១ ត្រូវតែរករបៀបបាត់បែងព្រះសហគមន៍ឲ្យស្របតាមរបៀបបច្ចុប្បន្ន ។ យើងត្រូវរករបៀបបាត់បែងមុខងារបម្រើព្រះសហគមន៍ (អភិបាល បូជាចារ្យ ឧបដ្ឋាក) នាបច្ចុប្បន្នកាលតាមរបៀបថ្មីដែរ ។ ប៉ុន្តែ ត្រូវនឹកជានិច្ចថា សព្វថ្ងៃគ្មានប្រទេសណា ឬព្រះសហគមន៍ណា អាចរស់នៅឯកឯងបានទេ គឺត្រូវមានទំនាក់ទំនងជាមួយព្រះសហគមន៍ឯទៀតៗ ដោយមានលោកអភិបាលក្រុងរ៉ូមជាអ្នកបង្រួបបង្រួមព្រះសហគមន៍ទាំងឡាយឲ្យមានទំនាក់ទំនងជាមួយគ្នា ។

ការសិក្សាប្រវត្តិព្រះសហគមន៍អាចបន្ថែមជំនឿរបស់ខ្លួន នាំឲ្យយល់ឃើញថាមានជំនឿតែមួយ តែមានរបៀបប្រកាសជំនឿនេះផ្សេងៗពីគ្នា ស្របតាមអរិយធម៌និងតាមសម័យអ្នកប្រកាសនោះ ។ មានព្រះវិញ្ញាណតែមួយដែលណែនាំព្រះសហគមន៍គ្រប់សម័យ គឺណែនាំគ្រីស្តបរិស័ទឲ្យប្រកាសជំនឿតាមអរិយធម៌របស់ខ្លួន ។ ព្រះអង្គពិតជាប្រភពនៃជីវិត ដែលធ្វើឲ្យជីវិតផុសឡើងជានិច្ចពីផ្ទៃព្រះសហគមន៍ ។ យើងជាគ្រីស្តបរិស័ទនៅសតវត្សទី ២១ ប្រៀបដូចជា ***«ធម្មាចារ្យម្នាក់ដែលទទួលការអប់រំអំពីព្រះរាជ្យ*** *(គឺគ្រីស្តបរិស័ទ)* ***ជាមេផ្ទះ*** *(គឺអ្នកដឹកនាំព្រះសហគមន៍)* ***ដែលយកទ្រព្យទាំងចាស់*** *(ព្រះបន្ទូលរបស់ព្រះយេស៊ូ)* ***ទាំងថ្មី*** *(ត្រូវតាមសភាពការណ៍របស់ខ្លួន)* ***ពីឃ្លាំងរបស់គាត់*** *(ពីជំនឿរបស់ព្រះសហគមន៍)» (មថ ១៣, ៥២)* ។ នៅពេលយើងរិះគិតអំពីប្រវត្តិព្រះសហគមន៍ ត្រូវនឹកជានិច្ចអំពីព្រះបន្ទូលរបស់ព្រះយេស៊ូដែលបាត់គ្រីស្តទូតឲ្យទៅ៖ ***«ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសាននៃពិភពលោក»*** (មថ ២៨,២០) ។

ព្រះសហគមន៍ប្រៀបដូចជាស្ត្រីម្នាក់ ដែលចាស់ជរាណាស់ទៅហើយ តែនៅក្មេងជានិច្ច ដូចលោក**ហែរម៉ាស**សសរសេរនៅសម័យព្រះសហគមន៍ដើមដំបូង ។ (1)

ដើមសតវត្សទី ២ លោកហែរម៉ាស (Hermas) សរសេរសៀវភៅមួយក្រោមចំណងជើងថា «*លោកគង្វាល*» ។ លោកយកចិត្តទុកដាក់អំពីបញ្ហានានាដែលកើតឡើងក្នុងព្រះសហគមន៍នាសម័យនោះ ជាពិសេសអំពីអគ្គសញ្ញាលើកលែងទោស ។ លោកថែងថា លោកស្រមៃឃើញទេវទូតនិម្មិតខ្លួនជាគង្វាលម្នាក់ដ៏ក្មេង ។ យុវជនគង្វាលនោះអាចឆ្លើយតបនឹងសំនួរទាំងប៉ុន្មានរបស់លោក ។ ព្រះសហគមន៍ប្រៀបដូចជាយាយចាស់ជរាម្នាក់ ព្រោះព្រះជាម្ចាស់មានព្រះតម្រិះនឹកអំពីព្រះសហគមន៍តាំងពីដើមរៀងមក ប៉ុន្តែ គ្រីស្តបរិស័ទមិនសូវយកចិត្តទុកដាក់នឹងព្រះជាម្ចាស់ ហើយអំពើបាបរបស់គេបណ្ដាលឲ្យយាយនេះបាត់បង់កម្លាំង និងអំណរសប្បាយរបស់ខ្លួន ។

## ប្រវត្តិព្រះសហគមន៍

លោក**អឺសែប** (Eusèbe) ជាអភិបាលព្រះសហគមន៍នៅក្រុងសេសារេ ស្រុកប៉ាឡេស្ទីន *(កើតប្រ.នៅ គ.ស. ២៦៣ ស្លាប់ប្រ. នៅគ.ស. ៣៤០)* ។ គ្រីស្តបរិស័ទបាត់លោកទុកជា «*បិតានៃប្រវត្តិព្រះសហគមន៍*» ព្រោះលោកនិពន្ធសៀវភៅមួយក្រោមចំណងជើងថា «*ប្រវត្តិព្រះសហគមន៍*» គឺលោកចម្លងឯកសារពីសតវត្សដើមដំបូងជាច្រើន ។ មានតែលោកទេដែលចម្លងឯកសារទាំងនោះ ប្រសិនបើលោកមិនបានចម្លងទុកទេ ឯកសារទាំងនោះមុខជាបាត់បង់ទៅហើយ ។ លោកអឺសែបពន្យល់អំពីគោលបំណងរបស់លោក នៅពេលចាប់ផ្ដើមនិពន្ធសៀវភៅនេះ ។ (2)

Layout Histor.qxd 2/10/07 10:08 AM Page 5

## ① ព្រះសហគមន៏ប្រៀបដូចជាស្ត្រីចាស់ជរាម្នាក់ ដែលកាន់តែក្មេងទៅៗ

យាយចាស់ជរាម្នាក់ស្លៀកពាក់យ៉ាងស្រស់ឆើតឆាយមកដល់ ទាំងកាន់សៀវភៅនៅដៃ ។ យាយអង្គុយម្នាក់ឯង ហើយជម្រាបសួរខ្ញុំថា «ជម្រាបសួរ**ហោរម៉ាស**» ។ ខ្ញុំកំពុងតែកើតទុក្ខព្រួយខ្ញុំយំផង ឆ្លើយតបទៅគាត់ផង «ជម្រាបសួរលោកយាយ» ។ (...)

ខ្ញុំសួរយុវជនម្នាក់ថា៖ តើលោកយាយនេះជានរណា?

យុវជននោះឆ្លើយមកខ្ញុំថា៖ គឺព្រះសហគមន៍ ។

ខ្ញុំសួរទៀតថា៖ ហេតុអ្វីបានជាលោកយាយចាស់ម្ល៉េះ?

យុវជននោះឆ្លើយថា៖ មកពីព្រះជាម្ចាស់បង្កើតព្រះសហគមន៍មុនអ្វីៗទាំងអស់ ។ ហេតុនេះហើយបានជាគាត់ចាស់ ។ ព្រះអង្គបានសូនពិភពលោកសម្រាប់ព្រះសហគមន៍ ។

(...) ពេលខ្ញុំនិម្មិតឃើញលោកយាយលើកដំបូង គាត់ជាដូនចាស់ម្នាក់អង្គុយលើកៅអីធំមួយ ។ កាលខ្ញុំនិម្មិតឃើញលោកយាយលើកទីពីរ គាត់មានរូបរាងក្មេងជាងពីមុន តែខ្លួននិងសក់គាត់នៅដដែល គាត់មានប្រសាសន៍មកខ្ញុំទាំងឈរ ហើយក៏សប្បាយចិត្តជាងពីមុនដែរ ។ ពេលខ្ញុំនិម្មិតឃើញលោកយាយលើកទីបី គាត់ក្មេងទាំងស្រុង ហើយស្អាតណាស់ គឺគាត់មានសក់សស្គុះគាត់អង្គុយលើជើងម៉ា ស្រស់ស្រាយរីករាយទៀតផង ។

(...) យុវជននោះនិយាយមកខ្ញុំថា «ពេលអ្នកនិម្មិតឃើញលើកដំបូង លោកយាយចាស់ជរានិងអង្គុយលើកៅអី ព្រោះវិញ្ញាណរបស់អ្នករាល់គ្នាចាស់បាត់សម្រស់ ហើយល្វើយគ្មានកម្លាំង ដោយអ្នករាល់គ្នាមិនសូវយកចិត្តទុកដាក់នឹងព្រះជាម្ចាស់ ហើយក៏មានចិត្តសង្ស័យដែរ ។ (...)

ពេលអ្នកនិម្មិតឃើញលោកយាយលើកទីពីរ គាត់ឈរ ទឹកមុខគាត់ក្មេង និងរីករាយជាងពីមុន ប៉ុន្តែ ខ្លួននិងសក់ចាស់ដដែល (...) ។ ព្រះអម្ចាស់អាណិតអាសូរអ្នករាល់គ្នា ព្រះអង្គធ្វើឲ្យវិញ្ញាណរបស់អ្នករាល់គ្នាទៅជាក្មេង ។ អ្នករាល់គ្នាបោះបង់ភាពទន់ខ្សោយ ហើយអ្នករាល់គ្នាមានកម្លាំងឡើងវិញ និងពង្រឹងជំនឿរបស់ខ្លួន ។ (...)

ពេលអ្នកឃើញលោកយាយនៅលើកទីបី គាត់ក្មេង រូបរាងស្រស់សោភា និងស្រស់ស្រាយរីករាយជាងពីមុន (...) ។ អស់អ្នកដែលប្រែចិត្តគំនិត មុខជានឹងទៅជាក្មេងទាំងស្រុង ហើយមានជំនឿរឹងប៉ឹងពុំខាន (...) ។

ហោរម៉ាស "លោកគង្វាល" ២,២; ៨,១; ១៨,៣-៤; ២០; ២១

## ② គោលបំណងលោកអឺសែប

ខ្ញុំមានបំណងរៀបរាប់អំពីក្រុមគ្រីស្តទូតដ៏វិសុទ្ធជាបន្តបន្ទាប់រហូតមកសព្វថ្ងៃ សេចក្តីដែលកើតឡើង ចាប់តាំងពីព្រះយេស៊ូជាព្រះសង្គ្រោះនៃយើងរហូតមកដល់យើងដែរ ព្រមទាំងស្នាដៃដ៏អស្ចារ្យជាច្រើនដែលគ្រីស្តបរិស័ទបានសម្រេចតាមប្រវត្តិសាស្ត្រដ៏យូរលង់របស់ព្រះសហគមន៍ ។ ខ្ញុំនឹងរៀបរាប់អំពីគ្រីស្តបរិស័ទដ៏ឆ្នើមដែលធ្វើជាប្រធាននៃព្រះសហគមន៍ និងណែនាំសហគមន៍នានាដ៏ប្រសើរតាមប្រវត្តិសាស្ត្រ គឺអស់លោកដែលជាទូតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយប្រកាសក្តី ឬដោយនិពន្ធសៀវភៅក្តី តាមសម័យនីមួយៗ ។ ខ្ញុំនឹងថែងអំពីឈ្មោះ អំពីឋានៈ អំពីសម័យរបស់បុគ្គលទាំងឡាយ ដែលបណ្តោយខ្លួនឲ្យវង្វេង ចាញ់បោក ដោយជាប់ចិត្តនឹងសេចក្តីថ្មីៗ រួចបែរទៅជាអ្នកប្រកាសវិជ្ជាភូតភរកុហកទៅវិញ ។ គេប្រៀបដូចជាចចកដ៏កាចសាហាវ ដែលបានបំផ្លាញហ្វូងចៀមរបស់ព្រះគ្រីស្តយ៉ាងឃោរឃៅ ។ ខ្ញុំនឹងថែងអំពីគ្រោះកាចដែលកើតដល់ជនជាតិយូដាទាំងមូល ក្រោយពីគេបានឃុបឃិតធ្វើបាបព្រះសង្គ្រោះនៃយើង ។ ខ្ញុំនឹងថែងអំពីការប្រយុទ្ធរបស់សាសន៍ដទៃប្រឆាំងនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ថែងអំពីវីរបុរសដែលទទួលទារុណកម្ម ហើយស្លាប់ព្រោះតែព្រះបន្ទូលនោះតាមកាលៈទេសៈនានា ខ្ញុំនឹងថែងថែមទៀតអំពីគ្រីស្តបរិស័ទផ្តល់សក្ខីភាពសព្វថ្ងៃ និងអំពីព្រះហឫទ័យមេត្តាករុណាប្រោសប្រណីសន្តោសរបស់ព្រះយេស៊ូជាព្រះសង្គ្រោះនៃយើង ។ នេះជាសេចក្តីទាំងអស់ ដែលខ្ញុំមានបំណងនឹងសរសេរទុក ។

ខ្ញុំមិនចាប់ផ្តើមសរសេររឿងផ្សេងក្រៅពីព្រះយេស៊ូជាព្រះអម្ចាស់ ជាព្រះសង្គ្រោះនៃយើង និងជាព្រះគ្រីស្តរបស់ព្រះជាម្ចាស់ប្រសូតមកជាមនុស្សនោះទេ ។

ប៉ុន្តែ ការនិពន្ធសេចក្តីទាំងនេះហួសពីកម្លាំងខ្ញុំហើយ ហេតុនេះសូមអ្នកអានមេត្តាអនុគ្រោះខ្ញុំផង ព្រោះខ្ញុំពុំអាចបំពេញពាក្យសន្យារបស់ខ្ញុំនេះយ៉ាងពេញលេញបានទេ ដ្បិតខ្ញុំជាអ្នកនិពន្ធមុនគេ ដែលចាប់ផ្តើមសាកល្បងសរសេរសៀវភៅបែបនេះ ។ ខ្ញុំដូចជាត្រូវត្រាយផ្លូវដ៏ស្ងាត់ជ្រងំដែលគ្មាននរណាបានដើរពីមុននោះឡើយ ។

អឺសែប "ប្រវត្តិនៃព្រះសហគមន៍" ១,១



Layout Histor.qxd 2/10/07 10:08 AM Page 7



# កំណើតព្រះសហគមន៍

## ក_ សម័យគ្រីស្តទូត

គ្រីស្តបរិស័ទជាអ្នកផ្ញើជីវិតទាំងស្រុងទៅលើលោក**យេស៊ូ**ដោយប្រកាសថា លោកជា «***ព្រះគ្រីស្ត***» និងជា «***ព្រះអម្ចាស់***» ។

លោកយេស៊ូកើតប្រហែលនៅឆ្នាំ ៧ ឬ ៦ មុនគ្រីស្តសករាជ ។ លោកសម្តែងធម្មទេសនាប្រហែលអស់រយៈពីរឆ្នាំកន្លះ គឺតាំងពីចុង គ.ស. ២៧ (ឬពីដើម គ.ស. ២៨) រហូតដល់ថ្ងៃទី ៧ មេសា គ.ស. ៣០ ។ លោកប្រៀនប្រដៅជនជាតិយូដាតាមរបៀបព្យាការីពីដើម តែលោកប្រកាសដំណឹងល្អថា បន្តិចទៀតព្រះជាម្ចាស់យាងមកគ្រងរាជ្យ គឺយាងមករំដោះប្រជារាស្ត្រព្រះអង្គឲ្យរួចផុតពីអ្វីៗទាំងអស់ដែលសង្កត់សង្កិនគេ មនុស្សយើងមានព្រះបិតាតែមួយព្រះអង្គដែលស្រឡាញ់យើង ។ ហេតុនេះហើយ ត្រូវប្រែចិត្តគំនិតទៅរកព្រះជាម្ចាស់ដោយចិត្តស្មោះ និងត្រូវស្រឡាញ់អ្នកផងទាំងពួងដូចបងប្អូន ដោយមិនរើសមុខនរណាឡើយ ។ លោកតែងតែទាក់ទងជាមួយមនុស្សគ្រប់ប្រភេទ ទាំងមនុស្សល្អ ទាំងមនុស្សខិលខូច ទាំងជនបរទេស បណ្តាលឲ្យអ្នកកាន់សាសនាយូដាយ៉ាងតឹងរ៉ឹងទាស់ចិត្តជាខ្លាំង ។ លោកយេស៊ូតែងស្តីបន្ទោសគេថា ទោះបីគេប្រតិបត្តិតាមវិន័យសាសនាយ៉ាងតឹងរ៉ឹងក្តី ក៏ចិត្តរបស់គេនៅឆ្ងាយពីព្រះជាម្ចាស់ដែរ ។ កិច្ចការដែលលោកធ្វើ និងពាក្យលោកប្រកាសនោះ នាំឲ្យអ្នកដឹកនាំសាសនាយូដាខឹងប្រឆាំងនឹងលោក ហើយចោទថា លោកមានបំណងចង់បំផ្លាញសាសនារបស់គេ ។ ពួកគេក៏ចាប់លោក និងសម្លាប់យ៉ាងសែនឃោរឃៅ សែនអាម៉ាស់ទុកដូចជាជនឧក្រិដ្ឋ ដោយភ្ជាប់លោកទៅលើឈើឆ្កាងតាមរបៀបជនជាតិរ៉ូម៉ាំងធ្វើឃាតទាសករ ឬអ្នកដែលបះបោរប្រឆាំងនឹងរដ្ឋអំណាច ។ លោកយេស៊ូទទួលមរណភាពប្រហែលថ្ងៃទី ៧ មេសា គ.ស. ៣០ ។

តែក្រោយមក លោកសម្តែងខ្លួនឲ្យសាវ័កជឿថា លោកទទួលជីវិតថ្មីដ៏រុងរឿងពីព្រះជាម្ចាស់ លោកពោរពេញដោយសិរីរុងរឿងរបស់ព្រះបិតា ព្រះជាម្ចាស់បានតែងតាំងលោកជា «**ព្រះគ្រីស្ត និង ជាព្រះអម្ចាស់**» *(កក ២,២២-៣៦)* ។ ក្រុមសាវ័កមានបទពិសោធន៍ដ៏អស្ចារ្យ ជាបទពិសោធន៍ដែលគេពុំអាចប្រកែកបាន គឺព្រះវិញ្ញាណរបស់ព្រះយេស៊ូគង់នៅជាមួយគេ ។ ③

ទោះបីគ្មាននរណាអាចបង្ហាញភស្តុតាងយ៉ាងជាក់លាក់អំពីព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿងក៏ដោយ ក៏អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រត្រូវតែគិតថា ជំនឿរបស់ក្រុមសាវ័កដ៏អស្ចារ្យនេះ គ្មានមនុស្សណាអាចបង្កើតបានឡើយ ព្រោះជំនឿនេះផ្ទុយស្រឡះនឹងគំនិតអ្នកប្រាជ្ញ គឺ «*រារាំងជនជាតិយូដាមិនឲ្យជឿ រីឯជនជាតិក្រិកវិញយល់ឃើញថាជារឿងលេលា*» *(១ ករ ២,២៣)* ។ គ្មាននរណាអាចប្រឌិតជំនឿនេះដោយខ្លួនឯងបានទេ ។ ប៉ុន្តែ ក្រុមសាវ័កនាំគ្នាប្រកាសជំនឿនេះអស់មួយជីវិត រហូតហ៊ានបូជាជីវិតទៀតផង ។ ជំនឿដែលក្រុមសាវ័កប្រកាស និងរបៀបគេរស់នៅ ពិតជាសញ្ញាសម្គាល់បញ្ជាក់អំពីលោកយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿងនោះយ៉ាងពិតប្រាកដមែន ។

*លោកសិលា និង លោកអន់ដ្រេ*
*ព្រះវិហាររ៉ាវ៉ែណា (សតវត្សទី ៦)*

Layout Histor.qxd 2/10/07 10:08 AM Page 8

③

## ព្រះជាម្ចាស់តែងតាំងលោកយេស៊ូជាព្រះអម្ចាស់និងជាព្រះគ្រីស្ត

*«ព្រះជាម្ចាស់បានរ៉ាប់រង ទទួលលោក**យេស៊ូ**ជាអ្នកភូមិណាសារ៉ែត ទុកជាព្យាការីនៅកណ្ដាលចំណោមបងប្អូន ព្រះអង្គបានសម្ដែងការអស្ចារ្យ ឫទ្ធិបាដិហារិយ៍ និងទីសម្គាល់ផ្សេងៗតាមរយៈលោក ដូចបងប្អូនជ្រាបស្រាប់ហើយ ។ បងប្អូនបានចាប់បញ្ជូនលោកយេស៊ូនេះទៅឲ្យជនជាតិរ៉ូម៉ាំង ជាជនពាលឥតសាសនាឆ្កាងសម្លាប់ (...) ។ ប៉ុន្តែ ព្រះជាម្ចាស់ប្រោសលោកឲ្យក្រោកឡើង យើងទាំងអស់គ្នាជាសាក្សី ។ ឥឡូវនេះ ព្រះជាម្ចាស់បានលើកលោកយេស៊ូឡើង ដោយឫទ្ធានុភាពរបស់ព្រះអង្គ លោកបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធពីព្រះបិតាមក តាមព្រះបន្ទូលសន្យា ហើយចាក់បង្ហូរព្រះវិញ្ញាណនេះលើយើង (...) ។ ព្រះជាម្ចាស់បានតែងតាំងលោកដែលបងប្អូនបានឆ្កាងនោះ ជាព្រះអម្ចាស់និងជាព្រះគ្រីស្ត» (កក ២,២២...៣៦) ។*

# ១_ កំណើតព្រះសហគមន៍

គម្ពីរ «*កិច្ចការរបស់គ្រីស្តទូត*» មានចែងប្រវត្តិដើមដំបូងនៃគ្រីស្តសាសនា ។ អ្នកនិពន្ធកណ្ឌគម្ពីរនោះប្រមែប្រមូលឯកសារផ្សេងៗពីបុរាណមក ដោយមានគោលបំណងរិះគិតអំពីអត្ថន័យព្រឹត្តិការណ៍ដែលកើតឡើងក្នុងចំណោមអ្នកជឿ គឺលោកចង់ជួយពង្រឹងជំនឿគ្រីស្តបរិស័ទតំណទីពីរ តពីតំណអ្នកដែលបានស្គាល់ព្រះយេស៊ូដោយផ្ទាល់ ។ លោកគ្មានបំណងរៀបរាប់ព្រឹត្តិការណ៍ឲ្យចំៗ ដូចព្រឹត្តិការណ៍ទាំងនោះបានកើតឡើងទេ ឬដូចអ្នកកាសែតធ្លាប់រៀបរាប់នោះឡើយ គឺលោកនិពន្ធ «*ប្រវត្តិដ៏វិសុទ្ធ*» ម្យ៉ាង គឺលោករៀបរាប់អំពីព្រះសកម្មភាពរបស់ព្រះយេស៊ូដែលទទួលព្រះជន្មថ្មីដ៏រុងរឿង គង់នៅក្នុងសហគមន៍របស់អ្នកជឿ ។

អ្នកនិពន្ធចែងអំពីព្រះសហគមន៍គំរូ សម្រាប់គ្រីស្តបរិស័ទជំនាន់ក្រោយៗយកតម្រាប់តាម គឺអ្នកជឿទទួលពិធីជ្រមុជទឹក ដើម្បីរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ គេព្យាយាមស្ដាប់ក្រុមគ្រីស្តទូតបង្រៀន គឺពន្យល់ឲ្យគេយល់ថា ព្រះយេស៊ូពិតជាព្រះគ្រីស្ត និងជាព្រះអម្ចាស់ស្របតាមគម្ពីររបស់គេ ។ អស់លោកបង្រៀនអំពីព្រះរាជកិច្ចដែលព្រះយេស៊ូបានប្រព្រឹត្ត និងព្រះបន្ទូលព្រះអង្គបានថ្លែង ។ ដូច្នេះ មិនយូរប៉ុន្មានក្រោយមក កើតមានសហគមន៍តូចៗរបស់អ្នកផ្ញើជីវិតលើព្រះយេស៊ូ ។ គេស្រឡាញ់គ្នាដូចបងប្អូន គឺយកទ្រព្យសម្បត្តិរបស់ខ្លួនចែកគ្នាប្រើប្រាស់ គេព្យាយាមធ្វើពិធីកាច់នំប៉័ង ដែលរំឭកគេអំពីព្រះយេស៊ូបូជាព្រះជន្មនៅពេលព្រះអង្គធ្វើពិធីជប់លៀងក្រុមសាវ័កចុងក្រោយបង្អស់ និងអំពីព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង ។ ព្រះគ្រីស្តគង់នៅជាមួយគេ ហើយគេក៏រង់ចាំព្រះអង្គយាងមកវិញយ៉ាងរុងរឿង ។ *(កក ២, ៤២-៤៦ ជាដើម)*

ជនជាតិយូដាយល់ឃើញថា អ្នកជឿលើព្រះយេស៊ូជាគណៈយូដាម្យ៉ាងក្នុងសាសនារបស់គេ ដូចគណៈផារីស៊ី គណៈសាឌូស៊ី គណៈអ្នកជាតិនិយម ឬគណៈអេសេញ៉ាំង ជាដើម ។ ជនជាតិយូដាតែងហៅគេថា «គណៈណាសារ៉ែត» ។ ពួកគេទទួលឈ្មោះថា «គ្រីស្តបរិស័ទ» នៅក្រុងអន់ទីយ៉ូក *(កក ១២,២៦)* ជាពាក្យមើលងាយពួកគេ ។ យូរៗទៅ មនុស្សទូទៅទទួលស្គាល់ថា អ្នកជឿលើព្រះយេស៊ូគឺជាក្រុមមួយផ្សេងពីគណៈផ្សេងៗនៃសាសនាយូដា ។ ប្រជាជនធ្លាប់ប្រើឈ្មោះ «គ្រីស្តបរិស័ទ» នេះចាប់តាំងពីសតវត្សទី ២ មកជាទូទៅ ។ ក្រុងអន់ទីយ៉ូកក្លាយជាទីតាំងថ្មី សម្រាប់គ្រីស្តបរិស័ទបាត់អ្នកចេញទៅប្រកាសដំណឹងល្អក្នុងចក្រភពរ៉ូម៉ាំងទាំងមូល ។

Layout Histor.qxd 2/10/07 10:08 AM Page 9

# គ_ ព្រះសហគមន៍លែងជាគណៈមួយនៃសាសនាយូដា



## **ដំណឹងល្អមិនជាប់នឹងក្រុងយេរូសាឡឹមទៀតទេ**

ព្រះសហគមន៍ចាប់ផ្ដើមនៅក្រុងយេរូសាឡឹម អ្នកជឿលើព្រះយេស៊ូដើមដំបូងសុទ្ធតែជនជាតិយូដា ដែលនិយាយភាសាអារ៉ាមេអាំង ក្រោយមក មានជនជាតិយូដាដែលនិយាយភាសាក្រិក ។ ដោយក្រុមទាំងពីរពិបាករួមរស់ជាមួយគ្នា ព្រោះគេមានទំនៀមទម្លាប់ខុសគ្នា ដូច្នេះក្រុមគ្រីស្ដទូត ១២ នាក់ ក៏តែងតាំង ៧ នាក់ទៀតឲ្យទទួលខុសត្រូវអ្នកជឿដែលនិយាយភាសាក្រិក *(កក ៦)* ។ លោក**ស្ទេផាន**នៅក្នុងចំណោមអ្នកទាំង ៧ នោះ ។ មានថ្ងៃមួយ លោករិះគន់របៀបអ្នកកាន់សាសនាយូដា ហើយលោកប្រកាសអំពីរបៀបគោរព «*តាមព្រះវិញ្ញាណ និងសេចក្ដីពិត*» ដូចព្រះយេស៊ូបានបង្រៀន ។ ជនជាតិយូដាខឹងក្ដៅក្រហាយ យកដុំថ្មគប់សម្លាប់លោកចោល *(កក ៧)* ហើយនាំគ្នាធ្វើទុក្ខបុកម្នេញអស់អ្នកជឿលើព្រះយេស៊ូ ។ អ្នកទាំងនោះភៀសខ្លួនទៅស្រុកសាម៉ារី ទៅតាមតំបន់ឆ្នេរសមុទ្រមេឌីទេរ៉ាណេ និងទៅនៅក្រុងអន់ទីយ៉ូកជាក្រុងធំនៅសម័យនោះ *(កក ៨-១១)* ។ ពួកគេក៏នាំគ្នាប្រកាសដំណឹងល្អដល់ជនជាតិយូដា ដែលរស់នៅតំបន់ទាំងនោះ ។ លោក**សូល** (នៅពេលក្រោយហៅថា «ប៉ូល») ធ្វើទុក្ខបុកម្នេញសាវ័កព្រះយេស៊ូ តែត្រូវព្រះយេស៊ូ «*ចាប់ខ្លួន*» នៅតាមផ្លូវទៅក្រុងដាម៉ាស *(កក ៩)* ហើយគាត់ត្រឡប់ទៅជាអ្នកប្រកាសដំណឹងល្អប្រសើរជាងគេ ។

## **ជនជាតិដទៃជឿលើព្រះយេស៊ូមិនបាច់កាន់តាមប្រពៃណីយូដា**

ជនជាតិយូដារាប់ធម្មវិន័យរបស់គេ ទុកជាព្រះអំណោយទានយ៉ាងពិសេសរបស់ព្រះជាម្ចាស់មកប្រជារាស្ដ្រអ៊ីស្រាអែល ។ ដោយព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមកសណ្ឋិតលើលោក**គ័រនេលាុស**ជានាយទាហានរ៉ូម៉ាំង លោក**សិលា**សុខចិត្តទទួលស្គាល់ថា មនុស្សលោកទាំងអស់ដែលជឿលើព្រះយេស៊ូ មិនបាច់អនុវត្តតាមធម្មវិន័យរបស់លោក**ម៉ូសេ**ទេ គឺមុននឹងទៅជាគ្រីស្ដបរិស័ទ សាសន៍ដទៃមិនបាច់ចូលសាសនាយូដាទេ ។ លោកក៏ទទួលលោកគ័រនេលាុសក្នុងព្រះសហគមន៍ ដោយធ្វើពិធីជ្រមុជទឹកជូនលោក *(កក ១០-១១)* ។

ព្រះសហគមន៍ក្រុងអន់ទីយ៉ូក ចាត់លោក**ប៉ូល**និងលោក**បារណាបា**ឲ្យទៅប្រកាសដំណឹងល្អ *(កក ១៣-១៤)* ។ មុនដំបូង លោកទាំងពីរប្រកាសដំណឹងល្អដល់ជនជាតិយូដាតាមធម្មសាលារបស់គេ ។ បន្ទាប់មក លោកប្រកាសដំណឹងល្អដល់ជនជាតិដទៃ ដោយមិនបង្ខំឲ្យប្រតិបត្តិតាមធម្មវិន័យរបស់លោកម៉ូសេទេ ។ ប៉ុន្តែគ្រីស្ដបរិស័ទនៅក្រុងយេរូសាឡឹមខ្លះយល់ឃើញថា បងប្អូនគ្រីស្ដបរិស័ទថ្មីៗត្រូវតែទទួលពិធីកាត់ស្បែក គឺត្រូវតែចូលក្នុងប្រជារាស្ដ្ររបស់ព្រះជាម្ចាស់សិន ទើបគេអាចទទួលការសង្គ្រោះពីព្រះយេស៊ូបាន ។

នៅក្រុងអន់ទីយ៉ូក មានគ្រីស្ដបរិស័ទពីរក្រុម មួយក្រុមជាគ្រីស្ដបរិស័ទជាតិយូដាដែលនៅតែកាន់តាមធម្មវិន័យលោកម៉ូសេ និងគ្រីស្ដបរិស័ទមួយក្រុមទៀតជាជនជាតិដទៃ ។ គ្រីស្ដបរិស័ទទាំងនោះមិនអាចបរិភោគអាហាររួមគ្នាបានទេ ពីព្រោះធម្មវិន័យហាមជនជាតិយូដាបរិភោគម្ហូបខ្លះ មានសាច់ជ្រូក ឈាមសាច់សត្វស្លាប់ដោយគេប្របាច់កជាដើម ។ តើគ្រីស្ដបរិស័ទទាំងពីរក្រុមនោះធ្វើពិធីអរព្រះគុណរួមជាមួយគ្នាដូចម្ដេចបាន បើតាមធម្មតា គេនាំគ្នាធ្វើពិធីអរព្រះគុណនេះក្រោយពីបរិភោគរួមជាមួយគ្នា ដូចព្រះគ្រីស្ដបានប្រព្រឹត្តនៅថ្ងៃព្រហស្បតិ៍មុនព្រះអង្គសោយទិវង្គត ។ សេចក្ដីនេះបង្កើតជម្លោះ ដែលមានចែងតាមរបៀបផ្សេងៗក្នុង កក.១៥ និងក្នុងលិខិតលោកប៉ូល ផ្ញើជូនគ្រីស្ដបរិស័ទក្រុងកាឡាទី ។ លោក**សិលា**នៅតែស្ទាក់ស្ទើរ ហើយប្រើល្បិចពង្វាង គឺលោកសុខចិត្តទទួលជន

ជាតិដទៃក្នុងព្រះសហគមន៍ដោយគ្មានល័ក្ខខ័ណ្ឌ តែពេលជាមួយគ្នានោះ លោកមិនហ៊ានបរិភោគរួមជាមួយពួកគេទេ ព្រោះលោកខ្លាចគ្រីស្តបរិស័ទមកពីយេរូសាឡឹមរករឿងលោក ។ លោក**ប៉ូល**ស្តីបន្ទោសលោក**សិលា**យ៉ាងខ្លាំង *(កាឡ ២)* ។

គ្រីស្តទូតដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរនេះ ដោយរកផ្លូវកណ្តាល គឺក្រុមអ្នកដឹកនាំព្រះសហគមន៍ជួបជុំគ្នាដើម្បីរិះគិត និងសម្រេចសេចក្តីនៅ *«មហាសន្និបាតនៅក្រុងយេរូសាឡឹម»* ប្រហែល គ.ស. ៤៩ ។ ម្ខាងមានលោក**យ៉ាកុប**ជាអ្នកដឹកនាំព្រះសហគមន៍យេរូសាឡឹម ម្ខាងទៀតមានលោកប៉ូល និងលោក**បារណាបា**ដែលត្រឡប់មកពីប្រកាសដំណឹងល្អ ។ លោកសិលាជាអាជ្ញាកណ្តាល ។ អង្គប្រជុំយល់ស្របតាមលោកប៉ូល គឺពួកគេមិនបង្ខំឲ្យជនជាតិដទៃដែលជឿលើព្រះគ្រីស្តប្រព្រឹត្តតាមធម្មវិន័យរបស់សាសន៍យូដាទេ ។ ប៉ុន្តែ លោកយ៉ាកុប ឆ្លៀតបង្ខំឲ្យគ្រីស្តបរិស័ទជាតិដទៃនោះប្រតិបត្តិតាមវិន័យខ្លះៗដូចជា នៅពេលពួកគេរួមរស់ជាមួយគ្រីស្តបរិស័ទជាតិយូដា គឺពួកគេមិនត្រូវបរិភោគឈាម និងម្ហូបខ្លះដែលជនជាតិយូដាខ្ពើម ។

តាំងពីពេលនោះមក ជំនឿរបស់គ្រីស្តបរិស័ទមិនជាប់ជាមួយសាសន៍យូដាទៀតទេ ។ នរណាក៏ដោយ បើចង់ជឿលើព្រះយេស៊ូ មិនត្រូវផ្ទេរវប្បធម៌របស់ខ្លួនទេ ។ ពេលនោះ ព្រះសហគមន៍ក្លាយទៅជាព្រះសហគមន៍សកលយ៉ាងពិតប្រាកដ ។ ទោះបីលោកប៉ូល និងលោកយ៉ាកុប ខ្វែងគំនិតគ្នាក្តី ក៏លោកទាំងពីរខិតខំធ្វើឲ្យក្រុមផ្សេងៗរួបរួមគ្នាតាមជំនឿក្នុងព្រះសហគមន៍តែមួយ ដោយគោរពគ្នាទៅវិញទៅមក ។ ពេលក្រោយ លោកប៉ូល ក៏រៃប្រាក់ក្នុងចក្រភពរ៉ូម៉ាំងទាំងមូលទៅជួយគ្រីស្តបរិស័ទក្រុងយេរូសាឡឹម *(១ ករ ១៦,១-៣ ; កាឡ ២,១០)* ។




*សិលាចារឹកលើផ្នូរលោកសិលា និង លោកប៉ូល*

## ④ លោកប៉ូលតាមគម្ពីរក្លែងក្លាយ

*លោក**អូណេស៊ីភ័រ**ធ្វើដំណើរតាមផ្លូវជាតិឆ្ពោះទៅដល់ក្រុងលីស្ត្រា ដើម្បីស្វែងរកលោក**ប៉ូល** លោកចេះតែសំឡឹងមើលអ្នកធ្វើដំណើរ តាមសេចក្តីលោក**ទីតូស**បានប្រាប់ ។ គាត់ឃើញលោកប៉ូលដើរមកជាមនុស្សមាឌតូច ក្បាលទំពែក មានកម្លាំង មានចិញ្ចើមក្រាស់ មានច្រមុះកោងបន្តិច មុខស្អាត ។ ជួនកាលលោកមានមុខដូចមនុស្សធម្មតា ជួនកាលមានមុខដូចទេវទូត ។ ពេលលោកប៉ូលឃើញលោកអូណេស៊ីភ័រ លោកញញឹម ។ លោកអូណេស៊ីភ័រមានប្រសាសន៍ថា៖ «ជម្រាបសួរអ្នកបម្រើរបស់ព្រះជាម្ចាស់» ។ លោកប៉ូលតបឆ្លើយថា៖ «សូមព្រះជាម្ចាស់ប្រណីសន្តោសដល់អ្នក និងដល់ក្រុមគ្រួសាររបស់អ្នក» ។*

*កិច្ចការលោកប៉ូល ២-៤ (គម្ពីរក្លែងក្លាយ) ។*

Layout Histor.qxd 2/10/07 10:08 AM Page 11



*ផ្លូវអាពីយ៉ា (នៅក្បែរក្រុងរ៉ូម)*



*ជិះសាធារណៈនៅសម័យក្រុមគ្រីស្តទូត*

## លោកប៉ូលពង្រីកព្រះសហគមន៍ពាសពេញចក្រភពរ៉ូម៉ាំង

លោក**ប៉ូល** ធ្វើដំណើរលើកទីពីរ ដោយឆ្លងកាត់ស្រុកអាស៊ីមីន័រ ។ លុះទៅដល់ក្រុងត្រូអាស លោកនិមិ្មតឃើញអ្នកស្រុកម៉ាសេដូនម្នាក់ឈរអង្វរលោកថា៖ «*សូមលោកឆ្លងមកស្រុកម៉ាសេដូនជួយយើងខ្ញុំផង!*» (កក ១៦,៩) ។ នៅ គ.ស. ៥0 នេះ លោកឆ្លងទៅដល់ទ្វីបអឺរ៉ុប ប្រកាសដំណឹងល្អ ហើយបង្កើតព្រះសហគមន៍នៅក្រុងភីលីព ក្រុងថេស្សាឡូនិក ក្រុងកូរិនថូស ។ល ។ នេះពិតជាដំណាក់កាលដ៏សំខាន់មួយសម្រាប់ព្រះសហគមន៍ ។ លោកប៉ូល ក៏ចូលដល់ក្រុងអាថែន ជាក្រុងមានអរិយធម៌ខ្ពង់ខ្ពស់ ។ លោកខិតខំពន្យល់បង្ហាញថា ទស្សនវិជ្ជាក្រិកនិងដំណឹងល្អមិនទាស់គ្នាទេ លោកក៏សូត្រកំណាព្យមួយជាភាសាក្រិកថែមទៀត តែការខិតខំនោះឥតបានការ «*យើងចាំស្ដាប់លោកនៅពេលក្រោយទៀត...*» (កក ១៧,១៦-៣៣) ។ ហេតុនេះ នៅពេលលោកប្រកាសដំណឹងល្អនៅក្រុងកូរិនថូស លោកមិនសូវគិតគូរធ្វើឲ្យអ្នកស្ដាប់គាប់ចិត្តទេ គឺលោកប្រកាសតែអំពី «*ព្រះយេស៊ូគ្រីស្ត គឺព្រះយេស៊ូគ្រីស្តដែលសោយទិវង្គតនៅលើឈើឆ្កាង*» ។ (១ ករ ២, ២)

Layout Histor.qxd 2/10/07 10:08 AM Page 12

លោក**ប៉ូល** ធ្វើដំណើរលើកទីបី ដើម្បីទៅសួរសុខទុក្ខព្រះសហគមន៍នៅស្រុកអាស៊ី និងនៅទ្វីបអឺរ៉ុប ។ លោកជួបការលំបាកជាច្រើន ដូចលោកសរសេរយ៉ាងខ្លីៗក្នុងលិខិតរបស់លោក ។ មានជនជាតិយូដាខ្លះមិនព្រមទទួលស្គាល់ថាលោកយេស៊ូជាព្រះគ្រីស្ត ហើយនាំគ្នាជំទាស់នឹងលោក ។ មានសាសន៍ដទៃខ្លះខឹងនឹងលោកដែលបំផ្លាញការរកស៊ីរបស់គេ ព្រោះគេធ្លាប់លក់គ្រឿងសក្ការបូជាសម្រាប់ថ្វាយព្រះរបស់គេ *(កក ១៩)* ។ ក្នុងព្រះសហគមន៍ខ្លះ ជាពិសេសនៅក្រុងកូរិនថូស គ្រីស្តបរិស័ទបាក់បែកគ្នា *(១ ករ ៣,៣-៩)* អ្នកខ្លះរំជើបរំជួលជាខ្លាំងចង់តែទទួលព្រះអំណោយទានដ៏អស្ចារ្យពីព្រះវិញ្ញាណ ឲ្យចេះនិយាយភាសាចម្លែកអស្ចារ្យ ដែលគ្មាននរណាយល់ដឹង *(១ ករ ១៣ និង ១៤)* អ្នកមានមិនព្រមចែកទ្រព្យសម្បត្តិឲ្យអ្នកក្រីក្រ *(១ ករ ១១)* អ្នកខ្លះប្រើសិទ្ធិសេរីភាពរបស់គ្រីស្តបរិស័ទហួសហេតុ *(១ ករ ៥)* ។ល។

ចាប់ពីឆ្នាំ ៥១ ដល់ ៦៣ លោកសរសេរលិខិត ១៣ ច្បាប់ ដើម្បីលើកទឹកចិត្តគ្រីស្តបរិស័ទដែលជួបឧបសគ្គ ឆ្លើយតបនឹងសំណួររបស់គេ ឬស្តីបន្ទោសគេ ។ គ្រីស្តបរិស័ទនាំគ្នាប្រមូលលិខិតទាំងនោះទុកដោយប្រុងប្រយ័ត្ន ។

លោកប៉ូល ទៅជួបលោក**យ៉ាកុប** នៅក្រុងយេរូសាឡឹម និងយកប្រាក់រៃអង្គាសមកជូនព្រះសហគមន៍ ។ លោកសុខចិត្តចូលព្រះវិហារក្រុងយេរូសាឡឹម ដើម្បីបញ្ជាក់ថា លោកនៅតែគោរពប្រពៃណីរបស់ជនជាតិយូដា ។ តែជនជាតិយូដាខ្លះយល់ឃើញថា លោកចង់បង្ករឿងហេតុទៅវិញ ។ ពេលកើតចលាចល ទាហានរ៉ូម៉ាំងចាប់លោកប៉ូលដាក់មន្ទីរឃុំឃាំងនៅក្រុងសេសារេ អស់រយៈពេលពីរឆ្នាំ ។ ដោយលោកអះអាងថា លោកជាពលរដ្ឋរ៉ូម៉ាំង លោកសូមឲ្យគេបញ្ជូនសំណុំរឿងរបស់លោកទៅព្រះចៅអធិរាជកាត់ក្តី ។ ហេតុនេះហើយ បានជាលោកទេសាភិបាលបញ្ជូនលោកទៅក្រុងរ៉ូម ។ លោកធ្វើដំណើរដ៏សែនលំបាកទើបទៅដល់រាជធានី ។ គេកាត់ទោសឲ្យមានទាហានតាមឃ្លាំមើលលោកគ្រប់ពេលអស់រយៈពេលពីរឆ្នាំ ។ លោក *«ប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងបង្រៀនអំពីសេចក្តីដែលទាក់ទងនឹងព្រះអម្ចាស់យេស៊ូគ្រីស្តដោយចិត្តអង់អាច និងដោយគ្មានអ្វីមករារាំងឡើយ»* ។



*រូបចចកបំបៅក្មេងពីរនាក់ ជានិមិត្តរូបអំពីក្រុងរ៉ូម*

# ឃ. គ្រីស្តទូតឯទៀតប្រកាសដំណឹងល្អ

អ្នកនិពន្ធគម្ពីរកិច្ចការគ្រីស្តទូត មានគោលបំណងបង្ហាញឲ្យដឹងថា ដំណឹងល្អទៅដល់ក្រុងរ៉ូម ជារាជធានីចក្រភពរ៉ូម៉ាំង ។ ក្រុងរ៉ូមក្លាយទៅជាកន្លែងដែលដំណឹងល្អចេញបន្តទៅទៀតជំនួសក្រុងយេរូសាឡឹម ហេតុនេះហើយ បានជាលោករៀបរាប់អំពីលោក**ប៉ូល**ច្រើនជាងគេ នាំឲ្យអ្នកអានភ័ន្តច្រឡំដោយស្មានថា មានតែលោកប៉ូលទេដែលបានប្រកាសដំណឹងល្អ ។ ប៉ុន្តែ មានគ្រីស្តទូតឯទៀតៗក៏ទៅប្រកាសដំណឹងល្អនៅច្រើនកន្លែងដែរ ។ នៅក្នុង កក ២,៥-១២ មានចែងអំពីជនជាតិយូដាមកពីស្រុកជាច្រើន រហូតដល់បូព៌ាប្រទេសយ៉ាងឆ្ងាយ គឺគេមកពី *«ស្រុកប៉ារថូស ស្រុកមេឌី ស្រុកអេឡាំ ព្រមទាំងអ្នកស្រុកមេសូប៉ូតាមី ស្រុកយូដា ស្រុកប៉ុនតុស ស្រុកអាស៊ី ស្រុកព្រីគី ស្រុកប៉ាមភីលី ស្រុកអេស៊ីប ស្រុកលីប៊ីដែលនៅក្បែរស្រុកគីរេន និងអ្នកមកពីក្រុងរ៉ូម ទាំងអ្នកមកពីកោះក្រែត ទាំងជនជាតិអារ៉ាប់»* ។ នៅក្នុងគម្ពីរវិវរណៈ ក៏មានចែងអំពីព្រះសហគមន៍ទាំងប្រាំពីរដែលលោកយ៉ូហានបង្កើតដែរ *(វវ ២-៣)* ។ លោកប៉ូលសរសេរលិខិតទៅព្រះសហគមន៍ក្រុងរ៉ូមដែលកើតរួចហើយមុនលោកទៅដល់ ។ គ្មាននរណាដឹងច្បាស់ថា លោកប៉ូលទៅស្រុកអេស្ប៉ាញឬយ៉ាងណាទេ *(រម ១៥, ២៤)* ។ លិខិតទីមួយដែលគ្រីស្តបរិស័ទតែងរាប់ទុកថា លោក**សិលា**សរសេរនោះ ក៏ចែងអំពីស្រុកជាច្រើនដែលលោកនាំដំណឹងល្អ *(១ សល ១,១; ៥,១៣)* ។ គ្រីស្តបរិស័ទតែងតែរៀបរាប់ថា លោកសិលាទៅក្រុងរ៉ូម តែឯកសារដែលរៀបរាប់សេចក្តីនេះ និពន្ធយូរឆ្នាំក្រោយ ហើយប្រហែលជាឯកសារមិនប្រាកដផង ។

## សេចក្តីដែលគ្រីស្តបរិស័ទរៀបរាប់តៗគ្នាមក

លោក**អឺសែប** ស្រមៃឃើញថា ក្រុមគ្រីស្តទូតចែកពិភពលោកឲ្យគ្រីស្តទូតម្នាក់ៗទៅប្រកាសដំណឹងល្អ តាមកន្លែងមានព្រះសហគមន៍នៅពេលក្រោយ ។ គម្ពីរក្លែងក្លាយចែងសេចក្តីផ្សេងៗ ដែលពិបាកសន្និដ្ឋានថាត្រូវឬខុស មានចែងរឿងផ្សេងៗជាច្រើនអំពីគ្រីស្តទូត**ថូម៉ាស**ថា លោកទៅប្រកាសដំណឹងល្អនៅខាងបូព៌ាប្រទេស រហូតដល់ប្រទេសឥណ្ឌា ។ ក្នុងចំណោមរឿងទាំងនោះ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រសន្និដ្ឋានថា ប្រហែលមានសេចក្តីខ្លះពិតប្រាកដ ។ ⑤

⑤

### គ្រីស្តទូតប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែង

*ចាស់បុរាណតែងតំណាលថា គេចាត់លោក**ម៉ាកុស**អោយទៅស្រុកអេស៊ីបមុនគេ ។ លោកប្រកាសដំណឹងល្អនៅស្រុកនោះ គឺលោកប្រកាសគម្ពីរដែលលោកនិពន្ធ ។ លោកតែងតាំងព្រះសហគមន៍នៅស្រុកអេស៊ីប គឺនៅក្រុងអាឡិចសង់ឌ្រីមុនគេ ។*

*លោកអឺសែប ប្រវត្តិព្រះសហគមន៍ ២.១៦,១*

*គ្រីស្តទូតនិងសាវ័កនៃព្រះសង្គ្រោះរបស់យើងខ្ចាត់ខ្ចាយលើផែនដីទាំងមូល ។ គេធ្លាប់និយាយតៗមកថា លោក**ថូម៉ាស**ទៅស្រុកប៉ារថូស ។ លោក**ម៉ាថាយ**ទៅស្រុកអេធ្យូពី លោក**បារថូឡូមេ**ទៅស្រុកឥណ្ឌា លោក**អន់ដ្រេ**ទៅស្រុកសីត លោក**យ៉ូហាន**ទៅនៅស្រុកអាស៊ី និងទទួលមរណភាពនៅក្រុងអេភេសូ ។ លោក**សិលា**ដូចជាទៅប្រកាសដំណឹងល្អដល់ជនជាតិយូដាដែលខ្ចាត់ខ្ចាយក្នុងស្រុកប៉ុនតុស ស្រុកកាឡាទី ស្រុកប៊ីធីនី ស្រុកកាប៉ាដូស និងនៅស្រុកអាស៊ី ។ នៅទីបញ្ចប់ លោកក៏មកដល់ក្រុងរ៉ូម ហើយត្រូវគេឆ្កាងក្បាលចុះក្រោម តាមសំណូមពររបស់លោក ។ លោក**ប៉ូល**ប្រកាសដំណឹងល្អអំពីព្រះគ្រីស្តតាំងពីក្រុងយេរូសាឡឹមទៅដល់ ស្រុកអ៊ីលីរី ហើយបូជាជីវិតជាមរណសាក្សីនៅក្រុងរ៉ូម ក្នុងរជ្ជកាលព្រះចៅអធិរាជណេរ៉ុង ។*

*លោកអឺសែប ប្រវត្តិព្រះសហគមន៍ ៣,១*

Layout Histor.qxd 2/10/07 10:08 AM Page 14




ផែនទីមជ្ឈិមបូព៌ា

Layout Histor.qxd 2/10/07 10:08 AM Page 15

# ៤_ ព្រឹត្តិការណ៍សំខាន់នៅចុងសតវត្សទី ១

## ១- ព្រះចៅណេរ៉ុងធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ

ព្រះចៅ**ណេរ៉ុង** (Neron) ធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ (គ.ស. ៦៤) បណ្តាលឲ្យគ្រីស្តទូត**សិលា**និង**ប៉ូល**បាត់បង់ជីវិត ។ ប៉ុន្តែ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រមិនអាចបញ្ជាក់ច្បាស់លាស់អំពីឆ្នាំដែលលោកទាំងពីរធ្វើជាមរណសាក្សីទេ ។ លោកសិលាទទួលមរណភាពប្រហែលនៅគ.ស. ៦៤ ។ អ្នកខ្លះបញ្ជាក់ថា លោកប៉ូលទទួលមរណភាពនៅ គ.ស. ៦៣ តែអ្នកខ្លះថា នៅគ.ស. ៦៧ ។

ព្រះចៅអធិរាជរ៉ូម៉ាំងតែងធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ មកពីទ្រង់ខ្លាចកើតអសន្តិសុខក្នុងចក្រភព ។ នៅគ.ស. ៤៩ ព្រះចៅ**ក្លូដ**ដេញជនជាតិយូដាពីក្រុងរ៉ូម *(កក ១៨,២)* ព្រោះមានទំនាស់រវាងគ្រីស្តបរិស័ទនិងជនជាតិយូដាអំពីព្រះគ្រីស្ត ។ ព្រះចៅណេរ៉ុង ដុតសង្កាត់មួយនៅក្រុងរ៉ូមបោល ជាសង្កាត់អ្នកក្រីក្ររស់នៅ រួចបែរទៅចោទគ្រីស្តបរិស័ទថាជាអ្នកដុត (ប្រហែលមកពីព្រះមហេសីដែលជាសាសនិកយូដា ហើយស្អប់គ្រីស្តបរិស័ទ) ។ នៅក្នុងគម្ពីរវិវរណៈមានចែងអំពីព្រះចៅ**ដូមីស៊ីយ៉ាំង**សម្លាប់គ្រីស្តបរិស័ទជាច្រើន នៅគ.ស. ៩២ ។ *(វវ ៧, ១៤)*

## ២- សេចក្តីសន្និដ្ឋានអំពីលោកសិលានិងលោកប៉ូល

តាមគ្រីស្តបរិស័ទនិយាយតៗមកថា គ្រីស្តបរិស័ទក្រុងរ៉ូមជ្រាបភ្ជាប់ជាមួយលោកសិលា និងលោកប៉ូល ទុកជាសសរនិងជាគ្រឹះព្រះសហគមន៍របស់គេ ។ ក្រុងរ៉ូមជាទីកន្លែងលោកទាំងពីរបូជាជីវិត ក្នុងឋានៈជាមរណសាក្សី ហើយផ្នូររបស់លោកទាំងពីរក៏នៅក្រុងរ៉ូមដែរ ។ ប៉ុន្តែ ឯកសារបញ្ជាក់ថា លោកទាំងពីរបូជាជីវិតនៅក្រុងរ៉ូម ជាឯកសារចែងនៅចុងសតវត្សទីពីរប៉ុណ្ណោះ ។ ហេតុនេះ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្លះមានការសង្ស័យថា ជាការណ៍មិនពិត ។

គ្រីស្តបរិស័ទកាតូលិកតែងតែអះអាងថា អភិបាលព្រះសហគមន៍ក្រុមរ៉ូម (ហៅតាមរបៀបលោកិយថា "**សម្តេចប៉ាប**") មានមុខងារពិសេសនៅក្នុងព្រះសហគមន៍សកល មកពីលោកបន្តមុខតំណែងពីលោកសិលាមក ។ នៅសម័យកែទម្រង់ព្រះសហគមន៍ (សតវត្សទី ១៦) គ្រីស្តបរិស័ទប្រូតេស្តង់តែងអះអាងថា ក្នុងគម្ពីរគ្មានចែងអំពីលោកសិលា មកដល់ក្រុងរ៉ូមទេ គឺមានតែគម្ពីរក្លែងក្លាយប៉ុណ្ណោះ ដែលរៀបរាប់អំពីរដ្ឋអំណាចធ្វើទារុណកម្មដល់លោក ។

ប៉ុន្តែ សព្វថ្ងៃអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រសន្និដ្ឋានថា លោកសិលា និងលោកប៉ូល បានរស់នៅក្រុងរ៉ូមពិតមែន លោកទាំងពីរក៏បានបូជាជីវិតនៅទីនោះដែរ ដោយសំអាងលើសេចក្តីដូចតទៅ៖

### *ក_ ការពិនិត្យអត្ថបទសម្ពន្ធមេត្រីថ្មីជាច្រើនយ៉ាងល្អិតល្អន់*

ក្នុងគម្ពីរកិច្ចការគ្រីស្តទូត មានបញ្ជាក់យ៉ាងច្បាស់ថា លោកប៉ូល ទៅដល់ក្រុងរ៉ូម *(កក ២៨, ១៦-៣១)* ។ គ្មាននរណាដឹងថា លោកធ្វើអ្វីនៅឆ្នាំចុងបញ្ចប់នៃជីវិតរបស់លោក ហើយទទួលមរណភាពយ៉ាងណានោះដែរ ។ លោកប៉ូល មានបំណងទៅស្រុកអេស្ប៉ាញ *(រម ១៥,២៤-២៨)* ។ ដូច្នេះ គ្រីស្តបរិស័ទខ្លះសន្និដ្ឋានថា នៅគ.ស. ៦៣ រាជការដោះលែងលោកប៉ូល រួចលោកទៅប្រកាសដំណឹងល្អនៅស្រុកនោះ ។ សេចក្តីនេះត្រូវតាមលោក**ក្លេម៉ង់**ដែលចែងថា «*លោកប៉ូលទៅដល់* 6 *ទីដាច់ស្រយាលនៃបស្ចិមប្រទេសហើយ*» ។ បន្ទាប់មកទៀត លោកត្រឡប់មកស្រុកអាស៊ីមីន័រ (ទួរគីសព្វថ្ងៃ) និងស្រុកក្រិក ។ គេតែងតែនិយាយថា ពេលនោះលោកចែងលិខិតផ្ញើជូនលោក**ធីម៉ូថេ** និងលោក**ទីតុស** ។ គេថារាជការចាប់លោកម្តងទៀត *(១ ធម ១)* ហើយសម្លាប់លោកនៅ គ.ស. ៦៧ ។ ប៉ុន្តែ អ្នកបកស្រាយ

Layout Histor.qxd 2/10/07 10:08 AM Page 16

គម្ពីរផ្សេងៗទៀតសន្និដ្ឋានថា អ្នកនិពន្ធគម្ពីរកិច្ចការគ្រីស្តទូតមិនចែងអំពីឆ្នាំចុងក្រោយនៃជីវិតរបស់លោក**ប៉ូល** មកពីគេសម្លាប់លោករួចទៅហើយ ។

### *ខ_ ការស្រាវជ្រាវវត្ថុបុរាណ*

អ្នកស្រាវជ្រាវវត្ថុបុរាណរកឃើញវិមានតូចមួយក្រោមព្រះវិហារសន្ត**សិលា**
7 (នៅជម្រាលភ្នំវ៉ាទីកង់) ប្រហែលជា «*ប្រាសាទជ័យជម្នះ*» តាមលោក**ហ្គាយ៉ូស** ចែង (លោក**អឺសែប**ចម្លងទុកមក) ។ អ្នកស្រាវជ្រាវវត្ថុបុរាណក៏រកឃើញវត្ថុក្រោម «*ព្រះវិហារសន្តប៉ូលក្រៅកំផែង*» (ជាវិហារនៅជាយក្រុងរ៉ូម) ប្រហែលជា «*ប្រាសាទនៃជ័យជម្នះតាមផ្លូវទៅអូស្ទីយ៉ា*» ដូចលោកហ្គាយ៉ូសចែងដែរ ។

### *គ_ មានឯកសារបុរាណ*

គឺលិខិតលោក**ក្លេម៉ង់**ជាដើម ធ្វើជាសាក្សី ។ នៅចុងសតវត្ស ទី ២ លោក**ទែរទូលីយ៉ាំង** (Tertullien) ចែងមុនគេថា គេកាត់កលោកប៉ូល នៅក្រុងរ៉ូម ។

## ៣- កងទ័ពរ៉ូម៉ាំងបំផ្លាញក្រុងយេរូសាឡឹម

តាំងពី គ.ស ៦៦ មក ជនជាតិយូដានាំគ្នាបះបោរប្រឆាំងនឹងកងទ័ពរ៉ូម៉ាំង ដើម្បីទាមទារឯករាជ្យ ។ ពួកគេចង់បង្កើតប្រទេសមួយ ដែលគោរពបម្រើព្រះជាម្ចាស់ទុកជាព្រះមហាក្សត្ររបស់គេ ស្របតាមធម្មវិន័យរបស់លោក**ម៉ូសេ** ។ គ្រីស្តបរិស័ទរត់ចេញពីក្រុងយេរូសាឡឹម ភៀសខ្លួនទៅខាងនាយទន្លេយ័រដាន់ (នៅតំបន់ពេត្រា) ។ កងទ័ពរ៉ូម៉ាំងបង្ក្រាបគេដោយគ្មានត្រាប្រណី ។ នៅ គ.ស. ៧០ កងទ័ពរ៉ូម៉ាំងបំផ្លាញក្រុងយេរូសាឡឹមឲ្យវិនាសសាបសូន្យ ដុតបំផ្លាញព្រះវិហារ និងចាប់អ្នកក្រុងធ្វើជាទាសករ ។

ក្រោយគ.ស. ៧០ ក្រុមផារីស៊ីប្រជុំគ្នានៅក្រុងយ៉ាមនីញ៉ា (ខាងត្បូងក្រុងតែលអាវីវ (Tel-Aviv) សព្វថ្ងៃនៅប្រទេសអ៊ីស្រាអែល) ដើម្បីបាត់ចែងសាសនារបស់គេតាមរបៀបថ្មី ព្រោះគ្មានព្រះវិហារទៀត ។ គេនាំគ្នាប្រឆាំងនឹងគណៈផ្សេងៗ ជាពិសេសប្រឆាំងនឹងគ្រីស្តបរិស័ទ ។ ពួកផារីស៊ីកំណត់បញ្ជាក់ប្រតិទិន និងបញ្ជាក់សាសនបញ្ញត្តិរបស់សាសនាយូដា គឺបញ្ជីកណ្ឌគម្ពីរដែលគេចាត់ទុកជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ពួកគេទាត់ចោលគម្ពីរភាសាក្រិក (LXX) ដោយចោទថា ជាគម្ពីរគ្រីស្តបរិស័ទ ។ តាំងពីពេលនោះមក គ្រីស្តសាសនានិងសាសនាយូដាដាច់ពីគ្នា ។

ក្នុងចំណោមគ្រីស្តបរិស័ទ មានតែមួយចំនួនតូចប៉ុណ្ណោះដែលនៅកាន់តាមទំនៀមទម្លាប់របស់ជនជាតិយូដា ។ ដោយព្រះវិហារខ្ទេចខ្ទីដូច្នេះ គ្រីស្តបរិស័ទជាតិយូដា លែងជាប់ចិត្តនឹងសាសនាយូដា ដោយយល់ឃើញថា ព្រះជាម្ចាស់សម្តែងឲ្យដឹងច្បាស់ថា ធម្មវិន័យរបស់លោកម៉ូសេ លែងមានប្រយោជន៍ទៀតហើយ ។ គេយល់ឃើញកាន់តែច្បាស់ថា ដំណឹងល្អមានសារៈសំខាន់សម្រាប់មនុស្សលោកទាំងមូល ។

## ៤- គ្រីស្តបរិស័ទនាំគ្នាចាត់ចែងគម្ពីរសម្ពន្ធមេត្រីថ្មី

នៅចុងសតវត្សទី ១ នេះ គ្រីស្តបរិស័ទនាំគ្នាចាត់ចែងគម្ពីរសម្ពន្ធមេត្រីថ្មី ។ គេប្រមែប្រមូលលិខិតរបស់គ្រីស្តទូតប៉ូលធ្វើជាក្បួនមួយ ។ គេនិពន្ធគម្ពីរដំណឹងល្អជាស្ថាពរ ដោយយល់ឃើញថា អន្តរាយនៃក្រុងយេរូសាឡឹមផ្តល់ឲ្យព្រះបន្ទូលព្រះយេស៊ូទទួលតម្លៃនិងអត្ថន័យថ្មី ។ ប៉ុន្តែ គេមិនទាន់កំណត់គម្ពីរណាដែលជាគ្រឹះនៃជំនឿរបស់គេទេ *(សាសនបញ្ញត្តិ)* ។ គេកំណត់សាសនបញ្ញត្តិប្រហែលនៅ គ.ស. ១៤០-១៥០ ។ *(សូមអានសៀវភៅ «ដើមកំណើតគម្ពីរសម្ពន្ធមេត្រីថ្មី» ទំព័រ ៩៧-១០៤)*

នៅចុងសតវត្សទី ១ គ្រីស្តសាសនាបែរទៅកាន់បស្ចិមប្រទេស ហើយគ្រីស្តបរិស័ទនាំគ្នាប្រើប្រាស់រចនាសម្ពន្ធនៃចក្រភពរ៉ូម៉ាំង ដើម្បីប្រកាសដំណឹងល្អ ។

## ⑥ គ្រីស្តទូតសិលា និង គ្រីស្តទូតប៉ូលជាមរណសាក្សី

*«លិខិតរបស់ព្រះសហគមន៍ក្រុងរ៉ូមផ្ញើជូនព្រះសហគមន៍ក្រុងកូរិនថូស»* ជាឯកសារបុរាណជាងគេ ដែលគ្រីស្តបរិស័ទបាននិពន្ធក្រោយពីគម្ពីរសម្ពន្ធមេត្រីថ្មី ។ គ្រីស្តបរិស័ទតែងសន្មតថា លោក**ក្លេម៉ង់** (៨៨-៩៧) ជា «អភិបាល» ព្រះសហគមន៍ក្រុងរ៉ូមបន្ទាប់ពីលោក**លីណូ** (៦៤-៧៦) និងលោក**អាណាក្លែត** (៧៦-៨៨) ។ លោកនិពន្ធលិខិតនេះប្រហែលនៅ គ.ស. ៩៥ ។ លោកក្លេម៉ង់មានបំណងចង់ឲ្យគ្រីស្តបរិស័ទក្រុងកូរិនថូសដែលបាក់បែកគ្នាបានរួបរួមគ្នាវិញ ក្រោយពីគ្រីស្តបរិស័ទមួយក្រុមបានទម្លាក់ក្រុមចាស់ទុំនៃព្រះសហគមន៍ ។ លោកសរសេរថា បក្សពួកដែលមានចិត្តប្រណែនឈ្នានីស បានបណ្តាលឲ្យលោក**សិលា**និងលោក**ប៉ូល**ទទួលមរណភាពរួចហើយ ។ ពាក្យរបស់លោកមិនសូវច្បាស់ប៉ុន្មាន តែសេចក្តីនេះជាសក្ខីភាពបុរាណជាងគេ ស្តីអំពីគ្រីស្តទូតទាំងពីរនាក់បូជាជីវិតជាមរណសាក្សីនៅក្រុងរ៉ូម ។

*យើងមិនរៀបរាប់អំពីអ្នកជឿកាលពីសម័យមុនៗទេ គឺយើងគ្រាន់តែសូមលើកអ្នកបូជាជីវិតដោយចិត្តក្លាហាន នៅសម័យថ្មីៗនេះទុកជាគំរូប៉ុណ្ណោះ ។ រដ្ឋអំណាចធ្វើទុក្ខបុកម្នេញដល់លោក ដែលជាសសរខ្ពស់ជាងគេ និងសុចរិតជាងគេនៃព្រះសហគមន៍ ព្រោះអ្នកខ្លះប្រណែនឈ្នានីស ។ លោកបានប្រយុទ្ធរហូតដល់ទទួលមរណភាព ។ សូមក្រឡេកមើលគ្រីស្តទូតដ៏ឆ្នើមរបស់យើង គឺថា៖*

*ដោយមានអ្នកខ្លះប្រណែនឈ្នានីសមិនត្រឹមត្រូវ លោកសិលារងទុក្ខលំបាកជាច្រើន មិនគ្រាន់តែមួយឬពីរយ៉ាងប៉ុណ្ណោះទេ គឺលោករងទារុណកម្មច្រើនយ៉ាង ។ ក្រោយពីលោកបានផ្តល់សក្ខីភាពមក លោកអញ្ជើញទៅស្ថានបរមសុខប្រកបដោយសិរីរុងរឿង ទៅទទួលរង្វាន់ ។*

*ដោយអ្នកខ្លះមានចិត្តប្រណែនឈ្នានីស និងទាស់ទែងបាក់បែកគ្នា លោកប៉ូលក៏បង្ហាញអំពីរបៀបគ្រីស្តបរិស័ទទទួលរង្វាន់ចំពោះចិត្តអត់ធ្មត់របស់ខ្លួន ។ គេដាក់ច្រវាក់លោក ៧ ដង លោកត្រូវគេនិរទេស ត្រូវគេយកដុំថ្មគប់ចង់សម្លាប់ចោល ។ ដូច្នេះ លោកទៅជាវីរបុរសនៅបូព៌ា និងនៅបស្ចិមប្រទេស ។ លោកទទួលសិរីរុងរឿងដ៏ត្រចះត្រចង់ ព្រោះតែជំនឿលោក ។ បន្ទាប់ពីលោកបង្រៀនអំពីសេចក្តីសុចរិតពាសពេញពិភពលោករហូតដល់ទីដាច់ស្រយាលនៃបស្ចិមប្រទេស លោកបានផ្តល់សក្ខីភាពនៅចំពោះមុខអ្នកដឹកនាំរដ្ឋាភិបាល រួចលោកចែកឋានទៅនៅឯស្ថានបរមសុខធ្វើជាគំរូ លោកជាអ្នកមានចិត្តអត់ធ្មត់ ។*

*លិខិតលោកក្លេម៉ង់ ផ្ញើជូនគ្រីស្តបរិស័ទក្រុងកូរិនថូស ៣*

## ⑦ ផ្នូររបស់គ្រីស្តទូតសិលា និង គ្រីស្តទូតប៉ូល នៅក្រុងរ៉ូម

*គេនិទានថា នៅក្នុងរជ្ជកាលព្រះ**ចៅណេរ៉ុង** ទាហានកាត់កលោក**ប៉ូល**នៅក្រុងរ៉ូម ដូចលោក**សិលា**ត្រូវគេឆ្កាងដែរ ។ គេបញ្ជាក់ព្រឹត្តិការណ៍នេះ ដោយដាក់ឈ្មោះទីកន្លែងបញ្ចុះសពក្នុងក្រុងនេះ តាមឈ្មោះលោក**សិលា**និងលោកប៉ូល រហូតមកដល់សព្វថ្ងៃ ។ លោកបូជាចារ្យ**ហ្គាយ៉ូស*** (Gaïus) *ដែលរស់នៅក្នុងសម័យរបស់លោក**ហ្សេហ្វិរ៉ាំង*** (Zéphyrin) *ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម (១៩៩-២១៧) ក៏បញ្ជាក់សេចក្តីនេះដែរ គឺលោកសរសេរសេចក្តីប្រឆាំងនឹងលោក**ប្រូគ្លូស*** (Proclus) *(...) បញ្ជាក់ជាលាយលក្ខអក្សរ អំពីកន្លែងគេបញ្ចុះសាកសពដ៏សក្ការៈរបស់គ្រីស្តទូតថា៖ «ចំពោះខ្ញុំ ខ្ញុំអាចបង្ហាញប្រាសាទនៃជ័យជម្នះរបស់គ្រីស្តទូតបាន ។ ប្រសិនបើអ្នកអញ្ជើញទៅភ្នំវ៉ាទីកង់ ឬទៅតាមផ្លូវឆ្ពោះទៅក្រុងអូស្ទីយ៉ា អ្នកមុខជានឹងឃើញប្រាសាទនៃជ័យជម្នះរបស់លោកទាំងពីរ ដែលបង្កើតព្រះសហគមន៍នោះ» ។*

*លោកអឺសែប "ប្រវត្តិព្រះសហគមន៍" ២, ២៥: ៥-៧*

Layout Histor.qxd 2/10/07 10:08 AM Page 18



# គ្រីស្តបរិស័ទ រស់នៅក្នុងសង្គមដែលមិនយល់ចិត្តគេ

## (ពីសតវត្សទី ១–៣)

*ចំនួនគ្រីស្តបរិស័ទចេះតែកើនឡើងជាលំដាប់ យូរៗទៅអ្នកស្រុកយល់ឃើញថា គ្រីស្តបរិស័ទប្លែកពីជនជាតិយូដា ។ ជនជាតិយូដាមានឯកសិទ្ធិនិងលក្ខន្តិកៈយ៉ាងពិសេសក្នុងចក្រភពរ៉ូម៉ាំង ក្នុងការគោរពសាសនារបស់ខ្លួន ។ ពួកគេខិតខំពន្យល់ថា គ្រីស្តបរិស័ទមិនមែនជាបរិស័ទរបស់ពួកគេទេ ។ ចាប់តាំងពីពេលសាវ័ករបស់ព្រះគ្រីស្តឡើងជាក្រុមមួយដ៏ធំ រដ្ឋអំណាចចាប់ផ្តើមបារម្ភនឹងពួកគេ ។ គ្រីស្តបរិស័ទតែងតែធ្វើពិធីបុណ្យយ៉ាងស្ងាត់ៗដាច់ពីគេ បណ្តាលឲ្យអ្នកស្រុកនឹកឆ្ងល់ ហើយស្មានថាពួកគេប្រព្រឹត្តបទអាក្រក់ជាទីបំផុត ។ ម៉្យាងទៀត គ្រីស្តសាសនាហូរមកពីប៉ូពាប្រទេស ហើយអ្នកស្រុកមិនសូវយល់អំពីទំនៀមទម្លាប់ និងសីលធម៌របស់គេទេ ។ អ្នកស្រុកចាត់គេទុកជាគណៈមួយ ឬនិកាយមួយដែលប្រព្រឹត្តបទអាក្រក់ ។ ហេតុនេះហើយ បានជាជនជាតិរ៉ូម៉ាំងនាំគ្នាស្អប់គ្រីស្តបរិស័ទ ។ គ្រីស្តបរិស័ទខ្លះនិពន្ធសៀវភៅ ដើម្បីការពារព្រះសហគមន៍ អំពីពាក្យចោទប្រកាន់របស់មហាជន និងអំពីរដ្ឋអំណាច ។ គ្រីស្តបរិស័ទតែងហៅអ្នកនិពន្ធទាំងនោះថា "អ្នកការពារ" ។ ប៉ុន្តែ អ្នកនិពន្ធទាំងនោះមិនអាចឃាត់ឃាំងរដ្ឋអំណាច មិនឲ្យធ្វើទុក្ខបុកម្នេញមកលើគ្រីស្តបរិស័ទបានឡើយ ។*

*គ្រីស្តបរិស័ទនិពន្ធសៀវភៅឆ្លើយដោះសានឹងពាក្យចោទប្រកាន់របស់ប្រជាជន ។ ក្នុងសៀវភៅទាំងនោះ អ្នកនិពន្ធចម្លងសេចក្តីដែលអ្នកស្រុកចោទប្រកាន់គ្រីស្តសាសនានៅពេលនោះ ។ អ្នកប្រឆាំងថែងពាក្យមួលបង្កាច់យ៉ាងគ្រោតគ្រាត មានបំណងសរសេរជំទាស់នឹងលទ្ធិគ្រីស្តសាសនា ។ ពាក្យចោទទាំងនោះក៏ដូចពាក្យចោទលើយើងសព្វថ្ងៃដែរ (អំពីចក្រភពរ៉ូម៉ាំង សូមអានសៀវភៅ «ដើមកំណើតគម្ពីរសម្ពន្ធមេត្រីថ្មី ទំព័រ ១-៣១») ។*

Layout Histor.qxd 2/10/07 10:08 AM Page 20

# ក_ ទស្សនៈរបស់អ្នកខាងក្រៅ

អ្នកស្រុកទូទៅមិនស្គាល់គ្រីស្តបរិស័ទដែលតែងតែជួបជុំគ្នាជាប់ឡែកនៅទីស្ងាត់ ។ យើងស្គាល់ពាក្យបោទប្រកាន់ទាំងនោះដោយមានគ្រីស្តបរិស័ទសរសេរសៀវភៅក្នុងគោលបំណងឆ្លើយតបតវ៉ានឹងពាក្យបោទទាំងនោះ ។ មានពាក្យបោទមូលបង្កាច់ពីប្រជាជនទូទៅ និងពាក្យបោទរបស់អ្នកប្រាជ្ញ មានពួកទស្សនវិទូជាដើម ។ ពាក្យបោទខ្លះ ជាពាក្យបោទមកយើងសព្វថ្ងៃដែរ ។

## ១- ពាក្យមួលបង្កាច់របស់ប្រជាជនទូទៅ

មានពាក្យបោទប្រកាន់បីយ៉ាងធ្ងន់ជាងគេទៅលើគ្រីស្តបរិស័ទ គឺ៖

**ក_ គេចោទថា** គ្រីស្តបរិស័ទមិនគោរពព្រះណាសោះ ។ ប្រជាជនបោទដូច្នេះ មកពីគ្រីស្តបរិស័ទមិនចូលរួមក្នុងពិធីគោរពបូជាតាមប្រពៃណី តាមក្រុង ឬតាមក្រុមអាជីវកម្ម គេមិនគោរពវិញ្ញាណក្ខ័ន្ធដូនតា គ្រូបាធ្យាយ ហើយជាពិសេសមិនចូលក្នុងពិធីគោរពបូជាព្រះចៅអធិរាជដែរ ។ គេសន្និដ្ឋានថា គ្រីស្តបរិស័ទមិនកាន់សាសនាណាមួយសោះ ។ ប្រជាជននៅសម័យនោះយល់ឃើញថា អ្នកមិនគោរពសាសនាណាមួយជាអ្នកលេលាម្យ៉ាង ។ ប្រជាជនសន្និដ្ឋានថា គ្រីស្តបរិស័ទមុខជាបណ្តាលឲ្យកើតគ្រោះកាចដល់ក្រុងរបស់គេ ព្រោះព្រះនៃក្រុងដែលគ្រីស្តបរិស័ទមើលងាយនោះ មុខជានឹងសងសឹក បណ្តាលឲ្យកើតវិបត្តិ ឲ្យទឹកជន់លិចក្រុង ឲ្យមេឃរាំងស្ងួត ឲ្យផែនដីរញ្ជួយ ឲ្យជំងឺរាលដាល ឬឲ្យខ្មាំងសត្រូវលុកលុយទឹកដី ។ល ។ ប្រជាជននឹកស្មានទៀតថា គ្រីស្តបរិស័ទនាំគ្នាគោរពសត្វលា ឬគោរពចោរប្លន់ម្នាក់ដែលត្រូវគេឆ្កាង ។ល ។

**ខ_ គេចោទថា** គ្រីស្តបរិស័ទជិតក្បត់គូស្វាមីភរិយា សាហាយស្មន់គ្នា ឪពុកម្តាយរួមដំណេកនឹងកូន ។ គេបោទថា គ្រីស្តបរិស័ទតែងជួបជុំគ្នាជប់លៀងពេលយប់
⑧ ដើម្បីស៊ីផឹកហួសប្រមាណ និងប្រព្រឹត្តកាមគុណថោកទាបរវាង *«បងប្អូន»* ឯង ។

**គ_ គេចោទថា** គ្រីស្តបរិស័ទបរិភោគសាច់មនុស្ស ។ ព្រះកាយនិងព្រះលោហិតដែលពួកគេបរិភោគ គឺជាសាច់ឈាមក្មេងដែលគេសម្លាប់បូជាក្នុងយញ្ញនោះ ។ មានអ្នកខ្លះមិនយល់ស្របនឹងពាក្យមួលបង្កាច់ទាំងនេះទេ ប៉ុន្តែ ប្រជាជនទូទៅមើលងាយគ្រីស្តបរិស័ទអស់រយៈពេលជាច្រើនឆ្នាំ ។

លោក**ព្លីន** (Pline គ.ស. ៦២-១១៤) ជាអ្នកនិពន្ធនិងជាអភិបាលស្រុកប៊ីធីនី (ទួរគីសព្វថ្ងៃ) ចែងអំពីគ្រីស្តសាសនាថាជា *«អបិយជំនឿសម្រាប់អ្នកដែលគ្មានប្រាជ្ញា និងអ្នកដែលមិនចេះប្លឹងប្លែង»* ។ លោក**ស៊ុយអេតុន** (Suétone ប្រហែល គ.ស. ១២០) ជាអ្នកនិពន្ធប្រវត្តិសាស្ត្រក្រុងរ៉ូមបោទថា គ្រីស្តសាសនាជា *«អបិយជំនឿថ្មីគួរឲ្យខ្លាច»* ។ លោក**តាស៊ីត** (Tacite គ.ស ៥៥-១២០) ជាអ្នកនិពន្ធប្រវត្តិសាស្ត្រក្រុងរ៉ូមដែរ បោទគ្រីស្តសាសនាថា ជា *«អបិយជំនឿគួរឲ្យស្អប់ខ្ពើម»* ។ ព្រះចៅ**ម៉ាក់-អូរ៉ែល** (Marc-Aurèle គ.ស ១៦២-១៨០) ដែលប្រកបដោយគតិបណ្ឌិតខ្ពង់ខ្ពស់ ចាត់គ្រីស្តបរិស័ទទុកជាមនុស្សចចេសរឹងរូស ។ លោក**លុយស៊ីយ៉ាំង** (Lucien គ.ស ១១៥-១៩២) ជាអ្នកនិពន្ធកំប្លែងយល់ឃើញថា
គ្រីស្តបរិស័ទជាអ្នកឆោតល្ងង់ ឆាប់ជឿអ្នកដទៃតែងឆបោកយ៉ាងស្រួល ។ ⑨

## ២- ពាក្យមួលបង្កាច់ពីសំណាក់អ្នកប្រាជ្ញ និងអ្នកនយោបាយ

អ្នកនិយាយបង្ខូចឈ្មោះគ្រីស្តបរិស័ទមកពីគេមិនស្គាល់ ។ ពួកអ្នកប្រាជ្ញចាប់ផ្តើមស៊ើបសួរអំពីគ្រីស្តបរិស័ទ ពួកគេយកព្រះគម្ពីរទៅអាន ហើយក្រោយមកពួកគេចាប់ផ្តើមជំទាស់ នឹងលទ្ធិគ្រីស្តសាសនា ដោយរិះគន់ជំនឿរបស់គ្រីស្ត
បរិស័ទ ។ អ្នកនិពន្ធពីរនាក់មានឈ្មោះល្បីជាងគេ គឺលោក**សែល្ស** (Celse គ.ស ⑩
១៧០) និងលោក**ព័រហ្វីរ** (Porphyre គ.ស ២៣៤-៣០៥) រិះគន់គ្រីស្តសាសនា ⑪
តាមមុខព្រួញបីយ៉ាងគឺ៖

8

## ពាក្យចចាមអារាម

លោក**មិនុស៊ិយ៉ូស-ហ្វេលិស** *(Minucius Félix)* ជាមេធាវីនៅក្រុងរ៉ូម ។ លោករស់នៅប្រហែល គ.ស. ២០០ ។ លោកសរសេរពាក្យសន្ទនារវាងគ្រីស្តបរិស័ទម្នាក់ឈ្មោះ **អុកតាវិយ៉ូស** *(Octavius)* និងអ្នកកាន់សាសនាដទៃម្នាក់ ។ អ្នកនោះរៀបរាប់ពាក្យចចាមអារាមគួរឲ្យរន្ធត់ចិត្ត ស្ដីអំពីគ្រីស្តបរិស័ទ ។ រីឯគ្រីស្តបរិស័ទអុកតាវីយ៉ូស តបឆ្លើយនឹងអ្នកនោះដោយចិត្តអំណត់ និងចង់បញ្ចុះបញ្ចូលគេ ។

*ខ្ញុំឮគេនិយាយថា មានជំនឿមិនទំនងដែលជំរុញគ្រីស្តបរិស័ទឲ្យឧទ្ទិសថ្វាយបង្គំក្បាលសត្វលា ដែលជាសត្វថោកទាបបំផុត ។ ពួកគេរៀបរាប់គ្រប់គ្នា អំពីពិធីបញ្ចូលចំណូលថ្មីក្នុងសាសនាគេគួរឲ្យព្រឺសាច់រន្ធត់ចិត្ត គឺគេដាក់ក្មេងដ៏តូចម្នាក់លាបម្សៅពេញខ្លួន ដើម្បីបោកបញ្ឆោតចំណូលថ្មីដែលទុកចិត្តគេនោះ ។ គេបំភ័ន្តអ្នកចំណូលថ្មីនោះដែលស្មានថា ក្មេងនោះជាដុំម្សៅ ។ គេនឹកស្មានថា គេយកកាំបិតចាក់ដុំម្សៅនោះមិនមែនជាការប្រព្រឹត្តអាក្រក់ទេ តែតាមពិត ចំណូលថ្មីនោះសម្លាប់ក្មេងម្នាក់ (...) ។ ពួកគេនាំគ្នាលិទ្ធឈាមរបស់ក្មេងនោះដូចជាស្រេកឃ្លានយ៉ាងខ្លាំង គេយកសាច់ចែកគ្នា ។ ពួកគេពង្រឹងសម្ពន្ធមេត្រីរវាងពួកគេ ដោយធ្វើយញ្ញដ៏មានជីវិតនេះ ហើយពួកគេសន្យានឹងគ្នាថា នឹងមិនប្រាប់នរណាឲ្យដឹងថា គេចូលរួមក្នុងបទឧក្រិដ្ឋនេះឡើយ (...) ។*

*មនុស្សគ្រប់ៗគ្នាស្គាល់ពិធីជប់លៀងរបស់ពួកគេ ហើយមនុស្សក៏តែងតែនិយាយគ្រប់គ្នាដែរ (...) ។ នៅពេលបុណ្យធំពួកគេជួបជុំគ្នាជប់លៀងរួមជាមួយកូនចៅ ជាមួយបងប្អូន និងជាមួយម្ដាយ មនុស្សគ្រប់ភេទនិងគ្រប់អាយុ ។ ក្រោយពីគេបរិភោគអាហារយ៉ាងបរិបូណ៌រួចហើយ គេស្រវឹងគ្រប់គ្នា ។ ពេលនោះ កម្លាំងតណ្ហាបណ្ដាលឲ្យគេសាហាយស្មន់នឹងគ្នា ។ គេចងឆ្កែមួយបន្ទាយទៅនឹងបង្គោលចង្កៀង រួចបោះចំណិតសាច់តាមបណ្ដោយខ្សែដែលគេចងវា ។ ពេលនោះ ឆ្កែស្ទុះទៅស៊ីចំណី ក៏ទាញទម្លាក់បង្គោលចង្កៀងចុះ ពន្លឺក៏រលត់បាត់ឈឹង (...) ។ ពេលនោះពួកគេឱបគ្នា ហើយរួមភេទតាមចៃដន្យ ។ ទោះបីពួកគេមិនរួមភេទគ្រប់គ្នាយ៉ាងពិតប្រាកដក្ដី ក៏គេមានចេតនាសាហាយស្មន់នឹងគ្នាដែរ ។*

*លោក មីនុស៊ីយ៉ូស ហ្វេលីស "អុកតាវីយ៉ូស" ៩,៦*

9

## គ្រីស្តបរិស័ទជាមនុស្សឆាប់ជឿសេចក្ដីផ្ដេសផ្ដាស

លោក**លុយស៊ីយ៉ាំង** (គ.ស. ១២៥-១៩២) ជាជនជាតិក្រិក មានដើមកំណើតនៅស្រុកស៊ីរី ។ លោកធ្វើដំណើរទៅច្រើនកន្លែង ហើយនិពន្ធអត្ថបទជាច្រើនជាការសន្ទនាខ្លីៗ ។ លោករៀបរាប់អំពីសង្គមនៅជំនាន់នោះតាមរបៀបកំប្លែង ទាំងរិះគន់ទស្សនវិជ្ជា និងសាសនាទាំងប៉ុន្មានក្នុងសម័យនោះ ។ លោកសរសេរសៀវភៅមួយក្រោមចំណងជើងថា «*លោក**ប៉េរ៉េហ្គ្រិនូស** (Péré grinus) ទទួល មរណភាព*» គឺលោករៀបរាប់អំពីមនុស្សម្នាក់ ពូកែនិយាយបោកបញ្ឆោតគ្រីស្តបរិស័ទដែលជាមនុស្សឆាប់ជឿ ។

*អ្នកទាំងនោះតែងជឿថា ពួកគេមានជីវិតអមតៈនិងរស់នៅអស់កល្បជានិច្ច ។ ដូច្នេះ គេមិនខ្លាចស្លាប់ទេ គេស្ម័គ្រចិត្តប្រថុយជីវិត ។ អ្នកបង្កើតសាសនារបស់គេ បញ្ចុះបញ្ចូលឲ្យពួកគេជឿថា គេជាបងប្អូននឹងគ្នា ។ ហេតុនេះហើយ បានជាគេបោះបង់ព្រះរបស់ជនជាតិក្រិកចោល បែរទៅគោរពអ្នកមានប្រាជ្ញាក្លែងក្លាយម្នាក់ដែលស្លាប់លើឈើឆ្កាង ពួកគេក៏ប្រព្រឹត្តតាមពាក្យទូន្មានរបស់អ្នកនោះដែរ ។ ហេតុនេះហើយ បានជាគេយកទ្រព្យសម្បត្តិទាំងអស់ប្រើប្រាស់រួមគ្នា (...) ។ ប្រសិនបើអ្នកបោកប្រាស់ដ៏ឆ្លាតវាងវៃម្នាក់ ពូកែឆ្លៀតឱកាស អ្នកនោះមុខជានឹងទៅជាអ្នកមានធនធានច្រើន ព្រោះពួកគេមិនយល់អ្វីសោះ ។*

Layout Histor.qxd 2/10/07 10:08 AM Page 22

# ⑩ គំនិតជំទាស់របស់អ្នកប្រាជ្ញម្នាក់ ប្រឆាំងនឹងលទ្ធិគ្រីស្តសាសនា

នៅគ.ស. ១៧០ លោក**សែលសុ** (Celse) ជាអ្នកប្រាជ្ញម្នាក់ដែលកាន់សាសនារ៉ូម៉ាំង ។ លោកស្រាវជ្រាវយ៉ាងច្រើនអំពីគ្រីស្តសាសនា តែបែរជាជំទាស់យ៉ាងខ្លាំងប្រឆាំងលទ្ធិ និងកិរិយាមារយាទរបស់គ្រីស្តបរិស័ទ ។ លោកនិពន្ធសៀវភៅជាភាសាក្រិក ក្រោមចំណងជើងថា «*ពាក្យសំដីអំពីសេចក្តីពិត*» ។

មានពូជពង្សមនុស្សថ្មីម៉្យាងដែលទើបនឹងកកើត គ្មានស្រុកទេស គ្មានទំនៀមទម្លាប់ បានរួមគ្នាប្រឆាំងរបនាសម្ពន្ធសាសនាទាំងប៉ុន្មាន និងរបនាសម្ពន្ធស៊ីវិលថែមទៀតផង ។ ចៅក្រមតែងដេញតាមគេ គេល្បីឈ្មោះខាងអាក្រក់ទូទាំងពិភពលោក តែគេបែរជាអួតខ្លួនដោយមនុស្សគ្រប់គ្នាស្អប់ខ្ពើមគេ ។ អ្នកទាំងនោះ គឺពួកគ្រីស្តបរិស័ទ (...) ។

គេមានពាក្យទូន្មានដូចតទៅ៖ «អស់អ្នកមានវប្បធម៌ អស់អ្នកដែលមានប្រាជ្ញា ឬអ្នកមានគំនិតពេះរិះគិត ចូរថយឲ្យឆ្ងាយពីទីនេះទៅ» ព្រោះពួកគេយល់ថា សេចក្តីប្រៀនប្រដៅរបស់អ្នកទាំងនោះសុទ្ធតែអាក្រក់ ។ បើមាននរណាម្នាក់ល្ងង់ខ្លៅ អាប់ប្រាជ្ញា មិនបានរៀនសូត្រ ល្ងីល្ងើ ពួកគេរាប់រកដោយចិត្តអង់អាច» គេគិតថា អ្នកទាំងនោះសមនឹងព្រះរបស់គេណាស់ គេបញ្ជាក់យ៉ាងច្បាស់ថា ពួកគេចង់ ហើយក៏បេះបញ្ចុះបញ្ចូលតែមនុស្សភ្លីភ្លើ ថោកទាប និងមនុស្សល្ងង់ខ្លៅ ទាសករ អ្នកក្រីក្រ ស្ត្រីៗ និងក្មេងៗ (...) ។

យើងមិនបាច់និយាយច្រើនទេ គ្មានព្រះណាយាងមកផែនដី ដើម្បីប្រោសមនុស្សឲ្យបានសុចរិតទេ ។ តើព្រះនោះយាងមកទីនេះមានគម្រោងការណ៍អ្វីខ្លះ? តើព្រះនោះចង់ជ្រាបអ្វីដែលកើតឡើងក្នុងចំណោមមនុស្សឬ? ប្រហែលព្រះអង្គជ្រាបអ្វីៗទាំងអស់ មានឫទ្ធានុភាពខ្សោយពេក មិនអាចកែប្រែអ្វីបាននៅលើផែនដីហើយឬ បានជាទ្រង់ត្រូវតែចាត់ព្រះមួយអង្គទៀតមកពិភពលោកនេះ (...) ? តើព្រះជាម្ចាស់បានសម្តែងព្រះអង្គឲ្យមនុស្សស្គាល់ ដើម្បីសង្គ្រោះតែអស់អ្នកដែលទទួលស្គាល់ព្រះអង្គ ដោយចាត់ទុកថា ជាអ្នកប្រព្រឹត្តតាមគុណធម៌ និងដាក់ទណ្ឌកម្មដល់អស់អ្នកដែលមិនទទួលស្គាល់ព្រះអង្គ ចាត់ទុកគេថា គឺជាអ្នកប្រព្រឹត្តអាក្រក់ដូច្នេះឬ? តើយើងត្រូវគិតយ៉ាងណាទៅ? តើយើងត្រូវគិតថា យូរសតវត្សកន្លងមកហើយ ព្រះជាម្ចាស់មិនរវីរវល់នឹងមនុស្សសោះ តែព្រះអង្គទើបមានព្រះហឫទ័យប្រោសឲ្យមនុស្សបានសុចរិតនៅសម័យនេះ ។ (...) ឬគិតថា ព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរសល្អប្រសើរបំផុតលើសអ្វីៗទាំងអស់ និងល្អឥតខ្ចោះនោះ ។ ប្រសិនបើព្រះអង្គយាងចុះមកផែនដីមែន គង់តែព្រះអង្គប្រែប្រួលជាពុំខាន គឺព្រះហឫទ័យសប្បុរស ក្លាយទៅជាព្រះហឫទ័យកាចសាហាវ ភាពល្អឥតខ្ចោះក្លាយជាអាក្រក់វិញ សុភមង្គលក្លាយទៅជាទុក្ខលំបាក ភាពពេញលក្ខណៈក្លាយជាលំអៀងអាក្រក់រាប់មិនអស់មិនខាន (...) ។ ការប្រែប្រួលបែបនេះ មិនសមគួរនិងឋានៈព្រះជាម្ចាស់ឡើយ ។

ប្រសិនបើគ្រីស្តបរិស័ទមិនថ្វាយយញ្ញបូជាតាមទម្លាប់ ហើយមិនព្រមគោរពអ្នករាជការ ដែលធ្វើជាអធិបតីក្នុងសក្ការបូជាទាំងនោះ គឺពួកគេពិតជាមិនទទួលស្គាល់ដល់អ្នកប្រគល់សេរីភាពឲ្យគេទៅជាមនុស្សជាដែរ ដូច្នេះ ពួកគេមិនត្រូវរៀបអាពាហ៍ពិពាហ៍ មិនត្រូវមានកូនតទៅទៀត និងមិនត្រូវបំពេញភារកិច្ចប្រចាំជីវិតដែរ គឺពួកគេត្រូវទៅឲ្យឆ្ងាយពីទីនេះ ដោយមិនទុកឲ្យមានពូជពង្សនៅទីនេះសោះឡើយ ដើម្បីឲ្យផែនដីបានជ្រះស្អាត គ្មានពូជមនុស្សបែបនេះទៀត ។ ប៉ុន្តែ ប្រសិនបើពួកគេនៅតែចង់រៀបអាពាហ៍ពិពាហ៍ ចង់បានកូន ចង់បរិភោគភោគផលនៃផែនដី ហើយចង់ចូលរួមសប្បាយរួមទុក្ខ ដូចគេដូចឯងនៅក្នុងសង្គម គេត្រូវគោរពអស់លោកដែលទទួលបន្ទុកកិច្ចការរដ្ឋបាល (...) ។

ប្រសិនបើមនុស្សទាំងអស់ប្រព្រឹត្តដូចពួកគេនោះ ព្រះចៅអធិរាជមុខជានឹងច្បាំងតែមួយព្រះអង្គឯង ពីព្រោះប្រជារាស្ត្របោះបង់ព្រះអង្គចោលគ្រប់ៗគ្នា ។ ពេលនោះខ្មាំងសត្រូវដ៏កាចសាហាវ អាចដណ្តើមយកពិភពលោកបាន ។ ពេលនោះគ្មានសាសនាដ៏ល្អរបស់ពួកគេទៀតទេ ហើយក៏គ្មានសិរីរុងរឿងនៃគតិបណ្ឌិតដ៏ពិតប្រាកដក្នុងចំណោមមនុស្សទៀតដែរ (...) ។

ចូរគាំទ្រព្រះចៅឲ្យអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ការពារច្បាប់រួមជាមួយព្រះអង្គ ប្រសិនបើកាលៈទេសៈហុចឲ្យ ចូរច្បាំងថ្វាយព្រះអង្គ ។ ចូរជួយព្រះអង្គដោយស្ម័គ្រចិត្ត ចូលបម្រើកងទ័ព ។ ហេតុនេះ ចូរឈប់គេចខ្លួន មិនបម្រើកិច្ចការរាជការ ចូរលែងគេចខ្លួនពីការបម្រើយោធា ។ ចូរទទួលមុខតំណែងជារាជការដើម្បីសង្គ្រោះច្បាប់ និងគោរពប្រណិប័តន៍ព្រះករុណាផង ។

លោកសែលសុ "ពាក្យសំដីអំពីសេចក្តីពិត"

(តាមលោកអូរីសែនកត់ត្រាទុកនៅសតវត្សទី ៣)

11

## គ្រីស្តសាសនាជាលទ្ធិលេលា

លោក**ព័រហ្វឺរ** (*Porphyre* គ.ស. ២៣៤-៣០៥) ជាជនជាតិសែម កើតនៅក្រុងទីរ៉ូស ។ លោកជាសិស្សរបស់ទស្សនវិទូ **ប្លូតាំង** (*Plotin*) ។ លោកជាទស្សនវិទូដែលមានគំនិតខ្ពង់ខ្ពស់តាមសីលធម៌ ហើយចាប់អារម្មណ៍នឹងវិជ្ជាខាងមន្តអាគម ។ លោកសរសេរសៀវភៅមួយក្រោមចំណងជើងថា «*ប្រឆាំងនឹងគ្រីស្តបរិស័ទ*» ។ ក្នុងសៀវភៅនោះ លោកជំទាស់នឹងគម្ពីរដំណឹងល្អទាំងបួនកណ្ឌដែលមិនត្រូវគ្នា ហើយក៏ជំទាស់ប្រឆាំងនឹងលទ្ធិគ្រីស្តសាសនាដែលលោកចោទថា ជាលទ្ធិលេលានោះដែរ ជាពិសេសលោកប្រឆាំងជំទាស់ និងគោលលទ្ធិស្តីអំពីព្រះជាម្ចាស់ប្រសូតជាមនុស្ស និងអំពីព្រះជាម្ចាស់ប្រោសលោកយេស៊ូឲ្យទទួលជីវិតថ្មីដ៏រុងរឿង ។

*ទោះបីយើងសន្និដ្ឋានថា ជនជាតិក្រិកដ៏ល្ងង់ខ្លះនាំគ្នានឹកគិតថា ព្រះរបស់គេស្ថិតនៅក្នុងរូបបដិមាក្តី ក៏គំនិតបែបនោះ ត្រឹមត្រូវនិងប្រសើរជាងជំនឿថា ព្រះមកចាប់កំណើតក្នុងផ្ទៃនាងព្រហ្មចារិនីម៉ារី ហើយកើតទៅជាទារកដែលម្តាយរុំដោយសំពត់ប្រឡាក់ដោយឈាម ទឹកប្រមាត់ និងលាមកទៀតផងដែរ (...) ។*

*ហេតុអ្វីបានជាពេលគេនាំព្រះគ្រីស្តនៅចំពោះមុខលោកមហាបូជាចារ្យ និងនៅចំពោះមុខលោកទេសាភិបាល ព្រះគ្រីស្តនេះគ្មានបញ្ចេញពាក្យណាមួយបញ្ជាក់ថា លោកជាអ្នកប្រាជ្ញ ឬជាមនុស្សផង និងព្រះផងដូច្នេះ (...)? ព្រះគ្រីស្តបណ្តោយឲ្យគេវាយ ឲ្យគេខាកស្តោះទឹកមាត់ដាក់មុខ ឲ្យគេយកបន្លាមកពាក់ជាមកុដ (...) ។ ទោះបីជាលោកត្រូវរងទុក្ខលំបាកតាមបញ្ជារបស់ព្រះជាម្ចាស់ ហើយយល់ព្រមនឹងទទួលទារុណកម្មក៏ដោយ ក៏លោកគួរនិយាយឲ្យបានច្បាស់ ប្រកបដោយគតិបណ្ឌិត មុននឹងរងទុក្ខលំបាកដូច្នេះ មកកាន់លោក**ពីឡាត**ជាអ្នកកាត់ទោស ។ ផ្ទុយទៅវិញ លោកបណ្តោយឲ្យជនទុច្ចរិតណាក៏ជេរប្រមាថមើលងាយបានដែរ ។*

*សេចក្តីប្រកាសថា លោកយេស៊ូដែលទទួលជីវិតថ្មីដ៏រុងរឿងពីព្រះជាម្ចាស់ (យោងតាម ១ ថស ៤,១៤) ជាពាក្យកុហកដ៏អស្ចារ្យម៉្យាង ប្រសិនបើយើងតែងបទអំពីរឿងនេះមកច្រៀងនៅមុខសត្វតិរច្ឆាន មុខជាសត្វទាំងនោះនឹងនាំគ្នាស្រែក ហើយយំយ៉ាងខ្លាំងៗពុំខាន ដោយនឹកថា មនុស្សមានសាច់ មានឈាម អាចហោះហើរនៅលើមេឃ ដូចបក្សាបក្សីហើរនៅលើអាកាស ឬដើរលើដុំពពក (...) ។*

### *ក- គ្រីស្តបរិស័ទសុទ្ធតែជាមនុស្សក្រីក្រល្ងង់ខ្លៅនិងក្រអឺតក្រទម*

គ្រីស្តបរិស័ទជាច្រើនមានឋានៈទាបជាងគេក្នុងសង្គម ជាពលករដែលអ្នកចេះដឹងតែងតែមើលងាយ ជាអ្នកសិតរោមចៀម ជាងធ្វើស្បែកជើង អ្នកបោកគក់ខោអាវ ។ល។ ដូច្នេះ អ្នកប្រាជ្ញចោទប្រកាន់ថា គ្រីស្តបរិស័ទតែងទាក់ទងតែជាមួយស្ត្រីៗ ក្មេងៗ និងជាមួយពួកទាសករប៉ុណ្ណោះ ដោយយល់ឃើញថា អ្នកទាំងនោះឆាប់ជឿគេ ។ គេចោទទៀតថា គ្រីស្តបរិស័ទមិនគោរពអារ្យធម៌រ៉ូម៉ាំង ព្រោះតាមអារ្យធម៌រ៉ូម៉ាំង ប្រជាជនរាប់រកតែអ្នកប្រាជ្ញ អ្នកមានសម្បត្តិច្រើន ហើយអ្នកដែលមិនធ្វើការដោយផ្ទាល់ដៃ ប្រឡាក់ខ្លួនដូចទាសករ ។ គេថា គ្រីស្តបរិស័ទលើកតម្លៃស្ត្រីៗ និងកូនក្មេង ឲ្យមានកិត្តិយសលើសពីស្វាមី និងលើសពីឪពុករបស់ខ្លួន ហេតុនេះហើយ បានជាពួកគេបំផ្លាញអំណាចស្វាមីមកលើភរិយា និងអំណាចឪពុកមកលើកូន ។

អ្នកប្រាជ្ញយល់ឃើញថា ព្រះជាម្ចាស់ប្រសូតជាមនុស្ស ជាលទ្ធិមិនសមហេតុសមផល ។ តើព្រះដ៏ល្អឥតខ្ចោះដែលទ្រង់មិនប្រែប្រួល ព្រះអង្គបន្ទាបព្រះអង្គក្លាយទៅជាក្មេងតូចដូចម្តេចបាន? ។ ម្យ៉ាងទៀត ហេតុអ្វីបានជាព្រះជាម្ចាស់ប្រសូតជាយូរសតវត្សក្រោយមនុស្សលោកកើតមកដូច្នេះ? ព្រះយេស៊ូគ្រាន់តែជាមនុស្សដ៏ថោកទាប មិនស្ថិតក្នុងឋានៈអ្នកប្រាជ្ញដូចលោក**សូក្រាត** (Socrate)

Layout Histor.qxd 2/10/07 10:08 AM Page 24

ទេ ។ នៅពេលលោកយេស៊ូប្រៀនប្រដៅ លោកគ្រាន់តែយកលទ្ធិរបស់ជនជាតិអេស៊ីបនិងជនជាតិក្រិកពីដើម មកប្រាប់គ្នាប៉ុណ្ណោះ ។ លទ្ធិប្រកាសថា មនុស្សស្លាប់នឹងទទួលជីវិតថ្មីពីព្រះជាម្ចាស់ គឺជាពាក្យភូតភរកុហកដ៏អាក្រក់បំផុត ។ លោក**ពរហ្វីរ**យល់ឃើញថា ក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ និងគម្ពីរសម្ពន្ធមេត្រីថ្មីសុទ្ធតែមានកត់ត្រាទុករឿងដ៏គ្រោតគ្រាត ថែងអំពីព្រះជាម្ចាស់តាមរបៀបមនុស្សសាមញ្ញធម្មតា ។ តាមគម្ពីរសម្ពន្ធមេត្រីថ្មី ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យមេត្តាករុណា ប្រៀនប្រដៅអំពីសន្តិភាព ផ្ទុយនឹងព្រះជាម្ចាស់ ដែលចេះតែធ្វើសឹកសង្គ្រាម តាមគម្ពីរសម្ពន្ធមេត្រីចាស់ ។ គម្ពីរដំណឹងល្អទាំងបួនថែងអំពីលោកយេស៊ូរងទុក្ខលំបាកនិងស្លាប់ មិនដូចគ្នាទេ ។ ពិធីបុណ្យរបស់គ្រីស្តបរិស័ទទាស់នឹងសីលធម៌ ។ ឧប. នៅក្នុងពិធីជ្រមុជទឹក បើទឹកតែបន្តិចបន្តួចធ្វើឲ្យមនុស្សបានរួចពីបាបមែន ពិធីនេះជំរុញមនុស្សឲ្យប្រព្រឹត្តអំពើបាបតទៅទៀត ។ ទោះបីគ្រីស្តបរិស័ទពន្យល់អំពីពិធីអរព្រះគុណតាមរបៀបជានិមិត្តរូបក្តី ក៏ក្នុងពិធីអរព្រះគុណនេះ គ្រីស្តបរិស័ទនៅតែពិសាសាច់មនុស្ស ។ នៅទីបញ្ចប់ អ្នកប្រាជ្ញសង្កេតឃើញថា គ្រីស្តបរិស័ទបាក់បែកជានិកាយជាច្រើន ដែលសុទ្ធតែអួតថា មានតែខ្លួនគេទេត្រឹមត្រូវ ហើយស្តីបន្ទោសគ្នាយ៉ាងខ្លាំងផង ។

### *ខ- គ្រីស្តបរិស័ទតបឆ្លើយនឹងអ្នកបង្ខាប់បង្អោនពួកគេ*

គ្រីស្តបរិស័ទខ្លះមានបំណងបំភ្លឺមតិប្រជាជន អំពីសាសនារបស់ខ្លួន ព្រមទាំងចង់ការពារព្រះសហគមន៍ ។ ពួកគេនាំគ្នាសរសេរសៀវភៅ ដើម្បីពន្យល់អំពីលទ្ធិគ្រីស្តសាសនាឲ្យបានច្បាស់ អំពីកិរិយាមារយាទរបស់គេ កុំឲ្យប្រជាជនយល់ច្រឡំ ។ គ្រីស្តបរិស័ទតែងហៅអត្ថបទ និងសៀវភៅទាំងនោះថា «*សៀវភៅការពារគ្រីស្តសាសនា*» ។ បំណងដើងនេះក៏មានន័យថា គេចង់ដោះសាពន្យល់លទ្ធិរបស់ខ្លួន និងរបៀបរស់នៅរបស់ព្រះសហគមន៍ឲ្យបានត្រឹមត្រូវ ។

## ៣- អស់លោកសរសេរសៀវភៅការពារគ្រីស្តសាសនា

គ្រីស្តបរិស័ទខ្លះនិពន្ធសៀវភៅសម្រាប់អ្នកគ្មានជំនឿលើព្រះគ្រីស្តដូចគេ គឺគេសរសេរថ្វាយទៅព្រះចៅអធិរាជ សរសេរជូនមន្ត្រីរាជការ ជូនបញ្ញវន្ត ហើយក៏ជូនប្រជាជនទូទៅផងដែរ ។ អស់លោកខិតខំរកពាក្យពេចន៍សម្រាប់ឲ្យអ្នកអានងាយយល់ គឺគេនិពន្ធតាមវប្បធម៌ក្រិក-ឡាតាំងនោះ ។ ដូច្នេះ គ្រីស្តសាសនាលែងនៅជាប់ឡែកពីវប្បធម៌របស់ប្រជាជនទូទៅទៀតហើយ ។ គ្រីស្តបរិស័ទជាអ្នកនិពន្ធទាំងនោះតែងរិះគិតអំពីគ្រីស្តសាសនាតាមអារ្យធម៌ក្រិក ហើយក៏ធ្វើឲ្យអារ្យធម៌ក្រិកនេះទទួលឥទ្ធិពលពីគ្រីស្តសាសនាដែរ ។ ពួកគេក៏ចាប់ផ្តើមបង្កើតទេវវិជ្ជានៃគ្រីស្តសាសនា ។

យើងមិនស្គាល់គ្រីស្តបរិស័ទដែលនិពន្ធសម្រាប់ការពារគ្រីស្តសាសនាទាំងនោះទេ គឺយើងគ្រាន់តែស្គាល់ឈ្មោះរបស់គេ និងអត្ថបទដែលគេសរសេរខ្លះៗប៉ុណ្ណោះ តាមលោក**អឺសែប** (Eusèbe) ជាអភិបាលព្រះសហគមន៍ក្រុងសេសារេបានចម្លងទុកមក ។ មានស្នាដៃដ៏សំខាន់ខ្លះស្ថិតនៅរហូតដល់សព្វថ្ងៃ ឧប. ៖

លោក**យូស្តាំង** (Justin ប្រ.គ.ស.១៤០-១៥០) ។ លោកបង្កើតសាលាទស្សនវិជ្ជានៃគ្រីស្តសាសនានៅក្រុងរ៉ូម ។ លោកការពារជំនឿរបស់គ្រីស្តបរិស័ទពីជនជាតិយូដា និងពីអ្នកកាន់សាសនាដទៃដែលប្រឆាំងនឹងគ្រីស្តសាសនា ។

អ្នកនិពន្ធម្នាក់ទៀតសរសេរលិខិតផ្ញើជូនលោក**ឌីយ៉ូញ៉ែត** (Diognète) ។ ⑫
លោកថែងថា គ្រីស្តបរិស័ទដូចជាវិញ្ញាណនៃពិភពលោក ។ តាមទស្សនវិជ្ជាក្រិក «*វិញ្ញាណ*» ផ្តល់ឲ្យរូបកាយមនុស្សមានជីវិតរស់រវើក ។ យ៉ាងណាមិញ គ្រីស្តបរិស័ទផ្តល់ឲ្យពិភពលោកមានជីវិតរស់រវីក និងផ្តល់អត្ថន័យដល់ពិភពលោកនោះផង ។ លោកឆ្លើយតបសំណួរគេថា តើគ្រីស្តបរិស័ទខុសប្លែកពីមនុស្សដទៃនៅត្រង់ណា? គឺគ្រីស្តបរិស័ទរស់នៅដូចគេដូចឯង តែមានជំនឿលើព្រះយេស៊ូ ខិតខំរស់នៅដោយនឹកគិតដល់ស្ថានបរមសុខជាមាតុភូមិរបស់គេ ។

Layout Histor.qxd 2/10/07 10:08 AM Page 25

## ⑫ គ្រីស្តបរិស័ទក្នុងសង្គមមនុស្ស

គ្មាននរណាដឹងថា នរណានិពន្ធ «លិខិតផ្ញើជូនលោក**ឌីយ៉ូញ៉េត**» (*Diognète*) ទេ ។ ប្រហែលគេនិពន្ធលិខិតនេះនៅក្រុងអាឡិចសង់ឌ្រី នៅក្នុងគ.ស. ១៩០ ។ លោកមានបំណងការពារគ្រីស្តសាសនាយ៉ាងខ្លាំង ។

*គ្រីស្តបរិស័ទមិនរស់នៅក្នុងប្រទេសមួយដោយឡែកពីគេទេ ពួកគេមិននិយាយភាសាប្លែកពីអ្នកដទៃ មិនស្លៀកពាក់ប្លែកពីអ្នកដទៃ ហើយក៏មិនកាន់ប្រពៃណីឬទំនៀមទម្លាប់ប្លែកពីអ្នកដទៃទៀតដែរ ។ ពួកគេមិនរស់នៅក្នុងក្រុងសម្រាប់តែពួកគេទេ ពួកគេមិននិយាយភាសាប្លែកអស្ចារ្យទេ និងរបៀបរស់នៅរបស់ពួកគេក៏មិនខុសពីអ្នកឯទៀតៗដែរ ។ ការប្រៀនប្រដៅដែលពួកគេកាន់នេះ មិនហូរចេញមកពី មនុស្សស្រមៃឃើញ ឬយល់សុបិនឃើញឡើយ ។ ពួកគេមិនប្រកាន់លទ្ធិដែលមនុស្សបានបង្កើតឡើងទេ ។*

*គ្រីស្តបរិស័ទរស់នៅក្នុងក្រុងអ្នកមានអារ្យធម៌ខ្ពស់នៃជនជាតិក្រិក និងក្នុងក្រុងអ្នកមានអារ្យធម៌ទន់ទាប តាមវាសនារៀងៗខ្លួន ។ ពួកគេស្លៀកពាក់ដូចគេដូចឯងដែរ ។ ចំពោះចំណីអាហារ និងរបៀបរស់នៅប្រចាំថ្ងៃ ពួកគេក៏ធ្វើតាមអ្នកឯទៀតៗដែរ ទាំងបង្ហាញវិន័យដ៏អស្ចារ្យរបស់ខ្លួន គឺវិន័យដ៏ប្រសើរនៃប្រទេសរបស់ខ្លួនខាងវិញ្ញាណផង ។*

*ពួកគេរស់នៅក្នុងមាតុភូមិរៀងៗខ្លួន តែគេហាក់ដូចជាអាណិកជនបរទេសដែលមកតាំងទីលំនៅក្នុងប្រទេសនេះ ។ ពួកគេបំពេញភារកិច្ចទាំងប៉ុន្មាន តាមឋានៈជាប្រជាពលរដ្ឋទូទៅ ហើយបង់ពន្ធដារក្នុងឋានៈជាអាណិកជន ។ ប្រទេសទាំងប៉ុន្មានសុទ្ធតែជាមាតុភូមិរបស់ខ្លួន ពួកគេក៏រាប់មាតុភូមិរបស់ខ្លួនទុកជាប្រទេសដទៃដែរ ។ ពួកគេរៀបអាពាហ៍ពិពាហ៍ដូចអ្នកឯទៀតៗ គេបង្កើតកូនដូចគេ ប៉ុន្តែ ពួកគេមិនលះបង់បោលកូនដែលទើបកើតនោះទេ ។ ពួកគេចូលរួមតុជាមួយគ្នា តែមិនរួមដំណេកជាមួយគ្នាទេ ។*

*ពួកគេរស់នៅក្នុងលោកិយ ប៉ុន្តែពួកគេមិនរស់នៅតាមលោកិយទេ ។ ពួកគេរស់នៅលើផែនដី តែពួកគេជាប្រជារាស្ត្រនៃស្ថានបរមសុខ ។ ពួកគេធ្វើតាមច្បាប់រដ្ឋអំណាច តែរបៀបគេរស់នៅ ប្រសើរជាងច្បាប់ទម្លាប់ដ៏ល្អប្រសើរទាំងអស់ ។*

*ពួកគេស្រឡាញ់មនុស្សទាំងអស់ តែមនុស្សទាំងអស់ធ្វើទុក្ខបុកម្នេញដល់គេ ។ ប្រជាជនមិនស្គាល់ចិត្តពួកគេ និងដាក់ទោសគេ ។ រដ្ឋអំណាចសម្លាប់ពួកគេ តែគេទទួលជីវិតវិញ ។ ពួកគេជាអ្នកក្រីក្រ តែគេធ្វើឲ្យមនុស្សជាច្រើនជាអ្នកមាន ។ ពួកគេខ្វះខាតអ្វីៗទាំងអស់ តែគេមានយ៉ាងលើសលប់ក្នុងគ្រប់វិស័យ ។ ប្រជាជនតែងមើលងាយពួកគេ តែពួកគេទទួលសិរីរុងរឿងដោយប្រជាជនទាំងនោះមើលងាយវិញ ។ ប្រជាជនបង្ខូចឈ្មោះពួកគេថា ជាមនុស្សអាក្រក់ តែព្រះជាម្ចាស់ប្រោសគេឲ្យបានសុចរិត ។ ប្រជាជនជេរប្រមាថពួកគេ តែគេជូនពរទៅវិញ ។*

*និយាយឲ្យខ្លីទៅ វិញ្ញាណផ្តល់ជីវិតឲ្យរូបកាយយ៉ាងណា គ្រីស្តបរិស័ទផ្តល់ជីវិតឲ្យមនុស្សលោកយ៉ាងនោះដែរ ។ វិញ្ញាណស្ថិតនៅគ្រប់សរីរាង្គកាយរបស់ខ្លួនមនុស្សយ៉ាងណា គ្រីស្តបរិស័ទស្ថិតនៅគ្រប់ក្រុងក្នុងពិភពលោកយ៉ាងនោះដែរ ។ វិញ្ញាណស្ថិតនៅក្នុងរូបកាយ ប៉ុន្តែ វិញ្ញាណមិនមែនជារូបកាយទេ ដូចគ្រីស្តបរិស័ទរស់នៅក្នុងពិភពលោក ប៉ុន្តែ ពួកគេមិនមែនធ្វើតាមពិភពលោកទេ ។ វិញ្ញាណកាន់តែល្អប្រសើរ ដោយប្រព្រឹត្តតាមសីលធម៌យ៉ាងណា គ្រីស្តបរិស័ទក៏ដូច្នេះដែរ រដ្ឋអំណាចធ្វើទុក្ខបុកម្នេញពួកគេ គេកើនចំនួនកាន់តែច្រើនឡើងជារៀងរាល់ថ្ងៃដែរ ។ ពួកគេគ្មានសិទ្ធិរត់បោលមុខងារដែលព្រះជាម្ចាស់បានប្រគល់ឲ្យគេនោះទេ ព្រោះមុខងារនេះប្រសើរបំផុត ។*

*លិខិតផ្ញើជូនលោក ឌីយ៉ូញ៉េត ៥-៦*

លោក**ទែរទូលីយ៉ាំង** (Tertullien) ជាអ្នកល្បីឈ្មោះជាងគេ ក្នុងចំណោមគ្រីស្តបរិស័ទដែលនិពន្ធសៀវភៅការពារគ្រីស្តសាសនា ។ លោករស់នៅក្នុងក្រុងកាតាស្ស (Carthage) (សព្វថ្ងៃក្រុងទុយនិស្ស ទ្វីបអាហ្វ្រិក) ហើយជាមេធាវី ។ លោកសរសេរសៀវភៅមួយមានចំណងជើងថា *«សេចក្តីការពារគ្រីស្តសាសនា»* ដែលបង្ហាញទេពកោសល្យនិងចិត្តក្លាហានរបស់លោក (ប្រ.នៅគ.ស. ១៩៧) ។

គ្រីស្តបរិស័ទជាអ្នកនិពន្ធសៀវភៅការពារទាំងនោះ ប្រកាសយ៉ាងខ្លាំងៗថា ពាក្យចោទប្រកាន់គ្រីស្តបរិស័ទ ការធ្វើទុក្ខបុកម្នេញ ការកាត់ក្តី និងការផ្តន្ទាទោសគេ សុទ្ធតែជាអំពើអយុត្តិធម៌ទាំងអស់ ។ អស់លោកតបឆ្លើយនឹងសេចក្តីនីមួយៗរបស់អ្នកប្រឆាំងទាំងនោះ ។

## ៤- គ្រីស្តបរិស័ទមិនរស់ដោយស្ងាត់កំបាំងទេ

អ្នកនិពន្ធទាំងនោះតែងប្រកាសថា គ្រីស្តបរិស័ទអាចរៀបរាប់អំពីពិធីបុណ្យរបស់ពួកគេប្រាប់អ្នកប្រឆាំងបាន ។ ដូច្នេះ សៀវភៅរបស់លោក**យូស្ទាំង** (Justin) នាំយើងឲ្យស្គាល់ពិធីសំខាន់របស់គ្រីស្តបរិស័ទនៅសតវត្សទី ២ ។ លោកទែរទូលីយ៉ាំង ក៏ពន្យល់អំពីរបៀបចាត់ចែងព្រះសហគមន៍ដែរ ។ អ្នកខាងក្រៅចោទគ្រីស្តបរិស័ទថា គេលាក់ខ្លួនដូចសត្វកណ្តុរ ។ តែតាមពិតគេរស់នៅគ្រប់ទីកន្លែង ។ គេមានសកម្មភាពដូចអ្នកឯទៀតៗ ហូបម្ហូបអាហារដូចអ្នកដទៃ គេក៏ស្លៀកពាក់ដូចអ្នកដទៃដែរ ។ គេគ្រាន់តែមិនព្រមចូលវិហារព្រះផ្សេងៗ និងមិនព្រមទៅទស្សនាល្បែងក្នុងកីឡាដ្ឋានប៉ុណ្ណោះ ។

## ៥- «គឺអ្នករាល់គ្នាទេដែលមានមារយាទថោកទាប!»

ជនជាតិរ៉ូម៉ាំងអនុញ្ញាតឲ្យឪពុកមានសិទ្ធិសម្លាប់កូនរបស់ខ្លួនទើបកើតបាន និងឲ្យស្ត្រីពន្លូតកូនបានដែរ ។ រីឯគ្រីស្តបរិស័ទហាមផ្តាច់មិនឲ្យប្រព្រឹត្តអំពើទាំងពីរនោះទេ ។ អ្នកខាងក្រៅចូលចិត្តការស្រើបស្រាល ហើយក៏ចូលចិត្តនិទានអំពីព្រះនានាពូកែស្នេហាគ្នាយ៉ាងអស្ចារ្យ អ្នកខាងក្រៅព្រមឲ្យបុរសផ្លាស់ប្តូរភរិយាគ្នាទៅវិញទៅមកបាន ។ របៀបរស់នៅរបស់គ្រីស្តបរិស័ទដែលមានសីលធម៌ល្អបណ្តាល ឲ្យអភិជនរ៉ូម៉ាំងទាស់ចិត្តយ៉ាងខ្លាំង ព្រោះជំទាស់នឹងការរស់នៅរបស់ខ្លួន ។ ម្យ៉ាងទៀត គ្រីស្តបរិស័ទក៏មិនគោរពព្រះផ្សេងៗ ដែលគេចាត់ទុកជាព្រះក្លែងក្លាយដែរ ។ លោកទែរទូលីយ៉ាំងសរសេរប្រឆាំងខ្លាំងហួស ។



*សក្ការៈបូជាថ្វាយព្រះមីត្រា*

Layout Histor.qxd 2/10/07 10:08 AM Page 27

## ៦- គ្រីស្តសាសនាជាលទ្ធិត្រូវតាមប្រាជ្ញារបស់មនុស្ស

អ្នកនិពន្ធការពារគ្រីស្តសាសនា តែងតែភ្ជាប់លទ្ធិគ្រីស្តសាសនាទៅនឹងគម្ពីរសម្ពន្ធមេត្រីចាស់ ដោយមានបំណងបញ្ជាក់ថា គ្រីស្តសាសនាកើតមុនទស្សនវិជ្ជាក្រិក ។ ឧប. លោក**ម៉ូសេ**កើតមុនអ្នកប្រាជ្ញជាតិក្រិក អ្នកប្រាជ្ញជាតិក្រិកទាំងនោះគ្រាន់តែបានលួចគំនិតពីលោកម៉ូសេ ប៉ុណ្ណោះ ។ រីឯលោក**សេលស្ស**សរសេរបញ្ជាក់ថា លោកម៉ូសេ លួចគំនិតពីជនជាតិអេស៊ីបវិញ ។ ដូច្នេះ អ្នកប្រាជ្ញដែលប្រឆាំងនឹងគ្រីស្តសាសនា និងអ្នកនិពន្ធការពារគ្រីស្តសាសនា មិនយល់ចិត្តគ្នាទេ ។ ជួនកាលអស់លោកនាំគ្នាការពារគ្រីស្តសាសនា ដោយប្រឆាំងសាសនាដទៃយ៉ាងខ្លាំង ទាំងមិនសូវមានចិត្តសាស្ត្រទេ ឧបមាថា គេប្រកាសថា ព្រះរបស់សាសនាដទៃនោះសុទ្ធតែជាមារ ដែលប្រព្រឹត្តខុសសីលធម៌ ។ លោក**យូស្តាំង**ប្រកាសថា៖ «*យើងមិនគោរពព្រះក្លែងក្លាយរបស់អ្នករាល់គ្នាទេ*» ។

## ៧- គ្រីស្តបរិស័ទជាប្រជាពលរដ្ឋដ៏ល្អ

នៅសតវត្សដើមដំបូងនៃ គ.ស. គ្រីស្តបរិស័ទមិនដឹងគិតយ៉ាងណាអំពីរដ្ឋអំណាចទេ ។ កូនចៅលោក**យ៉ូហាន**ដែលនិពន្ធគម្ពីរវិវរណៈ និងអ្នកអត្ថាធិប្បាយគម្ពីរនោះ ចាត់រដ្ឋអំណាចរ៉ូម៉ាំងទុកជា «*ក្រុងបាប៊ីឡូន*» ដ៏ខិលខូច ឬជាសត្តិរច្ឆានដ៏សាហាវ ដ្បិតរដ្ឋអំណាចរ៉ូម៉ាំងតែងថ្វាយសក្ការបូជា ចំពោះរូបបដិមា និងតែងធ្វើទុក្ខបុកម្នេញដល់ព្រះសហគមន៍ ។ គេទស្សន៍ទាយថា រដ្ឋអំណាចនោះត្រូវវិនាសសាបសូន្យជាពុំខាន ដូចរូបបដិមាដ៏ធំមហិមាដែលមានជើងសិតអំពីដីឥដ្ឋ ។ ម្យ៉ាងទៀត គ្រីស្តបរិស័ទទន្ទឹងរង់ចាំព្រះគ្រីស្តយាងមកវិញនៅពេលឆាប់ៗ ដូច្នេះ គេមិនសូវចាប់អារម្មណ៍អំពីពិភពលោកនេះទេ ។ ប៉ុន្តែ អ្នកនិពន្ធការពារ
(13) គ្រីស្តសាសនានៅតែប្រកាសថា គេមានចិត្តស្មោះត្រង់ចំពោះរដ្ឋអំណាចស្របតាម រ៉ូម ១៣,១-៧ និង ១ សល ២, ១៣ ។

គ្រីស្តបរិស័ទមិនព្រមគោរពព្រះចៅអធិរាជទុកជាព្រះអម្ចាស់ទេ ប៉ុន្តែ គេនៅតែប្រណិប័តន៍តាមបញ្ជាព្រះចៅ និងអង្វរព្រះជាម្ចាស់ប្រទានពរមកព្រះចៅដែរ ។ គ្រីស្តបរិស័ទនាំគ្នាបង់ពន្ធមុនគេ ។

## ៨- គ្រីស្តបរិស័ទក្នុងជួររាជការនិងយោធា

លោក**ទែរទូលីយ៉ាំង** សរសេរថា មានគ្រីស្តបរិស័ទនៅគ្រប់ទីកន្លែង សូម្បី (14)
តែក្នុងជួរយោធាក៏មានដែរ ។ ប្រហែលដប់ឆ្នាំ ក្រោយពីលោកនិពន្ធសៀវភៅ
«*សេចក្តីការពារ*» នោះ លោកនិពន្ធសៀវភៅមួយទៀតដែលមានចំណងជើងថា (15)
«*កម្រងផ្ការបស់ទាហាន*» ។ ក្នុងសៀវភៅនោះ លោកបញ្ចេញគំនិតថា គ្រីស្តបរិស័ទមិនអាចធ្វើទាហានបានទេ ។ លោកសរសេរដូច្នេះ ប្រហែលបណ្តាលមកពីលោក ចូលក្នុងនិកាយលោក**មុនតាំង** (Montan) ដែលកាន់គំនិតជ្រុល ហើយតែងប្រកាសថា គ្រីស្តបរិស័ទត្រូវដាច់ស្រឡះពីមនុស្សលោក ដែលត្រូវវិនាសសាបសូន្យក្នុងពេលឆាប់ៗខាងមុខនេះ ។ គ្រីស្តបរិស័ទដែលនិពន្ធសៀវភៅក្នុងសម័យជាមួយគ្នានោះ ក៏មិនសូវយល់ស្របឲ្យគ្រីស្តបរិស័ទបម្រើកងទ័ព និងធ្វើជាអ្នករាជការដែរ ។ មុនទទួលអគ្គសញ្ញាជ្រមុជទឹក គេតែងសួរបេក្ខជនអំពីអាជីពរបស់គេ ហើយមិនព្រមទទួលទាហាន និងមន្ត្រីរាជការទេ ។

លោក**អ៊ីប៉ូលីត** (Hippolyte) ជាបូជាចារ្យក្នុងព្រះសហគមន៍ក្រុងរ៉ូម រស់នៅខាងដើមសតវត្សទី ៣ ។ លោកនិពន្ធសៀវភៅមួយដែលមានចំណងជើងថា «*សេចក្តីប្រៀនប្រដៅទទួលតៗពីក្រុមគ្រីស្តទូតមក*» ។ លោកក៏មិនព្រមឲ្យគ្រីស្តបរិស័ទធ្វើទាហាន ឬធ្វើអ្នករាជការ មកពីមូលហេតុពីរយ៉ាងគឺ៖

ជួនកាលទាហានត្រូវទទួលបេសកកម្មដែលប្រឆាំងនឹងដំណឹងល្អ គឺគង់តែថ្ងៃណាមួយ អ្នករាជការនិងទាហាន ត្រូវចូលរួមក្នុងពិធីថ្វាយបង្គំព្រះក្លែងក្លាយ ឬថ្វាយបង្គំព្រះចៅអធិរាជ ឬត្រូវប្រើហឹង្សា ។ ចៅក្រមគង់តែត្រូវកាត់ក្តីមនុស្ស

Layout Histor.qxd 2/10/07 10:08 AM Page 28

ដាក់ទោសដល់ជីវិត រីឯទាហានក៏គង់តែត្រូវប្រហារជីវិតមនុស្សនៅលើសមរភូមិពុំខានដែរ ។ ហេតុនេះហើយ បានជាលោកសុំគ្រីស្តបរិស័ទដែលមានអំណាចដាក់
16 ទោសដល់ជីវិត ឲ្យបោះបង់មុខតំណែងរបស់ខ្លួនបោល ។ ចំពោះសភាពការណ៍ទាហានវិញស្មុគស្មាញបន្តិច គឺនៅសម័យនោះ កងទ័ពមានសុទ្ធតែទាហានស្ម័គ្រចិត្ត ព្រះសហគមន៍តែងតែទូន្មានគ្រីស្តបរិស័ទ កុំស្ម័គ្រចិត្តចូលបម្រើកងទ័ព ។ តែជួនកាលមានទាហានខ្លះប្រែចិត្តមកជឿលើព្រះយេស៊ូវិញ តើពួកគេត្រូវចេញពីជួរឬយ៉ាងណា? ប៉ុន្តែ អ្នកដែលស្ម័គ្រចិត្តបម្រើកងទ័ព ត្រូវបម្រើឲ្យបានម្ភៃឆ្នាំ មិនអាចបោះបង់តំណែងជាមុនបានឡើយ ។ ព្រះសហគមន៍ហាមគ្រីស្តបរិស័ទសម្លាប់មនុស្ស ហាមស្បថបម្រើព្រះចៅអធិរាជ ដោយយល់ឃើញថា ព្រះចៅជាព្រះក្លែងក្លាយ ។ តែសេចក្តីទាំងពីរនេះមិនងាយអនុវត្តទេ ។

បើគ្រីស្តបរិស័ទចំនួនតិចគ្មានបញ្ហាចោទឡើងទេ តែពេលគ្រីស្តបរិស័ទកើនចំនួនច្រើនឡើង ទើបកើតវិបត្តិ ជាពិសេសនៅពេលខ្មាំងសត្រូវធ្វើសឹកសង្គ្រាមវាយសម្រុកតាមព្រំដែន ។ នេះជាមូលហេតុលោក**សែល្ស**ស្តីបន្ទោសគ្រីស្តបរិស័ទថា ជាអ្នកព្រួតដៃជាមួយខ្មាំង ។

ក្រោយពេលព្រះចៅ**កុងស្តង់តាំង** (Constantin) ប្រោសប្រទានសេចក្តីសុខសាន្តដល់ព្រះសហគមន៍ *(គ.ស. ៣១៣)* អ្នកដឹកនាំព្រះសហគមន៍លែងហាមឃាត់គ្រីស្តបរិស័ទធ្វើទាហានទៀតហើយ ព្រោះពេលគេស្បថបម្រើព្រះចៅអធិរាជនោះ មានន័យថា គេលែងស្បថបម្រើព្រះក្លែងក្លាយទៀតហើយ ។ ក៏ប៉ុន្តែ អស់លោកនៅតែមិនសូវពេញចិត្តនឹងគ្រីស្តបរិស័ទបម្រើកងទ័ពដដែល ។ រីឯទាហានដែលបានបង្ហូរឈាម គឺត្រូវតែធ្វើពិធីជម្រះខ្លួនឲ្យបានបរិសុទ្ធដែរ ។

13

## ពាក្យអធិដ្ឋានបុរាណជាងគេសម្រាប់រដ្ឋអំណាច

លោក**ក្លេម៉ង់**បញ្ចប់លិខិតដោយចែង *"ពាក្យអធិដ្ឋានសកល"* យ៉ាងវែងមួយសម្រាប់គ្រីស្តបរិស័ទនិងមនុស្សទាំងអស់ ។

*ឱ! ព្រះអម្ចាស់អើយ! សូមទ្រង់ព្រះមេត្តាប្រទានសេចក្តីសុខសាន្ត និងសន្តិភាពឲ្យយើងខ្ញុំ និងឲ្យមនុស្សទាំងអស់នៅលើផែនដី ដូចព្រះអង្គប្រោសប្រទានឲ្យបុព្វបុរសរបស់យើងខ្ញុំកាលពីដើម គឺនៅពេលគេអង្វរព្រះអង្គតាមជំនឿ និងតាមសេចក្តីពិត ។ សូមព្រះអង្គមេត្តាប្រោសយើងខ្ញុំ ឲ្យសុខចិត្តចុះចូលក្រោមអំណាចរបស់ព្រះអង្គដ៏មានឫទ្ធានុភាពសព្វប្រការ និងជាព្រះដ៏វិសុទ្ធបំផុត ហើយក៏សុខចិត្តចុះចូលនឹងអស់លោកដែលគ្រប់គ្រង និងដឹកនាំយើងខ្ញុំនៅលើផែនដីដែរ ។ បពិត្រព្រះអម្ចាស់! គឺព្រះអង្គហើយដែលប្រទានឲ្យអស់លោកអាចប្រើអំណាចរបស់ខ្លួន ព្រះអង្គមានឫទ្ធានុភាពដ៏រុងរឿងរកថ្លែងពុំបាន ។ យើងខ្ញុំដឹងថា ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសឲ្យលោកទាំងនោះដូចយើងខ្ញុំឃើញសព្វថ្ងៃ ហេតុដូច្នេះហើយបានជាយើងខ្ញុំសូមចុះចូលក្រោមអំណាចអស់លោក ហើយក៏មិនប្រព្រឹត្តអ្វីផ្ទុយនឹងព្រះហឫទ័យព្រះអង្គដែរ ។ សូមព្រះអង្គប្រទានឲ្យអស់លោកបានសុខភាពល្អ សេចក្តីសុខសាន្ត សន្តិភាពនឹងនក្នុងមុខតំណែងរបស់អស់លោក ដើម្បីឲ្យអស់លោកគ្រងរាជ្យតាមអំណាចព្រះអង្គប្រោសប្រទានឲ្យអស់លោក ។*

*លោកក្លេម៉ង់ ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម*
*លិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងកូរិនថូស ៦០-៦១*

Layout Histor.qxd 2/10/07 10:09 AM Page 29

## ⑭ លោកទែរទូលីយ៉ាំងរៀបរាប់អំពីព្រះសហគមន៍ឱ្យអ្នករាជការដឹង

លោក**ទែរទូលីយ៉ាំង** (ប្រ.គ.ស. ១៥៥-២២២) កើតនៅក្រុងកាតាស្ស (ក្រុងទូនិស្សសព្វថ្ងៃ) ។ លោកយកទេពកោសល្យជាមេធាវីទៅបម្រើព្រះសហគមន៍ ។ គាត់ជឿលើព្រះគ្រីស្តដោយឃើញគ្រីស្តបរិស័ទមានសេចក្តីរឹងប៉ឹង និងមានសេចក្តីក្លាហានយ៉ាងអស្ចារ្យ ។ លោកនិពន្ធអំពីគ្រីស្តសាសនាច្រើនជាងគេនៅជំនាន់បុរាណនោះ ។ ប៉ុន្តែ ពេលលោកសរសេរការពារគ្រីស្តសាសនា លោកប្រឆាំងនឹងអ្នករិះគន់ខ្លាំងហួស ។

*យើងទើបកើតមក តែយើងនៅគ្រប់ទីកន្លែងនៅលើផែនដី និងកាន់មុខងារទាំងអស់របស់អស់លោករួចទៅហើយ គឺយើងនៅគ្រប់ទីក្រុង កោះ បន្ទាយ សង្កាត់ ភូមិ សូម្បីតែនៅជំរំទាហាន ទីបាត់ការយោធា ព្រះរាជវាំង ព្រឹទ្ធសភា ទីផ្សារ ក៏យើងនៅដែរ ។ យើងទុកតែវិហារទាំងប៉ុន្មានរបស់អស់លោកឲ្យអស់លោកនៅម្នាក់ឯងប៉ុណ្ណោះ ។*

*(...) ឥឡូវនេះ ដល់ពេលឲ្យខ្លួនខ្ញុំផ្ទាល់រៀបរាប់អំពីកិច្ចការរបស់ «គណៈគ្រីស្តបរិស័ទ» ឲ្យអស់លោកជ្រាប ។ មុនដំបូងខ្ញុំនឹងបង្ហាញឲ្យអស់លោកដឹងថា កិច្ចការគណៈគ្រីស្តបរិស័ទនេះមិនអាក្រក់ទេ រួចខ្ញុំនឹងបង្ហាញថា កិច្ចការទាំងនោះល្អវិញ ។ ខ្ញុំនឹងប្រាប់តាមសេចក្តីពិត ។ យើងទាំងអស់ជា «រូបកាយ» តែមួយ ព្រោះយើងមានជំនឿតែមួយ វិន័យតែមួយ ហើយក៏មានសេចក្តីសង្ឃឹមតែមួយដូចគ្នាដែរ ។ យើងរួមគ្នាជាបក្សសម្ពន្ធមួយ ជាក្រុមគ្រួសារមួយ យកពាក្យអធិដ្ឋានរបស់យើងមកឡោមព័ទ្ធព្រះជាម្ចាស់ ដូចកងទ័ពដ៏មានកម្លាំង ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងហឹង្សាបែបនេះ ។ យើងក៏អធិដ្ឋានសម្រាប់ព្រះចៅអធិរាជ មន្ត្រីរាជការ អ្នកកាន់អំណាច សម្រាប់មនុស្សលោក ឲ្យប្រកបដោយសន្តិភាព កុំឲ្យវិនាសឡើយ ។*

*(...) មនុស្សជាច្រើនមើលងាយយើង ជាពិសេសមកពីយើងមានមេត្តាករុណា ។ គេធ្លាប់និយាយថា «មើលន៎! គ្រីស្តបរិស័ទស្រឡាញ់គ្នាទៅវិញទៅមកយ៉ាងខ្លាំងណាស់» មកពីពួកគេតែងតែស្អប់គ្នា ។ ពួកគេនិយាយទៀតថា «មើលន៎! គ្រីស្តបរិស័ទសុខចិត្តស្លាប់ ដើម្បីជួយគ្នាទៅវិញទៅមក» មកពីគេតែងតែសម្លាប់គ្នាវិញ ។ រីឯរបៀបយើងហៅគ្នាថា «បងប្អូន» គឺពិតជាបងប្អូននឹងគ្នាមែន ខ្ញុំជឿថា ក្នុងចំណោមពួកគេ គេតែងហៅគ្នា «បងប្អូន» ដែរ តែគេមានសេចក្តីស្រឡាញ់ក្លែងក្លាយប៉ុណ្ណោះ ។ តាមច្បាប់និងតាមធម្មជាតិ យើងក៏ជាបងប្អូនអស់លោកដែរ តាមពិតអស់លោកមិនសូវមានលក្ខណៈជាមនុស្សទេ ព្រោះអស់លោកជាបងប្អូនដ៏អាក្រក់ ។ យើងហៅគ្នាថា "បងប្អូន" ពិតជាត្រឹមត្រូវ ព្រោះយើងរាប់អស់អ្នកដែលទទួលស្គាល់ព្រះជាម្ចាស់តែមួយព្រះអង្គទុកជាព្រះបិតា និងអស់អ្នកដែលទទួលព្រះវិញ្ញាណតែមួយព្រះអង្គ ដែលប្រោសមនុស្សឲ្យបានវិសុទ្ធ ព្រមទាំងអស់អ្នកដែលចេញពីភាពល្ងង់មកឃើញពន្លឺដ៏អស្ចារ្យនៃសេចក្តីពិតថា ពិតជាបងប្អូនមែន ។*

*(...) យើងរស់នៅជាមួយអស់លោក ហូបអាហារដូចអស់លោក ស្លៀកពាក់ដូចអស់លោក ហើយរស់នៅតាមបែបបទដូចអស់លោក និងមានសេចក្តីត្រូវការសម្រាប់រស់នៅដូចអស់លោកដែរ ។ យើងមិនមែនជាព្រាហ្មណ៍ទេ យើងក៏មិនមែនជាតាបសឥសីរស់នៅក្នុងព្រៃនៅប្រទេសឥណ្ឌាដែរ យើងក៏មិនមែនត្រូវគេដេញឆ្ងាយពីការរស់នៅរបស់មនុស្សឡើយ (...) ។ យើងតែងតែចូលកន្លែងដែលអស់លោកជួបជុំគ្នា ចូលផ្សារអស់លោក ចូលកន្លែងអស់លោកងូតទឹក ហាងលក់ទំនិញ អាហារដ្ឋាន និងផ្ទះសំណាក់ ចូលផ្សារណាត់ ហើយក៏ចូលកន្លែងពាណិជ្ជកម្មផ្សេងៗទៀតដែរ ។ យើងរស់នៅក្នុងពិភពលោកនេះរួមជាមួយអស់លោក ។ យើងក៏ធ្វើដំណើរតាមផ្លូវទឹក ធ្វើទាហានបម្រើកងទ័ព ធ្វើស្រែបង្កបង្កើតផល ហើយយើងក៏ធ្វើជំនួញដែរ (...) ។*

*លោកទែរទូលីយ៉ាំង "សេចក្តីការពារ" ជំពូក ៣៧, ៣៩ និង ៤២*



ទាហានរ៉ូម៉ាំង

## ⑮ គ្រីស្តបរិស័ទមិនអាចធ្វើទាហានបានទេ

លោក**ទែរទូលីយ៉ាំង**ហាមគ្រីស្តបរិស័ទដែលធ្វើទាហាន ពាក់កម្រងផ្កាក្នុងពិធីបុណ្យតាមសាសនាផ្សេងៗ ។ តាមយោបល់លោក គ្រីស្តបរិស័ទមិនអាចបម្រើកងទ័ពបានឡើយ ។

*(...) ព្រះអម្ចាស់មានព្រះបន្ទូលថា នរណាយកដាវមកកាប់គេ អ្នកនោះនឹងត្រូវគេសម្លាប់ដោយមុខដាវ ។ ដូច្នេះ តើគ្រីស្តបរិស័ទមានសិទ្ធិប្រកបអាជីវកម្មធ្វើទាហានកាន់ដាវឬទេ? គ្រីស្តបរិស័ទជាបុត្រនៃសេចក្តីសុខសាន្ត សូម្បីតែឈ្លោះគ្នាក៏គ្មានសិទ្ធិដែរ តើគេមានសិទ្ធិចេញទៅច្បាំងបានឬទេ? ។ គេមិនបេះសងសឹកនឹងអ្នកជេរប្រមាថខ្លួន តើគេមានសិទ្ធិដាក់ច្រវាក់ខ្នោះ ដាក់អ្នកទោសក្នុងគុក ធ្វើទារុណកម្ម ឬសម្លាប់មនុស្សបានឬទេ? (...) តើគេមានសិទ្ធិយាមនៅមុខវិហារព្រះក្លែងក្លាយ ដែលគេបានបោះបង់បោលរួចហើយបានឬទេ? តើគេមានសិទ្ធិបរិភោគបាយ នៅកន្លែងដែលគ្រីស្តទូត**ប៉ូល**ហាមឃាត់ឬទេ? គេបានបណ្តេញពួកមារនៅក្នុងពិធីដេញមារ តើឥឡូវនេះ គេត្រូវការពារពួកមារពេលយប់ ដោយកាន់លំពែង ដែលទាហានចាក់ព្រះយេស៊ូត្រង់ឆ្អឹងជំនីរបានឬទេ? តើគេមានសិទ្ធិកាន់ទង់ជ័យរបស់មារ ដែលប្រឆាំងនឹងព្រះគ្រីស្តបានឬទេ?*

*លោកទែរទូលីយ៉ាំង "កម្រងផ្ការបស់ទាហាន" (ប្រ.គ.ស. ២១០)*

## ⑯ អាជីវកម្មដែលព្រះសហគមន៍ហាមមិនឱ្យធ្វើ

លោក**អ៊ីប៉ូលីត**ជាបូជាចារ្យនៅក្រុងរ៉ូម លោករស់នៅដើមសតវត្សទី ៣ ។ លោកនិពន្ធសៀវភៅមួយក្រោមចំណងជើងថា «*សេចក្តីប្រៀនប្រដៅទទួលតៗពីក្រុមគ្រីស្តទូតមក*» ។ ក្នុងសៀវភៅនោះ លោកសរសេរពាក្យអធិដ្ឋានគំរូសម្រាប់ធ្វើពិធីបុណ្យ លោកក៏បញ្ជាក់លក្ខ័ណ្ឌដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក និងទទួលមុខងារបម្រើព្រះសហគមន៍ ។ល ។

*(...) អ្នកដែលជាបូជាចារ្យព្រះក្លែងក្លាយ អ្នកយាមរូបព្រះក្លែងក្លាយត្រូវឈប់ធ្វើការនោះ ឬត្រូវបណ្តេញគេចេញពីក្រុមអ្នកទទួលការអប់រំជំនឿ ។*

*ទាហានថ្នាក់ក្រោមមិនត្រូវសម្លាប់មនុស្សណាឡើយ ។ ប្រសិនបើគេទទួលបញ្ជាឲ្យសម្លាប់មនុស្ស មិនត្រូវប្រតិបត្តិតាមបញ្ជានោះជាដាច់ខាត គេក៏មិនត្រូវស្បថបម្រើព្រះចៅអធិរាជដែរ ។ បើគេមិនព្រមតាមសេចក្តីនេះត្រូវបណ្តេញគេចេញពីក្រុមអ្នកទទួលការអប់រំជំនឿ ។ អ្នកកាន់អំណាចដែលសម្លាប់ជីវិតមនុស្ស អ្នកធ្វើអភិបាលក្រុង ត្រូវលាលែងមុខតំណែងខ្លួន ឬត្រូវបណ្តេញគេចេញពីក្រុមអ្នកទទួលការអប់រំជំនឿដែរ ។ ត្រូវបណ្តេញអ្នកទទួលការអប់រំជំនឿ ឬគ្រីស្តបរិស័ទដែលចង់ធ្វើទាហាន ដ្បិតគេមើលងាយព្រះជាម្ចាស់រួចហើយ ។*

*លោកអ៊ីប៉ូលីត "សេចក្តីប្រៀនប្រដៅទទួលតៗពីក្រុមគ្រីស្តទូតមក"*

Layout Histor.qxd 2/10/07 10:09 AM Page 31

# ខ_ ព្រះចៅអធិរាជធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ

អ្នកនិពន្ធការពារគ្រីស្តសាសនា មិនបានជ័យជម្នះក្នុងការណែនាំអ្នកប្រឆាំងគ្រីស្តសាសនាឲ្យទុកចិត្តលើគ្រីស្តបរិស័ទឡើយ ។ ពេលរដ្ឋអំណាចស្វែងរកមូលហេតុបណ្តាលឲ្យអ្នកក្រុង ឬសង្គមទាំងមូលជួបទុក្ខលំបាកផ្សេងៗ គេនាំគ្នាចោទលើគ្រីស្តបរិស័ទ (ឧប. សង្គ្រាម ជំងឺអាសន្នរោគ អគ្គិភ័យ ។ល ។) ប្រជាជនតែងតែខឹងបះបោរប្រឆាំងនឹងគេ ។ នៅពេលនោះ រដ្ឋអំណាចកាត់ក្តីផ្តន្ទាទោសគ្រីស្តបរិស័ទ ដើម្បីឲ្យប្រជាជនស្ងប់ស្ងៀម ។ នេះជាមូលហេតុ ដែលបណ្តាលឲ្យរដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ ។

## ១- ទុក្ខបុកម្នេញ និង មរណសាក្សី

### *ក- « ការធ្វើទុក្ខបុកម្នេញ » មានអត្ថន័យជាច្រើន*

អស់រយៈពេលបីសតវត្សខាងដើមដំបូងនៃ គ.ស. រដ្ឋអំណាចមិនធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទឥតឈប់ឈរនោះទេ ហើយក៏មិនធ្វើទុក្ខបុកម្នេញគេនៅគ្រប់កន្លែងដែរ ។ ឧប. ព្រះចៅ**ណេរ៉ុង**គ្រាន់តែធ្វើទុក្ខបុកម្នេញលើគ្រីស្តបរិស័ទនៅក្នុងក្រុងរ៉ូមប៉ុណ្ណោះ រីឯព្រះចៅ**ឌីយ៉ូក្លេស៊ីយ៉ាំង** (Dioclétien) ធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទពាសពេញចក្រភពរ៉ូម៉ាំងវិញ ។ យើងអាចសន្និដ្ឋានថា ក្នុងរយៈពេលបីសតវត្សដើមដំបូងនៃ គ.ស. គ្រីស្តបរិស័ទកន្លែងខ្លះរស់នៅដោយគ្មានសុវត្ថិភាព ប៉ុន្តែ នៅកន្លែងជាច្រើនក៏មានគ្រីស្តបរិស័ទរស់នៅយ៉ាងសុខសាន្ត អស់រយៈពេលជាយូរអង្វែងផងដែរ ។

### *ខ- អ្វីទៅ « មរណសាក្សី »?*

ពាក្យ «មរណសាក្សី» សំដៅទៅលើគ្រីស្តបរិស័ទដែលសុខចិត្តស្លាប់ព្រោះជំនឿរបស់ខ្លួន គឺគេធ្វើសាក្សីអំពីជំនឿលើព្រះយេស៊ូថា ជាព្រះអម្ចាស់តែមួយអង្គគត់ គ្មានព្រះអម្ចាស់ផ្សេងទៀតទេ ព្រះចៅអធិរាជក៏មិនមែនជាព្រះអម្ចាស់ដូចព្រះយេស៊ូឡើយ ។ គ្រីស្តបរិស័ទមិនចង់ឲ្យគេធ្វើទុក្ខបុកម្នេញដល់ខ្លួនទេ ប៉ុន្តែពេលរដ្ឋអំណាចតាមចាប់ គេសុខចិត្តធ្វើជាសាក្សីអំពីជំនឿរបស់ខ្លួនរហូតដល់បូជាជីវិត ដូចព្រះយេស៊ូរងទុក្ខលំបាករហូតដល់សោយទិវង្គតដែរ ។ ពេលនោះ មរណសាក្សីដូចព្រះយេស៊ូបេះបិទ ដោយសង្ឃឹមថា នឹងទទួលជីវិតដ៏ពេញលេញនៅស្ថានបរមសុខ រួមជាមួយព្រះអម្ចាស់របស់ខ្លួនដែរ ។

### *គ- ឯកសាររៀបរាប់អំពីរដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ* 17

ឯកសារជាច្រើនរៀបរាប់អំពីរដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទគឺ៖

- មានអ្នកនិពន្ធប្រវត្តិសាស្ត្រដែលមិនមែនជាគ្រីស្តបរិស័ទចែងក្នុងសៀវភៅរបស់គេ ដូចលោក**តាស៊ីត** (Tacite) ជាជនជាតិរ៉ូម៉ាំង (ប្រ.គ.ស. ៥៥-១២០) ឬលោក**ព្លីន** (Pline) ជាជនជាតិរ៉ូម៉ាំងដែរ (គ.ស. ៦២-១១៤) ។
- មានសេចក្តីកត់ត្រានៅពេលរដ្ឋអំណាចកាត់ក្តីដាក់ទោសគេ ។
- មានឯកសារខ្លះហៅថា «*កិច្ចការរបស់មរណសាក្សី*» ឧប. ការផ្តន្ទាទោសលោក**ស៊ីព្រីយ៉ាំង** (Cyprien) ជាអភិបាលព្រះសហគមន៍ក្រុងកាតាស្ស (ទីក្រុងទុយនិស្សសព្វថ្ងៃ) ។ អ្នកខ្លះឃើញផ្ទាល់នឹងភ្នែក ហើយកត់ត្រាទុកព្រឹត្តិការណ៍ដែលគេឃើញនោះ ។ ឧប. រឿងមរណសាក្សីនៅក្រុងលីយ៉ុង (គ.ស ១៧៧) ។ គួរឲ្យជឿទុកចិត្តលើឯកសារទាំងនោះ ។ ក្រោយពេលព្រះចៅ**កុងស្តង់តាំង** ប្រោសប្រទានសន្តិភាពដល់ព្រះសហគមន៍ (គ.ស. ៣១៣) គ្រីស្តបរិស័ទលើកតម្កើងមរណសាក្សីខ្លាំងណាស់ ហើយព្រះសហគមន៍ជាច្រើនកន្លែងយកមរណសាក្សីធ្វើជាសន្តបុគ្គល ជួយថែរក្សាការពារខ្លួន ។ ពេលនោះ គេប្រឌិតរឿងជាច្រើនមិនសូវពិតប្រាកដទេ ។

Layout Histor.qxd 2/10/07 10:09 AM Page 32

## (17) ក្នុងរជ្ជកាលព្រះចៅអធិរាជណេរ៉ុង (គ.ស. ៦៤)

ព្រះចៅអធិរាជ**ណេរ៉ុង**ដុតសង្កាត់ខ្លះនៃក្រុងរ៉ូម ជាសង្កាត់សុទ្ធតែអ្នកក្រីក្ររស់នៅ ។ រួចទ្រង់ចោទគ្រីស្តបរិស័ទជាអ្នកដុត ។ លោក**តាស៊ីត**ជាជនជាតិរ៉ូម៉ាំង (ប្រ.គ.ស. ៥៥-១២០) និងជាអ្នកនិពន្ធប្រវត្តិសាស្ត្រចក្រភពរ៉ូម៉ាំង ។ អត្ថបទខាងក្រោមនេះ បញ្ជាក់សេចក្តីខ្លះអំពីព្រះគ្រីស្ត ។ ទោះបីលោកពុំមែនជាគ្រីស្តបរិស័ទក្តី ក៏លោកអាណិតគ្រីស្តបរិស័ទដែលរងទុក្ខដោយអយុត្តិធម៌ ។

*ពាក្យចចាមអារាមចោទព្រះចៅណេរ៉ុងថា ទ្រង់បញ្ជាឲ្យគេដុតទីក្រុងរ៉ូមនោះចេះតែលាន់ឮខ្លាំងឡើងៗ ទោះបីទ្រង់ប្រើគ្រប់មធ្យោបាយឲ្យស្ងប់ស្ងៀមក៏ដោយ ដូចជាចែកទាន និងធ្វើពិធីបុណ្យសុំលាងទោសជាដើម ។ ទ្រង់ចោទអ្នកដែលប្រជាជនស្អប់ថា ជាអ្នកប្រព្រឹត្តការអាក្រក់គួរឲ្យខ្ពើម គឺពួកដែលគេហៅថា «គ្រីស្តបរិស័ទ» ។ ឈ្មោះ «គ្រីស្តបរិស័ទ»នេះមកពីពាក្យ«ព្រះគ្រីស្ត»ដែលទេសាភិបាល**ប៉ុនពីឡាត**បញ្ជូនទៅធ្វើទារុណកម្មក្នុងរជ្ជកាលព្រះចៅ**ទីប៊ែរ** ។ ពួកគេខិតខំបំបាត់អប្បិយជំនឿគួរស្អប់ខ្ពើមនេះ តែវាលេចឡើងវិញ មិនគ្រាន់តែនៅស្រុកយូដា ជាកន្លែងអប្បិយជំនឿដ៏អាក្រក់នេះកើតឡើងប៉ុណ្ណោះទេ គឺលេចមករហូតដល់ទីក្រុងរ៉ូម ជាកន្លែងដែលមានមនុស្សមកពីគ្រប់ទីកន្លែងនៅលើពិភពលោកទាំងមូលចូលមករស់នៅ និងមានអ្នកកាន់តាមជាច្រើនដែរ ។ ទ្រង់ចោទគេដូច្នេះ ដើម្បីធ្វើឲ្យពាក្យចចាមអារាម ចោទព្រះអង្គបានស្ងប់ស្ងៀម ។ រដ្ឋអំណាចផ្តើមចាប់ចងអ្នកដែលប្រកាសជំនឿរបស់ខ្លួន ។ បន្ទាប់មក រដ្ឋអំណាចចាប់គេជាច្រើនអនេក តាមពួកអ្នកដែលគេចាប់លើកមុនឲ្យឈ្មោះ ។ រដ្ឋអំណាចចោទគេមិនត្រឹមថា បានដុតក្រុងរ៉ូមប៉ុណ្ណោះទេ គឺចោទពួកគេថា ជាអ្នកស្អប់មនុស្សជាតិទាំងមូល និងទុកជាសត្រូវទៀតផង ។ រដ្ឋអំណាចមិនសម្លាប់គេភ្លាមទេ គឺបំពាក់ពួកគេដោយស្បែកសត្វដើម្បីឲ្យឆ្កែហែកស៊ី ។ ជួនកាល រដ្ឋអំណាចចងភ្ជាប់ពួកគេនឹងឈើឆ្កាង ឬលាបគេដោយជ័រងាយឆេះ ដុតពួកគេសម្រាប់បំភ្លឺពេលយប់ដូចចន្លុះ ។ ព្រះចៅណេរ៉ុង ប្រោសប្រទានសួនឧទ្យានរបស់ព្រះអង្គឲ្យប្រជាជនអាចមកមើលបាន ។ ទ្រង់ចាត់ចែងល្បែងក្នុងពហុកីឡាដ្ឋាន ជួនកាលទ្រង់លាយឡំ នឹងប្រជាជនដោយស្លៀកពាក់ជាអ្នកបររទេះសេះ ជួនកាលទ្រង់រត់ប្រណាំងទាំងឈរនៅលើរទេះរបស់ព្រះអង្គ ។ ថ្វីបើអ្នកទាំងនោះត្រូវមានទោស ក៏ប្រជាជនជាច្រើនអាណិតអាសូរគេ ដ្បិតប្រជាជនតែងតែនិយាយថា រដ្ឋអំណាចសម្លាប់ពួកគេ មិនមែនដើម្បីប្រយោជន៍ទូទៅទេ គឺមកពីព្រះហឫទ័យដ៏សាហាវឃោរឃៅរបស់ព្រះចៅតែមួយព្រះអង្គប៉ុណ្ណោះ ។*

*លោកតាស៊ីត "របាក្សត្រ" ១៥,៤៤ (បោះពុម្ព ប្រ.នៅ គ.ស. ១១៥)*



*«ខ្ញុំឃើញកូនចៀមមួយឈរ...ដូចជាគេកាត់ករួចហើយ» (វវ ៥,៦)*




*ព្រះឆាយាលក្ខណ៍ ព្រះចៅអធិរាជណេរ៉ុង*



*ពហុកីឡាដ្ឋានកូឡូសេអូ ជាកន្លែងព្រះចៅណេរ៉ុងឲ្យគេធ្វើទារុណកម្មដល់គ្រីស្តបរិស័ទជាច្រើននៅ គ.ស ៦៤*

## ២- រដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ នៅសតវត្សទី ១-២

នៅសតវត្សទីមួយនិងទីពីរ រដ្ឋអំណាចមិនធ្វើទុក្ខបុកម្នេញដល់គ្រីស្តបរិស័ទជាទូទៅទេ ហើយក៏គ្មានច្បាប់ចែងឲ្យច្បាស់លាស់អំពីគ្រីស្តបរិស័ទដែរ ។ គេធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទតាមកន្លែង និងក្នុងរយៈពេលដ៏ខ្លី ។

### *ក- ព្រះចៅណេរ៉ុងធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទមុនគេ*

លោក**តាស៊ីត** (Tacite) ជាអ្នកនិពន្ធខាងប្រវត្តិសាស្ត្រ កត់ត្រាទុកអំពីព្រះចៅអធិរាជ**ណេរ៉ុង**ធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ ។ នៅគ.ស. ៦៤ មានអគ្គិភ័យនៅក្រុងរ៉ូម ។ តែគ្រីស្តបរិស័ទសរសេរអំពីរឿងនេះមិនច្បាស់ទេ ។ លោកតាស៊ីតទទួលស្គាល់ថា គ្រីស្តបរិស័ទមានឈ្មោះល្បីអាក្រក់គួរស្អប់ខ្ពើម ប៉ុន្តែលោកមិនជឿថាគ្រីស្តបរិស័ទជាអ្នកដុតទីក្រុងទេ ។ ព្រះចៅណេរ៉ុង ដាក់ទោសគ្រីស្តបរិស័ទតាមច្បាប់ផ្តន្ទាទោសអ្នកដុតផ្ទះ ។ ប៉ុន្តែ ព្រះចៅមិនធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទដែលរស់នៅក្រៅក្រុងរ៉ូមទេ ។ គ្រីស្តបរិស័ទតែងនិទានតៗគ្នាថា ព្រះចៅណេរ៉ុងសម្លាប់លោក**សិលា** និងលោក**ប៉ូល** ។

### *ខ- ក្នុងរជ្ជកាលព្រះចៅត្រាយ៉ាណូ* (*Trajan ៩៨-១១៧*)

លោក**ព្លីន**ជាទេសាភិបាលស្រុកប៊ីធីនី (ផ្នែកខាងជើងប្រទេសទួរគីសព្វថ្ងៃ) លោកផ្ញើលិខិតថ្វាយព្រះចៅ**ត្រាយ៉ាណូ**ផ្តល់ព័ត៌មានថា ក្នុងស្រុកលោកត្រួតត្រានោះ រដ្ឋអំណាចតែងតែចាប់ចងគ្រីស្តបរិស័ទនិងប្រហារជីវិតគេ ។ លោកមិនសូវពេញចិត្តនឹងគ្រីស្តបរិស័ទទេ ប៉ុន្តែ លោកសង្កេតឃើញថា គ្រីស្តបរិស័ទមិនធ្វើអ្វីខុសឡើយ ។ ដូច្នេះលោកត្រូវប្រព្រឹត្តយ៉ាងណា? តើលោកផ្តន្ទាទោសគេ ព្រោះពួកគេមានឈ្មោះថា ជាគ្រីស្តបរិស័ទឬយ៉ាងណា? ឬមួយចៅក្រមត្រូវរកភស្តុតាងបោទថា ពួកគេពិតជាបានប្រព្រឹត្តអំពើឧក្រិដ្ឋ ឬយ៉ាងណា? ព្រះចៅ ត្រាយ៉ាណូសរសេរព្រះរាជចុតហ្មាយតបឆ្លើយថា «*យើងមិនអាចបង្កើតច្បាប់ជាទូទៅដែលមិនអាចប្រែប្រួលបាននៅពេលក្រោយឡើយ*» គឺមិនត្រូវដេញចាប់ចងគ្រីស្តបរិស័ទទេ ហើយក៏មិនត្រូវយល់ស្របតាមអ្នកបោទបែបអនាមិកដែរ ។ ប៉ុន្តែ ត្រូវផ្តន្ទាទោសដល់អស់អ្នកដែលនៅតែប្រកាសថា ខ្លួនជាគ្រីស្តបរិស័ទ ។ (18)

លិខិតលោកព្លីនសបញ្ជាក់ឲ្យដឹងថា ទេសាភិបាលមិនដឹងជាប្រព្រឹត្តយ៉ាងណាចំពោះពួកគ្រីស្តបរិស័ទឡើយ ។ ម្យ៉ាងទៀត លិខិតនេះក៏ផ្តល់ព័ត៌មានអំពីរបៀបដែលព្រះសហគមន៍ពីដើមរស់នៅ ។

លោក**អ៊ីញ៉ាស** (Ignace) ជាអភិបាលព្រះសហគមន៍ក្រុងអន់ទីយ៉ូក និងជាមរណសាក្សីដ៏មានឈ្មោះល្បីល្បាញម្នាក់ លោកសុខចិត្តបូជាជីវិតព្រោះព្រះគ្រីស្តក្នុងសម័យព្រះចៅអធិរាជត្រាយ៉ាណូ ។ លោកសរសេរលិខិតជាច្រើនផ្ញើជូនព្រះសហគមន៍នានា នៅពេលគេបញ្ជូនលោកទៅធ្វើទារុណកម្មនៅក្រុងរ៉ូម ។ ប៉ុន្តែគ្មាននរណាដឹងច្បាស់ថា លោកបូជាជីវិតតាមបែបណាទេ ។

Layout Histor.qxd 2/10/07 10:09 AM Page 34

## ⑱ លិខិតរបស់លោកព្លីន ថ្វាយព្រះចៅត្រាយ៉ាណូ

លោក**ព្លីន** (គ.ស. ៦១-១១៤) ជាមេធាវីនិងជាអ្នកនយោបាយពូកែថ្លែងសេចក្តី ។ ព្រះចៅ**ត្រាយ៉ាណូ**តែងតាំងលោកធ្វើរាជប្រតិភូនៅស្រុកប៊ីធីនី ។ លោកជាមនុស្សប្រកបដោយគុណធម៌ ហើយលោកក៏ជាអ្នកចេះដឹងខាងវប្បធម៌ដែរ ។ លោកសរសេរលិខិតថ្វាយព្រះចៅអធិរាជ**ត្រាយ៉ាណូ**ស្តីអំពីគ្រីស្តបរិស័ទ ។ សៀវភៅលោកក៏កត់ចម្លើយរបស់ព្រះចៅអធិរាជដែរ ។

(...) ទូលបង្គំមិនដែលចូលរួមក្នុងការកាត់ក្តីគ្រីស្តបរិស័ទទេ ហេតុនេះ បានជាទូលបង្គំមិនដឹងត្រូវដាក់ទោសគេអំពីបទឧក្រិដ្ឋណាទេ ។ ទូលបង្គំក៏មិនដឹងថា ត្រូវស៊ើបអង្កេតអំពីរឿងអ្វី និងត្រូវសួរចម្លើយដល់ណាដែរ (...) ។ តើត្រូវដាក់ទោសពួកគេ មកពីគេគ្រាន់តែមានឈ្មោះជាគ្រីស្តបរិស័ទ ប៉ុណ្ណោះ ទោះបីពួកគេមិនប្រព្រឹត្តបទឧក្រិដ្ឋក្តី ក៏ត្រូវផ្តន្ទាទោសគេដែរ ព្រោះបទឧក្រិដ្ឋតែងតែជាប់នឹងឈ្មោះនោះឬ? សូមថ្វាយព្រះករុណាអំពីគោលការណ៍ ដែលទូលបង្គំយកមកអនុវត្តបណ្តោះអាសន្នចំពោះអស់អ្នកដែលគេបញ្ជូនមកទូលបង្គំទាំងចោទថាពួកគេជាគ្រីស្តបរិស័ទ ។ ទូលបង្គំសួរពួកគេដោយខ្លួនទូលបង្គំផ្ទាល់ តើគេជាគ្រីស្តបរិស័ទពិតឬទេ? ចំពោះអស់អ្នកដែលសារភាពថាពិតជាគ្រីស្តបរិស័ទមែននោះ ទូលបង្គំសួរម្តងទៀត ហើយសួរម្តងទៀតជាបីដង ទាំងគំរាមកំហែងថានឹងផ្តន្ទាទោសពួកគេ ។ ទូលបង្គំប្រហារជីវិតអស់អ្នកដែលនៅតែប្រកាសថាខ្លួនគឺជាគ្រីស្តបរិស័ទ ទោះបីការទទួលសារភាពរបស់គេមានអត្ថន័យយ៉ាងណាក្តី ក៏ទូលបង្គំយល់ឃើញច្បាស់ថា គេត្រូវតែទទួលទោស ព្រោះគេមានចិត្តចចេសរឹងរូសមិនព្រមផ្លាស់ប្តូរសោះ ។ អ្នកជឿស៊ប់នឹងជំនឿលេលានេះ ខ្លះជាប្រជាពលរដ្ឋរ៉ូម៉ាំង ទូលបង្គំក៏កត់ឈ្មោះគេដើម្បីបញ្ជូនទៅក្រុងរ៉ូម (...) ។

អ្នកខ្លះបដិសេធថា ខ្លួនមិនមែនជាគ្រីស្តបរិស័ទទេ ហើយក៏មិនដែលជាគ្រីស្តបរិស័ទដែរ ។ ក្រោយពីពួកគេអង្វរព្រះទាំងឡាយតាមទូលបង្គំ ពួកគេដុតធូបនិងថ្វាយស្រា បន់ស្រន់ដល់រូបបដិមាព្រះអង្គ ទាំងជេរប្រមាថព្រះគ្រីស្តនោះ ទូលបង្គំដោះលែងគេ ព្រោះទូលបង្គំឮពួកគេនិយាយថា គ្មាននរណាអាចបង្ខំគ្រីស្តបរិស័ទដ៏ពិតប្រាកដ ឲ្យប្រព្រឹត្តការទាំងនេះបានទេ ។

អ្នកខ្លះទៀតបញ្ជាក់ថា គេលែងជាគ្រីស្តបរិស័ទហើយ អ្នកខ្លះថា គេលែងជាគ្រីស្តបរិស័ទតាំងពីបីឆ្នាំ អ្នកខ្លះថាតាំងពីច្រើនឆ្នាំ អ្នកខ្លះថាតាំងពីម្ភៃឆ្នាំមកម្ល៉េះ ។ អ្នកទាំងនោះក៏បានគោរពបដិមារបស់ព្រះចៅអធិរាជ គោរពថ្វាយបង្គំបដិមាព្រះទាំងឡាយ ហើយក៏ជេរប្រមាថព្រះគ្រីស្តដែរ ។

ម្យ៉ាងទៀត ពួកគេប្រកាសថាគ្មានកំហុសទេ គឺពួកគេគ្រាន់តែជួបជុំគ្នាតាមថ្ងៃកំណត់មុនថ្ងៃរះ ដើម្បីច្រៀងឆ្លើយឆ្លងគ្នា គឺច្រៀងបទថ្វាយព្រះគ្រីស្តជាព្រះមួយអង្គ ហើយគេស្បថថា មិនប្រព្រឹត្តបទឧក្រិដ្ឋណាមួយ គឺមិនលួចប្លន់ មិនជិតក្បត់ចិត្តស្វាមីភរិយា ឬក្បត់ពាក្យសន្យា មិនប្រកែក សុខចិត្តសងប្រាក់ដែលអ្នកដទៃផ្ញើទុក ។ ក្រោយមក ពួកគេបែកចេញពីគ្នា និងជួបជុំគ្នាវិញដើម្បីពិសាអាហារជាអាហារធម្មតា គ្មានរឿងអ្វីអាក្រក់ទេ ។ ប៉ុន្តែ បន្ទាប់ពីទូលបង្គំហាមឃាត់មិនឲ្យគេជួបជុំគ្នាតាមព្រះបញ្ជារបស់ព្រះអង្គ ពិធីនេះគេលែងប្រារព្ធទៀតហើយ ។ ទូលបង្គំយល់ឃើញថា ត្រូវស្វែងរកសេចក្តីពិតជាចាំបាច់អំពីពួកគេ ទូលបង្គំបានធ្វើទារុណកម្មទៅលើទាសករពីរនាក់ ដែលគេតែងហៅថា ឧបដ្ឋាការិនី ដើម្បីស្វែងរកសេចក្តីពិត ។ ទូលបង្គំរកឃើញថា គ្មានអ្វីក្រៅពីអបិយជំនឿម៉្យាងនោះ ដែលទាស់នឹងប្រាជ្ញាមនុស្សហួសហេតុប៉ុណ្ណោះ ។

ហេតុនេះ ទូលបង្គំផ្អាកស៊ើបសួរ ដើម្បីមកសួរយោបល់របស់ព្រះអង្គ ។ តាមយោបល់ទូលបង្គំគួរប្រព្រឹត្តដូច្នេះ ព្រោះមនុស្សជាច្រើនជាប់ទោសបែបនេះ ។ មានមហាជនគ្រប់អាយុគ្រប់ឋានៈទាំងពីរភេទ ត្រូវក្រសួងយុត្តិធម៌កោះហៅរួចហើយ ឬត្រូវកោះហៅពេលខាងមុខទៀត ។ សាសនានេះប្រៀបដូចជាជំងឺរាតត្បាត មិនគ្រាន់តែនៅទីក្រុងប៉ុណ្ណោះទេ គឺសូម្បីតែក្នុងភូមិនៅជនបទក៏ជំងឺនេះលុកលុយទៅដល់ដែរ ។ ទូលបង្គំជឿថា យើងអាចបញ្ឈប់ពួកគេ និងព្យាបាលជំងឺនេះបាន ។ ដូច្នេះ ទូលបង្គំឃើញយល់ថា ប្រជាជនដែលបោះបង់ចោលវិហារយើងរួចហើយ ឥឡូវនេះ ពួកគេនាំគ្នាចូលវិហារវិញ (...) ។

លោកព្លីន លិខិត ១០,៩៦

### *គ- រជ្ជកាលព្រះចៅម៉ាក់-អូរ៉ែល (១៦១-១៨០)*

ព្រះចៅ**ម៉ាក់-អូរ៉ែល** (Marc-Aurèle) ជាទស្សនវិទូមួយរូប ។ ក្នុងរជ្ជកាលរបស់ព្រះចៅអង្គនេះ រដ្ឋអំណាចដាក់ទោសប្រហារជីវិតលោក**យូស្ទាំង** (Justin) ជាអ្នកនិពន្ធសៀវភៅការពារគ្រីស្តសាសនា និងប្រហារជីវិតលោក**ប៉ូលីកាប** (Poly carpe) ជាអភិបាលព្រះសហគមន៍ក្រុងស្មៀរណា ជាសាវ័ករបស់លោក**យ៉ូហាន** ។ នៅពេលគ្រីស្តបរិស័ទរៀបរាប់អំពីរដ្ឋអំណាចប្រហារជីវិតលោកប៉ូលីកាប គេក៏ថែងអំពីការគោរពអដ្ឋិធាតុរបស់មរណសាក្សីជាលើកដំបូងដែរ ។ នៅថ្ងៃខួបមរណសាក្សីបូជាជីវិតព្រោះតែព្រះគ្រីស្ត គ្រីស្តបរិស័ទនាំគ្នាជួបជុំ ហើយនឹករឭកអំពីមរណភាពរបស់អ្នករងទុក្ខលំបាក និងស្លាប់ទុកជា«*ថ្ងៃកំណើត*» ដ៏ពិតប្រាកដ
19 របស់គេ គឺគេមានជីវិតថ្មីនៅស្ថានបរមសុខ ។ លោក**អ៊ីរ៉ែសេប**ជាអភិបាលព្រះសហគមន៍ក្រុងសេសារេ ចម្លងលិខិតរបស់គ្រីស្តបរិស័ទក្រុងលីយ៉ុង (ប្រទេសបារាំងសព្វថ្ងៃ) ផ្ញើជូនបងប្អូនគ្រីស្តបរិស័ទនៅស្រុកអាស៊ី (ប្រទេសទួរគីសព្វថ្ងៃ) ស្តីអំពីរដ្ឋអំណាចធ្វើទារុណកម្ម ដល់គ្រីស្តបរិស័ទនៅ គ.ស. ១៧៧ ។ ពេលនោះប្រជាជនបះបោរ បណ្តាលឲ្យរដ្ឋអំណាចចាប់ចង និងប្រហារជីវិតគ្រីស្តបរិស័ទប្រមាណ ៥0 នាក់ ។ ក្នុងចំណោមអ្នកទាំងនោះ មានលោក**ប៉ូថាំង** (Pothin) អាយុកៅសិបឆ្នាំ និងជាអភិបាលព្រះសហគមន៍ មានលោក**សង្ទូស** (Sanctus) ជាឧបដ្ឋាករបស់លោក និងនាង**ប្លង់ឌីន** (Blandine) ជាទាសីដ៏ទន់ខ្សោយម្នាក់ដែលទទួលមរណភាពក្រោយគេបង្អស់ ។ លិខិតនេះ ជាឯកសារបុរាណជាងគេបញ្ជាក់ថា មានគ្រីស្តបរិស័ទនៅស្រុកហ្គោល (Gaule) (ប្រទេសបារាំងសព្វថ្ងៃ) ។

### *ឃ- តើរដ្ឋអំណាចធ្វើទារុណកម្មដល់គ្រីស្តបរិស័ទត្រូវតាមច្បាប់ណា?*

អ្នកស្រាវជ្រាវប្រវត្តិវិទ្យាមិនដឹងថា រដ្ឋអំណាចធ្វើទារុណកម្មគ្រីស្តបរិស័ទក្នុងកំឡុងពេលពីរសតវត្សដើមដំបូងនៃគ.ស. ដោយសំអាងលើច្បាប់ណាទេ ។ ក្នុងចក្រភពរ៉ូម៉ាំង មានច្បាប់អនុញ្ញាតឲ្យប្រជារាស្ត្រកាន់សាសនាខ្លះ តែសាសនាខ្លះទៀតមិនអនុញ្ញាតទេ ។ រដ្ឋអំណាចឲ្យជនជាតិយូដាមានសិទ្ធិកាន់សាសនារបស់ខ្លួនបាន *(សូមអាន «កំណើតនៃគម្ពីរសម្ពន្ធមេត្រីថ្មី» ទំព័រ ៧)* ។ រីឯគ្រីស្តសាសនាដែលបែកចេញពីសាសនាយូដា គេចាត់ទុកជាសាសនាដែលគ្មានច្បាប់អនុញ្ញាតទេវិញ ។ ប៉ុន្តែ ជនជាតិរ៉ូម៉ាំងមិនធ្លាប់ប្រកាន់សាសនាទេ ហើយនៅមុនសតវត្សទី ៣ នៃ គ.ស. រដ្ឋអំណាចក៏មិនបង្ខំប្រជារាស្ត្រទាំងអស់ក្នុងចក្រភពទាំងមូលឲ្យគោរពថ្វាយបង្គំព្រះចៅអធិរាជដែរ ។ ព្រះចៅអធិរាជ**ណេរ៉ុង**គ្មានចេញព្រះរាជក្រិត្យហាមគ្រីស្តបរិស័ទមិនឲ្យកាន់សាសនារបស់ខ្លួនទេ ។ រដ្ឋអំណាចបៀតបៀនធ្វើបាបគ្រីស្តបរិស័ទ តាមច្បាប់ចាត់ចែងប្រជាជនឲ្យមានរបៀបរៀបរយ តែទេសាភិបាលយកច្បាប់មកអនុវត្តតាមទំនើងចិត្តរបស់ខ្លួន ។ នៅពេលប្រជាជនបះបោរប្រឆាំងនឹងគ្រីស្តបរិស័ទ រដ្ឋអំណាចតែងដាក់ទោសពួកគេដោយចោទថាគ្រីស្តបរិស័ទដុតទីក្រុង គឺជាឃាតករ ។ល ។ នៅសម័យនោះគ្មានយុត្តិធម៌ទេ ។ ពេលរដ្ឋអំណាចផ្តន្ទាទោសគ្រីស្តបរិស័ទ ប្រជាជនធូរស្រាលក្នុងចិត្ត ។ ម្យ៉ាងទៀត រដ្ឋអំណាចចាប់ចងគ្រីស្តបរិស័ទ ធ្វើជាតួអង្គសម្រាប់លេងល្បែងនៅកីឡាដ្ឋានមានការប្រយុទ្ធជាមួយសត្វសាហាវជាដើម ។

## ៣- សតវត្សទី ៣ រដ្ឋអំណាចធ្វើទុក្ខបុកម្នេញដល់គ្រីស្តបរិស័ទ

នៅចុងសតវត្សទីពីរ ចាប់ផ្តើមកើតវិបត្តិធ្ងន់ធ្ងរក្នុងចក្រភពរ៉ូម៉ាំង គឺកើតសង្គ្រាមស៊ីវិល ខ្មាំងសត្រូវវាយលុកលុយតាមព្រំដែន ប្រាក់ចុះតម្លៃ ចំនួនប្រជាពលរដ្ឋចុះថយ ។ល ។ព្រះចៅអធិរាជមានព្រះរាជបំណងបំបាត់នូវមូលហេតុដែលបណ្តាលឲ្យប្រជាជនបែកបាក់គ្នា ហើយមានព្រះរាជបំណងរឹតចំណងមេត្រីភាពក្នុងចំណោមប្រជាពលរដ្ឋ ដោយបញ្ជាឲ្យប្រជាពលរដ្ឋគ្រប់ៗរូបគោរពថ្វាយបង្គំព្រះចៅអធិរាជទុកជាព្រះរបស់ខ្លួន ។ ទោះបីគ្រីស្តបរិស័ទតែងតែប្រកាសថា ខ្លួន

19

# មរណសាក្សីនៅក្រុងលីយ៉ុង (គ.ស. ១៧៧)

លោក**សន្ទូស**ឆ្លើយជាភាសាឡាតាំងចំពោះគ្រប់សំណួរថា៖ «ខ្ញុំជាគ្រីស្តបរិស័ទ» ។ លោកពោលតែពាក្យនេះប៉ុណ្ណោះ គឺមិនព្រមប្រាប់ឈ្មោះលោក ក្រុងលោករស់នៅ និងពូជពង្សរបស់លោកឡើយ ។ អ្នកធ្វើទារុណកម្មលោកមិនបានឮពាក្យអ្វីផ្សេងទៀតចេញពីមាត់លោកទាល់តែសោះ ។ (...)

នៅទីបញ្ចប់ ពួកគេយកបន្ទះដែកស្ពើងទៅដុតឲ្យឡើងក្រហមមកដាក់លើរាងកាយលោក ។ រាងកាយលោករលេះរលួយ ប៉ុន្តែ លោកនៅតែមានសេចក្ដីក្លាហាន មិនព្រមដូរចិត្តឡើយ គឺលោកនៅតែប្រកាសជំនឿតទៅទៀត ។ លោកដូចជាទទួលកម្លាំងពីទឹកដែលហូរចេញពីផ្ទៃជំនីរបស់ព្រះគ្រីស្តមកពីស្ថានបរមសុខដូចទឹកសន្សើម ។ រូបកាយលោកសុទ្ធតែស្នាមរបួសគ្រប់កន្លែង លែងមានលក្ខណៈជាមនុស្សទៀតហើយ ។ ព្រះគ្រីស្តកំពុងតែរងទុក្ខលំបាកនៅក្នុងខ្លួនលោក ហើយសម្ដែងការដ៏អស្ចារ្យប្រកបដោយសិរីរុងរឿង ព្រះអង្គកម្ទេចមារសត្រូវលែងឲ្យមានកម្លាំង ព្រះអង្គក៏សម្ដែងឲ្យគ្រីស្តបរិស័ទឯទៀតៗដឹងថា ទីណាមានព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា ទីនោះក៏គ្មានភ័យខ្លាចអ្វីឡើយ ទីណាមានសិរីរុងរឿងរបស់ព្រះគ្រីស្ត ទីនោះក៏គ្មានរងទុក្ខវេទនាដែរ (...) ។

លោក**ប៉ូថាំង**ទទួលមុខងារជាអភិបាលព្រះសហគមន៍ក្រុងលីយ៉ុង កាលលោកអាយុជាង ៩០ ឆ្នាំ ។ រូបកាយលោកទន់ខ្សោយ ដកដង្ហើមទាំងពិបាក ។ ប៉ុន្តែឫទ្ធានុភាពនៃព្រះវិញ្ញាណជួយកម្លាំងលោកដោយលោកមានបំណងប្តូរផ្តាច់ចង់បូជាជីវិតក្នុងឋានៈជាមរណសាក្សី ។ លោកត្រូវគេនាំទៅមុខតុលាការ ។ ខ្លួនប្រាណលោកខ្សោយ ព្រោះលោកចាស់ជរា និងមានជំងឺផង ប៉ុន្តែ វិញ្ញាណលោកនៅតែប្រុងប្រៀបជានិច្ច ដើម្បីធ្វើឲ្យព្រះគ្រីស្តសម្ដែងសិរីរុងរឿងដោយសារលោក ។ នៅពេលទាហាននាំលោកទៅមុខតុលាការ អ្នកមុខអ្នកការក្រុង និងប្រជាជនទាំងមូល ហែហមលោក ទាំងស្រែកទ្រហឹងអឺងកង ហាក់បីដូចលោកជាព្រះគ្រីស្តតែម្ដង ។ លោកផ្តល់សក្ខីភាពយ៉ាងប្រសើរ ។ លោកទេសាភិបាលសួរលោកអំពីព្រះដែលគ្រីស្តបរិស័ទគោរពថ្វាយបង្គំនោះ ។ លោកឆ្លើយថា "ប្រសិនបើលោកមានចិត្តគំនិតសមរម្យនឹងព្រះអង្គ លោកមុខជាស្គាល់ព្រះអង្គពុំខាន" (...) ។

គេចងនាង**ប្លង់ឌីន**ព្យួរនឹងបង្គោលឈើដើម្បីធ្វើជាចំណីសត្វសាហាវហែកស៊ី ។ បងប្អូនគ្រីស្តបរិស័ទដែលកំពុងតយុទ្ធនឹងសត្វសាហាវ មានចិត្តក្លាហានកាន់តែខ្លាំងឡើងៗ ដោយឃើញគេព្យួរនាងដូចជាព្យួរនៅលើឈើឆ្កាងម្យ៉ាង និងដោយស្ដាប់នាងបន្លឺសំឡេងអង្វរព្រះជាម្ចាស់ ។ ក្នុងពេលប្រយុទ្ធនឹងសត្វសាហាវ ពួកគេសង្កេតមើលនាងដូចជាឃើញព្រះគ្រីស្ត ដែលត្រូវគេឆ្កាងសម្រាប់ពួកគេ ។

ដូច្នេះអស់អ្នកដែលជឿសង្ឃឹមលើព្រះគ្រីស្ត ជឿជាក់ថានាងរងទុក្ខលំបាកដើម្បីសម្ដែងសិរីរុងរឿងរបស់ព្រះគ្រីស្ត និងរួមរស់ជានិច្ចជាមួយព្រះដ៏មានព្រះជន្មគង់នៅ ។ ពេលនាងលាចាកលោកនេះទៅ ប្រៀបដូចជាគេអញ្ជើញនាងឲ្យទៅចូលរួមក្នុងពិធីជប់លៀងមង្គលការមួយ មិនមែនជាការបោះនាងទៅឲ្យសត្វព្រៃហែកស៊ីសាច់ឡើយ ។ គេយកខ្សែតីមកវាយនាង គេយកនាងឲ្យសត្វព្រៃហែកស៊ីសាច់ គេដាក់នាងលើកៅអីដែលក្តៅរលេះរលួយ រួចគេដាក់នាងក្នុងសំណាញ់មួយបោលនៅមុខគោបា ។ គោនោះវាត់សំណាញ់បោះនាងឡើងលើជាច្រើនលើកច្រើនសា តែនាងមិនដឹងអំពីទារុណកម្មដែលគេធ្វើមកលើរូបកាយនាងឡើយ ដោយនាងគិតអំពីសេចក្ដីសង្ឃឹមថា នឹងបានទទួលសម្បត្តិសួគ៌ ហើយនាងក៏កំពុងតែសន្ទនាជាមួយព្រះគ្រីស្តដែរ ។ ទីបញ្ចប់ គេប្រហារជីវិតនាងដោយអារក ។ សូម្បីតែអ្នកកាន់សាសនាដទៃក៏ទទួលស្គាល់ថា នៅក្នុងស្រុកគេ មិនដែលមានស្ត្រីណាម្នាក់ស៊ូទ្រាំនឹងទារុណកម្មដ៏សែនឈឺចុកចាប់ និងច្រើនដូចនាងប្លង់ឌីននោះទេ (...) ។

មរណសាក្សីក្រុងលីយ៉ុង ២១-២៤; ២៩-៣១; ៥៣-៥៤

Layout Histor.qxd 2/10/07 10:09 AM Page 37

ស្មោះត្រង់នឹងព្រះចៅក្តី ក៏គេមិនព្រមថ្វាយបង្គំព្រះចៅ ទុកជាព្រះអម្ចាស់ជាដាច់ខាត ។ ហេតុនេះហើយ បានជាព្រះចៅអធិរាជចេញព្រះរាជក្រិត្យជាច្រើនលើកប្រឆាំងនឹងគ្រីស្តបរិស័ទ ឲ្យអនុវត្តក្នុងចក្រភពទាំងមូល ។

## *ក- ព្រះរាជក្រិត្យរបស់ព្រះចៅសែបទីម-សេវែរ (១៩៣-២១១)*

ព្រះចៅ**សែបទីម-សេវែរ** (Septime Sevère) មានព្រះរាជបំណងរារាំងសាសនានានាមិនឲ្យចម្រើនឡើង ទ្រង់ហាមសាសនិកយូដា គ្រីស្តបរិស័ទផ្សព្វផ្សាយសាសនារបស់ខ្លួន ។ ហេតុនេះ អ្នកអប់រំជំនឿ គឺជាអ្នកប្រព្រឹត្តកិច្ចការខុសច្បាប់ ហើយអ្នកទទួលការអប់រំក៏ខុសច្បាប់ដែរ (គ.ស. ២០២) ។ ប្រហែលរដ្ឋអំណាចអនុវត្តតាមព្រះរាជ្យក្រិត្យនេះហើយ ទើបធ្វើទារុណកម្មដល់នាង**ហ្វេលី**
(20) **ស៊ីតា** (Félicita) និងនាង**ពែរពេទួអា** (Perpétua) កំពុងទទួលការអប់រំជំនឿ ហើយនាងទាំងពីរទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងមន្ទីរឃុំឃាំង (គ.ស. ២០៣) ។

ព្រះចៅ**ម៉ាក់ស៊ីម៉ាំង** (Maximin) បញ្ជាឲ្យរដ្ឋអំណាចសម្លាប់ក្រុមបូជាចារ្យ ដើម្បីឲ្យព្រះសហគមន៍ចុះអន់ថយ (គ.ស. ២៣៥) ។

## *ខ- ពីព្រះចៅដែស្ស (២៤៩-២៥១) ដល់ព្រះចៅវ៉ាឡេរីយ៉ាំង (២៥៣-២៦០)*

នៅសម័យនោះខ្មាំងសត្រូវវាយលុកលុយតាមព្រំដែនចក្រភព ។ ព្រះចៅ**ដែស្ស** (Dèce) មានព្រះរាជបំណងឲ្យប្រជារាស្ត្រនៅសមរភូមិក្រោយរួមគ្នាជាធ្លុងតែមួយ ។ ព្រះអង្គបញ្ជាឲ្យប្រជាពលរដ្ឋទាំងអស់ ថ្វាយយញ្ញបូជាដល់ព្រះទាំងឡាយដែលតែងតែការពារចក្រភព ។ ប្រជាពលរដ្ឋម្នាក់ៗត្រូវទទួលលិខិតបញ្ជាក់ថា គេបានថ្វាយយញ្ញបូជាពិតមែន (គ.ស. ២៥០) ។ ព្រះរាជក្រិត្យនេះបណ្តាលឲ្យរដ្ឋអំណាចធ្វើទុក្ខបុកម្នេញដល់គ្រីស្តបរិស័ទទូទាំងចក្រភពទាំងមូល ព្រោះគ្រីស្តបរិស័ទមិនព្រមថ្វាយយញ្ញបូជាដល់ព្រះឯណាសោះ ។ គ្រីស្តបរិស័ទជាច្រើនសុខចិត្តបូជាជីវិតទៅជាមរណសាក្សី ប៉ុន្តែ គ្រីស្តបរិស័ទមួយចំនួនក៏ថ្វាយយញ្ញបូជាតាមព្រះរាជក្រិត្យនោះដែរ ព្រោះពួកគេមិនបានប្រុងប្រយ័ត្នអំពីជំនឿ
របស់ខ្លួន ។ លោក**ស៊ីព្រីយ៉ាំង** (Cyprien) ជាអភិបាលព្រះសហគមន៍ក្រុងកាតាស្ស (21)
រៀបរាប់អំពីគ្រីស្តបរិស័ទបោះបង់ជំនឿចោលនៅពេលនោះ បណ្តាលឲ្យព្រះសហគមន៍នៅអាហ្វ្រិកច្របូកច្របល់ជាខ្លាំង ។ ពេលមានសន្តិភាពវិញ គ្រីស្តបរិស័ទខ្វែងគំនិតគ្នា អំពីអ្នកដែលបានថ្វាយយញ្ញបូជាដល់ព្រះដទៃនោះ រួចមានបំណងចង់ចូលព្រះសហគមន៍វិញ ។

ព្រះចៅ**វ៉ាឡេរីយ៉ាំង** (Valérien) មានព្រះរាជបំណងឲ្យប្រជារាស្ត្រទាំងអស់រួបរួមគ្នាជាធ្លុងតែមួយ ប្រឆាំងនឹងសត្រូវជាតិពៃរ្យ ។ ព្រះចៅឈ្វេងយល់ថាគ្រីស្តបរិស័ទជាក្រុមមួយប្លែកពីគេ ។ គ.ស. ២៥៧ ព្រះចៅចេញព្រះរាជក្រិត្យប្រឆាំងក្រុមបូជាចារ្យហាមឃាត់គ្រីស្តបរិស័ទរួមគ្នាធ្វើពិធីគោរពបម្រើព្រះអម្ចាស់ និងហាមជួបជុំគ្នានៅទីកប់សពទៀត ។ អស់អ្នកដែលមិនព្រមថ្វាយយញ្ញបូជាដល់រូបបដិមាព្រះចៅអធិរាជនោះ ទ្រង់ព្រះរាជបញ្ជាឲ្យសម្លាប់ (គ.ស. ២៥៨) ។ លោកស៊ីព្រីយ៉ាំង ជាអភិបាលព្រះសហគមន៍ក្រុងកាតាស្ស លោក**ស៊ិស្ត** (Sixt) ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម និងលោក**ឡូរ៉ង់** (Laurent) ជាឧបដ្ឋាករបស់លោក បូជាជីវិតជាមរណសាក្សីនៅពេលនោះ ។



*ចង្កៀងបុរាណ*

Layout Histor.qxd 2/10/07 10:09 AM Page 38

## ⑳ នាងហ្វេលីស៊ីតា បូជាជីវិតជាមរណសាក្សីនៅក្រុងកាតាស្ស (គ.ស. ២០៣)

នាង**ហ្វេលីស៊ីតា**ជាទាសីម្នាក់ជាប់ឃុំឃាំងជាមួយនាង**ពែរពេទួអា**ជាស្ត្រីត្រកូលខ្ពស់ ។ អ្នកសរសេររឿងនាងទាំងពីរធ្លាប់ថែងអំពីព្រះគ្រីស្តគង់នៅជាមួយអ្នកបូជាជីវិតព្រោះតែព្រះអង្គ ។

នៅពេលគេចាប់ខ្លួននាងហ្វេលីស៊ីតា នាងមានផ្ទៃ ៨ ខែហើយ ។ ការប្រយុទ្ធជាមួយសត្វសាហាវកាន់តែជិតមកដល់ ។ នាងព្រួយចិត្តជាខ្លាំង នាងនឹកគិតថា ប្រហែលជាគេឃាត់នាងមិនឲ្យចូលប្រយុទ្ធជាមួយសត្វកាចសាហាវ ដូចគ្រីស្តបរិស័ទឯទៀតៗទេមើលទៅ ពីព្រោះច្បាប់ហាមសម្លាប់ស្ត្រីមានផ្ទៃពោះ ។ នាងខ្លាចក្រែងមិនបានបង្ហូរឈាមដ៏បរិសុទ្ធរបស់នាងរួមជាមួយបងប្អូនឯទៀតៗ ។ គ្រីស្តបរិស័ទឯទៀតៗដែលជាប់ឃុំឃាំងជាមួយនាងក៏ព្រួយបារម្ភដែរ ខ្លាចក្រែងគេទុកបងស្រីដែលមានចិត្តល្អជាមិត្តសំឡាញ់កំពុងដើរជាមួយគេនៅលើផ្លូវនៃសេចក្ដីសង្ឃឹមដ៏រុងរឿងដូចគ្នានេះ បោលឲ្យនៅម្នាក់ឯង ។ ហេតុនេះហើយ បានជាបីថ្ងៃមុនពេលប្រយុទ្ធ ពួកគេនាំគ្នាទទូចអង្វរព្រះអម្ចាស់ ។ គេទើបតែបញ្ចប់អធិដ្ឋាន ស្រាប់តែនាងហ្វេលីស៊ីតា ចាប់ផ្ដើមឈឺពោះសម្រាលកូន ។ នាងថ្ងូរដោយឈឺចាប់យ៉ាងខ្លាំង ព្រោះមិនទាន់ដល់ពេលសម្រាលកូនទេ ។ ពេលនោះ ទាហានយាមគុកប្រាប់នាងថា៖ «ឥឡូវនេះនាងថ្ងូរ ។ ពេលនាងនៅមុខសត្វសាហាវ តើនាងនឹងថ្ងូរយ៉ាងណាទៅវិញ»? នាងតបឆ្លើយថា៖ «ថ្ងៃនេះ ខ្លួនខ្ញុំផ្ទាល់ឈឺចុកចាប់មែន ។ ប៉ុន្តែ នៅថ្ងៃនោះនឹងមានម្នាក់ផ្សេងទៀតនៅក្នុងរូបខ្ញុំ ហើយព្រះអង្គឈឺចុកចាប់ជំនួសខ្ញុំ ព្រោះខ្ញុំសុខចិត្តឈឺចាប់ព្រោះតែព្រះអង្គ» ។ បន្ទាប់មកនាងកើតកូនស្រីមួយ ។ គ្រីស្តបរិស័ទម្នាក់យកកូននោះទៅចិញ្ចឹម ទុកដូចជាកូនបង្កើតផ្ទាល់ ។

មរណសាក្សីស្រុកអាហ្វ្រិក

## ㉑ លោកស៊ីព្រីយ៉ាំងបូជាជីវិតព្រោះតែព្រះគ្រីស្ត (គ.ស. ២៥៨)

- លោកទេសាភិបាល**កាឡេរីយ៉ូស-ម៉ាស៊ីម៉ូស** បញ្ជាឲ្យគេចាប់ចងលោក**ស៊ីព្រីយ៉ាំង** នាំមកនៅមុខលោក (...) ។
- លោកទេសាភិបាលសួរ «លោកពិតជាឈ្មោះតាស៊ីយ៉ូស-ស៊ីព្រីយ៉ាំង មែនទេ?»
- លោកស៊ីព្រីយ៉ាំងឆ្លើយថា «បាទ! គឺខ្ញុំនេះហើយ»
- លោកទេសាភិបាលសួរ «លោកជាអ្នកណែនាំពួកគ្រីស្តបរិស័ទទាំងនោះមែនទេ?»
- លោកស៊ីព្រីយ៉ាំងឆ្លើយថា «បាទ! គឺខ្ញុំនេះហើយ»
- លោកទេសាភិបាលសួរ «ព្រះចៅបញ្ជាឲ្យលោកថ្វាយយញ្ញតាមច្បាប់»
- លោកស៊ីព្រីយ៉ាំង «បាទ តែខ្ញុំបាទមិនព្រមថ្វាយយញ្ញទេ»
- លោកទេសាភិបាល «ចូរប្រយ័ត្នខ្លួន!»
- លោកស៊ីព្រីយ៉ាំង «បាទ! សូមលោកប្រព្រឹត្តតាមបញ្ជាដែលលោកបានទទួលចុះ»
- លោកទេសាភិបាល «រឿងនេះច្បាស់ហើយ មិនបាច់ស៊ើបសួរអ្វីទៀតទេ»

លោកទេសាភិបាលកាឡេរីយ៉ូស-ម៉ាស៊ីម៉ូស ពិភាក្សារកខុសត្រូវជាមួយក្រុមប្រឹក្សារបស់លោក រួចហើយក៏ដាក់ទោសលោកស៊ីព្រីយ៉ាំងដោយពោលថា «លោករស់នៅជាយូរឆ្នាំក្នុងឋានៈជាមនុស្សប្រមាថព្រះចៅអធិរាជ លោកបានប្រមែប្រមូលអ្នកសេពគប់ជាមួយលោកជាច្រើននាក់ ឃុបឃិតប្រព្រឹត្តការដ៏អាក្រក់នេះ ។ លោកតាំងខ្លួនជាសត្រូវរបស់ព្រះនៃជនជាតិរ៉ូម៉ាំង និងមិនព្រមគោរពថ្វាយបង្គំព្រះទាំងនោះទេ ។ ព្រះចៅអធិរាជដ៏ជាទីគោរពសក្ការៈ **វ៉ាឡេរីយ៉ាំង** និង **ហ្គាលីយ៉ាំង** គ្មានសមត្ថភាពណែនាំលោកឲ្យធ្វើតាមពិធីបុណ្យនៃប្រជាជនរ៉ូម៉ាំងឡើយ ។ យើងមានភស្តុតាងថា លោកជាមេញុះញង់គេ និងជាអ្នកនាំមុខក្នុងបទឧក្រិដ្ឋដ៏អាក្រក់បំផុតនេះ ។ ហេតុដូចនេះហើយ លោកត្រូវទទួលទោសជាគំរូសម្រាប់អស់អ្នកដែលលោកណែនាំឲ្យប្រព្រឹត្តអាក្រក់នោះ ។ លោកត្រូវតែទទួលទោស ។

ក្រោយមក លោកទេសាភិបាលអានពាក្យដាក់ទោសដែលគេចារលើបន្ទះឈើមួយថា៖ «**តាសីយ៉ូស-ស៊ីព្រីយ៉ាំង** ត្រូវសម្លាប់ដោយមុខដាវ យើងបញ្ជាដូច្នេះឯង» ។ លោកអភិបាលស៊ីព្រីយ៉ាំងតបឆ្លើយថា "សូមអរព្រះគុណព្រះជាម្ចាស់!" ។

Layout Histor.qxd 2/10/07 10:09 AM Page 39

### *គ- សេរីភាពខាងសាសនា*

កងទ័ពរៀបចាប់ព្រះចៅ**វ៉ាឡេរីយ៉ាំង**ធ្វើគុត ។ គ្រីស្តបរិស័ទយល់ឃើញថា ព្រះជាម្ចាស់ពិតជាដាក់ទោសព្រះអង្គ ។ ព្រះចៅ**ហ្គាលីយ៉ាំង** (Gallien) ដែលស្នងរាជ្យ ចេញព្រះរាជក្រឹត្យនៅគ.ស. ២៦១ អនុញ្ញាតឲ្យគ្រីស្តបរិស័ទមានសិទ្ធិសេរីភាពកាន់សាសនារបស់ខ្លួនបាន ។ ព្រះសហគមន៍មានសេចក្ដីសុខសាន្តរយៈពេលសែសិបឆ្នាំ ប្រជាជនបះបោរប្រឆាំងនឹងគេតែនៅតំបន់ខ្លះប៉ុណ្ណោះ ។ គ្រីស្តបរិស័ទកើនចំនួនឡើងយ៉ាងឆាប់រហ័ស ជាពិសេសនៅខាងអាស៊ីមីន័រ *(ទួរគីសព្វថ្ងៃ)* ។ គេកសាងព្រះវិហារជាច្រើន ។

## ៤- ព្រះចៅឌីយ៉ូក្លេស៊ីយ៉ាំង ធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ

### *ក- អំណាចលទ្ធិផ្ដាច់ការ*

ព្រះចៅ**ឌីយ៉ូក្លេស៊ីយ៉ាំង** (Dioclétien) ឡើងគ្រងរាជ្យនៅ គ.ស. ២៨៥ ។ ព្រះអង្គមានព្រះរាជបំណងចាត់ចែងរាជការសាជាថ្មីនៅក្នុងចក្រភពទាំងមូល ។ ទ្រង់បែកចក្រភពជាបួនផ្នែកគឺ៖

**- នៅខាងបូព៌ា** ទ្រង់តែងតាំងព្រះចៅអធិរាជពីរអង្គ គឺព្រះចៅឌីយ៉ូក្លេស៊ីយ៉ាំងផ្ទាល់ និងព្រះ**ចៅកាឡេរ** (Galère) ។

**- នៅខាងបស្ចិម** មានព្រះចៅពីរអង្គទៀត គឺព្រះចៅ**ម៉ាក់ស៊ីមីយ៉ាំង** (Maximien) និងព្រះចៅ**កុងស្តង់ ក្លរ័** (Constance Chlore) ។ ស្រុកចំនួន ៩៦ ស្ថិតនៅក្នុងភូមិភាគ ១២ ។ ព្រះចៅទារពន្ធដារហួសហេតុ គ្មានមេត្តា ព្រោះព្រះចៅត្រូវចិញ្ចឹមកងទ័ពដ៏ច្រើន និងក៏សង់អាគារដ៏ធំមហិមាដែរ ។ រដ្ឋាភិបាលត្រួតត្រាប្រជាជនដោយកាន់លទ្ធិផ្ដាច់ការ ទាំងប្រើនគរបាលគំរាមផង ។ ក្រសួងយុត្តិធម៌តឹងរ៉ឹងឡើងៗ ។ ប្រជាជនត្រូវតែគោរពថ្វាយបង្គំព្រះចៅដែលពាក់មកុដនិងកាន់ដំបងរាជ្យដោយខានមិនបាន ។ ដូច្នេះ ការចាត់ចែងចក្រភពសាជាថ្មី គឺមានលក្ខណៈជានយោបាយផងនិងសាសនាផង ។ គេតែងចោទថា អ្នកមិនព្រមធ្វើតាមរបៀបរៀបរយដែលចាត់ចែងឡើងនេះថា ជាមនុស្សប្រព្រឹត្តបទឧក្រិដ្ឋ ។ រដ្ឋអំណាចតែងដេញតាមចាប់ចងអ្នកកាន់សាសនាប្លែកពីគេ ជាពិសេសអស់អ្នកដែលកាន់តាមលោក**ម៉ានី** (គ.ស. ២៩៧) ។ ក្រោយមក គេក៏ដេញតាមចាប់ចងគ្រីស្តបរិស័ទដែរ ។

### *ខ- ត្រូវសម្លាប់គ្រីស្តបរិស័ទឲ្យអស់*

ទាហានខ្លះជាគ្រីស្តបរិស័ទ ។ ពួកគេមិនព្រមធ្វើពិធីគោរពព្រះចៅអធិរាជទុកជាព្រះទេ បណ្ដាលឲ្យព្រះចៅ**ឌីយ៉ូក្លេស៊ីយ៉ាំង**អន់ព្រះទ័យ ។ រីឯព្រះចៅ**កាឡេរ** ដែលគ្រងរាជ្យភាគខាងបូព៌ា ព្រះអង្គឈ្វេងយល់ថា គ្រីស្តសាសនានាំឲ្យសង្គមពីបុរាណរលាយ ។ នេះជាមូលហេតុបណ្ដាលឲ្យព្រះចៅធ្វើទុក្ខបុកម្នេញដល់គ្រីស្តបរិស័ទជាលើកចុងក្រោយយ៉ាងធ្ងន់បំផុត ។ ចាប់ពីខែកុម្ភៈ គ.ស. ៣០៣ ដល់ខែកុម្ភៈ គ.ស. ៣០៤ ព្រះចៅអធិរាជចេញព្រះរាជក្រឹត្យជាច្រើនបន្តបន្ទាប់ និងកាន់តែតឹងរ៉ឹងឡើងៗ គឺទ្រង់បញ្ជាឲ្យគេដុតគម្ពីរ រុះរើព្រះវិហារ និងកន្លែងគោរពបូជាចោល ។ គ្រីស្តបរិស័ទបាត់បង់សិទ្ធិជាប្រជាពលរដ្ឋ ។ ព្រះចៅបង្ខំមនុស្សទូទៅឲ្យថ្វាយយញ្ញបូជា និងផ្ដន្ទាទោសប្រហារជីវិតអ្នកមិនព្រមថ្វាយយញ្ញបូជា ឬផ្ដន្ទាទោសឲ្យគេធ្វើការយ៉ាងធ្ងន់នៅរ៉ែអំបិល ។ល ។ រដ្ឋអំណាចអនុវត្តរាជក្រឹត្យតាមរបៀបផ្សេងៗពីគ្នាទៅតាមតំបន់ ។ ឧប. ស្រុកហ្គោល *(ប្រទេសបារាំងសព្វថ្ងៃ)* ព្រះចៅអធិរាជ**កុងស្តង់ក្លរ័**គ្រាន់តែរុះព្រះវិហារខ្លះៗប៉ុណ្ណោះ ។ នៅស្រុកអ៊ីតាលី ស្រុកអេស្ប៉ាញ និងស្រុកអាហ្វ្រិក រដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទយ៉ាងខ្លាំង (គ.ស. ៣០៣-៣០៥) រីឯផ្នែកខាងបូព៌ាប្រទេស រដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទយ៉ាងធ្ងន់ អស់រយៈពេលជាយូរដែរ គឺចាប់ពី គ.ស. ៣០៣ ដល់ គ.ស. ៣១៣ ។

តំបន់ទាំងនោះ គ្រីស្តបរិស័ទមានចំនួនច្រើន ប្រមាណ ៥0 ភាគរយនៃប្រជាជនទាំងមូល ។ ព្រះចៅអធិរាជ**កាឡេរ** (Galère) ផ្សព្វផ្សាយគម្ពីរក្លែងក្លាយមួយដើម្បីប្រឆាំងនឹងគ្រីស្តបរិស័ទ ហើយចៅក្រមធ្វើបាបគ្រីស្តបរិស័ទយ៉ាងឃោរឃៅរកនិយាយមិនកើត ។

## *គ- សន្តិភាពត្រឡប់មកវិញ*

ចាប់ពី គ.ស. ៣0៦ របនាសម្ពន្ធនយោបាយរបស់ព្រះចៅ**ឌីយ៉ូក្លេស៊ីយ៉ាំង** លែងមានប្រសិទ្ធភាព ព្រោះព្រះចៅអធិរាជមានដល់ទៅ ៧ អង្គ ដែលប្រឆាំងគ្នាទៅវិញទៅមក ។ នៅខាងបស្ចិមប្រទេស ព្រះចៅ**កុងស្តង់តាំង** (Constantin) ជាបុត្រព្រះចៅ**កុងស្តង់-ក្លូរ៍** និងគ្រីស្តបរិស័ទស្រីម្នាក់ឈ្មោះនាង**ហេឡែន** (Hélène) ជាម្តាយ វាយឈ្នះព្រះចៅអធិរាជឯទៀតៗ មួយអង្គម្តងៗ ។ នៅគ.ស. ៣១២ ព្រះអង្គវាយឈ្នះព្រះចៅ**ម៉ាសង្ស** (Maxence) នៅស្ពានមិលវីយ៉ូស (Milvius) ក្បែរក្រុងរ៉ូម ហើយបញ្ចប់សង្គ្រាមស៊ីវិល ។ យូរឆ្នាំក្រោយមក លោក**ឡាកតង្ស** (Lactance) និងលោក**អឺសែប** ជាអភិបាលព្រះសហគមន៍សេសារេ និពន្ធរឿងនេះដោយពន្យល់ថា ព្រះចៅកុងស្តង់តាំងមានជ័យជំនះពេលនោះ ដោយព្រះគ្រីស្តជួយគាំទ្រព្រះអង្គ ។ គេនិទានថា ព្រះចៅកុងស្តង់តាំងទតឃើញឈើឆ្កាងមួយនៅលើមេឃ មានពន្លឺចែងចាំង និងទតឃើញពាក្យចែងថា «*លោកនឹងយកជ័យជម្នះបានដោយសារសញ្ញានេះ*» ។ ព្រះអង្គប្រែចិត្តជឿលើព្រះគ្រីស្ត ហើយបញ្ជាឲ្យគេគូសសញ្ញារបស់ព្រះគ្រីស្តនៅលើទង់កងទ័ពធ្វើឲ្យគេមានជ័យជម្នះ ។

## *ឃ- ព្រះសហគមន៍បានសេចក្តីសុខសាន្ត (៣១៣)*

ច្រើនឆ្នាំក្រោយមក នៅបស្ចិមប្រទេសរដ្ឋអំណាចលែងធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទទៀតហើយ ។ នៅបូព៌ាប្រទេស គ.ស. ៣១១ ព្រះចៅកាឡេរដែលហៀបនឹងសោយទិវង្គត ចេញព្រះរាជក្រិត្យអនុញ្ញាតឲ្យគ្រីស្តបរិស័ទមានសិទ្ធិសេរីភាពកាន់សាសនារបស់ខ្លួនបាន ។ ប៉ុន្តែ ព្រះចៅដែលស្នងរាជ្យបន្តពីព្រះអង្គ មិនអនុវត្តតាមព្រះរាជក្រិត្យនោះទេ ។ ព្រះចៅ**លីស៊ីញ៉ូស** (Lisinius) ដែលស្នងរាជ្យបន្តទៀត បញ្ជាឲ្យមានសន្តិភាពខាងសាសនាវិញ ។ នៅឆ្នាំ ៣១៣ ព្រះចៅទាំងពីរអង្គ គឺព្រះចៅកុងស្តង់តាំង និងព្រះចៅលីស៊ីញ៉ូស ព្រមព្រៀងគ្នាប្រោសប្រទានសន្តិភាពនិងសេរីភាពខាងសាសនា ។ ព្រះចៅទាំងពីរចុះព្រះរាជសារផ្ញើជូនលោកទេសាភិបាលនៅស្រុកប៊ីធីនី ហៅថា «*ព្រះរាជក្រិត្យពីក្រុងមីឡង់*» ។ តាមព្រះរាជសារនេះ ព្រះចៅទាំងពីរអង្គទទួលស្គាល់ថា ប្រជាពលរដ្ឋក្នុងចក្រភពទាំងមូល មានសិទ្ធិសេរីភាពពេញទី មានសិទ្ធិកាន់សាសនានិងគោរពបូជាព្រះតាមចិត្ត ទោះបីសាសនាណាក៏ដោយ ។ រដ្ឋអំណាចត្រូវប្រគល់អាគារទាំងប៉ុន្មានដែលរឹបអូសពីគ្រីស្តបរិស័ទឲ្យទៅគ្រីស្តបរិស័ទវិញ ។ សាសនាទាំងអស់ក្នុងចក្រភពទាំងមូលហាក់ដូចជាមានសិទ្ធិស្មើគ្នា ។ តែមិនសូវយូរប៉ុន្មាន គ្រីស្តសាសនាបែរជាមានសិទ្ធិច្រើនជាងសាសនាឯទៀតៗ ។ ដូច្នេះ នៅ គ.ស. ៣១៣ ព្រះសហគមន៍និងចក្រភពចាប់ផ្តើមសម័យកាលថ្មីដែលហៅថា «*ព្រះសហគមន៍សម័យព្រះចៅកុងស្តង់តាំង*» ឬ «*ចក្រភពគ្រីស្តបរិស័ទ*» ។

## *ង- ចំនួនមរណសាក្សី*

តើមរណសាក្សីដែលបូជាជីវិតព្រោះតែព្រះគ្រីស្តមានចំនួនប៉ុន្មាននាក់? កាលពីដើម គ្រីស្តបរិស័ទតែងតែនិយាយថា មានមរណសាក្សីរាប់ពាន់នាក់ រហូតដល់រាប់លាននាក់ ។ រីឯអ្នកប្រវត្តិសាស្ត្រសព្វថ្ងៃ រាប់តែអ្នកដែលមានឈ្មោះក្នុងអត្ថបទផ្សេងៗប៉ុណ្ណោះទុកជាមរណសាក្សី គេសន្និដ្ឋានថា នៅពេលរដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទពេលចុងក្រោយបង្អស់ មានមរណសាក្សីតែបីពាន់នាក់ប៉ុណ្ណោះ ។ តាមពិតទៅ មានចំនួនច្រើនជាងនេះទៅទៀត ។

22

Layout Histor.qxd 2/10/07 10:09 AM Page 41

### ច- មរណសាក្សីទាមទារសិទ្ធិសេរីភាពខាងជំនឿ

ព្រះសហគមន៍បាក់គ្រឹះយ៉ាងមាំលើមរណសាក្សី ។ មរណសាក្សីផ្តល់សក្ខីភាពអំពីជំនឿរបស់ខ្លួនទៅលើព្រះគ្រីស្ត គឺថាគេសុខចិត្តរួមស្លាប់ជាមួយព្រះគ្រីស្ត ដោយយល់ដល់ជីវិតលោកខាងមុខជាមួយព្រះអង្គ ។ ប៉ុន្តែ យើងមិនត្រូវបំបែកគ្រីស្តបរិស័ទជាមរណសាក្សីចេញពីមនុស្សឯទៀតៗតាំងពីដើមរៀងមក ដែលសុខចិត្តបូជាជីវិតក្នុងការទាមទារសិទ្ធិសេរីភាពខាងគំនិតប្រាជ្ញា និងខាងជំនឿនៅចំពោះមុខរដ្ឋអំណាចផ្តាច់ការ ឬអស់អ្នកដែលសុខចិត្តបូជាជីវិតដើម្បីរកយុត្តិធម៌ក្នុងសង្គមនោះទេ ។ ទោះបីគេមិនមែនជាគ្រីស្តបរិស័ទក្តី ក៏ជាមរណសាក្សីដែរ ។

### ㉒ ព្រះរាជសារផ្ញើជូនលោកទេសាភិបាលស្រុកប៊ីធីនី ហៅថា “ព្រះរាជក្រិត្យពីក្រុងមីឡង់”

*យើង**កុងស្តង់តាំង-អូគូស្ទ** និងយើង**លីស៊ីញ៉ូស-អូគូស្ទ**ជួបជុំគ្នានៅក្រុងមីឡង់ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងសន្តិសុខជាប្រយោជន៍រួម ។ ជាបឋម យើងឈ្វេងយល់ច្បាស់ថា ត្រូវបាត់វិជានការណ៍ដើម្បីនាំប្រយោជន៍ដល់មនុស្សភាគច្រើន គឺឲ្យគេគោរពព្រះរបស់ខ្លួន ។ យើងប្រទានឲ្យគ្រីស្តបរិស័ទនិងមនុស្សឯទៀតៗមានសិទ្ធិសេរីភាព អាចកាន់សាសនាតាមខ្លួនជ្រើសរើសធ្វើដូច្នេះ ព្រះទាំងឡាយនៅស្ថានបរមសុខ មុខជាមេត្តាករុណាអាណិតអាសូរដល់យើង និងដល់អស់ប្រជារាស្ត្រដែលស្ថិតនៅក្រោមអំណាចរបស់យើងដែរ ។ ហេតុនេះហើយ បានជាយើងមានបំណងយ៉ាងស្មោះត្រង់បំផុត ចង់សង្គ្រោះប្រជារាស្ត្រ យើងឈ្វេងយល់យ៉ាងច្បាស់ថា គឺយើងត្រូវទទួលស្គាល់មនុស្សគ្រប់ៗរូប ទោះបីគេជាប់ចិត្តនឹងសាសនារបស់គ្រីស្តបរិស័ទក្តី ឬជាប់ចិត្តនឹងសាសនាដែលខ្លួនយល់ឃើញថា ត្រូវនឹងខ្លួនក្តី ដើម្បីឲ្យព្រះដ៏ខ្ពង់ខ្ពស់បំផុតដែលយើងគោរពបូជាដោយចិត្តស្មោះ ទ្រង់ព្រះមេត្តាករុណា និងប្រោសប្រណីដល់យើងជាប្រក្រតីក្នុងគ្រប់កិច្ចការទាំងអស់ ។ ហេតុនេះ សូមលោកឯកឧត្តមជ្រាបនូវសេចក្តីដែលយើងបានសម្រេច គឺថា ត្រូវបំបាត់ច្បាប់ទាំងប៉ុន្មាន ដែលចែងក្នុងព្រះរាជក្រិត្យចុះផ្សាយកាលពីមុនៗមក ត្រូវជម្រាបតាមគ្រប់ការិយាល័យរបស់លោកអំពីគ្រីស្តបរិស័ទ ។ យើងលប់បំបាត់នូវរាជក្រិត្យដែលយើងយល់ថា មិនទំនង និងផ្ទុយពីព្រះហឫទ័យមេត្តាករុណារបស់យើង ។ តាំងពីពេលនេះតទៅ សូមអស់លោកអនុញ្ញាតឲ្យអស់អ្នកណា ដែលសម្រេចចិត្តកាន់គ្រីស្តសាសនា ឲ្យគេកាន់ដោយសិទ្ធិសេរីភាពពេញទីដោយគ្មាននរណាមករំខាន ឬមកធ្វើបាបឡើយ (...) ។*



*ប្រាក់កាក់ដែលមានព្រះឆាយាល័ក្ខណ៍របស់ព្រះចៅកុងស្តង់តាំងកាន់ឈើឆ្កាង*

*សេចក្តីបញ្ជូនមកដោយលោកឡាកតង្ស ក្នុងសៀវភៅ*
*”អ្នកធ្វើទុក្ខបុកម្នេញស្លាប់ទៅហើយ” ។*

Layout Histor.qxd 2/10/07 10:09 AM Page 42



# ការរស់នៅ ជាគ្រីស្ទបរិស័ទសតវត្សដើមដំបូង

**(ពីសតវត្សទី ១-៣)**

*គ្រីស្ទបរិស័ទជាអ្នកជឿលើព្រះគ្រីស្ទនិងដំណឹងល្អរបស់ព្រះអង្គ គេក៏ប្រែរបៀបរស់នៅស្របតាមដំណឹងល្អនោះដែរ ។ ពួកគេប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែង ។ គេទទួលអគ្គសញ្ញាជ្រមុជទឹកនៅតាមដងស្ទឹង ឬតាមដងទន្លេក៏បានដែរ ។ គ្រីស្ទបរិស័ទមិនរស់នៅដាច់ឡែកពីគ្នាទេ គឺគេចូលរួមក្នុងសហគមន៍មួយ ពោលគឺគេចូលរួមក្នុងប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់ និងជាសមាជិកនៃព្រះសហគមន៍ ។ ព្រះយេស៊ូមិនបង្កើតក្បួនមាត្រារបស់សហគមន៍ណាមួយទេ គ្រីស្ដទូតក៏មិនបង្កើតលក្ខន្តិកៈសម្រាប់ព្រះសហគមន៍នោះដែរ ។ ប៉ុន្តែ ក្រុមមួយដែលចង់រស់នៅតាមដំណឹងល្អនោះ ត្រូវចំណាយពេលយ៉ាងយូរ ចាត់ចែងខ្លួនបន្តិចម្ដងៗតាមសេចក្តីត្រូវការ និងតាមសង្គមដែលខ្លួនរស់នៅ ។ គ្រីស្ទបរិស័ទត្រូវការកន្លែងសម្រាប់ជួបជុំគ្នា ត្រូវអប់រំអ្នកដែលសុំទៅជាគ្រីស្ទបរិស័ទ ត្រូវធ្វើពិធីអរព្រះគុណរាល់ថ្ងៃអាទិត្យ ។ល ។ ហេតុនេះហើយ បានជាគេបង្កើតក្បួនច្បាប់ធ្វើពិធីបុណ្យនានាជាបណ្ដើរៗ ។*

*នៅក្នុងជំពូកនេះ យើងនឹងពិនិត្យមើលអំពីការរស់នៅរបស់ព្រះសហគមន៍នានា អំពីរបៀបបង្កើតក្បួនពិធីនានា ដូចជាក្បួនពិធីចូលព្រះសហគមន៍តាមអគ្គសញ្ញាជ្រមុជទឹក ពិធីអរព្រះគុណ និងការអធិដ្ឋាន ។ យើងក៏ពិនិត្យមើលអំពីអ្នកទទួលខុសត្រូវក្នុងព្រះសហគមន៍ និងអំពីទំនាក់ទំនងរវាង គ្រីស្ទបរិស័ទនៅក្នុងចក្រភពរ៉ូម៉ាំងទាំងមូលដែរ ។ល ។*

Layout Histor.qxd 2/10/07 10:09 AM Page 44

# ក_ ពិធីទានា និង ការអធិដ្ឋាន

## ១- ពីផ្ទះឯកជនទៅគេហដ្ឋានសម្រាប់គោរពបូជា

នៅដើមដំបូងនៃព្រះសហគមន៍ គ្រីស្តបរិស័ទតែងតែជួបជុំគ្នានៅផ្ទះឯកជន គឺនៅផ្ទះធំទូលាយ ។ នៅបូព៌ាប្រទេស គ្រីស្តបរិស័ទតែងតែជួបជុំគ្នានៅក្នុងបន្ទប់ខាងលើជាបន្ទប់ស្ងាត់ និងដាច់ពីគេ *(កក ២០,៧-១១)* ។ នៅបស្ចិមប្រទេស គេធ្លាប់ជួបជុំគ្នាក្នុងបន្ទប់ទទួលទានបាយរបស់គ្រីស្តបរិស័ទជាអ្នកមាន ។ គេតែងតែធ្វើអគ្គសញ្ញាជ្រមុជទឹកក្នុងបន្ទប់ទឹក ឬក្នុងអាងមុជទឹក ។ ពេលជាតុអាកាសល្អ ពួកគេតែងជួបជុំគ្នានៅខាងក្រៅផ្ទះ គឺនៅកន្លែងមានរបងជុំវិញ ឬតាមសួនច្បារ ឬនៅតាមទីសុសាន ។ ចាប់ពីសតវត្សទី ២ មកគ្រីស្តបរិស័ទខ្លះប្រគល់ផ្ទះរបស់ខ្លួនសម្រាប់ឲ្យព្រះសហគមន៍ចាត់ចែងពិធីតែម្តង ។ នៅពាក់កណ្តាលសតវត្សទី ៣ គេសាងសង់ព្រះវិហារយ៉ាងពិតប្រាកដ ។ ផ្ទះបុរាណជាងគេដែលគ្រីស្តបរិស័ទធ្លាប់ជួបជុំគ្នា គឺផ្ទះនៅឌូរ៉ា អឺរ៉ូប៉ូស តាមដងទន្លេអឺប្រ្វាត (គ.ស. ២៥០) ។ នៅសម័យព្រះចៅ**ឌីយ៉ូក្លេស៊ីយ៉ាំង**គេបានសាងសង់ព្រះវិហារគ្រីស្តសាសនាច្រើនកន្លែងហើយ ។ នៅពេលព្រះចៅចាប់ផ្តើមធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ ទ្រង់ចេញរាជបញ្ជាឲ្យរុះរើព្រះវិហារទាំងនោះចោល ។

## ២- របៀបណែនាំមនុស្សឲ្យទៅជាគ្រីស្តបរិស័ទ

ពាក្យថា *"ការណែនាំមនុស្សម្នាក់ឲ្យទៅជាគ្រីស្តបរិស័ទ"* *(មថ ២៨,១៩)* មានអត្ថន័យថា អប់រំមនុស្សម្នាក់ឲ្យទទួលអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្ងាស និងអគ្គសញ្ញាអរព្រះគុណ ។

សាវ័ករបស់ព្រះយេស៊ូយកពិធីជ្រមុជទឹកតាមប្រពៃណីសាសនាយូដា ដើម្បីណែនាំមនុស្សឲ្យទៅជាគ្រីស្តបរិស័ទ ។ ជនជាតិយូដាតែងធ្វើពិធីជ្រមុជទឹក ដើម្បីបញ្ជាក់ថា គេប្រែចិត្តគំនិត ចង់ជម្រះខ្លួនឲ្យបរិសុទ្ធ ។ ក្រុមសាវ័កបន្ថែមអត្ថន័យថ្មី គឺអគ្គសញ្ញាជ្រមុជទឹកបញ្ជាក់ថា មនុស្សកើតជាថ្មីដោយព្រះវិញ្ញាណ គឺគ្រីស្តបរិស័ទរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូគ្រីស្ត *(រម ៦,២-១១; កាឡ ៣,២៧; កូឡ ២,១១-១៣)* ។ ហេតុនេះ គេទទួលអគ្គសញ្ញាជ្រមុជទឹកតែមួយដងគត់ ។ អ្នកមានបំណងចង់ទៅជាគ្រីស្តបរិស័ទ ត្រូវតែទទួលសារភាពអំពើបាបរបស់ខ្លួន ត្រូវប្រតិបត្តិតាមវិន័យ ជឿលើដំណឹងល្អ និងប្រកាសជំនឿលើព្រះយេស៊ូជាព្រះសង្គ្រោះ ។ ហេតុនេះហើយ បានជាគេត្រូវទទួលការអប់រំជំនឿជាមុនសិន ។ កាលពីដើមដំបូងគេអប់រំអ្នកចំណូលថ្មីក្នុងរយៈពេលយ៉ាងខ្លី ។ 23

នៅសម័យនោះ ព្រះសហគមន៍មិនទាន់ចាត់ចែងនៅគ្រប់កន្លែងតាមរបៀបដូចគ្នាឬដូចសព្វថ្ងៃទេ គឺគេចាត់ចែងពិធីតាមរបៀបប្លែកៗពីគ្នាតាមកាលៈទេសៈ និងតាមកន្លែងផ្សេងៗដែរ ។

យើងស្គាល់ក្បួនពិធីនៅក្រុងរ៉ូមយ៉ាងច្បាស់ ចាប់តាំងពីសតវត្សទី ៣ មក 24
ដោយសៀវភៅ *«សេចក្តីប្រៀនប្រដៅទទួលតៗពីក្រុមគ្រីស្តទូត»* របស់លោក**ហ៊ីប៉ូលីត** (Hippolyte) ។ សម័យនោះ គេអប់រំជំនឿអ្នកសុំទទួលអគ្គសញ្ញាជ្រមុជទឹកអស់រយៈពេលបីឆ្នាំ ។ គ្រីស្តបរិស័ទដែលនាំគេមក ត្រូវធានាថាអ្នកនោះមានចិត្តទៀងត្រង់ ។ បេក្ខជនត្រូវលះបង់មុខរបររកស៊ីខ្លះ ដែលជាប់ទាក់ទិននឹងការគោរពព្រះក្លែងក្លាយ ឬខុសសីលធម៌ ។

ព្រះសហគមន៍អប់រំអ្នកចង់ទទួលអគ្គសញ្ញាជ្រមុជទឹក ដោយបង្រៀនអំពីគោលសំខាន់ៗនៃលទ្ធិ និងសីលធម៌គ្រីស្តសាសនា ។ ការអប់រំនេះ (ពាក្យដើមគឺ *«ការស្តាប់ព្រះបន្ទូលលាន់ឮឡើង»*) (Catéchèse) ណែនាំអ្នកដែលភ្ញាក់ខ្លួនឲ្យឮអំពីដំណឹងល្អ ជាសេចក្តីសង្ខេបដូចគ្រីស្តទូត**សិលា**និងគ្រីស្តទូត**ប៉ូល** ប្រកាសក្នុងគម្ពីរកិច្ចការ ។ លោក**ហ៊ីប៉ូលីត**សរសេរថា *«អ្នកណែនាំ»* ជូនកាលជាបូជាចារ្យ ឬជាគ្រីស្តបរិស័ទធម្មតាម្នាក់ ។ បន្ទាប់ពីអ្នកណែនាំបានអប់រំ គេរួមគ្នាអធិដ្ឋាន

ហើយអ្នកណែនាំដាក់ដៃលើគេ ។ ពេលអប់រំជំនឿចប់ ព្រះសហគមន៍ពិនិត្យមើលចរិយាមារយាទរបស់បេក្ខជននោះ ។

ថ្ងៃសុក្រ មុនទទួលអគ្គសញ្ញាជ្រមុជទឹក គឺមុនថ្ងៃបុណ្យចម្លង បេក្ខជននិងគ្រីស្តបរិស័ទនៃព្រះសហគមន៍ទាំងមូលនាំគ្នាតមអាហារ ។ ថ្ងៃសៅរ៍ បេក្ខជនជួបជុំគ្នាជាលើកចុងក្រោយបង្អស់ ។ ពេលនោះ លោកអភិបាលដាក់ដៃលើបេក្ខជន ហើយធ្វើពិធីបណ្តេញមារចេញពីពួកគេ លោកផ្លុំខ្យល់លើមុខគេ គូសសញ្ញាឈើឆ្កាងលើថ្ងាស លើត្រចៀក និងលើច្រមុះរបស់គេ ។ អ្នកដែលហៀបនឹងទទួលអគ្គសញ្ញាជ្រមុជទឹក ស្តាប់ព្រះបន្ទូលនិងសេចក្តីអប់រំពេញមួយយប់ថ្ងៃសៅរ៍ ។

នៅចុងរាត្រីបុណ្យចម្លង គេធ្វើពិធីជ្រមុជទឹកជូនពួកគេ ។ កាលអ្នកទទួលអគ្គសញ្ញាជ្រមុជទឹកស្លៀកពាក់សម្លៀកបំពាក់ឡើងវិញរួចហើយ លោកអភិបាលដាក់ដៃនិងលាបប្រេងជូនគេ ។ ពិធីលាបប្រេងចុងក្រោយនេះ ជាដើមកំណើតនៃអគ្គសញ្ញាលាបថ្ងាស ដែលគ្រីស្តបរិស័ទធ្វើនៅសតវត្សក្រោយៗ ។ អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកថ្មីៗ ទទួលអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធ ជាពិធីបញ្ចប់ការអប់រំឲ្យទៅជាគ្រីស្តបរិស័ទ ។

នៅក្នុងព្រះសហគមន៍ជាច្រើន អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកតែងតែស្លៀកពាក់ពណ៌ស អស់មួយអាទិត្យ ។ ព្រះសហគមន៍ខ្លះ អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកថ្មីពាក់មកុដធ្វើអំពីស្លឹកឈើស្រស់ គេទទួលទានទឹកដោះគោនិងទឹកឃ្មុំ ជាពិធីរំឭកគេថា គេទើបតែមកដល់ទឹកដីសន្យា គឺចូលព្រះសហគមន៍ហើយ ។

គេធ្វើអគ្គសញ្ញាជ្រមុជទឹកជូនតែមនុស្សពេញវ័យប៉ុណ្ណោះ ។ ជួនកាលគេធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យក្មេងគ្រប់វ័យក៏បាន រួមជាមួយឪពុកម្តាយវា ឬប្រសិនបើឪពុកម្តាយវាជាគ្រីស្តបរិស័ទ ហើយគេក៏ធ្លាប់ធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យកូនដែរ ។ តែគ្រីស្តបរិស័ទខ្លះប្រឆាំង មិនព្រមធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យក្មេងៗជាដាច់ខាត ។ លោក**ទែរទូលីយ៉ាំង**ជាមេជាវីនៅក្រុងកាតាស្សជំទាស់ថា៖ «*មនុស្សមិនកើតជាគ្រីស្តបរិស័ទទេ គឺមនុស្សទៅជាគ្រីស្តបរិស័ទវិញ*» ។

## ㉓ អគ្គសញ្ញាជ្រមុជទឹកនៅសតវត្សទី ២

មានសៀវភៅមួយក្រោមចំណងជើងថា « **ឌីដាខេ** » (Didachè) (មានន័យថា «*ព្រះបន្ទូលប្រៀនប្រដៅរបស់ព្រះអម្ចាស់បញ្ជូនមកគ្រប់ជាតិសាសន៍តាមរយៈក្រុមសាវ័កទាំងដប់ពីរ*») ។ សៀវភៅនេះ ហាក់ដូចជាក្បួនមួយសម្រាប់អ្នកចេញទៅប្រកាសដំណឹងល្អ ។ គ្រីស្តបរិស័ទនិពន្ធសៀវភៅនេះនៅដើមសតវត្សទី ២ នៅស្រុកស៊ីរី ។ ក្នុងសៀវភៅនោះមានចែងអំពីការអប់រំសីលធម៌តាមរបៀប «*មាគ៌ាពីរ*» (*គឺសេចក្តីស្លាប់និងជីវិត*) ព្រមទាំងមានសេចក្តីខ្លះស្តីអំពីពិធីបុណ្យនានា និងពាក្យប្រៀនប្រដៅសម្រាប់អ្នកណែនាំទៀតផង ។

*ត្រូវធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ បន្ទាប់ពីបានបង្រៀនសេចក្តីទាំងអស់ខាងលើនេះ ត្រូវធ្វើដូចតទៅ «ចូរជ្រមុជគេក្នុងទឹករស់ក្នុងនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ» (មថ ២៩,១៩) ។ ប្រសិនបើគ្មានទឹករស់ទេ ចូរជ្រមុជគេក្នុងទឹកផ្សេងទៀត ។ បើគ្មានទឹកត្រជាក់ ចូរជ្រមុជក្នុងទឹកក្តៅ ។ បើអ្នកគ្មានទឹកទាំងនោះទេ សូមចាក់ទឹកលើក្បាលគេបីដង «ក្នុងនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ» ។ បើអាចធ្វើបាន អ្នកធ្វើអគ្គសញ្ញាជូនគេ អ្នកទទួលអគ្គសញ្ញា និងអ្នកផ្សេងទៀតតមអាហារ យ៉ាងហោចណាស់ក៏ត្រូវបញ្ជាឲ្យអ្នកទទួលអគ្គសញ្ញាតមអាហារមួយថ្ងៃ ឬពីរថ្ងៃមុនទទួលអគ្គសញ្ញាជ្រមុជទឹក ។»*

*ឌីដាខេ ៧*

Layout Histor.qxd 2/10/07 10:09 AM Page 46

## ㉔ អគ្គសញ្ញាជ្រមុជទឹកនៅសតវត្សទី ៣

លោក**ហ៊ីប៉ូលីត** (Hippolyte) ជាបូជាចារ្យព្រះសហគមន៍ក្រុងរ៉ូម នៅដើមសតវត្សទី ៣ ។ ជាច្រើនដង លោកតែងប្រឆាំងនឹងលោកអភិបាលព្រះសហគមន៍ក្រុងរ៉ូម រហូតដល់បង្កើតព្រះសហគមន៍មួយដាច់ឡែកពីគេ ។ លោកទទួលមរណភាពនៅ គ.ស. ២៣៥ ក្នុងឋានៈជាមរណសាក្សី ។ លោកសរសេរសៀវភៅផ្សេងៗប្រឆាំងនឹងអ្នកបែកចេញពីជំនឿ លោកសរសេរសេចក្ដីអត្ថាធិប្បាយអំពីព្រះគម្ពីរ ព្រមទាំងសរសេរសៀវភៅមួយក្រោមចំណងជើងថា «*សេចក្ដីប្រៀនប្រដៅទទួលតៗពីក្រុមគ្រីស្ដទូតមក*» ។ ក្នុងសៀវភៅនោះ លោករៀបរាប់អំពីពិធីនានាក្នុងព្រះសហគមន៍ក្រុងរ៉ូម ។

ពេលមាន់រងាវមុនដំបូង ត្រូវអធិដ្ឋានសូមព្រះជាម្ចាស់ប្រទានពរលើទឹក (...) អ្នកដែលហៀបទទួលអគ្គសញ្ញាជ្រមុជទឹកត្រូវស្រាត រួចត្រូវធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យក្មេងៗមុនគេ ។ អស់អ្នកដែលអាចនិយាយដោយខ្លួនឯងបាន សូមឲ្យគេនិយាយទៅ រីឯអស់អ្នកដែលមិនអាចនិយាយដោយខ្លួនឯងបាន សូមឪពុកម្ដាយឬបងប្អូនម្នាក់និយាយជំនួសគេ ។ បន្ទាប់មកទៀតត្រូវធ្វើអគ្គសញ្ញាជ្រមុជទឹកជូនបុរសៗ ។ នៅទីបញ្ចប់ ត្រូវធ្វើអគ្គសញ្ញាជ្រមុជទឹកជូនស្ត្រីៗ គឺក្រោយពីនាងស្រាយចំណងសក់ ដោះគ្រឿងអលង្ការចេញពីខ្លួន ។ ពេលចុះទឹក សូមកុំឲ្យនរណាម្នាក់ពាក់វត្ថុអ្វីជាប់នឹងខ្លួនឡើយ ។

ពេលកំណត់ធ្វើអគ្គសញ្ញាជ្រមុជទឹក លោកអភិបាលអរព្រះគុណព្រះជាម្ចាស់នៅលើប្រេង រួចលោកដាក់ប្រេងទៅក្នុងភាជន៍មួយ ។ គេហៅប្រេងនោះថា «ប្រេងអរព្រះគុណ» ។ លោកយកប្រេងផ្សេងទៀត ហើយធ្វើពិធីបណ្ដេញមារ ។ គេហៅប្រេងនោះថា «ប្រេងបណ្ដេញមារ» ។ ឧបដ្ឋាកម្នាក់យកប្រេងបណ្ដេញមារនេះមកឈរនៅខាងឆ្វេងលោកបូជាចារ្យ ។ ឧបដ្ឋាកម្នាក់ទៀតយកប្រេងអរព្រះគុណមកឈរនៅខាងស្ដាំលោកបូជាចារ្យ ។ លោកបូជាចារ្យហៅឈ្មោះអ្នកដែលត្រូវទទួលអគ្គសញ្ញាជ្រមុជទឹកម្នាក់ម្ដងៗ ហើយបង្គាប់ឲ្យគេលះបង់មារចោល ដោយម្នាក់ៗប្រកាសថា៖ «ខ្ញុំសូមលះបង់មារសាតាំងឯងចោល លះបង់កលល្បិចរបស់ឯងចោល លះបង់គ្រប់កិច្ចការរបស់ឯងចោលដែរ» ។ ក្រោយពីម្នាក់ៗ លះបង់ចោលមាររួចហើយ លោកបូជាចារ្យយកប្រេងមកលាបគេលើថ្ងាសទាំងពោលថា៖ «សូមមារអាក្រក់គ្រប់យ៉ាងចេញឆ្ងាយពីប្អូន» ។ រួចលោកបញ្ជូនគេទៅលោកអភិបាល ឬលោកបូជាចារ្យដែលនៅក្បែរទឹក ដើម្បីធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ ។

ឧបដ្ឋាកម្នាក់ចុះក្នុងទឹកជាមួយគេ ។ នៅពេលប្អូនដែលត្រូវទទួលអគ្គសញ្ញាជ្រមុជទឹកចុះក្នុងទឹករួចហើយ លោកដែលធ្វើអគ្គសញ្ញាជូនគេ ដាក់ដៃលើគេទាំងសួរថា៖ «តើប្អូនជឿលើព្រះជាម្ចាស់ជាព្រះបិតាដ៏មានតេជានុភាពសព្វប្រការឬទេ?» ។ អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកនោះឆ្លើយតបវិញថា៖ «ខ្ញុំជឿ» ។ ភ្លាមនោះលោកដែលធ្វើអគ្គសញ្ញាជូនគេ ដាក់ដៃលើក្បាលគេ និងជ្រមុជគេក្នុងទឹកជាលើកទីមួយ ។

បន្ទាប់មកលោកសួរថា៖ «តើអ្នកជឿលើព្រះយេស៊ូគ្រីស្ដជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលព្រះអង្គប្រសូតដោយព្រះវិញ្ញាណដ៏វិសុទ្ធ ពីព្រះនាងព្រហ្មចារិនីម៉ារី ព្រះអង្គត្រូវគេឆ្កាងនៅជំនាន់លោកប៉ុនពីឡាត ព្រះអង្គសោយទិវង្គត និងតើនឡើងពីក្នុងចំណោមមនុស្សស្លាប់នៅថ្ងៃទីបី មានព្រះជន្មគង់នៅយាងឡើងស្ថានបរមសុខ គង់នៅខាងស្ដាំព្រះបិតា ព្រះអង្គនឹងយាងមកវិញ ដើម្បីកាត់ក្ដីមនុស្សទាំងរស់ទាំងស្លាប់ឬទេ?» ។ អ្នកទទួលអគ្គសញ្ញាតបឆ្លើយថា «ខ្ញុំជឿ» រួចលោកបូជាចារ្យជ្រមុជគេក្នុងទឹកជាលើកទីពីរ ។

លោកសួរជាថ្មីទៀតថា៖ «តើអ្នកជឿលើព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅក្នុងព្រះសហគមន៍ដ៏វិសុទ្ធឬទេ?» ។ អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកនោះឆ្លើយតបថា៖ «ខ្ញុំជឿ» ពេលនោះលោកបូជាចារ្យជ្រមុជគេក្នុងទឹកជាលើកទីបី ។

បន្ទាប់មក នៅពេលគេឡើងពីទឹក លោកបូជាចារ្យយកប្រេងអរព្រះគុណមកលាបឲ្យគេ ទាំងមានប្រសាសន៍ថា៖ «ខ្ញុំលាបប្អូនដោយប្រេងក្នុងនាមព្រះយេស៊ូគ្រីស្ដ» ។ បន្ទាប់មកអ្នកដែលបានទទួលអគ្គសញ្ញាជ្រមុជទឹករួច ជូតខ្លួន ស្លៀកពាក់ឡើងវិញ ហើយចូលព្រះវិហារ ។

លោកអភិបាលដាក់ដៃលើពួកគេទាំងអង្វរថា៖ «បពិត្រព្រះអម្ចាស់! ព្រះអង្គប្រោសប្រណីលើកលែងទោសឲ្យអ្នកទាំងនេះដោយពិធីជ្រមុជទឹក ដើម្បីឲ្យគេកើតជាថ្មី សូមទ្រង់ព្រះមេត្តាប្រោសឲ្យពួកគេបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ សូមប្រណីសន្ដោសដល់ប្អូនទាំងនេះ ដើម្បីឲ្យគេបម្រើព្រះអង្គតាមព្រះហឫទ័យព្រះអង្គ ។ សូមព្រះអង្គជាព្រះបិតា និងព្រះបុត្រា រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ បានប្រកបដោយសិរីរុងរឿងក្នុងព្រះសហគមន៍នៅពេលនេះ ហើយរហូតតរៀងទៅ ។ អាម៉ែន ។»

បន្ទាប់មក លោកអភិបាលចាក់ប្រេងអរព្រះគុណ ដាក់ដៃលើពួកគេ ទាំងមានប្រសាន៍ថា៖ «ខ្ញុំយកប្រេងដ៏វិសុទ្ធចាក់លើប្អូន ដើម្បីឲ្យប្អូនរួមជាមួយព្រះជាម្ចាស់ជាព្រះបិតាដ៏មាន

● ● ●

Layout Histor.qxd 2/10/07 10:09 AM Page 47

*ឫទ្ធានុភាពសព្វប្រការ ជាមួយព្រះគ្រីស្តយេស៊ូ និងជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ» ។*

*បន្ទាប់ពីដៅចំណាំពួកគេលើថ្ងាសហើយ លោកអភិបាលជើបគេ ទាំងមានប្រសាសន៍ថា៖ «សូមព្រះអម្ចាស់គង់នៅជាមួយប្អូន» ។ អ្នកដែលបានទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយឆ្លើយតបថា៖ «ហើយជាមួយលោកផង» ។ លោកអភិបាលធ្វើដូច្នេះម្នាក់ម្តងៗ ។*

*តាំងពីពេលនេះតទៅ ពួកគេអធិដ្ឋានរួមជាមួយប្រជារាស្ត្រទាំងមូល ។*

*លោកហ៊ីប៉ូលីត នៅក្រុងរ៉ូម*
*«សេចក្តីប្រៀនប្រដៅទទួលតៗពីក្រុមគ្រីស្តទូតមក»*

## ៣- អគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធ ឬពិធីលើកតម្កើងព្រះអម្ចាស់យេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង

នៅរៀងរាល់ថ្ងៃអាទិត្យ គ្រីស្តបរិស័ទតែងតែនាំគ្នាធ្វើពិធីនឹករលឹកអំពីព្រះជាម្ចាស់ប្រោសលោកយេស៊ូឲ្យក្រោកឡើងពីក្នុងចំណោមមនុស្សស្លាប់ ។ នៅថ្ងៃអាទិត្យជាថ្ងៃទីមួយក្នុងសប្តាហ៍ គឺព្រះជាម្ចាស់បង្កើតពិភពលោកជាថ្មី ដូចព្រះអង្គបានបង្កើតពិភពលោកនៅថ្ងៃដំបូងបង្អស់ដែរ ។ តែថ្ងៃអាទិត្យក៏ជាថ្ងៃទី ៨ ដែរ គឺជាថ្ងៃបង្ហើយពេលវេលា នៅពេលព្រះគ្រីស្តយាងមកវិញ ។

### *ក- ថ្ងៃបុណ្យចម្លង*

នៅថ្ងៃបុណ្យចម្លង គេប្រារព្ធពិធីយ៉ាងឱឡារិកជាងគេ គឺគេនាំគ្នារំលឹកអំពីព្រះអម្ចាស់តើនពីក្នុងចំណោមមនុស្សស្លាប់ ទទួលព្រះជន្មថ្មីដ៏រុងរឿង ។ មុនដំបូងប្រហែលមានតែគ្រីស្តបរិស័ទនៅបូព៌ាប្រទេសទេធ្វើពិធីបុណ្យចម្លងនោះ រីឯគ្រីស្តបរិស័ទនៅបស្ចិមប្រទេសគ្រាន់តែប្រារព្ធពីធីរៀងរាល់ថ្ងៃអាទិត្យវិញ ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅចុងសតវត្សទី ២ គ្រីស្តបរិស័ទនាំគ្នាប្រារព្ធពិធីបុណ្យចម្លងគ្រប់ៗគ្នា តែកាលបរិច្ឆេទមិនត្រូវគ្នាទេ ។ ស្រុកខ្លះគឺនៅខាងបូព៌ា គ្រីស្តបរិស័ទនាំគ្នាធ្វើបុណ្យចម្លងរួមជាមួយជនជាតិយូដា ស្រុកផ្សេងៗទៀត គេប្រារព្ធបុណ្យព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង នៅថ្ងៃអាទិត្យក្រោយបុណ្យចម្លងរបស់ជនជាតិយូដាវិញ ។ គ្រីស្តបរិស័ទនាំគ្នាជជែកវែកញែកអំពីកាលបរិច្ឆេទនេះ ។ លោក**អ៊ីរេណេ**ជាអភិបាលព្រះសហគមន៍ក្រុងលីយ៉ុង ខិតខំធ្វើឲ្យគ្រីស្តបរិស័ទស្រុះស្រួលគ្នា ឈប់ឈ្លោះគ្នាអំពីរឿងនេះ ។ ប្រហែលនៅ គ.ស. ១៩០ គ្រីស្តបរិស័ទកំណត់យកថ្ងៃអាទិត្យ ក្រោយបុណ្យចម្លងរបស់ជនជាតិយូដា ធ្វើជាថ្ងៃរំលឹកអំពីព្រះគ្រីស្តទទួលព្រះជន្មថ្មីដ៏រុងរឿង ។



*សត្វហ្វេនិកដែលមានឈ្មោះល្បីថាស្លាប់ហើយរស់ឡើងវិញ ជានិមិត្តរូបអំពីព្រះយេស៊ូ*

Layout Histor.qxd 2/10/07 10:09 AM Page 48

### *ខ- អគ្គសញ្ញាអរព្រះគុណជីវិសុទ្ធ*

នៅថ្ងៃអាទិត្យ ជាពិសេសថ្ងៃបុណ្យចម្លង គ្រីស្តបរិស័ទនាំគ្នានឹករឭកអំពីព្រះអម្ចាស់ធ្វើពិធីជប់លៀងចុងក្រោយបង្អស់ដែលគេហៅថា «*ពិធីកាច់នំបុ័ង*» ជាពិធីអរព្រះគុណរួមជាមួយព្រះយេស៊ូដែលសោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿង ។ នៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី មានចែងបន្តិចបន្តួចអំពីពិធី «*កាច់នំបុ័ង*» (*កក ២,៤២; ២០,៧-១១; ២៧, ៣៥; ១ ករ ១០,១៦; ១១,១៧-៣៣*) ។ លោកទេសាភិបាល
18 រ៉ូម៉ាំង**ព្លីន**ចាប់អារម្មណ៍អំពីពិធីជប់លៀងនេះ នៅពេលលោកស៊ើបអង្កេតអំពីគ្រីស្តបរិស័ទ ។ អ្នកនិពន្ធសៀវភៅ**ឌីដាខេ** សុំឲ្យអ្នកចូលរួមក្នុងពិធីនេះសារភាពអំពើបាបរបស់ខ្លួនជាមុនសិន ។ នៅក្នុងលិខិតលោក**យូស្តាំង** មានចែងអំពីរបៀបធ្វើពិធីអរព្រះគុណប្រហែលនឹងយើងប្រារព្ធសព្វថ្ងៃដែរ ។ គ្រីស្តបរិស័ទតែងវែក
25 ញែកអំពីគម្ពីរ (Homélie សព្វថ្ងៃហៅថា "*ធម្មទេសនា*" ឬ "*អធិប្បាយ*") ជារបៀបអប់រំជំនឿរបស់គ្រីស្តបរិស័ទថ្មី ។ ក្នុង «*ពិធីវែកញែក*» នេះ គ្រីស្តបរិស័ទរិះគិតអំពីទំនាក់ទំនងគម្ពីរសម្ពន្ធមេត្រីចាស់ជាមួយព្រះយេស៊ូ និងដាស់តឿនគ្នាឲ្យប្រព្រឹត្តតាមសីលធម៌ ។ រីឯលោក**ហ៊ីប៉ូលីត**វិញ លោកបង្ហាញអំពីរចនាសម្ពន្ធសម្រាប់ពិធីអរព្រះគុណ តែលោកទុកឲ្យអធិបតីអង្គប្រជុំបង្កើតធម៌អរព្រះគុណតាមខ្លួននឹកឃើញដោយឥតព្រាងទុកជាមុន ។

គ្រីស្តបរិស័ទទទួលយកនំបុ័ងប្រសិទ្ធិនៅលើបាតដៃ ហើយលោកអភិបាលព្រះសហគមន៍ ពោលទៅអ្នកដែលទទួលនំប្រសិទ្ធិនេះថា «*អាហារដែលចុះពីស្ថាន*
*បរមសុខក្នុងព្រះគ្រីស្តយេស៊ូ*» ។ អ្នកទទួលឆ្លើយថា «*អាម៉ែន*» ។ របៀបនេះក៏ 26
ជារបៀបសព្វថ្ងៃដែរ ។ គ្រីស្តបរិស័ទតែងតែរក្សាទុកនំប្រសិទ្ធិក្នុងពិធីអរព្រះគុណតាមផ្ទះរៀងៗខ្លួន ។ ពួកគេទទួលទាននំប្រសិទ្ធិមុនពេលបរិភោគអាហារធម្មតា ។ គេតែងបាច់ទុកនំប្រសិទ្ធិក្នុងពិធីអរព្រះគុណដូចជាឱសថម៉្យាង ។


*របៀបអធិដ្ឋានគ្រីស្តបរិស័ទដើមដំបូង*

25

## អគ្គសញ្ញាអរព្រះគុណនៅសតវត្សទី ២

នៅពាក់កណ្តាលសតវត្សទី ២ លោក**យូស្តាំង** (Justin) មានបំណងឆ្លើយតបនឹងអស់អ្នកដែលចោទថា គ្រីស្តបរិស័ទប្រព្រឹត្តខុសសីលធម៌ពេលគេរួមគ្នាធ្វើពិធីនានា ។ លោកនិពន្ធលិខិតមួយថ្វាយព្រះចៅអធិរាជ**អង់តូណាំង** (Antonin) ក្រោមចំណងជើងថា «*សេចក្តីការពារគ្រីស្តបរិស័ទ*» ។ លោកចែងថា «*ក្នុងចំណោមយើងខ្ញុំគ្មានអ្វីដ៏អាថ៌កំបាំងឡើយ ខ្ញុំសូមរៀបរាប់អំពីរបៀបយើងធ្វើពិធីរបស់យើង*» ។ ដូច្នេះលោកនាំយើងឲ្យស្គាល់របៀបគេធ្វើអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាអរព្រះគុណនៅសតវត្សទី ២ ។

នៅក្នុងអត្ថបទខាងក្រោមនេះ យើងឃើញរបៀបអភិបូជាដូចយើងធ្លាប់ធ្វើសព្វថ្ងៃដែរ គឺមានពិធីលើកតម្កើងព្រះបន្ទូល (*ថ្លែងអត្ថបទគម្ពីរ សេចក្តីអត្ថាធិប្បាយ ពាក្យអធិដ្ឋានសាកល*) និងពិធីអរព្រះគុណ ។

*នៅថ្ងៃដែលគេហៅថា «ថ្ងៃអាទិត្យ» គ្រីស្តបរិស័ទទាំងអស់ទាំងនៅទីក្រុង ទាំងនៅជនបទ តែងតែជួបជុំគ្នានៅកន្លែងតែមួយ ។ ពួកគេនាំគ្នាអានសេចក្តីដែលអស់គ្រីស្តទូតកត់ត្រាទុក និងពាក្យប្រៀនប្រដៅរបស់ព្យាការីទាំងឡាយ ។ គេអានយ៉ាងយូរអស់ពីចិត្តរបស់គេ ។*

•••

Layout Histor.qxd 2/10/07 10:09 AM Page 49

នៅពេលគេអានចប់ លោកអធិបតីប្រៀនប្រដៅ ដើម្បីរំឭក និងដាស់តឿនគេឲ្យអនុវត្តតាមសេចក្ដីប្រៀនប្រដៅដ៏ប្រសើរទាំងនោះ ។

បន្ទាប់មក យើងក្រោកឈរឡើង ហើយអធិដ្ឋានរួមគ្នាដោយបន្លឺសំឡេង ។ (...) លុះអធិដ្ឋានរួចហើយ មានគេយកនំប៉័ង ស្រា និងទឹកមក ។ លោកអធិបតីបន្លឺពាក្យអធិដ្ឋានឡើង និងពាក្យអរព្រះគុណអស់ពីចិត្តរបស់លោក ហើយប្រជាជនទាំងមូលតបឆ្លើយទាំងអបអរសាទរដោយថ្លែងថា «អាម៉ែន» ។

បន្ទាប់មកទៀត គេចែកចំណិតនំប៉័ងនិងស្រាដែលលោកអធិបតីបានប្រសិទ្ធិ និងអរព្រះគុណនោះ ឲ្យគ្រីស្តបរិស័ទម្នាក់ៗ ហើយគេក៏យកមួយចំណែកទៀត ឲ្យលោកឧបដ្ឋាកយកទៅជូនអស់អ្នកដែលពុំបានមកចូលរួមប្រជុំ ។

គ្រីស្តបរិស័ទមានបំណងចែកអ្វីដែលខ្លួនមានដោយការងារដែលគេធ្វើ ហើយប្រមូលអ្វីៗទាំងនោះ ប្រគល់ជូនលោកអធិបតី ។ លោកយកទៅជួយក្មេងកំព្រា ស្ត្រីមេម៉ាយ អ្នកជំងឺ អ្នកក្រតោកយ៉ាក អ្នកជាប់ឃុំឃាំង ជនបរទេស ។ សរុបទៅ គឺលោកជួយមនុស្សទាំងអស់ដែលមានទុក្ខលំបាក និងដែលត្រូវការឲ្យគេជួយ ។

យើងតែងតែជួបជុំគ្នារៀងរាល់ថ្ងៃអាទិត្យ ព្រោះជាថ្ងៃដើមដំបូង គឺព្រះជាម្ចាស់បានបង្កើតពិភពលោកថ្មីចេញពីភាពងងឹតនៅថ្ងៃនោះ ។ នៅថ្ងៃដដែលនោះ ព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះនៃយើង តើនពីក្នុងចំណោមមនុស្សស្លាប់ ។

មុនចែងសេចក្ដីនេះ លោក**យូស្ដាំង**បញ្ជាក់ពីលក្ខណៈខ្លះរបស់មនុស្សដែលមានសិទ្ធិចូលរួមក្នុងពិធីអរព្រះគុណ គឺមិនមែនជាពិធីជប់លៀងធម្មតាទេ ។

យើងតែងតែហៅអាហារនេះថា «អរព្រះគុណ» ហើយគ្មាននរណាម្នាក់អាចចូលរួមទទួលទានបានទេ ។ គេត្រូវប្រកាសសេចក្ដីពិតតាមជំនឿរបស់យើង ហើយត្រូវទទួលពិធីជ្រមុជទឹកដើម្បីឲ្យរួចពីបាប និងមានជីវិតជាថ្មីសិន ទើបទទួលទានបាន និងត្រូវរស់នៅស្របតាមព្រះបញ្ញារបស់ព្រះគ្រីស្តដែរ ។ យើងមិនបរិភោគអាហារនេះដូចជានំប៉័ងនិងភេសជ្ជៈធម្មតាទេ ។ ដោយអានុភាពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះនៃយើង ព្រះអង្គប្រសូតជាមនុស្សពិតប្រាកដយ៉ាងណា អាហារដែលប្រសិទ្ធិដោយពាក្យអធិដ្ឋាន យោងពីព្រះបន្ទូលរបស់ព្រះគ្រីស្ត ហើយដែលចិញ្ចឹមយើង ក៏ពិតជាព្រះកាយនិងព្រះលោហិតរបស់ព្រះបន្ទូល ដែលប្រសូតមកជាមនុស្សយ៉ាងនោះដែរ ។

លោកយូស្ដាំង "សេចក្ដីការពារគ្រីស្តបរិស័ទ" ៦៧ និង ៦៦

## (26) ពាក្យអរព្រះគុណនៅដើមសតវត្សទី ៣

លោក**ហ៊ីប៉ូលីត** ចម្លងអត្ថបទនេះពីឯកសារបុរាណមួយទុក ។ តាំងពីសតវត្សទី ៤ រហូតមក គ្រីស្តបរិស័ទបញ្ចូលបទចម្រៀង «ព្រះដ៏វិសុទ្ធ» នៅខាងមុខធម៌អរព្រះគុណ ។ នៅកណ្ដាលសតវត្សទី ៥ គេច្រៀងបទនេះជាទូទៅ ។

លោកឧបដ្ឋាកយកតង្វាយទៅជូនលោកអភិបាលព្រះសហគមន៍ ។ រួចលោកអភិបាលរួមជាមួយក្រុមបូជាចារ្យដាក់ដៃលើតង្វាយទាំងនេះ ហើយមានប្រសាសន៍ទាំងអរព្រះគុណថា៖ «សូមព្រះអម្ចាស់គង់ជាមួយបងប្អូន» ។
គ្រីស្តបរិស័ទទាំងអស់ឆ្លើយថា៖ «ហើយជាមួយលោកផង» ។
«សូមលើកចិត្តថ្វាយព្រះអង្គ»
«យើងលើកចិត្តថ្វាយព្រះអង្គហើយ»
«សូមអរព្រះគុណព្រះអម្ចាស់»
«ពិតជាការគួរណាស់ហើយប្រពៃផង» ។

លោកបន្តទៀតថា៖ «បពិត្រព្រះជាម្ចាស់! យើងខ្ញុំសូមអរព្រះគុណព្រះអង្គ រួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ដែលព្រះអង្គបាត់ឲ្យយាងមកនៅពេលចុងក្រោយបង្អស់នេះ ទុកជាព្រះសង្គ្រោះដែលរំដោះយើងខ្ញុំ និងនាំដំណឹងអំពីគម្រោងការណ៍របស់ព្រះអង្គ ។ ព្រះបុត្រាជាព្រះបន្ទូលផ្ទាល់របស់ព្រះអង្គ ព្រះអង្គក៏បង្កើតអ្វីៗទាំងអស់តាមតែព្រះហឫទ័យ ព្រះអង្គចាត់ព្រះបុត្រាពីស្ថានបរមសុខមកឲ្យចាប់ផ្ទៃនឹងស្ត្រីព្រហ្មចារិនីម្នាក់ ។ ទ្រង់បានប្រសូតជាមនុស្ស ហើយសម្ដែងឲ្យមនុស្សលោកដឹងថា ទ្រង់ជាព្រះបុត្រារបស់ព្រះអង្គ ដែលប្រសូតដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយស្ត្រីព្រហ្មចារិនី ។ ព្រះបុត្រាធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ បានរំដោះប្រជារាស្ត្រមួយដ៏វិសុទ្ធថ្វាយព្រះអង្គ ទ្រង់លាតព្រះហស្តនៅពេលរងទុក្ខ ដើម្បីរំដោះអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គបានរួចពីការឈឺចាប់ ។

ពេលទ្រង់សព្វព្រះហឫទ័យរងទុក្ខលំបាក ដើម្បីបំផ្លាញសេចក្ដីស្លាប់ បំបាក់ប្រវ៉ាក់របស់មារបោល ហើយជាន់ឈ្លីនរកព្រមទាំងនាំមនុស្សសុចរិតទៅកាន់ពន្លឺដោយមានសង្ឃឹមថា នឹងទទួលជីវិតថ្មី ទ្រង់យកនំប៉័ងមកកាន់ អរព្រះគុណព្រះបិតា •••

Layout Histor.qxd 2/10/07 10:09 AM Page 50

*ទាំងមានព្រះបន្ទូលថា៖ «សូមអ្នករាល់គ្នាយកពិសាចុះ នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា» ។ ព្រះអង្គធ្វើតាមរបៀបដដែល ទ្រង់យកពែងស្រាឡើង ទាំងមានព្រះបន្ទូលថា៖«នេះជាលោហិតរបស់ខ្ញុំ ដែលត្រូវគេបង្ហូសម្រាប់អ្នករាល់គ្នា ។ ពេលអ្នករាល់គ្នាធ្វើដូច្នេះ សូមនឹករឭកដល់ខ្ញុំ» ។*

*ដូច្នេះ យើងខ្ញុំសូមនឹករឭកអំពីព្រះបុត្រាសោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿង ។ យើងខ្ញុំសូមថ្វាយនំបុ័ងនិងស្រានេះ ទាំងអរព្រះគុណព្រះអង្គ ដ្បិតព្រះអង្គប្រោសប្រណីដល់យើងខ្ញុំឲ្យបម្រើព្រះអង្គ និងឈរនៅចំពោះព្រះភ័ក្ត្រព្រះអង្គក្នុងឋានៈជាបូជាចារ្យ ។*

*យើងខ្ញុំសូមអង្វរព្រះអង្គ សូមទ្រង់ព្រះមេត្តាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ លើតង្វាយរបស់ព្រះសហគមន៍ដ៏វិសុទ្ធនេះ ។ សូមទ្រង់ព្រះមេត្តាប្រមូលផ្ដុំអស់អ្នកដែលចូលរួមក្នុងពិធីដ៏វិសុទ្ធនេះ បានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យគេមានជំនឿកាន់តែមាំមួនឡើងនៅក្នុងសេចក្ដីពិត ដើម្បីឲ្យយើងខ្ញុំលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ រួមជាមួយព្រះយេស៊ូគ្រីស្ដជាព្រះបុត្រាព្រះអង្គ គឺដោយព្រះបុត្រា យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿង និងព្រះកិត្តិនាមថ្វាយព្រះអង្គ រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ក្នុងព្រះសហគមន៍ដ៏វិសុទ្ធនាពេលនេះ និងនៅអស់កល្បជាអង្វែងតរៀងទៅ ។ អាម៉ែន ។*

*លោកអភិបាលអរព្រះគុណព្រះជាម្ចាស់ ដូចចែងខាងលើ ប៉ុន្តែ មិនបាច់ឲ្យលោកពោលពាក្យអរព្រះគុណព្រះជាម្ចាស់ដោយរត់មាត់ តាមពាក្យដែលយើងសរសេរនោះទេ ។ ម្នាក់ៗត្រូវអធិដ្ឋានដោយអស់ពីចិត្តរៀងៗខ្លួន ។ បើនរណាម្នាក់អធិដ្ឋានបានវែង និងអធិដ្ឋានយ៉ាងឱឡារិក ល្អហើយ! ។ តែបើមានម្នាក់ទៀតពោលពាក្យអធិដ្ឋានខ្លីក៏បានដែរ ឲ្យតែគេពោលពាក្យអធិដ្ឋានយ៉ាងត្រឹមត្រូវតាមលទ្ធិគ្រីស្ដសាសនា ។*

*លោកហ៊ីប៉ូលីត នៅរ៉ូម*

*"សេចក្ដីប្រៀនប្រដៅទទួលតៗពីក្រុមគ្រីស្ដទូតមក" ៤ និង ៩ ។*

## ៤- អគ្គសញ្ញាលើកលែងទោស

ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មីមានចែងថា ព្រះជាម្ចាស់លើកលែងទោសឲ្យមនុស្សនៅពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក *(កក ២,៣៨)* ។ ប៉ុន្តែ ព្រះយេស៊ូប្រទានឲ្យក្រុមគ្រីស្ដទូតទាំងដប់ពីរនាក់ និងឲ្យព្រះសហគមន៍ទាំងមូលមានអំណាចលើកលែងទោស ព្រមទាំងដេញអ្នកបាបចេញពីព្រះសហគមន៍ *(យហ ២០,២២-២៣; មថ ១៦,១៨-១៩ និង១៨,១៥-១៨)* ។ គ្រីស្ដទូត**ប៉ូល**សូមឲ្យគេដកមនុស្សប្រព្រឹត្តអំពើខុសសីលធម៌ធ្ងន់ធ្ងរចេញពីព្រះសហគមន៍ក្រុងកូរិនថូស *(១ ករ ៥)* ។ តើគេអាចលើកលែងទោសអ្នកបាបទាំងអស់បានឬទេ? អត្ថបទខ្លះមានអត្ថន័យមិនច្បាស់ ហើយគ្រីស្ដបរិស័ទបកស្រាយតាមរបៀបផ្សេងៗពីគ្នា ។ *(មថ ១២,៣១-៣២; ១ យហ ៥,១៦-១៧; ហប ៦,៤-៦ និង ១០,២៦-៣១)*

នៅសតវត្សទី ២ អ្នកនិពន្ធសៀវភៅ**ឪដាខេ** *(៤,១៤ និង ១៤,១)* ដាស់តឿនគ្រីស្ដបរិស័ទឲ្យ *«លន់តួបាបរបស់ខ្លួន»* មុនអធិដ្ឋាននិងមុនទទួលអគ្គសញ្ញាអរព្រះគុណ ។ អ្នកទទួលអគ្គសញ្ញាជ្រមុជទឹករួច មិនត្រូវប្រព្រឹត្តអំពើបាបទៀតទេ ប៉ុន្តែ មនុស្សទន់ខ្សោយណាស់ ។

នៅសតវត្សទី ២ គ្រីស្ដបរិស័ទយល់ព្រមទាំងទើសទាល់ ប្រោសប្រណីដល់
អ្នកប្រព្រឹត្តបាបធ្ងន់ *(បោះបង់ជំនឿ ឃាតកម្ម ប្រាសចាកសីលធម៌ជាដើម)* តែ 27
គេប្រោសប្រណីតែមួយដងគត់ក្នុងមួយជីវិត ។ គេយល់ដូច្នេះ ដោយនឹកគិតអំពី
អគ្គសញ្ញាជ្រមុជទឹក គឺពេលគេធ្វើពិធីលើកលែងទោស គេហាក់ដូចជាទទួលអគ្គ
សញ្ញាជ្រមុជទឹកសាជាថ្មី ។ មុនដំបូងលោក**ទែរទូលីយ៉ាំង**យល់ស្រប ។ ក្រោយមក
លោកយល់ឃើញវិញថា មិនត្រូវប្រណីដល់អ្នកប្រផិតក្បត់ស្វាមី-ភរិយាជាដាច់
ខាត ។ ពេលព្រះចៅ**ដេស្ស**ធ្វើទុក្ខបុកម្នេញគ្រីស្ដបរិស័ទ *(គ.ស. ២៥០)* គ្រីស្ដ 28
បរិស័ទខ្វែងគំនិតគ្នា អំពីការលើកលែងទោសដល់អ្នកដែលលះបង់ជំនឿបោល ។
ក្នុងព្រះសហគមន៍ក្រុងរ៉ូមនិងក្រុងកាតាស្ស គ្រីស្ដបរិស័ទខ្លះមានចិត្តអធ្យាស្រ័យ
ច្រើន នេះជាមូលហេតុនាំឲ្យព្រះសហគមន៍បែកគ្នា និងកើតនិកាយផ្សេងៗ ។
ប៉ុន្តែ យើងមិនសូវដឹងច្បាស់អំពីរបៀបព្រះសហគមន៍ធ្វើពិធីលើកលែងទោសនៅ
ក្នុងកំឡុង ៣ សតវត្សខាងដើមដំបូងទេ ។

Layout Histor.qxd 2/10/07 10:09 AM Page 51

## 27 គ្រីស្តបរិស័ទមិនត្រូវប្រព្រឹត្តអំពើបាបទៀតឡើយ

លោក**ហែរម៉ាស់** (Hermas) សន្ទនាជាមួយទេវទូតដែលលើកលែងទោសឲ្យមនុស្ស គឺជាមួយលោកគង្វាល *(សូមអានសេចក្តីអត្ថាធិប្បាយត្រង់អត្ថបទទី ១)* ។

*លោកហែរម៉ាស់៖ ខ្ញុំឮគ្រូអាចារ្យខ្លះនិយាយថា ពេលយើងចូលក្នុងទឹក គឺនៅថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក ព្រះអង្គនឹងលើកលែងទោសឲ្យយើងចំពោះអំពើបាប ដែលយើងបានប្រព្រឹត្តកាលពីពេលមុនៗ ។ ក្រោយមក ព្រះជាម្ចាស់មិនលើកលែងទោសទៀតទេ ។*

*លោកគង្វាល៖ លោកឮច្បាស់ហើយ! ពិតដូច្នោះមែន! អ្នកដែលព្រះជាម្ចាស់លើកលែងទោសឲ្យនៅពេលគេទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយ មិនត្រូវប្រព្រឹត្តអំពើបាបទៀតឡើយ តែត្រូវរស់នៅយ៉ាងបរិសុទ្ធ ។ ប៉ុន្តែ ព្រះអម្ចាស់ឈ្វេង យល់ចិត្តគំនិតមនុស្ស ព្រះអង្គជ្រាបនូវអ្វីៗទាំងអស់ជាមុនថា មនុស្សទន់ខ្សោយ ហើយមារក៏មានកលល្បិចយ៉ាងខ្លាំង (...) ។ ដូច្នេះ ព្រះអម្ចាស់ប្រកបដោយព្រះហឫទ័យមេត្តាករុណាយ៉ាងលើសលប់ ព្រះអង្គអាណិតអាសូរដល់សត្វលោកដែលទ្រង់បានបង្កើត ហើយបាត់ចែងការលើកលែងទោស ទ្រង់ក៏ប្រទានអំណាចឲ្យខ្ញុំលើកលែងទោសបែបនេះថែមទៀត ។ ហេតុនេះហើយ បានជាខ្ញុំសូមប្រកាសថា ប្រសិនបើនរណាម្នាក់ចាញ់ការល្បួង និងបែរជាធ្លាក់ក្នុងអំពើបាប ក្រោយពីព្រះអង្គបានត្រាស់ហៅគេយ៉ាងឱឡារិក និងយ៉ាងសំខាន់នោះ ព្រះជាម្ចាស់លើកលែងទោសឲ្យអ្នកនោះតែម្តងគត់ ។ បើគេប្រព្រឹត្តអំពើបាបសាជាថ្មី ទោះបីគេស្តាយក្រោយក្តី ក៏ការនឹកស្តាយក្រោយនោះគ្មានប្រយោជន៍ទៀតទេ គេនឹងជួបការលំបាកក្នុងការរស់នៅ ។*

*លោកហែរម៉ាស "លោកគង្វាល" ១១,១-៦*

## 28 ទុក្ខវេទនាដ៏លំបាក

លោក**ទែរទូលីយ៉ាំង** ទទួលស្គាល់ថា ព្រះជាម្ចាស់អាចលើកលែងទោសចំពោះអំពើបាបធ្ងន់មួយដងក្នុងមួយជីវិត ។ ក្រោយពេលលោកចូលក្នុងនិកាយមួយដែលកាន់កិរិយាយ៉ាងតឹងរ៉ឹង លោកយល់ឃើញថា ព្រះសហគមន៍មិនអាចលើកលែងទោសចំពោះអំពើបាបខ្លះ មានបទប្រាសចាកសីលធម៌ជាដើម ។

*ព្រះជាម្ចាស់លើកលែងទោសលើកទីពីរនោះតែមួយដងគត់ ហើយការលើកលែងទោសនោះក៏មានព្រំដែនដែរ ។ អ្នកបាបក៏ត្រូវរងទុក្ខវេទនាដ៏លំបាកយ៉ាងធ្ងន់ដែរ ។ អ្នកដែលចង់ឲ្យព្រះជាម្ចាស់លើកលែងទោសឲ្យ មិនគ្រាន់តែប្រែចិត្តគំនិតប៉ុណ្ណោះទេ គឺត្រូវតែប្រព្រឹត្តកិច្ចការថែមទៀត ។ កិច្ចការនោះ (...) គឺការលន់តួបាបរបស់ខ្លួនចំពោះព្រះជាម្ចាស់ (...) ។*

*ព្រះអង្គដាក់វិន័យថា អ្នកបាបត្រូវក្រាបដល់ដី និងដាក់ខ្លួន ។ ព្រះអង្គក៏បញ្ជាអ្នកបាបនោះឲ្យរស់នៅតាមរបៀបគួរឲ្យទ្រង់អត់ទោសឲ្យបាន ។ ចំណែកឯសម្លៀកបំពាក់និងម្ហូបអាហារ វិន័យបញ្ជាឲ្យអ្នកបាបដេកលើបាវ និងនៅលើផេះ ឲ្យស្លៀកពាក់រហែករយីរយៃ ពណ៌ស្រអាប់ ។ អ្នកបាបនោះត្រូវសុខចិត្តឈឺចាប់ ប្រែចិត្តគំនិត ដោយធ្វើបាបខ្លួនយ៉ាងតឹងរ៉ឹង (...) ។ តាមធម្មតា ការប្រែចិត្តគំនិតតែងតែពង្រឹងពាក្យអធិដ្ឋានរបស់គេដោយតមអាហារ ត្អូញត្អែរ យំស្រែកអង្វរព្រះអម្ចាស់ ជាព្រះរបស់គេទាំងយប់ទាំងថ្ងៃ គាត់រមៀលខ្លួននៅជិតជើងក្រុមបូជាចារ្យ លុតជង្គង់នៅមុខអស់អ្នកបម្រើព្រះជាម្ចាស់ សុំបងប្អូនទាំងអស់រួមគ្នាអង្វរព្រះជាម្ចាស់ឲ្យគាត់ផង ។*

*លោកទែរទូលីយ៉ាំង "សៀវភៅស្តីអំពីការលើកលែងទោស"*

Layout Histor.qxd 2/10/07 10:09 AM Page 52

## ៥- អំពីការអធិដ្ឋាន និង ពិធីបុណ្យ

មេដឹកនាំព្រះសហគមន៍ជាច្រើន តែងតែដាស់តឿនគ្រីស្តបរិស័ទឲ្យអធិដ្ឋានច្រើនដងក្នុងមួយថ្ងៃ គឺពេលព្រឹក គ្រីស្តបរិស័ទត្រូវអធិដ្ឋានដោយបែរខ្លួនទៅទិសខាងកើត «*ជាទិសពន្លឺដ៏ពិតប្រាកដកើតមក*» ។ ម៉ោង ៩ ព្រឹក ថ្ងៃត្រង់ម៉ោង ៣ រសៀល ពេលថ្ងៃលិចដែលជាពេលអុជចង្កៀងក៏ត្រូវអធិដ្ឋានដែរ ។ តាមធម្មតា គ្រីស្តបរិស័ទតែងអធិដ្ឋានទាំងឈរ និងលើកដៃឡើងដោយលាតបាតដៃទៅលើ ។ គេក៏អធិដ្ឋាននៅពេលកំណត់ដ៏សំខាន់ៗប្រចាំជីវិតគេដែរ គឺចាប់តាំងពីកំណើតរហូតដល់ស្លាប់ ប៉ុន្តែ គ្មានកំណត់ពិធីមួយណាសម្រាប់ដំណាក់កាលនីមួយៗទេ ។ ឧប. នៅសតវត្សដើមដំបូង គ្រីស្តបរិស័ទគ្មានធ្វើពិធីអាពាហ៍ពិពាហ៍ តាមរបៀបគ្រីស្តសាសនាទេ ។

អ្នកនិពន្ធលិខិតផ្ញើទៅលោក**ឌីយ៉ូញ៉ែត** (Diognète) ថា៖ «*គ្រីស្តបរិស័ទរៀបអាពាហ៍ពិពាហ៍ដូចមនុស្សឯទៀតៗទាំងអស់*» ។ គ្រីស្តបរិស័ទផ្តល់អត្ថន័យថ្មីដល់ការរស់នៅជាគូស្វាមីភរិយា ប៉ុន្តែ គេកាន់តាមទំនៀមទម្លាប់ជាប្រពៃណី ដោយបោះបង់ឬកែប្រែពិធីណាដែលទាស់នឹងជំនឿរបស់ខ្លួន ។ គេបោទប្រកាន់ទម្លាប់ខ្លះក្នុងសីលធម៌ប្រចាំសម័យនោះ គឺគេមិនព្រមពន្លូតកូន មិនព្រមបោះបង់កូនបោល ។ គេអប់រំចិត្តគំនិតគូស្វាមីភរិយា ដោយយោងតាមសេចក្តីប្រៀនប្រដៅរបស់គ្រីស្តទូតប៉ូល (អភ ៥) មក ។ គ្រីស្តបរិស័ទជាគូស្វាមីភរិយាមិនលែងលះគ្នា គឺពិតជាកាន់កិរិយាថ្មីក្នុងសង្គមនាសម័យនោះ ។ គេយល់ឃើញថា ត្រូវឲ្យគូស្វាមីភរិយាកាន់ជំនឿតែមួយដូចគ្នា ។ នៅសតវត្សដំបូង គ្រីស្តបរិស័ទតែងតែអធិដ្ឋាន សូមព្រះជាម្ចាស់ប្រទានពរឲ្យគូស្វាមីភរិយា ប៉ុន្តែ ពាក្យអធិដ្ឋាននេះមិនទាន់ជាពិធីអាពាហ៍ពិពាហ៍នៅឡើយទេ ។

អស់លោកដែលទទួលខុសត្រូវលើព្រះសហគមន៍ ក៏តែងតែទៅសួរសុខទុក្ខអ្នកជំងឺ និងយកប្រេងប្រសិទ្ធិមកលាបអ្នកជំងឺ ។ អ្នកជំងឺក៏តែងពិសាប្រេងនេះទុកជាឱសថ ។ គ្រីស្តបរិស័ទតែងគោរពមរណបុគ្គល ដូចអ្នកស្រុកឯទៀតៗក្នុងសម័យនោះ និងគោរពវិញ្ញាណក្ខន្ធមរណសាក្សីយ៉ាងពិសេស ។ គេនាំគ្នាធ្វើពិធីខួបថ្ងៃអស់លោកទទួលមរណភាព ហើយចាត់ថ្ងៃនោះទុកជា «*ថ្ងៃកំណើត*» របស់ 29
អស់លោក ។ មុនដំបូង គ្រីស្តបរិស័ទតែងតែកប់សពនៅទីស្មសានជាមួយអ្នកកាន់សាសនាដទៃដែរ តែចាប់តាំងពីសតវត្សទី ៣ មក គ្រីស្តបរិស័ទទិញកន្លែងបញ្ចុះសព ដូចក្រុមផ្សេងៗធ្លាប់ទិញតាមក្រុងនានា ។ នៅក្រុងរ៉ូម គ្រីស្តបរិស័ទទិញរូងក្នុងដី ហៅថា «កាតាកុំ» (Catacombes) ធ្វើជាទីស្មសានរបស់គេ ។

### *សិល្បៈរបស់គ្រីស្តបរិស័ទ*

ទីស្មសានទាំងនោះត្រឡប់ទៅជាកន្លែងគ្រីស្តបរិស័ទបង្កើតសិល្បៈ គឺគេនាំគ្នាគូររឿងចែងក្នុងគម្ពីរដំណឹងល្អ និងក្នុងគម្ពីរសម្ពន្ធមេត្រីចាស់នៅលើជញ្ជាំងរូងទីស្មសាន ។ គេក៏គូរនិមិត្តរូបអំពីជំនឿនៃគ្រីស្តសាសនា គឺគេគូររូបយុថ្កា (ជានិមិត្តរូបអំពីសេចក្តីសង្ឃឹម) ត្រីជានិមិត្តរូបអំពីព្រះគ្រីស្ត ។

> *ភាសាក្រិក «ត្រី» គេថា "អ៊ីគធូស" (Ichtus) ។ តួអក្សរនីមួយៗរបស់ពាក្យ "អ៊ីគធូស" នោះចាប់ផ្តើមពាក្យមួយគឺយេស៊ូ (Iesous) គ្រីស្ត (Christos) របស់ព្រះជាម្ចាស់ (Theou) ព្រះបុត្រា (Uios) ជាព្រះសង្គ្រោះ (Sôter) ។ ដូច្នេះ ពេលគូរត្រីគេប្រកាសជំនឿថា «ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ (និងជា) ព្រះសង្គ្រោះ» ។ ត្រីក៏ជាសញ្ញាឲ្យគ្រីស្តបរិស័ទស្គាល់គ្នាថា «ជាគ្នាឯង» ដែរ ។*

គ្រីស្តបរិស័ទបារសិលាចារឹកលើផ្នូររបស់សព គឺចារឹកមុនគេនៅចុងសតវត្សទី ២ និងដើមសតវត្សទី ៣ មានសិលាចារឹករបស់លោក**អាល់បែរស៊ីយ៉ូស**ជាដើម ។ ផ្ទាំងគំនូរនិងសិលាចារឹកទាំងនោះ នាំឲ្យយើងស្គាល់យ៉ាងច្បាស់អំពីជំនឿគ្រីស្តបរិស័ទនៅសម័យនោះ ។

Layout Histor.qxd 2/10/07 10:09 AM Page 53

## 29 អាពាហ៍ពិពាហ៍របស់គ្រីស្តបរិស័ទ តាមលោកទែរទូលីយ៉ាំង

លោក**ទែរទូលីយ៉ាំង**សរសេរលិខិតផ្ញើជូនភរិយារបស់លោក ដើម្បីគិតគូរអំពីអ្វីដែលនាងត្រូវធ្វើ ក្រោយពេលលោកស្លាប់ ។ មុនដំបូង លោកសុំនាងមិនឲ្យរៀបការជាថ្មី ។ ក្រោយមក លោកយល់ព្រមឲ្យនាងរៀបការជាមួយបុរសថ្មីបាន លុះត្រាតែបុរសជាគ្រីស្តបរិស័ទ ។ លោកទែរទូលីយ៉ាំងថែងអំពីរបៀបគូស្វាមីភរិយាជាគ្រីស្តបរិស័ទរស់នៅ ។ លោកមានបំណងចង់ពន្យល់ថា ជំនឿបំភ្លឺចិត្តគំនិតគ្រីស្តបរិស័ទជាគូស្វាមីភរិយា ដោយយោងតាមគ្រីស្តទូត**ប៉ូល** ។ លោកមិនថែងថា នៅសតវត្សទី ២ គ្រីស្តបរិស័ទរៀបពិធីអាពាហ៍ពិពាហ៍ប្លែកពីគេទេយ៉ាងណាទេ ។

*តើខ្ញុំនឹងយោងកម្លាំងពីណាមក ដើម្បីពិពណ៌នាអំពីសុភមង្គលរបស់គូស្វាមីភរិយាតាមព្រះសហគមន៍? (...) ទេវទូតប្រកាសអំពីអាពាហ៍ពិពាហ៍នោះ រីឯព្រះបិតានៅស្ថានបរមសុខក៏សព្វព្រះហឫទ័យទទួលស្គាល់ដែរ ។*

*គ្រីស្តបរិស័ទទាំងពីរនាក់ គឺជាគូស្វាមីភរិយាដ៏ប្រសើរ ភ្ជាប់ចិត្តជាមួយគ្នាដោយមានសេចក្តីសង្ឃឹមតែមួយ មានបំណងប្រាថ្នាតែមួយ មានវិន័យតែមួយ បម្រើព្រះអម្ចាស់តែមួយព្រះអង្គដូចគ្នា ។ អ្នកទាំងពីរជាបុត្រធីតារបស់ព្រះបិតាតែមួយព្រះអង្គ បម្រើព្រះអម្ចាស់តែមួយអង្គ ។ គ្មានអ្វីអាចបំបែកចិត្តគំនិត និងរូបកាយគេបានទេ ។ ផ្ទុយទៅវិញ អ្នកទាំងពីរពិតជារូបកាយតែមួយ ។ បើរូបកាយនៅតែមួយ វិញ្ញាណក៏នៅតែមួយដែរ ។ គេអធិដ្ឋានរួមជាមួយ គ្នាក្រាបថ្វាយបង្គំរួមជាមួយគ្នា តមអាហារក៏រួមជាមួយគ្នាដែរ ។ គេអប់រំគ្នាទៅវិញទៅមក ដាស់តឿនគ្នាទៅវិញទៅមក ហើយក៏លើកទឹកចិត្តគ្នាទៅវិញទៅមកដែរ ។ គេមានឋានៈស្មើគ្នាក្នុងព្រះសហគមន៍របស់ព្រះជាម្ចាស់ គេស្មើគ្នាក្នុងពិធីជប់លៀងរបស់ព្រះជាម្ចាស់ គេស្មើគ្នានៅពេលរងទុក្ខលំបាក ស្មើគ្នានៅពេលរងទុក្ខបុកម្នេញ ហើយក៏ស្មើគ្នានៅពេលព្រះអង្គសម្រាលទុក្ខរបស់គេដែរ (...) ។*

*លោកទែរទូលីយ៉ាំង "លិខិតផ្ញើជូនភរិយាខ្ញុំ"*




*ត្រីជានិមិត្តរូបអំពីព្រះគ្រីស្ត (សតវត្សទី ១-៣)*

Layout Histor.qxd 2/10/07 10:09 AM Page 54

# ខ- គ្រីស្តបរិស័ទចាត់ចែងមុខងារបម្រើព្រះសហគមន៍

*គ្រីស្តបរិស័ទចាត់ចែងមុខងារបម្រើព្រះសហគមន៍បន្តិចម្តងៗ ។ យើងមិនដឹងច្បាស់អំពីកំណើតមុខងារទាំងនោះទេ ។ គ្រីស្តបរិស័ទតែងតែប្រើពាក្យផ្សេងៗសំដៅលើមុខងារទាំងនោះ ។ ពាក្យខ្លះដូចគ្នា តែសំដៅទៅលើមុខងារផ្សេងៗពីគ្នាតាមព្រះសហគមន៍ និងតាមសម័យផ្សេងពីគ្នាវិញ ។ ទោះជាយ៉ាងណាក្តី ក៏ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មីគ្មានចែងអំពីមុខងារបម្រើ និងរចនាសម្ពន្ធព្រះសហគមន៍ដូចសព្វថ្ងៃទេ ។*

## ១- ព្រះសហគមន៍របស់ជនជាតិយូដានៅស្រុកប៉ាលេស្ទីន

ព្រះសហគមន៍ដើមដំបូង ចាត់ចែងអ្នកណែនាំតាមរបៀបពីរយ៉ាង គឺមាន **ក្រុម ១២ នាក់** ហើយ**ក្រុម ៧ នាក់** ។ នៅពេលព្រះយេស៊ូរស់នៅលើផែនដីនេះ ព្រះអង្គចាត់ចែងក្រុមដប់ពីរនាក់ (មក ៣,១៦-១៩) ហើយក្រោយពេលយូដាស្លាប់ គេក៏បន្ថែមឲ្យគ្រប់ចំនួនដប់ពីរនាក់ដែរ (កក ១,១៥-២៦) ។

ក្រុមដប់ពីរនាក់ណែនាំព្រះសហគមន៍នៅស្រុកប៉ាលេស្ទីនដែលនិយាយភាសាហេប្រឺ *(ឬភាសាអារ៉ាមេអាំង)* ។ មានក្រុមមួយទៀត គឺក្រុមប្រាំពីរនាក់ដែលមានលោក**ស្ទេផាន**ជាដើម (កក ៦,១-៦) ។ ក្រុមប្រាំពីរនាក់នេះណែនាំព្រះសហគមន៍ជនជាតិយូដាដែលនិយាយភាសាក្រិក ។

## ២- គ្រីស្តបរិស័ទចេញទៅប្រកាសដំណឹងល្អ

ក្រោយពីជនជាតិយូដាសម្លាប់លោកស្ទេផានមក គេក៏ចាប់ផ្តើមធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទឯទៀតៗដែរ បណ្តាលឲ្យគ្រីស្តបរិស័ទដែលនិយាយភាសាក្រិកបែកខ្ញែកគ្នាទៅប្រកាសដំណឹងល្អ ។ តាំងពីពេលនោះមក ព្រះសហគមន៍ចាត់ចែងខ្លួនឯងតាមរបៀបផ្សេងៗពីគ្នាតាមកន្លែង ។

ព្រះសហគមន៍ក្រុងយេរូសាឡឹមនិងក្រុងផ្សេងៗទៀត ដែលមានជនជាតិយូដាច្រើន ចាត់ចែងខ្លួនតាមរបៀបសហគមន៍សាសនាយូដា ។ គេតែងតាំងក្រុមចាស់ទុំ ឬក្រុមព្រឹទ្ធាចារ្យឲ្យណែនាំព្រះសហគមន៍ ។ លោក**យ៉ាកុប**ជានាយកក្រុមព្រឹទ្ធាចារ្យនៅក្រុងយេរូសាឡឹម ។ ក្រុម ១២ នាក់ បង្កើតព្រះសហគមន៍មួយចំនួនតាមរបៀបចាត់ចែងនេះ ។

ព្រះសហគមន៍នៅក្រុងអន់ទីយ៉ូក ចាត់លោក**ប៉ូល**និងលោក**បារណាបា**ទៅប្រកាសដំណឹងល្អ ។ គេចាត់ចែងព្រះសហគមន៍តាមរបៀបពីរយ៉ាងគឺ៖

**ក-** គ្រីស្តបរិស័ទខ្លះជា «*អ្នកប្រកាសដំណឹងល្អចល័ត*» (តាម ១ ករ ១២, ២៨) ពេញពេលប្រចាំជីវិត អ្នកទាំងនោះបំពេញមុខងាររបស់ខ្លួនតាមព្រះវិញ្ញាណបំភ្លឺ ។ គេហៅអ្នកទាំងនោះថា «*គ្រីស្តទូត*» ទោះបីអ្នកខ្លះមិននៅក្នុងក្រុម ១២ នាក់ក្តី ឧប. លោកប៉ូលនិងលោកបារណាបាជា «*គ្រីស្តទូត*» តែលោកទាំងពីរមិនមែនចូលក្នុងក្រុមដប់ពីរនាក់ទេ ។ គេទទួលបន្ទុកប្រកាសដំណឹងល្អ និងធ្លាប់ធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀតដោយមិនឈប់ឈរ ។ មានគ្រីស្តបរិស័ទខ្លះទៀតជា «*ព្យាការី*» ដែលតែងអត្ថាធិប្បាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងអង្គប្រជុំ ។ មាន «*គ្រូអាចារ្យ*» ដូចជាធម្មាចារ្យ ជាគ្រីស្តបរិស័ទដែលបេះបកស្រាយគម្ពីរហើយបង្រៀនគេ ។

**ខ-** ពេលអ្នកប្រកាសដំណឹងល្អធ្វើដំណើរបង្កើតព្រះសហគមន៍តាមក្រុងនីមួយៗ គេតែងតាំង «*អភិបាល*» (អ្នកថែរក្សា) និង «*ឧបដ្ឋាក*» (អ្នកបម្រើ) ឲ្យណែនាំព្រះសហគមន៍ទាំងនោះ (ភល ១,១) ។ អ្នកនិពន្ធលិខិតផ្ញើជូនលោក**ទីតុស** ក៏ហៅ

Layout Histor.qxd 2/10/07 10:09 AM Page 55

អភិបាលថា «*ព្រឹទ្ធាចារ្យ*» ដែរ (ទត ១,៦-៩) ។ លោកដែលទទួលខុសត្រូវលើព្រះសហគមន៍តាមក្រុងទាំងនេះ ត្រូវជាមេគ្រួសារដ៏ប្រសើរ (ទត ១; ធម ៣,១-១៣) ។ លោកទាំងនោះបកស្រាយគម្ពីរ ធ្វើពិធីជ្រមុជទឹក ធ្វើជាអធិបតីក្នុងពិធីអរព្រះគុណ ។ មេដឹកនាំព្រះសហគមន៍តែងតាំងអ្នកបម្រើទាំងនោះដោយដាក់ដៃលើគេ ដោយអធិដ្ឋាននិងតមអាហារ (កក ៦,៦; ១៣,៣; ១ ធម ៥, ២២) ។ ប៉ុន្តែ នៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី ការបាត់បែងនេះមិនសូវច្បាស់ទេ ។ តាមអត្ថបទខ្លះមានចែងអំពីមុខងារអ្នកបម្រើដោយមានរបៀបផ្សេងទៀត គឺមានគ្រីស្តទូតព្យាការី អ្នកប្រកាសដំណឹងល្អ គង្វាល និងអ្នកបង្រៀនជាដើម (អភ ៤,១១) ។

## ៣- គេចាប់ផ្តើមតែងតាំងមុខងារបម្រើព្រះសហគមន៍

នៅចុងសតវត្សទី ១ និងនៅដើមសតវត្សទី ២ អ្នកនិពន្ធសៀវភៅនៅតែ
30 ប្រើពាក្យមិនច្បាស់ស្របតាមគម្ពីរសម្ពន្ធមេត្រីថ្មី ។ ឧ. លោក**ក្លេម៉ង់**ជាអភិបាល
ព្រះសហគមន៍ក្រុងរ៉ូម និងអ្នកនិពន្ធសៀវភៅ**ឌីដាខេ**សរសេរថា ក្នុងព្រះសហគមន៍
នានាមានអភិបាល ព្រឹទ្ធាចារ្យ និងឧបដ្ឋាក ។ យូរៗទៅ ប្រជានក្រុមព្រឹទ្ធាចារ្យ
និងអភិបាលទាំងនោះច្បាស់ជាមានមុខងារប្លែកពីព្រឹទ្ធាចារ្យឯទៀតៗ ហើយ
31 ទទួលឈ្មោះថា «*អភិបាល*» ។ លោកឧបដ្ឋាកគឺជាអ្នកបំពេញមុខងារជាប់នឹង
លោកអភិបាល ។ យូរៗទៅ គេចែកមុខងារបម្រើព្រះសហគមន៍ជាបីកម្រិតគឺ
អភិបាល ព្រឹទ្ធាចារ្យ និងឧបដ្ឋាក ។ លោក**អ៊ីញ៉ាស**ជាអភិបាលព្រះសហគមន៍
ក្រុងអន់ទីយ៉ូក សរសេរលិខិតបញ្ជាក់មុនគេ អំពីការបាត់បែងតាមរបៀបនេះ ។
32 ពេលនោះ គេចាប់ផ្តើមចែងអំពីមុខងាររបស់ «*លោកអភិបាលដែលមានអំណាច
តែម្នាក់ឯង*» គឺលោកដាច់ចេញពីក្រុមព្រឹទ្ធាចារ្យ ។ យូរៗទៅលែងមានអ្នកបម្រើ
ចល័តដែលធ្វើដំណើរទៅកន្លែងផ្សេង ។ «*គ្រីស្តទូត*» (គឺអ្នកដែលបន្តមុខងារពីគ្រីស្តទូតមក) ស្ថិតនៅជាប់នឹងព្រះសហគមន៍មួយ ហើយទៅជាអភិបាលដែលគ្រីស្តបរិស័ទចាត់ទុកជាផ្លូវការថា ជាអ្នកបន្តមុខងារពីក្រុមគ្រីស្តទូតមក ។

មានមុខងារបម្រើផ្សេងទៀតដែលមានចំនួនមិនទៀង ស្របទៅតាមព្រះសហគមន៍និងតាមសម័យ ។ ឧ. ប្រហែលនៅគ.ស. ២៥0 អភិបាលព្រះសហគមន៍ក្រុងរ៉ូមចែងអំពីព្រះសហគមន៍របស់លោកដូចតទៅ៖ «*ព្រឹទ្ធាចារ្យមាន ៤៦ នាក់ ឧបដ្ឋាក ៧ នាក់ អនុឧបដ្ឋាក ៧ នាក់ អ្នកអម ៤២ នាក់ អ្នកបណ្តេញមារ ៥២ នាក់ អ្នកប្រកាសព្រះបន្ទូល អ្នកចាំទ្វារ ស្ត្រីមេម៉ាយនិងជនក្រីក្រជាង ១៥00 នាក់ (...)*» ។ (*លោកអឺសែប "ប្រវត្តិព្រះសហគមន៍" ៦,៤៣,១១*)

នៅដើមដំបូង មានតែលោកអភិបាលធ្វើជាអធិបតីនៅក្នុងពិធីអរព្រះគុណ លោកបកស្រាយគម្ពីរ ធ្វើអគ្គសញ្ញាជ្រមុជទឹក ព្រមទាំងលើកលែងទោសឲ្យអ្នកបាប ។ អស់លោកព្រឹទ្ធាចារ្យគ្រាន់តែជួយលោកអភិបាលប៉ុណ្ណោះ ។ ពេលគ្រីស្តបរិស័ទកើនចំនួនឡើង ចំនួនអភិបាលក៏កើនឡើងដែរ ជាពិសេសក្នុងតំបន់ខ្លះ គឺនៅទ្វីបអាហ្វ្រិកខាងជើងជាដើម ។ នៅទីក្រុងធំៗ គឺក្រុងរ៉ូម និងក្រុងអាឡិចសង់ឌ្រីជាដើម គេបង្កើតកន្លែងគោរពថ្វាយបង្គំជាច្រើន ដូច្នេះ គេតែងតាំងក្រុមព្រឹទ្ធាចារ្យឲ្យទទួលខុសត្រូវនៅកន្លែងទាំងនោះ ។

អស់លោកអភិបាល និងប្រជាជន តែងតែជ្រើសរើសគ្រីស្តបរិស័ទឲ្យបំពេញមុខងារបម្រើព្រះសហគមន៍តាមរបៀបផ្សេងៗ ។ ក្នុងពិធីតែងតាំងអ្នកបម្រើទាំងនោះ ពិធីសំខាន់ជាងគេ គឺពិធីដាក់ដៃ ។ លោកអភិបាលដាក់ដៃតែងតាំងអភិបាលម្នាក់ទៀត លោកអភិបាលនិងក្រុមព្រឹទ្ធាចារ្យដាក់ដៃតែងតាំងព្រឹទ្ធាចារ្យឯទៀតៗ ។ លោកអភិបាលតែម្នាក់ដាក់ដៃតែងតាំងឧបដ្ឋាក តែងតាំងអ្នកបម្រើព្រះសហគមន៍ផ្សេងៗទៀត ដោយគ្រាន់តែប្រគល់វត្ថុដែលគេត្រូវប្រើតាមមុខងាររៀងៗខ្លួន ។ ឧប. លោកប្រគល់គម្ពីរឲ្យអ្នកប្រកាសព្រះបន្ទូល ។

Layout Histor.qxd 2/10/07 10:09 AM Page 56

### *ក- អ្នកបំពេញមុខងារបម្រើ និង បូជាចារ្យ*

ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី អ្នកបម្រើព្រះសហគមន៍យកចិត្តទុកដាក់ប្រកាសដំណឹងល្អ (១ ករ ១,១៧) តែពួកគេក៏ធ្វើជាអធិបតីក្នុងអង្គប្រជុំ អធិដ្ឋាន ធ្វើពិធីកាច់នំបុ័ង និងចាត់ចែងកិច្ចការរួមទូទៅដែរ ។ គ្រីស្តបរិស័ទមិនរាប់គេទុកដូចជាបូជាចារ្យនៃសាសន៍យូដា ឬជាបូជាចារ្យសាសន៍ដទៃទេ ។ គ្រីស្តបរិស័ទទាំងអស់សុទ្ធតែជា «*ក្រុមបូជាចារ្យព្រះស្តេច*» *(១ សល ២,៩)* ព្រោះគ្រីស្តបរិស័ទរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូជាមហាបូជាចារ្យតែមួយគត់ ។ ព្រះអង្គថ្វាយព្រះជន្មជាយញ្ញបូជាតែម្តងជាសូរេច ។ ដូច្នេះ គ្រីស្តបរិស័ទមិនត្រូវការបូជាចារ្យណាទៀតទេ ។ យូរៗទៅគ្រីស្តបរិស័ទយល់ឃើញថា អ្នកបម្រើព្រះសហគមន៍មានមុខងារពិសេសក្នុងពិធីនានា ដូចអ្នកធ្វើអធិបតីនៅក្នុងពិធីរបស់សាសនាដទៃដែរ ។ គេយល់ឃើញដូច្នោះ ដោយអានគម្ពីរសម្ពន្ធមេត្រីចាស់ និងប្រៀបធៀបគ្រីស្តសាសនានឹងសាសនាដទៃ ។ ហេតុនេះ បានជាដើមសតវត្សទី ៣ លោក**ហ៊ីប៉ូលីត**ចែងអំពីអ្នកទទួលខុសត្រូវលើព្រះសហគមន៍ ទុកជា «*បូជាចារ្យ*» ។ ហេតុដូច្នេះ ពាក្យ «*បូជាចារ្យ*» មានអត្ថន័យមិនច្បាស់ គឺកាលពីដើម (ឧបមា. នៅក្នុងគម្ពីរ) មានន័យថា «*អ្នកធ្វើយញ្ញ*» ទទួលអត្ថន័យថ្មីថា «*ចាស់ទុំជាអ្នកណែនាំព្រះសហគមន៍*» ឬជាព្រឹទ្ធាចារ្យ ។

មានអភិបាលខ្លះ ដូចជាលោក**ស៊ីព្រីយ៉ាំង**ជាអភិបាលព្រះសហគមន៍កាតាស្យសម្រេចចិត្តថានឹងបួស តែអ្នកបម្រើព្រះសហគមន៍ជាច្រើនមានគ្រួសារវិញ ។

---

(30) **មុខងារជាអ្នកបម្រើព្រះសហគមន៏នៅចុងសតវត្សទី ១**

លោក**ក្លេម៉ង់**ស្តីបន្ទោសគ្រីស្តបរិស័ទក្រុងកូរិនថូស ដែលទម្លាក់អ្នកបំពេញមុខងារបម្រើព្រះសហគមន៍របស់គេដោយគ្មានមូលហេតុ ។ លោករំឭកគេអំពីដើមកំណើតនៃមុខងារបម្រើទាំងនោះ ។ ក្នុងលិខិតនេះ លោកមិនទាន់កំណត់ពាក្យឲ្យបានច្បាស់ទេ គឺជួនកាលលោកប្រើពាក្យ «*អភិបាល*» ជួនកាលលោកប្រើពាក្យ «*ព្រឹទ្ធាចារ្យ*» តែពាក្យទាំងពីរម៉ាត់នោះ សំដៅលើមុខងារតែមួយដដែល ។ *(សូមអានពាក្យលំនាំអត្ថបទទី ៦)*

*ព្រះយេស៊ូគ្រីស្តចាត់ក្រុមគ្រីស្តទូតឲ្យនាំដំណឹងល្អ ។ ព្រះជាម្ចាស់ចាត់ព្រះយេស៊ូគ្រីស្តឲ្យយាងមក ។ ដូច្នេះ ព្រះយេស៊ូគ្រីស្តយាងមកពីព្រះជាម្ចាស់ ហើយក្រុមគ្រីស្តទូតក៏មកពីព្រះគ្រីស្តចាត់ឲ្យមកដែរ ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យចាត់ព្រះគ្រីស្តនិងក្រុមគ្រីស្តទូតតាមលំដាប់ ។ ព្រះអម្ចាស់យេស៊ូគ្រីស្តបង្រៀនក្រុមគ្រីស្តទូត ហើយពេលព្រះអង្គទទួលព្រះជន្មថ្មីដ៏រុងរឿង ទ្រង់បង្ហាញព្រះអង្គ ដើម្បីឲ្យគេមានជំនឿមាំមួនលើព្រះបន្ទូលព្រះជាម្ចាស់ ។ គ្រីស្តទូតធ្វើដំណើរដោយចិត្តអង់អាចមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ទៅប្រកាសដំណឹងល្អគ្រប់ទីកន្លែងថាព្រះរាជ្យនៃស្ថានបរមសុខមកដល់ហើយ ។ អស់លោកប្រកាសព្រះបន្ទូលតាមភូមិនិងក្រុងនានា ។ អស់លោកជ្រើសរើសអ្នកដែលទទួលព្រះបន្ទូលនេះមុនគេនិងអ្នកប្រសើរជាងគេ លចិត្តគំនិតគេ ។ បន្ទាប់មក អស់លោកតែងតាំងគេជាអភិបាល និងជាឧបដ្ឋាកសម្រាប់ណែនាំអ្នកក្រោយៗទៀត ។*

*ក្រុមគ្រីស្តទូតក៏ជ្រាបថា ពួកគេនឹងឈ្លោះប្រកែកគ្នាអំពីឋានៈជាអភិបាលដែរ ។ ហេតុនេះហើយ ដោយដឹងច្បាស់នូវអ្វីៗដែលនឹងកើតឡើងពេលអនាគតនោះ បានជាអស់លោកតែងតាំងអ្នកបម្រើដូចយើងសរសេរខាងលើនេះ ។ អស់លោកក៏ដាក់វិន័យថា ពេលអស់លោកទទួលមរណភាពទៅ ត្រូវមានមនុស្សដែលត្រូវបានគេល្បងលមើលចិត្តគំនិតរួចហើយ បន្តមុខងាររបស់អស់លោក ។*

*យើងយល់ឃើញថា ការបណ្តេញអស់អ្នកដែលទទួលមុខតំណែងពីក្រុមគ្រីស្តទូតមក ឬការបណ្តេញអ្នកឯទៀតដ៏ប្រសើរដែលព្រះសហគមន៍យល់ព្រមឲ្យបម្រើហ្វូងចៀមរបស់ព្រះគ្រីស្តដោយឥតកំហុសនោះ ពិតជាអយុត្តិធម៌មែន ។ អស់អ្នកទម្លាក់មនុស្សដែលថ្វាយតង្វាយចំពោះព្រះជាម្ចាស់ដោយចិត្តគោរពយ៉ាងល្អឥតខ្ចោះ ឲ្យធ្លាក់ពីមុខតំណែងជាអភិបាលនោះពិតជាប្រព្រឹត្តបាបធ្ងន់ ។*

*អស់ព្រឹទ្ធាចារ្យដែលបំពេញមុខងាររបស់ខ្លួនរួចហើយ ពិតជាមានសុភមង្គលហើយ (...) ។*

*លោកក្លេម៉ង់ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម*
*លិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងកូរិនថូស ៤២ និង ៤៤*

Layout Histor.qxd 2/10/07 10:09 AM Page 57

## 31 អ្នកបម្រើចល័ត និង អ្នកបម្រើព្រះសហគមន៍តាមក្រុង

ក្នុងអត្ថបទនេះ មានចែងអំពី «*គ្រីស្តទូត ព្យាការី និងគ្រូបង្រៀន*» ។ ត្រូវស្វែងយល់អំពីមុខងារទាំងបីនោះ តាម ១ ករ ១២,២៨ ។ អ្នកនិពន្ធអត្ថបទនេះប្រហែលរស់នៅក្រោយពេលក្រុមគ្រីស្តទូតទទួលមរណភាព ។

*ចំពោះគ្រីស្តទូតនិងព្យាការី សូមបងប្អូនប្រព្រឹត្តតាមព្រះបន្ទូលផ្ដែផ្ដាំក្នុងគម្ពីរដំណឹងល្អ គឺថាត្រូវទទួលគ្រីស្តទូតទាំងអស់ដែលអញ្ជើញមកផ្ទះបងប្អូន ដូចទទួលព្រះជាម្ចាស់ផ្ទាល់ ។ ប៉ុន្តែ លោកនោះត្រូវស្នាក់នៅតែមួយថ្ងៃ ឬក្នុងករណីចាំបាច់ លោកអាចស្នាក់នៅពីរថ្ងៃបាន ។ ប្រសិនបើគាត់ស្នាក់នៅបីថ្ងៃ គាត់ពិតជាព្យាការីក្លែងក្លាយ ។ ពេលគ្រីស្តទូតចេញដំណើរគាត់មិនត្រូវទទួលយកអ្វីសោះ ក្រៅពីអាហារល្មមសម្រាប់គាត់ទៅដល់កន្លែងមួយទៀត ។ ប្រសិនបើគាត់សុំប្រាក់ អ្នកនោះពិតជាព្យាការីក្លែងក្លាយ (...) ។*

*ព្យាការីត្រឹមត្រូវដែលចង់ស្នាក់នៅផ្ទះ «សមនឹងទទួលអាហារ» (មថ ១០,១០) ។ គ្រូដ៏ត្រឹមត្រូវក៏ «សមនឹងទទួលអាហារក្នុងឋានៈជាកម្មករម្នាក់» ដែរ ។*

*ដូច្នេះ សូមបងប្អូនជ្រើសរើសមនុស្សសមនឹងព្រះអម្ចាស់ធ្វើជាអភិបាល និងជាឧបដ្ឋាក គឺអស់អ្នកដែលបងប្អូនបានល្បងលមើលចិត្តរួចហើយ ។ មនុស្សទាំងនោះក៏បំពេញមុខងារជាព្យាការី និងជាគ្រូសម្រាប់បងប្អូនដែរ ។ ហេតុនេះ សូមបងប្អូនកុំមើលងាយគេឡើយ ព្រោះក្នុងចំណោមបងប្អូន ពួកគេមានកិត្តិយសដូចព្យាការី និងគ្រូអាចារ្យដែរ ។*

*ឌីដាខេ ១១,១៣,១៥*

## 32 មុខងារបម្រើព្រះសហគមន៍បីយ៉ាង

លោក**អ៊ីញ៉ាស**ទទួលខុសត្រូវលើព្រះសហគមន៍ក្រុងអន់ទីយ៉ូក ។ ទាហានរ៉ូម៉ាំងចាប់បញ្ជូនលោកទៅផ្ដន្ទាទោសដល់ជីវិតនៅក្រុងរ៉ូម (ប្រ.គ.ស. ១១០) ។ តាមផ្លូវលោកសរសេរលិខិតផ្ញើជូនព្រះសហគមន៍ជាច្រើននៅស្រុកអាស៊ី ដើម្បីលើកទឹកចិត្តគ្រីស្តបរិស័ទ និងដាស់តឿនគេឲ្យរួបរួមគ្នាជាធ្លុងតែមួយ និងឲ្យមានជំនឿយ៉ាងស្មោះលើព្រះជាម្ចាស់ ។ លោកបញ្ជាក់យ៉ាងច្បាស់ថា កាលនៅសម័យលោក គឺមានមុខងារបម្រើព្រះសហគមន៍បីយ៉ាងដែលមានកម្រិតខុសគ្នា គឺលោកអភិបាលដាច់ចេញពីក្រុមព្រឹទ្ធាចារ្យ និងក្រុមឧបដ្ឋាក ។ ប៉ុន្តែ ពាក្យទាំងបីនោះមិនទាន់មានអត្ថន័យយ៉ាងច្បាស់នៅឡើយទេ ។

*សូមបងប្អូនទាំងអស់គ្នាធ្វើតាមលោកអភិបាល ដូចព្រះយេស៊ូគ្រីស្តធ្វើតាមព្រះហឫទ័យព្រះបិតាដូច្នោះដែរ ឬដូចក្រុមព្រឹទ្ធាចារ្យធ្វើតាមក្រុមគ្រីស្តទូត ។ រីឯឧបដ្ឋាកនានា សូមគោរពអស់លោកដូចគោរពធម្មវិន័យរបស់ព្រះជាម្ចាស់ ។ សូមកុំឲ្យនរណាម្នាក់ធ្វើការអ្វីមួយក្នុងព្រះសហគមន៍ ដោយមិនរួបរួមជាមួយលោកអភិបាលឡើយ ។ សូមចាត់ទុកពិធីអរព្រះគុណជាត្រឹមត្រូវតាមផ្លូវការ ចំពោះតែពិធីណាដែលគេថ្វាយក្រោមអធិបតីភាពលោកអភិបាល ឬក្រោមអធិបតីភាពលោកដែលទទួលបន្ទុកនោះប៉ុណ្ណោះ ។ កន្លែងណាមានលោកអភិបាលកន្លែងនោះក៏មានព្រះសហគមន៍ដែរ ដូចកន្លែងណាព្រះគ្រីស្តយេស៊ូគង់នៅកន្លែងនោះក៏មានព្រះសហគមន៍កាតូលិកដែរ ។ បងប្អូនគ្មានសិទ្ធិធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ ឬជួបជុំគ្នាបរិភោគដោយសេចក្ដីស្រឡាញ់ដោយគ្មានលោកអភិបាលទេ ។ អ្វីៗដែលលោកអភិបាលយល់ស្រប ក៏គាប់ព្រះហឫទ័យព្រះជាម្ចាស់ដែរ ។*

*លិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងស្មៀរណា ជំពូក ៨*

*សូមបងប្អូនទាំងអស់គ្នាគោរពឧបដ្ឋាកយ៉ាងជ្រាលជ្រៅដូចគោរពព្រះយេស៊ូគ្រីស្ត ក៏ដូចជាគោរពលោកអភិបាលដែលជារូបតំណាងរបស់ព្រះបិតាដែរ ។ សូមគោរពក្រុមព្រឹទ្ធាចារ្យដូចជាគោរពព្រឹទ្ធសភារបស់ព្រះជាម្ចាស់ និងជាអង្គប្រជុំរបស់គ្រីស្តទូតដែរ ។ បើគ្មានអ្នកទាំងនោះទេ ក៏គ្មានព្រះសហគមន៍ដែរ ។*

*លោកអ៊ីញ៉ាស ជាអភិបាលព្រះសហគមន៍ក្រុងអន់ទីយ៉ូក*
*លិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងត្រាល ជំពូក ៣*

Layout Histor.qxd 2/10/07 10:09 AM Page 58

## *ខ- អ្នកបម្រើព្រះសហគមន៍ភេទស្រី*

នៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី មានចែងអំពីស្ត្រីៗដើរតាមព្រះយេស៊ូ *(លក ៨, ១-៣)* ហើយស្ត្រីខ្លះប្រកាសដំណឹងល្អ និងធ្វើជាព្យាការិនី *(រម ១៦,១-៣; ភល ៤,២-៣; ១ករ ១១,៤-៥; កក ២១,៩)* ។ ប៉ុន្តែ អ្នកបម្រើជានារីមិនដូចអ្នកបម្រើជាបុរសទេ ។ ក្នុងអង្គប្រជុំ គ្រីស្តបរិស័ទមិនសូវពេញចិត្តឲ្យស្ត្រីៗបំពេញមុខងារយ៉ាងសកម្មទេ *(១ ករ ១៤,៣៤ត; ១ ធម ២, ១១-១៤)* ។ មាន «*ក្រុមមេម៉ាយ*» កើតក្នុងព្រះសហគមន៍ *(១ ធម ៥,៣-១៦)* ។ ក្រុមស្ត្រីមេម៉ាយទាំងនោះតែងអធិដ្ឋាន និងបំពេញការងារផ្សេងៗ ឧប. ទៅសួរសុខទុក្ខអ្នកជំងឺ ។

នៅសតវត្សទី ៣ នៅស្រុកស៊ីរីច្បាស់ជាមានឧបដ្ឋាការិនី ។ ឧបដ្ឋាការិនី
ទាំងនោះ តែងបម្រើស្ត្រីៗ ដូចឧបដ្ឋាកតែងបម្រើបុរសៗដែរ ។ លោកអភិបាល
តែងតាំងឧបដ្ឋាការិនីដោយដាក់ដៃលើគេ ដូចលោកតែងតាំងឧបដ្ឋាកដែរ ។
33 ចំណែកឯ «*ក្រុមស្ត្រីព្រហ្មចារិនី*» ជាក្រុមមួយដោយឡែកពីគេ ។ នៅកន្លែងខ្លះ
ឧបដ្ឋាការិនី ស្ត្រីមេម៉ាយ និងស្ត្រីព្រហ្មចារិនី មានមុខងារខ្លះស្រដៀងគ្នា ។



*រូបចម្លាក់នៅលើផ្នូរគ្រីស្តបរិស័ទ ។*
*អក្សរដើមនៃពាក្យ «ព្រះគ្រីស្ត» (XP) និងអក្សរដើមនិងចុងនៃព្យញ្ជនៈក្រិក (AΩ)*

33

### ឧបដ្ឋាការិនីនៅស្រុកស៊ីរី នាសតវត្សទី ៣

*ជម្រាបលោកអភិបាល! សូមលោកលើកអ្នកធ្វើការដ៏សុចរិតសម្រាប់ជួយលោក គឺអ្នកដែលអាចរួមសហការជាមួយលោក ដើម្បីនាំការសង្គ្រោះ ។ សូមលោកជ្រើសរើសមនុស្សដែលគាប់ចិត្តលោកក្នុងចំណោមប្រជាជនទាំងមូល ហើយតែងតាំងគេជាឧបដ្ឋាក គឺបុរសម្នាក់សម្រាប់បំពេញមុខងារជាច្រើនដ៏ចាំបាច់ និងស្រីម្នាក់ធ្វើជាឧបដ្ឋាការិនីដើម្បីបម្រើស្ត្រីៗ ដ្បិតនៅកន្លែងខ្លះលោកមិនអាចចាត់ឧបដ្ឋាកទៅបម្រើស្ត្រីៗបានទេ តែលោកអាចចាត់ឧបដ្ឋាការិនីវិញបាន ។ ម្យ៉ាងទៀត ក្នុងករណីយកិច្ចជាច្រើនផ្សេងៗទៀត លោកត្រូវការឧបដ្ឋាការិនីជាចាំបាច់ ។ ឧបមាថា ក្នុងពេលធ្វើអគ្គសញ្ញាជ្រមុជទឹក មុនដំបូង ពេលស្ត្រីៗចូលទៅក្នុងទឹក ឧបដ្ឋាការិនីត្រូវយកប្រេងមកលាបពួកនាង (...) ។ ប៉ុន្តែ ពេលពួកនាងនៅក្នុងទឹក សូមឲ្យបុរសម្នាក់អង្វរព្រះនាមព្រះជាម្ចាស់លើគេ ។ ពេលនាងម្នាក់ទទួលអគ្គសញ្ញាជ្រមុជទឹក រួចហើយចេញពីទឹក សូមឲ្យឧបដ្ឋាការិនីម្នាក់ទទួលនាង ហើយបង្រៀន និងអប់រំគេអំពីរបៀបថែរក្សាត្រានៃអគ្គសញ្ញាជ្រមុជទឹកនោះយ៉ាងបរិសុទ្ធ និងវិសុទ្ធផង ។*

*សេចក្តីប្រៀនប្រដៅរបស់ក្រុមគ្រីស្តទូត*

Layout Histor.qxd 2/10/07 10:09 AM Page 59

# គ_ មូលហេតុផ្សេងៗបណ្ដាលឲ្យព្រះសហគមន៍បែកបាក់គ្នា និងចំណងមេត្រីភាពរវាងព្រះសហគមន៍ទាំងឡាយ

## ១- ព្រះសហគមន៍ផ្សព្វផ្សាយពាសពេញពិភពលោក

លោក**អាប៊ែរស៊ីយ៉ូស** (Albercius) លោក**អូរីសែន** (Origène) និងលោក**អ៊ីរ៉េណេ** (Irénée) ថែងថា តាំងពីចុងសតវត្សទី ២ មក មានគ្រីស្ដបរិស័ទនៅគ្រប់ទីកន្លែង គឺនៅពាសពេញពិភពលោកទាំងមូល (តាមពិតនៅតែក្នុងចក្រភពរ៉ូម៉ាំងប៉ុណ្ណោះ) ។ ចំនួនគ្រីស្ដបរិស័ទច្រើនជាងគេនៅខាងបូព៌ាប្រទេស (អាស៊ីម៉ីន័រ ស្រុកស៊ីរី ស្រុកប៉ាលេស្ទីន) គឺសូម្បីនៅជនបទក្ដី ក៏មានគ្រីស្ដបរិស័ទយ៉ាងច្រើនដែរ ។ នៅសម័យព្រះចៅ**ដេស្យ**ធ្វើទុក្ខបុកម្នេញគ្រីស្ដបរិស័ទ លើកចុងក្រោយ (គ.ស ២៥០) ប្រជាជនភាគច្រើនក្នុងក្រុងជាគ្រីស្ដបរិស័ទ ។

នៅខាងបស្ចិមប្រទេស ការប្រកាសដំណឹងល្អមិនលឿនស្មើគ្នានៅគ្រប់កន្លែងទេ ។ ចំនួនគ្រីស្ដបរិស័ទមានច្រើននៅស្រុកអ៊ីតាលីកណ្ដាល នៅស្រុកអេស្ប៉ាញខាងត្បូង នៅទ្វីបអាហ្វ្រិកខាងជើង ។ គ្រីស្ដបរិស័ទនៅស្រុកអ៊ីល្លីរី (ស្រុកអាល់បានីសព្វថ្ងៃ) នៅស្រុកអ៊ីតាលីខាងជើង និងនៅស្រុកហ្គោល (ស្រុកបារាំងសព្វថ្ងៃ) មានចំនួនតិចតួចប៉ុណ្ណោះ ។

ក្រៅពីចក្រភពរ៉ូម៉ាំង មានប្រជាជនខ្លះក៏ជឿលើព្រះគ្រីស្ដដែរ ឧប. ប្រជាជននៃព្រះរាជាណាចក្រអេដែស្ស (ប្រទេសទួរគីសព្វថ្ងៃ) នាំគ្នាជឿលើព្រះគ្រីស្ដនៅ គ.ស. ២០០ ។ គ្រីស្ដបរិស័ទជាច្រើននៅម៉េសូប៉ូតាមីខាងជើង ។ នៅពេលព្រះចៅពែរ្សច្បាំងប្រឆាំងនឹងក្រុងអន់ទីយ៉ូក (គ.ស. ២៤០-២៧២) ទ្រង់ជម្លៀសគ្រីស្ដបរិស័ទ និងអស់លោកអភិបាលឲ្យទៅនៅក្នុងចក្រភពរបស់ព្រះអង្គ រួចធ្វើទុក្ខបុកម្នេញជល់គេទៀត ។ នៅគ.ស. ៣០០ ជនជាតិអារមេនី (Arménie) ប្រែចិត្តគំនិតជឿលើព្រះគ្រីស្ដ ។



*រូបសត្វដែលបូជាជីវិតសម្រាប់ចិញ្ចឹមកូន ជានិមិត្តរូបអំពីព្រះយេស៊ូ*

Layout Histor.qxd 2/10/07 10:09 AM Page 60

## ២- មូលហេតុបណ្ដាលឲ្យព្រះសហគមន៍បែកបាក់

ព្រះសហគមន៍នៅដដែលពាសពេញពិភពលោក ប៉ុន្ដែ មូលហេតុផ្សេងៗអាចបំបាក់បំបែកព្រះសហគមន៍នៅគ្រប់សម័យបាន ។ មានជម្លោះកើតឡើងអំពីរបៀបធ្វើពិធីនានា អំពីការលើកលែងទោសឲ្យអ្នកក្បត់សាសនា នៅពេលរដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្ដបរិស័ទ ។ មិនត្រូវភ្លេចថា បុគ្គលនិងបុគ្គលក៏តែងតែប្រកួតប្រជែងដើម្បីទទួលមុខងារជាអភិបាលដែរ ។

នៅសតវត្សទី ២ ផ្ទៃក្នុងព្រះសហគមន៍មានលទ្ធិផ្សេងៗបណ្ដាលឲ្យមានក្រុមប្រកួតប្រជែងគ្នា ។ តើមានក្បួនណាអាចបញ្ជាក់ជំនឿដ៏ពិតប្រាកដបាន? នេះជាបញ្ហាយ៉ាងធ្ងន់ធ្ងរដែលអាចបំបាក់បំបែកព្រះសហគមន៍បាន ។ យើងនឹងលើកតែឧទាហរណ៍ខ្លះៗប៉ុណ្ណោះ ។

គ្រីស្ដបរិស័ទជាតិយូដាចង់រក្សាទុកនូវក្បួនពិធី និងទេវវិជ្ជារបស់ខ្លួន ជាពិសេសពួកគេនៅតែធ្វើពិធីកាត់ស្បែក និងកាន់តាមបញ្ញត្ដិហាមបរិភោគអាហារខ្លះ ។ ពួកគេខ្លះយកចិត្ដទុកដាក់ប្រកាសថា តាមគម្ពីរ មានព្រះជាម្ចាស់តែមួយព្រះអង្គគត់ ពួកគេចាត់ព្រះយេស៊ូទុកជាមនុស្សម្នាក់ដែលព្រះជាម្ចាស់ទទួលទុកជាព្រះបុត្រា នៅពេលព្រះអង្គទទួលពិធីជ្រមុជទឹក ។ ពួកគេមិនព្រមទាក់ទងជាមួយសាសន៍ដទៃទេ ។ មិនសូវយូរប៉ុន្មាន ព្រះសហគមន៍ឯទៀតៗចាត់ពួកគេទុកជាអ្នកបែកឆ្ងាយពីជំនឿ ។

### *ក- ក្រុម និង និកាយកើតច្រើនដេរដាស*

គ្រីស្ដបរិស័ទខ្លះយល់អំពីជំនឿតាមទស្សនវិជ្ជាក្រិក ដែលធ្លាប់បំបែកជាតុនិងវិញ្ញាណក្នុងខ្លួនមនុស្ស គឺមានរូបកាយនិងវិញ្ញាណប្រឆាំងគ្នា ។ គេចេះតែរំពឹងគិតអំពីបញ្ហាទុក្ខលំបាក ។ ហេតុនេះហើយបានជាមានគ្រីស្ដបរិស័ទខ្លះបកស្រាយអត្ថន័យគម្ពីរសម្ពន្ធមេត្រីទាំងចាស់ទាំងថ្មីតាមរបៀបប្លែកពីព្រះសហគមន៍ ។ ពួកគេមិនយល់ស្របនឹងជំនឿព្រះសហគមន៍ដែលប្រកាសថា ព្រះជាម្ចាស់ប្រសូតជាមនុស្ស ។ គេពឹងលើចំណេះដ៏អស្ចារ្យម្យ៉ាង ដែលគេបញ្ជូនតៗមកតាមក្រុមតូចរបស់គេ (Gnosis «ង្ញូសីស» គឺចំណេះ) ។ គេហៅខ្លួនឯងថា «ចំណេះនិយម» ។ គេប្រកាសថា ចំណេះដ៏អស្ចារ្យម្យ៉ាងអាចសង្គ្រោះគេបាន ។ ពួកគេជ្រើសេចក្ដីខ្លះមកពីគ្រីស្ដសាសនា សេចក្ដីខ្លះមកពីសាសនាយូដា សេចក្ដីខ្លះមកពីអរិយធម៌ក្រិក និងសេចក្ដីខ្លះទៀតមកពីសាសនាស្រុកអ៊ីរ៉ង់ ។ អ្នកនិពន្ធខាងគ្រីស្ដសាសនាចាត់ពួកគេទុកជាអ្នកបែកឆ្ងាយពីជំនឿ ។ (សព្វថ្ងៃអ្នកស្រាវជ្រាវប្រវត្ដិសាស្ដ្រតែងយល់ឃើញថា ប្រហែលពួកគេធ្លាប់កាន់សាសនាដទៃ ហើយយកសេចក្ដីខ្លះពីគ្រីស្ដសាសនាមកផ្សំផ្គុំជាមួយសាសនារបស់ខ្លួនវិញ) ។

លោក**អ៊ីរ៉េណេ** (Irénée) ជាអភិបាលក្រុងលីយ៉ុង (ប្រទេសបារាំងសព្វថ្ងៃ) 34
ថែងសៀវភៅមួយមានចំណងជើងថា «*ប្រឆាំងអ្នកវង្វេងឆ្ងាយពីជំនឿ*» មាន 35
លោក**ម៉ារស៊ីយ៉ុង** ជាដើម ។ លោកម៉ារស៊ីយ៉ុង ដកសេចក្ដីទាំងអស់ថែងអំពីព្រះ 36
ជាម្ចាស់បង្កើតពិភពលោក និងអំពីព្រះជាម្ចាស់ប្រសូតជាមនុស្ស ចេញពីគម្ពីរ ព្រោះតាមទស្សនៈរបស់លោកជាតុទាំងប្រាំនិងរូបកាយ ពិតជាអាក្រក់ ។

លោក**ម៉ានី** (Mani) (២១៦-២៧៧) កើតនៅស្រុកម៉េសូប៉ូតាមី ។ លោកផ្សំផ្គុំលទ្ធិគ្រីស្ដសាសនានិងលទ្ធិសាសនានៅស្រុកអ៊ីរ៉ង់ ។ លោកបង្រៀនថា មានតួសភាវៈល្អនិងតួសភាវៈអាក្រក់តែងតែប្រឆាំងគ្នា ។ ប្រវត្ដិសាស្ដ្រពិភពលោកគឺជាការប្រយុទ្ធយ៉ាងធំអស្ចារ្យ គឺព្រះនៃសភាវៈល្អឬព្រះនៃពន្លឺ ច្បាំងប្រឆាំងនឹងព្រះនៃសភាវៈអាក្រក់ ឬព្រះនៃភាពងងឹត ។ មនុស្សប្រៀបដូចជាគ្រាប់ពន្លឺដ៏តូចៗ ដែលជាប់ឃុំឃាំងក្នុងជាតុដ៏អាក្រក់ ។ គ្រាប់ពន្លឺដ៏តូចៗទាំងនោះ ត្រូវជម្រះខ្លួនជាច្រើនដង ឬត្រូវចាប់ជាតិជាច្រើនដង ដើម្បីចូលក្នុងព្រះរាជ្យនៃសភាវៈល្អ ។ ព្រះយេស៊ូបង្ហាញមាគ៌ា ហើយលោកម៉ានី ជាទូតដែលព្រះអង្គចាត់ឲ្យមក គឺជា «*ព្រះដែលជួយការពារ*» ថ្មី ។

Layout Histor.qxd 2/10/07 10:09 AM Page 61

អ្នកស្រុកជាច្រើនចូលចិត្តជឿតាមលទ្ធិទាំងនោះ ព្រោះលទ្ធិទាំងនោះជួយបន្ធូរការតប់ប្រមល់កប់នៅក្នុងជម្រៅចិត្តមនុស្ស ។ អ្នកចំណោះនិយមខ្លះពិតជាចង់ស្គាល់ព្រះជាម្ចាស់មែន ។ គ្រីស្តបរិស័ទដែលបានចែងអំពីពួកគេ សុទ្ធតែជាអ្នកប្រឆាំងនឹងពួកគេ ។ ហេតុនេះហើយ បានជាជួនកាលគ្រីស្តបរិស័ទមិនស្គាល់គេច្បាស់ ឬរៀបរាប់ពាក្យចចាមអារាម ដោយមិនវែកញែករកខុសត្រូវទេ ។ លទ្ធិទាំងនោះអាចបណ្តាលឲ្យគ្រីស្តបរិស័ទជាច្រើនបាត់ជំនឿ ។

## 34 ព្រះសហគមន៍ផ្សព្វផ្សាយរហូតដល់ទីដាច់ស្រយាលនៃផែនដី

គ្រីស្តបរិស័ទម្នាក់ចារឹកនៅផ្ទាំងលើសិលាអំពីជំនឿរបស់ខ្លួនលើព្រះយេស៊ូ លើព្រះសហគមន៍ និងអំពីអគ្គសញ្ញាអរព្រះគុណ ។ លោកធ្វើជាសាក្សីបញ្ជាក់ថា ព្រះសហគមន៍នៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល គឺព្រះសហគមន៍ពិតជា «*កាតូលិក*» (ពាក្យនេះប្រែថា *"សកល"*) ។ ត្រី (ជាភាសាក្រិក *"អ៊ិគធូស"*) ជាសញ្ញាសម្គាល់អំពីព្រះគ្រីស្ត ព្រោះអក្សរនៃពាក្យ «*ត្រី*» នោះផ្សំអក្សរផ្ដើមពាក្យ «*ព្រះយេស៊ូ-ព្រះគ្រីស្ត-ព្រះបុត្រា-របស់ព្រះជាម្ចាស់-ជាព្រះសង្គ្រោះ*» ។ លោកចែងតាមរបៀបជាកំណាព្យ ។

*ខ្ញុំឈ្មោះ**អាបែរស៊ីយ៉ូស**ជាសាវ័ករបស់គង្វាលដ៏វិសុទ្ធម្នាក់ដែលឃ្វាលហ្វូងចៀមរបស់គាត់ឲ្យស៊ីស្មៅលើភ្នំ និងតាមវាល ។ គង្វាលនោះភ្នែកធំៗមើលសព្វទិសទី ។ លោកបង្រៀនខ្ញុំអំពីគម្ពីរគួរឲ្យជឿ ។ លោកបាត់ខ្ញុំឲ្យទៅក្រុងរ៉ូមដើម្បីរំពៃមើលព្រះមហាក្សត្រីយានីដ៏ប្រសើរឧត្ដម ពាក់ព្រះពស្ត្រនិងស្បែកជើងធ្វើអំពីមាស ។ នៅទីនោះ ខ្ញុំឃើញប្រជាជនដែលគេបោះត្រាបញ្ចេញពន្លឺរស្មី ។ ខ្ញុំក៏ឃើញវាលស្រុកស៊ីរី និងក្រុងនានាក្រុងនីស៊ីបនៅខាងនាយទន្លេអឺប្រ៉ាត ។ គ្រប់ទីកន្លែងខ្ញុំបានជួបគ្រីស្តបរិស័ទ ។ គ្រប់ទីកន្លែងជំនឿណែនាំខ្ញុំ ជំនឿនោះប្រគល់អាហារឲ្យខ្ញុំ គឺត្រីមួយមកពីប្រភពទឹក ត្រីនេះធំណាស់ បរិសុទ្ធបំផុត ដែលស្រីព្រហ្មចារីដ៏វិសុទ្ធម្នាក់នេសាទឲ្យ ។ ជំនឿប្រគល់ត្រីនោះជាអាហារ ឲ្យមិត្តសំឡាញ់គេដោយឥតឈប់ឈរ ។ ជំនឿក៏មានស្រាដ៏ឆ្ងាញ់ពិសា ដែលគាត់ចែកឲ្យបរិភោគជាមួយអាហារដែរ ។ ខ្ញុំអាបែរស៊ីយ៉ូស អាយុ ៧២ ឆ្នាំ ឲ្យគេសរសេរសេចក្ដីទាំងនេះ ។ សូមបងប្អូនដែលយល់សេចក្ដីទាំងនេះ អង្វរព្រះជាម្ចាស់សម្រាប់អាបែរស៊ីយ៉ូសផង (...) ។*

*សិលាចារិកលើផ្នូររបស់លោកអាបែរស៊ីយ៉ូស*
*ជាអភិបាលព្រះសហគមន៍នៅស្រុកព្រីគី នៅចុងសតវត្សទី ២*

## 35 គ្រីស្តបរិស័ទប្រកាសដំណឹងល្អដល់មនុស្សគ្រប់ឋានៈ វណ្ណៈ ក្នុងសង្គម

លោក**អ៊ូរីសែន**កើតនៅក្រុងអាឡិចសង់ឌ្រី ធ្លាប់ធ្វើដំណើរជាច្រើនដងក្នុងចក្រភពរ៉ូម៉ាំងនិងនៅមជ្ឈិមបូព៌ា ។ លោកប្រកាសដំណឹងល្អ ហើយនិពន្ធសៀវភៅខាងទេវវិជ្ជាបុរាណជាងគេក្រោមចំណងជើងថា «*គោលលទ្ធិដើមដំបូង*» (នៅដើមសតវត្សទី ៣) ។

*បើយើងរិះគិតអំពីដំណឹងល្អចម្រើនឡើងក្នុងរយៈប៉ុន្មានឆ្នាំកន្លងមក ទោះបីគេធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទក្ដី ទោះបីគេដាក់ទណ្ឌកម្មរហូតដល់ស្លាប់ នឹងរឹបអូសយកទ្រព្យសម្បត្តិគេយ៉ាងណាក្ដី ទោះបីអ្នកប្រកាសដំណឹងល្អមានចំនួនតិចក្ដី ក៏យើងបាត់ទុកថា គេប្រកាសដំណឹងល្អលើផែនដីទាំងមូលដែរ ។ ទាំងជនជាតិក្រិក ទាំងអ្នករស់នៅជនបទ ទាំងអ្នកប្រាជ្ញ ទាំងមនុស្សល្ងង់ក៏ជឿលើព្រះគ្រីស្តដែរ ។ យើងជឿជាក់ថា ការចម្រើនយ៉ាងនេះហួសពីកម្លាំងមនុស្ស ដ្បិតព្រះយេស៊ូបានបង្រៀនប្រកបដោយអំណាចគ្រប់យ៉ាង និងបំភ្លឺគេតាមសេចក្ដីត្រូវការដើម្បីឲ្យគេជឿលើព្រះបន្ទូលព្រះអង្គ ។*

*លោកអូរីសែន "គោលលទ្ធិដើមដំបូង" ជំពូក ៤,១.២*

Layout Histor.qxd 2/10/07 10:09 AM Page 62

## 36 គោលលទ្ធិរបស់លោកម៉ារស៊ីយ៉ុង អាចបំបែកបំបាក់ព្រះសហគមន៍បាន

គោលលទ្ធិក្រុមនិងគណៈជាច្រើនអនេកកើតឡើង អាចបណ្ដាលឲ្យដំណឹងល្អរលាយ និងអាចបំបាក់បំបែកព្រះសហគមន៍សកលបាន ។ ហេតុនេះហើយ បានជាលោក**អ៊ីរ៉េណេ**មានបំណងចង់បង្ហាញឲ្យដឹងថា អ្នកអួតខ្លួនថា ព្រះវិញ្ញាណបានសម្ដែងសេចក្ដីអាថ៌កំបាំងដល់គេ សុទ្ធតែជាគ្រីស្តបរិស័ទក្លែងក្លាយ ។ ក្នុងចំណោមអ្នកទាំងនោះ លោក**ម៉ារស៊ីយ៉ុង**មានឈ្មោះល្បីជាងគេ ។ ពាក្យប្រៀនប្រដៅរបស់លោកម៉ារស៊ីយ៉ុងមិនស្មុគ្រស្មាញទេ ហើយក៏មានកត្តវិជ្ជាស្រួលដែរ ហេតុនេះហើយបានជាត្រូវខ្លាចគោលលទ្ធិនោះ ។ លោកម៉ារស៊ីយ៉ុង ញែកព្រះជាម្ចាស់ដែលចែងក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ ជាព្រះអាទិករ និងជាព្រះដ៏កាចសាហាវ ចេញពីព្រះជាម្ចាស់ដែលព្រះយេស៊ូបានសម្ដែង ដែលជាព្រះប្រកបដោយព្រះហឫទ័យមេត្តាករុណាវិញ ។ លោកមិនជឿថា ព្រះយេស៊ូជាព្រះជាម្ចាស់ពិតប្រាកដទេ គ្រាន់ជាព្រះនិមិត្តជាមនុស្សប៉ុណ្ណោះ ហេតុនេះហើយ គាត់មិនព្រមទទួលស្គាល់ថា ព្រះយេស៊ូបានសង្គ្រោះមនុស្សលោកទាំងស្រុងដែរ ។

*លោក**ម៉ារស៊ីយ៉ុង**កើតនៅស្រុកប៉ុនតុស ។ គាត់ប្រៀនប្រដៅដោយអំណួត និងដោយប្រមាថព្រះជាម្ចាស់ ដែលមានចែងក្នុងគម្ពីរធម្មវិន័យនិងក្នុងគម្ពីរព្យាការី ។ តាមគាត់បង្រៀន ព្រះនោះអាក្រក់ ទ្រង់សព្វព្រះហឫទ័យនឹងសង្គ្រាម ចេះតែប្រែប្រួលព្រះហឫទ័យ មានព្រះបន្ទូលផ្ទុយគ្នា ។ រីឯព្រះបិតាដ៏ខ្ពង់ខ្ពស់ជាងព្រះអាទិករ ព្រះអង្គចាត់ព្រះយេស៊ូឲ្យយាងមក ។ ព្រះយេស៊ូយាងមកស្រុកយូដានៅជំនាន់លោក**ប៉ុនពីឡាត**ជាទេសាភិបាលតំណាងព្រះចៅអធិរាជ**ទីប៊ែរ** ។ ព្រះយេស៊ូនិម្មិតខ្លួនជាមនុស្សឲ្យជនជាតិយូដាឃើញ ។ ព្រះអង្គបំបាត់ខ្លឹមសារនៃគម្ពីរព្យាការី គម្ពីរធម្មវិន័យ និងស្នាព្រះហស្ដទាំងឡាយរបស់ព្រះអាទិករ ដែលលោកម៉ារស៊ីយ៉ុង ហៅថា «ព្រះអម្ចាស់នៃពិភពលោក» ។*



*«សេចក្ដីសង្ឃឹមប្រៀបបីដូចជាយុថ្កាមួយ» (ហេប្រឺ ៦,១៩)*

*លើសពីនេះទៅទៀត លោកម៉ារស៊ីយ៉ុង កាត់សេចក្ដីខ្លះចេញពីក្នុងគម្ពីរដំណឹងល្អតាមលោកលូកាចោល គឺលោកលុបបំបាត់សេចក្ដីទាំងប៉ុន្មាន ដែលរៀបរាប់អំពីព្រះអម្ចាស់ប្រសូតជាមនុស្ស និងព្រះបន្ទូលជាច្រើនរបស់ព្រះអម្ចាស់ គឺព្រះបន្ទូលប្រកាសយ៉ាងច្បាស់ថា ព្រះអាទិករនៃពិភពលោក ពិតជាព្រះបិតារបស់ព្រះអង្គ ។ ដូច្នេះ លោកម៉ារស៊ីយ៉ុង នាំកូនសិស្សលោកឲ្យជឿថា លោកត្រឹមត្រូវជាងក្រុមគ្រីស្តទូតដែលបញ្ជូនគម្ពីរដំណឹងល្អមក ។ តែផ្ទុយទៅវិញ គាត់ប្រគល់តែផ្នែកខ្លះនៃគម្ពីរដំណឹងល្អនេះឲ្យគេ លោកមិនប្រគល់គម្ពីរដំណឹងល្អទាំងមូលទេ ។ គាត់ក៏កាត់សេចក្ដីខ្លះក្នុងលិខិតរបស់គ្រីស្តទូត**ប៉ូល**គឺគាត់លុបបំបាត់អត្ថបទបញ្ជាក់យ៉ាងច្បាស់ថា ព្រះជាម្ចាស់ដែលបង្កើតពិភពលោក ក៏ជាព្រះបិតារបស់ព្រះយេស៊ូជាព្រះអម្ចាស់នៃយើងដែរ ។ គាត់ក៏លុបបោលអត្ថបទចែងថា ព្យាការីជូនដំណឹងជាមុនអំពីព្រះអម្ចាស់យាងមក ។*

*តាមលោកម៉ារស៊ីយ៉ុង ព្រះជាម្ចាស់សង្គ្រោះតែវិញ្ញាណមនុស្សទេ គឺវិញ្ញាណរបស់អ្នកដែលរៀនពាក្យប្រៀនប្រដៅរបស់គាត់ប៉ុណ្ណោះ ។ ចំណែករូបកាយវិញ ព្រះជាម្ចាស់មិនសង្គ្រោះទេ ព្រោះព្រះអង្គសូនរូបកាយនេះចេញពីដីមក ។*

*លោកអ៊ីរ៉េណេជាអភិបាលក្រុងលីយ៉ុង*
*"ប្រឆាំងអ្នកវង្វេងឆ្ងាយពីជំនឿ" ១ ជំពូក ២៧,២-៣*

Layout Histor.qxd 2/10/07 10:09 AM Page 63

## *ខ- ក្បួនច្បាប់នៃជំនឿ*

នៅចុងសតវត្សទី ២ លោក**អ៊ីរ៉េណេ** ជាអភិបាលព្រះសហគមន៍ក្រុងលីយ៉ុង
37 សរសេរសៀវភៅ «*ប្រឆាំងអ្នកវង្វេងឆ្ងាយពីជំនឿ*» ។ លោកចែងអំពីលទ្ធិជា
ច្រើនដែលលោកយល់ថា លេលា ។ ក្រោយមកលោកបញ្ជាក់ថា តើឯណាព្រះ
38 សហគមន៍ដ៏ពិតប្រាកដ? ។ តើឯណាទៅលទ្ធិដ៏ពិតប្រាកដ? គ្រីស្តបរិស័ទត្រូវ
តែយោងតាមសេចក្តីប្រៀនប្រដៅដែលក្រុមគ្រីស្តទូតបានបញ្ជូនបន្តមក ។ សេច
ក្តីប្រៀនប្រដៅដ៏ពិតប្រាកដនោះ ស្ថិតនៅតែក្នុងព្រះសហគមន៍ដែលជាប់នឹង
ក្រុមគ្រីស្តទូត ដោយមានអភិបាលឬព្រឹទ្ធាចារ្យបន្តមុខតំណែងតៗគ្នារហូតមក ។
ហេតុនេះហើយ បានជាលោកអ៊ីរ៉េណេ យកចិត្តទុកដាក់ចុះឈ្មោះលោកអភិបាល
ព្រះសហគមន៍ក្រុងរ៉ូមជាបន្តបន្ទាប់ ចាប់តាំងពីលោក**សិលា**និងលោក**ប៉ូល** រៀង
រហូតមក ។

ក្នុងព្រះសហគមន៍ក្រុងស្មៀរណា និងក្រុងអេភេសូ ក៏មានអភិបាលជាបន្ត
បន្ទាប់ចាប់តាំងពីក្រុមគ្រីស្តទូតមកដែរ ។ លោកអ៊ីរ៉េណេ សរសេរលិខិតផ្ញើជូន
មិត្តសំឡាញ់របស់លោកម្នាក់ លោកនឹករឭកទាំងរំជួលចិត្តថា កាលពីមុន លោក
បានស្តាប់លោក**ប៉ូលីកាប** ជាអភិបាលព្រះសហគមន៍ក្រុងស្មៀរណា និយាយអំពី
លោក**យ៉ូហាន** ដែលបានឃើញព្រះអម្ចាស់ ។ ដូច្នេះ ជំនឿនិងមុខងាររបស់លោក 39
អ៊ីរ៉េណេ ជាជំនឿនិងមុខងារតជាប់នឹងព្រះយេស៊ូជាអម្ចាស់ តាមលោកប៉ូលីកាប
និងលោកយ៉ូហានមក ។

### លក្ខណៈព្រះសហគមន៍ដ៏ពិតប្រាកដ

### 37 ព្រះសហគមន៍ប្រកាសដំណឹងល្អតែមួយដូចគ្នាទូទាំងពិភពលោក

បន្ទាប់ពីលោក**អ៊ីរ៉េណេ**ចែងសេចក្តីប្រឆាំងនឹងលទ្ធិក្លែងក្លាយ លោកចែងអំពីលក្ខណៈនៃព្រះសហគមន៍ដ៏ពិតប្រាកដ ។

*ព្រះសហគមន៍ទទួលពាក្យប្រៀនប្រដៅនិងជំនឿនេះ ។ ទោះបីជាព្រះសហគមន៍ខ្ចាត់ខ្ចាយក្នុងពិភពលោកទាំងមូលក្តី ក៏ព្រះសហគមន៍នៅតែថែរក្សាជំនឿនេះដោយប្រុងប្រយ័ត្ន ហាក់ដូចគ្រីស្តបរិស័ទរស់នៅក្នុងផ្ទះតែមួយ ។ ព្រះសហគមន៍មានជំនឿតែមួយ ហាក់ដូចជាមានវិញ្ញាណតែមួយ មានចិត្តគំនិតតែមួយ ។ ព្រះសហគមន៍ប្រកាស បង្រៀន និងបញ្ជូនបន្តជំនឿនេះដោយមានសំឡេងតែមួយ ហាក់ដូចចេញពីមាត់តែមួយ ។*

*ទោះបីភាសាផ្សេងៗពីគ្នាក្នុងពិភពលោកក្តី ក៏សេចក្តីដែលព្រះសហគមន៍បញ្ជូនបន្តនោះ មានតែមួយដដែលនៅគ្រប់កន្លែង ។ ព្រះសហគមន៍ដែលនៅស្រុកសែរម៉ានី (ស្រុកអាល្លឺម៉ង់សព្វថ្ងៃ) ក៏គ្មានជំនឿប្លែក គ្មានសេចក្តីបញ្ជូនបន្តផ្សេងដែរ ។ ព្រះសហគមន៍នៃជនជាតិអ៊ីប៊ែរ (ស្រុកអេស្ប៉ាញសព្វថ្ងៃ) ព្រះសហគមន៍នៃជនជាតិសែលត៍ ព្រះសហគមន៍នៅខាងមជ្ឈិមបូព៌ា នៅស្រុកអេស៊ីប នៅស្រុកលីប៊ី ព្រះសហគមន៍ស្ថិតនៅកណ្តាលពិភពលោក (គឺក្រុងរ៉ូម) ក៏មានជំនឿ និងសេចក្តីបញ្ជូនបន្តតែមួយដូចគ្នាដែរ ។ ព្រះអាទិត្យជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់មានតែមួយ និងបំភ្លឺមនុស្សទាំងអស់ក្នុងពិភពលោកទាំងមូលយ៉ាងណា ក៏ពន្លឺមកពីការប្រកាសសេចក្តីពិត ក៏ភ្លឺគ្រប់ទីកន្លែង និងបំភ្លឺដល់មនុស្សទាំងអស់ដែលចង់ «ស្គាល់សេចក្តីពិតប្រាកដយ៉ាងនោះដែរ» (១ ធម ២,៤) ។*

Layout Histor.qxd 2/10/07 10:09 AM Page 64

38

## ព្រះសហគមន៏បន្តបញ្ជូនសេចក្ដីដែលក្រុមគ្រីស្ដទូតបានបញ្ជូនមក ដោយមានអភិបាលព្រះសហគមន៏បន្តបន្ទាប់រៀងរហូតមក

*អស់អ្នកដែលចង់ឃើញសេចក្ដីពិត អាចស្គាល់សេចក្ដីពិតនោះបានក្នុងគ្រប់ព្រះសហគមន៍ គេអាចស្គាល់សេចក្ដីដែលក្រុមគ្រីស្ដទូតបញ្ជូនបន្តមក ហើយដែលគ្រីស្ដបរិស័ទបង្ហាញក្នុងពិភពលោកទាំងមូល ។ យើងក៏អាចរាយឈ្មោះលោកអភិបាលព្រះសហគមន៍ទាំងប៉ុន្មានដែលក្រុមគ្រីស្ដទូតបានតែងតាំង និងឈ្មោះអស់លោកដែលបន្តមុខតំណែងរបស់អស់លោករហូតមកសព្វថ្ងៃដែរ (...) ។ ក្រុមគ្រីស្ដទូតចង់ឲ្យអភិបាលដែលបន្តមុខតំណែងរបស់ខ្លួន និងទទួលភារកិច្ចបង្រៀននោះបានសុក្រិត្យ និងល្អឥតខ្ចោះ គ្មានកំហុសណាមួយសោះ (...) ។ ប៉ុន្តែ នៅក្នុងសៀវភៅនេះ យើងមិនអាចរាយឈ្មោះអស់លោកអភិបាលដែលបន្តមុខតំណែងរបស់គ្រីស្ដទូត ក្នុងព្រះសហគមន៍ទាំងអស់បានទេ ខ្លាចវែងពេក ។ យើងសូមលើកយកឧទាហរណ៍ព្រះសហគមន៍តែមួយប៉ុណ្ណោះ គឺព្រះសហគមន៍ក្រុងរ៉ូម ដែលធំនិងបុរាណជាងគេ ដែលគេស្គាល់គ្រប់គ្នា ហើយមានគ្រីស្ដទូតដ៏ប្រសើរពីរនាក់ គឺលោក**ប៉ូល**និងលោក**សិលា**បានតែងតាំង ។ យើងនឹងបង្ហាញឲ្យដឹងថា សេចក្ដីដែលព្រះសហគមន៍នោះទទួលពីក្រុមគ្រីស្ដទូត ហើយក៏បញ្ជូនបន្តមក និងជំនឿដែលព្រះសហគមន៍នេះប្រកាសឲ្យមនុស្សបានមកដល់យើង ដោយមានអភិបាលជាបន្តបន្ទាប់រហូតមក ។ ដូច្នេះ យើងនឹងផ្ចាញ់ផ្ចាលអស់អ្នកដែលបង្កើតក្រុមផ្ដេសផ្ដាស ដោយមូលហេតុណាមួយក្ដី ដោយអួតខ្លួនក្ដី ដោយស្វែងរកកិត្តិយសដ៏ឥតបានការក្ដី ដោយមិនដឹងខ្លួនក្ដី ឬដោយវង្វេងក្ដី ។*

*ព្រះសហគមន៍ណាក៏ដោយ គឺគ្រីស្ដបរិស័ទពីគ្រប់កន្លែងត្រូវតែរួមចិត្តគំនិតជាមួយនឹងព្រះសហគមន៍រ៉ូមនេះជាចំបាច់ ព្រោះព្រះសហគមន៍នេះមានដើមកំណើតយ៉ាងប្រសើរជាងគេ ហើយក្នុងព្រះសហគមន៍រ៉ូមនេះ គេថែរក្សាសេចក្ដីដែលបញ្ជូនបន្តពីក្រុមគ្រីស្ដទូតមកជានិច្ច ដើម្បីជាប្រយោជន៍ដល់មនុស្សនៅគ្រប់កន្លែង ។*

*លោកអ៊ីរ៉េណេ ជាអភិបាលព្រះសហគមន៍នៅក្រុងលីយ៉ុង*
*"ប្រឆាំងអ្នកវង្វេងឆ្ងាយពីជំនឿ" ជំពូក ៣, ១-២*

39

## ពីលោកអ៊ីរ៉េណេ ទៅដល់ព្រះយេស៊ូ

ប្រហែលគ.ស. ១៩០ លោក**អ៊ីរ៉េណេ**សរសេរលិខិតផ្ញើជូនមិត្តសម្លាញ់ម្នាក់ឈ្មោះ**ហ្វ្លូរិនូស** ដែលចូលក្រុមដាច់ឆ្ងាយពីជំនឿ ។ លោករំឭកសម្លាញ់នោះថា កាលនៅពីក្មេង អ្នកទាំងពីរតែងតែស្ដាប់លោកប៉ូលីកាប ។ លោកប៉ូលីកាប ភ្ជាប់លោកអ៊ីរ៉េណេទៅនិងសម្លាញ់លោកជាមួយព្រះគ្រីស្ដតាមរយៈលោកយ៉ូហាន ។

*ខ្ញុំអាចនិយាយអំពីកន្លែងលោកប៉ូលីកាប តែងតែអង្គុយដើម្បីនិយាយអំពីរបៀបលោកចេញចូល របៀបលោករស់នៅ អំពីរូបរាង អំពីលោកសន្ទនានៅមុខបណ្ដាជន អំពីរបៀបលោកទាក់ទងជាមួយលោកយ៉ូហាន និងគ្រីស្ដទូតឯទៀតៗដែលបានឃើញព្រះអម្ចាស់ របៀបលោកនឹករលឹកប្រសាសន៍របស់អស់លោក និងអ្វីៗដែលអស់លោកបានឮគេនិយាយអំពីព្រះអម្ចាស់ អំពីការអស្ចារ្យ និងអំពីសេចក្ដីដែលព្រះអង្គបង្រៀន ។ លោក**ប៉ូលីកាប**ទទួលសេចក្ដីទាំងនោះពីសាក្សីដែលឃើញព្រះអម្ចាស់ជាព្រះបន្ទូលរស់នៅដោយផ្ទាល់នឹងភ្នែក ហើយរៀបរាប់ស្របតាមគម្ពីរ ។ ដោយព្រះជាម្ចាស់មេត្តាករុណាដល់រូបខ្ញុំ ខ្ញុំក៏បានស្ដាប់សេចក្ដីទាំងនេះដោយយកចិត្តទុកដាក់ ខ្ញុំកត់ត្រាទុកមិនមែនលើក្រដាសទេ គឺខ្ញុំបានកត់ត្រាទុកក្នុងចិត្តខ្ញុំវិញ ។ ដោយព្រះជាម្ចាស់នៅតែប្រណីសន្ដោស ខ្ញុំនឹកសញ្ជឹងគិត ទំពាដោយចិត្តស្មោះ ។ ដូច្នេះ ខ្ញុំហ៊ានបញ្ជាក់ចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ថា ប្រសិនបើព្រឹទ្ធាចារ្យជាគ្រីស្ដទូតនោះបានឮសេចក្ដីដូចបង**ហ្វ្លូរីនូស**និយាយនោះ លោកមុខជានឹងស្រែកហើយបិទត្រចៀកពុំខានឡើយ (...) ។*

*តាមលោកអឺសែប ជាអភិបាលព្រះសហគមន៍ក្រុងសេសារ៉េ*
*"ប្រវត្តិព្រះសហគមន៍" ជំពូក ៥, ២២,៦-៧*

### *គ- គម្ពីររបស់គ្រីស្តបរិស័ទ*

លោក**អ៊ីរ៉េណេ**សូមកុំទទួលស្គាល់គម្ពីរណាក្រៅពីគម្ពីរក្រុមអភិបាលបញ្ជូនបន្តវៀងមក ។ តើត្រូវធ្វើយ៉ាងណា? រហូតដល់ដើមសតវត្សទីពីរ គ្រីស្តបរិស័ទមិនបានចាប់អារម្មណ៍ថា គម្ពីរសម្រាប់តែក្រុមគេទេ ព្រោះទាំងគ្រីស្តបរិស័ទ និងអ្នកកាន់សាសនាយូដាតែងយល់ថា គម្ពីរមានតែមួយគត់ គឺគម្ពីរដែលយើងហៅសព្វថ្ងៃថា «*គម្ពីរសម្ពន្ធមេត្រីចាស់*» ។ ប៉ុន្តែ ពេលគ្រីស្តបរិស័ទអានគម្ពីរ គេយល់អត្ថន័យតាមរបៀបប្លែកពីអ្នកកាន់សាសនាយូដា គឺគេយល់ឃើញថា គម្ពីរនោះទស្សន៍ទាយអំពីព្រះគ្រីស្ត ។ ពេលគេអានគម្ពីរ គេចង់ស្គាល់ព្រះយេស៊ូ និងឋានៈរបស់ព្រះអង្គ ជាជាងចង់ស្គាល់ប្រវត្តិរបស់ជនជាតិហេប្រឺ ។

អ្នកដែលចង់និយាយអំពីព្រះយេស៊ូ ត្រូវតែនឹកគិតដល់សក្ខីភាពរបស់ក្រុមគ្រីស្តទូត និងរបស់អស់អ្នកដែលរស់នៅជាមួយអស់លោក ។ មុនដំបូងក្រុមគ្រីស្តទូតផ្តល់សក្ខីភាពដោយផ្ទាល់មាត់ ។ ពេលអស់លោកមិននៅជាមួយ ឬពេលអស់លោកទទួលមរណភាពទៅ គ្រីស្តបរិស័ទនាំគ្នាកត់ត្រាទុកជាលាយលក្ខណ៍អក្សរនូវសេចក្តីដែលអស់លោកបាននិយាយ ។ ប៉ុន្តែ អ្នកនិពន្ធជាច្រើនធ្លាប់យកឈ្មោះគ្រីស្តទូតទុកជាអ្នកនិពន្ធសំណេរបស់ខ្លួន ដើម្បីឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់នឹងសៀវភៅរបស់គេ ។ ក្រុមតូចៗសុទ្ធតែអួតថា មានសៀវភៅដំណឹងល្អមួយពិសេសដែលគ្រីស្តទូតម្នាក់បាននិពន្ធ គឺមានសៀវភៅដំណឹងល្អតាមលោក**ថូម៉ាស** លោក**យ៉ាកុប** លោក**ប៉ូល** លោក**សិលា** ។ល ។ ក្រុមខ្លះជ្រើសរើសតែអត្ថបទខ្លះមកកត់ទុកតាមអំពើចិត្តរបស់គេ មានលោក**ម៉ារស៊ីយ៉ុង**ជាដើម ។

ដោយមានសៀវភៅជាច្រើនកើតឡើង ព្រះសហគមន៍ស្វែងរកលក្ខណៈខ្លះដើម្បីបញ្ជាក់ថា សៀវភៅនេះជាគ្រឹះនៃជំនឿរបស់ខ្លួន ។ គ្រីស្តបរិស័ទយល់ឃើញថា គម្ពីរជាគ្រឹះនៃជំនឿ គឺគម្ពីរគ្រីស្តទូតនិពន្ធ ។ ប៉ុន្តែ អ្នកនិពន្ធក្លែងក្លាយជាច្រើនអួតថា សំណេរបស់ខ្លួនជាស្នាដៃរបស់គ្រីស្តទូតម្នាក់និពន្ធ ។ គ្រីស្តបរិស័ទកំណត់បញ្ជីក័ណ្ឌគម្ពីរជាច្រើន (*សាសនបញ្ញត្តិ*) នៅសតវត្សទី ២ ។ ចំពោះលោក**អ៊ីរ៉េណេ**មានគម្ពីរដំណឹងល្អតែបួនក័ណ្ឌប៉ុណ្ណោះ ដែលគ្រីស្តបរិស័ទទូទៅទទួលស្គាល់ជាសកល ។ លោកពន្យល់ថា គម្ពីរដំណឹងល្អទាំងបួននេះ ពិតជាស្នាដៃរបស់គ្រីស្តទូតម្នាក់ផ្ទាល់ ឬជាស្នាដៃរបស់កូនចៅរបស់អស់លោក គឺលោកទទួលស្គាល់**គម្ពីរដំណឹងល្អទី ១** ទុកជាស្នាដៃរបស់គ្រីស្តទូត**ម៉ាថាយ គម្ពីរដំណឹងល្អទី ២** ទុកជាស្នាដៃលោក**ម៉ាកុស**ជាកូនចៅរបស់លោក**សិលា គម្ពីរតាមលោកលូកា និងកិច្ចការ**ជាស្នាដៃរបស់លោក**លូកា** ជាកូនចៅរបស់លោក**ប៉ូល គម្ពីរដំណឹងល្អទី ៤** ទុកជាស្នាដៃរបស់គ្រីស្តទូត**យ៉ូហាន**និពន្ធ ។ លោកអ៊ីរ៉េណេ ក៏ទទួលស្គាល់លិខិតពីរច្បាប់របស់លោកសិលា លិខិតនានារបស់លោកប៉ូល ព្រមទាំងវិវរណៈ និងលិខិតបីច្បាប់របស់លោកយ៉ូហានដែរ ។ ពាក់កណ្តាលសតវត្សទី ១៨ លោក**ម៉ូរ៉ាតូរី**រកឃើញឯកសារមួយដែលគ្រីស្តបរិស័ទក្រុងរ៉ូមចែងប្រហែលនៅ គ.ស. ១៥០ បញ្ជាក់បញ្ជីក័ណ្ឌគម្ពីរដែលពួកគេទទួលស្គាល់នោះ ។ ជួនកាលគ្រីស្តបរិស័ទស្ទាក់ស្ទើររួញរាមិនព្រមទទួលស្គាល់ក័ណ្ឌគម្ពីរខ្លះ (*ឧប. វិវរណៈ យូដា ។ល ។*) ។ ផ្ទុយទៅវិញ គ្រីស្តបរិស័ទខ្លះទទួលស្គាល់សៀវភៅ «*ឌីដាខេ*» «*គង្វាល*» របស់លោក**ហេរម៉ាស** «*លិខិតលោកបារណាបា*» ទុកជាគម្ពីរ ។ នៅចុងសតវត្សទីពីរ ព្រះសហគមន៍បញ្ជាក់សាសនាបញ្ញត្តិនៃគម្ពីរសម្ពន្ធមេត្រីថ្មីជាស្ថាពរ ។

*(សូមអាន "ដើមកំណើតគម្ពីរសម្ពន្ធមេត្រីថ្មី" ទំព័រ ៨០-១០៥)*

## ៣- កំណើតនៃទេវវិទ្យា

ពេលឃើញលទ្ធិក្លែងក្លាយជាច្រើនកើតឡើង អស់លោកទទួលខុសត្រូវលើព្រះសហគមន៍ ក៏យកចិត្តទុកដាក់បំភ្លឺចិត្តគំនិតគ្រីស្តបរិស័ទ អំពីជំនឿដ៏ពិតរបស់ព្រះសហគមន៍ ។ អស់លោកបកស្រាយគម្ពីរដែលគ្រីស្តបរិស័ទទទួលស្គាល់គ្រប់គ្នានោះដោយមានបំណងបង្ហាញថា ព្រះគ្រីស្តពិតជាធ្វើឲ្យគម្ពីរសម្ពន្ធមេត្រីចាស់ទាំង

មូលកើតជារូបរាងហើយ ។ អស់លោកបកស្រាយអត្ថន័យគម្ពីរដោយផ្ទាល់មាត់
ក្នុងពិធីអរព្រះគុណ និងពេលអប់រំជំនឿអ្នកស្វែងយល់ ។ អភិបាល បូជាចារ្យ
និងអ្នកផ្សេងទៀតជាច្រើន និពន្ធសៀវភៅ ហើយបង្កើតទេវវិទ្យាដើមដំបូង ។

ដើមសតវត្សទី ២ លោក**អ៊ីញ៉ាស**ជាអភិបាលព្រះសហគមន៍ក្រុងអន់ទីយ៉ូក
សរសេរលិខិត ៧ ច្បាប់ ដើម្បីជួយព្រះសហគមន៍ទាំងអស់នៅអាស៊ីមីន័រ ឲ្យ
រក្សាជំនឿ ។ ពេលនោះ គ្រីស្តបរិស័ទជាច្រើនតែងនិយាយថា ព្រះយេស៊ូជាព្រះ
មួយអង្គដែលនិម្មិតខ្លួនជាមនុស្ស ។ ផ្ទុយទៅវិញ លោកអ៊ីញ៉ាសបញ្ជាក់យ៉ាងខ្លាំង
ថា ព្រះយេស៊ូជាមនុស្សដ៏ពិតប្រាកដ ដូចមនុស្សឯទៀតៗបេះបិទ ព្រះអង្គពិត
ជាប្រសូតតាមប្រវត្តិសាស្ត្រមែន ។ គ្រីស្តបរិស័ទអាចជួបព្រះយេស៊ូបាននៅក្នុង
32 ព្រះសហគមន៍ ដែលរួមគ្នាថ្វាយពិធីអរព្រះគុណ ។ លោកសរសេរថា «*សូមចូល
រួមក្នុងពិធីអរព្រះគុណតែមួយគត់ ដ្បិតមានព្រះកាយតែមួយរបស់ព្រះយេស៊ូគ្រីស្ត
ជាអម្ចាស់នៃយើង មានពែងតែមួយដែលបង្រួបបង្រួមយើង ក្នុងព្រះលោហិត
របស់ព្រះអង្គប៉ុណ្ណោះ* (...) *មានអភិបាលតែមួយដែរ*» (...) ។

36 លោក**អ៊ីរ៉េណេ**ជាអភិបាលព្រះសហគមន៍ក្រុងលីយ៉ុង ខិតខំដោះស្រាយ
ជម្លោះអំពីកាលបរិច្ឆេទនៃបុណ្យចម្លង ហើយជំទាស់នឹងអស់អ្នកដែលអួតថា
ព្រះយេស៊ូបានសម្ដែងសេចក្ដីអស្ចារ្យដល់ពួកគេផ្ទាល់ ។ លោកអ៊ីរ៉េណេសរសេរ
37 សៀវភៅពីរច្បាប់ មានចំណងជើងថា «*ប្រឆាំងអ្នកវង្វេងឆ្ងាយពីជំនឿ*» និង
38 «*ការពន្យល់អំពីសេចក្ដីប្រកាសរបស់ក្រុមគ្រីស្តទូត*» ដើម្បីអប់រំជំនឿអ្នកស្វែង
យល់តាមគម្ពីរ ។ លោកអ៊ីរ៉េណេបាត់បែងទេវវិជ្ជា ដោយយកសេចក្ដីដែលគ្រីស្ត
ទូតប៉ូលថែងអំពីព្រះគ្រីស្ត «*ប្រមូលអ្វីៗទាំងអស់ឲ្យរួមនៅក្នុងអង្គតែមួយ*» (អភ
១,១០) មកធ្វើជាគ្រឹះ ។ ប្រវត្តិមនុស្សជាតិប្រៀបដូចជាដំណើរដ៏យឺតយ៉ាវក្រោម
ការណែនាំនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ពេលព្រះបន្ទូលព្រះជាម្ចាស់ប្រសូត
ជាមនុស្សក្នុងព្រះយេស៊ូ ព្រះបន្ទូលនោះប្រមូលមនុស្សទាំងអស់ ហើយប្រមូល
ប្រវត្តិសកលលោកទាំងមូលក្នុងព្រះអង្គផ្ទាល់ ។ លោកសរសេរថា៖ «*សិរីរុងរឿង
របស់ព្រះជាម្ចាស់ គឺមនុស្សដែលមានជីវិតរស់នៅ រីឯជីវិតមនុស្ស គឺការមើល
ឃើញព្រះជាម្ចាស់*» ។

លោក**អូរីសែន**មានដើមកំណើតនៅក្រុងអាឡិចសង់ឌ្រី (ស្រុកអេស៊ីប គ.ស.
១៨៥-២៥៣) ។ លោកអប់រំជំនឿអ្នកស្វែងយល់ និងប្រកាសដំណឹងល្អអស់មួយ
ជីវិត ។ លោកអូរីសែន ណែនាំសាលាអប់រំជំនឿអ្នកស្វែងយល់ លោកបាត់បែង 39



*កំលោះ គឺលោកម៉ាថាយ*



*តោ គឺលោកម៉ាកុស*



*គោ គឺលោកលូកា*


*ឥន្ទ្រី គឺលោកយ៉ូហាន*

*រូបសត្វជានិមិត្តរូបអំពីអ្នកនិពន្ធគម្ពីរដំណឹងល្អទាំង ៤ នាក់ (តាមលោកអ៊ីរ៉េណេ)*

Layout Histor.qxd 2/10/07 10:09 AM Page 67

សាលារបៀបនេះមុនគេ ។ លោកធ្វើដំណើរជាច្រើនកន្លែង ។ ពេលលោកនៅក្រុងសេសារេ ស្រុកប៉ាលេស្ទីន លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ហើយបង្កើតបណ្ណាល័យយ៉ាងធំមួយ ប្រមូលសៀវភៅដែលគ្រីស្តបរិស័ទនិពន្ធ ។ លោកទទួលមរណភាពដោយរងទារុណកម្ម នៅពេលព្រះចៅ**ដេស្យ**ធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ ។ លោកអូរីសែនពន្យល់អត្ថាធិប្បាយព្រះគម្ពីរអស់មួយជីវិត ។ លោកសរសេរសៀវភៅជាច្រើន តែសៀវភៅទាំងនោះភាគច្រើនបាត់បង់ ព្រោះ
40 ពីរសតវត្សក្រោយ គ្រីស្តបរិស័ទខ្លះចោទលោកថា វង្វេងដាច់ឆ្ងាយពីជំនឿ ។

លោកអូរីសែនយល់ថា ព្រះគ្រីស្តគង់នៅក្នុងគម្ពីរទាំងមូល គឺតួអង្គក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ និងព្រឹត្តិការណ៍នានាដែលកើតឡើងតាមប្រវត្តិប្រជាជនអ៊ីស្រាអែលសុទ្ធតែទស្សន៍ទាយអំពីព្រះគ្រីស្ត អំពីអគ្គសញ្ញានានា និងអំពីព្រះសហគមន៍ ។ លោកយោងគំនិតតាមទស្សនវិជ្ជាក្រិកមកសរសេរថា មនុស្សមានរូបកាយ និងមានជីវិត និងមានវិញ្ញាណយ៉ាងណា ក៏ព្រះគម្ពីរមានអត្ថន័យបីយ៉ាងនោះដែរ
គឺមានអត្ថន័យតាមប្រវត្តិសាស្ត្រ តាមសីលធម៌ និងតាមវិញ្ញាណ ។ ដូច្នេះ លោក 41
អូរីសែន ពន្យល់គម្ពីរដោយបកស្រាយតាមនិមិត្តរូបដែលសព្វថ្ងៃលំបាកយល់ ។



*ថូ និង នំប៉័ង ជានិមិត្តរូបអំពីអគ្គសញ្ញាអរព្រះគុណ ។ ក្ងោក ជានិមិត្តរូបអំពីជីវិតអមតៈ ។ ផ្សោត និង យុថ្កា ជានិមិត្តរូបអំពីសេចក្ដីសង្ឃឹម ។*

# លោកអ៊ូរីសែន (១៨៥_២៥៣)

## 40 ព្រះគម្ពីរមានអត្ថន័យខាងវិញ្ញាណជានិច្ច ប៉ុន្តែជួនកាលគ្មានអត្ថន័យខាងប្រវត្តិសាស្ត្រទេ

*កំពែងក្រុងយេរីខូត្រូវរលំ ពេលជនជាតិហេប្រឺផ្លុំត្រែ ។ ក្រុងយេរីខូនេះ ជានិមិត្តរូបអំពីពិភពលោក ។ យើងយល់ឃើញថា ស្នូរត្រែរបស់ព្រឹទ្ធាចារ្យបំផ្លាញកម្លាំង និងកំពែងនៃពិភពលោក ។ កម្លាំងនិងកំពែងទាំងនេះ ជានិមិត្តរូបអំពីការគោរពបូជាព្រះក្លែងក្លាយ (...) ។ លោក**យ៉ូស៊ូអា**ដែលជានិមិត្តរូបអំពីព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើង ដែលយាងមកតាមក្រោយ ។ ព្រះអង្គចាត់គ្រីស្តទូតដូចលោកយ៉ូស៊ូអា ចាត់ពួកបូជាចារ្យដែលកាន់ត្រែលាន់ឮឡើងរំពង ជានិមិត្តរូបអំពីដំណឹងល្អ (...) ។*

*នៅពេលនោះ គ្រឿងទាំងប៉ុន្មានសម្រាប់គោរពបូជាព្រះក្លែងក្លាយ និងគោលលទ្ធិនៃទស្សនវិទូ ត្រូវរលាយដល់គ្រឹះ ។*

*សេចក្ដីអត្ថាធិប្បាយអំពី "គម្ពីរយ៉ូស៊ូអា"*

## 41 អ្នកស្រុកសាម៉ារីមានចិត្តសប្បុរស (លក ១០,៣០–៣៧)

*«បុរសម្នាក់ធ្វើដំណើរពីក្រុងយេរូសាឡឹមឆ្ពោះទៅក្រុងយេរីខូ» ។ យើងយល់ឃើញថា បុរសនោះគឺជាលោកអដាំ គឺមនុស្សនិងវាសនាដ៏ពិតប្រាកដរបស់ខ្លួន ។ ក្រោយពីលោកអដាំប្រព្រឹត្តអំពើបាប លោកធ្លាក់ដល់ដី ។ «ក្រុងយេរូសាឡឹម» គឺស្ថានបរមសុខ ឬក្រុងយេរូសាឡឹមនៃស្ថានបរមសុខ ។ «ក្រុងយេរីខូ» គឺពិភពលោក ។ «ពួកចោរ» គឺអំណាចដែលប្រឆាំងនឹងមនុស្ស គឺពួកមារ និងគ្រូអាចារ្យក្លែងក្លាយ ដែលបានមកមុនព្រះគ្រីស្ត ។ «ស្នាមរបួស» គឺអំពើបាបនិងការមិនស្ដាប់តាមព្រះជាម្ចាស់ ។ «គេប្លន់ខោអាវ» ជានិមិត្តរូបអំពីមនុស្សបាត់បង់សភាពដែលមិនចេះរលួយ និងភាពអមតៈរបស់ខ្លួន ព្រមទាំងបាត់បង់ព្រហ្មវិហារធម៌ទាំងប៉ុន្មាន ។ «ទុកគាត់ចោលមិនដឹងខ្លួន» ជានិមិត្តរូបអំពីមនុស្សជាតិយើងសព្វថ្ងៃ ដែលមិនដឹងខ្លួនជិតស្លាប់ (រីឯវិញ្ញាណមានជីវិតអមតៈវិញ) ។ «បូជាចារ្យ» គឺធម្មវិន័យ ។ «ពួកលេវី» សំដៅទៅលើព្យាការី ។ «ជនជាតិសាម៉ារី» គឺព្រះគ្រីស្តដែលចាប់កំណើតមកជាមនុស្សក្នុងផ្ទៃនាងម៉ារី ។ «សត្វជំនិះ» គឺព្រះកាយព្រះគ្រីស្ត ។ «ស្រា» គឺព្រះបន្ទូលរបស់ព្រះគ្រីស្ត (ដែលប្រោសឲ្យជាសះស្បើយ) ។ «ប្រេង» គឺព្រះបន្ទូលមេត្តាករុណាចំពោះមនុស្សលោក និងព្រះហឫទ័យសប្បុរស ។ «ផ្ទះសំណាក់» គឺជាព្រះសហគមន៍ ។ «ម្ចាស់ផ្ទះសំណាក់» គឺក្រុមគ្រីស្តទូត និងអស់លោកដែលបន្តមុខងាររបស់ក្រុមគ្រីស្តទូត និងគ្រូបាធ្យាយនៃព្រះសហគមន៍ (...) ។ «ជនជាតិសាម៉ារីដែលមកវិញ» គឺព្រះគ្រីស្តយាងមកលើកទីពីរ ។*

*លោកអ៊ូរីសែន "សេចក្ដីអត្ថាធិប្បាយគម្ពីរដំណឹងល្អលោកលូកា ២"*

Layout Histor.qxd 2/10/07 10:09 AM Page 69

លោក**ទែរទូលីយ៉ាំង**ថែងថា «*លោហិតរបស់មរណសាក្សី ពិតជាពូជបង្កើតគ្រីស្តបរិស័ទ*» ព្រោះនៅពេលលោកកាន់សាសនាដទៃ លោកស្ងើចសរសើរចិត្ត
14 15 ក្លាហានរបស់គ្រីស្តបរិស័ទ ដែលទាញចិត្តលោកឲ្យបែរទៅជឿលើព្រះគ្រីស្ត ។
28 29 លោកមានចិត្តខ្លាំងក្លា ។ ពេលលោកចាស់ លោកចូលក្រុមដាច់ឆ្ងាយពីជំនឿ គឺក្រុមដែលកាន់យ៉ាងតឹងរ៉ឹងនិងប្រកាន់គេ ។ ពេលនោះ លោកប្រឆាំងនឹងព្រះសហគមន៍នៅក្រុងកាតាស្ស និងនៅក្រុងរ៉ូម ។ ទោះបីលោកមានទេពកោសល្យជាអ្នកប្រឆាំងក្តី ក៏មិនត្រូវបំភ្លេចថា លោកជាទេវវិទូដ៏ចំណាប់ គឺលោកជ្រើសរើសពាក្យពេចន៍នៃភាសាឡាតាំងសម្រាប់រិះគិតអំពីជំនឿនៃគ្រីស្តសាសនា ។

លោក**ស៊ីព្រីយ៉ាំង** (គ.ស. ២០០-២៥៨) ជាអ្នកកាន់សាសនាដទៃ ។ លោកយល់ឃើញថា គ្រីស្តសាសនាផ្តល់សេរីភាពខាងផ្លូវចិត្ត លោកក៏ប្រែចិត្តជឿលើព្រះគ្រីស្ត ។ លោកទៅជាបូជាចារ្យនិងជាអភិបាលព្រះសហគមន៍ក្រុងកាតាស្ស ។ ពេលមួយ លោកខ្វែងគំនិតជាមួយនឹងអភិបាលព្រះសហគមន៍ក្រុងរ៉ូមអំពីអគ្គសញ្ញាជ្រមុជទឹក ។ នៅព្រះសហគមន៍ក្រុងកាតាស្ស លោកតែងធ្វើអគ្គសញ្ញាជ្រមុជទឹកម្តងទៀត ជូនអ្នកដែលលះបង់ជំនឿ បន្ទាប់ពីគេប្រែចិត្តគំនិតមកវិញ ។ រីឯនៅក្រុងរ៉ូម លោកអភិបាលចាត់ទុកថា អគ្គសញ្ញាជ្រមុជទឹកលើកទី ១ នៅតែបានការ ។ លោកស៊ីព្រីយ៉ាំង បូជាជីវិតជាមរណសាក្សី ។ លោកពិតជាគង្វាលព្រះសហគមន៍ ។ ក្នុងសៀវភៅទាំងប៉ុន្មានដែលលោកសរសេរ លោកថែងអំពីការរស់នៅជាគ្រីស្តរិស័ទ គឺអំពីការអធិដ្ឋាន ការធ្វើទាន ។ល ។ ក្រោយពីព្រះចៅអធិរាជធ្វើទុក្ខបុកម្នេញ លោកសរសេរសៀវភៅជាច្រើន ដោយមានបំណងចង់ការពារព្រះសហគមន៍ ។ ប្រសិនបើព្រះសហគមន៍រួបរួមជាធ្លុងតែមួយ ព្រះសហគមន៍ពិតជាសញ្ញាសម្គាល់បញ្ជាក់ថា គ្រីស្តបរិស័ទពិតជារួមរស់ជាមួយព្រះគ្រីស្តមែន ។ ព្រះសហគមន៍រួបរួមគ្នាជាធ្លុងតែមួយ លុះត្រាតែអភិបាលទាំងប៉ុន្មានរួបរួមគ្នាដែរ ។ លោកស៊ីព្រីយ៉ាំង ថែងអំពីតួអង្គជាច្រើន និងព្រឹត្តិការណ៍ជាច្រើនដែលកើតឡើងក្នុងសម័យនោះ ។



*ត្រីនិងនំបុ័ង ជានិមិត្តរូបអំពីព្រះកាយព្រះគ្រីស្ត*

Layout Histor.qxd 2/10/07 10:09 AM Page 70



# ព្រះសហគមន៍នៅសម័យចក្រភពគ្រីស្តបរិស័ទ

## (ពីសតវត្សទី ៤–៥)

### ព្រះសហគមន៍តាមបែបព្រះចៅអធិរាជកុងស្តង់តាំង (Constantin)

*នៅគ.ស. ៣១៣ ព្រះសហគមន៍បានសចក្តីសុខសាន្ត ។ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រចាត់ គ.ស. ៣១៣ ទុកជាដើមសម័យ «ព្រះសហគមន៍តាមបែបព្រះចៅកុងស្តង់តាំង» គឺសំដៅទៅលើទំនាក់ទំនងថ្មីរវាងព្រះសហគមន៍និងសង្គម ។ ព្រះសហគមន៍រស់នៅក្នុងចក្រភពមួយ ដែលចាត់ខ្លួនថាជាគ្រីស្តបរិស័ទ ។ នេះជាមូលហេតុបណ្តាលឲ្យរដ្ឋអំណាចជ្រៀតចូលក្នុងការរស់នៅរបស់ព្រះសហគមន៍ និងមានបំណងឲ្យព្រះសហគមន៍គាំទ្រនយោបាយរបស់រដ្ឋអំណាចវិញ ។ ព្រះចៅអធិរាជខិតខំសម្របសម្រួលជម្លោះនានាក្នុងព្រះសហគមន៍ អំពីគោលលទ្ធិគ្រីស្តសាសនា ដែលបណ្តាលឲ្យកើតអសន្តិសុខក្នុងសង្គម ។ ទ្រង់ក៏កោះហៅអភិបាលនានាឲ្យមកប្រជុំជាមហាសន្និបាត ។ ពេលនោះ ព្រះសហគមន៍ទទួលអត្ថប្រយោជន៍ពីរដ្ឋអំណាច គឺរដ្ឋអំណាចជួយឧបត្ថម្ភជាថវិកា ជាសម្ភារៈ និងបង្កើតច្បាប់សម្រាប់អនុគ្រោះដល់ព្រះសហគមន៍ទៀតផង ។ ព្រះសហគមន៍ក៏ពឹងលើព្រះចៅអធិរាជ ដើម្បីប្រឆាំងនឹងគ្រីស្តបរិស័ទដែលវង្វេងជំនឿ និងដើម្បីប្រឆាំងអ្នកកាន់សាសនាដទៃ ។*

*តាមធម្មតា អ្នកនិយាយអំពីព្រះសហគមន៍តាមបែបព្រះចៅកុងស្តង់តាំង យល់ឃើញថា របៀបព្រះសហគមន៍រស់នៅពេលនោះ មិនសូវល្អប៉ុន្មានទេ គឺគេយល់ថា តាំងពីពេលនោះមក ព្រះសហគមន៍ហាក់ដូចជាជាប់ក្នុងក្របខ័ណ្ឌនយោបាយ និងវប្បធម៌ដ៏ជ្រៅម្យ៉ាង ធ្វើឲ្យដំណឹងល្អរបស់ព្រះគ្រីស្តសាបរលាប ។ គ្រីស្តបរិស័ទខ្លះយល់ឃើញថា ព្រះសហគមន៍បែបព្រះចៅ**កុងស្តង់តាំង**ចប់នៅមហាសន្និបាតសកលវ៉ាទីកង់ទី ២ (១៩៦២-១៩៦៥) ដែលទទួលស្គាល់ថា សាសនានិងរដ្ឋអំណាច ជាវិស័យ ២ ប្លែកពីគ្នា ។*

*តាមពិត ការប្រែប្រួលនៃព្រះសហគមន៍នៅសម័យនោះ ចាប់ផ្តើមវិវត្តន៍មុនសម័យព្រះចៅកុងស្តង់តាំង ហើយក៏បន្តនៅពេលក្រោយទៀត ។ នៅចុងសតវត្ស ទី ៣ មានអភិបាលព្រះសហគមន៍ខ្លះកាន់អំណាចតាមលំនាំប្រហាក់ប្រហែលនឹងអភិបាលខេត្តនៃរដ្ឋអំណាចរ៉ូម៉ាំង ។ ម្យ៉ាងទៀត*

*គ្រីស្តសាសនាបែរទៅជាសាសនារដ្ឋ  តែក្នុងរជ្ជកាលព្រះចៅ**ទេអូដូស** (Théodose) ប៉ុណ្ណោះ (៣៨០) ។*

*ការប្រែប្រួលនោះ បណ្តាលមកពីព្រះសហគមន៍ទទួលឥទ្ធិពលពីវប្បធម៌  និងពីច្បាប់រដ្ឋអំណាចនៅសម័យនោះ  មិនមែនមកពីបំណងអ្នកទទួលខុសត្រូវលើព្រះសហគមន៍  និងអ្នកដឹកនាំរដ្ឋទេ ។*

*ក្នុងជំពូកនេះ មានចែងអំពីព្រះសហគមន៍ប្រែប្រួលក្នុងចក្រភពដែលយោគយល់ដល់ព្រះសហគមន៍  ម្យ៉ាងទៀត ព្រះសហគមន៍ក៏ប្រែប្រួលតាមសង្គមដែលប្រែប្រួលយ៉ាងខ្លាំងដែរ ។  ព្រះសហគមន៍ត្រឡប់ទៅជារចនាសម្ព័ន្ធដ៏សំខាន់នៅគ្រប់ទីកន្លែង  និងគ្រប់វិស័យនៃការរស់នៅរបស់មនុស្សនៅទ្វីបអឺរ៉ុប ។*

# ក_ គ្រីស្តសាសនាទៅជាសាសនារដ្ឋ

## ១- សាសនានៃព្រះចៅអធិរាជកុងស្តង់តាំង

ព្រះចៅអធិរាជ**កុងស្តង់តាំង**ប្រសូតនៅគ.ស. ២៨០ នៅក្នុងក្រុងនីស្ស (Nis ប្រទេសសែរប៊ីសព្វថ្ងៃ)  ទ្រង់ជាព្រះរាជបុត្ររបស់ព្រះចៅ**កុងស្តង់ក្លរ**និងព្រះនាង**ហេឡែន** (Hélène) ដែលជាគ្រីស្តបរិស័ទ ។  ព្រះអង្គទៅជាគ្រីស្តបរិស័ទតាំងពី គ.ស. ៣១២ ។  គ្មាននរណាដឹងច្បាស់អំពីរបៀបព្រះអង្គប្រែចិត្តគំនិតទេ ។  ក្នុងព្រះញាតិវង្សរបស់ព្រះអង្គ  គេធ្លាប់ជឿលើព្រះអាទិត្យ  គឺដូចជាជឿលើព្រះតែមួយព្រះអង្គ ។  គ្រីស្តបរិស័ទធ្លាប់រៀបរាប់រឿងព្រេងថា  ទ្រង់ប្រែចិត្តបែរទៅជឿលើព្រះគ្រីស្តនៅពេលទ្រង់កំពុងធ្វើសង្គ្រាមត្រង់ស្ពានមីលវីយ៉ូស ។  ចាប់តាំងពីពេលនោះមក ព្រះចៅអធិរាជកុងស្តង់តាំង ចាត់ខ្លួនទុកជាគ្រីស្តបរិស័ទម្នាក់

42

ទ្រង់សព្វព្រះហឫទ័យជឿសេចក្តីដែលគ្រីស្តបរិស័ទនិយាយ គឺថា  ព្រះគ្រីស្តបានប្រទានជ័យជំនះដល់ព្រះអង្គ ។   ទោះបីជាលោក**អឺសែប**កោតសរសើរព្រះចៅអធិរាជកុងស្តង់តាំងក្តី  ក៏ព្រះអង្គមិនមែនជាគ្រីស្តបរិស័ទល្អទេ ។  ទ្រង់ទទួលអគ្គសញ្ញាជ្រមុជទឹក  នៅពេលទ្រង់ហៀបចូលទិវង្គតនា គ.ស. ៣៣៧ ។  ទ្រង់ប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនដែលបញ្ជាក់ថា  ទ្រង់នៅតែប្រព្រឹត្តតាមសីលធម៌បុរាណ  មិនមែនជាសីលធម៌គ្រីស្តបរិស័ទទេ ។  ទ្រង់សម្លាប់ព្រះញាតិវង្ស  ព្រះរាជបុត្រមួយអង្គ  ព្រះមហេសី  ឲ្យគេសម្លាប់ឪពុកក្មេក  និងបងប្អូនប្រុសថ្លៃបីនាក់ទៀត ។ ប្រហែលជាទ្រង់មានជំនឿ  តែមិនប្រព្រឹត្តតាមជំនឿទេ ។

### *ក- ព្រះចៅកុងស្តង់តាំងជាព្រះចៅអធិរាជតែមួយអង្គគត់*

នៅគ.ស. ៣១៣ ព្រះចៅ**កុងស្តង់តាំង**គ្រងរាជ្យប៉ែកខាងបស្ចិមប្រទេស  រីឯព្រះចៅ**លីស៊ីញ៉ូស** (Lisinius)  គ្រងរាជ្យខាងបូព៌ាប្រទេស ។  មិនយូរប៉ុន្មាន ព្រះចៅអធិរាជទាំងពីរអង្គប្រឆាំងគ្នា  ហើយព្រះចៅលីស៊ីញ៉ូសបែរជាធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ ។  ដូច្នេះហើយ គ្រីស្តបរិស័ទគិតថា  ព្រះចៅកុងស្តង់តាំងធ្វើសង្គ្រាមប្រឆាំងព្រះចៅលីស៊ីញ៉ូស  ទ្រង់ការពារព្រះសហគមន៍ ។  ព្រះចៅលីស៊ីញ៉ូសបាញ់

សង្គ្រាម ហើយត្រូវគេធ្វើគុត ។ ចាប់តាំងពីឆ្នាំ ៣២៤ នៃគ.ស.មក ព្រះចៅកុងស្តង់តាំងគ្រងរាជ្យតែមួយព្រះអង្គ លើប៉ែកបស្ចិមនិងប៉ែកបូព៌ា ។ នៅឆ្នាំនោះហើយដែលគេបាត់ទុក ជាកាលបរិច្ឆេទដំបូងបង្អស់នៃ *«ចក្រភពគ្រីស្តបរិស័ទ»* ។

## *ខ- កំណើតក្រុងកុងស្តង់ទីណូប្លូ*

ព្រះចៅកុងស្តង់តាំងសម្រេចព្រះហឫទ័យគង់នៅបូព៌ាប្រទេស ។ ព្រះអង្គជ្រើសរើសយកក្រុងតូចមួយឈ្មោះប៊ីហ្សង់ (Bizance) នៅច្រកសមុទ្របុសហ្វ័រ (Bosphore) ហើយទ្រង់ដាក់ឈ្មោះថា *«កុងស្តង់ទីណូប្លូ» (Constantinople)* គឺ *«ក្រុងរបស់ព្រះចៅកុងស្តង់តាំង»* ធ្វើជាព្រះរាជធានីថ្មីមួយសម្រាប់ចក្រភពទាំងមូល ។ ទ្រង់មានបន្ទូលថា ព្រះជាម្ចាស់បង្ហាញកន្លែងនេះឲ្យទ្រង់ជ្រាបតាមការយល់សប្តិ ។ គេបាក់គ្រឹះក្រុងនេះយ៉ាងឱឡារិក នៅថ្ងៃទី ១១ មីនា គ.ស. ៣៣០ ដោយធ្វើពិធីបុណ្យតាមគ្រីស្តសាសនាផង និងតាមសាសនាដទៃផង ។ ការផ្លាស់ប្តូររាជធានីថ្មីនេះមានសារៈសំខាន់សម្រាប់ចក្រភពផង និងសម្រាប់ព្រះសហគមន៍ផង គឺយូរៗទៅព្រះចៅអធិរាជលែងជាប់ព្រះទ័យនឹងប៉ែកបស្ចិមប្រទេស ហើយបែរជាយកព្រះទ័យទុកដាក់នឹងបូព៌ាប្រទេសវិញ ។ រីឯព្រះសហគមន៍វិញ ព្រះចៅបាត់ទុកក្រុងកុងស្តង់ទីណូប្លូជា *«ក្រុងរ៉ូមទីពីរ»* ហើយគ្រីស្តបរិស័ទដែលមានអរិយធម៌ក្រិក យកចិត្តទុកដាក់គាំទ្រក្រុងកុងស្តង់ទីណូប្លូវិញ ។ កំណើតរាជធានីថ្មីនោះ បណ្តាលឲ្យព្រះសហគមន៍បាក់បែកនៅជំនាន់ក្រោយ ។

(42) **ចក្រភពរបស់ព្រះចៅអធិរាជកុងស្តង់តាំង គឺព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដីហើយមើលទៅ?**

*មនុស្សទាំងអស់រួចផុតពីការកៀបសង្កត់ពីព្រះចៅដែលកាន់អំណាចផ្តាច់ការដ៏ឃោរឃៅ រួចផុតពីទុក្ខវេទនាទាំងឡាយកន្លងមក ។ ម្នាក់ៗទទួលស្គាល់ព្រះដែលបានប្រយុទ្ធជំនួសមនុស្សមកគោរពប្រតិបត្តិទុកជាព្រះតែមួយអង្គគត់ ហើយជាពិសេសចំពោះយើងដែលផ្ញើជីវិតលើព្រះគ្រីស្ត យើងត្រេកអរណាស់រកអ្វីថ្លែងពុំបាន យើងប្រកបដោយសុភមង្គល ដោយបានឈ្នះលើព្រះចៅឃោរឃៅមុនៗ ដែលឥឡូវរលំដួលអស់ហើយ ។ ឥឡូវនេះ យើងរស់ឡើងវិញ ក្រោយពីគេបានបំផ្លាញ ។ យើងឃើញព្រះវិហារសាងសង់ឡើងវិញ មានកំពស់ដល់មេឃ ខ្ពស់ជាងព្រះវិហារដែលគេបានបំផ្លាញបាក់បែកខ្ទេចខ្ទីកាលពីមុន ។*

*ប៉ុន្តែ ព្រះចៅអធិរាជដែលមានឋានៈខ្ពង់ខ្ពស់បំផុត គឺព្រះចៅ**កុងស្តង់តាំង**និងព្រះចៅ**លីស៊ីញ៉ូស** បង្កើតក្បួនច្បាប់ថ្មីដែលអនុគ្រោះគ្រីស្តបរិស័ទ ។ ធ្វើដូច្នេះ គឺទ្រង់ពង្រីកនិងលាតត្រដាងព្រះអំណោយទានដ៏រុងរឿងរបស់ព្រះជាម្ចាស់ ។ លើសពីនេះទៅទៀត លោកអភិបាលព្រះសហគមន៍តែងទទួលលិខិតកិត្តិយស និងអំណោយដ៏ថ្លៃថ្នូរយ៉ាងឱឡារិកពីព្រះចៅអធិរាជ ។*

*គ្រីស្តបរិស័ទភ្លេចទុក្ខលំបាកពីអតីតកាល លែងនឹកនាពីការប្រមាថគ្រប់បែបយ៉ាង ហើយនាំគ្នាចាប់អារម្មណ៍នឹងទ្រព្យសម្បត្តិលោកិយ ។ លើសពីនេះទៅទៀតគេសង្ឃឹមថា នឹងបានទ្រព្យសម្បត្តិសួគ៌ដែរ ។ ហេតុនេះហើយ បានជារាជការតែងតែប្រកាសគ្រប់ទីកន្លែង នូវព្រះរាជក្រិត្យប្រកបដោយមនុស្សធម៌របស់ព្រះចៅអធិរាជដែលមានជ័យជំនះនោះ ។ គេសម្តែងការគោរពប្រណិប័តន៍ដ៏ពិតប្រាកដ និងសរសើរដល់ព្រះអង្គ ។ របបកៀបសង្កត់គ្រប់យ៉ាងបានរលាយអស់ហើយ ។ មានតែព្រះចៅ**កុងស្តង់តាំង** និងព្រះរាជវង្សានុវង្សគ្រប់គ្រងចក្រភពប៉ុណ្ណោះដែលកាន់អំណាចយ៉ាងមាំមួនដោយគ្មាននរណាជំទើមបាន ។ ព្រះរាជកិច្ចដ៏សំខាន់ជាងគេរបស់ព្រះចៅគឺ ធ្វើឲ្យមនុស្សក្នុងពិភពលោកទាំងមូលលែងស្អប់ព្រះជាម្ចាស់ ។ ហេតុនេះហើយបានជាព្រះចៅប្រព្រឹត្តព្រះរាជកិច្ចផ្សេងៗ បង្ហាញព្រះហឫទ័យស្រឡាញ់ ព្រហ្មវិហារធម៌ ស្រឡាញ់ព្រះជាម្ចាស់ គោរពប្រណិប័តន៍ព្រះអង្គ និងអរព្រះគុណព្រះអង្គ ស្របតាមអំណោយដែលព្រះចៅបានទទួលព្រះជាម្ចាស់ ។*

*អឺសែប "ប្រវត្តិព្រះសហគមន៍" ១០,២-៩*

## ២- ព្រះចៅអធិរាជសុទ្ធតែជាគ្រីស្តបរិស័ទបន្តបន្ទាប់

ព្រះចៅអធិរាជតែងចាត់ទុកខ្លួនថា ជា«*ស្ពានមេត្រីដ៏ខ្ពង់ខ្ពស់*» (Souverain Pontife) គឺជាមហាបូជាចារ្យ និងជាមេដឹកនាំសាសនាប្រជារាស្ត្រនៅក្រុងរ៉ូម ។ ដោយព្រះចៅអធិរាជបែរជាគ្រីស្តបរិស័ទនោះ ទ្រង់ក៏ទុកងារជា «*ស្ពានមេត្រីដ៏ខ្ពង់ខ្ពស់*» ក្នុងព្រះសហគមន៍ដែរ ។ ចាប់តាំងពី គ.ស. ៣១៥ មក មានចារសញ្ញារបស់ព្រះគ្រីស្តនៅលើប្រាក់កាក់ ។ ដូច្នេះហើយ បានជាប្រាក់កាក់ត្រឡប់ទៅជាគ្រឿងឧបករណ៍សម្រាប់ផ្សព្វផ្សាយគ្រីស្តសាសនាពាសពេញចក្រភព ។ រីឯព្រះចៅអធិរាជផ្ទាល់ ទ្រង់ចាត់ទុកព្រះអង្គផ្ទាល់ថា «*ស្មើនឹងគ្រីស្តទូត*» ឬជា «*អភិបាលខាងក្រៅរបស់ព្រះសហគមន៍*» ។ ហេតុនេះហើយបានជាទ្រង់ចាត់ទុកថា ព្រះអង្គមានសិទ្ធិចូលប្រឡូកក្នុងរឿងគ្រីស្តសាសនា ។ ចំពោះលោក**អឺសែប** និងគ្រីស្តបរិស័ទភាគច្រើននៅសម័យនោះ គេសប្បាយចិត្តនឹងសភាពការណ៍ថ្មីនេះ ព្រោះពួកគេធ្លាប់ស្គាល់តែទុក្ខវេទនា ដោយព្រះចៅអធិរាជធ្វើទុក្ខបុកម្នេញយ៉ាងឃោរឃៅកាលពីមុន ។ គេយល់ឃើញថា ព្រះរាជ្យរបស់ព្រះជាម្ចាស់មកដល់នៅលើផែនដីហើយ ។ គ្រីស្តបរិស័ទក៏ទទួលស្គាល់ថា ព្រះចៅអធិរាជជាព្រះម៉្យាង និងជាមេដឹកនាំប្រជារាស្ត្រគ្រីស្តបរិស័ទ ព្រះអង្គប្រៀបបីដូចជាលោកម៉ូសេថ្មី ឬព្រះបាទដាវីឌថ្មី ។ ព្រះអង្គកោះហៅអស់លោកអភិបាលឲ្យប្រជុំជាមហាសន្និបាត ដោយសំអាងលើឋានៈរបស់ព្រះអង្គបែបនេះ ។

### *ក- ព្រះចៅអធិរាជជួយគ្រីស្តបរិស័ទ*

គ្រីស្តបរិស័ទដឹងគុណព្រះចៅអធិរាជ ដែលជួយគេយ៉ាងខ្លាំង ។ ព្រះអង្គប្រទានអាគារជាព្រះរាជសម្បត្តិ គឺតុលាការ *(Basilique)* និងវិមានរដ្ឋសម្រាប់ប្រើទុកជាព្រះវិហារ ។ ទ្រង់កសាងព្រះវិហារយ៉ាងល្អប្រណិត មានព្រះវិហារសន្តសិលានៅជម្រាលភ្នំវ៉ាទីកង់ ព្រះវិហារនៅផ្នូររបស់ព្រះយេស៊ូនាក្រុងយេរូសាឡឹម ព្រះវិហារនៅបេថ្លេហឹម និងព្រះវិហារនានានៅកុងស្តង់ទីណូប្លួ ។ល ។ ព្រះអង្គអនុញ្ញាតឲ្យសហគមន៍គ្រីស្តបរិស័ទមានសិទ្ធិទទួលកេរមត៌ក ឬទទួលអំណោយពីគ្រីស្តបរិស័ទដែលជិតទទួលមរណភាព ។ ហេតុដូចនេះហើយ បានជាយូរៗទៅព្រះសហគមន៍មានទ្រព្យសម្បត្តិយ៉ាងសម្បើមមហិមា ។ ក្រុមបូជាចារ្យទទួលឯកសិទ្ធតាមផ្លូវច្បាប់ ។ តុលាការអភិបាលព្រះសហគមន៍មានសិទ្ធិស្មើតុលាការរដ្ឋ ។

### *ខ- នគរបាលសាសនា*

ព្រះចៅអធិរាជតែងតែយកព្រះទ័យទុកដាក់កិច្ចការសាសនា ជាពិសេសពេលវិបត្តិសាសនាបង្កើតភាពវឹកវរក្នុងចក្រភព ព្រះអង្គខិតខំដោះស្រាយវិបត្តិនានា ។ ម្យ៉ាងទៀត ពេលគ្រីស្តបរិស័ទកើតជម្លោះគ្នាឯង គេក៏តែងតែយករឿងឡើងទៅព្រះចៅអធិរាជដោះស្រាយដែរ ។ ក្នុងជំពូកបន្ទាប់ទៀត មានរៀបរាប់អំពីព្រះចៅអធិរាជចូលប្រឡូកក្នុងរឿងសាសនា នៅពេលកើតវិបត្តិរបស់លោក**អារីយ៉ូស**ចាប់តាំងពី គ.ស. ៣២៥ រហូតមក ។ ឧប. នៅ គ.ស. ៣១៣ គ្រីស្តបរិស័ទនៅទ្វីបអាហ្វ្រិក សូមព្រះចៅជួយដោះស្រាយរឿងលោក**ដូណាត** (Donat) គឺនៅ គ.ស. ៣១២ គ្រីស្តបរិស័ទខ្លះប្រកែក ជំទាស់អំពីការបោះឆ្នោតជ្រើសរើសលោក**សេស៊ីលីយ៉ាំង** (Cécilien) ជាអភិបាលព្រះសហគមន៍ក្រុងកាតាស្ស ។ ពួកគេចោទថា ពេលព្រះចៅ**ឌីយ៉ូក្លេស៊ីយ៉ាំង**ធ្វើទុក្ខបុកម្នេញព្រះសហគមន៍ អស់លោកដែលបានតែងតាំងលោកសេស៊ីលីយ៉ាំង សុទ្ធតែលះបង់ជំនឿចោល ។ ពួកគេក៏ជ្រើសរើសលោកដូណាត មកជំនួសវិញ ។ ការជំទាស់ប្រកែកនេះកើតមានក្នុងស្រុកអាហ្វ្រិកទាំងប៉ុន្មានដែលស្ថិតនៅក្រោមអំណាចក្រុងរ៉ូម ។ ក្នុងក្រុងជាច្រើនមានអភិបាលព្រះសហគមន៍ពីរនាក់ប្រឆាំងគ្នា ។ ព្រះចៅតែងប្រទានប្រាក់ជំនួយពីព្រះរាជទ្រព្យ ឲ្យអភិបាលតែងតាំងត្រឹមត្រូវតាមច្បាប់ គឺទ្រង់ឲ្យតែលោកសេស៊ីលីយ៉ាំង និងមិត្តភក្តិរបស់លោកប៉ុណ្ណោះ ។ ប៉ុន្តែ គ្រីស្តបរិស័ទដែលគាំទ្រលោក

ដូណាត ឡើងសំណុំរឿងទៅព្រះចៅអធិរាជ សូមទ្រង់ទទួលស្គាល់ថា ពួកគេតែងតាំងលោកត្រឹមត្រូវតាមច្បាប់ដែរ ។ ព្រះចៅអធិរាជបញ្ជូនរឿងនេះទៅអភិបាលស្រុកអ៊ីតាលី និងអភិបាលស្រុកហ្គោលដោះស្រាយ (នៅអ័រលឺ គ.ស. ៣១៤) អស់លោកដាក់ទោសលោក**ដូណាត** តែគ្រីស្តបរិស័ទដែលគាំទ្រលោកនាំគ្នាបះបោរប្រឆាំងព្រះចៅ**កុងស្តង់តាំង** ។ ពេលនោះ ព្រះចៅក៏ចាត់កងទ័ពឲ្យដេញពួកគេចេញពីព្រះវិហារដែលពួកគេកាន់កាប់ ។ ដោយសង្គ្រាមសាសនានេះមិនចប់ ព្រះចៅអធិរាជក៏ព្រះរាជអនុញ្ញាតឲ្យគ្រីស្តបរិស័ទទាំងសងខាងមានសិទ្ធិសេរីភាពកាន់តាមអ្នកណាក៏បាន ហើយទ្រង់ក៏ប្រទានថវិកាឲ្យគ្រីស្តបរិស័ទ ដើម្បីកសាងព្រះវិហារផ្សេងៗឡើងវិញ ។

## ៣- ព្រះចៅបំបាត់សាសនាដទៃបណ្តើរៗ

គ.ស. ៣១៣ ព្រះចៅអធិរាជប្រោសប្រទានសិទ្ធិសេរីភាពខាងជំនឿ ឲ្យអ្នកកាន់សាសនាទាំងអំបាលម៉ាន ។ទោះបីអ្នកស្រុកចាប់ផ្តើមបោះបោលជំនឿបុរាណបណ្តើរៗក្តី ក៏ជំនឿនោះនៅតែមានឥទ្ធិពលនៅឡើយ ។ ក្នុងស្រុកនានាមានគ្រីស្តបរិស័ទតិចជាង ៥០% ក្នុងចំណោមប្រជាជន លើកលែងតែនៅបូព៌ាប្រទេសដែលមានច្រើនជាង ។ ព្រឹទ្ធាចារ្យនៃរដ្ឋអំណាចរ៉ូម៉ាំងនិងបញ្ញវ័ន្ត នៅតែជាប់ចិត្តនឹងប្រពៃណីនិងនយោបាយដែលជាប់នឹងសាសនារបស់គេ ។ រីឯប្រជាជននៅតាមជនបទក៏នៅតែគោរពអារក្ខអ្នកតាយ៉ាងខ្ជាប់ខ្ជួន ព្រោះគេត្រូវការម្ចាស់ទឹកម្ចាស់ដីផ្តល់ឲ្យស្រែចម្ការអាចបង្កបង្កើតផល និងឲ្យសត្វបង្កើតកូនបានដែរ ។



*ព្រះយេស៊ូជាគង្វាលដ៏ល្អ (ផ្នូរព្រះនាងកាឡាប្លាសីដា សតវត្សទី ៥)*

Layout Histor.qxd 2/10/07 10:09 AM Page 76

### *ក- ការបំបាត់អប្បិយជំនឿ*

សតវត្សទី ៤ ព្រះចៅអធិរាជចេញច្បាប់កាន់តែតឹងរ៉ឹង ប្រឆាំងនឹងសាសនា
43 បុរាណ រហូតដល់ហាមប្រាមមិនឲ្យកាន់សាសនាទាំងនោះ ។ ព្រះចៅអធិរាជហាមធ្វើមន្តអាគម ហាមការទស្សន៍ទាយដោយពិនិត្យមើលពោះវៀនសត្វដែលគេសម្លាប់ ។ ព្រះចៅ**កុងស្តង់** (Constance) ហាមថ្វាយសក្ការបូជាថ្វាយព្រះដទៃ និងឲ្យបិទវិហារព្រះទាំងនោះ ។ អ្នកថ្វាយសក្ការបូជាដល់ព្រះដទៃ ត្រូវផ្តន្ទាទោសដល់ជីវិត (គ.ស. ៣៥៦) ។ ប៉ុន្តែ រាជការមិនអនុវត្តតាមច្បាប់ទាំងនោះនៅគ្រប់កន្លែងទេ ។ យូរៗទៅពាក្យ «*សាសនា*» ទទួលន័យថ្មីថា «*គ្រីស្តសាសនា*» ។

### *ខ- ព្រះចៅយូលីយ៉ាំងក្បត់គ្រីស្តសាសនា* (Julien l'Apostat)

នៅសម័យព្រះចៅអធិរាជ**យូលីយ៉ាំង** (គ.ស. ៣៦១-៣៦៣) សាសនាដទៃមានកម្លាំងរស់ឡើងវិញ ។ គ្រីស្តបរិស័ទឲ្យឈ្មោះព្រះចៅនោះថា «*យូលីយ៉ាំងក្បត់គ្រីស្តសាសនា*» ។ ព្រះអង្គជាក្មួយរបស់ព្រះចៅ**កុងស្តង់តាំង** ។ ព្រះរាជាដែលស្នងរាជ្យបន្តពីព្រះចៅកុងស្តង់តាំង បានសម្លាប់ព្រះរាជវង្សានុវង្សទាំងអស់ សល់តែទ្រង់យូលីយ៉ាំង មួយព្រះអង្គប៉ុណ្ណោះរួចផុតពីឃាតកម្មនោះ ។ ហេតុនេះ ទ្រង់ស្អប់គ្រីស្តសាសនា ។ ទោះបីទ្រង់ទទួលការអប់រំតាមបែបគ្រីស្តសាសនាក្តី តែនៅពេលទ្រង់គ្រងរាជ្យ ទ្រង់ខិតខំបង្អាប់បង្អោនគ្រីស្តសាសនា ហើយលើកតម្កើងសាសនាបុរាណវិញ ។ ព្រះអង្គនិពន្ធសៀវភៅក្រោមចំណងជើងថា «*ការប្រឆាំងនឹងពួកកាលីឡេ*» ។ ទោះបីព្រះចៅយូលីយ៉ាំងកាន់តាមព្រហ្មវិហារធម៌យ៉ាងល្អត្រឹមត្រូវក្តី ក៏ប្រជារាស្ត្រមិនស្រឡាញ់ព្រះអង្គដែរ ។ ពេលទ្រង់សោយទិវង្គតលើសមរភូមិ ប្រជារាស្ត្រយល់ឃើញថា ព្រះជាម្ចាស់ដាក់ទណ្ឌកម្មលើព្រះអង្គ ។ សម័យនោះគ្មានអ្វីអាចរារាំងដំណើរនៃគ្រីស្តសាសនាបានឡើយ ។ យូរៗទៅគ្រីស្តបរិស័ទមើលងាយនិងធ្វើបាបអ្នកកាន់សាសនាដទៃ ។

### *គ- សាសនាដទៃជាសាសនាក្រៅច្បាប់*

ក្រោយពីពេលព្រះចៅអធិរាជ**យូលីយ៉ាំង**ចូលទិវង្គតទៅ ព្រះចៅដែលស្នងរាជ្យបញ្ចេញច្បាប់កាន់តែច្រើនឡើងៗ ប្រឆាំងអ្នកកាន់សាសនាដទៃ ប្រឆាំងនិងគ្រីស្តបរិស័ទដែលវង្វេងជំនឿ ។ នៅគ.ស. ៣៨០ ព្រះចៅ**ទេអូដូស** (Théodose)
ប្រកាសថា គ្រីស្តសាសនាជាសាសនារដ្ឋ ។ គេតាមចាប់អ្នកកាន់សាសនាដទៃ និង 43
គ្រីស្តបរិស័ទវង្វេងជំនឿ ។ គ.ស. ៣៩២ គេហាមឃាត់មនុស្សមិនឲ្យកាន់សាសនាដទៃ ហាមធ្វើបុណ្យតាមសាសនាដទៃ និងរុះវិហាររបស់គេបោល ។ គ្រីស្តបរិស័ទ




*រូបឆ្លាក់លើផ្នូរ នៅលីយ៉ុង (សតវត្សទី ៥)*
*ព្រះគ្រីស្តជាដើមនិងជាចុងនៃអ្វីៗទាំងអស់ ព្រះអង្គប្រទានជីវិតអមតៈឲ្យមនុស្សលោក*

Layout Histor.qxd 2/10/07 10:09 AM Page 77

ខ្លះស្មានថា គេមានសិទ្ធិប្រើហិង្សាប្រឆាំងអ្នកកាន់សាសនាដទៃ និងប្រឆាំងវិហាររបស់គេ ។ នៅសតវត្សទី ៤ គ្រីស្តបរិស័ទដែលត្រូវគេធ្វើទុក្ខបុកម្នេញកាលពីមុននោះ បែរជាធ្វើទុក្ខបុកម្នេញគេវិញ ។ រីឯមន្ត្រីរាជការដែលធ្លាប់បម្រើសាសនាដទៃកាលពីមុន បែរជាបម្រើគ្រីស្តសាសនាវិញ ។ ពួកគេប្រព្រឹត្តដូច្នេះ ព្រោះនៅសម័យនោះ សាសនានិងរដ្ឋអំណាចជាប់គ្នាយ៉ាងស្អិតល្មួតបំផុត ។ រដ្ឋអំណាចយល់ឃើញថា សាសនាជាគ្រឹះនៃសង្គម អាចបង្រួបបង្រួមមនុស្សបាន ។ អ្នកស្រុកគ្រាន់តែដូរសាសនាប៉ុណ្ណោះ ទំនាក់ទំនងសាសនានិងរដ្ឋអំណាចនៅដដែល គេមិនទាន់ប្រែចិត្តគំនិតទៅលើព្រះគ្រីស្តនៅឡើយទេ ។

## 43 ពីសេរីភាពខាងសាសនា ទៅសាសនារដ្ឋ

រដ្ឋអំណាចប្រមូលផ្តុំព្រះរាជក្រិត្យរបស់ព្រះចៅអធិរាជ ចម្លងចូលក្នុងក្បួនច្បាប់ជាច្រើន ។ ក្បួនច្បាប់សំខាន់ជាងគេ គឺក្បួនច្បាប់ព្រះចៅ**ទេអូដូស**ទី ២ (នៅ គ.ស. ៣៩២) និងក្បួនច្បាប់ព្រះចៅ**យូស្ទីញ៉ាំង** (នៅ គ.ស. ៥២៩) ។ គេរក្សាឈ្មោះអ្នកតែងច្បាប់ទាំងនោះទុកថែមទៀត ។ នៅ គ.ស. ៣៩២ ពាក្យ «*សាសនា*» មានន័យថា «*គ្រីស្តសាសនា*» តែម្តង ។

### ព្រះចៅអធិរាជកុងស្តង់តាំង គ.ស. ៣១៩

*(ក្បួនច្បាប់ព្រះចៅទេអូដូស ៩,១៦:២)*

*យើងហាមប្រាមដល់អស់លោកទស្សន៍ទាយដោយពិនិត្យមើលពោះវៀនសត្វ ទាំងបូជាចារ្យ ទាំងអ្នកជ្រេងទៀត ដែលធ្លាប់ទស្សន៍ទាយបែបនេះ មិនឲ្យចូលក្នុងផ្ទះឯកជន ឬឆ្លងកាត់ទ្វារផ្ទះគេឡើយ ទោះបីអ្នកទាំងនេះមានបំណងសម្តែងសេចក្តីស្រឡាញ់ដល់គេក្តី ។ អ្នកដែលមិនអនុវត្តតាមច្បាប់នេះ ត្រូវផ្តន្ទាទោសជាកំហិត ។ ប៉ុន្តែ ចំពោះអ្នកដែលយល់ឃើញថាការទស្សន៍ទាយបែបនេះមានប្រយោជន៍សម្រាប់ខ្លួន សូមនាំគ្នាទៅរកអាសនៈឯកជន ឬទៅកាន់វិហារ ហើយប្រារព្ធពិធីតាមទម្លាប់ចុះ ។ យើងមិនហាមឃាត់ប្រារព្ធធ្វើពិធីទាំងនេះនៅពេលថ្ងៃទេ ព្រោះគេធ្លាប់ធ្វើជាយូរមកហើយ ។ ប៉ុន្តែ សូមកុំធ្វើពិធីទាំងនោះនៅពេលយប់ជាដាច់ខាត ។*

### ព្រះចៅកុងស្តង់ គ.ស. ៣៥៦

*(ក្បួនច្បាប់ព្រះចៅទេអូដូស ១៦,១០:៦)*

*យើងប្រកាសថា អស់អ្នកដែលចូលរួមថ្វាយយញ្ញបូជា ឬថ្វាយបង្គំរូបបដិមា ត្រូវផ្តន្ទាទោសប្រហារជីវិត ។*

### ព្រះចៅទេអូដូស ព្រះរាជក្រិត្យនៅក្រុងថេស្សាឡូនិក គ.ស. ៣៨០ *(ក្បួនច្បាប់របស់ព្រះចៅទេអូដូស ១៦,១:២)*

*យើងសព្វព្រះហឫទ័យឲ្យប្រជារាស្ត្រទាំងអស់ដែលរស់នៅក្រោមម្លប់បារមីដ៏ត្រជាក់ត្រជុំរបស់យើង អនុវត្តតាមជំនឿដែលគ្រីស្តទូត**សិលា**បានបញ្ជូនមកគ្រីស្តបរិស័ទក្រុងរ៉ូម គឺតាមជំនឿដែលគេប្រកាសរហូតសព្វថ្ងៃ ដូចលោកផ្ទាល់បានប្រកាសដែរ ហើយដូចមហាបូជាចារ្យ**ដាម៉ាស** និងលោក **សិលា**ជាអភិបាលព្រះសហគមន៍ក្រុងអាឡិចសង់ឌ្រីបានប្រកាស ដូចគេដឹងគ្រប់ៗគ្នាដែរ ។ (...) យើងបញ្ញត្តិថា មានតែអ្នកដែលប្រតិបត្តិតាមច្បាប់នេះប៉ុណ្ណោះ ដែលមានសិទ្ធិហៅខ្លួនថា ជាគ្រីស្តបរិស័ទកាតូលិក ។ រីឯមនុស្សឯទៀតៗសុទ្ធតែជាអ្នកវិកលចរិតនិងលេលាគេត្រូវអាម៉ាសមុខ ដោយបែកចេញពីជំនឿ ។ ដំបូងពួកគេត្រូវព្រះជាម្ចាស់សងសឹក បន្ទាប់មកត្រូវតែយើងធ្វើទារុណកម្មដល់គេថែមទៀត ឲ្យស្របតាមយើងសម្រេចព្រះហឫទ័យ គឺតាមព្រះជាម្ចាស់បានបំភ្លឺយើង ។*

### ព្រះចៅទេអូដូស អ័រកាឌីយ៉ូស និងអូណូរីយ៉ូស គ.ស. ៣៩២ *(ក្បួនច្បាប់របស់ព្រះចៅទេអូដូស ១៦,១២)*

*ប្រសិនបើនរណាម្នាក់អុជធូបគោរពថ្វាយបង្គំរូបបដិមាដែលជាស្នាដៃរបស់មនុស្ស (...) ឬដាក់កម្រងផ្កានិងខ្សែតូចៗតុបតែងដើមឈើ ឬយកដុំដីមកសង់អាសនៈ (...) គឺអ្នកនោះប្រព្រឹត្តបទល្មើសទាំងស្រុង និងពិតប្រាកដទាស់នឹងសាសនា ។ អ្នកនោះមានទោសដោយរំលោភសាសនា ត្រូវរដ្ឋអំណាចរឹបអូសផ្ទះ ឬដីធ្លីរបស់គេ ។ នៅកន្លែងនោះគេបានបង្ហាញថា ខ្លួនជាទាសករនៃជំនឿអកុសលរបស់សាសនាដទៃនោះ ។*

Layout Histor.qxd 2/10/07 10:09 AM Page 78

### *ឃ- ការបញ្ចុះបញ្ចូល  ឬការគៀបសង្កត់*

គ្រីស្តបរិស័ទភាគច្រើនពេញចិត្តឲ្យរដ្ឋអំណាចជួយគេ ហើយជំទាស់ប្រឆាំងនឹងសាសនាដទៃ ។ ប៉ុន្តែ នៅពេលព្រះចៅផ្តន្ទាទោសលោក**ព្រីស៊ីលីយ៉ាំង** (Pris cillien) មានអភិបាលខ្លះមិនពេញចិត្តសោះ ។ រឿងនេះមានដូចតទៅ៖

គ.ស. ៣៨០ លោកព្រីស៊ីលីយ៉ាំងជាអភិបាលក្រុងអាវីឡា (Avila) ប្រទេសអេស្ប៉ាញ លោកបង្កើតសហគមន៍មួយ គោរពប្រណិប័តន៍ព្រះជាម្ចាស់យ៉ាងខ្លាំង ពួកគេកាន់វិន័យយ៉ាងតឹងរ៉ឹង ប៉ុន្តែ សហគមន៍នោះលាក់ខ្លួនមិនចង់ឲ្យអ្នកដទៃស្គាល់ ។ ហេតុនេះហើយ បានជាលោកអភិបាលប្រទេសអេស្ប៉ាញពីរនាក់ចោទប្រកាន់លោកព្រីស៊ីលីយ៉ាំង នៅចំពោះព្រះចៅអធិរាជថា លោកកាន់តាមគណៈលោក**ម៉ានី** ។ ពេលនោះ លោក**ម៉ារតាំង**ជាអភិបាលព្រះសហគមន៍ក្រុងតួរ (Martin de Tours) ជាស់តឿនលោកអភិបាលដែលចោទនោះឲ្យលែងប្តឹង និងអង្វរព្រះចៅអធិរាជកុំឲ្យបង្ខូរឈាម ។ លោកពោលថា *«ពិតជារឿងថ្មីអស្ចារ្យមួយគួរខ្ពើម គឺចៅក្រមខាងនយោបាយបែរទៅវិនិច្ឆ័យរឿងសាសនា!»* ។ ប៉ុន្តែ ព្រះចៅអធិរាជផ្តន្ទាទោសប្រហារជីវិតលោកព្រីស៊ីលីយ៉ាំង និងអ្នកគាំទ្រដោយចោទថាពួកគេប្រព្រឹត្តខុសសីលធម៌ និងប្រើមន្តអាគម (គ.ស. ៣៨៥) ។ លោក**អាំប្រូស៍** (Ambroise) ជាអភិបាលព្រះសហគមន៍មីឡង់ (Milan ស្រុកអ៊ីតាលី) ផ្តាច់ទំនាក់ទំនងជាមួយអភិបាលដែលបានចោទប្រកាន់លោកព្រីស៊ីលីយ៉ាំងនោះ ។ អ្នកកាន់សាសនាដទៃដែលមានវប្បធម៌ខ្ពស់ ក៏ទាស់ចិត្តព្រះចៅយ៉ាងខ្លាំងដែរ ។

លោក**អូគូស្តាំង** (Augustin) ជាអភិបាលក្រុងហ៊ីប៉ូន (Hippone) នៅខាងជើងទ្វីបអាហ្វ្រិក (Bône ប្រទេសអាល់ហ្សេរីសព្វថ្ងៃ) ក៏ជួបប្រទះសភាពការណ៍ដ៏ស្មុគ្រស្មាញក្នុងភូមិភាគរបស់លោកដែរ គឺព្រះសហគមន៍បាក់បែកគ្នាព្រោះរឿងលោក**ដូណាត** ។ លោកអូគូស្តាំង យល់ព្រមឲ្យរដ្ឋអំណាចជួយប្រយុទ្ធប្រឆាំងនឹងអ្នកបំបែកបក្សពួកក្នុងព្រះសហគមន៍ ហើយតែងតែប្រើហឹង្សាទាំងអាវុធផង ។

## ៤- សង្គមមនុស្សប្រែតាមឥទ្ធិពលនៃជំណឿងល្អ

តើដំបូន្មានរបស់ព្រះគ្រីស្ត ជ្រួតជ្រាបក្នុងរដ្ឋអំណាចនៃចក្រភពដែរឬទេ? ចាប់ពី គ.ស. ៣២៥ មក រដ្ឋអំណាចតែងតែប្រើប្រតិទិនតាមគ្រីស្តសាសនា ប្រជាជនឈប់សម្រាកនៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យធំៗរបស់គ្រីស្តបរិស័ទ ។ លោក**ឌិនិស**ដ៏តូច កំណត់ឆ្នាំព្រះយេស៊ូប្រសូត ។ ឥទ្ធិពលគ្រីស្តសាសនាចូលក្នុងក្បួនច្បាប់គ្រួសារ ។ ឧបមា. ច្បាប់ហាមប្រាសចាកសីលធម៌ជាមួយទាសី ។ ទោះបីគូស្វាមីភរិយាមានសិទ្ធិលែងលះគ្នាក្តី ក៏ច្បាប់បង្កើតឧបសគ្គខ្លះ មិនឲ្យលែងលះគ្នាយ៉ាងស្រួលដូចពីមុនទេ ។ រដ្ឋអំណាចមិនជំទាស់នឹងឲ្យអ្នកមានស្តុកស្តម្ភប្រើទាសករទេ សូម្បីតែព្រះសហគមន៍ក៏ប្រើទាសករដែរ ។ ប៉ុន្តែ រដ្ឋអំណាចបង្កើតច្បាប់ហាមបំបែកគ្រួសារទាសករទាំងនោះ ។ រដ្ឋអំណាចក៏ជួយទាសករឲ្យមានសេរីភាពកាន់តែស្រួល គឺម្ចាស់គ្រាន់តែប្រកាសក្នុងព្រះវិហារ ឬចំពោះមុខក្រុមបូជាចារ្យតែប៉ុណ្ណោះ ទាសករត្រឡប់ជាមនុស្សជាតាមច្បាប់ ។ គេចាប់ផ្តើមសម្តែងមនុស្សធម៌ខ្លះៗចំពោះអ្នកជាប់ឃុំឃាំង គឺឆ្មាំគុកមិនបណ្តោយឲ្យអ្នកទោសស្លាប់ដោយអត់អាហារដូចពីមុនទៀតទេ ។ អ្នកទោសត្រូវចេញពីបន្ទប់ងងឹត ឃើញពន្លឺព្រះអាទិត្យមួយថ្ងៃម្តង ក្រុមបូជាចារ្យក៏មានសិទ្ធិទៅសួរសុខទុក្ខអ្នកទោសនៅក្នុងមន្ទីរឃុំឃាំងបានដែរ ។ល។

### *ក- អង្គការសប្បុរសធម៌*

គ្រីស្តបរិស័ទមិនទាន់ប្រែរចនាសមន្ទនៃសង្គមទេ ប៉ុន្តែ គេយកចិត្តទុកដាក់បង្កើតអង្គការសប្បុរសធម៌ជាច្រើន ។ យូរៗទៅរចនាសម្ពន្ធក្នុងសង្គមក៏ប្រែប្រួលដោយសារអង្គការទាំងនោះ ។ តាំងពីដើមរៀងមក តាមគម្ពីរកិច្ចការគ្រីស្តទូតគ្រីស្តបរិស័ទធ្លាប់ចែកទានដល់អ្នកក្រីក្រ តែយូរៗទៅគ្រីស្តបរិស័ទក្នុងចក្រភពធ្វើទានកាន់តែច្រើនឡើង ។ លោក**បាស៊ីល** (Basile) ជាអភិបាលព្រះសហគមន៍

ក្រុងសេសារេ៉ នៅស្រុកកាប៉ាដូស (Cappadoce) បង្កើតក្រុងដែលមានលក្ខណៈជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ គឺមានព្រះវិហារ មានវត្តអារាមសម្រាប់បព្វជិត មានគេហដ្ឋានសម្រាប់ទទួលជនពិការ និងមានមន្ទីរពេទ្យ ។ គេទទួលអ្នកដំណើរ អ្នកជំងឺ និងជនក្រីក្រឲ្យស្នាក់នៅ ។ បុគ្គលិកបម្រើមន្ទីរទាំងនោះ សុទ្ធតែបព្វជិតដែលទទួលការហ្វឹកហ្វឺនដើម្បីទទួលគេ ។ អភិបាលព្រះសហគមន៍ក្រុងអាឡិចសង់ឌ្រី គ្រប់គ្រងលើគិលានុបដ្ឋាកចំនួន ៥០០ នាក់ ។ នៅកំពង់ផែអូស្ទីយ៉ា មានបាត់ថែងកន្លែងសម្រាប់ទទួលអ្នកធ្វើដំណើរ ។ល ។

***ខ- គំនិតគ្រីស្តបរិស័ទមិនទាន់ជ្រួតជ្រាបចូលក្នុងសង្គម***

ប៉ុន្តែ ព្រះដំបូន្មានរបស់ព្រះយេស៊ូមិនសូវជ្រាបចូលជ្រៅក្នុងសង្គមនៅសម័យនោះទេ ។ អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកថ្មី មិនសូវយកចិត្តទុកដាក់ប្តូរសីលធម៌ដ៏អាក្រក់របស់គេទេ ។ ច្បាប់ហាមសម្លាប់ទារក តែអនុញ្ញាតឲ្យគេបោលទារកហាលថ្ងៃហាលក្តៅឲ្យស្លាប់ ។ ច្បាប់ហាមមនុស្សប្រយុទ្ធគ្នារហូតដល់ស្លាប់ក្នុងកីឡាដ្ឋាន តែសតវត្សទី ៤ នៅមានការប្រយុទ្ធបែបនេះនៅឡើយ ។ គ្រីស្តបរិស័ទចូលបម្រើកងទ័ពលែងស្ទាក់ស្ទើរទៀត ។ ព្រះចៅគ្រងរាជ្យដោយប្រើលទ្ធិផ្តាច់ការ ប្រើនគរបាលដែលរំលោភបំពានច្បាប់តាមអំពើចិត្ត ។ ក្រសួងយុត្តិធម៌តែងតែធ្វើទារុណកម្មអ្នកទោសជារឿយៗ ។ ពេលខ្លះអស់លោកអភិបាលនាំគ្នាប្រឆាំងនឹងអំពើហឹង្សាទាំងនេះ ។ ឧបមា. លោក**អាំប្រាស៍**ទូលសុំព្រះចៅអធិរាជ**ទេអូដូស**ដែលសម្លាប់រង្គាលមនុស្ស ៧ ពាន់នាក់ នៅក្រុងថេស្សាឡូនិក (គ.ស. ៣៩០) ឲ្យធ្វើទារុណកម្មដល់ព្រះអង្គផ្ទាល់ មុនចូលរួមថ្វាយអភិបូជា ។

# ១_ ក្បួនពិធីចម្រើន គេយកចិត្តទុកដាក់ប្រកាសដំណឹងល្អឲ្យកាន់តែច្រើនឡើង

## ១- អគ្គសញ្ញាជ្រមុជទឹក និង អគ្គសញ្ញាលើកលែងទោស

រហូតមកដល់ គ.ស. ៣១៣ អ្នកជឿលើព្រះគ្រីស្តប្រថុយខ្លួនឲ្យគេសម្លាប់ព្រោះតែជំនឿថ្មីរបស់គេ ដែលប្លែកពីជំនឿអ្នកស្រុកទូទៅ ។ បន្ទាប់មក សភាពការណ៍ប្រែប្រួល ។ ប្រជារាស្ត្រក្នុងចក្រភពភាគច្រើនប៉ងប្រាថ្នាក្លាយទៅជាគ្រីស្តបរិស័ទ ដោយ «*ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស*» ដើម្បីឲ្យគាប់ព្រះចៅនិងរាជការ តែគេមិនសូវព្រមធ្វើតាមព្រះបញ្ញារបស់ព្រះយេស៊ូទេ ។ ក្បួនពិធីធ្វើអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលើកលែងទោសនៅដដែល តែគេអនុវត្តតាមរបៀបប្លែកពីមុន ។

***ក- អគ្គសញ្ញាជ្រមុជទឹក***

មនុស្សជាច្រើនទទួលការអប់រំអំពីសេចក្តីជំសំខាន់ៗដើមដំបូង មុននឹងចូលក្នុងក្រុមអ្នកទទួលអប់រំជំនឿ ។ បូជាចារ្យគូសសញ្ញាឈើឆ្កាងលើគេ គេទទួលអំបិលជានិមិត្តរូបអំពីឱជារសនៃព្រះបន្ទូល ។ ប៉ុន្តែ គេមិនព្រមទៅមុខទៀតទេ គេបន្លាយពេលទទួលអគ្គសញ្ញាជ្រមុជទឹកយ៉ាងយូរ គឺរហូតដល់ចាស់ជរា ឬដល់ពេលស្លាប់ក៏មាន ។ គេជឿថា អគ្គសញ្ញាជ្រមុជទឹកអាចលើកលែងទោសមនុស្សឲ្យបានរួចពីបាបទាំងអស់ ហើយព្រះសហគមន៍លើកលែងទោសតែម្តងគត់ក្នុងមួយជីវិត ។ ដូច្នេះ គេចូលចិត្តរង់ចាំរហូតដល់អស់តណ្ហា ទើបគេទទួលអគ្គសញ្ញា

44

ជ្រមុជទឹកនោះ ។ ដូច្នេះ ព្រះសហគមន៍មិនសូវយកចិត្តទុកដាក់នឹងក្រុមទទួលការអប់រំជំនឿបែបនេះ ហើយបែរទៅរកតែអ្នកសូមទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងពេលឆាប់ៗ ។

រដូវសែសិបថ្ងៃបានក្លាយទៅជាពេលរៀបចំអ្នកជឿ ឲ្យទទួលអគ្គសញ្ញាជ្រមុជទឹក ។ នៅដើមរដូវសែសិបថ្ងៃ អ្នកទាំងនោះចុះឈ្មោះ ។ លោកអភិបាល ឬតំណាងរបស់លោកពន្យល់ធម៌ប្រកាសជំនឿដើម្បីអប់រំជំនឿគេ ។ លោកហាមអ្នកទទួលការអប់រំជំនឿ មិនឲ្យយកសេចក្ដីដែលគេរៀននោះទៅប្រាប់អ្នកដទៃឡើយ ដើម្បីឲ្យការអប់រំមានតម្លៃ ហើយដើម្បីឲ្យគេប្រព្រឹត្តតាម ។ នៅពេលថ្វាយអភិបូជានាថ្ងៃអាទិត្យក្នុងរដូវសែសិបថ្ងៃ អ្នកទទួលការអប់រំធ្វើពិធីជម្រះចិត្តគំនិត ។ បូជាចារ្យអានធម៌ប្រកាសជំនឿយ៉ាងឱឡារិក គឺធម៌ប្រកាសជំនឿដែលពួកគេត្រូវថ្លែងនៅថ្ងៃសៅរ៍ពិសិដ្ឋខាងមុខ ។ ព្រះសហគមន៍ខ្លះគេប្រព្រឹត្តតាមរបៀបដដែលនេះចំពោះធម៌ *«ឱព្រះបិតា»* ដែរ ។ ពិធីនៅរាត្រីបុណ្យចម្លងនៅដដែល ។ ពន្លកថ្មីទទួលការអប់រំជំនឿមួយសប្ដាហ៍ទៀតក្រោយបុណ្យចម្លង ។ ប៉ុន្តែនៅកន្លែងខ្លះ មុនទទួលអគ្គសញ្ញាជ្រមុជទឹក គេទទួលការអប់រំតែអំពី «ធម៌ប្រកាសជំនឿ» និងការប្រែចិត្តគំនិតតាមសីលធម៌ប៉ុណ្ណោះ ។ ក្រោយពេលទទួលអគ្គសញ្ញាជ្រមុជទឹកហើយ គេទទួលការអប់រំអំពីអគ្គសញ្ញានានាដែលគេធ្លាប់ហៅ *«សេចក្ដីអប់រំជំនឿតាមអគ្គសញ្ញានានា» (Mystagogie)* នៅក្នុងពេលអប់រំនោះ គេពន្យល់តែអំពីអត្ថន័យអគ្គសញ្ញាជ្រមុជទឹក និងអត្ថន័យអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធ ។

នៅសម័យនោះ រដ្ឋអំណាចនិងអ្នកជងទាំងពួងមិនប្រឆាំងជំទាស់នឹងគ្រីស្តបរិស័ទទៀតទេ ។ ហេតុនេះ ទេវវិជ្ជាសង្កត់ទៅលើតម្លៃនៃពិធីដ៏សក្ដិសិទ្ធិ ដែលសម្ដែងអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ។ សន្ត**អូគូស្តាំង**មានបំណងលើកទឹកចិត្តគ្រីស្តបរិស័ទអោយធ្វើអគ្គសញ្ញាជ្រមុជទឹកជូនក្មេងៗ ហេតុនេះហើយបានជាលោកគូសសង្កត់លើ *«បាបឪពុកម្ដាយដើម»* គឺទោះបីក្មេងគ្មានប្រព្រឹត្តអំពើបាបដោយខ្លួនឯងក្ដី ក៏ត្រូវព្រះជាម្ចាស់សង្គ្រោះវាដែរ ។

## *ខ- ពិធីលើកលែងទោស*

គ្រីស្តបរិស័ទដែលមិនសូវគោរពប្រណិប័តន៍ព្រះអម្ចាស់ តែងតែធ្វើអំពើបាបធ្ងន់ធ្ងរ តែព្រះសហគមន៍លើកលែងទោសឲ្យគេតែម្ដងគត់ក្នុងមួយជីវិត ។ ដូច្នេះ អ្នកបាបតែងតែសូមធ្វើពិធីលើកលែងទោស នៅពេលគេចាស់ជរា ឬនៅពេលជិតស្លាប់ ។ ព្រះសហគមន៍ធ្វើពិធីលើកលែងទោសជាផ្លូវការយ៉ាងពិសេស មិនមែនជាពិធីធម្មតាទេ ។ មានតែអ្នកប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ និងអ្នកនាំឲ្យអ្នកដទៃប្រព្រឹត្តអំពើបាបទេ ដែលត្រូវធ្វើពិធីនោះ ពីព្រោះគេមិនអាចចូលរួមក្នុងពិធីអរព្រះគុណបានជាដាច់ខាត ។ គ្រីស្តបរិស័ទភាគច្រើនមិនត្រូវធ្វើពិធីលើកលែងទោសយ៉ាងឱឡារិកនេះទេ ។

ធម្មតា គ្រីស្តបរិស័ទដែលប្រព្រឹត្តអំពើបាបធ្ងន់ លន់តួមកលោកអភិបាលព្រះសហគមន៍ដោយសម្ងាត់ ។ លោកអភិបាលក៏សុំឲ្យអ្នកបាបមកចូលក្នុងពិធីលើកលែងទោសរួមដែរ ។ ពិធីលើកលែងទោសរួមនោះ ប្រព្រឹត្តតាមដំណាក់កាលផ្សេងៗក្នុងពេលថ្វាយអភិបូជា ។ នៅពេលនោះ លោកអភិបាលដាក់ដៃលើពួកអ្នកបាប និងឲ្យគេពាក់អាវក្នុងធ្វើអំពីរោមពពែ ។ ពួកគេចូលរួមក្នុងក្រុមអ្នកសុំព្រះជាម្ចាស់លើកលែងទោស ជាក្រុមដោយឡែកក្នុងព្រះសហគមន៍ ។ គេមិនចូលរួមថ្វាយតង្វាយ និងមិនទទួលព្រះកាយទៀតទេ ។ នៅក្នុងរដូវសែសិបថ្ងៃ ក្រុមបូជាចារ្យដាក់ដៃលើពួកគេសាជាថ្មី ។ ត្រូវប្រើរយៈពេលដ៏យូរ គឺជួនកាលរហូតដល់ច្រើនឆ្នាំក៏មាន ទៅតាមអំពើបាបរបស់គេ ។ លោកអភិបាលតែងធ្វើពិធីសម្រុះសម្រួលពួកអ្នកបាបដោយដាក់ដៃលើគេ ។ តាមធម្មតា លោកធ្វើពិធីនេះនៅថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ។

Layout Histor.qxd 2/10/07 10:09 AM Page 81

## (44) អំពីមូលហេតុផ្សេងៗរបស់អ្នកសុំទទួលអគ្គសញ្ញាជ្រមុជទឹក នាពាក់កណ្ដាលសតវត្សទី ៤

លោក**ស៊ីរិល** (គ.ស. ៣១៥-៣៨៧) ជាអភិបាលព្រះសហគមន៍ក្រុងយេរូសាឡឹម ។ រដ្ឋអំណាចនិរទេសលោកបីដង ព្រោះរឿងលោក**អារីយ៉ូស**បែកពីជំនឿ ។ លោកថ្លែងសេចក្ដីអប់រំជំនឿចំនួន ២៤ នៅព្រះវិហារសង់ត្រង់ផ្នូរព្រះយេស៊ូ ។ អត្ថបទខាងក្រោមនេះ ដកស្រង់ពីសេចក្ដីអប់រំខាងដើមដំបូង គឺពេលគេមកចុះឈ្មោះសុំទទួលអគ្គសញ្ញាជ្រមុជទឹក នៅដើមរដូវសែសិបថ្ងៃ ។ លោកស៊ីរិលមិនបាញ់បោកគេអំពីគោលបំណងអ្នកសុំទទួលអគ្គសញ្ញាជ្រមុជទឹកនោះទេ ។

*យើងជាអ្នកបម្រើព្រះគ្រីស្ត យើងតែងតែទទួលអស់អ្នកដែលមកជួបយើងដោយមិនរើសមុខ ។ យើងដូចជាឆ្មាំទ្វារនៅតែរង់ចាំ ទ្វារបើកចំហជានិច្ច ។ ហេតុដូចនេះហើយ បានជាអ្នកមានចិត្តគំនិតប្រឡាក់ដោយអំពើបាប ឬដោយមានគោលបំណងមិនបរិសុទ្ធ ក៏អាចចូលបានដែរ ។ អ្នកអើយ! អ្នកចូលព្រោះអ្នកយល់ឃើញថា ខ្លួនសមនឹងចូលបាន ។ អ្នកចុះឈ្មោះហើយ! តើអ្នកឃើញអង្គប្រជុំដ៏ល្អរបស់យើងឬទេ? តើអ្នកបានឃើញសណ្ដាប់ធ្នាប់ និងវិន័យអង្គប្រជុំយើងឬទេ? តើអ្នកសង្កេតឃើញពិធីថ្លែងព្រះគម្ពីរ វត្តមានក្រុមបូជាចារ្យ និងអំពីរបៀបរៀបរយនៃការអប់រំរបស់យើងឬទេ? ចូរអ្នកដាក់ភ្នែកនៅទីនេះចុះ ហើយរៀនអំពីអ្វីៗដែលអ្នកឃើញ ។ ពេលនេះសូមអញ្ជើញចេញទៅចុះ ហើយថ្ងៃស្អែកសូមអ្នកចូលមកវិញដោយមានចិត្តទៀងត្រង់ ។*

*បើអ្នកពោរពេញដោយចិត្តកំណាញ់ សូមមកវិញដោយមានសម្លៀកបំពាក់ផ្សេង ។ ចូរដកសម្លៀកបំពាក់ចាស់ចេញ ហើយបំពាក់សម្លៀកបំពាក់មួយទៀត ។ ចូរដកការប្រាសចាកសីលធម៌ និងអ្វីៗដែលមិនបរិសុទ្ធចេញពីខ្លួន ហើយស្លៀកពាក់ឆើតឆាយ គឺពាក់ចិត្តបរិសុទ្ធជំនួសវិញ ។ រីឯខ្ញុំវិញ ខ្ញុំសូមទូន្មានបងប្អូនមុនពេលព្រះយេស៊ូយាងមក ព្រះអង្គជាស្វាមីនៃវិញ្ញាណរបស់បងប្អូន សូមកុំឲ្យព្រះអង្គទតឃើញសម្លៀកបំពាក់របស់បងប្អូន ។ អ្នកមានពេលគឺអស់រយៈពេលសែសិបថ្ងៃ សូមព្រះអង្គលើកលែងទោស ។ ពិតជាឱកាសល្អសម្រាប់ដោះសម្លៀកបំពាក់ចេញ លាងសំអាតខ្លួនប្រាណ រួចស្លៀកពាក់ថ្មីហើយសឹមត្រឡប់មកវិញ ។ តែប្រសិនបើចិត្តអ្នកនៅតែមិនល្អបរិសុទ្ធទេ ខ្ញុំជាអ្នកនិយាយទៅកាន់អ្នកថា ខ្ញុំមិនទទួលខុសត្រូវឡើយ ។ រីឯអ្នកវិញកុំសង្ឃឹមថា ព្រះជាម្ចាស់ប្រោសប្រណីដល់អ្នក ។ ទឹកនឹងទទួលអ្នក តែព្រះវិញ្ញាណមិនទទួលអ្នកឡើយ ។ បើនរណាម្នាក់ដឹងថាខ្លួនមានរបួស សូមរុំមុខរបួសនោះសិន ។ បើនរណាម្នាក់ដួលសូមឲ្យគេក្រោកឡើងសិន ។*

*ប្រហែលជាអ្នកមកនេះ មានបំណងមួយផ្សេងទៀត ។ ប្រហែលបុរសម្នាក់ចូលមកទីនោះ ដោយមានបំណងចង់គាប់ចិត្តភរិយា ។ យើងអាចនិយាយសេចក្ដីដដែល ចំពោះស្ត្រីៗដែលចង់គាប់ចិត្តប្ដីដែរ ។ ជួនកាលទាសករម្នាក់ចង់គាប់ចិត្តម្ចាស់គេ ឬមិត្តសម្លាញ់ចង់គាប់ចិត្តមិត្តរបស់ខ្លួន ។*

*ខ្ញុំសុខចិត្តទទួលស្គាល់នុយនៅផ្លែសន្ទូច ខ្ញុំសុខចិត្តទទួលអ្នកដែលអញ្ជើញមកដោយមានចេតនាអាក្រក់ ប៉ុន្តែខ្ញុំសង្ឃឹមថា ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកពុំខាន ។ អ្នកប្រហែលជាមិនដឹងថា ខ្លួនមកពីទីណាទេ ហើយក៏មិនស្គាល់សំណាញ់ដែលចាប់អ្នកដែរ គឺអ្នកត្រូវចាប់ខ្លួនក្នុងសំណាញ់នៃព្រះសហគមន៍ហើយ ។ ចូរបណ្ដោយខ្លួនឲ្យគេចាប់អ្នកទាំងរស់ កុំរត់ឡើយ ព្រោះព្រះយេស៊ូនេះហើយដែលចាប់យកអ្នកដោយផ្លែសន្ទូចនោះ មិនមែនដើម្បីអ្នកស្លាប់ទេ គឺដើម្បីឲ្យអ្នកមានជីវិតវិញ ក្រោយពីបានសម្លាប់អ្នកហើយ ។ អ្នកត្រូវស្លាប់និងត្រូវទទួលជីវិតថ្មី ។ អ្នកធ្លាប់បានឮគ្រីស្តទូតមានប្រសាសន៍ថា៖ «យើងស្លាប់ គឺលែងប្រព្រឹត្តអំពើបាប តែយើងមានជីវិតដើម្បីប្រព្រឹត្តតាមព្រះហឫទ័យព្រះជាម្ចាស់» ។ ចូរសុខចិត្តស្លាប់ គឺលែងប្រព្រឹត្តអំពើបាប និងទទួលជីវិត ដើម្បីប្រព្រឹត្តតាមព្រះហឫទ័យព្រះជាម្ចាស់ទៅ! ដូច្នេះ អ្នកនឹងមានជីវិតតាំងពីថ្ងៃនេះតទៅ ។*

*លោកស៊ីរិល ជាអភិបាលក្រុងយេរូសាឡឹម (គ.ស. ៣១៣-៣៨៧)*
*"សេចក្ដីអប់រំជំនឿមុននឹងទទួលអគ្គសញ្ញាជ្រមុជទឹក"*

លោកអភិបាលដាក់ទណ្ឌកម្មធ្ងន់ធ្ងរយ៉ាងពិសេស ឲ្យអ្នកសូមលើកលែងទោស គឺគេត្រូវពាក់សម្លៀកបំពាក់ដូចជនក្រីក្រ មិនសំអាតខ្លួន ត្រូវតមអាហារ មិនបរិភោគសាច់ ត្រូវធ្វើទាន ហាមប្រកបមុខរបរខ្លះ ហាមរួមបវេណីជាមួយភិរិយាឬជាមួយស្វាមី ។ សូម្បីតែក្រោយពេលគេធ្វើពិធីលើកលែងទោសរួចហើយក្តី ក៏ព្រះសហគមន៍នៅតែហាមមិនឲ្យប្រកបមុខរបរខ្លះ និងមិនរួមបវេណីជាមួយភិរិយាឬជាមួយស្វាមីរហូតដល់ស្លាប់ ។ គេបាត់ទុកគ្រីស្តបរិស័ទដែលមិនគោរពតាមវិន័យជាអ្នកក្បត់សាសនា ហើយលោកអភិបាលមិនលើកលែងទោសគេម្តងទៀតទេ ។ គេសង្ឃឹមថា នឹងទទួលព្រះកាយព្រះគ្រីស្តបាននៅពេលហៀបនឹងស្លាប់តែប៉ុណ្ណោះ ។

ដោយព្រះសហគមន៍លើកលែងទោសជាផ្លូវការតឹងរ៉ឹងយ៉ាងនេះ អ្នកទទួលការអប់រំជំនឿសុំពន្យាពេលទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីឲ្យព្រះជាម្ចាស់លើកលែងទោសឲ្យគេនៅថ្ងៃណាមួយ ដោយព្រះសហគមន៍មិនដាក់ទណ្ឌកម្មពិសេសនោះ ។ រីឯអ្នកបាបដែលទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយ គេពន្យាពេលធ្វើពិធីលើកលែងទោសរហូតដល់ពេលចុងក្រោយ ដ្បិតគេមិនអាចបោះបង់បោលមុខរបរចិញ្ចឹមជីវិតរបស់គេបានទេ ហើយក៏តមរួមបវេណីមិនបានដែរ ។ ម្យ៉ាងទៀត លោកអភិបាលមិនព្រមធ្វើពិធីលើកលែងទោសជូនមនុស្សដែលនៅក្មេងទេ ដូច្នេះ ពិធីនោះក្លាយទៅជាពិធីសម្រាប់តែមនុស្សចាស់ជរា និងមនុស្សជិតស្លាប់ ។

គេអញ្ជើញអ្នកបាបឲ្យធ្វើកិច្ចការខ្លះរៀងរាល់ថ្ងៃ បញ្ជាក់ថា គេចង់ឲ្យព្រះសហគមន៍លើកលែងទោសឲ្យគេនៅថ្ងៃចុងក្រោយបំផុត គឺគេលត់ដំខ្លួន ធ្វើទាន តមអាហារ អធិដ្ឋាន ។ល ។ ពួកគេមិនត្រូវចូលរួមក្នុងពិធីអរព្រះគុណឡើយ ។ អ្នកបាបដែលបណ្តាលឲ្យអ្នកដទៃប្រព្រឹត្តអំពើបាប ព្រះសហគមន៍ដេញគេចេញដោយប្រកាសឈ្មោះ ។ តែអ្នកបាបជាច្រើន ក្រោយពីតមមួយរយៈ គេក៏ទទួលព្រះកាយវិញ ទោះបីគេមិនបានធ្វើពិធីលើកលែងទោសជាមុនក្តី ។ មានអ្នកខ្លះយល់ឃើញថា ពិធីទទួលព្រះកាយ លុបបំបាត់ស្នាមនៃអំពើបាបរបស់គេ ។

នៅសតវត្សទី ៥ គ្រីស្តបរិស័ទជាច្រើនមិនសូវចាប់អារម្មណ៍នឹងរបៀបលើកលែងទោសនេះទេ ពីព្រោះអ្នកបាបមិនព្រមទទួលទណ្ឌកម្មដ៏តឹងរ៉ឹងនេះឡើយ ។ ផ្ទុយទៅវិញ គ្រីស្តបរិស័ទដែលចង់ធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ ក៏សុខចិត្តចុះចូលធ្វើពិធីលើកលែងទោសជាផ្លូវការ ដោយចិត្តសុភាពរាបសា ។

## ២- គ្រីស្តបរិស័ទនាំគ្នាធ្វើពិធីគោរពបូជាយ៉ាងរុងរឿង

ពិធីអរព្រះគុណកាន់តែអឺកអធឹកយ៉ាងរុងរឿង ដោយគ្រីស្តបរិស័ទសាងសង់ព្រះវិហារល្អឆើតឆាយនិងអាគារធំៗ ។ សម្លៀកបំពាក់របស់បូជាចារ្យ និងគ្រឿងឧបករណ៍សម្រាប់ពិធីនោះក៏កាន់តែមានតម្លៃ ។ គេថ្លែងអត្ថបទព្រះបន្ទូលកាន់តែច្រើនឡើងៗ ដង្ហែក្បួនយ៉ាងឱឡារិក និងចូលចិត្តសម្តែងធម្មទេសនាកាន់តែវែងទៅៗ ។ នៅប៉ែកខាងបស្ចិមប្រទេស មានទម្លាប់ធ្វើពិធីអរព្រះគុណជារៀងរាល់ថ្ងៃ រីឯប៉ែកខាងបូព៌ាប្រទេសវិញ គេមានទំនៀមទម្លាប់ផ្សេង ។

### *ក- ប្រតិទិនខាងពិធីបុណ្យប្រចាំឆ្នាំ*

ចាប់ពីសតវត្សទី ២ រហូតមក គ្រីស្តបរិស័ទតែងតែបន្តអំណរសប្បាយនៃបុណ្យចម្លងអស់រយៈពេល ៥០ ថ្ងៃ ។ នៅចុងសតវត្ស ទី ៤ គ្រីស្តបរិស័ទនាំគ្នាធ្វើបុណ្យថ្ងៃទី ៥០ ទុកជាបុណ្យលើកតម្កើងព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណ ។ គ្រីស្តបរិស័ទក៏នាំគ្នាលើកពីរថ្ងៃ មុនបុណ្យចម្លងភ្ជាប់នឹងបុណ្យដ៏ឱឡារិកនេះ ទុកជាថ្ងៃតមអាហារសម្រាប់រៀបចំខ្លួន ជាពិសេសសម្រាប់អ្នកទទួលការអប់រំជំនឿ មុនទទួលអគ្គសញ្ញាជ្រមុជទឹកនារាត្រីបុណ្យចម្លង ។ ក្រោយពីព្រះសហគមន៍ទទួលបានសេចក្តីសុខសាន្ត គឺតាំងពី គ.ស. ៣១៣ រហូតមក គេចាប់ផ្តើមចាត់ចែងរដូវសែសិបថ្ងៃបន្តិចម្តងៗ ។ មុនដំបូង គ្រីស្តបរិស័ទត្រូវតមអាហារមួយសប្តាហ៍មុន

Layout Histor.qxd 2/10/07 10:09 AM Page 83

បុណ្យចម្លង បន្ទាប់មកគេនាំគ្នាតមអាហារ ៤០ ថ្ងៃតែម្តង ។ តែគេរាប់សែសិបថ្ងៃតាមរបៀបផ្សេងពីគ្នា ។ គេមានបំណងធ្វើតាមព្រះយេស៊ូ ដែលតមអាហារអស់រយៈពេល ៤០ ថ្ងៃនៅវាលរហោស្ថាន ។ ដោយព្រះសហគមន៍រៀបចំអ្នកទទួលការអប់រំជំនឿ ឲ្យទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឱកាសបុណ្យចម្លងនៅពេលខាងមុខនោះ ទើបរដូវសែសិបថ្ងៃនោះមានអត្ថន័យនិងតម្លៃជា «រដូវអប់រំពិសេស» វិញ ។

នៅសតវត្សទី ៤ គ្រីស្តបរិស័ទចាប់ផ្តើមកំណត់ថ្ងៃបុណ្យពីរ តាមកាលបរិច្ឆេទជាក់ច្បាស់ គឺនៅបូព៌ាប្រទេស គេនាំគ្នាប្រារព្ធធ្វើបុណ្យព្រះយេស៊ូសម្តែងព្រះអង្គនៅថ្ងៃទី ៦ ខែមករា គឺគេនាំគ្នានឹករឭកថ្ងៃព្រះយេស៊ូប្រសូតផង ថ្ងៃព្រះអង្គទទួលពិធីជ្រមុជទឹកផង នៅថ្ងៃទី ៦ មករា ដដែលនោះ ជាថ្ងៃអ្នកស្រុកអេស៊ីបធ្លាប់ធ្វើបុណ្យគោរពព្រះអាទិត្យ ។ រីឯនៅបស្ចិមប្រទេសវិញ ប្រហែលនៅ គ.ស ៣៣០ គេចាប់ផ្តើមធ្វើពិធីរឭកព្រះយេស៊ូប្រសូត នៅថ្ងៃទី ២៥ ខែធ្នូ ។ នៅថ្ងៃនោះ ជនជាតិរ៉ូម៉ាំងតែងតែនាំគ្នាធ្វើពិធីគោរពព្រះអាទិត្យដែលឈ្នះភាពងងឹត និងសេចក្តីស្លាប់ ព្រោះតាំងពីថ្ងៃ ២៥ ធ្នូនោះ ព្រះអាទិត្យចាប់ផ្តើមរះឡើងព្រឹកជាងថ្ងៃមុនមួយថ្ងៃបន្តិចៗ ។ នៅចុងសតវត្សទី ៤ គ្រីស្តបរិស័ទទាំងខាងបស្ចិម ទាំងខាងបូព៌ានាំគ្នាធ្វើពិធីបុណ្យទាំងពីរនោះជាបន្តបន្ទាប់គ្នា ។ នៅបស្ចិមប្រទេស ថ្ងៃទី ២៥ ធ្នូ គេធ្វើពិធីអបអរសាទរព្រះយេស៊ូប្រសូតនៅបេថ្លេហិម ហើយនៅថ្ងៃទី ៦ មករា គេនាំគ្នាធ្វើពិធីអបអរសាទរពួកហោរាចារ្យមកថ្វាយបង្គំព្រះយេស៊ូ ព្រះយេស៊ូទទួលពិធីជ្រមុជទឹក និងព្រះអង្គប្រែទឹកជាស្រានៅភូមិកាណាផង ។

## *ខ- ពិធីគោរពមរណសាក្សី និង បូជនីយេសក៍*

នៅសម័យនោះ គ្រីស្តបរិស័ទនាំគ្នាគោរពមរណសាក្សីជាច្រើនទៅតាមបែបដ៏អស្ចារ្យ ។ ជួនកាលគេត្រាប់តាមទំនៀមទម្លាប់សាសនាដទៃពីដើម ឧប. គេនាំគ្នាយកអាហារឧទ្ទិសជូនដល់មរណសាក្សីនៅលើផ្នូររបស់អស់លោក ។ គេកសាងព្រះវិហារយ៉ាងធំសម្បើមនៅកន្លែងបញ្ចុះសពមរណសាក្សី ។ ឧប. ព្រះវិហារសន្ត**សិលា** នៅជម្រាលភ្នំវ៉ាទីកង់ ។ គេសូមកប់សពរបស់ខ្លួននៅក្បែរផ្នូរមរណសាក្សីទាំងនោះ ។ គ្រីស្តបរិស័ទចូលចិត្តគោរពធាតុរបស់មរណសាក្សី ។ នៅសម័យនោះគេអះអាងថា បានរកឃើញវត្ថុផ្សេងៗគួរឲ្យរំភើបអស្ចារ្យ ឧបមា. គេរកឃើញឈើឆ្កាងរបស់**ព្រះយេស៊ូ** ជាតុរបស់សន្ត**ស្ទេផាន** ជាតុរបស់គ្រីស្តទូត ។ល។ គេក៏ផ្ញើជាតុទាំងនោះទៅគ្រប់ព្រះសហគមន៍ ។ គ្រីស្តបរិស័ទយកចិត្តទុកដាក់នឹងកន្លែងដែលចែងក្នុងព្រះគម្ពីរ កន្លែងព្រះគ្រីស្តគង់នៅនិងប្រព្រឹត្តព្រះរាជកិច្ចផ្សេងៗ ។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទចាប់ផ្តើមចូលចិត្តទៅបូជនីយដ្ឋាន ដើម្បីបានចូលទៅគោរពបូជាកន្លែងទាំងនោះផង ។ យើងក៏ស្គាល់សេចក្តីរាយការណ៍របស់អ្នកស្រី**អេសេរី** (Egérie) ដែលជាបូជនីយេសក៍ទៅយេរូសាឡឹម ប្រហែល (45)
នៅ គ.ស. ៤០០ ។ ដោយសារពួកបូជនីយេសក៍ឆាប់ជឿរឿងផ្សេងៗ អ្នកនាំផ្លូវ«*រកឃើញ*» វត្ថុបុរាណ ឬកន្លែងដ៏អស្ចារ្យកាន់តែច្រើនឡើងៗ ទោះជាវត្ថុខ្លះក្លែងក្លាយក្តី ឬគ្មានកើតអ្វីនៅកន្លែងនោះក្តី ។

## ៣- គេយកចិត្តទុកដាក់ប្រកាសដំណឹងល្អ

### *ក- នៅខាងក្នុងចក្រភព*

យូរៗទៅ ប្រជាជននៅក្រុងនានាក្នុងចក្រភពរ៉ូម៉ាំង បែរទៅជាគ្រីស្តបរិស័ទស្ទើរតែគ្រប់គ្នា ។ គ្រីស្តបរិស័ទភ្លេចសភាពការណ៍ពីដើម កាលពីរដ្ឋអំណាចធ្វើទុក្ខបុកម្នេញជូនតារបស់គេ ។ ពួកគេបែរជាទៅបំផ្លាញវិហារសាសនាដទៃដែលនៅសេសសល់ ។ អស់លោកអភិបាលព្រះសហគមន៍ យកចិត្តទុកដាក់ប្រកាសដំណឹងល្អទៅប្រជាជននៅតាមជនបទ ជាកន្លែងដែលអ្នកស្រុកនៅតែគោរពអារក្ខអ្នកតាម្ចាស់ទឹកម្ចាស់ដីនៅឡើយ ។ សន្ត**ម៉ារតាំង** ជាអភិបាលព្រះសហគមន៍នៅក្រុងតួរ (Tours ប្រទេសបារាំងសព្វថ្ងៃ) ពីគ.ស. ៣៧០ ដល់គ.ស. ៣៩៧ លោក

Layout Histor.qxd 2/10/07 10:09 AM Page 84

ល្បីល្បាញជាងគេ ក្នុងការប្រកាសដំណឹងល្អដល់ប្រជាជនរស់នៅតាមជនបទ ។ ទោះបីគ្រីស្តបរិស័ទរៀបរាប់រឿងរបស់លោក ដោយបំផ្លើសដូចរឿងព្រេងក្តី ក៏ត្រូវដឹងថា អ្នកប្រកាសដំណឹងល្អធ្លាប់រំលំរូបបដិមានានារបស់ព្រះដទៃ កាប់ដើមឈើសក្ការៈ ដុតបំផ្លាញវិហារ ឬកន្លែងគោរពបូជារបស់គេ ហើយកសាងព្រះវិហារធំតូចនៅកន្លែងនោះវិញ ។ បណ្តាជនយល់ព្រម សូមទទួលអគ្គសញ្ញាជ្រមុជទឹក ។ ប៉ុន្តែ សាសនាពីដើមស្ថិតនៅកប់ក្នុងចិត្តគេ ជួនកាលសាសនានេះរើឡើងវិញ ។ ការប្រកាសដំណឹងល្អតាមជនបទ បណ្តាលឲ្យកើត *"ភូមិគ្រីស្តបរិស័ទ"* ជាច្រើនជាភូមិស្វយ័ត ផ្ញើទុកឲ្យព្រឹទ្ធាចារ្យម្នាក់ណែនាំ ។ ព្រឹទ្ធាចារ្យមិនរស់នៅក្នុងក្រុងជាមួយលោកអភិបាលទៀតទេ ។ ទីស្នាក់ការរបស់អភិបាលព្រះសហគមន៍កើនឡើងនៅដើមសតវត្ស ទី ៤ ។ ឧបមា. គ.ស. ៣០០ នៅស្រុកអ៊ីតាលីខាងជើងមានអភិបាលតែ ៥ ឬ ៦ នាក់ប៉ុណ្ណោះ នៅគ.ស. ៤០០ មានអភិបាល ៥០ នាក់ ។

## *ខ- នៅខាងក្រៅចក្រភព*

នៅពាក់កណ្តាលសតវត្សទី ៤ ក្នុងស្រុកពែរ្ស រដ្ឋអំណាចធ្វើទុក្ខបុកម្នេញព្រះសហគមន៍ ។ តាំងពីមហាសន្និបាតក្រុងសេលីស៊ី (Bagdad បាដាតសព្វថ្ងៃ) នា គ.ស. ៤១០ ព្រះសហគមន៍នោះរស់ឡើងវិញ ហើយនាំគ្នាចេញទៅប្រកាសដំណឹងល្អនៅបូព៌ាប្រទេស គឺនៅតំបន់ឈូងសមុទ្រពែរ្ស និងនៅអាស៊ីកណ្តាល ។ ព្រះសហគមន៍នៅស្រុកអ័រមេនី (Arménie) ចម្រើនឡើង ហើយនៅសតវត្សទី ៥ គេយកភាសាជាតិធ្វើជាភាសាវប្បធម៌ ដោយសន្ត**មេស្រូប** (Misrop) (ទទួលមរណភាពនៅ គ.ស. ៤៤១) បង្កើតអក្សរក្រមអ័រមេនី ។ គ្រីស្តសាសនាចាក់ឫសនៅស្រុកនានាក្នុងតំបន់កូកាស (Caucase) ដោយសន្តី**នីណូ** (Nino) ជាទាសីម្នាក់ដែលរួចពីអំណាចជនជាតិរ៉ូម៉ាំង នាំដំណឹងល្អដល់ជនជាតិសេអ័រស៊ី (Géorgie) ។ មនុស្សជាប់ជាឈ្លើយ មួយក្រុមប្រកាសដំណឹងល្អនៅស្រុកអេធ្យូពី (Ethiopie) ហើយភ្ជាប់ព្រះសហគមន៍របស់ខ្លួនទៅនឹងព្រះសហគមន៍ក្រុងអាឡិចសង់ឌ្រី ។

សន្ត**វុលហ្វីឡា** (Wulfila) (ទទួលមរណភាពនៅ គ.ស. ៣៨៣) នាំដំណឹងល្អទៅដល់ជនជាតិអាល្លឺម៉ង់ តាមរបៀបលោក**អារីយ៉ូស** ។

នៅសតវត្សទី ៥ ព្រះសហគមន៍ដែលនៅខាងក្រៅចក្រភព មិនព្រមអនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាតក្រុងអេភេសូ និងក្រុងកាលសេដូន (*សូមអាននៅជំពូក ៥ ទំព័រ ១០១-១០៤*) ។ ព្រះសហគមន៍ទាំងនោះក៏បែកចេញពីព្រះសហគមន៍ដែលនៅក្នុងចក្រភព ។ ប៉ុន្តែ ពួកគេនៅតែបន្តប្រកាសដំណឹងល្អ ។



*រូបចម្លាក់ដោយផ្ដិថុតូចៗមានន័យថា៖ ព្រះគ្រីស្តគង់នៅតាំងពីដើម សព្វថ្ងៃ ហើយកំពុងតែយាងមក*

Layout Histor.qxd 2/10/07 10:09 AM Page 85

## ㊺ បូជនីយេសក៏លើទឹកដីដ៏វិសុទ្ធ នៅសតវត្សទី ៤

គ្មាននរណាដឹងច្បាស់ថា បងស្រី**អេសេរី**ជានរណានោះទេ ។ តាមគេស្មាន បងស្រីជាអភិជនជាតិអេស្ប៉ាញម្នាក់ រស់នៅចុងសតវត្សទី ៤ ។ ប្រហែលបងស្រីជាបព្វជិតា ឬយ៉ាងហោចណាស់ជាស្ត្រីព្រហ្មចារី រស់នៅក្នុងចំណោមមនុស្សឯទៀតៗ ។ គាត់ជាបូជនីយេសចក៏នៅលើទឹកដីដ៏វិសុទ្ធ រួចគាត់ធ្វើសេចក្ដីរាយការណ៍ជូនបព្វជិតាជាបងប្អូនរបស់គាត់ ។ សេចក្ដីដែលគាត់រាយការណ៍នោះនាំឲ្យយើងដឹងអំពីគ្រីស្ដបរិស័ទនៅមជ្ឈិមបូព៌ានាសតវត្សទី ៤ និងអំពីពិធីនានានៅក្រុងយេរូសាឡឹមដែរ ។ ហើយម្យ៉ាងទៀត បងស្រីអេសេរីបង្ហាញឲ្យដឹងថា មនុស្សឆាប់ជឿរឿងផ្សេងៗ ដោយមិនរិះគិតពិចារណាអំពីទីកន្លែងនៃព្រឹត្តិការណ៍សំខាន់ៗនៅក្នុងគម្ពីរដែលកើតមានឡើង ។

*យើងចុះពីភ្នំរបស់ព្រះជាម្ចាស់ (គឺពីភ្នំស៊ីណៃ) ប្រហែលជាម៉ោងបួនរសៀល យើងទៅដល់គុម្ពោតបន្លា គឺព្រះជាម្ចាស់មានព្រះបន្ទូលពីគុម្ពោតក្នុងភ្លើងនោះ មកកាន់លោក**ម៉ូសេ** ។ នៅទីនោះមានអាស្រមឥសីជាច្រើន និងព្រះវិហារមួយនៅចុងជ្រលងភ្នំ ។ នៅមុខព្រះវិហារមានសួនឧទ្យានមួយស្អាតណាស់ ដែលមានទឹកច្រើននិងឆ្ងាញ់ពិសា គឺក្នុងសួនឧទ្យាននេះហើយ ដែលមានគុម្ពោតបន្លា ។ គេបង្ហាញនៅក្បែរទីនោះ នូវកន្លែងលោកម៉ូសេបានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ថា «ចូរដោះស្បែកជើងចេញ...» ។ល ។ យើងទៅដល់កន្លែងនោះម៉ោងជាងបួនរសៀលទៅហើយ ។ ដោយយប់ពេក យើងមិនបានថ្វាយដង្វាយទេ ប៉ុន្តែ យើងអធិដ្ឋានក្នុងព្រះវិហារ និងនៅក្នុងសួនឧទ្យាននៅក្បែរគុម្ពោត ។ យើងអានអត្ថបទក្នុងគម្ពីរលោកម៉ូសេតាមទម្លាប់ ។ លុះពេលល្ងាចយើងពិសាអាហារនៅទីនោះ នៅមុខគុម្ពោត រួមជាមួយបុរសដ៏វិសុទ្ធទាំងនោះ (...) ។*

*ពីលើភ្នំណេបូ យើងបានមើលឃើញទឹកដីរបស់អ្នកស្រុកសូដុម ។ គេក៏បង្ហាញស្តូបភរិយារបស់លោក**ឡុត**ឲ្យឃើញ គឺកន្លែងដែលមានចែងក្នុងព្រះគម្ពីរ ។ ប៉ុន្តែ បងស្រីជាទីគោរព! សូមជឿខ្ញុំចុះ យើងមិនអាចឃើញស្តូបនោះបានទេ គឺគេបង្ហាញតែកន្លែងប៉ុណ្ណោះ ។ រីឯស្តូបវិញ គេនិយាយថា ប្រហែលវាលិចក្នុងសមុទ្រមរណៈ ។ យើងបានឃើញកន្លែង ខ្ញុំមិនអាចបញ្ឆោតបងប្អូនអំពីរឿងនេះបានទេ ។ លោកអភិបាលតំបន់នោះប្រាប់យើងថា គេលែងឃើញស្តូបនោះជាច្រើនឆ្នាំហើយ (...) ។*

*ពេលនោះ ខ្ញុំនឹកឃើញថា ក្នុងគម្ពីរមានចែងថា លោក**យ៉ូហាន**ធ្វើពិធីជ្រមុជទឹកថ្វាយព្រះយេស៊ូ នៅអែណូន នៅក្បែរភូមិសាលីម (យហ ៣,២៣) ។ ខ្ញុំក៏សួរទៅលោកបូជាចារ្យថា «កន្លែងនោះចម្ងាយប៉ុន្មាន?» ។ លោកប្រាប់មកខ្ញុំថា «២០០ ជំហានពីទីនេះប៉ុណ្ណោះ បើអ្នកចង់ទៅខ្ញុំជូនភ្លាម ។ ទឹកជាច្រើន និងថ្លាល្អដែលអ្នកឃើញក្នុងភូមិនេះ គឺចេញពីប្រភពនោះមក» ។ ភ្លាមនោះយើងនាំគ្នាដើរជាមួយលោកបូជាចារ្យតាមជ្រលងភ្នំដ៏ស្អាត រហូតទៅដល់ចម្ការដើមឈើមានផ្លែ លោកក៏បង្ហាញប្រភពទឹកមានទឹកថ្លានិងឆ្ងាញ់ពិសាផុសឡើងនៅកណ្ដាលចម្ការ ហើយក្លាយទៅជាអូរមួយ ។ នៅខាងមុខប្រភពទឹកនោះ មានអាងមួយ ច្បាស់ជាកន្លែងដែលលោកយ៉ូហានបាទីស្ដធ្វើពិធីជ្រមុជទឹកជូនប្រជាជន (...) ។*

*បងស្រីអេសេរី "សេចក្ដីកំណត់ទុកតាមដំណើរ"*

Layout Histor.qxd 2/10/07 10:09 AM Page 86

# គ_ ដើមកំណើតរបស់បព្វជិត

## ១- ដើមកំណើតនៃការរស់នៅជាបព្វជិតក្នុងព្រះសហគមន៍

សហគមន៍គ្រីស្តបរិស័ទ តែងតែលើកតម្កើងគ្រីស្តបរិស័ទដែលសម្រេចចិត្តរស់នៅជាព្រហ្មចារី ដោយយល់ដល់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ។ គេសម្រេចចិត្តរស់នៅតាមរបៀបនេះ ស្របតាមរបៀបព្រះយេស៊ូរស់នៅ និងស្របតាមព្រះបន្ទូលរបស់ព្រះអង្គ (មថ ១៩,២២.៣០) ហើយក៏ស្របតាមពាក្យរបស់គ្រីស្តទូត **ប៉ូល**ដែរ (១ ករ ៧) ។ ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី មានចែងអំពីក្រុមស្ត្រីមេម៉ាយ (១ ធម ៥) អំពីកូនក្រមុំបួននាក់របស់លោក**ភីលីព**ដែលថ្លែងព្រះបន្ទូល (កក ២១,៨-៩) និងរស់នៅជាព្រហ្មចារី គឺនាងថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់មុនគេបង្អស់ ។

នៅសតវត្សទី ២-៣ មានចែងអំពីបុរសស្ត្រីកាន់តែច្រើនឡើងៗ សម្រេចចិត្តរស់នៅធ្វើតបៈធម៌ និងរស់នៅជាព្រហ្មចារិយ ។ អស់លោកអ្នកមានចិត្តគំនិតតាមព្រះគ្រីស្ត គឺសុខចិត្តលះបង់អ្វីៗទាំងអស់ ដោយយល់ដល់ព្រះគ្រីស្ត ។ ប៉ុន្តែមានមូលហេតុផ្សេងៗទៀត នាំឲ្យគេបួសបែបនោះ គឺគ្រីស្តបរិស័ទខ្លះធុញទ្រាន់នឹងចរិយាខិលខូចរបស់មនុស្សសម័យនោះ ។ ស្ត្រីៗខ្លះចង់រួចផុតពីអំណាចរបស់បុរស ដែលតែងតែជិះជាន់ស្ត្រីៗក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ ។ ស្ត្រីៗចង់បានសេរីភាព ។

ពីដើមដំបូង ស្ត្រីព្រហ្មចារីដែលថ្វាយខ្លួន បន្តការរស់នៅក្នុងក្រុមគ្រួសាររបស់គេតទៅទៀត ហើយក៏រស់នៅដូចគ្រីស្តបរិស័ទឯទៀតៗដែរ ។ យូរៗទៅពួកនាងរស់នៅជុំគ្នា នាងគ្មានសម្លៀកបំពាក់ដូចៗគ្នាទេ ។ ព្រះសហគមន៍ទូន្មាននាងឲ្យរស់នៅជាអ្នកក្រីក្រ សូមឲ្យនាងបំពេញកិច្ចការសម្តែងមេត្តាករុណាធម៌ គឺឲ្យទៅសួរសុខទុក្ខអ្នកក្រីក្រនិងអ្នកជំងឺ ព្រមទាំងរំពឹងសញ្ជឹងគិតអំពីព្រះគម្ពីរ ។ តាំងពីសតវត្សទី ៣ រហូតមក ពួកគេចាប់ផ្តើមធ្វើពាក្យសច្ចាប្រណិធាន ។ ប៉ុន្តែគេធ្វើពាក្យសច្ចាយ៉ាងសម្ងាត់ មិនមែនជាពាក្យប្រកាសជាសាធារណៈទេ ហើយក៏មិនមែនសម្រាប់អស់មួយជីវិតដែរ ។

អស់លោកដែលសរសេរអំពីព្រហ្មចារិយធម៌នៅសម័យនោះ សូមឲ្យគិតគូរអំពីព្រហ្មចារិយធម៌តាមព្រះវិញ្ញាណ ។ អស់លោកពន្យល់ថា ការរស់នៅជាព្រហ្មចារី គឺជាការបន្តកិច្ចសន្យារបស់គ្រីស្តបរិស័ទ នៅពេលទទួលអគ្គសញ្ញាជ្រមុជទឹក ការរស់នៅជាព្រហ្មចារិយនេះ ធ្វើឲ្យគេរស់នៅដូចនៅសម័យមុនលោក**អដាំ**ប្រព្រឹត្តអំពើបាប ។ អស់លោកចាប់ផ្តើមប្រៀបផ្ទឹមជីវិតអ្នកបួសដូចជាគេរៀបអាពាហ៍ពិពាហ៍ជាមួយព្រះគ្រីស្ត ។ ពេលជាមួយគ្នានោះ ក៏មានរបៀបបួសក្លែងក្លាយកើតឡើងដែរ គឺអ្នករស់នៅជាព្រហ្មចារីខ្លះអួតខ្លួន ក្រអឺតក្រអោង ដោយខ្លួនបានជ្រើសរើសការរស់នៅជាព្រហ្មចារីនោះ ។ មាននាងខ្លះទៀតរស់នៅជាមួយបុរសដែលសម្រេចចិត្តនឹងរស់នៅជាព្រហ្មចារីដូចគ្នា ហាក់បីដូចជាគេរៀបអាពាហ៍ពិពាហ៍តាមព្រះវិញ្ញាណ ។ គ្រីស្តបរិស័ទខ្លះទៀតលើកតម្កើងព្រហ្មចារិយធម៌ខ្លាំងហួស បែរជាទៅមើលងាយការរស់នៅជាគូស្វាមីភរិយា រហូតដល់ហាមឃាត់គ្រីស្តបរិស័ទរៀបអាពាហ៍ពិពាហ៍ទៀតផង ។

## ២- បព្វជិតដំបូងនៅបូព៌ាប្រទេស

ចាប់ពី គ.ស. ៣១៣ កាលព្រះចៅ**កុងស្តង់តាំង**ប្រោសប្រទានសុខសន្តិភាពឲ្យព្រះសហគមន៍ គ្រីស្តបរិស័ទលែងធ្វើជាមរណសាក្សីទៀតបាន ។ អ្នកដែលសូមទៅជាគ្រីស្តបរិស័ទ ក៏មិនប្រថុយជីវិតទៀតដែរ ហើយគ្រីស្តបរិស័ទភាគច្រើនមិនសូវកាន់តាមជំនឿយ៉ាងពិតប្រាកដទេ ។ តែមានគ្រីស្តបរិស័ទខ្លះមានបំណងចង់

Layout Histor.qxd 2/10/07 10:09 AM Page 87

រស់នៅជាគ្រីស្តបរិស័ទ ដែលគោរពប្រណិប័តន៍ព្រះគ្រីស្តដោយមិនជាប់ជំពាក់នឹងកង្វល់លោកិយ ។ គ្រីស្តបរិស័ទទាំងនោះចេញទៅរស់នៅក្នុងវាលរហោស្ថាន ។

46 លោក**អន់ទន** (Antoine នៅគ.ស. ២៥១-៣៥៦) ។ លោក**អាថាណាស្ស** (Athanase) ជាអភិបាលព្រះសហគមន៍ក្រុងអាឡិចសង់ឌ្រី រៀបរាប់ជីវប្រវត្តិរបស់លោកអន់ទនដូចជារឿងប្រលោមលោកមួយ ។ លោកអន់ទនរស់នៅក្នុងវាលរហោស្ថានស្រុកអេស៊ីបមុនគេបង្អស់ ។ មានគ្រីស្តបរិស័ទជាច្រើនលើកលោកធ្វើជាគំរូ ហើយនាំគ្នាខិតខំប្រព្រឹត្តតាម ។

លោក**ប៉ាកូម** (Pacôme គ.ស. ២៨៦-៣៤៦) បង្កើតក្រុមបព្វជិតរស់នៅជាមួយគ្នា ឯនាង**ម៉ារី** ជាប្អូនស្រីរបស់លោក ក៏បង្កើតសហគមន៍បព្វជិតាដែរ ។

គ្រីស្តបរិស័ទនៅពាសពេញស្រុកអេស៊ីប ស្រុកប៉ាលេស្ទីន ស្រុកស៊ីរី និងនៅតំបន់មេសូប៉ូតាមី ចូលចិត្តរបៀបរស់នៅបែបនោះ ហើយចូលជាបព្វជិតបព្វជិតាជាច្រើន ។ សម័យនោះ សហគមន៍បព្វជិតមិនមានរចនាសម្ពន្ធច្បាស់លាស់ទេ ។ គ្រីស្តបរិស័ទដែលចង់ទៅជាបព្វជិត ត្រូវស្ថិតនៅក្រោមការណែនាំខាងផ្លូវវិញ្ញាណពីម្នាក់ដែលហៅថា «*លោកឪពុក*» រហូតដល់គេអាចរស់នៅជាបព្វជិតដោយខ្លួនគេបាន ។ ឥសីបេះតែធ្វើទុក្ករកិរិយាដោយប្រកួតប្រណាំងគ្នា ។ ឧបមា. មានឥសីខ្លះរស់នៅលើដើមឈើ ឥសីខ្លះរស់នៅក្នុងរូងថ្មដ៏តូច ឥសីខ្លះស៊ីស្មៅដូចសត្វគោ ឥសីខ្លះរស់នៅលើសសរមួយ ឥសីខ្លះរស់នៅខ្លួនទទេ គ្មានស្លៀកពាក់សោះ ។ល ។ តាមពិតការរស់នៅជាបព្វជិត ជារបៀបកាន់គ្រីស្តសាសនាតាមរបៀបប្រជាប្រិយ គឺសង្កត់ទៅលើការប្រឆាំងនឹងមារ ខ្មោច អារក្ខ អ្នកតា ទេវតាព្រៃភ្នំ ដែលគេស្មានថា មាននៅគ្រប់ទីកន្លែង ។ បព្វជិតទាំងនោះមានបំណងឲ្យមនុស្សលោករស់នៅ ដូចនៅសម័យមុនលោក**អដាំ**ធ្វើអំពើបាប គឺគេចង់បង្ក្រាបសត្វសាហាវ ។ ទោះបីបព្វជិតតែងតែអធិដ្ឋាន ធ្វើសមាធិក្តី ក៏អស់លោកយកចិត្តទុកដាក់ទទួលភ្ញៀវដែរ ។ បព្វជិតខ្លះមិនព្រមសិក្សាទាល់តែសោះ បណ្តាលឲ្យពួកគេតប់ប្រមល់នឹងតណ្ហា បណ្តាលឲ្យគេវង្វេងជំនឿក៏មានដែរ ។

លោក**បាស៊ីល** (Basile) ជាអភិបាលព្រះសហគមន៍ក្រុងសេសារេ (គ.ស. ៣៣០-៣៧៩) លោកតែងតែប្រឆាំងនឹងបព្វជិតដែលប្រព្រឹត្តតាមរបៀបនេះ ។ លោកនិពន្ធ «*ក្បួនវិន័យសម្រាប់បព្វជិត*» ។ ក្នុងក្បួនតម្រានេះ លោកសូមឲ្យបព្វជិតរស់នៅរួមគ្នាជាសហគមន៍ លោកទូន្មានអស់លោកឲ្យយកចិត្តទុកដាក់សិក្សា រិះគិត និងចាប់អារម្មណ៍អ្នកក្រីក្រ ។ បព្វជិតត្រូវយកព្រះសហគមន៍ក្រុងយេរូសាឡឹមដើមដំបូងធ្វើជាគំរូ ។ បព្វជិតត្រូវស្តាប់តាមបង្គាប់លោកឪពុកជាប្រធានវត្តអារាម ព្រោះលោកមានភារកិច្ចបកស្រាយអត្ថន័យគម្ពីរដំណឹងល្អដែលជាក្បួនវិន័យដ៏ប្រសើរជាងគេ ឲ្យអស់លោកអនុវត្តតាមជារៀងរាល់ថ្ងៃ ។ គ្រីស្តបរិស័ទជាតិក្រិកជាច្រើន ដែលចែងអំពីទេវវិជ្ជានៃការរស់នៅជាបព្វជិតតែងតែសំអាងលើទ្រឹស្តីមនុស្សវិជ្ជារបស់លោក**ប្លាតុង** (Platon) ដែលតែងមើលងាយបន្ថោកតម្លៃរូបកាយមនុស្ស ។ ហេតុដូចនេះហើយ បានជាគ្រីស្តបរិស័ទយល់ឃើញថា វត្តអារាមជាគំរូសម្រាប់សង្គមមនុស្ស ជំនួសសង្គមមនុស្សធម្មតា ។

*បពិតព្រះអម្ចាស់!*
*សូមព្រះអង្គរំដោះកូនឲ្យបានរួចពីអាត្មា*
*សូមព្រះអង្គយាងមកស្ថិតនៅក្នុងខ្លួនខ្ញុំជំនួសអាត្មានោះ ។*
*សូមឲ្យខ្ញុំស្លាប់នៅទីនេះ ដើម្បីរស់នៅជាមួយព្រះអង្គនៅទីនោះ*
*សូមប្រោសឲ្យខ្ញុំស្រឡាញ់ព្រះអង្គ សូមឲ្យខ្ញុំស្រឡាញ់តែព្រះអង្គគត់ (...)*
*តើព្រះអង្គគង់នៅឯណា?*
*ឱព្រះអង្គជាទីបណ្តូលចិត្តខ្ញុំ ខ្ញុំស្រឡាញ់ព្រះអង្គខ្លាំងណាស់ ខ្ញុំចង់ឃើញព្រះអង្គ (...)*
*ខ្ញុំអង្វរព្រះអង្គ សូមរស់នៅក្នុងសួនឧទ្យាននៃសេចក្តីស្រឡាញ់របស់ព្រះអង្គ*
*នៅទីនោះអ្វីៗមិនប្រែប្រួល គឺស្ថិតនៅជានិច្ច ។*

*លោកសង្ឃកាតូលិកជាតិទួរគី (១២៣៩)*

46

# លោកអន់ទនជាបិតារបស់តាបសឥសី

(..) ថ្ងៃនោះ លោក**អន់ទន**ទៅព្រះវិហារតាមទម្លាប់ ។ លោកដើរបណ្ដើរ នឹកសញ្ជឹងគិតអធិដ្ឋានបណ្ដើរ អំពីសាវ័កសុខចិត្តលះបង់អ្វីៗទាំងអស់ដើម្បីទៅតាមព្រះគ្រីស្ដ ។ លោកក៏នឹកសញ្ជឹងគិតអំពីអ្នកជឿ ដែលបានលក់អ្វីៗដែលគេមានប្រគល់ប្រាក់ឲ្យក្រុមគ្រីស្ដទូត ដើម្បីឲ្យអ្នកក្រីក្រប្រើប្រាស់តាមសេចក្ដីត្រូវការ ។ ពួកគេសង្ឃឹមយ៉ាងខ្លាំងថា នឹងបានចូលស្ថានបរមសុខ ។ លោកចូលក្នុងព្រះវិហារ ទាំងនឹកគិតអំពីសេចក្ដីទាំងនោះ ។ ស្រាប់តែនៅពេលគេថ្លែងគម្ពីរដំណឹងល្អ លោកឮព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់អ្នកមានថា «បើអ្នកចង់ទៅជាមនុស្សពេញលក្ខណៈ ចូរលក់អ្វីៗដែលអ្នកមានហើយយកប្រាក់ចែកឲ្យជនក្រីក្រ រួចសឹមអញ្ជើញមកតាមខ្ញុំចុះ អ្នកនឹងបានសម្បត្តិសួគ៌» ។ លោកអន់ទន ទទួលសេចក្ដីដែលជនដ៏វិសុទ្ធនឹកចាំនោះ ហាក់ដូចគេថ្លែងព្រះបន្ទូលសម្រាប់ខ្លួនលោកផ្ទាល់ ។ រួចលោកក៏ចេញពីព្រះវិហារយ៉ាងរហ័ស ។ លោកចែកទ្រព្យសម្បត្តិដែលលោកបានទទួលទុកជាកេរមត៌កពីឪពុកម្ដាយ គឺដីធ្លីមានជីជាតិល្អ ៣០០ អារ ជូនអ្នកនៅក្នុងភូមិ ដើម្បីកុំឲ្យលោកនិងប្អូនស្រីលោកជួបឧបសគ្គដោយសារដីនោះ ។ លោកក៏លក់គ្រឿងសង្ហារឹមទាំងអស់ យកប្រាក់ចែកជនក្រីក្រ លោកទុកតែមួយចំណែកតូចសម្រាប់ប្អូនស្រីប៉ុណ្ណោះ ។

លោកអន់ទន ទៅរស់នៅម្នាក់ឯងដាច់ឆ្ងាយពីគេ ហើយធ្វើទុក្ករកិរិយាកាន់តែតឹងរ៉ឹងឡើងៗ តែលោកមានជ័យជម្នះលើមារដែលវាយសម្រុក (..) ។

ប៉ុន្តែ មារជាសត្រូវទាស់នឹងអំពើល្អ មានចិត្តប្រណែនឈ្នានីស មិនអាចទ្រាំនឹងបុរសដ៏ក្មេងម្នាក់បែបនេះ ដែលមានបំណងដូច្នេះ (...) ។ មុនដំបូង វាល្បួងលឲ្យលោកអន់ទនលះបង់តបៈធម៌ ដោយនាំឲ្យលោកនឹកគិតដល់ទ្រព្យសម្បត្តិប្អូនស្រី បងប្អូនក្នុងក្រុមគ្រួសារ ការស្រឡាញ់ប្រាក់ ចង់បានកិត្តិយស នឹកដល់ម្ហូបអាហារដ៏ឆ្ងាញ់ ការសប្បាយផ្សេងៗក្នុងការរស់នៅ ហើយនៅទីបំផុត នឹកដល់ការលំបាកប្រព្រឹត្តតាមព្រហ្មវិហារធម៌ និងការនឿយហត់ពេលធ្វើទុក្ករកិរិយានេះ (..) ។ នៅពេលយប់ មារចង្រៃដ៏ថោកទាបនោះយករូបជាស្ត្រីម្នាក់មក ធ្វើកាយវិការប្រលោមចិត្តលោកអន់ទន ។ តែលោកដាក់ព្រះគ្រីស្ដនៅក្នុងចិត្ត ដោយនឹកសញ្ជឹងគិតអធិដ្ឋាន អំពីកិត្តិយសមកពីព្រះអង្គ អំពីតម្លៃនៃវិញ្ញាណ ហើយពន្លត់ភ្លើងរបស់មារដែលចង់បញ្ឆោតលោក (...) ។ យប់មួយ មារបន្លឺស្នូរអឺងកងរំពងយ៉ាងខ្លាំង ធ្វើឲ្យបន្ទប់នោះរង្គើ ។ ជញ្ជាំងផ្ទះដ៏តូចនោះដូចបាក់បែក ស្រាប់តែពួកមារលុកចូលមកដោយក្លាយខ្លួនជាសត្វនានា ។ កន្លែងនោះ ពោរពេញទៅដោយខ្មោច តោខ្លាឃ្មុំ គោបា ពស់វែក ខ្យារដំរី និងឆ្កែចចក ។ សត្វនីមួយៗប្រព្រឹត្តតាមធម្មជាតិរបស់វា គឺសឹង្ហគ្រហឹមចង់ស៊ីសាច់លោក គោបាចង់ជល់លោក ពស់លូនវារមកជិតតែមិនចឹក ឆ្កែចចកស្ទុះឡើងចង់ខាំលោក ។ សត្វទាំងនោះបន្លឺសំឡេងគួរឲ្យភ័យតក់ស្លុត និងបង្ហាញមុខដ៏កាចសាហាវ (...) ។

លោកអន់ទន រស់នៅដាច់ពីគេដូច្នេះ ទាំងធ្វើតបធម៌យ៉ាងតឹងរ៉ឹងជិតម្ភៃឆ្នាំ លោកមិនចេញទៅក្រៅ មិនបង្ហាញខ្លួនឲ្យនរណាឃើញឡើយ ។ នៅទីបញ្ចប់ មានមនុស្សជាច្រើនចង់គ្រាប់តាមតបធម៌របស់លោក ។ មិត្តសម្លាញ់របស់លោកបុកទម្លាយទ្វារផ្ទះលោក ។ លោកអន់ទនចេញមក ហាក់ដូចជាបានស្គាល់គម្រោងការដ៏អស្ចារ្យ ហាក់ដូចជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បំភ្លឺ ។ ពេលនោះ អស់អ្នកដែលមកបានឃើញលោកស្ញើចសរសើរ គឺលោកមានរាងកាយដដែល មិនជាត់ដោយមិនធ្វើចលនា មិនស្គមដោយបានតមអាហារ និងបានប្រឆាំងនឹងពួកមារឡើយ គឺលោកនៅដដែល ដូចគេធ្លាប់ស្គាល់លោកមុនលោកចូលធ្វើសមាធិ ។ ស្មារតីនៅរឹងមាំ មិនចង្អៀតចិត្តដោយទុក្ខព្រួយ ហើយក៏មិនធូរដោយការសប្បាយឡើយ ។ លោកមិនសើច ហើយក៏គ្មានមុខព្រួយដែរ ។ ពេលលោកឃើញបណ្ដាជនជាច្រើនសំពះលោក លោកមានចិត្តនឹងនរ លោកគ្មានអំណរសប្បាយហួសហេតុឡើយ លោកនៅតែនឹងធឹងដដែលដូចធម្មតាដោយលោកមានប្រាជ្ញាណែនាំ ។ ដោយសារលោក ព្រះអម្ចាស់ប្រោសមនុស្សជាច្រើនដែលឈឺក្នុងខ្លួន ព្រះអង្គក៏ជម្រះមនុស្សផ្សេងៗទៀតឲ្យរួចពីពួកមារ ។ ព្រះជាម្ចាស់ប្រណីសន្ដោសដល់លោកអន់ទន មានទេពកោសល្យអាចសម្រាលទុក្ខមនុស្ស ដែលមានទុក្ខព្រួយ អាចសម្រុះសម្រួលមនុស្សដែលទាស់ទែងគ្នា ។ លោកតែងប្រាប់គេថា កុំបាត់ទុកអ្វីៗក្នុងលោកនេះប្រសើរជាងព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្ដ ។ លោកក៏ដាស់តឿនក្រើនរំលឹកគ្រីស្ដបរិស័ទ ឲ្យនឹកដល់សម្បត្តិសួគ៌ដែលគេនឹងទទួលពេលអនាគត នឹកដល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះគេ ព្រះអង្គមិនរួញរានឹងបាត់ព្រះបុត្រារបស់ព្រះអង្គផ្ទាល់បញ្ជូនឲ្យគេធ្វើគុតសម្រាប់យើង ។ លោកបានបញ្ចុះបញ្ចូលមនុស្សជាច្រើន ឲ្យរស់នៅម្នាក់ឯងដូចលោក ។ ហេតុនេះហើយបានជាគេសាងសង់វត្តអារាមជាច្រើននៅលើភ្នំ ហើយមានបព្វជិតជាច្រើនរស់នៅតាមវាលរហោស្ថាន គឺសុទ្ធតែមនុស្សដែលលះបង់សម្បត្តិទ្រព្យទាំងអស់ និងចុះឈ្មោះក្នុងក្រុងនៃស្ថានបរមសុខរួចហើយ ។

"ជីវិតនិងកិរិយារបស់សន្ដអន់ទនជាឪពុករបស់យើង"

(ប្រហែលលោក អាថាណាស្ស និពន្ធ)

Layout Histor.qxd 2/10/07 10:09 AM Page 89

## ៣- ការរស់នៅជាបព្វជិតនៅបស្ចិមប្រទេស

ស្ត្រីព្រហ្មចារិនី និងឥសីជាច្រើនដែលថ្វាយខ្លួនទៅព្រះជាម្ចាស់ ក៏រស់នៅជាមួយក្រុមគ្រួសាររបស់គេដូចនៅសម័យមុនៗដែរ ។ អ្នកដំណើរមកពីបូព៌ាប្រទេស មានលោក**អាថាណាស្ស** លោក**យេរ៉ូម** (Jérôme គ.ស ៣៤៧-៤១៩) ជាដើម តែងឃោសនាអំពីការរស់នៅជាបព្វជិត ។ ដោយមានចំនួនព្រហ្មចារិនីជាច្រើននៅបស្ចិម ហើយដោយបព្វជិតខ្លះប្រព្រឹត្តផ្តេសផ្តាសហួសហេតុ បានជាគេយកការរស់ជាបព្វជិតនាបូព៌ាប្រទេសធ្វើជាគំរូ ។ យូរៗទៅ គេបាត់ចែងរចនាសម្ពន្ធសម្រាប់ណែនាំការរស់នៅអ្នកដែលថ្វាយខ្លួនទៅព្រះជាម្ចាស់ ។ ប្រហែលនៅ គ.ស.៣៥០ ស្ត្រីៗត្រកូលខ្ពស់ៗនៅក្រុងរ៉ូម តែងតាំងក្រុមស្ត្រីៗជាច្រើន ហើយបង្កើតពិធីញែកស្រីៗព្រហ្មចារិនីថ្វាយព្រះជាម្ចាស់ និងឲ្យនាងពាក់ស្បៃលើក្បាល គេក៏ចាត់ចែងពិធីនោះ ដោយនឹកគិតអំពីអាពាហ៍ពិពាហ៍ជានិមិត្តរូប អំពីការញែកខ្លួនថ្វាយទៅព្រះគ្រីស្តជាស្វាមី ។ លោក**អាំប្រូស៍**លើកយកនាងព្រហ្មចារិនី**ម៉ារី**ធ្វើជាគំរូសម្រាប់ឲ្យស្ត្រីព្រហ្មចារីទាំងនោះប្រព្រឹត្តតាម ។

លោកយេរ៉ូម ជាបព្វជិតនៅបូព៌ាប្រទេស លោកឃោសនាអំពីការរស់នៅជាបព្វជិតក្នុងចំណោមស្ត្រីអភិជនក្រុងរ៉ូម ។ លោកតែងតែគូសសង្កត់យ៉ាងធ្ងន់អំពីតម្លៃនៃការរស់នៅជាព្រហ្មចារី ដែលលោកយល់ឃើញថា ប្រសើរជាងការរស់នៅដោយមានគ្រួសារ ។ ក្រោយពេលលោកត្រឡប់ទៅស្រុកប៉ាលេស្ទីនវិញ លោករួមជាមួយសម្លាញ់ស្រីលោកម្នាក់ឈ្មោះ**ប៉ូឡា** បង្កើតសហគមន៍ស្ត្រីជាច្រើនក្រុមនៅក្រុងបេថ្លេហិម ចាត់ចែងតាមឋានៈក្នុងសង្គម ។ លោកបង្កើតសហគមន៍បុរសនៅកន្លែងលោករស់នៅ ។ លោកធ្វើឲ្យបព្វជិតស្រឡាញ់ព្រះគម្ពីរ គឺបព្វជិតខិតខំស្វែងរកអត្ថន័យគម្ពីរ ជាអាហារខាងវិញ្ញាណ ។ លោកជាបុព្វបុរសរបស់បព្វជិតដែលយកចិត្តទុកដាក់បម្រើវប្បធម៌គ្រីស្តបរិស័ទ និងវប្បធម៌ទូទៅ នៅក្រោយពេលអរិយធម៌រ៉ូម៉ាំងអន់ថយ ។

លោក**អូគូស្តាំង** (Augustin គ.ស ៣៥៤-៤៣០) ក្រោយពេលលោកប្រែចិត្តជឿលើព្រះគ្រីស្ត លោកមានបំណងចង់រស់នៅជាបព្វជិត តែលោកទទួលមុខងារជាអភិបាលព្រះសហគមន៍ក្រុងហ៊ីប៉ូន (Hippone) ខាងជើងទ្វីបអាហ្វ្រិក ។ លោកចង់ឲ្យក្រុមបូជាចារ្យរបស់លោករស់នៅតាមគោលការណ៍សំខាន់ៗរបស់បព្វជិត ។ នេះជាគោលជំហរថ្មីក្នុងព្រះសហគមន៍ គឺលោកតែងជ្រើសរើសបូជាចារ្យនៅក្នុងចំណោមបព្វជិត ហើយក៏សូមឲ្យបូជាចារ្យបួសតទៅទៀត ។ នៅក្នុង «*ក្បួនវិន័យរបស់សន្តអូគូស្តាំង*» មានចែងពាក្យទូន្មានទូទៅសម្រាប់បព្វជិត ។

លោក**យ៉ូហាន កាស៊ីយ៉ាំង** (Jean Cassien គ.ស ៣៦០-៤៣៥) ។ លោកមានដើមកំណើតនៅរូម៉ានី ។ លោកទៅសួរសុខទុក្ខបព្វជិតនៅបូព៌ាប្រទេស រួចលោកបង្កើតវត្តអារាមពីរនៅទីក្រុងម៉ារសៃល (Marseille ប្រទេសបារាំង) មួយសម្រាប់បុរស និងមួយទៀតសម្រាប់ស្ត្រីៗ ។ លោកនិពន្ធសៀវភៅអំពីបព្វជិត គឺលោកធ្វើឲ្យបព្វជិតនៅបូព៌ា និងបព្វជិតនៅបស្ចិមប្រទេសទាក់ទងគ្នា ។ លោកចាត់ទុកការបេះលាក់ការណ៍ ជាគុណធម៌ដ៏សំខាន់របស់បព្វជិត ។



*ចម្លាក់លើថ្មដោយប្រើអក្សរកាត់មានន័យថា៖*
*ព្រះគ្រីស្តគង់នៅតាំងពីដើម សព្វថ្ងៃ និងរហូតអស់កល្បជានិច្ច*

Layout Histor.qxd 2/10/07 10:09 AM Page 90

## ៨- ក្បួនវិន័យរបស់សន្តបេណេឌិកតូ

លោក**ប៉ាទ្រិក** (Patrik) លោក**កូឡុមបា** (Colomba) លោក**កូឡុមបង់** (Colomban) ជាជនជាតិអៀរឡង់ដ៍ (Irlande) បង្កើតក្រុមបព្វជិតដែលមិនសូវមានរបៀបរៀបរយ ដូចបព្វជិតដំបូងខាងបូព៌ាប្រទេស (សតវត្សទី ៥-៦) ។

ផ្ទុយទៅវិញ លោក**បេណេឌិកតូ** (Benoît ប្រ.គ.ស ៤៨០-៥៤៧) បង្កើត
47 *«ក្បួនវិន័យ»* ណែនាំអារាមបព្វជិតខាងបស្ចិមប្រទេសស្ទើរតែទាំងអស់ រហូតដល់
48 សតវត្សទី ១២ ។ *«ក្បួនវិន័យ»* នេះ គឺសរុបទំនៀមទម្លាប់របស់បព្វជិត តាំងពី
អតីតកាលរហូតមក ។ ក្នុងក្បួនវិន័យនោះលោកគូសសង្កត់ថា បព្វជិតត្រូវតែសន្យាថា នឹងស្ថិតនៅជាប់ក្នុងវត្តអារាមរបស់ខ្លួន ។ *«លោកឪពុក»* គឺបព្វជិតមេវត្ត ត្រូវបំពេញមុខងារដ៏សំខាន់ គឺជួយដល់បព្វជិតទាំងអស់ឲ្យរួមរស់ជាមួយគ្នា ។ លោកទទួលមុខងារពីរ គឺលោកអប់រំជំនឿបព្វជិតនៅក្នុងអារាមផង និងណែនាំសហគមន៍បព្វជិតផង ។ បព្វជិតទាំងអស់បោះឆ្នោតជ្រើសតែងតាំងលោក លោកក៏កាន់មុខងាររហូតទទួលមរណភាព ។ បព្វជិតត្រូវតែស្ដាប់បង្គាប់លោកក្នុងគ្រប់កិច្ចការទាំងអស់ ។ ដោយបព្វជិតស្ដាប់តាមបង្គាប់លោកដូច្នេះ បព្វជិតមានទម្លាប់ដាក់ខ្លួន ។ ការដាក់ខ្លួនដូច្នេះ ជាមាគ៌ានាំឲ្យបព្វជិតចម្រើនឡើងខាងវិញ្ញាណ ។ បព្វជិតដែលស្ថិតនៅជាប់នឹងវត្តអារាមធ្លាប់ស្ដាប់តាមបង្គាប់ និងដាក់ខ្លួនដូច្នេះ ពិតជាធ្វើតបៈធម៌ក្នុងចិត្ត ។

លោកបេណេឌិកតូបង្កើតវិន័យសម្រាប់បព្វជិតដែលរស់នៅក្នុងប្រទេសដែលមានអាកាសធាតុមិនក្ដៅពេក មិនត្រជាក់ពេក ។ ដូច្នេះ លោកមិនព្រមធ្វើតាមរបៀបហួសហេតុដូចនៅបូព៌ាប្រទេសទេ ។ ក្រុមបព្វជិតរស់នៅជាជនក្រីក្រ ប៉ុន្តែ មិនសូវតឹងតែងអំពីពេលសម្រាក ស្លៀកពាក់ ម្ហូបអាហារ និងការអធិដ្ឋានទេ ។ ជារៀងរាល់ថ្ងៃ បព្វជិតអធិដ្ឋាន ធ្វើពិធីបុណ្យ អានគម្ពីរ ស្មឹងស្មាធ និងធ្វើការដោយផ្ទាល់ដៃ ហើយសម្រាកកាយ ។ ការសិក្សាព្រះគម្ពីរជាការសំខាន់ ។

ក្បួនវិន័យរបស់សន្តបេណេឌិកតូ មានឥទ្ធិពលយ៉ាងខ្លាំងអស្ចារ្យ ព្រោះក្បួនវិន័យនេះ ចែងនូវគោលជំហរដ៏រឹងមាំ យ៉ាងជាក់ច្បាស់ សម្រាប់បព្វជិតអាចរួមរស់ក្នុងវត្តអារាមបាន ក្បួនវិន័យនេះមិនតឹងពេកទេ ។ វត្តអារាមបេណេឌិកតូជួយប្រជាជនទ្វីបអឺរ៉ុបឲ្យចម្រើនឡើងវិញ ក្រោយពេលចក្រភពរ៉ូម៉ាំងនៅបស្ចិមប្រទេសដួលរលំ ។ *(សូមអានជំពូក ៧)*

47

### ក្បួនវិន័យរបស់សន្តបេណេឌិកតូ

***បុរេកថា***

*ម្នាលកូនអើយ! សូមស្ដាប់ពាក្យទូន្មានរបស់គ្រូដោយយកចិត្តទុកដាក់យ៉ាងស្មោះ ។ ចូរសុខចិត្តទទួលការអប់រំរបស់ឪពុកដ៏ល្អប្រសើរនោះ ហើយអនុវត្តតាម ។ បើកូនស្ដាប់តាមនោះ កូនមុខជានឹងបែរទៅរកព្រះគ្រីស្ដដែលកូនឃ្លាតឆ្ងាយ ដោយខ្វះសេចក្ដីក្លាហាន និងដោយមិនស្ដាប់បង្គាប់នោះ ។ ហេតុនេះខ្ញុំនិយាយទៅកូន កូនជានរណាក៏ដោយ គឺជាមនុស្សដែលបោះបង់ចិត្តប៉ងប្រាថ្នារបស់ខ្លួន និងយកកម្លាំងដោយអាវុធមកពីធ្វើតាមបង្គាប់គេ ដើម្បីប្រយុទ្ធនៅក្រោមទង់របស់ព្រះអម្ចាស់យេស៊ូគ្រីស្ដ ជាព្រះមហាក្សត្រដ៏ពិតប្រាកដរបស់យើង (...) ។*

*យើងចង់បង្កើតសាលាមួយជាកន្លែងបម្រើព្រះអម្ចាស់ ។ ក្នុងសាលានោះ យើងសង្ឃឹមថាមិនតែងតាំងអ្វីដ៏តឹងរឹងធ្ងន់ធ្ងរទេ ក៏ប៉ុន្តែ ប្រសិនបើមានអ្វីដ៏តឹងរឹងនិងធ្ងន់ធ្ងរ យើងបាត់បែងដោយយុត្តិធម៌ ដើម្បីកែលំអការអាក្រក់របស់ខ្លួន និងថែរក្សាសេចក្ដីស្រឡាញ់ ។ សូមប្រយ័ត្នកុំបាកចេញពីមាគ៌ានៃការសង្គ្រោះដោយខ្លាចភ្លាមៗនោះ ព្រោះពេលចាប់ផ្ដើមតែងតែលំបាកជានិច្ច ។ ពេលយើងចម្រើនឡើងតាមការរស់នៅជាបព្វជិត និងក្នុងជំនឿបន្តិចម្ដងៗ យើងតែងសប្បាយចិត្តរត់តាមមាគ៌ា កាន់តាមវិន័យរបស់ព្រះជាម្ចាស់ ចិត្តពោរពេញដោយសេចក្ដីស្រឡាញ់*

•••

Layout Histor.qxd 2/10/07 10:09 AM Page 91

ដែលរកថ្លៃងមិនបាន ។ ហេតុនេះហើយ ខ្ញុំសូមកុំឃ្លាតឆ្ងាយពីការអប់រំរបស់លោក ចូរព្យាយាមអនុវត្តតាមសេចក្តីប្រៀនប្រដៅនេះក្នុងវត្តអារាម រហូតដល់ពេលទទួលមរណភាព ។ យើងត្រូវរួមរងទុក្ខលំបាកជាមួយព្រះគ្រីស្ត ដើម្បីឲ្យមានកន្លែងក្នុងព្រះរាជ្យរបស់ព្រះអង្គផង ។

**សេចក្តីបញ្ចប់**

ក្បួនវិន័យដែលខ្ញុំទើបតែសរសេរនេះ ត្រូវតែអនុវត្តតាមវត្តនានា ដើម្បីបញ្ជាក់ថា កូនមានចិត្តទៀងត្រង់ខ្លះៗ និងចាប់ផ្តើមរស់នៅជាបព្វជិត ។ រីឯអ្នកដែលប្រាថ្នាចង់បានជីវិតដ៏ពេញលក្ខណៈ ត្រូវអនុវត្តតាមការប្រៀនប្រដៅរបស់បុព្វបុរសដ៏វិសុទ្ធ ។ អ្នកអនុវត្តតាម មុខជានឹងទៅដល់កំពូលនៃសេចក្តីដ៏ពេញលក្ខណៈល្អឥតខ្ចោះ ។ នៅក្នុងព្រះគម្ពីរ ទាំងសម្ពន្ធមេត្រីចាស់ ទាំងសម្ពន្ធមេត្រីថ្មី គ្រប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតជាវិន័យដ៏ភ្លឺថ្លា អាចណែនាំការរស់នៅរបស់យើងបាន ឬម្យ៉ាងទៀត សៀវភៅទាំងប៉ុន្មានដែលបុព្វបុរសកាតូលិកដ៏វិសុទ្ធតែងតែបង្រៀនមាគ៌ាដ៏ទៀងត្រង់ ទៅកាន់ព្រះអាទិកររបស់យើង ។ យ៉ាងណាមិញ «ការសន្ទនារបស់បុព្វបុរស» «ការបាត់បែង» និង «ការរស់នៅរបស់អស់លោក» (សៀវភៅ ៣ លោក**កាស៊ីយ៉ាំង**និពន្ធ) ព្រមទាំងក្បួនវិន័យរបស់សន្ត**បាស៊ីល**ជាបិតាដ៏វិសុទ្ធរបស់យើង សុទ្ធតែជាឧបករណ៍សម្រាប់ឲ្យបព្វជិតដ៏ល្អប្រសើរ អាចចម្រើនឡើងបានយ៉ាងពិតប្រាកដ និងអាចស្តាប់តាមបង្គាប់បាន ។

កូនជានរណាក៏ដោយ ដែលប្រញាប់ទៅរកមាតុភូមិនៃស្ថានបរមសុខ ចូរអនុវត្តតាមក្បួនវិន័យដ៏តូចនេះដោយព្រះគ្រីស្តជួយណែនាំដែរ ខ្ញុំសរសេរក្បួនវិន័យដ៏តូចនេះសម្រាប់បព្វជិតថ្មី ។ បើកូនធ្វើដូច្នេះ កូនមុខជានឹងបានទៅដល់កំពូលដ៏ខ្ពង់ខ្ពស់នៃគោលលទ្ធិ និងនៃព្រហ្មវិហារធម៌ដូចយើងទើបតែបានរំឭកដោយព្រះជាម្ចាស់ថែរក្សា ។

## 48 មេវត្តតាមក្បួនវិន័យរបស់សន្តបេណេឌិកតូ

យើងយល់ឃើញយ៉ាងជាក់ច្បាស់ថា មានបព្វជិត ៤ ប្រភេទ ។ ប្រភេទទី ១ គឺបព្វជិតរស់នៅជាមួយគ្នាក្នុងវត្តអារាម តយុទ្ធប្រឆាំងនឹងមារដោយកាន់ក្បួនវិន័យមួយ និងដោយធ្វើតាមបង្គាប់មេវត្តម្នាក់ (..) (ជំពូកទី ១) ។

មេវត្តហៅថា «លោកឪពុក» ត្រូវបព្វជិតយល់ឃើញថា មានសុភវិនិច្ឆ័យ អាចគ្រប់គ្រងអារាមបាន ។ លោកត្រូវនឹកជានិច្ចពីឈ្មោះរបស់ខ្លួន និងប្រព្រឹត្តតាមមុខងារជាមេគ្រួសារ ដ្បិតគេតែងតែចាត់ទុកលោកជាតំណាងរបស់ព្រះគ្រីស្តនៅក្នុងវត្តអារាម ។ ហេតុនេះហើយ បានជាលោកទទួលឈ្មោះ «លោកឪពុក» នោះ ជាព្រះនាមផ្ទាល់របស់ព្រះអម្ចាស់ បើតាមពាក្យគ្រីស្តទូត**ប៉ូល**ថា៖ «អ្នករាល់គ្នាបានទទួលព្រះវិញ្ញាណរបស់បុត្រធីតា ដែលបន្លឺសំឡេងក្នុងយើងថា "អប្បា" គឺមានន័យថា "ឪពុក" (...)» ។

អ្នកដែលសុខចិត្តទទួលបន្ទុកជាមេវត្ត ត្រូវតែគ្រប់គ្រងកូនចៅដោយបង្រៀនពួកគេតាមរបៀបពីរយ៉ាង គឺត្រូវបណ្តុះអ្វីដ៏ល្អនិងវិសុទ្ធក្នុងចិត្តគេ ដោយប្រព្រឹត្តកិច្ចការផ្សេងៗជាជាងមានប្រសាសន៍ទៅទៀត ។ លោកនិងបព្វជិតឯទៀតៗដែលមានប្រាជ្ញា ត្រូវបង្រៀនវិន័យរបស់ព្រះអម្ចាស់ដោយប្រើពាក្យសំដី ។ ចំពោះបព្វជិតមានចិត្តរឹងរូសនិងមិនសូវមានប្រាជ្ញាវិញ លោកត្រូវបង្ហាញអត្ថន័យវិន័យទាំងនោះឲ្យគេមើលកិច្ចការដែលលោកធ្វើទុកជាគំរូ ។ លោកក៏បង្រៀនកូនចៅលោកដោយកិច្ចការទាំងនោះ ឲ្យចៀសវាងអ្វីៗដែលលោកប្រាប់ថា ផ្ទុយនឹងក្បួនវិន័យរបស់ព្រះអង្គ (...) (ជំពូកទី ២) ។

ពេលណាត្រូវសម្រេចកិច្ចការមួយដ៏សំខាន់ក្នុងវត្ត លោកឪពុកត្រូវតែកោះហៅសហគមន៍ទាំងមូល និងពន្យល់រៀបរាប់អំពីរឿងនោះដោយលោកផ្ទាល់ ។ ក្រោយពីទទួលយោបល់ពីបងប្អូន លោករិះគិតដោយខ្លួនលោកផ្ទាល់ ហើយប្រព្រឹត្តតាមលោកយល់ឃើញថា មានប្រយោជន៍ច្រើនជាង ។ ហេតុនេះ បានជាយើងនិយាយថា ត្រូវសួរយោបល់បងប្អូនទាំងអស់ ពីព្រោះព្រះជាម្ចាស់តែងតែសម្តែងអ្វីដ៏ប្រសើរជាងគេ ឲ្យបងប្អូនក្មេងជាងគេ (ជំពូកទី ៣) ។

ការស្តាប់បង្គាប់និងធ្វើតាមដោយគ្មានបង្អង់ជាជំហានដំបូង គឺការដាក់ខ្លួន ។ អ្នកដែលស្រឡាញ់ព្រះគ្រីស្តលើសអ្វីៗទាំងអស់ ចូលចិត្តធ្វើតាមបង្គាប់ដូច្នេះ ។ គេមិនអាចបង្អង់ធ្វើអ្វីដែលមេវត្តបង្គាប់នោះទេ គឺហាក់បីដូចជាព្រះជាម្ចាស់បានបញ្ជាដោយផ្ទាល់ព្រះអង្គ ។ បព្វជិតខ្លះប្រព្រឹត្តតាមដោយនឹកដល់ពាក្យសច្ចាបម្រើព្រះអង្គ បព្វជិតខ្លះដោយខ្លាចធ្លាក់ស្ថាននរក និងបព្វជិតខ្លះដោយចង់បានសិរីរុងរឿងអស់កល្បជានិច្ចវិញ (ជំពូកទី ៤) ។

ក្បួនវិន័យសន្តបេណេឌិកតូ

Layout Histor.qxd 2/10/07 10:09 AM Page 92



# កំណើតនៃធម៌ប្រកាសជំនឿ

## (ពីសតវត្សទី ៤-៥)

### មហាសន្និបាតសកលដើមដំបូង

*គ្រីស្តបរិស័ទដើមដំបូង មិនរិះគិតអំពីទស្សនវិជ្ជា ឬទេវវិជ្ជាទេ គេគ្រាន់តែធ្វើសាក្សីថា ព្រះយេស៊ូមានព្រះបន្ទូលប្រាប់គេថា ព្រះជាម្ចាស់តែមួយព្រះអង្គគត់ជាព្រះបិតារបស់ព្រះអង្គ «លោកយេស៊ូនេះដែលបងប្អូនបានឆ្កាង ព្រះជាម្ចាស់បានតែងតាំងលោកឡើងជាព្រះអម្ចាស់ និងជាព្រះគ្រីស្តហើយ» (កក ២,២៤.៣៦) ។ តាមព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ព្រះនាម «ព្រះអម្ចាស់» នេះសំដៅទៅលើព្រះជាម្ចាស់ ។ ហេតុនេះហើយបានជាព្រះជាម្ចាស់ប្រទានព្រះនាមផ្ទាល់របស់ព្រះអង្គ គឺឋានៈផ្ទាល់របស់ព្រះអង្គឲ្យព្រះយេស៊ូជាព្រះបុត្រា (ភល ២,៦-១១) បានសេចក្តីថា ព្រះយេស៊ូជាព្រះគ្រីស្តនិងជាព្រះអម្ចាស់ គង់នៅក្បែរព្រះជាម្ចាស់មុនព្រះអង្គប្រសូតជាមនុស្ស ព្រះអង្គមានព្រះជន្មគង់នៅក្បែរព្រះជាម្ចាស់ ដូចមានចែងអំពីព្រះប្រាជ្ញាញាណក្នុងគម្ពីរសុភាសិត (ជំពូក ៨) ឬក្នុងគម្ពីរព្រះប្រាជ្ញាញាណ (ជំពូក ៨) ។ ព្រះគ្រីស្តក៏ចូលរួមជាមួយព្រះបិតា ក្នុងកិច្ចបង្កើតពិភពលោកដែរ (កឡ ១,១៥ត) ។ ខាងដើមគម្ពីរដំណឹងល្អតាមលោកយ៉ូហានមានចែងថា ព្រះយេស៊ូជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលប្រសូតជាមនុស្ស គឺព្រះបន្ទូលនេះហើយដែលបានបង្កើតពិភពលោក ។ ក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់មានចែងសេចក្តីជាច្រើនអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ទស្សនវិទូជាតិក្រិកក៏តែងតែរិះគិតអំពីព្រះបន្ទូល (Logos) ទុកជាព្រះតម្រិះ ឬជាព្រះប្រាជ្ញាញាណព្រះរបស់គេ ។*

*ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មីមានចែង «ធម៌ប្រកាសជំនឿ» ដើមដំបូង (១ ករ ៨,៦; ១៥,៣-៤) ។ តាមក្បួនពិធីអគ្គសញ្ញាជ្រមុជទឹក និងពិធីអរព្រះគុណ គ្រីស្តបរិស័ទតែងតែប្រកាសជំនឿតាមរបៀបព្រះគម្ពីរដែរ ប៉ុន្តែ គ្រីស្តបរិស័ទខិតខំធ្វើឲ្យមនុស្សរស់នៅជុំវិញគេយល់ជំនឿរបស់គេដែរ ។ ហេតុនេះ គេត្រូវតែពន្យល់ជំនឿដែលលំបាកយល់នោះ ។ ឧប. តើព្រះជាម្ចាស់តែមួយព្រះអង្គគត់ ជាព្រះបិតា និងជាព្រះបុត្រានៅពេលជាមួយគ្នាដូចម្តេចបាន? ហេតុអ្វីបានជាលោកយេស៊ូជាមនុស្សម្នាក់ដែលកើតមក រស់នៅជាមនុស្សធម្មតា ហើយស្លាប់ដូចចោរឧក្រិដ្ឋ អាចជាព្រះជាម្ចាស់បាន បើព្រះជាម្ចាស់មានព្រះជន្មអស់កល្បជានិច្ច មិនប្រែប្រួលទាល់តែសោះ? គ្រីស្តបរិស័ទខិតខំតបឆ្លើយនឹងសំណួរទាំងនេះ ហើយបង្កើត «ទេវវិជ្ជា» បន្តិចម្តងៗ ។ គ្រីស្តបរិស័ទនាំគ្នារិះគិតតាមទិសផ្សេងៗពីគ្នា ហើយក្រោយមក អស់លោកអភិបាលដែលទទួលខុសត្រូវលើព្រះសហគមន៍នានា រួបរួមគ្នាជាមហាសន្និបាត ដើម្បីប្រមែប្រមូលយោបល់ផ្សេងៗពីគ្នាមកបញ្ជាក់គោលលទ្ធិតែមួយ ។*

Layout Histor.qxd 2/10/07 10:09 AM Page 94

*រាល់ថ្ងៃអាទិត្យ យើងជាគ្រីស្តបរិស័ទតែងតែសូត្រ «ធម៌ប្រកាសជំនឿ» នៅក្នុងព្រះវិហារ ជាធម៌ប្រកាសជំនឿនៃមហាសន្និបាតកុងស្តង់ទីណូប្ល ។ កុំស្មានថា អស់លោកអភិបាលនិពន្ធធម៌ប្រកាសជំនឿនេះ ដោយនិយាយសន្ទនាជាមួយគ្នាយ៉ាងស្រួលនោះ គឺអស់លោកខ្វែងគំនិតគ្នាឈ្លោះគ្នា ប្រើហឹង្សា មិនមែនមកពីរឿងសាសនាទេ ។ បុគ្គលនិងបុគ្គលឈ្លោះប្រកែកគ្នា អរិយធម៌ប៉ះទង្គិចគ្នា គ្រីស្តបរិស័ទតាមតំបន់ផ្សេងៗទាស់ទែងគ្នា អភិបាលខ្លះត្រូវព្រះចៅនិរទេសចេញពីស្រុកកំណើត ជួនកាលមានបង្ហូរឈាមទៀតផងដោយកងទ័ពនិងប៉ូលីសធ្វើអន្តរាគមន៍ ។ល ។ ធម៌ប្រកាសជំនឿរបស់យើងកើតតាមរបៀបដូច្នេះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងរាប់ធម៌ប្រកាសជំនឿទុកជាជំនឿដែលមកពីក្រុមគ្រីស្តទូតពិតប្រាកដមែន ។*

# ក_ ព្រះយេស៊ូគ្រីស្ត និង ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់ដូចម្តេចបាន?

## ១- បុព្វហេតុនៃវិបត្តិនៅជំនាន់លោកអារីយ៉ូស

តាំងពីសតវត្សទី ២ មក គ្រីស្តបរិស័ទតែងតែរិះគិតតាមរបៀបផ្សេងៗដើម្បីប្រកាសជំនឿលើព្រះជាម្ចាស់តែមួយព្រះអង្គគត់ផង ព្រមទាំងរក្សាជំនឿលើព្រះត្រៃឯកផង ដូចគេធ្លាប់ប្រកាសនៅពេលទទួលអគ្គសញ្ញាជ្រមុជទឹក ។ គ្រីស្តបរិស័ទខ្លះស្មានថា ព្រះជាម្ចាស់ជាព្រះបិតាផង និងជាព្រះបុត្រាផង ហើយតែងនិយាយថា ព្រះបិតារងទុក្ខលំបាកដូចព្រះបុត្រាដែរ ។ គ្រីស្តបរិស័ទខ្លះទៀតគូសសង្កត់ថា ព្រះបិតានិងព្រះបុត្រាប្លែកពីគ្នា ព្រះបិតានិងព្រះបន្ទូលប្លែកពីគ្នា ព្រះបុត្រាពិតជាព្រះជាម្ចាស់ តាមរបៀបផ្សេងពីព្រះបិតា ។ ព្រះបុត្រាក្នុងឋានៈជាព្រះបន្ទូលស្ថិតក្រោមអំណាចរបស់ព្រះបិតា ។ អ្នកខ្លះយល់ឃើញថា ប្រហែលលោកយេស៊ូជាមនុស្សធម្មតា តែលោកទទួលសភាពជាព្រះជាម្ចាស់ គឺព្រះជាម្ចាស់ទទួលលោកទុកជាបុត្រធម៌ ។ គេបកស្រាយឃ្លាខ្លះៗក្នុងគម្ពីរដូច្នេះ (ឧប. យហ ១៤, ២៨) ។ ម្យ៉ាងទៀតអ្នកនិពន្ធខាងទេវវិជ្ជាជាជនជាតិប្លែកៗគ្នា និងនិយាយភាសាប្លែកពីគ្នា អ្នកខ្លះនិយាយភាសាឡាតាំង អ្នកខ្លះនិយាយភាសាក្រិក គេស្តាប់គ្នាមិនសូវបាន ។

មុន គ.ស. ៣១៣ គឺមុនព្រះចៅ**កុងស្តង់តាំង**ប្រោសព្រះសហគមន៍ឲ្យរស់នៅដោយសុខសន្តិភាព ពេលមានការប្រកែកវែកញែកបែបនេះ គេតែងជជែកវែកញែកតែក្នុងមួយតំបន់ប៉ុណ្ណោះ ។ ក្រោយ គ.ស. ៣១៣ ការប្រកែកវែកញែកបែបនោះផ្សព្វផ្សាយក្នុងចក្រភពទាំងមូល ។ វិបត្តិផ្ទៃក្នុងព្រះសហគមន៍អាឡិចសង់ឌ្រីរាលដាលពាសពេញព្រះសហគមន៍នៅបូព៌ាប្រទេសទាំងមូល ។

លោក**អារីយ៉ូស**ជាបូជាចារ្យម្នាក់នៅព្រះសហគមន៍អាឡិចសង់ឌ្រី ។ គ្រីស្តបរិស័ទស្រឡាញ់លោក ហើយលោកជាអ្នកឧស្សាហ៍ និងកាន់តាមវិន័យយ៉ាងតឹងរ៉ឹងល្អ ។ លោកអរីយ៉ូស មានបំណងលើកតម្កើងឯកសិទ្ធិរបស់ព្រះជាម្ចាស់ជាព្រះ 49
តែមួយអង្គគត់ និងគ្មានដើមកំណើត ។ ប្រសិនបើយើងប្រកាសថា ព្រះអង្គជាព្រះបិតា នោះបានសេចក្តីថា ពេលណាមួយព្រះអង្គបានបង្កើតព្រះបុត្រាមក ។

Layout Histor.qxd 2/10/07 10:09 AM Page 95

ហេតុនេះហើយ ទើបព្រះបុត្រាមានដើមកំណើតជាព្រះបុត្រា គ្មានសភាពដូចព្រះជាម្ចាស់ចំៗទេ ព្រះបុត្រាស្ថិតនៅក្រោមអំណាចព្រះបិតា ។ លោក**អារីយ៉ូស**សំអាងលើគម្ពីរសុភាសិត ៨,២២ និងយ៉ូហាន ១៤, ២៨ ។ ព្រះយេស៊ូសង្គ្រោះមនុស្សដោយដាស់តឿនគេឲ្យប្រព្រឹត្តតាមព្រះអង្គជាគំរូ ដើម្បីឲ្យព្រះជាម្ចាស់លើកតម្កើងគេរួមជាមួយព្រះអង្គនៅថ្ងៃណាមួយពុំខាន ។

លោក**អាឡិចសង់**ជាអភិបាលព្រះសហគមន៍អាឡិចសង់ឌ្រី មិនយល់ស្របនឹងទេវវិជ្ជានេះទេ ។ លោកតែងតែប្រកាសថា ព្រះបុត្រាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះអង្គមានព្រះជន្មគង់នៅអស់កល្បជានិច្ច ព្រះអង្គស្មើនឹងព្រះបិតា ។ បើព្រះបន្ទូលមិនមែនជាព្រះជាម្ចាស់យ៉ាងពិតប្រាកដទេ មនុស្សក៏មិនអាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់បានដែរ ពីព្រោះព្រះជាម្ចាស់មិនចាប់កំណើតជាមនុស្ស ហេតុនេះហើយ បានជាមនុស្សមិនអាចទទួលការសង្គ្រោះបានឡើយ ។ អស់លោកអភិបាលប្រជុំគ្នា ពិភាក្សាគ្នា តែមិនបានលទ្ធផលសោះ ។ លោកក៏ដេញលោកអរីយ៉ូសនិងកូនចៅ ១២ នាក់ ចេញពីព្រះសហគមន៍ (គ.ស. ៣១៨) ។
តែលោកអរីយ៉ូស មិនព្រមទទួលទោសនេះទេ ហើយដើរទៅញុះញង់គ្រីស្តបរិស័ទ
ជាច្រើននៅបូព៌ាដែលកាន់តាមលោក ។ គ្រីស្តបរិស័ទទាំងនោះយល់ឃើញថា
លោកកាន់តាមប្រពៃណីព្រះសហគមន៍ ។ នៅអាឡិចសង់ឌ្រីកើតចលាចលយ៉ាង
ខ្លាំង គេជេរប្រមាថគ្នា ពោលពាក្យទេវវិជ្ជាតាមផ្សារ ។ លោកអរីយ៉ូស ចង 50
ក្រងសៀវភៅ និងតែងបទចម្រៀងដើម្បីការពារគោលគំនិតរបស់លោក ។

ចាប់ពីព្រះចៅ**កុងស្តង់តាំង**មានជ័យជំនះលើព្រះចៅ**លីស៊ីញូស**មក ទ្រង់
សោយរាជ្យតែមួយព្រះអង្គ ។ ព្រះចៅសព្វព្រះហឫទ័យនាំសុខសន្តិភាពនៅបូព៌ា 51
ប្រទេស ។ តាមយោបល់ព្រះអង្គ ការជជែកវែកញែកបែបនេះគ្រាន់តែជាជម្លោះ
ពាក្យសំដីប៉ុណ្ណោះ ។ ទ្រង់សូមឲ្យម្នាក់ៗយកចិត្តទុកដាក់សម្រុះសម្រួលគ្នា ។ ប៉ុន្តែ
ដោយចលាចលនៅតែមានតទៅទៀត ព្រះចៅកុងស្តង់តាំង សម្រេចព្រះហឫទ័យ
កោះហៅអស់លោកអភិបាលឲ្យជួបជុំគ្នាជាមហាសន្និបាត ។

49

## ការប្រកែកអំពីលទ្ធិផ្សេងៗខាងគ្រីស្តសាសនា

### *លោកអរីយ៉ូស*

*១- ព្រះបន្ទូលមិនគង់នៅរួមជាមួយព្រះបិតាតាំងពីអស់កល្បជានិច្ចមកទេ ។*
*២- ព្រះជាម្ចាស់បង្កើតព្រះបន្ទូលដោយគ្មានអ្វីជាមុន ។*
*៣- ព្រះបន្ទូលមិនមែនជាព្រះបុត្រាយ៉ាងពិតប្រាកដរបស់ព្រះបិតាទេ ។*
*៤- សភាវៈរបស់ព្រះបុត្រាមិនហូរចេញពីសភាវៈរបស់ព្រះបិតាមកទេ ។*
*៥- ព្រះបន្ទូលមានជីវិតដោយព្រះបិតាសព្វព្រះហឫទ័យឲ្យមានព្រះជន្ម ។*
*៦- ព្រះបន្ទូលមានសភាវៈដែលតែងតែប្រែប្រួល ។*

### *លោកអាឡិចសង់*

*១- ព្រះបន្ទូលគង់នៅរួមជាមួយព្រះបិតាតាំងពីដើមរៀងមក ។*
*២- ព្រះជាម្ចាស់មិនបានបង្កើតព្រះបន្ទូលទេ គឺព្រះបន្ទូលបង្កើតអ្វីៗទាំងអស់វិញ ។*
*៣- ព្រះបន្ទូលជាព្រះបុត្រា មិនមែនមកពីព្រះបិតាទទួលព្រះបន្ទូលទុកជាបុត្រាធម៌ទេ គឺមកពីព្រះបុត្រាមានសភាវៈដូចព្រះបិតា ។*
*៤- ព្រះបុត្រាមានសភាវៈស្មើនឹងសភាវៈរបស់ព្រះបិតា ។*
*៥- ព្រះបន្ទូលយាងចេញមកពីព្រះបិតា ព្រះអង្គចែកសភាវៈរបស់ព្រះអង្គផ្ទាល់ឲ្យព្រះបន្ទូល ។*
*៦- ព្រះបន្ទូលមានសភាវៈជាព្រះជាម្ចាស់ មិនប្រែប្រួលសោះ មិនត្រូវរងទុក្ខឡើយ ។*

Layout Histor.qxd 2/10/07 10:09 AM Page 96

## 50 "ពិធីជប់លៀង" របស់លោកអរីយ៉ូស

លោក**អរីយ៉ូស**និពន្ធសៀវភៅ «*ពិធីជប់លៀង*» ដើម្បីពន្យល់ទ្រឹស្ដីរបស់លោក ។ មានសេចក្ដីខ្លះជាពាក្យកាព្យដែលបក្សពួករបស់លោកទន្ទេញចាំមាត់ ។

*(..) ព្រះជាម្ចាស់មិនមែនជាព្រះបិតាជានិច្ចនោះទេ ។ សម័យមួយ ព្រះអង្គមិនមែនជាព្រះបិតាទេ ក្រោយមក ព្រះអង្គក្លាយជាព្រះបិតាវិញ ។ ព្រះបុត្រាមិនមែនជាព្រះបុត្រាតាំងពីដើមរៀងមកដែរ ។ អ្វីៗទាំងអស់សុទ្ធតែកើតឡើងពីសូន្យមក អ្វីៗទាំងអស់សុទ្ធតែជាសត្វលោកដែលព្រះជាម្ចាស់បានបង្កើតមក ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្ទាល់ក៏កើតពីសូន្យដែរ ។*

*សម័យមួយគ្មានព្រះបន្ទូលទេ គឺព្រះបន្ទូលមិនស្ថិតនៅមុនព្រះជាម្ចាស់បង្កើតព្រះបន្ទូលនោះមក ដ្បិតពេលនោះព្រះជាម្ចាស់គង់តែមួយព្រះអង្គគត់ ព្រះបន្ទូលនិងព្រះប្រាជ្ញាញាណមិនទាន់មាននៅឡើយទេ (...) ។*

*ព្រះបន្ទូលមានសភាវៈដូចយើងទាំងអស់ដែរ គឺត្រូវប្រែប្រួលជានិច្ច តែទ្រង់មានសេរីភាព ។ បើទ្រង់សព្វព្រះហឫទ័យ ទ្រង់នៅតែមានមេត្តាករុណាជានិច្ច ។ បើទ្រង់សព្វព្រះហឫទ័យដូច្នេះ ទ្រង់អាចប្រែប្រួលដូចយើងរាល់គ្នាដែរ ព្រោះទ្រង់មានសភាវៈប្រែប្រួល (..) ។*

*ព្រះបន្ទូលមិនមែនជាព្រះជាម្ចាស់ពិតប្រាកដទេ ទោះបីយើងតែងហៅព្រះបន្ទូលថា ព្រះជាម្ចាស់ក្ដី ក៏ទ្រង់មិនមែនជាព្រះជាម្ចាស់យ៉ាងពិតប្រាកដដែរ គឺគ្រាន់តែចូលរួមចំណែកនឹងព្រះជាម្ចាស់ ដោយសារព្រះអង្គប្រណីសន្ដោសប៉ុណ្ណោះ (..) ។ អ្វីៗទាំងអស់សុទ្ធតែខុសប្លែកពីព្រះជាម្ចាស់ និងមានសភាវៈផ្សេងពីព្រះអង្គយ៉ាងណា ព្រះបន្ទូលក៏មានសភាវៈប្លែកស្រឡះពីសភាវៈរបស់ព្រះជាម្ចាស់ និងមានលក្ខណៈប្លែកពីព្រះបិតាយ៉ាងនោះដែរ ។ ព្រះបន្ទូលចូលរួមក្នុងចំណោមស្នាព្រះហស្ដព្រះជាម្ចាស់ និងសត្វលោកដែលទ្រង់បង្កើតមក ។ ព្រះបន្ទូលគ្រាន់តែជាសត្វលោកមួយ ដែលព្រះជាម្ចាស់បានបង្កើតប៉ុណ្ណោះ ។*

*សភាវៈរបស់ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធខុសប្លែកឆ្ងាយពីគ្នា បែកចេញពីគ្នា មិនមានទំនាក់ទំនងជាមួយគ្នាទេ ។ ហេតុនេះហើយ បានជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ប្លែកពីគ្នាទាំងស្រុង តាមសភាវៈផង និងតាមសិរីរុងរឿងផង ។*

## 51 ព្រះតម្រិះរបស់ព្រះចៅកុងស្តង់តាំង ចំពោះជម្លោះអំពីលទ្ធិគ្រីស្ដសាសនា

ព្រះចៅ**កុងស្តង់តាំង**ឈ្មោះព្រះចៅ**លីស៊ីញូស** នៅ គ.ស. ៣២៤ រួចទ្រង់គង់នៅរាជធានីក្រុងនីកូម៉េដឌី (ខាងត្បូងក្រុងកុងស្តង់ទីណូប្លួ) ជារាជធានីប៉ែកខាងបូព៌ាប្រទេស ។ ទ្រង់ព្រះសណ្ដាប់ថា មានជម្លោះអំពីទេវវិជ្ជាកើតនៅអាឡិចសង់ឌ្រី បណ្ដាលឲ្យប្រជាជននៅបូព៌ាប្រទេសទាំងមូលជ្រួលច្របល់ ។ ទ្រង់សព្វព្រះហឫទ័យតែងតាំងសន្តិភាព ទ្រង់អញ្ជើញគូវិវាទទាំងពីរនាក់ដែលឈ្លោះគ្នាអំពីពាក្យសំដីឲ្យសម្រុះសម្រួលគ្នា ។ ដោយកិច្ចការមិនបានសម្រេចតាមបំណង ទ្រង់កោះហៅមហាសន្និបាតនៅក្រុងនីសេ (ខាងត្បូងក្រុងកុងស្តង់ទីណូប្លួ) ។

*យើងព្រះចៅកុងស្តង់តាំង ដែលមានជ័យជំនះជាព្រះចៅដ៏ប្រសើរឧត្ដម ផ្ញើលិខិតឲ្យលោក**អាឡិចសង់**និងលោក**អរីយ៉ូស** សូមជ្រាប ។*

*យើងឮដំណឹងអំពីដើមហេតុលោកទាំងពីរខ្វែងគំនិតគ្នាហើយ គឺលោកអាឡិចសង់ (ជាអភិបាលព្រះសហគមន៍ក្រុងអាឡិចសង់ឌ្រី) សុំយោបល់អស់លោកបូជាចារ្យរបស់លោកអំពីអត្ថបទគម្ពីរ (សុភ ៨,២២) ឬនិយាយឲ្យត្រូវជាងអំពីចំណុចដ៏តូចឥតបានការមួយ ។ ឯលោកអរីយ៉ូសវិញផ្សព្វផ្សាយយ៉ាងមិនប្រុងប្រយ័ត្ននូវគំនិតដែលមិនត្រូវគិត ឬប្រសិនបើគិតក្នុងចិត្តមិនត្រូវប្រាប់គេសោះ ។ ហេតុនេះហើយ បានជាលោកទាំងពីរត្រូវបែកបាក់គ្នា មិនចុះសម្រុងគ្នា ប្រជាជនដ៏វិសុទ្ធក៏បែកបាក់គ្នា លែងមានឯកភាព ។ ឥឡូវនេះ សូមលោកទាំងពីរលើកលែងទោសគ្នាទៅវិញទៅមក និងអនុវត្តតាមដំបូន្មានយើងជាអ្នកបម្រើរបស់អស់លោក ។ កាលដើមដំបូង មិនគួរលើកសំណួរបែបនេះដើម្បីរកចម្លើយទេ ។ គ្មានវិន័យណាបង្គាប់ឲ្យស្វែងរកសេចក្ដីទាំងនេះទេ មានតែមនុស្សខ្ជិលប្រអូស គ្មានអ្វីធ្វើដែលបង្កើតការជជែកវែកញែកដ៏ឥតបានការនេះ ។ ការជជែកនេះគ្រាន់តែអាចជួយបង្ហាត់ឲ្យចេះរិះគិតប៉ុណ្ណោះ តែត្រូវកប់ទុក* • • •

Layout Histor.qxd 2/10/07 10:09 AM Page 97

*ក្នុងចិត្ត មិនត្រូវបញ្ចេញផ្តេសផ្តាសក្នុងអង្គប្រជុំសាធារណៈ ឬឲ្យប្រជាជនស្តាប់ឮទេ ។ តើមានមនុស្សប៉ុន្មាននាក់ ដែលអាចយល់បញ្ហាដ៏ស្មុគស្មាញនេះ ឬអាចពន្យល់ត្រឹមត្រូវបាន?*

*លោកទាំងពីរមិនខ្វែងគំនិតគ្នាអំពីបញ្ញត្តិក្នុងធម្មវិន័យឡើយ លោកទាំងពីរក៏មិនបញ្ចូលគោលលទ្ធិណាមួយថ្មីស្តីពីការគោរពព្រះជាម្ចាស់ដែរ ។ លោកទាំងពីរមានចិត្តគំនិតដូចគ្នាអាចរួបរួមគ្នាបានដែរ ។ មិនគួរ មិនសម មិនត្រឹមត្រូវឲ្យលោកទាំងពីរប្រកែកអំពីរឿងតូចបំផុតនោះ និងប្រើអំណាចរបស់ខ្លួនទៅលើប្រជាជន ដើម្បីជំរុញគេក្នុងជម្លោះរបស់លោកទាំងពីរឡើយ ។*

*ទោះបីទស្សនវិទូមានមុខងារស្វែងរកសេចក្តីពិតក្តី ក៏គេមិនចុះសម្រុងគ្នាទាំងអស់ត្រង់ចំណុចជាច្រើនដែរ ។ ទោះបីគេខ្វែងគំនិតគ្នាក្តី ក៏ពួកគេនៅតែរស់នៅរួមជាមួយគ្នា ស្វែងរកសេចក្តីពិតដូចគ្នា ។ រីឯលោកទាំងពីរជាអ្នកបម្រើព្រះជាម្ចាស់ត្រូវតែឲ្យលោកទាំងពីររួមគ្នាប្រកាសជំនឿតែមួយដូចគ្នា ទើបល្អប្រសើរ ។ ទោះបើលោកខ្វែងគំនិតអំពីចំណុចដ៏មិនសំខាន់ក្តីក៏លោកទាំងពីរអាចរួមគ្នាបានដែរ ។ ចូរលោកទាំងពីរមានជំនឿអំពីព្រះឧបការគុណ និងអំពីការគោរពព្រះជាម្ចាស់ដូចគ្នាបានហើយ (...) ហើយរក្សាសេចក្តីស្រឡាញ់យ៉ាងស្មោះស្ម័គ្រការរាប់អានគ្នា សេចក្តីពិតនៃជំនឿ ការប្រតិបត្តិតាមវិន័យរបស់ព្រះជាម្ចាស់ ។ សូមលោកទាំងពីរមានចិត្តសប្បុរស និងបង្រួបបង្រួមប្រជាជនទៅ (...)! ។*

*លិខិតព្រះចៅកុងស្តង់តាំង ចម្លងតាមលោកអឺសែប ២,៦៩*

## ២- មហាសន្និបាតនៅក្រុងនីសេ (គ.ស ៣២៥)

សតវត្សមុនៗ លោកអភិបាលព្រះសហគមន៍តែងតែជួបជុំគ្នាជាច្រើនដងជាសន្និបាតតាមតំបន់ ។ ពេលព្រះចៅកុងស្តង់តាំង កោះហៅលោកអភិបាលទាំងអស់ឲ្យមកប្រជុំគ្នានៅក្រុងនីសេ ទ្រង់បង្កើតរចនាសម្ពន្ធថ្មីមួយក្នុងព្រះសហគមន៍ គឺមហាសន្និបាតសកល (Concile œcuménique) ។ តាំងពីពេលនោះរហូតដល់សព្វថ្ងៃ គឺរហូតដល់មហាសន្និបាតវ៉ាទីកង់ទី ២ មានមហាសន្និបាតសកល ២១ ។

អភិបាលព្រះសហគមន៍ប្រមាណ ៣00 នាក់ ចូលរួមក្នុងមហាសន្និបាតនៅក្រុងនីសេនោះ ។ មានទុកឈ្មោះចំនួន ២២0 នាក់ សុទ្ធសឹងជាអភិបាលព្រះសហគមន៍ខាងបូព៌ា ដែលកាន់តាមអរិយធម៌ក្រិក ។ អស់លោកដែលរស់នៅតំបន់ក្បែរៗ ចូលចិត្តការជជែកវែកញែកអំពីគោលលទ្ធិសាសនា ។ ឯព្រះសហគមន៍ខាងបស្ចិម មានលោកអភិបាល**សេស៊ីលីយ៉ាំង** (Cécilien) មកពីក្រុងកាតាស្សព្រឹទ្ធាចារ្យពីរនាក់ជាតំណាងអភិបាលក្រុងរ៉ូម និងអភិបាលបួនប្រាំនាក់ទៀត ។ ការប្រជុំអភិបាលទាំងនោះ នាំឲ្យគេរំភើបចិត្តយ៉ាងខ្លាំង ។ តាំងពីដើមរៀងមក

52 ព្រះសហគមន៍មិនដែលប្រជុំអ្នកដឹកនាំច្រើនដូចនេះទេ ។ មានអភិបាលខ្លះត្រូវរដ្ឋអំណាចធ្វើទុក្ខបុកម្នេញកាលពីប៉ុន្មានឆ្នាំមកនេះ មានអភិបាលខ្លះជាអ្នកកាន់

អំណាចយ៉ាងខ្លាំង ដូចស្តេចត្រាញ់ និងអភិបាលខ្លះប្រកបអាជីវកម្មជាគង្វាល 53

សត្វ ។ អស់លោកស្ញប់ស្ញែងព្រះចៅអធិរាជដែលទទួលអស់លោក ។ អស់លោកស្ងើចសរសើរមាសដែលមានពាសពេញក្នុងបរមរាជវាំង និងឯកសណ្ឋានរបស់ទាហានដែលលើកអាវុធគោរពវន្ទាអស់លោក ។ លោកខ្លះយល់ឃើញថា តើព្រះរាជ្យរបស់ព្រះជាម្ចាស់ល្អប្រសើរលើសព្រះរាជ្យរបស់ព្រះចៅឬទេ?

លោកអភិបាលស្ទើរតែទាំងអស់ យល់ស្របនឹងដាក់ទោសលោក**អារីយ៉ូស** ។ ប៉ុន្តែ អស់លោកត្រូវតែបញ្ជាក់អំពីលទ្ធិរបស់ព្រះសហគមន៍ឲ្យបានត្រឹមត្រូវ ។ លោក**អឺសែប**ជាអភិបាលព្រះសហគមន៍ក្រុងសេសារេ យកធម៌ប្រកាសជំនឿរបស់ព្រះសហគមន៍លោក ឲ្យអស់លោកបញ្ចេញការយល់ព្រម ។ មហាសន្និបាតសុខចិត្តទទួលធម៌ប្រកាសជំនឿនោះ ទុកជាគោលនៃជំនឿព្រះសហគមន៍សកល ។ ប៉ុន្តែព្រះចៅ**កុងស្តង់តាំង** ដោយមានលោក**អូស៊ុយ៉ូស**ជាអភិបាលក្រុងក័រឌូ (ប្រទេសអេស្ប៉ាញ) បន្ថែមថា «*ព្រះបុត្រាមានសភាវៈដូចអង្គព្រះបិតា*» *(homoousios)* ។

ពាក្យនេះមានអត្ថន័យថា ព្រះបុត្រានិងព្រះបិតាស្មើគ្នាក្នុងគ្រប់ប្រការ ។ ដោយ 53

Layout Histor.qxd 2/10/07 10:09 AM Page 98

ព្រះចៅអធិរាជផ្ទាល់សូមបន្ថែមពាក្យនេះ អស់លោកអភិបាលយល់ស្របគ្រប់គ្នា លើកលែងតែពីរនាក់ប៉ុណ្ណោះ ។ ព្រះចៅបាននិរទេសលោកអភិបាលទាំងពីរនោះ ជាមួយលោក**អរីយ៉ូស** ។

មហាសន្និបាតសម្រេចអំពីវិន័យខ្លះៗក្នុងព្រះសហគមន៍ ។ អស់លោកកំណត់កាលបរិច្ឆេទថ្ងៃបុណ្យចម្លងតាមព្រះសហគមន៍ក្រុងរ៉ូម និងក្រុងអាឡិចសង់ឌ្រី ។ អស់លោកសម្រេចវិន័យខ្លះសម្រាប់ណែនាំអភិបាលព្រះសហគមន៍ គឺវិន័យសម្រាប់ស្ត្រីៗដែលរស់នៅជាមួយបូជាចារ្យ ។ តាមលោក**សូក្រាត** (នៅដើមសវត្ស ទី ៥) អស់លោកអភិបាលមានបំណងបង្ខំឲ្យអស់លោកដែលបំពេញមុខងារ ជាពិសេស
54 ក្នុងព្រះសហគមន៍លែងលះភរិយា ។ ប្រហែលគេអនុវត្តតាមវិន័យនេះនៅស្រុកអេស្ប៉ាញ ។ តែលោកអភិបាល**ប៉ាន្នូស**ទោះបីលោកគ្មានគ្រួសារក្តី ក៏មិនយល់ស្របនឹងសំណើរនេះទេ ទើបសន្និបាតបណ្តោយឲ្យអភិបាល បូជាចារ្យ និងឧបដ្ឋាកមានសេរីភាពក្នុងបញ្ហានេះ ។ អស់លោកសម្រេចសេចក្តីផ្សេងៗអំពីការលើកលែងទោសគ្រីស្តបរិស័ទដែលបានក្បត់សាសនា នៅពេលរដ្ឋអំណាចធ្វើទុក្ខបុកម្នេញ អំពីបែបបទក្នុងពិធីលើកលែងទោស ។ល ។



*ចង្កៀងបុរាណ*
*«ព្រះគ្រីស្តជាពន្លឺ»*

52

## មហាសន្និបាតសកលដំបូងនៅក្រុងនីសេ (គ.ស. ៣២៥)

*អ្នកបម្រើព្រះជាម្ចាស់ដ៏ប្រសើរជាងគេ បានមកជួបជុំគ្នាពីគ្រប់ព្រះសហគមន៍ ដែលមានពាសពេញទ្វីបអឺរ៉ុប ស្រុកលីប៊ី និងស្រុកអាស៊ី ។ ព្រះជាម្ចាស់ប្រកបដោយឫទ្ធិបាមី ពង្រីកផ្ទះអធិដ្ឋានតែមួយ គឺជនជាតិស៊ីរីនិងស៊ីលីស៊ី ជនជាតិភេនីស៊ី និងជនជាតិអារ៉ាប់ ជនជាតិប៉ាឡេស្ទីន និងជនជាតិអេស៊ីប ប្រជុំគ្នាអធិដ្ឋាន ។ លោកអភិបាលស្រុកពែរ្ស ក៏ចូលរួមមហាសន្និបាតដែរ ។ (...) លោកអភិបាលក្រុងរ៉ូមមិនបានមក ព្រោះលោកចាស់ជរា តែមានបូជាចារ្យពីរនាក់ជាតំណាងព្រះសហគមន៍របស់លោកមកដែរ (...) ។*

*អស់លោកអភិបាលចូលក្នុងបន្ទប់ធំមួយនៃបរមរាជវាំង ហើយម្នាក់ៗអង្គុយតាមឋានៈរបស់ខ្លួនលើកៅអីដែលរៀបចំជាស្រេច (...) ។ នៅពេលឮស្នូរសញ្ញាសម្គាល់ថា ព្រះចៅអធិរាជយាងមកដល់ អភិបាលទាំងអស់ក្រោកឈរឡើង ស្រាប់តែព្រះចៅអធិរាជយាងចូលមកនៅកណ្តាលមនុស្សត្រកូលខ្ពស់ជាច្រើន ហាក់ដូចជាព្រះមួយអង្គ ។ ព្រះភូសាពណ៌ក្រហមប្រាល និងរស្មីពន្លឺមាស និងត្បូងពេជ្រចាំងពន្លឺស្រវាំងភ្នែក (...) ។*

*នៅពេលមហាសន្និបាតជិតចប់ អស់លោកអភិបាលធ្វើពិធីបុណ្យខួបទីម្ភៃ ដែលព្រះចៅអធិរាជគ្រងរាជ្យគ្រប់ស្រុក ។ គេប្រារព្ធពិធីអធិកអធមនេះជាសាធារណៈ ។ ព្រះចៅអធិរាជក៏អញ្ជើញអ្នកបម្រើព្រះជាម្ចាស់មកជប់លៀងដែរ (...) ។ អស់លោកអភិបាលចូលរួមគ្រប់ៗគ្នា គ្មាននរណាមិនទៅឡើយ ។ ព្រឹត្តិការណ៍នេះហួសពីពាក្យសំដីរកថ្លែងមិនបាន ។ នៅបន្ទប់ចូលវាំង មានអង្គរក្ស និងកងកម្លាំងប្រដាប់អាវុធលើកដាវគ្រប់ដៃចេញពីស្រោម គោរពអស់លោកអភិបាល ។ អ្នកបម្រើព្រះជាម្ចាស់ចូលមកនៅកណ្តាលអ្នកកាន់អាវុធ ដោយមិនខ្លាចអ្វីឡើយ ។ លោកអភិបាលខ្លះអង្គុយរួមតុនឹងព្រះចៅអធិរាជ លោកឯទៀតៗតម្រេតលើគ្រែ រៀបជាស្ពែងក្របីសងខាង ។ អស់លោករំភើបចិត្ត ហាក់ដូចជាភ្លក្សឱជារសនៃព្រះរាជ្យរបស់ព្រះគ្រីស្តទុកជាមុន គេស្មានថាគេកំពុងយល់សប្តិ ។ បន្ទាប់ពីជប់លៀងដ៏ប្រសើរលើសលប់នេះ ព្រះចៅអធិរាជប្រទានព្រះអំណោយទានឲ្យម្នាក់ៗតាមឋានៈ និងតាមកិត្តិយសរបស់ខ្លួន ទុកជាសក្ខីភាពអំពីសិរីរុងរឿងដ៏អស្ចារ្យរបស់ព្រះអង្គ ។*

*អឺសែប "ជីវប្រវត្តិរបស់ព្រះចៅកុងស្តង់តាំង" ជំពូក ៣, ១៥, ១៦*

Layout Histor.qxd 2/10/07 10:09 AM Page 99

## 53 ធម៌ប្រកាសជំនឿមហាសន្និបាតនីសេ

*យើងជឿលើព្រះជាម្ចាស់តែមួយព្រះអង្គ ជាព្រះបិតាដ៏មានតេជានុភាពសព្វប្រការ ជាព្រះអាទិករនៃអ្វីៗសព្វសារពើ ដែលភ្នែកមើលឃើញ ។*

*យើងជឿលើព្រះអម្ចាស់តែមួយព្រះអង្គ គឺព្រះយេស៊ូគ្រីស្តជាព្រះបុត្រាតែមួយគត់របស់ព្រះបិតា ព្រះអង្គមានកំណើតពីព្រះបិតា គឺចេញពីសភាវៈព្រះបិតា ព្រះអង្គពិតជាព្រះជាម្ចាស់មានកំណើតពីព្រះជាម្ចាស់ ជាពន្លឺលេចចេញមកពីព្រះពន្លឺ ជាព្រះជាម្ចាស់ដ៏ពិតប្រាកដចេញមកពីព្រះដ៏ពិតប្រាកដ ។ ព្រះអង្គជាព្រះបុត្រានៃព្រះបិតា ព្រះអង្គពុំមានកំណើតដូចសត្វលោកទូទៅឡើយ ។ ព្រះអង្គមានសភាវៈដូចអង្គព្រះបិតា ។ អ្វីៗសព្វសារពើ ទាំងនៅលើមេឃ ទាំងនៅលើផែនដី ក៏កើតដោយសារព្រះអង្គបង្កើតដែរ ។*

*ព្រះអង្គយាងពីស្ថានបរមសុខមកព្រោះតែយើងខ្ញុំ គឺមកដើម្បីសង្គ្រោះយើងខ្ញុំ ព្រះអង្គប្រសូតជាមនុស្ស ព្រះអង្គសោយទុក្ខលំបាក ។ លុះថ្ងៃទី ៣ ព្រះអង្គតើនឡើងពីចំណោមមនុស្សស្លាប់ ព្រះអង្គយាងឡើងស្ថានបរមសុខ ព្រះអង្គនឹងយាងមកវិញដើម្បីកាត់ក្ដីមនុស្សទាំងរស់ទាំងស្លាប់ ។ យើងជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ។*

*ចំពោះអ្នកដែលនិយាយថា៖ «ពេលមួយគ្មានព្រះបុត្រា» និង «ព្រះបុត្រាគ្មានព្រះជន្មគង់នៅមុនព្រះអង្គប្រសូត» និង «ព្រះជាម្ចាស់បង្កើតព្រះបុត្រាពីសូន្យ» ឬចំពោះអ្នកដែលប្រកាសថា ព្រះបុត្រារបស់ព្រះជាម្ចាស់មានជាតិផ្សេងពីព្រះជាម្ចាស់ ឬមានសភាពផ្សេងពីព្រះអង្គ ឬថាព្រះជាម្ចាស់បង្កើតព្រះអង្គដូចសត្វលោកឯទៀតៗ ព្រះអង្គត្រូវតែប្រែប្រួល ឬត្រូវវិនាស ព្រះសហគមន៍កាតូលិកដែលកាន់ជំនឿស្របតាមក្រុមគ្រីស្តទូតគឺបណ្ដេញអ្នកទាំងនោះចេញពីព្រះសហគមន៍ហើយ ។*

## 54 លោកប៉ាន្នូស ថ្លែងសេចក្ដីអំពីការរស់នៅរបស់ក្រុមបូជាចារ្យដែលមានគ្រួសារ នៅមហាសន្និបាតនីសេ

លោក**សូក្រាត** (ប្រ.គ.ស. ៣៨០-៤៤០) ជាមេធាវីក្រុងកុងស្តង់ទីណូប្លិ លោកសរសេរប្រវត្តិព្រះសហគមន៍បន្តពីលោក**អឺសែប** ជាអភិបាលក្រុងសេសារ៉េមក ។ លោកថែងអំពីព្រឹត្តិការណ៍ខាងសាសនា ចាប់តាំងពី គ.ស. ៣០៥ រហូតដល់គ.ស. ៤៣៩ ។ លោកកត់ត្រាទុកព័ត៌មានជាច្រើន ។

*លោក**ប៉ាន្នូស**ជាអភិបាលព្រះសហគមន៍ក្រុងមួយ នៅភ្នំតេបាអ៊ីឌ ។ លោកគោរពប្រណិប័តន៍ព្រះជាម្ចាស់យ៉ាងខ្លាំង រហូតដល់អាចសម្ដែងការអស្ចារ្យបាន ។ ពេលរដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទ លោកខូចភ្នែកម្ខាង ។ ព្រះចៅអធិរាជគោរពលោកយ៉ាងខ្លាំង ទ្រង់តែងតែអញ្ជើញលោកមកព្រះបរមរាជវាំង ហើយទ្រង់តែងតែថើបភ្នែកម្ខាងដែលខ្វាក់នោះ ។*

*អស់លោកអភិបាលបានព្រមគ្នាបញ្ចេញវិន័យថ្មី គឺអស់លោកចង់បញ្ជាឲ្យអស់លោកអភិបាល លោកបូជាចារ្យ និងលោកឧបដ្ឋាកត្រូវបែកចេញពីភរិយាដែលរៀបការ មុនពេលអស់លោកមិនទាន់ទទួលមុខងារពិសេសនៅក្នុងព្រះសហគមន៍ ។ ពេលអង្គប្រជុំសួរយោបល់ លោក**ប៉ាន្នូស**ឈរឡើងនៅកណ្ដាលអភិបាលឯទៀតៗ ហើយបន្លឺសំឡេងយ៉ាងខ្លាំងៗថា មិនត្រូវដាក់នឹមធ្ងន់ពេកនេះឲ្យអ្នកបម្រើព្រះសហគមន៍ឡើយ ។ ការរស់នៅជាគូស្វាមីភរិយា គឺពិតជារបៀបរស់នៅគួរឲ្យគោរព ។ គូស្វាមីភរិយាដែលរួមដំណេកក៏មិនប្រព្រឹត្តអំពើបាបអ្វីឡើយ ។ ប្រសិនបើព្រះសហគមន៍តឹងពេកមុខជាកើតផលវិបាកពុំខាន ។ មនុស្សទាំងអស់គ្មានសមត្ថភាពរស់នៅជាលីវបានទេ ហើយស្រីៗជាភរិយារបស់គេ ប្រហែលក៏មិនអាចទ្រាំបានដែរ ។*

*លោកចាត់ទុកការរស់នៅជាគូស្វាមីភរិយាត្រឹមត្រូវថាជាការរស់នៅយ៉ាងបរិសុទ្ធ ។ គ្រាន់តែឲ្យលោកដែលចូលរួមក្នុងក្រុមបូជាចារ្យ មិនរៀបការទៀតបានហើយ តាមប្រពៃណីព្រះសហគមន៍ពីដើម ។ តែមិនត្រូវបង្ខំអ្នកដែលរៀបអាពាហ៍ពិពាហ៍មុនទទួលមុខងារបម្រើព្រះសហគមន៍ឲ្យបាកចេញពីភរិយាឡើយ ។ លោកបញ្ចេញយោបល់នេះ ទោះបីលោកមិនដែលរៀបការក្ដី ហើយក៏មិនដែលស្រឡាញ់ស្ត្រីណាដែរ ព្រោះលោករស់នៅក្នុងវត្តអារាមតាំងតែពីកុមារមក ហើយមនុស្សម្នាតែងតែសរសើរកិរិយាដ៏បរិសុទ្ធយ៉ាងល្អបំផុតរបស់លោក ។*

*អស់លោកអភិបាលបានយល់ស្របតាមគំនិតរបស់លោក**ប៉ាន្នូស**ហើយមិនបានជជែកអ្វីទៀតទេ គឺទុកឲ្យអស់លោកដែលរៀបអាពាហ៍ពិពាហ៍រួចហើយមានសេរីភាពពេញទី ។*

*លោកសូក្រាត "ប្រវត្តិរបស់ព្រះសហគមន៍" ជំពូក ១, ១១*

Layout Histor.qxd 2/10/07 10:09 AM Page 100

## ៣- ព្រះសហគមន៍ជួលច្របល់អស់រយៈពេលហាសិបឆ្នាំ

គ្រីស្តបរិស័ទជាច្រើនមិនព្រមទទួលស្គាល់ពាក្យ *«ព្រះបុត្រាមានសភាវៈដូចអង្គព្រះបិតា» (Homo-Ousia)* ដូចមានចែងក្នុងធម៌ប្រកាសជំនឿមហាសន្និបាតនីសេ ព្រោះពាក្យនេះគ្មានចែងក្នុងព្រះគម្ពីរទេ ។ គ្រីស្តបរិស័ទខ្លះរំឭកថា អ្នកវង្វេងឆ្ងាយពីជំនឿ ធ្លាប់ពោលពាក្យនេះ ដោយអ្នកទាំងនោះមិនញែកព្រះបិតាចេញពីព្រះបុត្រាទេ ។ មិនសូវយូរប៉ុន្មាន គ្រីស្តបរិស័ទនៅបូព៌ាប្រទេសភាគច្រើនមិនព្រមទទួលស្គាល់ធម៌ប្រកាសជំនឿនៃមហាសន្និបាតនីសេនោះ លើកលែងតែលោក**អាថាណាស្ស**ជាអភិបាលព្រះសហគមន៍អាឡិសង់ឌ្រី តាំងពីគ.ស. ៣២៨ ។ រីឯគ្រីស្តបរិស័ទបស្ចិមប្រទេសវិញ នៅតែសុខចិត្តទទួលធម៌ប្រកាសជំនឿនោះ ។

ព្រះចៅអធិរាជ**កុងស្តង់តាំង**ដែលគាំទ្រធម៌ប្រកាសជំនឿមហាសន្និបាតនៅនីសេកាលពីដើម ប្តូរយោបល់ដោយមានព្រះរាជបំណងធ្វើឲ្យគ្រីស្តបរិស័ទនៅបូព៌ាប្រទេសធូរចិត្ត តែគ្រីស្តបរិស័ទបែរជាប្រើហឹង្សា និងសងសឹកគ្នាជាបន្តបន្ទាប់ ។ គ.ស. ៣៣៥ សន្និបាតក្រុងទីរូសទម្លាក់លោកអាថាណាស្សពីតំណែង ព្រោះលោកមិនព្រមទទួលលោក**អរីយ៉ូស**ក្នុងព្រះសហគមន៍របស់លោកវិញ ។ គេនិរទេសលោកទៅក្រុងត្រែវ (Trèves) ត្រង់ព្រំដែនអាល្លឺម៉ង់ ។ លោកត្រូវគេនិរទេសបួនដងទៀត ព្រោះលោកជឿយ៉ាងស្មោះតាមធម៌ប្រកាសជំនឿនៅនីសេ ។

ក្នុងរាជ្យនៃព្រះបុត្រារបស់ព្រះចៅអធិរាជកុងស្តង់តាំង ព្រះសហគមន៍កាន់តែបែកបាក់គ្នា ។ សន្និបាតមួយនៅសាឌីក (គ.ស. ៣៤២-៣៤៣) បណ្តាលឲ្យក្រុមអភិបាលព្រះសហគមន៍នៅបស្ចិមប្រទេស និងអភិបាលព្រះសហគមន៍នៅបូព៌ាបែកខ្ញែកគ្នា ។ ចាប់ពីគ.ស. ៣៥១ ព្រះ**ចៅអធិរាជកុងស្តង់** (Constance) គ្រងរាជ្យតែមួយព្រះអង្គគត់ ព្រះចៅកាន់តាមលោកអរីយ៉ូសទាំងស្រុង គឺទ្រង់និរទេសអភិបាលពីបស្ចិមប្រទេសទៅបូព៌ាប្រទេស មានលោក**លីប៉ែរ** (Libère) ជាអភិបាលក្រុងរ៉ូម លោក**អ៊ីលែរ** (Hilaire) ជាអភិបាល**ព័រទីយេ** (ប្រទេសបារាំង) លោក**អូស៊ីយ៉ូស** (Osius) ជាអភិបាលក័រឌូ (ប្រទេសអេស្ប៉ាញ) ។ល។ អស់លោកអភិបាលតែងតែប្រជុំវែកញែក តែគ្មាននរណាម្នាក់ពេញចិត្តទេ ។ ឆ្នាំ ៣៥៩ ព្រះចៅអធិរាជបង្ខំអស់លោកអភិបាល ឲ្យទទួលពាក្យមួយដែលមិនបញ្ជាក់សេចក្តីច្បាស់លាស់ គឺពាក្យ *«ព្រះបុត្រាដូចព្រះបិតា» (homoios)* ។ សន្ត**យេរ៉ូម** មានប្រសាសន៍ថា *«មនុស្សលោកទាំងអស់នាំគ្នាថ្ងូរ និងឆ្ងល់ដោយយល់ឃើញថា គេកាន់ជំនឿតាមលោកអរីយ៉ូសហើយ»* ។

សូម្បីតែក្នុងព្រះសហគមន៍នៅបូព៌ាប្រទេស គ្រីស្តបរិស័ទក៏បែកបាក់គ្នាដែរ ឧបមាថា នៅក្រុងអន់ទីយ៉ូកមានរហូតដល់ប្រាំក្រុម ។ ដោយព្រះសហគមន៍ក្រុងរ៉ូមបាក់បែកដែរ គ្រីស្តបរិស័ទលំបាករកអ្នកស្នងមុខតំណែងលោកអភិបាលលីប៉ែរ (ឆ្នាំ ៣៦៦) គឺមានពីរនាក់ប្រឆាំងគ្នា ។ គេជ្រើសរើសលោក**ដាម៉ាស** (Damase) ក្រោយពីបានកាប់ចាក់គ្នា ស្លាប់គ្រីស្តបរិស័ទចំនួន ១៣៧ នាក់ ។

## ៤- មហាសន្និបាតនៅក្រុងស្តង់ទីណូប្ល បញ្ចប់វិបត្តិ (គ.ស ៣៨១)

ទោះបីព្រះសហគមន៍ច្របូកច្របល់ក្តី ក៏អភិបាលព្រះសហគមន៍រិះគិតអំពីទេវវិជ្ជាបណ្តើរៗដែរ និងបញ្ជាក់អត្ថន័យពាក្យពេចន៍ គឺញែកពាក្យ *«សភាព» (Ousia)* និង *«បុគ្គល»* ឬ *«អង្គ» hypostase* ធ្វើឲ្យគ្រីស្តបរិស័ទអាចនឹកគិតថា ព្រះបិតានិងព្រះបុត្រាមាន *«សភាព»* តែមួយដូចគ្នា ប៉ុន្តែជា *«អង្គ»* ប្លែកពីគ្នា ។

នៅគ.ស. ៣៧០-៣៧៩ លោក**បាស៊ីល**ជាអភិបាលក្រុងសេសារេ ខិតខំបង្រួបបង្រួមគ្រីស្តបរិស័ទដោយរិះគិតយ៉ាងជ្រៅខាងទេវវិជ្ជា ។ មានគេសួរថា៖ តើព្រះវិញ្ញាណជាព្រះជាម្ចាស់ឬទេ? អ្នកកាន់តាមលោកអរីយ៉ូសតបឆ្លើយថា ទេ ។ គ្រីស្តបរិស័ទតែងហៅពួកគេថា *«ពួកប្រឆាំងនឹងព្រះវិញ្ញាណ»* ។ លោក**បាស៊ីល**និពន្ធសៀវភៅមួយ មានចំណងជើងថា *«អំពីព្រះវិញ្ញាណដ៏វិសុទ្ធ»* ។ បញ្ជាក់ថា ព្រះវិញ្ញាណក៏មាន *«សភាវៈ»* ដូចព្រះបិតាដែរ ។

Layout Histor.qxd 2/10/07 10:09 AM Page 101

លោក**គ្រេគ័រ**ជាអភិបាលក្រុងណាស៊ីយ៉ង្ស (Grégoire de Naziance) និង
ជាមិត្តសម្លាញ់របស់លោក**បាស៊ីល** ក៏សរសេរសៀវភៅមួយដែលមានអត្ថន័យដូច
គ្នាដែរ ។ ម្យ៉ាងទៀត លោកបាស៊ីលរឹតចំណងមិត្តភាពយ៉ាងជិតស្និទ្ធជាមួយអស់
លោកអភិបាលខាងបូព៌ា ហើយក៏សុំលោក**អាថាណាស្ស**មានទំនាក់ទំនងជាមួយ
អស់លោកអភិបាលខាងបស្ចិមប្រទេសផងដែរ ។ លោកបាស៊ីលសរសេរលិខិតផ្ញើ
ជូនអស់លោកអភិបាលស្រុកហ្គោល (បារាំង) និងស្រុកអ៊ីតាលី ទាំងរៀបរាប់ពីទុក្ខ
លំបាកព្រះសហគមន៍នៅបូព៌ាប្រទេស ។ ប៉ុន្តែ លោក**ដាម៉ាស**ជាអភិបាលក្រុងរ៉ូម
មិនសូវខិតខំជួយសម្រុះសម្រួលព្រះសហគមន៍ប៉ុន្មានទេ ។

នៅគ.ស. ៣៧៨ ព្រះចៅអធិរាជ**វ៉ាឡេង្ស** (Valens) ដែលកាន់តាមលោក
**អរីយ៉ូស** បាញ់សង្គ្រាមប្រឆាំងជាតិហ្គ័ត (Goth) នៅអង់ឌ្រីណូប្ល ហើយត្រូវគេធ្វើ
55 គុត ។ គ្រីស្តបរិស័ទយល់ឃើញថា ព្រះជាម្ចាស់ដាក់ទោសព្រះចៅហើយ ។ ព្រះ
ចៅអធិរាជពីរអង្គស្នងរាជ្យ គឺព្រះចៅ**ក្រាស៊ីយ៉ាំង** (Gratien) នៅបស្ចិម និងព្រះ
ចៅ**ទេអូដូស** (Théodose) នៅបូព៌ា ។ ព្រះចៅទាំងពីរអង្គសម្រេចព្រះហឫទ័យ
បញ្ចប់ជម្លោះខាងទេវវិជ្ជានោះ ។

## *ព្រះសហគមន៍ស្ងប់ស្ងាត់វិញ*

គ.ស. ៣៨០ ព្រះចៅអធិរាជ**ទេអូដូស**លើកសាសនាកាតូលិកធ្វើជាសាសនា
រដ្ឋ ព្រះអង្គទទួលស្គាល់លោក**គ្រេគ័រ**ជាអភិបាលព្រះសហគមន៍ណាស៊ីយ៉ង្សទុកជា
អភិបាលព្រះសហគមន៍នៅកុងស្តង់ទីណូប្ល ។ ទ្រង់ក៏កោះហៅមហាសន្និបាតឲ្យមក
ជួបជុំនៅក្នុងរាជធានី (ឆ្នាំ ៣៨១) ។ មានតែអភិបាលប៉ែកបូព៌ាប៉ុណ្ណោះទេចូលរួម
ក្នុងមហាសន្និបាតនេះ ។ មហាសន្និបាតបញ្ជាក់ថា ត្រូវកាន់តាមធម៌ប្រកាសជំនឿ
ដូចមានបញ្ជាក់នៅមហាសន្និបាតនីសេ និងត្រូវបដិសេធនូវលទ្ធិវង្វេងពីសេចក្តីពិត
56 ដែលទើបកើតឡើងថ្មីៗ ។ មហាសន្និបាតនោះ គឺគ្រាន់តែបន្ថែមសេចក្តីអំពីព្រះ
វិញ្ញាណដ៏វិសុទ្ធ៖ «*យើងជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះអម្ចាស់ដែលគ្រងរាជ្យ
និងប្រទានជីវិត ។ ព្រះអង្គហូរចេញមកពីព្រះបិតា ត្រូវតែគោរពថ្វាយបង្គំព្រះ
វិញ្ញាណរួមជាមួយព្រះបិតា និងព្រះបុត្រា*» ។ នេះជាកំណើតនៃធម៌ប្រកាសជំនឿ
ម្យ៉ាងដែលគ្រីស្តបរិស័ទធ្លាប់សូត្ររៀងរាល់ថ្ងៃអាទិត្យ (ធម៌ប្រកាសជំនឿមហា
សន្និបាតនិសេ-កុងស្តង់ទីណូប្ល) ។ នៅសតវត្សទី ៨ គ្រីស្តបរិស័ទដែលនិយាយ
ភាសាឡាតាំង បន្ថែមពាក្យ «*ព្រះវិញ្ញាណហូរចេញមកពីព្រះបិតានិងព្រះបុត្រា
ដែរ*» ជាមូលហេតុមួយបណ្តាលឲ្យព្រះសហគមន៍និយាយភាសាឡាតាំង និងព្រះ
សហគមន៍និយាយភាសាក្រិក បែកពីគ្នានៅសតវត្សទី ១១ ។

នៅមហាសន្និបាតកុងស្តង់ទីណូប្លនោះ អភិបាលក៏ឈ្លោះគ្នាដែរ គឺលោកខ្លះ
មិនព្រមទទួលស្គាល់លោក**គ្រេគ័រ**ជាអភិបាលព្រះសហគមន៍កុងស្តង់ទីណូប្ល ព្រោះ
កាលពីមុន លោកជាអភិបាលព្រះសហគមន៍នៅណាស៊ីយង្សជាក្រុងតូចមួយ ។
លោកគ្រេគ័រឆ្អែតចិត្តក៏ទៅរស់នៅឯស្រុកដើមរបស់លោក ។ ពួកគេក៏ជ្រើសរើស
មន្ត្រីដែលចូលនិវត្តហើយតែងតាំងជំនួសវិញ ។

នៅឆ្នាំដដែល នៅអាគីឡេ (ក្បែរក្រុងទ្រីយ៉ែស Trieste) ព្រះចៅអធិរាជ
**ក្រាស៊ីយ៉ាំង** (Gratien) កោះហៅមហាសន្និបាតសម្រាប់អភិបាលនៅបស្ចិមប្រទេស
តែមានអភិបាលចំនួនតិចទេចូលមកប្រជុំ ។ គេទម្លាក់អស់លោកអភិបាលដែល
កាន់តាមលោកអរីយ៉ូស ហើយទូលសូមព្រះចៅអធិរាជប្រើអំណាច ដើម្បីបង្ខំគេ 57
ឲ្យអនុវត្តតាមការសម្រេចនេះ ។ លទ្ធិលោកអរីយ៉ូស បាត់បណ្តើរៗពីចក្រភព គឺ
ស្ថិតនៅតែប្រទេសអាល្លឺម៉ង់ប៉ុណ្ណោះ ។

ទោះបីអស់លោកអភិបាលរិះគិតវែកញែកតាមបែបមិនសូវសមគួរនឹងឋានៈ
របស់ខ្លួនជាគ្រីស្តបរិស័ទក្តី ក៏ការជជែកវែកញែកនេះ បានជួយបញ្ជាក់លទ្ធិអំពី
ព្រះត្រៃឯក គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណជាព្រះជាម្ចាស់តែមួយព្រះអង្គ
គត់ គឺព្រះបីអង្គរួមគ្នាជាអង្គតែមួយ ។

# មហាសន្និបាតនៅកុងស្តង់ទីណូប្លូ (គ.ស. ៣៨១)

## 55 ព្រះវិញ្ញាណពិតជាព្រះជាម្ចាស់

*នៅក្នុងចំណោមព្រះនាមទាំងប៉ុន្មាន ដែលយើងតែងតែសំដៅទៅលើព្រះជាម្ចាស់ តើមានព្រះនាមណាមួយមិនសមនឹងព្រះវិញ្ញាណឬទេ? ពេលយើងពោល ពេលយើងបង្រៀនអំពីព្រះនាមទាំងនោះ ពេលយើងបន្ថែមព្រះនាមថា «ព្រះដ៏ជួយការពារមួយអង្គទៀត» (យហ ១៤,១៦) ដូចយើងពោលថា ព្រះវិញ្ញាណជាព្រះជាម្ចាស់ទីពីរ ។ យើងដឹងថា អ្នកប្រមាថព្រះវិញ្ញាណ គឺប្រព្រឹត្តអំពើបាបដែលលើកលែងទោសមិនបាន (មថ ១២,៣១) ។ យើងក៏ដឹងហើយថា លោកអណាញ៉ាស និងភរិយាឈ្មោះសាភីរ៉ា ទទួលទោសយ៉ាងធ្ងន់ ព្រោះកុហកព្រះវិញ្ញាណដ៏វិសុទ្ធ គឺកុហកព្រះជាម្ចាស់ មិនមែនកុហកមនុស្សទេ (កក ៥) ។ ដូច្នេះ នៅពេលយើងប្រកាសថា ព្រះវិញ្ញាណជាព្រះជាម្ចាស់ តើអ្នកជឿសេចក្ដីនេះ ឬសេចក្ដីផ្សេងទៀត? ប្រសិនបើអ្នកនៅតែមានចិត្តសង្ស័យ បើត្រូវគេបង្រៀនអ្នកអំពីសេចក្ដីនេះ អ្នកពិតជាគ្មានប្រាជ្ញាសោះ និងនៅឆ្ងាយពីព្រះវិញ្ញាណទៀតផង ។*

*លោកគ្រេគ័រជាអភិបាលក្រុងណាស៊ីយ៉ង្ស*
*"ពាក្យវែកញែកអំពីទេវវិជ្ជា"*

## 56 ប្រជាជនទូទៅតែងតែជជែកវែកញែកអំពីទេវវិជ្ជានៅតាមផ្លូវ

*នៅគ្រប់ទីកន្លែងក្នុងក្រុង តាមផ្លូវតូចធំ តាមផ្លូវបំបែកសុទ្ធតែឮនិយាយអំពីសេចក្ដីទាំងនោះ ។ អ្នកលក់ខោអាវ អ្នកដូរលុយ អ្នកលក់ឥវ៉ាន់ចាប់ហួយ ក៏និយាយគ្នាអំពីសេចក្ដីនេះដែរ ។ ប្រសិនបើបងប្អូនសួរអ្នកដូរលុយ គាត់នឹងឆ្លើយដោយវែកញែកអំពីព្រះអង្គដែលកើតមក និងអំពីព្រះអង្គមិនដែលកើតនោះវិញ ។ ប្រសិនបើបងប្អូនសួរគេអំពីគុណភាពនិងតម្លៃនំប៉័ង អ្នកលក់មុខជានឹងឆ្លើយថា «ព្រះបិតាមានឋានៈធំជាងហើយព្រះបុត្រាក៏ចុះចូលក្រោមអំណាចព្រះបិតាដែរ» ។ ប្រសិនបើបងប្អូនសួរអ្នកកាន់កាប់អាងហែលទឹក គេរៀបចំទឹករួចហើយឬនៅ គាត់មុខជានឹងឆ្លើយថា ព្រះបុត្រាកើតមកពីសូន្យ ។*

*ខ្ញុំមិនដឹងថា ត្រូវដាក់ឈ្មោះការប្រព្រឹត្តបែបអាក្រក់នេះយ៉ាងណាទេ ជាការវក់វង្វេងស្មារតី ឬរោគលេលាវិញ (...) ។*

*លោកគ្រេគ័រ ជាអភិបាលក្រុងនីស្ស*
*"ព្រះបុត្រា និងព្រះវិញ្ញាណជាព្រះជាម្ចាស់"*

## 57 អភិបាលព្រះសហគមន៍ឈ្លោះប្រកែកគ្នាឥតបានការសោះ

លោក**គ្រេគ័រ**ជាអភិបាលព្រះសហគមន៍នៅណាស៊ីយ៉ង្សខិតខំបង្រួបបង្រួមអភិបាលទាំងអស់ ឲ្យមកជជែកវែកញែកជាមួយគ្នា ។

*លោកអភិបាលទាំងអស់និយាយប៉ប៉ាច់ប៉ប៉ោច ដូចសត្វចាបរកសំបុក ។ អស់លោកបន្លឺសំឡេងដូចក្មេងបន្លឺស្គររកងរំពង ឬដូចសំឡេងជាងក្នុងរោងថ្មី ឬដូចសន្ទុះខ្យល់ព្យុះដែលបក់ធ្លូលីយ៉ាងខ្លាំង (...) ។ ពួកលោកជជែកគ្នាដោយគ្មានសណ្ដាប់ធ្នាប់ ដូចសត្វឱម៉ាល់ចូលសំបុក ។ លោកចាស់ៗគួរឲ្យគោរព មិនព្រមនាំលោកក្មេងៗឲ្យបេះប្រមាណទេ ផ្ទុយទៅវិញ ធ្វើតាមពួកគេទៀត (...) ។*

*លោកគ្រេគ័រ ជាអភិបាលនៅក្រុងណាស៊ីយ៉ង្ស*
*"កំណាព្យអំពីជីវិតលោក" ខ. ១៦៨០ត*

# ២_ តើសភាវៈរបស់ព្រះជាម្ចាស់ និងសភាវៈរបស់មនុស្ស ជាប់គ្នាក្នុងអង្គព្រះយេស៊ូគ្រីស្តយ៉ាងដូចម្តេច?

## ១- ដើមអាទិ៍នៃការវែកញែកអំពីព្រះគ្រីស្ត

ពេលអស់លោកអភិបាលយល់ស្របគ្នានឹងប្រកាសថា ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធស្មើគ្នា គ្រីស្តបរិស័ទខ្លះសួរថា តើសភាវៈរបស់ព្រះបន្ទូលជាព្រះជាម្ចាស់ផ្សំជាមួយសភាវៈជាមនុស្សក្នុងអង្គព្រះយេស៊ូយ៉ាងដូចម្តេច? ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានព្រះជន្មគង់នៅអស់កល្បជានិច្ច តែព្រះយេស៊ូប្រសូតព្រះអង្គរងទុក្ខលំបាក និងសោយទិវង្គត ។ តើយើងអាចនិយាយថា ព្រះជាម្ចាស់ប្រសូត ព្រះអង្គស្រេកឃ្លាន ព្រះអង្គរងទុក្ខលំបាក និងសោយទិវង្គតបានឬទេ? ប្រសិនបើក្នុងអង្គព្រះយេស៊ូ យើងបំបែកសភាវៈព្រះជាម្ចាស់ ចេញពីសភាវៈជាមនុស្សឲ្យដាច់ស្រឡះពីគ្នា តើយើងនិយាយអំពីព្រះជាម្ចាស់ប្រសូតជាមនុស្សដូចម្តេចបាន? តើព្រះបន្ទូលទទួលយកសាច់ឈាមជាមនុស្សពិតប្រាកដឬយ៉ាងណា? តើព្រះយេស៊ូគ្រាន់តែជាព្រះជាម្ចាស់និមិត្តជាមនុស្សឬយ៉ាងណា? សំណួរទាំងនេះមានសារៈសំខាន់រហូតមកដល់សព្វថ្ងៃ ដើម្បីរិះគិតអំពីជម្រៅនៃការសង្គ្រោះ ។

លោក**អាប៉ូលីណែរ** (Appolinaire) អភិបាលព្រះសហគមន៍ក្រុងឡៅឌីសេ (ប្រទេសស៊ីរី គ.ស. ៣១០-៣៩០) ជាមិត្តជិតស្និទ្ធស្នាលរបស់លោក**អាថាណាស្ស** យល់និងគិតតាមមនុស្សវិជ្ជាសម័យនោះថា ព្រះយេស៊ូដូចមនុស្សឯទៀតៗទាំងអស់ គឺព្រះអង្គមានសាច់ឈាម រូបកាយដែលមានជីវិត ហើយក៏មានវិញ្ញាណដែរ ។ ប៉ុន្តែ ក្នុងអង្គព្រះយេស៊ូ ព្រះបន្ទូលជាវិញ្ញាណរបស់ព្រះអង្គ ។ ដូច្នេះ ព្រះយេស៊ូមិនអាចប្រព្រឹត្តអំពើបាបបានទេ ដោយហេតុថា ព្រះអង្គគ្មានវិញ្ញាណមនុស្សសុទ្ធសាធ ដែលអាចប្រព្រឹត្តអំពើបាប និងអាចវង្វេងបានឡើយ ។

មិនសូវយូរប៉ុន្មាន គ្រីស្តបរិស័ទខ្លះយល់ឃើញថា លោកអាប៉ូលីណែរ បំបាត់អត្ថន័យនៃការសង្គ្រោះឲ្យសាបសូន្យ ព្រោះថា «*មានតែអ្វីដែលព្រះគ្រីស្តទទួលយកប៉ុណ្ណោះទេ ដែលទទួលការសង្គ្រោះពីព្រះអង្គ*» ។ ប្រសិនបើព្រះគ្រីស្តគ្មានវិញ្ញាណសុទ្ធសាធដូចមនុស្សធម្មតាដូច្នេះ ព្រះអង្គមិនអាចសង្គ្រោះចិត្តគំនិតមនុស្សបានឡើយ ។ គេដាក់ទោសលោកអាប៉ូលីណែរ ជាច្រើនលើកជាច្រើនសា ។

### *ព្រះគ្រីស្តជាអង្គតែមួយ តែមានសភាវៈពីរយ៉ាង*

ពេលនោះ អស់លោកអភិបាលចាប់អារម្មណ៍តាមផ្លូវពីរយ៉ាងគឺ៖

នៅអាឡិចសង់ឌ្រី គេគូសសង្កត់ថា ព្រះគ្រីស្តជាអង្គតែមួយ មិនត្រូវញែកអ្វីក្នុងព្រះអង្គឡើយ ។ គេនិយាយថា ព្រះគ្រីស្តជាព្រះបន្ទូល *(គឺមានសភាវៈរបស់ព្រះជាម្ចាស់)* ដែលទទួលសាច់ឈាមមនុស្សឡើង ។ ដូច្នេះ ព្រះអង្គអាចប្រោសមនុស្សឲ្យបានទៅជាបុត្រធីតារបស់ព្រះជាម្ចាស់បាន ។

នៅអន់ទីយ៉ូកវិញ គេសង្កត់លើសភាវៈពីរក្នុងអង្គព្រះគ្រីស្តតែមួយព្រះអង្គ គឺព្រះគ្រីស្តមានសភាវៈជាព្រះជាម្ចាស់ផង និងមានសភាវៈជាមនុស្សផង តែជាអង្គតែមួយ ។ គេចង់បញ្ជាក់ថា ព្រះយេស៊ូជាមនុស្សដ៏ពិតប្រាកដដូចមនុស្សឯទៀតទាំងអស់ ។ សម័យនោះ ពាក្យពេចន៍ដែលគេប្រើមិនទាន់មានអត្ថន័យច្បាស់លាស់នៅឡើយទេ គឺគេប្រើពាក្យ «*សភាវៈ*» (*ហ្វីស៊ីស physis*) ដោយគេយល់តាមអត្ថន័យផ្សេងពីគ្នា គឺអ្នកខ្លះយល់ឃើញថា ព្រះយេស៊ូមាន «*ជាតិសភាវៈ*» តែមួយគត់ ។ រីឯអ្នកខ្លះទៀតយល់ឃើញថា ព្រះយេស៊ូមាន «*ជាតិសភាវៈ*» ពីរ

Layout Histor.qxd 2/10/07 10:09 AM Page 104

ផ្សេងគ្នា ។ អភិបាលពីរនាក់ គឺលោក**ណេស្តូរីយ៉ូស**និងលោក**ស៊ីរីល**ខ្វែងគំនិតគ្នា បែបនេះទាស់ទែងគ្នាយ៉ាងខ្លាំង បណ្ដាលឲ្យកើតជម្លោះមួយយ៉ាងធ្ងន់ ។

លោកណេស្តូរីយូស (Nestorius) កើតនៅក្រុងអន់ទីយ៉ូក ជាអភិបាលព្រះសហគមន៍នៅកុងស្តង់ទីណូប្លូ ។ ប្រហែលនៅ គ.ស. ៤២៨ លោកជំទាស់នឹងការគោរពនាង**ម៉ារី** តាមរបៀបប្រជាប្រិយថា នាងម៉ារីគឺជាព្រះមាតាព្រះជាម្ចាស់ (Théotokos) ។ លោកជំទាស់ថា ពាក្យនេះគ្មានចែងក្នុងព្រះគម្ពីរទេ នាងម៉ារីគ្រាន់តែជាព្រះមាតារបស់លោកយេស៊ូជាមនុស្សម្នាក់ប៉ុណ្ណោះ ។

តែផ្ទុយទៅវិញ លោកស៊ីរីលជាអភិបាលក្រុងអឡិសង់ឌ្រីចង់បញ្ជាក់ថា ព្រះគ្រីស្តជាអង្គតែមួយ បែងចែកគ្នាឯងមិនកើត តាមជំនឿគ្រីស្តបរិស័ទទូទៅ ។ លោកប្រកាន់ថា ព្រះគ្រីស្តមាន «*សភាវៈ*» តែមួយ ។ លោកស៊ីរីលទាក់ទងជាមួយលោក**សេលែស្តាំង** (Célestin) ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម ។ លោកសេលែស្តាំងក៏ដាក់ទោសលោកណេស្តូរីយ៉ូស (ឆ្នាំ ៤៣០) ។ ពេលនោះ លោកស៊ីរីលសូមលោកណេស្តូរីយ៉ូសចុះហត្ថលេខាលើសេចក្ដីប្រកាសមួយបញ្ជាក់ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងជាតិជាមនុស្សជ្រៀតគ្នាជាសភាវៈតែមួយក្នុងអង្គព្រះយេស៊ូ ។ លោកណេស្តូរីយ៉ូសហៅសម្លាញ់របស់លោកនៅក្រុងអន់ទីយ៉ូក (មានលោក**យ៉ូហាន**និងលោក**ទេអូដូរែត**) ហើយចោទប្រកាន់លោកស៊ីរីលថា លោកកាន់តាមលោក**អាប៉ូលីណែរ**វិញ ។ ព្រះសហគមន៍ជ្រួលច្របល់ដូច្នេះ ខែវិច្ឆិកា គ.ស. ៤៣០ ព្រះចៅអធិរាជ**ទេអូដូស ទី ២** កោះហៅអស់លោកអភិបាលឲ្យចូលរួមប្រជុំជាមហាសន្និបាតនៅក្រុងអេភេសូ ។ ទ្រង់សុំឲ្យមានអភិបាលតំណាងពីព្រះសហគមន៍គ្រប់ស្រុកក្នុងចក្រភពចូលរួមប្រជុំ ។ ទ្រង់អញ្ជើញលោកសេលែស្តាំង (Célestin) ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូមឲ្យចូលរួម ទ្រង់ក៏អញ្ជើញលោក**អូគូស្តាំង**ជាអភិបាលក្រុងហ៊ីប៉ូន (នៅទ្វីបអាហ្វ្រិកឲ្យមកដែរ) តែលោកទទួលមរណភាពតាំងពីខែសីហាក្នុងឆ្នាំដដែលទៅហើយ ។

## ២- មហាសន្និបាតក្រុងអេភេសូ (គ.ស ៤៣១)

មហាសន្និបាតក្រុងអេភេសូ មានដំណើរការជ្រួលច្របល់ជាខ្លាំង ។ លោក 58
ស៊ីរីល មកដល់អេភេសូ ក្នុងគោលបំណងទម្លាក់លោកណេស្តូរីយ៉ូស ពីមុខតំណែងជាអភិបាលកុងស្តង់ទីណូប្លូ ។ គ្មាននរណាហ៊ានជំទាស់នឹងលោកទេ ពីព្រោះលោកតែងតែប្រើគ្រប់មធ្យោបាយ ដើម្បីការពារមុខតំណែងរបស់ខ្លួន ដោយស្មានថាការពារជំនឿរបស់ព្រះសហគមន៍ដែរ ។ លោកស៊ីរីល នាំអភិបាលជាតិអេស៊ីបប្រមាណហាសិបនាក់ដែលកាន់ជើងលោក និងនាំយកអំណោយមួយចំនួនធំមកចែកសូកអភិបាលឯទៀតដែរ ។ ទោះបីពេលក្រោយព្រះសហគមន៍គោរពលោកស៊ីរីល ទុកជាសន្តបុគ្គលម្នាក់ក្ដី ក៏កិច្ចការលោកធ្វើនោះមិនល្អទាល់តែសោះ ។

ទោះបីលោកអភិបាលជាច្រើនអវត្តមាននៅថ្ងៃបើកមហាសន្និបាតក្ដី ហើយទោះបីតំណាងព្រះចៅអធិរាជ និងអភិបាលប្រហែល ៦០ នាក់ ជំទាស់ក្ដី ក៏លោកស៊ីរីលបើកមហាសន្និបាតនៅថ្ងៃទី ២២ មិថុនា គ.ស. ៤៣១ ដែរ ។ លោកអភិបាលប្រមាណ ២០០ នាក់ ទម្លាក់លោកណេស្តូរីយ៉ូស ហើយចាត់ទុកលោកជាយូដាថ្មីជាអ្នកវង្វេងជំនឿ ។ល។ បណ្ដាជននាំគ្នាសម្ដែងអំណរសប្បាយយ៉ាងខ្លាំង ហើយហែហមអស់លោកអភិបាលទាំងកាន់ប្រទីប និងទៀន ទៅលំនៅដ្ឋានរបស់អស់លោក ។ គ្រីស្តបរិស័ទយល់ឃើញថា ព្រះគ្រីស្តបានឈ្នះការវង្វេងជំនឿមែន ។

ពេលនោះ អ្នកកាន់តាមលោកណេស្តូរីយ៉ូស មួយចំនួន និងលោកអភិបាលដែលមិនចូលចិត្តរបៀបចាត់ចែងរបស់លោកស៊ីរីលមកដល់ ។ ពួកគេក៏ដាក់ទោសលោកស៊ីរីល និងបក្សពួកលោក ។ ពេលនោះគ្មាននរណាដឹងច្បាស់ថា អភិបាលណាមិនត្រូវទទួលទោសទេ គឺគេចោទគ្នាទៅវិញទៅមក ។ តំណាងព្រះចៅអធិរាជនឹកគិតថា នឹងទម្លាក់ទាំងលោកស៊ីរីល ទាំងលោកណេស្តូរីយ៉ូស ដើម្បីឲ្យគេស្រុះស្រួលគ្រប់គ្នាវិញ ។ តែលោកស៊ីរីលរត់រួច ហើយចូលអាឡិចសង់ឌ្រី ក្នុងឋានៈជាអ្នកឈ្នះ ។ រីឯលោកណេស្តូរីយ៉ូសវិញ ត្រូវគេនិរទេសរហូតដល់ពេល

Layout Histor.qxd 2/10/07 10:09 AM Page 105

លោកទទួលមរណភាព ។ ជម្លោះនេះមិនសមនឹងឋានៈគ្រីស្តបរិស័ទសោះ ។

### *តើត្រូវជឿគោលលទ្ធិមហាសន្និបាតអេភេសូឬយ៉ាងណា?*

មហាសន្និបាតនៅអេភេសូ មិនសូវយកចិត្តទុកដាក់បញ្ជាក់អំពីគោលលទ្ធិនៃជំនឿប៉ុន្មានទេ គឺអស់លោកអភិបាលគ្រាន់តែដាក់ទោសលោក**ណេស្តូរីយ៉ូស**ជាផ្លូវការប៉ុណ្ណោះ ។ តាមពិត មហាសន្និបាតនេះគាំទ្រមហាសន្និបាតនៅនីសេ និងគូសសង្កត់លើអង្គព្រះគ្រីស្តជាមនុស្សផង ជាព្រះជាម្ចាស់ផង គឺជាព្រះអង្គតែមួយ ។

តាំងពីពេលនោះមក គេមិនប្រកែកអំពីពាក្យ«*ព្រះមាតារបស់ព្រះជាម្ចាស់*»ទៀតទេ ។ សូម្បីតែនៅ គ.ស. ៤៣៣ លោក**យ៉ូហាន**ជាអភិបាលអន់ទីយ៉ូក និងជាអ្នកប្រឆាំងនឹងលោក**ស៊ីរិល**ផ្ដល់យោបល់មួយដើម្បីឲ្យគេរួមគ្នា ស្រុះស្រួលគ្នាថា៖ «*សភាវៈទាំងពីររួមគ្នា (...) ហេតុនេះទើបយើងប្រកាសថា ព្រះនាងព្រហ្មចារិនីជាព្រះមាតាព្រះជាម្ចាស់ ព្រោះព្រះបន្ទូលព្រះជាម្ចាស់យកសាច់ឈាម និងកើតជាមនុស្ស*» ។ លោកស៊ីរីលយល់ព្រមយ៉ាងរីករាយ លោក**ស៊ីសត៍** (Xyste) ជាអភិបាលក្រុងរ៉ូមសរសើរលោកទាំងពីរ ដែលយល់ព្រមទទួលពាក្យនេះ ។

58

## មហាសន្និបាតនៅក្រុងអេភេសូ តាមលោកសូក្រាត

*ព្រះចៅអធិរាជផ្សព្វផ្សាយព្រះរាជក្រិត្យ ទ្រង់បញ្ជាអស់លោកអភិបាលមកប្រជុំមហាសន្និបាតនៅអេភេសូ ។ លោក**ណេស្តូរីយ៉ូស**មកដល់ក្រោយបុណ្យចម្លងបន្តិច ដោយមានប្រជាជនជាច្រើនមកជាមួយផង ។ លោកជួបអភិបាលជាច្រើន ។ លោក**ស៊ីរីល**ជាអភិបាលក្រុងអាឡិចសង់ឌ្រីមកយឺតជាង គឺលោកមកដល់នៅពេលបុណ្យថ្ងៃទីហាសិប ។ លោក**យូវេណាល** (Juvénal) ជាអភិបាលយេរូសាឡឹម មកដល់ប្រាំថ្ងៃក្រោយបុណ្យនោះ ដោយលោក**យ៉ូហាន**ជាអភិបាលអន់ទីយ៉ូកមកយឺតពេក អស់លោកអភិបាលចាប់ផ្ដើមរិះគិតអំពីសំណុំរឿងនេះ ។*

*លោកស៊ីរីលចាប់ផ្ដើមការជជែកវែកញែក ហាក់ដូចជាយកពាក្យសំដីមកវាយសម្រុក ដើម្បីផ្ចាញ់លោកណេស្តូរីយ៉ូស ដែលលោកមិនស្រឡាញ់ ។ ដោយអភិបាលជាច្រើនប្រកាសថា ព្រះយេស៊ូគ្រីស្តពិតជាព្រះជាម្ចាស់ លោកណេស្តូរីយ៉ូសនិយាយថា៖ «ខ្ញុំមិនអាចហៅក្មេងអាយុ ២-៣ ខែ ថា ព្រះជាម្ចាស់បានទេ ហេតុនេះហើយ បានជាខ្ញុំមិនទទួលខុសត្រូវលើអស់លោក ។ តាំងពីពេលនេះតទៅ ខ្ញុំមិនជួបអស់លោកទៀតទេ» ។ លោកប្រជុំតែជាមួយអភិបាលណាដែលស្របតាមគំនិតលោក ។ រីឯអស់លោកអភិបាលដែលប្រជុំក្នុងមហាសន្និបាតជាមួយលោកស៊ីរីល កោះហៅលោកណេស្តូរីយ៉ូសឲ្យមកដោះសាខ្លួន តែលោកមិនព្រមចូលមក គឺលោកចាំលោកយ៉ូហានជាអភិបាលអន់ទីយ៉ូកមកដល់ ទើបលោកទៅ ។*

*លោកស៊ីរីលនិងអភិបាលដទៃទៀតពិនិត្យនិងពិចារណាធម្មទេសនារបស់លោកណេស្តូរីយ៉ូស អំពីរឿងនេះ ហើយយល់ឃើញថា លោកប្រមាថព្រះយេស៊ូគ្រីស្តហើយ ។ ដូច្នេះ អស់លោកក៏ទម្លាក់លោកណេស្តូរីយ៉ូសពីមុខតំណែងជាអភិបាល ។ រីឯអស់លោកអភិបាលខាងលោកណេស្តូរីយ៉ូសប្រជុំគ្នាដោយឡែក ក៏ទម្លាក់លោកស៊ីរីលនិងលោក**មឹមណុង** (Memnon) ជាអភិបាលអេភេសូដែរ ។ លោកយ៉ូហានជាអភិបាលអន់ទីយ៉ូកក៏មកដល់ លោកអន់ចិត្តទាំងបោទលោកស៊ីរីលថា លោកបង្កើតការជ្រួលច្របល់ ដោយទម្លាក់លោកណេស្តូរីយ៉ូសលឿនពេក ។ លោកស៊ីរីលក៏រួមជាមួយលោកយូវេណាលទម្លាក់លោកយ៉ូហានដើម្បីសងសឹក ។ នៅពេលលោកណេស្តូរីយ៉ូសឃើញថា ជម្លោះនោះខ្លាំងពេក បណ្ដាលឲ្យព្រះសហគមន៍បែកបាក់គ្នា លោកនឹកស្ដាយក្រោយអំពីអ្វីៗដែលកើតកន្លងមក ក៏មានប្រសាសន៍ថា៖ «ឲ្យគេហៅនាងម៉ារីថា ជាព្រះមាតារបស់ព្រះជាម្ចាស់តាមចិត្តគេចុះ ឲ្យតែបញ្ឈប់ការឈ្លោះប្រកែកគ្នា» ។ ទោះបីលោកផ្លាស់ប្ដូរគំនិតក៏ដោយ ក៏គ្មានអភិបាលណាម្នាក់សុខចិត្តទទួលលោកវិញដែរ លោកត្រូវគេនិរទេសនៅអូអាស៊ី (Oasis) ជាកន្លែងលោករស់នៅ (...) ។*

*ពេលលោកយ៉ូហានត្រឡប់ទៅអន់ទីយ៉ូកវិញ លោកប្រជុំអភិបាលជាច្រើន ហើយទម្លាក់លោកស៊ីរីល ដែលត្រឡប់ទៅអាឡិចសង់ឌ្រីវិញដែរ ។ តែនៅពេលក្រោយ លោកទាំងពីររួមគំនិតគ្នា ហើយតែងតាំងគ្នាឡើងវិញ ឲ្យកាន់មុខតំណែងតាមកន្លែងរៀងៗខ្លួន ។ ការទម្លាក់លោកណេស្តូរីយ៉ូស បណ្ដាលឲ្យព្រះសហគមន៍នៅកុងស្តាំងទីណូប្លមានភាពជ្រួលច្របល់ គ្រីស្តបរិស័ទខ្វែងគំនិត និងបែកបាក់គ្នា (...) ។*

*លោកសូក្រាត "ប្រវត្តិព្រះសហគមន៍" ៧,៣៤*

## ៣- មហាសន្និបាតកាលសេដូន (គ.ស ៤៥១)

លោកអភិបាលនៅតែជជែករកខុសត្រូវតទៅទៀត រហូតដល់មហាសន្និបាតកាលសេដូន ។ គូបដិបក្ខជ្រុលនិយមនៅតែមិនសុខចិត្តនឹងកិច្ចព្រមព្រៀងនេះ ។ ក្រោយពីគូបដិបក្ខដ៏សំខាន់ទទួលមរណភាពទៅ ជម្លោះក៏កើតឡើងសាជាថ្មីទៀត ។

លោក**ទេអូដូរ៉ែត** (Théodoret) ជាអភិបាលក្រុងសៀរ ស្រុកស៊ីរី នៅប្រកាន់ជានិច្ចថា ព្រះគ្រីស្តមានសភាវៈពីរ ដោយមិនពន្យល់យ៉ាងច្បាស់ថា *«ព្រះគ្រីស្តមានសភាវៈពីរក្នុងអង្គតែមួយ តែសភាវៈទាំងពីរនោះមិនលាយឡំគ្នា»* ។

លោក**អឺទីគែស** (Eutychès) ជាបព្វជិតចាស់ជរាម្នាក់នៅក្រុងកុងស្តង់ទីណូប្លូ លោកប្រកាសថា ក្នុងអង្គព្រះគ្រីស្ត សភាវៈជាព្រះម្ចាស់លេបយកសភាវៈជាមនុស្ស ។ ហេតុនេះ រូបកាយរបស់ព្រះគ្រីស្តមិនមានជាតិរូបកាយដូចមនុស្សយើងទេ ។ លោក**ផ្លាវីយ៉ាំង** (Flavien) ជាអភិបាលក្រុងកុងស្តង់ទីណូប្លូ កោះហៅសន្និបាត ដាក់ទោសលោកអឺទីគែស និងបណ្តេញលោកចេញពីព្រះសហគមន៍ ។ លោកអឺទីគែស តវ៉ាសូមឡើងសំណុំរឿងទៅលោក**ឡេអូ** (Léon) ជាអភិបាលក្រុងរ៉ូម និងលោក**ឌីយ៉ូសគ័រ** (Dioscore) ជាអភិបាលអាឡិចសង់ឌ្រី ។

### *ក- « ការឆក់ដណ្តើម » នៅអេភេសូ*

ព្រះចៅ**ទេអូដូស**ទី ២ ជាមិត្តសម្លាញ់របស់លោកអឺទីគែស កោះហៅលោកអភិបាលមកប្រជុំជាមហាសន្និបាត ទ្រង់អញ្ជើញតែអភិបាលដែលគាំទ្រលោកអឺទីគែសប៉ុណ្ណោះ រួមនឹងអភិបាលព្រះសហគមន៍ក្រុងរ៉ូម ។ លោក**ឡេអូ**ចាត់ឲ្យតំណាងរបស់លោកអានសេចក្តីស្តីអំពីព្រះជាម្ចាស់ប្រសូតជាមនុស្ស ក្រោមចំណងជើងថា «*លិខិតផ្ញើលោក**ផ្លាវីយ៉ាំង***» ។ លោកឡេអូមានគោលជំហរច្បាស់លាស់ថា ព្រះគ្រីស្តមានរូបកាយដ៏ពិតប្រាកដ ដែលមានសភាវៈជាមនុស្សដូចព្រះមាតារបស់ព្រះអង្គ ។ ដូច្នេះ ព្រះអង្គរក្សាទុកសភាវៈទាំងពីរ ដែលជួបគ្នាធ្វើជាបុគ្គលតែមួយព្រះអង្គ ។ តែតាមភាសាឡាតាំង គ្រីស្តបរិស័ទក៏បានបញ្ជាក់ជាយូរយារណាស់មកហើយថា *«សភាវៈ»* និង *«បុគ្គល»* *(Nature-Personne)* ខុសប្លែកពីគ្នា តែតាមភាសាក្រិក គេមិនទាន់បញ្ជាក់ឲ្យច្បាស់នៅឡើយទេ *(ហ្វូសីស និងហ៊ីបូស្តាសីស)* ។ មានអភិបាលគាំទ្រលោកអឺទីគែសជាច្រើន ចូលរួមមហាសន្និបាតនៅអេភេសូនោះនា គ.ស. ៤៤៩ ។ ក្នុងចំណោមអភិបាលទាំងនោះ មានលោក**ឌីយ៉ូសគ័រ**ជាអភិបាលក្រុងអាឡិចសង់ឌ្រី ដែលនាំបព្វជិតជាច្រើនប្រុងវាយគេ ។ តំណាងអភិបាលព្រះសហគមន៍ក្រុងរ៉ូមមិនចេះភាសាក្រិក មិនអាចបញ្ចេញយោបល់បានទេ ។ នៅពេលប្រជុំកក្រើករំពើក គេទម្លាក់លោកផ្លាវីយ៉ាំងពីមុខតំណែងជាអភិបាល ព្រមទាំងអស់លោកដែលប្រកាន់ថា ព្រះគ្រីស្តមានសភាវៈពីរ ។ លោកផ្លាវីយ៉ាំងត្រូវរបួសនៅពេលវាយគ្នា កងនគរបាលក៏ធ្វើអន្តរាគមន៍ដែរ ។ ក្រោយមក លោកក៏ទទួលមរណភាព ។ លោកទេអូដូរ៉ែតតវ៉ាសុំឡើងសំណុំរឿងទៅអភិបាលក្រុងរ៉ូម ។ លោកឡេអូតូចចិត្តចំពោះ *«ការឆក់ដណ្តើមនៅអេភេសូ»* នេះ ។

### *ខ- មហាសន្និបាតនៅកាលសេដូន*

ព្រះចៅ**ម៉ាស៊ីយ៉ាំង** (Marcien) ស្នងរាជ្យថ្មី ហើយផ្លាស់ប្តូររបៀបគ្រប់គ្រងសាសនា ។ ព្រះអង្គសុំលោកឡេអូមកធ្វើជាប្រធានក្នុងមហាសន្និបាតមួយ ។ ប៉ុន្តែលោកឡេអូមិនអាចចេញពីក្រុងរ៉ូមបានទេ ព្រោះជនជាតិហ៊ុន (Hun) ចូលលុកលុយពាសពេញបស្ចិមប្រទេសហើយ ។ លោកក៏ចាត់តំណាងម្នាក់ឲ្យទៅចូលរួមក្នុងមហាសន្និបាតនៅក្រុងកាលសេដូន (Chalcédoine គ.ស. ៤៥១) ស្ថិតនៅត្រើយម្ខាងប្រកសមុទ្របូសហ្វ័រ (Bosphore) នៅទល់មុខកុងស្តង់ទីណូប្លូ ។ ពេលនោះ អភិបាលព្រះសហគមន៍ក្រុងរ៉ូមធ្វើជាប្រធានក្នុងមហាសន្និបាតសកលលើកទី ១ ។ គូបដិបក្ខបុរាណទាំងពីរក្រុមនៅទល់មុខគ្នាក្នុងអង្គប្រជុំដោយមានព្រះគម្ពីរខណ្ឌ

Layout Histor.qxd 2/10/07 10:09 AM Page 107

គ្នា ។ មហាសន្និបាតតែងតាំងលោក**ផ្លាវីយ៉ាំង**សាជាថ្មី ។ គេអានធម៌ប្រកាសជំនឿមហាសន្និបាតនីសេ-កុងស្តង់ទីណូប្ល ដែលត្រឡប់ទៅជាគោលនៃជំនឿ ។ គេក៏អានលិខិតរបស់លោក**ស៊ីរិល** និង «*លិខិតលោក**ឡេអូ**ផ្ញើជូនលោកផ្លាវីយ៉ាំង*» ។
59 អត្ថបទនេះនាំឲ្យគេសប្បាយរីករាយជាខ្លាំង គេបន្លឺសំឡេងថា «*នេះជាជំនឿរបស់បុព្វបុរស! នេះជាជំនឿរបស់ក្រុមគ្រីស្តទូត! យើងទាំងអស់គ្នាក៏ជឿដូច្នេះដែរ ។ សូមបណ្តេញអស់អ្នកដែលមិនជឿដូច្នេះ ។ លោកឡេអូមានប្រសាសន៍តាមលោកសិលា (...) ។ លោកស៊ីរីលក៏បង្រៀនដូច្នេះដែរ (...) ។ លោកឡេអូនិងលោកស៊ីរីលក៏បង្រៀនដូចគ្នាដែរ*» ។

គេទម្លាក់លោក**ឌីយ៉ូស្គ័រ**ចេញពីមុខងារជាអភិបាល រួចនិរទេសលោក ។ គេដាក់ទោសអស់លោកដែលចូលរួមក្នុង «*ការឆក់ដណ្តើមនៅអេភេសូ*» ហើយយកធម៌ប្រកាសជឿ យោងពី «*លិខិតផ្ញើជូនទៅលោកផ្លាវីយ៉ាំង*» ទុកជាធម៌ប្រកាសជំនឿជាផ្លូវការរបស់ព្រហសហគមន៍ ជាធម៌ប្រកាសជំនឿដែលយើងសូត្រសព្វថ្ងៃ ។ អស់លោកអភិបាលពង្រីកធម៌ប្រកាសជំនឿ មហាសន្និបាតនីសេ-កុង 60
ស្តង់ទីណូប្ល គឺព្រះយេស៊ូជាបុគ្គលតែមួយ តែមានសភាវៈពីរផ្សេងគ្នា ។ ដូច្នេះ ចាប់ពីពេលនោះរហូតមក ព្រះសហគមន៍រិះគិតអំពីគ្រីស្តវិជ្ជាតាមគោលជំហរនេះ ។

ប៉ុន្តែ នៅពេលវប្បធម៌ផ្លាស់ប្តូរ ត្រូវតែស្រាវជ្រាវរកពាក្យបន្ថែមជាថ្មីតាមសម័យ ។ នៅមហាសន្និបាតកាលសេដូន អស់លោកអភិបាលសម្រេចអំពីចំណុចខ្លះខាងសីលធម៌ ។ ព្រះចៅអធិរាជប្រៀបដូចជា «ព្រះចៅកុងស្តង់តាំងថ្មី» យល់ស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាត ។ រីឯលោកឡេអូ ជាអភិបាលក្រុងរ៉ូម ទទួលស្គាល់តែសេចក្តីសម្រេចអំពីគោលលទ្ធិប៉ុណ្ណោះ ។

## 59 ការបញ្ជាក់គោលលទ្ធិតាមមហាសន្និបាតកាលសេដូន (គ.ស. ៤៥១)

*(...) ធម៌ប្រកាលជំនឿនៃមហាសន្និបាតនីសេ-កុងស្តង់ទីណូប្លប្រកបដោយគតិបណ្ឌិតគ្រប់គ្រាន់ ឲ្យមនុស្សលោកស្គាល់អំពីជំនឿយ៉ាងពេញលេញ ដែលនាំការសង្គ្រោះនិងពង្រឹងជំនឿដ៏ពិតប្រាកដ ដោយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអម្ចាស់ (...) ។ ប៉ុន្តែ ដោយអ្នកខ្លះចង់បំផ្លាញការបង្រៀនអំពីសេចក្តីពិត វង្វេងពីជំនឿនិងបង្កើតលទ្ធិដ៏ឥតបានការ គឺអ្នកខ្លះហ៊ានបង្ខូចគម្រោងការណ៍ដ៏អស្ចារ្យ អំពីព្រះអម្ចាស់ប្រសូតជាមនុស្សសម្រាប់យើង ដោយបដិសេធហៅនាងម៉ារីថា ព្រះមាតារបស់ព្រះជាម្ចាស់ អ្នកខ្លះនាំការលាយឡំ និងច្រឡំដោយស្រមៃយ៉ាងលេលាថា សាច់ឈាមមនុស្សនិងសភាវៈជាព្រះជាម្ចាស់ គឺជាសភាវៈតែមួយ ហើយសន្និដ្ឋានយ៉ាងអាក្រក់បំផុតថា សភាវៈព្រះជាម្ចាស់របស់ព្រះបុត្រាតែមួយ អាចរងទុក្ខលំបាកបាន ។*

*ហេតុដូចនេះហើយ បានជាមហាសន្និបាតសកលដ៏វិសុទ្ធជួបជុំគ្នានៅទីនេះ បង្រៀនលទ្ធិដែលមិនចេះប្រែប្រួលតាំងពីដើមរៀងមក ដែលមានបំណងបំបាត់កលល្បិចទាំងអស់របស់ពួកគេប្រឆាំងនឹងសេចក្តីពិត ។ ជាដំបូងមហាសន្និបាតសម្រេចថា មិនត្រូវប៉ះពាល់នឹងជំនឿរបស់អស់លោកអភិបាលទាំង ៣១៨ នាក់ដែលប្រជុំនៅនីសេទេ ។ មហាសន្និបាតគាំទ្រសេចក្តីបង្រៀនអំពីព្រះវិញ្ញាណ ដោយអភិបាល ១៥០ នាក់ ជួបជុំគ្នានៅរាជធានីព្រះចៅ (កុងស្តង់ទីណូប្ល គ.ស. ៣៨១) ។ ចំពោះអ្នកប្រឆាំងនឹងព្រះវិញ្ញាណ គឺអស់លោកប្រកាសឲ្យគ្រីស្តបរិស័ទគ្រប់គ្នាថាអស់លោកមិនចង់បន្ថែមអ្វីលើសេចក្តីដែលអស់លោកបានបង្រៀនកាលពីមុននោះឡើយ ហាក់បីដូចជាខ្វះសេចក្តីខ្លះ ។ អស់លោករៀបរាប់យ៉ាងក្បោះក្បាយ នូវគំនិតអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ដោយសំអាងលើព្រះគម្ពីរ ប្រឆាំងនឹងអស់អ្នកដែលខិតខំលះបង់ឋានៈរបស់ព្រះវិញ្ញាណជាព្រះអម្ចាស់ (...) ។ យើងធ្វើតាមអស់លោកដ៏វិសុទ្ធពីបុរាណ សូមបង្រៀនជាឯកច្ឆ័នថា មានព្រះបុត្រាតែមួយអង្គដដែល គឺព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើង ព្រះអង្គមានសភាវៈជាព្រះជាម្ចាស់យ៉ាងពេញលេញ ព្រះអង្គមានសភាវៈជាមនុស្សយ៉ាងពេញលេញដែរ ព្រះអង្គពិតជាព្រះជាម្ចាស់ផង និងពិតជាមនុស្សផង មានវិញ្ញាណចេះគិតគូរ មានរូបកាយ មានសភាវៈតែមួយរួមជាមួយព្រះបិតាតាមសភាវៈជាព្រះជាម្ចាស់ និងមានសភាវៈតែមួយរួមនឹងយើង តាមសភាវៈ*

Layout Histor.qxd 2/10/07 10:09 AM Page 108

*ជាមនុស្សដូចយើងបេះបិទ លើកលែងតែបាបចេញ ។ ព្រះអង្គមានដើមកំណើតពីព្រះបិតាមក មុនសម័យកាលទាំងអស់ តាមឋានៈជាព្រះជាម្ចាស់ ។ ប៉ុន្តែ នៅគ្រាចុងក្រោយបង្អស់ ព្រះអង្គប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ជាព្រះមាតារបស់ព្រះជាម្ចាស់ តាមឋានៈជាមនុស្ស ។ ព្រះអង្គជាព្រះគ្រីស្ដតែមួយព្រះអង្គគត់ដដែល ជាព្រះបុត្រា ជាព្រះអម្ចាស់ ជាព្រះបុត្រាតែមួយ ។ យើងទទួលស្គាល់ថាព្រះអង្គមានសភាវៈពីរមិនលាយឡំគ្នា មិនប្រែប្រួល មិនបែងចែក មិនផ្ដាច់ចេញពីគ្នា ។ សភាវៈទាំងពីរនោះមិនបាត់ដោយរួមជាមួយគ្នាទេ ផ្ទុយទៅវិញ លក្ខណៈនៃសភាវៈនីមួយៗនោះនៅដដែល ហើយជួបគ្នាក្នុងបុគ្គលឬមនុស្សតែម្នាក់ (...) ។*

## ***គ- នៅក្នុងចក្រភពរ៉ូម៉ាំង***

រាជរដ្ឋាភិបាលកុងស្តង់ទីណូប្ល បង្ខំឲ្យប្រជាជនគោរពតាមលទ្ធិដ៏ត្រឹមត្រូវនៃមហាសន្និបាតកាលសេដូន ។ ប៉ុន្តែ មានអ្នកស្រុកឬតំបន់ជាច្រើនមិនព្រមគោរពតាមដើម្បីបង្ហាញថា គេទាមទារឯករាជ្យខាងវប្បធម៌និងខាងសាសនា គេមិនព្រមធ្វើតាមគំនិតចក្រពត្តិនិយមវប្បធម៌ក្រិកនៃរាជការកុងស្តង់ទីណូប្លទេ ។ ឧ. នៅស្រុកអេស៊ីប គ្រីស្តបរិស័ទដែលស្មោះត្រង់នឹងលោក**ឌីយ៉ូស្គ័រ** និងលោក**ស៊ីរីល** សម្រេចកាន់តាមលទ្ធិប្រកាសថា ព្រះគ្រីស្តមានសភាវៈតែមួយ (Monophysites) ដើម្បីតាំងសាសនាប្រទេសរបស់ខ្លួនសម្រាប់គ្រីស្តបរិស័ទដែលនិយាយភាសាកុប្ត (Copte) ។ ចំណែកគ្រីស្តបរិស័ទដែលកាន់តាមលទ្ធិមហាសន្និបាតកាលសេដូនវិញ សុទ្ធតែជាជនភាគតិចដែលនិយាយភាសាក្រិក ហើយដែលមានទំនាក់ទំនងនឹងរដ្ឋអំណាច ។ នៅស៊ីរីក៏ដូច្នេះដែរ គឺគ្រីស្តបរិស័ទសម្រេចចិត្តយកលទ្ធិប្រកាសថា ព្រះគ្រីស្តមានសភាវៈតែមួយដដែលនោះ មកធ្វើជាសាសនាគ្រីស្តបរិស័ទដែលនិយាយភាសាស៊ីរីដែរ ។ រីឯអ្នកដែលគោរពតាមលទ្ធិកាលសេដូនទទួលឈ្មោះថា «*អ្នករាជានិយម*» (Melkites) ។ គ្រីស្តបរិស័ទដែលប្រកាន់ថា ព្រះគ្រីស្តមានសភាវៈតែមួយ តែងសូត្រធម៌ប្រកាសជំនឿរបស់នីសេ-កុងស្តង់ទីណូប្ល នៅក្នុងពិធីផ្សេងៗដើម្បីបង្ហាញថា ពួកគេស្មោះស្ម័គ្រនឹងប្រពៃណីបុរាណ ។



*នាវានៅកំពង់ផែ អូស្ទីយ៉ា ប្រទេសអ៊ីតាលី (នៅសតវត្សទី ៤-៥)*

Layout Histor.qxd 2/10/07 10:09 AM Page 109

### *ឃ- នៅខាងក្រៅចក្រភព*

ព្រះសហគមន៍តាមតំបន់ក្បែរព្រំដែនខាងបូព៌ា សុទ្ធសឹងតែជ្រើសរើសយកគោលលទ្ធិស្ដីអំពីព្រះគ្រីស្ដមានសភាវៈតែមួយ ឬគោលលទ្ធិតាមលោក**ណេស្ដូរីយ៉ូស** មកពីកាលៈទេសៈនយោបាយ ឬដោយបែជន្យ ។ នៅចុងសតវត្សទី ៥ ព្រះចៅអធិរាជបិទទេវវិទ្យាល័យក្រុងអេដេស (Edesse) ដោយទ្រង់យល់ថា ពួកគេបង្រៀនគោលលទ្ធិរបស់លោកណេស្ដូរីយ៉ូស ។ ទេវវិទ្យាល័យនោះតាំងទីស្ថិតនៅនីស៊ីបក្នុងទឹកដីពែរ្ស ។ មហាសន្និបាតក្រុងក្លេស៊ីផុង (Clésiphon ឆ្នាំ ៤៨៦) លទ្ធិលោកណេស្ដូរីយ៉ូស ក្លាយជាសាសនាផ្លូវការរបស់គ្រីស្ដបរិស័ទនៃចក្រភពពែរ្ស ព្រោះគ្រីស្ដបរិស័ទក្នុងចក្រភពពែរ្សនឹកគិតថា ដោយជឿតាមលទ្ធិនោះ គេជៀសវាងការចោទប្រកាន់ថា ពួកគេជាអ្នកស៊ើបការណ៍បម្រើព្រះចៅអធិរាជកុងស្ដង់ទីណូប្លូ ។ គ្រីស្ដបរិស័ទនិកាយលោកណេស្ដូរីយ៉ូសនៅចក្រភពពែរ្ស ផ្ដាច់ខ្លួនពីបស្ចិមប្រទេស ហើយចេញទៅប្រកាសដំណឹងល្អយ៉ាងឆ្ងាយរហូតដល់អាស៊ីកណ្ដាល និងប្រទេសចិន ។ សិលាចារឹកមួយនៅស៊ីញ៉ាំងហ្វូ (Si-Ngan-Fou) ជារាជធានីប្រទេសចិននៅសម័យនោះ ចារនៅ គ.ស. ៧៨១ ជាភាសាស៊ីរីនិងភាសាចិន បញ្ជាក់ថា និកាយណេស្ដូរីយ៉ូសយកចិត្តទុកដាក់ខ្នះខ្នែងប្រកាសដំណឹងល្អនៅស្រុកចិន ។ ចំពោះជនជាតិអាមេនី (Arménie) វិញ គេជ្រើសរើសយកគោលលទ្ធិអំពីព្រះគ្រីស្ដមានសភាវៈតែមួយ ដើម្បីប្រឆាំងនឹងជនជាតិពែរ្សដែលកាន់តាមនិកាយណេស្ដូរីយ៉ូស និងជនជាតិក្រិកនៅក្រុងកុងស្ដង់ទីណូប្លូ ។ ជនជាតិអេត្យូពីក៏គោរពតាមព្រះសហគមន៍នៅអាឡិចសង់ឌ្រីដែលកាន់តាមគោលលទ្ធិនោះដែរ ។

ព្រះចៅអធិរាជសង្ឃឹមជានិច្ចថា នឹងប្រមែប្រមូលប្រជាជនឲ្យរួបរួមគ្នាតាមគោលនយោបាយតែមួយ និងឲ្យមានសាសនាតែមួយដែរ ។ ព្រះចៅតែងតែរកពាក្យសម្របសម្រួល ប៉ុន្តែ មិនបានលទ្ធផលតាមរាជបំណងទេ ។ ផ្ទុយទៅវិញ ព្រះអង្គបណ្ដាលឲ្យកើតមានជម្លោះថ្មី គេតែងតែប្រើហឹង្សាកាន់តែខ្លាំងឡើងៗ ។ មហាសន្និបាតពីរលើកទៀត (កុងស្ដង់ទីណូប្លទី ២ នៅគ.ស. ៥៥៣ និងកុងស្ដង់ទីណូប្លទី ៣ នៅ គ.ស. ៦៨១) រិះគិតអំពីគោលលទ្ធិស្ដីពីព្រះគ្រីស្ដ ។ កុងស្ដង់ទីណូប្លទី ៣ ដាក់ទោសនិកាយវង្វេងជំនឿថ្មីដែលប្រកាន់ថា ព្រះគ្រីស្ដមានព្រះហឫទ័យតែមួយគត់ (Monothélisme) និងព្រះអង្គប្រព្រឹត្តិគ្រប់កិច្ចការដោយមានឫទ្ធានុភាពតែមួយដែរ (Monoénergisme) ។

## ៤- ព្រះសហគមន៍ដែលបែកបាក់មុនគេ

ទោះបីជាមហាសន្និបាតនៅក្រុងកាលសេដូនបញ្ចេញសេចក្ដីមិនខ្លាំងពេកក្ដី ក៏សេចក្ដីសុខសាន្តមិនកើតឡើងភ្លាមក្នុងព្រះសហគមន៍ដែរ ។ មហាសន្និបាតមិនអាចដោះស្រាយបញ្ហានានាម្ដងរួចជាស្រេចបានឡើយ ។ ការជជែកវែកញែកឈ្លោះប្រកែកគ្នាអំពីព្រះគ្រីស្ដនៅតែមាន ។ អ្នកប្រឆាំងនឹងសេចក្ដីប្រកាសរបស់មហាសន្និបាតកាលសេដូន បែកចេញពីព្រះសហគមន៍ ។ មានគ្រីស្ដបរិស័ទមួយចំនួនស្មានថា គេកាន់ស្មោះតាមលោក**ស៊ីរីល**ដោយប្រកាន់ថា ព្រះគ្រីស្ដមានសភាវៈតែមួយប៉ុណ្ណោះ (Monophysites) ។ រីឯព្រះសហគមន៍ដែលកាន់តាមលោក**ណេស្ដូរីយ៉ូស** វិញយល់ឃើញថា ព្រះគ្រីស្ដមានសភាវៈជាមនុស្សផង និងសភាវៈជាព្រះជាម្ចាស់ផង ។ ប៉ុន្តែ ត្រូវប្រុងប្រយ័ត្នកុំចោទទោសគេថា គេវង្វេងពីជំនឿឡើយ ព្រោះនៅសម័យនោះ ព្រះសហគមន៍នានាបាក់បែកគ្នា មកពីរឿងនយោបាយជាជាងមកពីគោលលទ្ធិនៃជំនឿ ។ ព្រះចៅក្រុងកុងស្ដង់ទីណូប្លបង្ខំគ្រីស្ដបរិស័ទឲ្យកាន់តាម *«លទ្ធិដ៏ត្រឹមត្រូវ» (Orthodoxe)* មកពីមហាសន្និបាតកាលសេដូន ។ រីឯតំបន់ជាច្រើន មិនព្រមកាន់តាមជំនឿនេះ ដើម្បីទាមទារសិទ្ធិសេរីភាពខាងវប្បធម៌ និងខាងសាសនាឲ្យរួចផុតពីអរិយធម៌ក្រិកនៃបរមរាជវាំងកុងស្ដាំងទីណូប្ល ។ ដូច្នេះ ពួកគេបង្កើតព្រះសហគមន៍ដែលប្រកាន់ថា ព្រះគ្រីស្ដមានសភាវៈតែមួយគត់ ។

Layout Histor.qxd 2/10/07 10:09 AM Page 110

# គ_ របៀបចាត់ចែងព្រះសហគមន៍ និង ទំនាក់ទំនងរវាងព្រះសហគមន៍នានា

មហាសន្និបាតសកលទាំងប៉ុន្មាន មិនគ្រាន់តែបញ្ជាក់អំពីគោលលទ្ធិគ្រីស្តសាសនាប៉ុណ្ណោះទេ គឺហុចឱកាសឲ្យអភិបាលព្រះសហគមន៍ទូទាំងចក្រភពជួបគ្នា ។ ព្រះសហគមន៍នីមួយៗមានទំនៀមទម្លាប់ប្រពៃណីរៀងៗខ្លួនតាមតំបន់ ។ មហាសន្និបាតនៅសតវត្សទី ៤ និងទី ៥ ធ្វើឲ្យរបៀបចាត់ចែងព្រះសហគមន៍នានាចុះសម្រុងគ្នា ជាពិសេសអំពីការតែងតាំងអភិបាល និងអំពីទំនាក់ទំនងរវាងព្រះសហគមន៍នានា ។

## ១- អភិបាលព្រះសហគមន៍ក្នុងស្រុក និង ទីរួមខេត្ត

តាមធម្មតា ព្រះសហគមន៍ចាត់ចែងខ្លួនឯង ស្របតាមការចាត់ចែងខាងរដ្ឋអំណាច និងខាងសេដ្ឋកិច្ចសម័យនោះ ។ អភិបាលព្រះសហគមន៍ជាអ្នកដឹកនាំគ្រីស្តបរិស័ទក្នុងក្រុងមួយ ។ អភិបាលព្រះសហគមន៍នៅក្នុងក្រុងមានសារៈសំខាន់ជាងអភិបាលព្រះសហគមន៍តាមជនបទ ។ លោកមានសិទ្ធិប្រជុំសន្និបាតនៅក្នុងតំបន់ លោកជាអ្នកទទួលស្គាល់អភិបាលឯទៀតៗដែលអ្នកភូមិជ្រើសរើ ។ មាត្រាទី ៤ នៃមហាសន្និបាតនីសេ បញ្ជាក់មុខងាររបស់លោក ។ នៅក្នុងមាត្រានោះក៏មានពន្យល់អំពីរបៀបតែងតាំងក្រុមអភិបាលដែរ ។



នៅក្នុងចំណោមព្រះសហគមន៍ មានព្រះសហគមន៍ខ្លះប្រសើរជាងព្រះសហគមន៍ឯទៀត ។ ដូច្នេះហើយ បានជាអភិបាលខ្លះខិតខំប្ដូរកន្លែងរបស់ខ្លួន ដើម្បីបានកន្លែងប្រសើរជាង ។ មាត្រាទី ១៥ នៃមហាសន្និបាតនីសេ ប្រឆាំងនឹងបំណងនេះ ។ លោកអភិបាលត្រូវយកតម្រាប់តាមព្រះគ្រីស្ត គឺត្រូវចាត់ទុកខ្លួនជាស្វាមីព្រះសហគមន៍របស់ខ្លួន ។ ដូច្នេះ លោកគ្មានសិទ្ធិចេញពីព្រះសហគមន៍មួយទៅកាន់ព្រះសហគមន៍មួយទៀតបានឡើយ ។ អ្នកដែលប្រឆាំងនឹងលោក**គ្រេគ័រ**ជាអភិបាលព្រះសហគមន៍ក្រុងណាស៊ីយ៉ង្ស សូមលោកលាលែងចេញពីមុខតំណែងជាអភិបាលកុងស្តង់ទីណូប្ល ព្រោះកាលពីមុនលោកជាអភិបាលក្រុងតូចមួយ ។ នៅពេលក្រោយ ព្រះសហគមន៍លប់មាត្រានេះ ។

## ២- ដើមកំណើតនៃអភិបាលសំខាន់ៗចំនួន ៥

ចាប់តាំងពីដើមកំណើតព្រះសហគមន៍មក អភិបាលព្រះសហគមន៍ខ្លះមានមុខងារប្រសើរជាងអភិបាលព្រះសហគមន៍ក្នុងក្រុងនិងស្រុកឯទៀតៗ គឺអភិបាលនៅក្រុងសំខាន់ៗក្នុងចក្រភព ដូចជាក្រុងរ៉ូម អាឡិចសង់ឌ្រី អន់ទីយ៉ូក និងក្រុងកាតាស្ស ។ អភិបាលព្រះសហគមន៍ក្រុងទាំងនោះ តែងតែបំពេញការងាររបស់ខ្លួនក្នុងតំបន់ដ៏ធំ គឺអស់លោកកោះហៅអភិបាលឯទៀតៗក្នុងតំបន់មកជួបជុំគ្នាជាសន្និបាត លោកតែងតាំងអភិបាលឯទៀតៗឲ្យទៅបំពេញមុខងារ ។ល។

ចាប់តាំងពីសម័យព្រះចៅ**ឌីយ៉ូក្លេស៊ីយាំង**មក ស្រុកនានារួមគ្នាជាតំបន់ធំៗដែលគេហៅថា «*ភូមិភាគ*» (នៅចុងសតវត្សទី ៤ មាន ១៥ ភូមិភាគ) ។ គេក៏ទទួលស្គាល់ថា លោកអភិបាលព្រះសហគមន៍ក្រុងអាឡិចសង់ឌ្រី និងអភិបាលព្រះសហគមន៍អន់ទីយ៉ូក មានសិទ្ធិតែងតាំងអភិបាលព្រះសហគមន៍នៅតាមភូមិភាគឯទៀតៗដែរ ។ សេចក្ដីនេះមានចែងក្នុងមាត្រា ទី ៦ នៃមហាសន្និបាតនៅនីសេ និងមាត្រាទី ២ នៃមហាសន្និបាតកុងស្តង់ទីណូប្ល ។

ដោយព្រះសហគមន៍ចាត់ចែងស្របតាមរចនាសម្ពន្ធខាងនយោបាយ ព្រះសហគមន៍ក្រុងកុងស្តង់ទីណូប្លទាមទារកិត្តិយសប្រសើរជាងគេ គឺបន្ទាប់ពីអភិបាលព្រះសហគមន៍ក្រុងរ៉ូម (*មាត្រា ៣ កុងស្តង់ទីណូប្ល*) ។ អស់លោកអភិបាលសម្រេចដូច្នេះ មិនមែនដើម្បីប្រឆាំងនឹងក្រុងរ៉ូមទេ គឺដើម្បីប្រឆាំងនឹងក្រុងអាឡិចសង់ឌ្រី

Layout Histor.qxd 2/10/07 10:09 AM Page 111

61 ដែលធ្លាប់ជាទីក្រុងទីពីរក្នុងចក្រភព និងនៅក្នុងព្រះសហគមន៍ ។ មហាសន្និបាត
បង្ហាញយ៉ាងច្បាស់ថា អភិបាលព្រះសហគមន៍អាឡិចសង់ឌ្រី មានចិត្តចចេសមានះ
62 ប្រឆាំងនឹងលោកអភិបាលព្រះសហគមន៍កុងស្តង់ទីណូប្ល ។ ព្រះសហគមន៍ក្រុងយេ
រូសាឡឹមសុំឲ្យខ្លួនបានកិត្តិយសពិសេស មកពីក្រុងនេះមានប្រវត្តិជាប់ទាក់ទងនឹង
ព្រះយេស៊ូផ្ទាល់ ។ មាត្រាទី ២៨ នៃមហាសន្និបាតកាលសេដូន បញ្ជាក់ពីអំណាច
ព្រះសហគមន៍ក្រុងកុងស្តង់ទីណូប្លលើទឹកដីដ៏ធំទូលំទូលាយ គឺមានអំណាចត្រួតត្រា
ភូមិភាគទាំងបី ពោលគឺប៉ុនតុស អាស៊ី និងត្រាស់ ព្រមទាំងតំបន់ប្រកាសដំណឹង
ល្អថ្មីៗ ។ នៅសម័យនោះ ខាងបូព៌ាមានភូមិភាគបួន គឺកុងស្តង់ទីណូប្ល អន់ទីយ៉ូក
យេរូសាឡឹម និងអាឡិចសង់ឌ្រី ។ ឯខាងបស្ចិមមានភូមិភាគតែមួយគឺរ៉ូម ។ ព្រះ
ចៅ**យ៉ូស្ទីញាំង** (Justinien) តែងតាំងភូមិភាគទាំងប្រាំនោះតាមច្បាប់ ។

## ៣- ព្រះសហគមន៍ក្រុងរ៉ូមជាប្រមុខព្រះសហគមន៍សកល

រហូតដល់សតវត្សទី ៦ គ្មានចែងអំពីមុខងារអភិបាលព្រះសហគមន៍ក្រុងរ៉ូមក្នុងឋានៈជាប្រមុខព្រះសហគមន៍សកលទេ ។ គ្រីស្តបរិស័ទនៅសម័យនោះតែងតែហៅអភិបាលព្រះសហគមន៍របស់ខ្លួនយ៉ាងស្និទ្ធស្នាលថា «*ប៉ាប*» ជាពាក្យដែលគេធ្លាប់ប្រើក្នុងគ្រួសារ មានន័យថា «*លោកតា*» ។

នៅបស្ចិមប្រទេស អភិបាលព្រះសហគមន៍ក្រុងរ៉ូមមានមុខងារប្រហែលនឹងអភិបាលក្រុងអាឡិចសង់ឌ្រីនៅខាងបូព៌ា ដែលណែនាំព្រះសហគមន៍ស្រុកអេស៊ីបនិងស្រុកលីប៊ីដែរ ។ ប៉ុន្តែ តាំងពីដើមរៀងមក ព្រះសហគមន៍ក្រុងរ៉ូមមានឋានៈពិសេសក្នុងព្រះសហគមន៍សកល ព្រោះគ្រីស្តទូត**សិលា**និង**ប៉ូល**មករស់នៅក្នុងព្រះសហគមន៍នោះ ហើយជាពិសេស មកពីក្រុងរ៉ូមជារាជធានីចក្រភពរ៉ូម៉ាំងដែរ ។ ម៉្យាងទៀត អភិបាលព្រះសហគមន៍ក្រុងរ៉ូម តែងតែចូលដៃធ្វើអន្តរាគមន៍ក្នុងការរស់នៅរបស់ព្រះសហគមន៍ឯទៀតៗដែរ ។ ឧបមាថា នៅគ.ស. ៩៦ លោក**ក្លេម៉ង់**ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម ស្តីបន្ទោសគ្រីស្តបរិស័ទខ្លះនៅក្នុងព្រះសហគមន៍កូរិនថូស ដែលទម្លាក់ក្រុមព្រឹទ្ធាចារ្យពីមុខតំណែងរបស់គេ ។ នៅគ.ស. ១៩០ លោក**វិកទ័រ** (Victor) បណ្តេញអភិបាលខ្លះដែលប្រារព្ធពិធីបុណ្យចម្លងនៅថ្ងៃផ្សេងពីក្រុងរ៉ូមចេញពីព្រះសហគមន៍ ។ លោក**ស្ទេផាន**ជាអភិបាលក្រុងរ៉ូម ស្តីបន្ទោសលោក**ស៊ីព្រីយ៉ាំង** ព្រោះគាត់ធ្វើអគ្គសញ្ញាជ្រមុជទឹកសារជាថ្មីជូនដល់អ្នកបោះបង់ជំនឿ នៅពេលរដ្ឋអំណាចបៀតបៀតធ្វើបាបគ្រីស្តបរិស័ទ ។ល ។ ជួនកាលព្រះសហគមន៍តាមតំបន់មិនពេញចិត្តនឹងអន្តរាគមន៍នោះទេ ។

ម៉្យាងទៀត ព្រះសហគមន៍នៅបូព៌ាទាំងអស់ តែងតែទទួលស្គាល់ថា ព្រះសហគមន៍ក្រុងរ៉ូមមានកិត្តិយសលើសគេ ។ យូរៗម្តង នៅពេលកើតបញ្ហាលំបាក គេអញ្ជើញអភិបាលព្រះសហគមន៍ក្រុងរ៉ូម ឲ្យជួយដោះស្រាយបញ្ហារបស់គេ ។ ឧបមាថា លោក**បាស៊ីល**អញ្ជើញអភិបាលក្រុងរ៉ូម មកជួយដោះស្រាយវិបត្តិដែលកើតមកពីលោក**អរីយ៉ូស** ។ គេអញ្ជើញលោក**ឡេអូ**មកជួយដោះស្រាយការជជែកវែកញែកអំពីព្រះគ្រីស្ត ។

អស់លោកអភិបាលព្រះសហគមន៍ក្រុងរ៉ូមមិនសូវសប្បាយចិត្ត ដោយយល់
ឃើញថា ព្រះសហគមន៍ក្រុងកុងស្តង់ទីណូប្លមានមុខងារនិងកិត្តិយសកាន់តែខ្ពស់
ឡើងៗ ។ អស់លោកខ្លាចថា ដោយមុខងារខាងនយោបាយរបស់ក្រុងរ៉ូមអន់ថយ
មុខងារនិងកិត្តិយសព្រះសហគមន៍របស់អស់លោកក៏ត្រូវអន់ថយដែរ ។ ហេតុនេះ
ហើយ បានជាចាប់ពីពាក់កណ្តាលសតវត្សទី ៤ អស់លោកអភិបាលក្រុងរ៉ូមនាំគ្នា 63
រំឭកថា មុខងារដ៏ប្រសើររបស់អស់លោក មកពីអស់លោកបន្តមុខងារតពីលោក
**សិលា**មក ហើយអស់លោកដាក់ឈ្មោះទីតាំងរបស់អស់លោកថា «*អាសនៈរបស់
គ្រីស្តទូត*» (Siège apostolique) ។ លោកឡេអូដ៏ប្រសើរឧត្តម មិនព្រមទទួល
ស្គាល់មាត្រាទី ២៨ នៃមហាសន្និបាតសកលកាលសេដូនទេ ព្រោះលោកនឹកគិតថា
អភិបាលក្រុង កុងស្តង់ទីណូប្ល លាតត្រដាងអំណាចខ្លាំងពេក ។

Layout Histor.qxd  2/10/07  10:09 AM  Page 112

# ការចាត់ចែងព្រះសហគមន៍ និងទំនាក់ទំនងរវាងព្រះសហគមន៍នានា

## 60 មាត្រានៃមហាសន្និបាតនីសេ (គ.ស. ៣២៥)

*៤- អភិបាលព្រះសហគមន៍ គឺអភិបាលទាំងអស់នៅក្នុងស្រុកតែងតាំង ។ បើមានករណីដ៏ចាំបាច់ជាបន្ទាន់ ឬផ្លូវឆ្ងាយពេក ត្រូវមានអភិបាលបីនាក់ជួបជុំគ្នាដាក់ដៃពីលើ ហើយត្រូវមានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអភិបាលឯទៀតៗដែលអវត្តមាន ។ អភិបាលព្រះសហគមន៍ក្នុងទីរួមខេត្តនីមួយៗមានសិទ្ធិបញ្ជាក់អភិបាលជាផ្លូវការ ។*

*៦- សូមរក្សាទម្លាប់ចាស់នៅស្រុកអេស៊ីប និងស្រុកលីប៊ី គឺថាអភិបាលព្រះសហគមន៍អាឡិចសង់ឌ្រី នៅរក្សាអំណាចលើអភិបាលព្រះសហគមន៍ខេត្តទាំងនោះ ដ្បិតអស់លោកមានទំនាក់ទំនងរបៀបនេះជាមួយនឹងអភិបាលព្រះសហគមន៍ក្រុងរ៉ូមដែរ ត្រូវទុកសិទ្ធិព្រះសហគមន៍អន់ទីយ៉ូក និងព្រះសហគមន៍ផ្សេងទៀតឲ្យមានសិទ្ធិដូចពីដើមដែរ (...) ។*

*១៥- ការទាស់ទែងខ្វែងគំនិតគ្នា ការបែកបាក់គ្នា នាំឲ្យយើងយល់ឃើញថា ត្រូវតែបំបាត់ប្រពៃណីប្រទេសខ្លះ ដែលផ្ទុយនឹងវិន័យ គឺយើងហាមអភិបាល បូជាចារ្យ និងឧបដ្ឋាកផ្លាស់ប្ដូរកន្លែងពីក្រុងមួយទៅក្រុងមួយទៀត ។ បើនរណាធ្វើខុសក្រិត្យនេះ និងវង្វេងតាមទម្លាប់បុរាណនោះ យើងប្រកាសថា ការតែងតាំងថ្មីពិតជាឥតបានការ ហើយគេត្រូវតែត្រឡប់មកព្រះសហគមន៍ដើម ព្រោះគេនឹងតែងតាំងអភិបាល ឬបូជាចារ្យ ដើម្បីបម្រើព្រះសហគមន៍នោះវិញ ។*

## 61 មាត្រានៃមហាសន្និបាតនៅកុងស្តង់ទីណូប្លូ (គ.ស. ៣៨១)

*២- អភិបាលភូមិភាគព្រះសហគមន៍មួយ មិនត្រូវចូលប្រឡុកក្នុងរឿងព្រះសហគមន៍ក្រៅពីព្រះសហគមន៍របស់ខ្លួនទេ ហើយមិនត្រូវបណ្ដាលឲ្យខូចរបៀបរៀបរយព្រះសហគមន៍ទាំងនោះដែរ ។ អនុលោមតាមមាត្រាទាំងនេះ លោកអភិបាលព្រះសហគមន៍អាឡិចសង់ឌ្រីត្រួតត្រាតែកិច្ចការនៅក្នុងស្រុកអេស៊ីបប៉ុណ្ណោះ ។ អស់លោកអភិបាលព្រះសហគមន៍នៅបូព៌ាប្រទេសត្រួតត្រាតែកិច្ចការនៅភូមិភាគបូព៌ា ទាំងគោរពបុព្វសិទ្ធិព្រះសហគមន៍អន់ទីយ៉ូក ដូចមានចែងក្នុងមាត្រានៃមហាសន្និបាតក្រុងនីសេ ។ អស់លោកអភិបាលព្រះសហគមន៍ស្រុកអាស៊ី ត្រួតត្រាតែកិច្ចការនៅស្រុកអាស៊ីប៉ុណ្ណោះ អភិបាលព្រះសហគមន៍ខាងប៉ុនតុស ត្រួតត្រាតែកិច្ចការខាងតំបន់ប៉ុនតុស អស់លោកអភិបាលព្រះសហគមន៍ស្រុកត្រាស់ ត្រួតត្រាតែកិច្ចការនៅខាងស្រុកត្រាស់ប៉ុណ្ណោះ (..) ។*

*៣- អភិបាលព្រះសហគមន៍នៅកុងស្តង់ទីណូប្លូ ត្រូវមានកិត្តិយសប្រសើរជាងគេ បន្ទាប់ពីអភិបាលព្រះសហគមន៍ក្រុងរ៉ូម ព្រោះក្រុងកុងស្តង់ទីណូប្លូនេះជាក្រុងរ៉ូមថ្មី ។*

## 62 មាត្រាទី ២៨ នៃមហាសន្និបាតនៅកាលសេដូន (គ.ស. ៤៥១)

*តាមក្រិត្យក្រមទាំងអស់របស់លោកអភិបាលដ៏វិសុទ្ធ និងដោយទទួលស្គាល់មាត្រា អភិបាលចំនួន ១៥០ (មហាសន្និបាតនៅកុងស្តង់ទីណូប្លូទី ២) ដែលទើបអានរួចនេះ យើងបោះឆ្នោតសម្រេច និងអនុមតិអំពីឯកសិទ្ធិរបស់ព្រះសហគមន៍ដ៏វិសុទ្ធបំផុតនៃកុងស្តង់ទីណូប្លូ ដែលជាក្រុមរ៉ូមថ្មី ។ អស់លោកអភិបាលពីដើម បានផ្ដល់ឯកសិទ្ធិព្រះសហគមន៍ក្រុមរ៉ូមចាស់ ពីព្រោះក្រុងរ៉ូមនោះជារាជធានីរបស់ព្រះចៅអធិរាជ ។ មូលហេតុដដែលនោះ អភិបាល ១៥០ នាក់ដែលគោរពប្រណិប័តន៍ព្រះជាម្ចាស់យ៉ាងខ្លាំង ក៏ផ្ដល់ឯកសិទ្ធិស្មើដល់អាសនៈដ៏វិសុទ្ធបំផុតនៃក្រុងរ៉ូមថ្មីនេះដែរ ព្រោះក្រុងនេះមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយវត្តមានព្រះចៅអធិរាជនិងព្រឹទ្ធសភានៃចក្រភព ។ ហេតុនេះហើយ បានជាក្រុងកុងស្តង់ទីណូប្លូមានបុព្វសិទ្ធិស្មើនឹងរាជធានីរ៉ូមចាស់មានសារៈសំខាន់យ៉ាងខ្លាំង នៅក្នុងកិច្ចការព្រះសហគមន៍បន្ទាប់ពីក្រុងរ៉ូមចាស់ ។ ហេតុនេះហើយ បានជាសន្តអាសនៈដ៏វិសុទ្ធបំផុតនៃព្រះសហគមន៍ដ៏វិសុទ្ធបំផុត នៃក្រុងកុងស្តង់ទីណូប្លូមានសិទ្ធិតែងតាំងអភិបាលនៅតាមភូមិភាគប៉ុនតុស ភូមិភាគអាស៊ី និងភូមិភាគត្រាស់ ព្រមទាំងអភិបាលនានាតាមតំបន់មិនទាន់មានគ្រីស្តបរិស័ទនៅឡើយ ។*

Layout Histor.qxd 2/10/07 10:09 AM Page 113

មហាសន្និបាតនៅកាលសេដូន លើកតម្កើងមុខងារអភិបាលព្រះសហគមន៍ក្រុងរ៉ូម ក្នុងការបញ្ជាក់គោលលទ្ធិនៃគ្រីស្តសាសនា ដោយថែងថា «*គ្រីស្តទូត**សិលា**មានប្រសាសន៍តាមរយៈលោក**ឡេអូ***» ។ លោកឡេអូ (*៤៤០-៤៦១*) សំអាងទៅលើអត្ថបទគម្ពីរដំណឹងល្អ (មថ ១៦,១៨-១៩) ដើម្បីពង្រីកទេវវិទ្យាអំពីមុខងារដ៏ប្រសើររបស់អភិបាលក្រុមរ៉ូមលើសអភិបាលឯទៀតៗទាំងអស់នោះ ដូចសន្និបាតក្រុងរ៉ូម នៅ គ.ស. ៣៨២ បានថែងរួចហើយ ។ លោកទាមទារសិទ្ធិនិងភារកិច្ចណែនាំព្រះសហគមន៍ទាំងមូល ក្នុងឋានៈជាអ្នកបន្តមុខងារពីលោកសិលាមក ។ អភិបាលព្រះសហគមន៍ឯទៀតៗគ្រាន់តែ «*ចូលរួមក្នុងកិច្ចណែនាំព្រះសហគមន៍តែគ្មានអំណាចពេញលេញដូចលោកទេ*» ។ លោកឡេអូយល់ឃើញថា អភិបាលព្រះសហគមន៍ក្រុងរ៉ូមជាអភិបាលនៃព្រះសហគមន៍សកល ជាអភិបាលណែនាំអស់លោកអភិបាល និងជាប្រភពនៃអំណាចរបស់អភិបាលទាំងអស់ ។ ផ្ទុយទៅវិញ នៅពេលក្រោយ លោក**គ្រេគ័រ**ដ៏ប្រសើរឧត្តម (៥៩០-៦០៤) ចាត់ទុកអភិបាលក្រុងរ៉ូម ជាអភិបាលម្នាក់ក្នុងចំណោមអភិបាលទាំងឡាយ គឺលោកគ្រាន់តែជាប្រធានអភិបាលប៉ុណ្ណោះ ។ លោកយល់ឃើញថា អភិបាលទាំងអស់រួមគ្នាណែនាំព្រះសហគមន៍ទាំងមូល ដូចអស់លោកអភិបាលនៅប៉ែកបូព៌ា ឬដូចមហាសន្និបាតវ៉ាទីកង់ទី ២ (១៩៦២-១៩៦៥) ។

## ការចាត់ចែងព្រះសហគមន៍ និងទំនាក់ទំនងរវាងព្រះសហគមន៍នានា

### 63 អភិបាលក្រុងរ៉ូមទទួលមុខតំណែងតាមព្រះបន្ទូលសន្យារបស់ព្រះយេស៊ូមកលោកសិលា

*ក្នុងពិភពទាំងមូល ព្រះគ្រីស្តបានជ្រើសរើសនិងតែងតាំងលោក**សិលា**តែម្នាក់គត់ ដើម្បីត្រាស់ហៅមនុស្សទាំងអស់ ។ ព្រះគ្រីស្តញែកតែលោកម្នាក់គត់ឲ្យធ្វើជាមេដឹកនាំក្រុមគ្រីស្តទូត និងអភិបាលព្រះសហគមន៍ទាំងអស់ ។ ដូច្នេះ ទោះបីក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់មានបូជាចារ្យនិងគង្វាលច្រើនក្តី ក៏លោកសិលាត្រួតត្រាអស់លោកដោយផ្ទាល់ ក្នុងឋានៈជាមេដឹកនាំ ដូចព្រះគ្រីស្តត្រួសត្រាយអស់លោកក្នុងឋានៈជាអ្នកដឹកនាំដែរ ។ បងប្អូនជាទីស្រឡាញ់ ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យសប្បុរស បានប្រោសប្រទានលោកសិលាឲ្យមានចំណែកនៃឫទ្ធានុភាពរបស់ព្រះអង្គយ៉ាងខ្លាំង និងយ៉ាងអស្ចារ្យ (...) ។*

*ព្រះគ្រីស្តមានព្រះបន្ទូលមកកាន់លោកសិលាថា៖ «ខ្ញុំនឹងប្រគល់កូនសោព្រះរាជ្យនៃស្ថានបរមសុខឲ្យអ្នក (...)» ។ គ្រីស្តទូតឯទៀតៗក៏បានទទួលសិទ្ធិប្រើអំណាចនេះដែរ ពិតហើយ របនាសម្ពន្ធដែលកើតមកពីព្រះបន្ទូលសម្រេចនេះ ក៏លាតដល់អភិបាលព្រះសហគមន៍នានាដែរ ។ ប៉ុន្តែ ព្រះគ្រីស្តបានប្រគល់ឲ្យលោកសិលាតែម្នាក់ នូវអំណាចដែលអស់លោកអភិបាលទទួលដែរ ។ ប្រសិនបើព្រះអង្គប្រគល់អំណាចឲ្យលោកសិលាផ្ទាល់ នោះបានសេចក្តីថា ត្រូវប្រគល់វិន័យរបស់លោកសិលាឲ្យមេដឹកនាំព្រះសហគមន៍ទាំងអស់ដែរ ។ លោកសិលារក្សាទុកឯកសិទ្ធិរបស់ខ្លួននៅគ្រប់កន្លែង ដែលលោកវិនិច្ឆ័យតាមសេចក្តីត្រឹមត្រូវ (...) ។ យើងសូមឧទ្ទិសទៅដល់លោកសិលាជាគង្វាលដ៏ល្អនៅថ្ងៃខួបដែលយើងទទួលមុខតំណែង សូមធ្វើពិធីរំឭកលោក ព្រោះលោកការពារយើង ជួយយើងឲ្យបានរួមចំណែកក្នុងមុខតំណែងរបស់លោក ។*

*លោកឡេអូដ៏ប្រសើរ "ធម្មទេសនា" ៤ (ឆ្នាំ ៩៥)*



# គ្រូបាធ្យាយនៃព្រះសហគមន៍

## គ្រីស្តបរិស័ទជាអ្នកនិពន្ធនៅសតវត្សដើមដំបូង

*ក្នុងជំពូកមុនៗ យើងបានរៀបរាប់អំពីព្រឹត្តិការណ៍ផ្សេងៗ អំពីគោលលទ្ធិ អំពីពាក្យអធិដ្ឋានខ្លះ យោងពីអត្ថបទគ្រីស្តបរិស័ទជាអ្នកនិពន្ធ គឺមានលោក**អ៊ីសែប** លោក**ទែរទូលីយ៉ាំង** លោក**អូរីសែន** លោក**អ៊ីរ៉េណេ** លោក**អូគូស្តាំង** លោក**អាថាណាស្ស** ជាដើម ។ល ។ គ្រីស្តបរិស័ទតែងតែដាក់ឈ្មោះអ្នកនិពន្ធទាំងនោះថា «**គ្រូបាធ្យាយនៃព្រះសហគមន៍**» ។ យើងចាប់អារម្មណ៍នឹងអស់លោកទាំងនោះ មិនគ្រាន់តែមកពីអស់លោករៀបរាប់អំពីប្រវត្តិសាស្ត្រព្រះសហគមន៍ប៉ុណ្ណោះទេ គឺមកពីអស់លោកជួយឲ្យយើងរិះគិតអំពីជំនឿរបស់អស់លោក ក៏ជាជំនឿរបស់យើងសព្វថ្ងៃដែរ ។ ព្រះសហគមន៍បញ្ជូនបន្តដំណឹងល្អមកយើង មិនគ្រាន់តែបញ្ជូនបន្តព្រះគម្ពីរប៉ុណ្ណោះទេ គឺជួយពន្យល់ដំណឹងល្អនោះទៀតផង ។ មានគ្រីស្តបរិស័ទរស់នៅមុនយើង បានពន្យល់អត្ថន័យព្រះគម្ពីរនោះតាមអរិយធម៌ផ្សេងៗ ហើយអស់លោកក៏រស់នៅតាមសហគមន៍ផ្សេងៗប្លែកពីគ្នាដែរ ។*

*ក្នុងជំពូកនេះ យើងនឹងស្វែងរកសេចក្តីដែលគ្រីស្តបរិស័ទជាអ្នកនិពន្ធដើមដំបូងទាំងនោះពន្យល់មក ។ ប្រធានបទនេះទូលំទូលាយអនេក តែយើងនឹងរៀបរាប់ដោយត្រួសៗប៉ុណ្ណោះ ។*

## ក_ នរណាជាគ្រូបាធ្យាយនៃព្រះសហគមន៍

### ១- គ្រូបាធ្យាយនៃព្រះសហគមន៍

កាលពីបុរាណ គេតែងហៅគ្រូរបស់ខ្លួនថា «*ឪពុក*» ពីព្រោះគ្រូបញ្ជូនគតិបណ្ឌិត និងសីលធម៌ ឲ្យកូនសិស្ស សម្រាប់ឲ្យកូនសិស្សរស់នៅយ៉ាងថ្លៃថ្នូរ ។ ថ្វីបើព្រះយេស៊ូមិនសព្វព្រះហឫទ័យនឹងពាក្យនេះក្តី *(មថ ២៣,៨-១១)* ក៏គ្រីស្តបរិស័ទតែងតែហៅអ្នកណែនាំព្រះសហគមន៍ថា «*លោកគ្រូ*» ឬ «*លោកឪពុក*» ដែរ ។ នៅក្នុង ១ ករ ៤,១៥ លោក**ប៉ូល**ចែងថា៖ «*ទោះបីបងប្អូនមានគ្រូអាចារ្យមួយម៉ឺននាក់ណែនាំតាមមាគ៌ា ព្រះគ្រីស្តក៏ដោយ ក៏បងប្អូនគ្មានឪពុកច្រើនដែរ គឺមានតែខ្ញុំហ្នឹងហើយដែលបានបង្កើតបងប្អូនមក ឲ្យរួមរស់ជាមួយព្រះយេស៊ូគ្រីស្ត ដោយបាននាំដំណឹងល្អមកជូនបងប្អូន*» ។ លោក**អ៊ីរ៉េណេ**មានប្រសាសន៍ថា៖ «*ពេលនរណាម្នាក់ទទួលសេចក្តីបង្រៀនពីនរណាម្នាក់ទៀត គេហៅអ្នកនោះថាជាកូនអ្នកបង្រៀនគេនោះ ហើយអ្នកទទួលការបង្រៀនក៏ត្រូវហៅអ្នកបង្រៀននោះថា "លោកឪពុក" ដែរ*» ។ នៅសតវត្សដើមដំបូងៗនៃព្រះសហគមន៍ លោកអភិបាលអប់រំនិងបង្រៀនគ្រីស្តបរិស័ទដោយផ្ទាល់ គ្រីស្តបរិស័ទក៏តែងតែហៅថា

Layout Histor.qxd 2/10/07 10:09 AM Page 116

«*លោកឪពុក*» ជួនកាលគេហៅលោកអភិបាលថា «*លោកប៉ាប*» ដែរ ជាពាក្យមានន័យថា «*លោកតា*» ។ បន្ទាប់មក គេហៅអ្នកបង្រៀនឬអ្នកអប់រំជំនឿនោះថា «*លោកឪពុក*» ទោះបីអ្នកនោះមិនមែនជាអភិបាលព្រះសហគមន៍ក៏ដោយ ។ លោកឪពុកជាអ្នកបញ្ជូនបន្តសេចក្តីសុខសាន្ត និងសេចក្តីស្មោះត្រង់ដល់កូនដល់ចៅ ។ តាំងពីដើមដំបូង សហគមន៍បព្វជិតរស់នៅក្នុងវត្ត ប្រៀបដូចជាក្រុមគ្រួសារមួយ រីឯលោកដែលណែនាំក្រុមបព្វជិតទាំងនោះប្រៀបដូចជា «*ឪពុក*» ឬ «*អាប្បា*» ហើយមានមុខងារដ៏សំខាន់នៅក្នុងវត្តនោះ ។ គ្រីស្តបរិស័ទក៏តែងហៅអស់លោកនិពន្ធសៀវភៅអំពីគ្រីស្តសាសនានៅដើមដំបូងថា «*គ្រូបាធ្យាយ*» គឺជាអ្នកដែលយកចិត្តទុកដាក់តែងតាំងព្រះសហគមន៍ ដោយយកគម្ពីរមករិះគិតតាមអរិយធម៌របស់ខ្លួន ។

គ្រូបាធ្យាយនៃព្រះសហគមន៍រស់នៅសម័យក្រោយព្រះយេស៊ូបន្តិច ។ អស់លោកប្រហែលយល់ព្រះបន្ទូលច្បាស់ជាងយើងដែលរស់នៅ ២១ សតវត្សក្រោយ ។ អស់លោកតែងតែអាននិងពន្យល់គម្ពីរសម្ពន្ធមេត្រីថ្មីមុនគេបង្អស់ ហើយរាប់ព្រះគម្ពីរទុកជាអាហារសម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រីស្តបរិស័ទដែរ ។ អស់លោកក៏ពន្យល់គម្ពីរសម្ពន្ធមេត្រីចាស់ ដោយនឹកគិតដល់ព្រះគ្រីស្តជានិច្ច ក្រោមការបំភ្លឺនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។

គ្រូបាធ្យាយទាំងនោះបានបន្តបញ្ជូនជំនឿមកពីគ្រីស្តទូតមុនគេ អស់លោកពិតជាកសាងព្រះសហគមន៍ ។ ក្រោយសតវត្សទី ៨ មិនសូវមានគ្រីស្តបរិស័ទនិពន្ធអំពីជំនឿទៀតទេ ។

## ២- គ្រូបាធ្យាយព្រះសហគមន៍ពន្យល់ជំនឿតាមអរិយធម៌របស់ខ្លួន

គ្រូបាធ្យាយខ្លះបានការពារគ្រីស្តសានាពីអ្នកដែលប្រឆាំង គឺអស់លោកខិតខំពន្យល់គ្រីស្តសាសនាឲ្យអ្នកប្រឆាំងយល់បានតាមអរិយធម៌ក្រិកនិងឡាតាំងដែលប្លែកទាំងស្រុងពីអរិយធម៌យូដា ជាអរិយធម៌របស់ព្រះយេស៊ូ និងជាអរិយធម៌របស់ក្រុមគ្រីស្តទូត ។ អស់លោករិះគិតតាមគតិបណ្ឌិតក្រិក គឺតាមសីលធម៌យ៉ាងតឹងរ៉ឹងរបស់ពួកស្តូអ៊ីក (Stoïques) (*តាមទស្សនវិជ្ជារបស់លោក**សេណុង*** Zénon) ឬរិះគិតតាមទស្សនវិទូរបស់លោក**ប្លាតុង** (Platon) ។ បន្តិចម្តងៗអស់លោកបំប្រែអរិយធម៌ក្រិកនិងឡាតាំងឲ្យក្លាយទៅជាអរិយធម៌នៃគ្រីស្តសាសនា ។

គ្រូបាធ្យាយជាច្រើន រិះគិតនិងនិពន្ធសៀវភៅតាមភាសាសំខាន់ៗពីរនៅសម័យនោះ គឺភាសាក្រិកនិងភាសាឡាតាំង ។ តែនៅខាងបូព៌ាមានលោកខ្លះនិពន្ធសៀវភៅជាភាសាស៊ីរី អេស៊ីប អាម៉េនី (Syriaque, Copte, Arménien) ។ល ។ អស់លោកមានអរិយធម៌ផ្សេងៗពីគ្នា បញ្ចេញរស្មីនៃពន្លឺគ្រីស្តសាសនាតែមួយតាមរបៀបផ្សេងៗពីគ្នាតាមតំបន់រៀងៗខ្លួន ។

ព្រះសហគមន៍គោរពអស់លោកទុកជាសាក្សីពិសេស ដែលបញ្ជូនបន្តជំនឿដ៏ពិតប្រាកដ (Tradition) គឺអស់លោកឯកភាពអំពីគោលលទ្ធិសំខាន់ៗនៃជំនឿរបស់ព្រះសហគមន៍តាមសម័យនីមួយៗ ។ អស់លោកក៏រកពាក្យពេចន៍ដើម្បីពន្យល់ព្រះគម្ពីរ និងប្រកាសជំនឿស្របតាមអរិយធម៌របស់អស់លោក ។ ជួនកាលអ្នករស់នៅសម័យក្រោយ មិនយល់ស្របនឹងពាក្យពេចន៍របស់អ្នកប្រកាសជំនឿនៅសម័យមុនៗទេ ។ អ្នកសិក្សាទេវវិជ្ជាក៏ត្រូវខិតខំអានសេចក្តីដែលអស់លោកបាននិពន្ធនោះ និងរិះគិតថា អស់លោកបានធ្វើឲ្យទេវវិជ្ជាចម្រើនឡើងជាលំដាប់ ។ សូមអានសេចក្តីរិះគិតរបស់លោក**វ៉ាំងសង់** នៅ ឡេរ៉ាំង ។ 72

ប៉ុន្តែ អស់លោកជាអ្នកបាបដូចយើងដែរ ។ ឧបមា លោក**យេរ៉ូម**ជាអ្នកខ្លាំងហួស ជួនកាលលោកស្តីបន្ទោសគេដោយអយុត្តិធម៌ ។ល ។ លោក**ស៊ីរីល** ជាអភិបាលក្រុងយេរូសាឡឹម ជាមនុស្សមិនសូវល្អ ។ល ។

អស់លោកក៏ជាស់តឿនយើងជាគ្រីស្តបរិស័ទកម្ពុជា ឲ្យរិះគិតអំពីលទ្ធិនៃជំនឿរបស់យើង តាមអរិយធម៌កម្ពុជានាបច្ចុប្បន្នដែរ ។

Layout Histor.qxd 2/10/07 10:09 AM Page 117

# ១. យុគសម័យដ៏ប្រសើររបស់គ្រូបាធ្យាយនៃព្រះសហគមន៍

ក្នុងជំពូកមុនមានចែងអំពី «*គ្រូបាធ្យាយនៃព្រះសហគមន៍*» ដូចជាលោក**អ៊ីរ៉េណេ** លោក**អូរីសែន** លោក**ទែរទូលីយ៉ាំង** ។ល។ ចាប់តាំងពីមហាសន្និបាតនីសេ (គ.ស. ៣២៥) មានយុគសម័យថ្មីកើតឡើង គឺចក្រភពរ៉ូម៉ាំងប្រកបដោយសុខសន្តិភាព ហើយអស់លោកអភិបាលតែងតែជួបជុំគ្នាជាមហាសន្និបាតសកល ។ ហេតុដូច្នេះហើយបានជានៅសម័យនោះ អក្សរសាស្ត្រនៃគ្រីស្តសាសនាអាចចម្រើនបាន ។ ចាប់តាំងពីមហាសន្និបាតនៅនីសេ (គ.ស. ៣២៥) រហូតដល់មហាសន្និបាតនៅកាល់សេដូន (គ.ស. ៤៥១) ជាសម័យមានអ្នកនិពន្ធសៀវភៅខាងគ្រីស្តសាសនាជាច្រើន ។

## ១ អស់លោកមកពីបូព៌ា

មានអ្នកនិពន្ធពីខាងបូព៌ាសរសេរតាមភាសារបស់ខ្លួន ។ ក្នុងចំណោមអ្នកទាំងនោះ មានលោក**អេហ្វ្រែម**ជាអ្នកស្រុកនីស៊ីប ឬហៅថា « **លោកអេហ្វ្រែម ជាអ្នកក្រុងអេដែស** » ក៏បាន (គ.ស. ៣០៦-៣៧៣ Ephrem de Nisibe) ។

លោកអេហ្វ្រែមកើតក្នុងតំបន់មេសូប៉ូតាមី ជាតំបន់ចក្រភពរ៉ូម៉ាំងហើយចក្រភពពែរ្សតែងតែវាយគ្នាដណ្តើមយកទឹកដី ។ ពេលក្រុងនីស៊ីបធ្លាក់ទៅក្នុងកណ្តាប់ដៃកងទ័ពពែរ្ស លោកក៏ភៀសខ្លួនទៅនៅក្រុងអេដែស ដែលមានព្រះសហគមន៍បុរាណ គ្រីស្តបរិស័ទព្រះសហគមន៍នោះនិយាយភាសាស៊ីរី ។ លោកអត្ថាធិប្បាយព្រះគម្ពីរ និងចែងពាក្យអធិដ្ឋានជាភាសាស៊ីរីនៅទីនោះ ។

លោកនិពន្ធធម្មទេសនា និពន្ធសៀវភៅអត្ថាធិប្បាយព្រះគម្ពីរជាច្រើន ។ ដោយលោកជាកវីដ៏ប្រសើរ លោកក៏តែងបទចម្រៀងប្រមាណ ៤៥0 បទដែលគ្រីស្តបរិស័ទបកប្រែជាច្រើនភាសា ។ ទេវវិជ្ជារបស់លោកអេហ្វ្រែម ក៏ដូចទេវវិជ្ជាអ្នកនិពន្ធតាមភាសាស៊ីរី គឺលោកជាប់នឹងព្រះគម្ពីរយ៉ាងស្អិតរមួត មិនទាន់រិះគិតអំពីជំនឿតាមវប្បធម៌ក្រិកទេ ។ លោកទទួលមរណភាពនៅក្រុងអេដែសដោយសារជំងឺអាសន្នរោគរាតត្បាត ។ (64)

(64) **លោកអេហ្វ្រែម ជាអ្នកស្រុកនីស៊ីប (គ.ស. ៣០៦–៣៧៣)**

លោក**អេហ្វ្រែម**សរសេរកំណាព្យជាភាសាស៊ីរី ។ បទនីមួយៗមានបន្ទរ ដែលគ្រីស្តបរិស័ទចងចាំរត់មាត់ ។ ក្នុង «បទអំពីសួនអេដែន» លោកប្រៀបធៀបលោក**អដាំ**និងតួផ្សេងៗនៅក្នុងសម្ពន្ធមេត្រីចាស់ទៅនឹងព្រះគ្រីស្ត ។

***បន្ទរ*** *សូមព្រះជាម្ចាស់ប្រោសឲ្យខ្ញុំគាប់ព្រះហឫទ័យដ៏សប្បុរសរបស់ព្រះអង្គ ដើម្បីឲ្យយើងខ្ញុំអាចចូលស្ថានបរមសុខបានផង (...)*

- *លោកអដាំនៅខ្លួនទទេ លោកស្អាតណាស់ ភរិយាលោកឧស្សាហ៍ណាស់ នឿយហត់ត្បាញសម្លៀកបំពាក់ដ៏គ្មានសៅហ្មង ។*
- *សួនឧទ្យានឃើញដូច្នេះ នឹកថាអាក្រក់ ហើយដេញគាត់ទៅខាងក្រៅ ប៉ុន្តែ ព្រះជាម្ចាស់បានធ្វើអាវថ្មីសម្រាប់គាត់ ដោយសារនាងម៉ារី ។ ចោរដែលគេឆ្កាងក៏ពាក់អាវនោះតាមព្រះបន្ទូលសន្យា ហើយខ្លួនប្រាណចោរក៏ភ្លឺឡើង ។*
- *សួនឧទ្យានឃើញចោរជារូបតំណាងលោក**អដាំ** នោះក៏ឱបគាត់ លោក**ម៉ូសេ**មានចិត្តសង្ស័យ លោកឃើញទឹកដីសន្យាតែមិនបានចូលទេ ដោយមានទន្លេយ័រដាន់បិទផ្លូវ ។*
- *លោកអដាំធ្វើបាប រួចចេញពីសួននៃជីវិត ខេរូប៊ីនបិទផ្លូវមិនឲ្យចូល ប៉ុន្តែលោកអាដាំ និងលោកម៉ូសេ ក៏អាចចូលបានដោយព្រះអម្ចាស់ទទួលព្រះជន្មថ្មីដ៏រុងរឿង ។*

Layout Histor.qxd 2/10/07 10:09 AM Page 118

## ២- អ្នកនិពន្ធជាភាសាក្រិកដ៏សំខាន់

នៅសតវត្សទី ៤ អ្នកនិពន្ធសំខាន់ៗខាងគ្រីស្ដសាសនា សុទ្ធតែជាអ្នកស្ទាត់
ជំនាញខាងវប្បធម៌ក្រិក ព្រោះការជជែកវែកញែកអំពីគោលលទ្ធិគ្រីស្ដសាសនា
ដែលកើតនៅបូព៌ា ជំរុញគេឲ្យរិះគិតយ៉ាងជ្រៅអំពីទេវវិជ្ជា ។

លោក**អាថាណាស្ស** (Athanase) ចម្រើនវ័យនៅពេលលោក**អរីយ៉ូស**ផ្សព្វ
ផ្សាយលទ្ធិរបស់គាត់ គឺលោកកើតក្នុងព្រះសហគមន៍អេស៊ីបដែលបែកបាក់គ្នា ។
ក្នុងឋានៈលោកជាឧបដ្ឋាក លោកចូលរួមក្នុងមហាសន្និបាតនីសេ (គ.ស. ៣២៥)
ជាមួយលោកអភិបាលអាឡិចសង់ឌ្រី ។ នៅគ.ស. ៣២៨ លោកក៏ទទួលមុខងារ
ជាអភិបាលព្រះសហគមន៍អាឡិចសង់ឌ្រីដែរ ។ ក្នុងកំឡុងពេលលោកធ្វើជាអភិ
បាល លោកតែងតែការពារជំនឿតាមមហាសន្និបាតនីសេ ប្រឆាំងនឹងគ្រីស្ដបរិស័ទ
65 ដែលកាន់តាមលោកអរីយ៉ូស ។ គេបណ្ដេញលោកចេញពីក្រុងអាឡិចសង់ឌ្រី អស់
៥ ដង ។ ម្ដងគេនិរទេសលោកដល់ក្រុងត្រែវ (Trèves) តាមព្រំប្រទល់ចក្រភព
រ៉ូម៉ាំង ។

លោកនិពន្ធសៀវភៅដើម្បីការពារជំនឿ និងពន្យល់ទេវវិជ្ជាអំពីព្រះបន្ទូល
ប្រសូតជាមនុស្ស និងមានឋានៈស្មើនឹងព្រះបិតា ។ លោកនិពន្ធសៀវភៅជាអាទិ៍
46 «*សេចក្ដីថ្លែងអំពីព្រះបន្ទូលប្រសូតជាមនុស្ស*» ។ គ្រីស្ដបរិស័ទសន្មតថា លោក
និពន្ធ «*ជីវិតនិងឥរិយាបថរបស់លោក**អន់ទន**ជាឪពុកជីវិសុទ្ធរបស់យើង*» ។ មាន
គ្រីស្ដបរិស័ទច្រើនអនេកអានសៀវភៅនោះ ហើយគ្រីស្ដបរិស័ទមួយចំនួនធំទៅជា
បព្វជិត ។ ក្នុងចំណោមគ្រីស្ដបរិស័ទទាំងនោះមានសន្ត**អូគូស្ដាំង**ជាដើម ។

ស្រុកកាប៉ាដូសជាតំបន់កណ្ដាលអាស៊ីមីន័រ គ្រូបាធ្យាយនៃព្រះសហគមន៍
ដ៏សំខាន់បីនាក់កើតក្នុងស្រុកនោះ គឺលោក**បាស៊ីល** លោក**គ្រេគ័រ** ជាអភិបាលក្រុង
ណាស៊ីយ៉ង្ស លោកគ្រេគ័រ ជាអភិបាលព្រះសហគមន៍ក្រុងនីស្ស ហើយនិងលោក
**យ៉ូហាន គ្រីស្ដស្តូម** ជាដើម ។



*សន្ត អាថាណាស្ស*

Layout Histor.qxd 2/10/07 10:10 AM Page 119

លោក**បាស៊ីល** (Basile គ.ស. ៣៣០-៣៧៩) ជាអភិបាលក្រុងសេសារេ ។
លោកទទួលការអប់រំយ៉ាងជ្រៅខាងអក្សរសាស្ត្រ លោកទទួលអគ្គសញ្ញាជ្រមុជទឹក
កាលអាយុពេញវ័យ ។ លោករស់នៅជាបព្វជិត មុនទទួលមុខងារជាអភិបាល
ព្រះសហគមន៍នៅក្រុងកំណើតរបស់លោក (គ.ស. ៣៧០) ។ ពេលលោកបំពេញ
មុខងារជាអភិបាល លោកចាប់អារម្មណ៍នឹងទិសដៅបីដូចតទៅគឺ៖

- លោកជុំរុញឲ្យគ្រីស្តបរិស័ទសម្តែងមេត្តាករុណា គឺនៅពេលកើតទុរ្ភិក្ស លោក
បាត់ចែងកន្លែងសង្គ្រោះជនក្រីក្រជាបន្ទាន់នៅក្នុងក្រុង ។
- លោកបាត់ចែងឲ្យបព្វជិតរួមរស់ជាមួយគ្នា ។ លោកក៏និពន្ធក្បួនច្បាប់ធំនិង
តូចសម្រាប់ណែនាំអស់លោក ។
- នៅសម័យនោះ គ្រីស្តបរិស័ទជ្រួលច្របល់ដោយសារលទ្ធិរបស់លោក**អរីយ៉ូស** ។
66 លោកចាប់អារម្មណ៍លើគោលលទ្ធិជំនឿដ៏ត្រឹមត្រូវ ឲ្យព្រះសហគមន៍រួបរួមគ្នា ។
លោកពន្យល់យុវជនគ្រីស្តបរិស័ទអំពីរបៀបអានសៀវភៅ ដែលអ្នកកាន់សាសនា
ដទៃនិពន្ធ ។ លោកធ្វើអត្ថាធិប្បាយព្រះគម្ពីរ និងបញ្ជាក់មុខងារនៃព្រះវិញ្ញាណ
ក្នុងសៀវភៅមានចំណងជើងថា «*អំពីព្រះវិញ្ញាណ*» ។ លោកបាស៊ីល ជាមនុស្ស
ចេះប្រមាណ ហើយចូលចិត្តសន្ទនានឹងអ្នកមានយោបល់ផ្សេងៗ ។ គ្រីស្តបរិស័ទ
ដាក់ឈ្មោះលោកថា «*លោកបាស៊ីលដ៏ប្រសើរឧត្តម*» ។

លោក**គ្រេគ័រ**អភិបាលព្រះសហគមន៍ណាស៊ីយ៉ង្ស (Grégoire de Naziance
គ.ស. ៣៣០-៣៩០) ។ លោករស់នៅសម័យលោកបាស៊ីល និងជាមិត្តសម្លាញ់
របស់លោកដែរ ។ គេតែងតាំងលោកជាអភិបាលព្រះសហគមន៍នៅកុងស្តង់ទី
55 ណូប្ល ។ លោកគ្មានទេពកោសល្យជាអ្នកណែនាំព្រះសហគមន៍ទេ គឺមិនពូកែ
57 សម្រេចចិត្តឬបាត់ចែងអ្វីទេ ។ ផ្ទុយទៅវិញ លោកមានទេពកោសល្យនិពន្ធវិញ ។
លោកនិពន្ធសៀវភៅមានចំណងជើងថា «*សេចក្តីថ្លែងអំពីទេវវិជ្ជា*» លោកក៏
និពន្ធកំណាព្យ និងសំបុត្រជាច្រើន ។

លោក**គ្រេគ័រ** ជាអភិបាលព្រះសហគមន៍នីស្ស (Grégoire de Nysse គ.ស.
៣៣៥-៣៩៤) ជាប្អូនរបស់លោកបាស៊ីល ។ គាត់រៀបអាពាហ៍ពិពាហ៍រួចចូលបួស
ក្នុងវត្តអារាមមួយ ។ ក្រោយមកគេតែងតាំងលោកជាអភិបាលព្រះសហគមន៍នៅ
ក្រុងនីស្ស ។ លោកជាទេវវិទូដ៏ពូកែម្នាក់បំពេញមុខងារដ៏សំខាន់ក្នុងមហាសន្និបាត
កុងស្តង់ទីណូប្ល ។ លោកជាអ្នកធ្លាប់ស្មឹងស្មាធិ ហើយនិពន្ធសៀវភៅជាច្រើនអំពី
ការស្មឹងស្មាធិ៍នោះ ។ លោកសរសេរថា មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់
មានសមត្ថភាពអាចស្គាល់ព្រះជាម្ចាស់បាន និងអាចទៅរកព្រះអង្គបាន លុះត្រាតែ 67
ជម្រះចិត្តគំនិតយ៉ាងយូរ ។

លោក**យ៉ូហាន គ្រីសូស្តូម** (Jean Chrysostome គ.ស. ៣៤៥-៤០៧) ជា 68
គ្រូបាធ្យាយក្រិក ដែលនិពន្ធសេចក្តីច្រើនជាងគេ ។ លោកកើតនៅក្រុងអន់ទី
យ៉ូក ។ លោករស់នៅជាបព្វជិត នៅតាមវាលរហោស្ថាន ។ បន្ទាប់មកទទួល
មុខងារជាឧបដ្ឋាក រួចទទួលមុខងារជាបូជាចារ្យនៅព្រះសហគមន៍អន់ទីយ៉ូក ។
លោកសម្តែងធម្មទេសនាដ៏ល្បីល្បាញ ។ ទោះបីលោករួញរាមិនព្រមក្តី ក៏នៅ
គ.ស. ៣៩៧ គេតែងតាំងលោកជាអភិបាលព្រះសហគមន៍កុងស្តង់ទីណូប្លដែរ ។
លោកមិនមែនជាមនុស្សចូលចិត្តកិត្តិយសទេ លោកក៏មិនមែនជាអ្នកនយោបាយ
ដែរ បានជាលោកលំបាកចិត្តនឹងរស់នៅក្នុងរាជធានីរបស់ព្រះចៅ ។ លោកកាន់
វិន័យយ៉ាងតឹងរ៉ឹង មានបំណងប្រែកិរិយាមារយាទរបស់ក្រុមបូជាចារ្យ និងអស់
លោកដែលរស់នៅក្នុងបរមរាជវាំង ។ ហេតុដូចនេះ បានជាព្រះមហាក្សត្រិយានី
ជិទាស់នឹងលោក ហើយលោក**ទេអូភីល** ជាអភិបាលព្រះសហគមន៍អាឡិចសង់ឌ្រី
ក៏ឃុបឃិតប្រឆាំងនឹងលោក ។ គេទម្លាក់លោកពីមុខតំណែងជាលើកដំបូងនៅ
គ.ស. ៤០៣ តែលោកអាចរស់នៅកុងស្តង់ទីណូប្លបាន ដោយមានប្រជាជនគាំទ្រ
លោកនិងនាំគ្នាតវ៉ា ។ គ.ស. ៤០៤ គេនិរទេសលោកម្តងទៀតទៅស្រុកអាស៊ី ។
លោកទទួលមរណភាពនៅទីនោះ នៅគ.ស. ៤០៧ ។

Layout Histor.qxd 2/10/07 10:10 AM Page 120

គ្រីស្តបរិស័ទដាក់ឈ្មោះលោកថា «*គ្រីសូស្តូម*» គឺ «*មាត់មាស*» ពីព្រោះលោកល្បីល្បាញអធិប្បាយព្រះគម្ពីរយ៉ាងកក់ក្តៅ ។ លោកអប់រំក្រុមអ្នកត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក ។ លោកនិពន្ធ «*សេចក្តីប្រៀនប្រដៅអ្នកត្រៀម
68 ទទួលអគ្គសញ្ញាជ្រមុជទឹក*» ។ លោកជាស់តឿនគ្រីស្តបរិស័ទឲ្យរស់នៅយ៉ាងត្រឹមត្រូវតាមរបៀបរស់នៅផ្សេងៗគ្នាដោយនិពន្ធ «*អំពីមុខងារជាបូជាចារ្យ*» «*អំពីការរស់នៅជាគូស្វាមីភរិយា*» «*អំពីការរស់នៅជាព្រហ្មចារី*» ។ល ។

ក្នុងជំពូកមុនៗ យើងបានបរិយាយខ្លះៗអំពីលោក**ស៊ីរីល** ជាអភិបាលក្រុង
យេរូសាឡឹម និងអំពីលោក**ស៊ីរីល** ជាអភិបាលអាឡិចសង់ឌ្រីរួចហើយ ។ 44

## លោកអាថាណាស្ស (គ.ស ២៩៥_៣៧៣)

### 65 ព្រះជាម្ចាស់ប្រសូតជាមនុស្ស ដើម្បីឱ្យយើងទៅជាព្រះជាម្ចាស់វិញ

*ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលគ្មានរូបកាយ និងមិនអាចរលួយបាន ទោះបីកាលពីមុនព្រះអង្គគង់នៅមិនឆ្ងាយពីយើងក្តី ក៏ឥឡូវនេះ ព្រះអង្គយាងមកក្នុងតំបន់យើងដែរ ។ ព្រះអង្គ ក៏មិនទុកកន្លែងក្នុងពិភពលោកដែលទ្រង់បង្កើតមកដោយមិនគង់នៅនោះទេ គឺព្រះអង្គដែលគង់នៅក្បែរព្រះបិតាព្រះអង្គក៏បំពេញអ្វីៗទាំងអស់ដែរ ។ ព្រះអង្គយាងមករស់នៅជាមួយយើង ដើម្បីសង្គ្រោះយើងដោយសម្តែងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ (...) ។*

*ព្រះអង្គអាណិតមេត្តាដល់ជាតិយើង ដោយព្រះហឫទ័យករុណាចំពោះយើងដែលមានភាពទន់ខ្សោយ ទ្រង់អាណិតអាសូរមនុស្សដែលតែងតែរលួយ ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យសេចក្តីស្លាប់គ្របសង្កត់លើយើងទេ ព្រះអង្គយករូបកាយមួយ គឺរូបកាយដែលមិនខុសប្លែកពីរូបកាយយើងឡើយ កុំឲ្យអ្វីៗដែលព្រះអង្គបង្កើតមកត្រូវវិនាសវិញ និងដើម្បីស្នាព្រះហស្តរបស់ព្រះបិតាព្រះអង្គមិនឥតប្រយោជន៍ដែរ ។*

*អ្នកនិយាយអំពីព្រះបន្ទូលមានសភាពជាមនុស្ស ត្រូវនឹកអំពីអ្វីៗ ដែលទាក់ទងនឹងសភាវៈព្រះអង្គជាព្រះជាម្ចាស់ដែរ (...) ។ នៅពេលគេនិយាយអំពីព្រះអង្គទ្រង់ព្រះកន្សែង គេក៏ដឹងថា ព្រះអម្ចាស់សម្តែងលក្ខណៈជាមនុស្សដោយសារទឹកភ្នែកនោះ ។ ព្រះអង្គក៏សម្តែងលក្ខណៈជាព្រះជាម្ចាស់ ដោយព្រះអង្គប្រោសលោកឡាសារឲ្យមានជីវិតថ្មី ។ គេក៏ដឹងដែរថា ព្រះអម្ចាស់ស្រេកឃ្លាន ទោះបីព្រះអង្គប្រទានអាហារដល់មនុស្ស ៥000 នាក់ ដោយនំបុ័ងតែ ៥ ដុំប៉ុណ្ណោះ តាមរបៀបជាព្រះជាម្ចាស់ ។ គេក៏ដឹងថា សពព្រះអង្គផ្តេកក្នុងផ្នូរ និងព្រះជាម្ចាស់ប្រោសឲ្យព្រះអង្គទទួលព្រះជន្មថ្មីដ៏រុងរឿង និងទៅជាព្រះកាយរបស់ព្រះជាម្ចាស់ ។*

*ព្រះបន្ទូលប្រសូតជាមនុស្ស ដើម្បីឲ្យយើងទៅជាព្រះជាម្ចាស់វិញ ។ ព្រះអង្គធ្វើឲ្យយើងមើលឃើញរូបកាយព្រះអង្គដើម្បីឲ្យយើងអាចគិតដល់ព្រះជាម្ចាស់ ដែលភ្នែកមនុស្សមើលមិនឃើញ ។ ព្រះអង្គក៏ស៊ូទ្រាំឲ្យមនុស្សមើលងាយ ដើម្បីឲ្យយើងបានជីវិតអមតៈ ។ ព្រះអង្គមិនខាតអ្វីឡើយ ពីព្រោះព្រះអង្គមិនអាចរងទុក្ខនិងមិនអាចរលួយបាន ក្នុងឋានៈជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ដោយព្រះអង្គប្រព្រឹត្តដូច្នេះ ទ្រង់រំដោះមនុស្សឲ្យបានរួចពីគ្រោះកាច ដោយសារព្រះអង្គរងទុក្ខទាំងនោះ ដើម្បីជាប្រយោជន៍ដល់មនុស្ស ។*

## លោកបាស៊ីលជាអភិបាលព្រះសហគមន៍សេសារេ (គ.ស ៣៣០_៣៧៩)

### 66 សេចក្តីអត្ថាធិប្បាយព្រះគម្ពីរនៅពេលកើតទុរ្ភិក្ស និងរាំងស្ងួត

*(...) គួរអាណិតអាសូរអ្នកស្រេកឃ្លានណាស់! នៅក្នុងចំណោមគ្រោះកាចដែលមនុស្សតែងជួបប្រទះ ការដាច់ពោះស្លាប់ដោយអត់អាហារ វេទនាជាងគេ (...) ។ អ្នកស្រេកឃ្លានរងទុក្ខយ៉ាងយូរ ឈឺចាប់ជាបន្តបន្ទាប់ កើតទុក្ខរហូតដល់ខ្លាចស្លាប់គ្រប់ពេល តែសេចក្តីស្លាប់បេះតែពន្យារពេលជានិច្ច ។ រូបកាយស្លេកស្លាំងទៅជាខ្មៅដោយជំងឺ (...) គ្មានអាហារក្នុងពោះ ពោះទទេ ឈឺចុកម្ជុល គ្មានរូបរាង ស្បែកជណ្តប់ឆ្អឹងខ្នងកោង ។*

Layout Histor.qxd 2/10/07 10:10 AM Page 121

អ្នកដើរផ្ញើព្រងើយនៅមុខរូបកាយអ្នកស្រេកឃ្លាននេះ មុខជានឹងត្រូវទទួលទោសធ្ងន់ ។ អ្នកនោះឃោរឃៅដល់កំពូល គួររាប់គេទុកដូចជាសត្វតិរច្ឆាន ជាជនឧក្រិដ្ឋ និងជាឃាតក ។ ពិតមែនហើយ អ្នកដែលមានលទ្ធភាពអាចសង្គ្រោះគេឲ្យរួចពីទុក្ខលំបាកនេះបាន តែកំណាញ់ ពន្យាពេល មិនសង្គ្រោះភ្លាមៗទេ ច្បាស់ជាត្រូវផ្តន្ទាទោសទុកជាឃាតកម្នាក់ ។

ប្រសិនបើអ្នកជាជនក្រីក្រ សូមមើលម្នាក់ទៀតដែលក្រជាងខ្លួន ។ អ្នកមានអាហារបរិភោគបានដប់ថ្ងៃ តែគេខ្លះមានអាហារសម្រាប់តែមួយថ្ងៃប៉ុណ្ណោះ សូមចែករំលែកអ្វីៗដែលអ្នកនៅសល់ឲ្យបានស្មើនឹងជនទីទ័លក្រ ពេលនោះអ្នកពិតជាមានចិត្តសប្បុរសមែន ។ កុំរួញរានឹងផ្តល់អ្វីៗដែលខ្លួនមាន ទោះបីតិចតួចក្តី កុំរកប្រយោជន៍ផ្ទាល់ខ្លួនដោយភ្លេចប្រយោជន៍រួម ។ សូម្បីអ្នកមាននំបុ័ងតែមួយដុំក្តី បើអ្នកសុំទាននៅមាត់ទ្វារ ក៏សូមយកនំបុ័ងនេះលើកឡើង ទាំងពោលត្អូញត្អែរពោរពេញដោយចិត្តសប្បុរសថា «បពិត្រព្រះអម្ចាស់! នំបុ័ងដែលព្រះអង្គទតឃើញនេះ ជានំបុ័ងចុងក្រោយបង្អស់ ខ្ញុំគ្មានអាហារទៀតទេ ហើយគ្រោះកាចក៏កាន់តែជិតមកដល់ដែរ ប៉ុន្តែ ខ្ញុំនឹកវិន័យព្រះអង្គជានិច្ច ។ ទោះបីខ្ញុំមានបន្តិចនេះក្តី ក៏ខ្ញុំចែកដល់បងប្អូនដែលកំពុងឃ្លាន ។ សូមព្រះអង្គប្រទានអាហារដល់ខ្ញុំ ដែលជាអ្នកបម្រើព្រះអង្គ ដែលកំពុងប្រឈមមុខនឹងគ្រោះកាចដល់ថ្នាក់ ។ ខ្ញុំស្គាល់ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ហើយក៏ផ្ញើជីវិតលើឫទ្ធានុភាពរបស់ព្រះអង្គដែរ ។ សូមកុំបង្អង់ឡើយ ប្រសិនបើព្រះអង្គសព្វព្រះហឫទ័យ សូមប្រទានព្រះអំណោយទានមកយើងខ្ញុំផង» ។

បើអ្នកនិយាយហើយប្រព្រឹត្តដូច្នេះ នំបុ័ងដែលអ្នកដាក់ទានទាំងខ្វះខាតនោះ នឹងទៅជាពូជសម្រាប់ប្រមូលភោគផល វាបង្កើតផលជាច្រើន ដោយនំបុ័ងនេះបង្ហាញពីចិត្តមេត្តាករុណារបស់អ្នក ព្រះអង្គមុខជានឹងប្រទានអាហារឲ្យអ្នកពុំខាន ។

*លោកបាស៊ីលជាអភិបាលព្រះសគហមន៍នៅសេសារេ*
*"សេចក្តីអត្ថាធិប្បាយនៅពេលកើតទុរ្ភិក្ស"*

## លោកគ្រេគ័រជាអភិបាលព្រះសហគមន៍នីស្ស (គ.ស ៣៣៥_៣៩៤)

67

### មនុស្សជានិមិត្តរូបអំពីព្រះជាម្ចាស់

មនុស្សបង្ហាញសម្រស់របស់ព្រះជាម្ចាស់ មិនមែនដោយមានមុខស្អាត ឬរូបរាងសង្ហាទេ គឺមនុស្សដូចព្រះអង្គដោយបានអំណរសប្បាយរកថ្លែងពុំបាន ដោយខ្លួនមានកិរិយាមារយាទដ៏ពេញលក្ខណៈ ។ ឧបមាថា ជាងគំនូរតែងផាត់ពណ៌លើតួអង្គលើផ្ទាំងគំនូរ ដើម្បីឲ្យអ្នកឃើញសម្ផស្សរបស់អ្នកនោះ ។ សូមអ្នកស្រមៃឃើញព្រះជាម្ចាស់ដែលសូនរូបយើងវិញ ពណ៌ដែលស្របតាមសម្ផស្សរបស់ព្រះអង្គ គឺព្រហ្មវិហារធម៌ដែលព្រះអង្គដាក់ក្នុងចិត្តគំនិតរបស់មនុស្ស ព្រះអង្គក៏ធ្វើឲ្យព្រហ្មវិហារធម៌នោះរីកឡើងក្នុងមនុស្សដែលជារូបតំណាងរបស់ព្រះអង្គ ដើម្បីសម្តែងឫទ្ធានុភាពរបស់ព្រះអង្គ ។ ពណ៌ផ្សេងៗដែលនៅក្នុងមនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់នោះ សម្តែងព្រះជាម្ចាស់យ៉ាងពិតប្រាកដ មិនមែនជាពណ៌ស ពណ៌ក្រហម ឬពណ៌លាយគ្នា ពណ៌ខ្មៅសម្រាប់ផាត់រោមភ្នែក និងពណ៌ផ្សេងៗទៀតតាមអ្នកគូរនឹកឃើញនោះទេ ។ សូមគិតឡើងវិញអំពីភាពបរិសុទ្ធ សេរីភាពខាងការរិះគិត សុភមង្គល ការរស់នៅឆ្ងាយពីអំពើបាបគ្រប់យ៉ាង គឺសូមគិតដល់អ្វីៗទាំងអស់ដែលធ្វើឲ្យយើងបានដូចព្រះជាម្ចាស់ ។ ព្រះដែលបង្កើតរូបតំណាងរបស់ព្រះអង្គផ្ទាល់ បានគូរជាតិមនុស្សយើងដោយពណ៌ទាំងនេះ ។ ប្រសិនបើបងប្អូនពិនិត្យលក្ខណៈឯទៀតៗនៃសម្ផស្សរបស់ព្រះជាម្ចាស់ បងប្អូនមុខជានឹងយល់ឃើញថា យើងពិតជារូបតំណាងរបស់ព្រះអង្គ ។ ព្រះអង្គដាក់អ្វីៗឲ្យយើងបានដូចព្រះអង្គ គឺលក្ខណៈទាំងនោះ ។ ព្រះជាម្ចាស់ជាព្រះវិញ្ញាណនិងជាព្រះបន្ទូល ដ្បិត «កាលពីដើមដំបូងបង្អស់មានព្រះបន្ទូល» ។ តាមលោក**ប៉ូល** ព្យាការីទាំងឡាយ «មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ត» ដែលមានព្រះបន្ទូលដោយសារអស់លោក ។ មនុស្សយើងក៏មានលក្ខណៈទាំងនោះដែរ គឺបងប្អូនមានប្រាជ្ញាបេះគិតគូរធ្វើតាមព្រះអង្គ ដែលជាព្រះវិញ្ញាណនិងជាព្រះបន្ទូល ។ ព្រះជាម្ចាស់ជាប្រភពនៃសេចក្តីស្រឡាញ់ដែរ ។ លោក**យ៉ូហាន**ដ៏ប្រសើរបំផុតមានប្រសាសន៍ថា៖ «សេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់» និង «ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់» ។ ព្រះដែលសូនមនុស្សយើង និងដាក់លក្ខណៈនេះក្នុងរូបយើង គឺថា «ព្រះអង្គមានព្រះបន្ទូលថា បើអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជានឹងដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន» ។ ដូច្នេះ បើគ្មានសេចក្តីស្រឡាញ់ទេ រូបតំណាងទាំងមូលខូចទម្រង់ហើយ ។

*លោកគ្រេគ័រ ជាអភិបាលក្រុងនីស្ស "កំណើតមនុស្ស" ជំពូក ៥*

Layout Histor.qxd 2/10/07 10:10 AM Page 122

## លោកយ៉ូហានគ្រីសូស្តូម (គ.ស ៣៣០_៣៧៩)

68

### គ្រីស្តបរិស័ទត្រូវតែខ្វល់ខ្វាយសង្គ្រោះបងប្អូនរបស់ខ្លួន

*ព្រះគ្រីស្តមិនរំដោះលោក**ប៉ូល** ឲ្យរួចផុតពីគ្រោះកាចទេ ព្រះអង្គបណ្តោយឲ្យលោករងគ្រោះ ។ ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សប្រើប្រាជ្ញាខ្លួនដល់កម្រិតខ្ពស់បំផុត ។ ព្រះអង្គសព្វព្រះហឫទ័យបង្រៀនយើងឲ្យយល់ថា សាវ័កក៏ជាមនុស្សដូចយើងដែរ ។ ព្រះអង្គមិនប្រណីសន្តោស ដោយប្រព្រឹត្តអ្វីៗទាំងអស់ជំនួសមនុស្សទេ បើមិនដូច្នេះទេ គេបាត់ទុកសាវ័កគ្រាន់តែជាដុំឈើប៉ុណ្ណោះ ។ ហេតុនេះ អស់លោកខិតខំបំពេញសកម្មភាពយ៉ាងខ្លាំងដោយខ្លួនលោកផ្ទាល់ ។ យើងក៏ត្រូវតែប្រព្រឹត្តដូច្នេះដែរ គឺខិតខំសង្គ្រោះបងប្អូនរបស់យើង ។ យើងត្រូវសុខចិត្តរងទុក្ខ ដើម្បីសង្គ្រោះមនុស្សជាច្រើន ការណ៍នេះមិនអន់ជាងការបូជាជីវិតជាមរណសាក្សីឡើយ ។ គ្មានអ្វីគាប់ព្រះហឫទ័យព្រះជាម្ចាស់ជាងការនោះទេ ។ គ្មានអ្វីសាបជាងគ្រីស្តបរិស័ទម្នាក់ដែលមិនសង្គ្រោះអ្នកឯទៀតៗទេ ។ ត្រង់នេះកុំនិយាយដោះសាខ្លួនថា ជាអ្នកក្រីក្រ ។ ស្ត្រីមេម៉ាយដែលដាក់ពីរកាក់ជាតង្វាយគាត់មុខជានឹងបិទមាត់អ្នកហើយ ។ លោក**សិលា** ក៏ដូច្នេះដែរ គឺលោកមានប្រសាសន៍ថា «ខ្ញុំគ្មានមាស គ្មានប្រាក់ទេ» ។ លោកប៉ូលក៏ក្រីក្រដែរ គ្មានអ្វីបរិភោគសោះ ។ អ្នកក៏មិនអាចដោះសាថា អ្នកមិនកើតក្នុងវង្សត្រកូលខ្ពស់ទេ ព្រោះគ្រីស្តទូតក៏ជាមនុស្សតូចតាច និងកើតពីឪពុកម្តាយតូចតាចដែរ ។ កុំដោះសាថា ខ្លួនមានកម្រិតវប្បធម៌ទាប ព្រោះគ្រីស្តទូតក៏មិនចេះអានអក្សរដែរ ។ ទោះបីអ្នកជាទាសករក្តី ឬជាអ្នកក្រៅច្បាប់ក្តី ក៏អាចធ្វើអំពើល្អប្រសើរជាងមុនបានដែរ ។ លោក**អូណេសិម** ក៏ដូច្នេះដែរ ។ (...) អ្នកឃើញលោកប៉ូលហៅគាត់ឲ្យទទួលកិត្តិយសយ៉ាងខ្ពស់ លោកមានប្រសាសន៍ថា «ឲ្យគាត់រួមជាមួយខ្ញុំដែលជាប់ច្រវាក់» ។ កុំដោះសាថាខ្លួនមានជំងឺ ព្រោះលោក**ធីម៉ូថេ** ក៏ឈឺជាញឹកញយដែរ ។ សូមស្តាប់លោកប៉ូលនិយាយថា «ចូរផឹកស្រាបន្តិចដើម្បីជួយក្រពះ» ។ ប្រសិនបើម្នាក់ៗសុខចិត្តធ្វើអ្វីៗទាំងអស់ដែលខ្លួនអាចធ្វើបាន ម្នាក់ៗក៏មានប្រយោជន៍សម្រាប់បងប្អូនដែរ ។ (...) អ្នកដែលខ្វល់ខ្វាយតែប្រយោជន៍ផ្ទាល់ខ្លួន គ្មានប្រយោជន៍ទាល់តែសោះ ។ (...) ស្ត្រីព្រហ្មចារិនីទាំងនោះបរិសុទ្ធល្អស្អាត មានព្រហ្មវិហារធម៌ខ្ពស់ តែគ្មានប្រយោជន៍សម្រាប់នរណាសោះឡើយ ។ ហេតុដូច្នេះហើយ ព្រះជាម្ចាស់ដុតគេចោល ។ អ្នកដែលមិនចិញ្ចឹមព្រះគ្រីស្តក៏ដូច្នោះដែរ ។ ចូរយល់ឲ្យច្បាស់ថា យើងមិនស្តីបន្ទោសគេទេ គឺកិរិយាមារយាទបន្ទោសគេវិញ យើងមិនស្តីបន្ទោសព្រោះគេប្រព្រឹត្តអំពើមិនបរិសុទ្ធទេ ឬព្រោះពាក្យប្រមាថព្រះជាម្ចាស់ទេ គឺយើងស្តីបន្ទោសគេព្រោះគេគ្មានប្រយោជន៍សម្រាប់អ្នកដទៃសោះ ។ គេដូចជាអ្នកបម្រើដែលលាក់ប្រាក់ណែនរបស់ខ្លួន ។ គេគ្មានកំហុសអ្វីទេ តែគ្មានប្រយោជន៍អ្វីសម្រាប់អ្នកដទៃសោះ ។*

*លោកយ៉ូហាន គ្រីសូស្តូម*

*សេចក្តីអត្ថាធិប្បាយព្រះគម្ពីរទី ២០ អំពី "កិច្ចការគ្រីស្តទូត"*

## ៣- អ្នកនិពន្ធជាភាសាឡាតាំងដ៏ល្បីល្បាញជាងគេ

គ្រូបាធ្យាយនិពន្ធជាភាសាឡាតាំងតែងតែយោងគំនិតពីគ្រូបាធ្យាយក្រិក ។ ក្រៅពីលោក**អូគូស្តាំង** អស់លោកមិនសូវមានយោបល់ថ្មីៗទេ ។

លោក**អាំប្រាស៍** (Ambroise ៣៤០-៣៩៧) ជាមន្ត្រីរាជការ គឺជាអភិបាលក្រុងមីឡង់ ស្រុកអ៊ីតាលី ។ ពេលលោកនៅទទួលការអប់រំជំនឿនៅឡើយ លោកទទួលបន្ទុកពីរដ្ឋអំណាច ឲ្យការពារសន្តិសុខក្នុងការបោះឆ្នោតជ្រើសរើសអភិបាលព្រះសហគមន៍ក្រុងមីឡង់ ។ នៅពេលនោះ ស្រាប់តែមានក្មេងម្នាក់បន្លឺសំឡេងឡើងថា៖ «*សូមជ្រើសរើសលោកអាំប្រាស៍ធ្វើជាអភិបាល*» ។ បណ្តាជនក៏នាំគ្នាស្រែកតាមក្មេងនោះដែរ ។ ពីរបីថ្ងៃក្រោយមក លោកទទួលអគ្គសញ្ញាជ្រមុជទឹក ហើយអគ្គសញ្ញាតែងតាំងជាបូជាចារ្យនិងជាអភិបាលព្រះសហគមន៍ ។ លោក

Layout Histor.qxd 2/10/07 10:10 AM Page 123

**អាំប្រាស៍**ចែកទ្រព្យសម្បត្តិរបស់ខ្លួនឲ្យជនក្រីក្រ ហើយលោកប្រៀនប្រដៅគ្រីស្តបរិស័ទឲ្យប្រព្រឹត្តតាមយុត្តិធម៌ក្នុងសង្គម ។ លោកមានប្រសាសន៍ថា៖ *«ដីធ្លីជាកម្មសិទ្ធិរបស់មនុស្សទាំងអស់ មិនមែនជាកម្មសិទ្ធិរបស់អ្នកមានទេ»* ។ លោកសូមព្រះចៅអធិរាជ**ទេអូដូស**ធ្វើទុក្ករកិរិយា ដើម្បីសូមព្រះជាម្ចាស់លើកលែងទោសក្រោយពីទ្រង់សម្លាប់រង្គាលប្រជាជននៅក្រុងថេស្សាឡូនិក ៧ ពាន់នាក់ ។

លោកអាំប្រាស៍ជាគង្វាលដ៏ល្អ លោកសរសេរសៀវភៅជាច្រើន ដូចជា *«ធម្មទេសនា»* *«សេចក្ដីប្រៀនប្រដៅអ្នកត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក»*
*«អំពីការរស់នៅជាព្រហ្មចារី»* ។ល។ លោកនាំគ្រីស្តបរិស័ទឲ្យច្រៀងបទតាម 69
ពិធីផ្សេងៗក្នុងព្រះវិហារនៅខាងបស្ចិមប្រទេស ។ លោកនិពន្ធទាំងទំនុកនិងទាំងបទភ្លេងដោយខ្លួនលោកផ្ទាល់ ។

## លោកអាំប្រាស៍ជាអភិបាលព្រះសហគមន៍នៅមីឡង់ (គ.ស. ៣៣៣_៣៩៧)

69
### ដំបូន្មានសម្រាប់អធិដ្ឋាន

ឥឡូវនេះ ចូរស្ដាប់អំពីរបៀបយើងត្រូវអធិដ្ឋាន ។ (...) គ្រីស្តទូតមានប្រសាសន៍ថា «ខ្ញុំចង់ឲ្យយើងអធិដ្ឋានគ្រប់ទីកន្លែងដោយលើកដៃយ៉ាងបរិសុទ្ធគ្មានកំហឹង ហើយគ្មានជម្លោះ» ។ តែព្រះអម្ចាស់មានព្រះបន្ទូលនៅក្នុងគម្ពីរដំណឹងល្អថា «ពេលអ្នកអធិដ្ឋានត្រូវចូលក្នុងបន្ទប់ បិទទ្វារ ហើយទូលអង្វរព្រះបិតា» ។តើអ្នកយល់ថា ពាក្យនេះផ្ទុយគ្នាឬយ៉ាងណា? គ្រីស្តទូតមានប្រសាសន៍ថាចូរអធិដ្ឋាននៅគ្រប់ទីកន្លែង រីឯព្រះអម្ចាស់វិញ ព្រះអង្គមានព្រះបន្ទូលថា សូមអធិដ្ឋានក្នុងបន្ទប់ ។ មិនផ្ទុយគ្នាទេ (...) ។ អ្នកអាចអធិដ្ឋាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាក្នុងបន្ទប់របស់អ្នកបានដែរ ។ អ្នកមានបន្ទប់មួយនៅគ្រប់ទីកន្លែង ទោះបីអ្នកនៅក្នុងចំណោមសាសន៍ដទៃក្ដី ឬនៅជាមួយជនជាតិយូដាក្ដី ក៏អ្នកមានបន្ទប់មួយដ៏ស្ងាត់កំបាំងដែរ បន្ទប់របស់អ្នកគឺចិត្តតែម្ដង ។ ទោះបីអ្នកនៅកណ្ដាលប្រជាជនក្ដី ក៏អ្នកមានបន្ទប់មួយបិទជិត និងសម្ងាត់ក្នុងជម្រៅចិត្តដែរ ។ រីឯអ្នកវិញពេលអ្នកអធិដ្ឋាន សូមចូលអធិដ្ឋានក្នុងបន្ទប់របស់អ្នក ។ ត្រូវចូលក្នុងបន្ទប់ ក្រែងអ្នកអធិដ្ឋានដូចជនជាតិយូដា ដែលព្រះជាម្ចាស់មានព្រះបន្ទូលថា «ប្រជាជននេះគោរពយើងតែបបូរមាត់ប៉ុណ្ណោះ តែចិត្តគំនិតគេនៅឆ្ងាយពីយើង» ។ ដូច្នេះ សូមកុំឲ្យពាក្យអធិដ្ឋានរបស់អ្នកគ្រាន់តែចេញពីបបូរមាត់ប៉ុណ្ណោះទេ ។ ត្រូវតាំងចិត្តទាំងស្រុងក្នុងជម្រៅចិត្តរបស់អ្នក (...) ។ អ្វីទៅដែលហៅថា ទ្វារបិទជិតនោះ? ចូរចាំពេលអ្នកអធិដ្ឋានអ្នកត្រូវបិទទ្វារ ។ ខ្ញុំបន់ឲ្យស្ត្រីៗយល់សេចក្ដីនេះ! (...) ។ ពេលអធិដ្ឋានកុំបន្លឺសំឡេងខ្លាំងៗ កុំពោលពាក្យអធិដ្ឋានរាត់រាយ កុំចង់បានមុខមាត់នៅចំពោះមុខបណ្ដាជន ។ ចូរអធិដ្ឋានដោយសម្ងាត់ម្នាក់ឯង ទាំងជឿជាក់ថាព្រះជាម្ចាស់ដែលព្រះសណ្ដាប់ឮ និងទតឃើញអ្វីៗទាំងអស់ព្រះអង្គក៏អាចព្រះសណ្ដាប់អ្នកក្នុងទីស្ងាត់ដែរ (...) ។ ចូរទូលអង្វរព្រះបិតានៅទីស្ងាត់កំបាំង ដ្បិតព្រះអង្គទតឃើញក្នុងទីស្ងាត់កំបាំង ក៏ព្រះសណ្ដាប់ពាក្យអធិដ្ឋានរបស់អ្នកដែរ ។ ហេតុអ្វីយើងត្រូវអធិដ្ឋានក្នុងទីស្ងាត់កំបាំង ជាជាងបន្លឺសំឡេងដូច្នេះ? សូមមើលជុំវិញខ្លួន ប្រសិនបើអ្នកសុំអ្វីមួយពីអ្នកដែលមិនថ្លង់ អ្នកយល់ថា មិនចាំបាច់ស្រែកទេ គឺសុំដោយសំឡេងស្រាលៗ សំឡេងស្រួល ។ ប្រសិនបើអ្នកសុំអ្វីមួយពីមនុស្សថ្លង់វិញ អ្នកចាប់ផ្ដើមស្រែកខ្លាំងៗដើម្បីឲ្យគាត់ឮមែនទេ? ដូច្នេះ អ្នកដែលស្រែកប្រហែលគិតថា ព្រះជាម្ចាស់ព្រះសណ្ដាប់ឮតែសំឡេងខ្លាំងៗទេមើលទៅ ។ ដោយអង្វរដូច្នេះ គាត់ក៏បន្ទាបឫទ្ធានុភាពរបស់ព្រះអង្គដែរ ។ តែផ្ទុយទៅវិញ អ្នកអធិដ្ឋានស្ងាត់ៗ ផ្ដល់សក្ខីភាពអំពីជំនឿ គឺទទួលស្គាល់ថាព្រះជាម្ចាស់ស្ទង់ចិត្តគំនិតរបស់មនុស្ស ព្រះអង្គទ្រង់ព្រះសណ្ដាប់ឮពាក្យអធិដ្ឋានរបស់អ្នក មុនពាក្យចេញពីមាត់អ្នកទៅទៀត ។

លោកអាំប្រាស៍ "អំពីអគ្គសញ្ញា" ៦,១១-១៦

លោក**យេរ៉ូម** (Jérôme គ.ស. ៣៤៧-៣៩៧) កើតនៅស្រុកដាលម៉ាស៊ី *(ក្រូអាតសព្វថ្ងៃ)* ។ មុនដំបូងលោករស់នៅជាជនអនាថា ។ លោកទៅរៀននៅក្រុងរ៉ូម តែលោកគិតតែពីលេងសប្បាយប៉ុណ្ណោះ ។ ក្រោយមក លោករស់នៅជាបព្វជិតនៅបូព៌ា ហើយទទួលមុខងារជាបូជាចារ្យទាំងទើសទាល់ ។ លោកទៅក្រុងរ៉ូមម្ដងទៀត (គ.ស. ៣៨២-៣៨៥) រួចហើយត្រឡប់ទៅបម្រើលោក**ដាម៉ាស** (Damase) ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូមនោះ និងជួយណែនាំក្រុមស្ត្រីៗខ្លះដែលគោរពប្រណិប័តន៍ព្រះជាម្ចាស់ ។ នៅទីបញ្ចប់ លោកទៅក្រុងបេថ្លេហឹម ហើយរស់នៅទីនោះ រួមជាមួយស្ត្រីៗជាមិត្តសម្លាញ់របស់លោក ។ នៅទីនោះ លោកតែងតាំងវត្តអារាមសម្រាប់ស្ត្រីផង និងសម្រាប់បុរសផង ។

លោកយេរ៉ូម មានចិត្តមិនសូវនឹងនរ ហើយអារម្មណ៍មិនស្រួលប៉ុន្មានទេ ។ ដូច្នេះ មនុស្សជាច្រើនមិនចូលចិត្តលោក ព្រោះលោកតែងតែនិយាយពាក្យសំដីខ្លាំងៗ ហើយតែងបោទគេឯងទាំងខុស ។ លោកប្រែគម្ពីរមកជាភាសាឡាតាំង ។ នេះជាស្នាដៃដ៏សំខាន់របស់លោក ។ លោកអភិបាលដាម៉ាស សុំឲ្យលោកកែសម្រួលព្រះគម្ពីរប្រែជាភាសាឡាតាំងកាលពីបុរាណ តែលោកចាប់ផ្ដើមបកប្រែគម្ពីរសម្ពន្ធមេត្រីចាស់សាជាថ្មី ដោយយកព្រះគម្ពីរភាសាហេប្រឺ និងភាសាអារ៉ាមេអាំងធ្វើជាប្រភពដើម ។ ព្រះសហគមន៍ដាក់ឈ្មោះគម្ពីរលោកបកប្រែសម្រួលសាជាថ្មីនោះថា *«គម្ពីររបស់ប្រជាជន» (Vulgate)* ពីព្រោះគេប្រើគម្ពីរនោះជាផ្លូវការទូទៅក្នុងព្រះសហគមន៍បស្ចិមប្រទេសរហូតមកសព្វថ្ងៃ ។ លោកក៏និពន្ធសេចក្ដីអត្ថាធិប្បាយគម្ពីរ សៀវភៅប្រឆាំងនឹងគេ ព្រមទាំងលិខិតជាច្រើនដែលមានសារៈសំខាន់ដែរ ។

លោក**អូគូស្ដាំង** (Augustin គ.ស. ៣៥៤-៤៣០) ជាគ្រូបាធ្យាយដែលមានឥទ្ធិពលខ្លាំងជាងគេលើអ្នករិះគិតខាងសាសនានៅបស្ចិមប្រទេស ។ លោកកើតនៅថាកាស្ដ ស្រុកនុយមីឌី (Thagasse de Numidie, Algérie) ម្ដាយឈ្មោះ



**ម៉ូនីក** (Monique) ជាស្ត្រីគោរពប្រណិប័តន៍ព្រះជាម្ចាស់យ៉ាងខ្លាំង ។ លោកជានិស្សិត រួចទៅជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យក្រុងកាតាស្ស ស្រុកអាហ្វ្រិក (Carthage, ទុយនីស្សសព្វថ្ងៃ) ។ ក្រោយមក លោកនៅក្រុងរ៉ូមនិងក្រុងមីឡង់ ។ លោកស្វែងរកសេចក្ដីពិតជាយូរឆ្នាំ ដោយអានសៀវភៅទស្សនវិទូនានា និងកាន់តាមលោក**ម៉ានី** ។ លោកយល់ឃើញថា ត្រូវតែលែងលះភរិយា និងកូនម្នាក់ឈ្មោះ**អាដេអូដា** (Adéodat) ទើបលោកអាចរកសេចក្ដីពិតឃើញ ។ នៅទីបញ្ចប់ លោកមើលពន្លឺឃើញដោយជួបលោក**អាំប្រាស៍** ។ លោកអំប្រាស៍ ធ្វើអគ្គសញ្ញាជ្រមុជទឹកជូនលោកនៅ គ.ស. ៣៨៧ ។ លោកសម្រេចចិត្តធ្វើជាបព្វជិត ប៉ុន្តែ គ្រីស្តបរិស័ទក្រុងហ៊ីប៉ូន (Hippone ស្រុកអាល់ហ្សេរីសព្វថ្ងៃ) ជ្រើសរើសលោកទុកជាបូជាចារ្យ និងបន្ទាប់មកឲ្យធ្វើជាអភិបាលព្រះសហគមន៍ទៀតនៅ គ.ស. ៣៩៥ ។ លោក**អូគូស្ដាំង**ធ្លាប់ធ្វើដំណើរទៅមកក្នុងស្រុកអាហ្វ្រិកខាងជើង ដើម្បីទាក់ទងនឹងអភិបាលឯទៀតៗ និងចូលរួមសន្និបាតតាមតំបន់ជាច្រើន ។ លោកក៏ជំទាស់នឹងគ្រីស្តបរិស័ទកាន់ជើងលោក**ដូណាត** ដែលបង្កើតព្រះសហគមន៍ប្រឆាំងនឹងលោក ។ លោកត្រូវបព្វជិតម្នាក់ឈ្មោះ**ប៉េឡាស** (Pélage) ជំទាស់ដោយវែកញែកជជែកអំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ។ លោកព្រួយចិត្តដោយសារជនជាតិវ៉ែនដាល (Vandales) លុកលុយស្រុកបំផ្លាញអ្វីៗទាំងអស់ ។ លោកអូគូស្ដាំងទទួលមរណភាពនៅពេលដែលខ្មាំងឡោមព័ទ្ធទីក្រុង ។

ក្នុងចំណោមសៀវភៅគ្រូបាធ្យាយទាំងប៉ុន្មាន នៅសល់សៀវភៅលោកអូគូស្ដាំងច្រើនជាងគេ ។ លោកជាគង្វាលមានគរុកោសល្យពូកែសម្ដែងធម្មទេសនា និងអប់រំជំនឿគេ ។ លោកធ្វើសេចក្ដីអត្ថាធិប្បាយយ៉ាងជ្រៅអំពីព្រះគម្ពីរ និពន្ធសៀវភៅទស្សនវិជ្ជា ទេវវិជ្ជា និងមានសៀវភៅខ្លះប្រឆាំងនឹងអ្នកវង្វេងជំនឿ ។ នៅក្នុងចំណោមសៀវភៅទាំងនោះ សៀវភៅ *«សេចក្ដីរៀបរាប់ជីវប្រវត្តិ»* ល្បីឈ្មោះជាងគេ ។ ក្នុងសៀវភៅនោះ លោកអរព្រះគុណព្រះជាម្ចាស់ ដែលទាក់

Layout Histor.qxd 2/10/07 10:10 AM Page 125

ទាញចិត្តលោកឲ្យជឿលើព្រះអង្គ ។ លោកក៏និពន្ធ *«ក្រុងរបស់ព្រះជាម្ចាស់»* ។ នៅក្នុងសៀវភៅនេះ លោករិះគិតអំពីប្រវត្តិសាស្ត្រពិភពលោក ដើម្បីជួយគ្រីស្តបរិស័ទដែលវិលវល់ក្នុងចិត្ត បាក់ស្បាតដោយលោក**អាឡារិក** (Alaric) ជាខ្មាំងសត្រូវវាយដណ្តើមយកក្រុងរ៉ូមបំផ្លាញខ្ទេចខ្ទីអស់នៅ គ.ស. ៤១០ ។ លោកនិពន្ធសៀវភៅមួយទៀតដែលល្បី គឺ *«ព្រះត្រៃឯក»* ។ ទេវវិទូទាំងអស់នៅជំនាន់ក្រោយៗ គឺលោក**លូធែរ កាល់វ៉ាំង**និង**យ៉ង់សែន** ក៏យោងគំនិតពីលោកដែរ ។

គ្រូបាធ្យាយឡាតាំងរាប់សិបនាក់ និពន្ធសៀវភៅតូចៗ ។ អត្ថបទខ្លះដែលអស់លោកនិពន្ធនោះល្បីឈ្មោះយ៉ាងខ្លាំង ឧបមាថា *«កំណត់ហេតុការណ៍»* របស់លោក**វ៉ាំងសង់ នៅឡេរ៉ាំង** (Vincent de Lérins) ។ យើងថែងសេចក្តីអំពីលោក 72
**ឡេអូ**ដ៏ប្រសើរឧត្តម ជាអភិបាលក្រុងរ៉ូម (គ.ស. ៤៤០-៤៦១) ហើយជាអធិបតីក្នុងមហាសន្និបាតកាលសេដូន (ទំព័រ ១០៦-១១៣) ។ គ្រីស្តបរិស័ទចាត់លោក**គ្រេគ័រ**ជាអភិបាលក្រុងរ៉ូម (គ.ស. ៥៩០-៦០៤) ទុកជាគ្រូបាធ្យាយម្នាក់ដ៏ប្រសើរក្នុងចំណោមគ្រូបាធ្យាយឡាតាំងទាំងឡាយ ។ លោកគ្រាន់តែយោងគំនិតអ្នកនិពន្ធមុនៗ ហើយជាពិសេសគំនិតរបស់លោកអូគូស្តាំងប៉ុណ្ណោះ ។

70

## ដំបូន្មានលោកយេរ៉ូមសម្រាប់អប់រំក្មេងស្រីតូចម្នាក់ (ឆ្នាំ ៤០០)

លោក**យេរ៉ូម**ទូន្មានអ្នកស្រី**ឡេតា**ជាសម្លាញ់របស់លោក ដែលរស់នៅជាមួយលោកនៅបេថ្លេហិម អំពីការអប់រំក្មេងស្រីម្នាក់ឈ្មោះ**ប៉ូឡា**ជាចៅរបស់អ្នកស្រីនោះ ។ លោកយកព្រះគម្ពីរជាគ្រឹះក្នុងការអប់រំនោះ ។

*(...) សូមកុំយកឈ្មោះដោយចៃដន្យ សម្រាប់ឲ្យនាងប៉ូឡាបង្កើតឃ្លា បន្តិចម្តងៗ គឺត្រូវជ្រើសរើសឈ្មោះយ៉ាងច្បាស់ផ្សំគ្នាដោយចេតនា ។ ឧបមា ត្រូវជ្រើសរើសឈ្មោះរបស់អស់លោកព្យាការីនិងគ្រីស្តទូត ។ សូមយកឈ្មោះបុព្វបុរសទាំងអស់បន្តបន្ទាប់ ចាប់តាំងពីលោក**អដាំ**មក ដូចមានចែងក្នុងគម្ពីរដំណឹងល្អតាមលោកម៉ាថាយ និងលោកលូកា ។ ដូច្នេះ ទោះបីនាងធ្វើការផ្សេងៗក្តី នាងក៏ទុកឈ្មោះទាំងនោះដាក់ក្នុងចិត្តសម្រាប់ពេលអនាគត ។*

*សូមតែងតាំងស្ត្រីព្រហ្មចារិនីម្នាក់ដែលមានបទពិសោធន៍ឲ្យទទួលខុសត្រូវក្នុងការអប់រំនាង គឺស្រីដែលជាគំរូអំពីជំនឿ អំពីសីលធម៌ ចេះអៀន បង្ហាត់បង្រៀននាងដោយធ្វើជាគំរូ ឲ្យក្រោកឡើងនៅពេលយប់ទៅស្រឹងស្មាធិ៍ និងសូត្រទំនុកតម្កើងច្រៀងបទតាំងពីព្រលឹមមក ។ ត្រូវឲ្យស្ត្រីនោះបង្ហាត់តយុទ្ធនៅម៉ោង ៩ ព្រឹក ថ្ងៃត្រង់ និងម៉ោង ៣ រសៀល ដូចទាហាននៃកងទ័ពរបស់ព្រះគ្រីស្ត ។ ទីបញ្ចប់ ឲ្យនាងអុជចង្កៀងតូចមួយថ្វាយសក្ការបូជានៅពេលល្ងាច (...) ។*

*សូមឲ្យនាងចូលចិត្តកណ្ឌព្រះគម្ពីរជាជាងត្បូងពេជ្រ និងអាវធ្វើអំពីសូត្រ ។ កុំឲ្យនាងសប្បាយចិត្ត ដោយឃើញគំនូរវិចិត្រផ្ដុំអំពីមាស (...) ។ តែផ្ទុយទៅវិញ សូមឲ្យនាងសប្បាយចិត្ត ដោយឃ្លោងឃ្លានិពន្ធយ៉ាងត្រឹមត្រូវនៃអត្ថបទនីមួយៗក្នុងគម្ពីរ ។ មុនដំបូងឲ្យនាងរៀនកណ្ឌទំនុកតម្កើង ដូច្នេះនាងជៀសចេញពីបទចម្រៀងឯទៀតៗ ។ សូមយកសុភាសិតរបស់ព្រះបាទ**សាឡូម៉ូន**ទៅអប់រំនាងសម្រាប់ការរស់នៅ ។ ដោយនាងអានកណ្ឌសាស្តា នាងមិនចាប់អារម្មណ៍អ្វីៗជាលោកិយ ។ ដោយអានគម្ពីរលោក**យ៉ូប** នាងនឹងភ្ជាប់ចិត្តនឹងមនុស្សម្នាក់ជាគំរូរបស់អ្នកមានសេចក្តីក្លាហាន និងចិត្តអត់ធ្មត់ខន្តី ។ រួចនាងនឹងរៀនដំណឹងល្អ ដែលនាងត្រូវកាន់ជាប់នឹងដៃជានិច្ច ។ សូមនាងយកចិត្តទុកដាក់ក្រេបជញ្ជក់គម្ពីរកិច្ចការគ្រីស្តទូត និងលិខិត ។ បន្ទាប់មកទៀត ក្រោយពីនាងយកទ្រព្យដ៏ថ្លៃថ្នូរទាំងនោះមកដាក់ក្នុងឃ្លាំងនៃដួងចិត្តរបស់នាង ហើយសូមចាំគម្ពីរព្យាការី និងកណ្ឌទាំងប្រាំពីរខាងដើមព្រះគម្ពីរ រួចកណ្ឌពង្សាវតាក្សត្រ លោក**អែសរ៉ា** និងព្រះនាង**អេសធែរ** ។*

*នៅទីបញ្ចប់ នាងអាចសិក្សាបទចម្រៀងរបស់ព្រះបាទ**សាឡូម៉ូន**ដោយមិនខ្លាចអ្វីឡើយ ។ ប្រសិនបើនាងចាប់ផ្តើមអានកណ្ឌនេះមុនគេ មុខជាវិញ្ញាណនាងត្រូវរបួស ពីព្រោះនាងមិនយល់អត្ថន័យអំពីចម្រៀងនៃអាពាហ៍ពិពាហ៍ខាងវិញ្ញាណកប់ទុកក្នុងពាក្យស្នេហាទាំងនោះ ។ ត្រូវឲ្យនាងប្រយ័ត្ននឹងកណ្ឌក្លែងក្លាយ (...) ។ មនុស្សត្រូវមានប្រាជ្ញាយ៉ាងជ្រៅ ទើបរកមាសកប់ក្នុងភក់បាន ។*

*លោកយេរ៉ូម លិខិតលេខ ១០៧*

## 71 អំពីការអប់រំជំនឿទាំងអំណរ

លោក**ដេអូក្រាស៊ីយ៉ាស** (Déogratias) ជាឧបដ្ឋាកនៅព្រះសហគមន៍ក្រុងកាតាស្ស ។ លោកជួបការលំបាកក្នុងពេលអប់រំមនុស្សពេញវ័យអំពីសេចក្តីសំខាន់ៗជាគ្រឹះនៃជំនឿ ព្រោះពួកគេមិនព្រមទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងពេលឆាប់ៗទេ ។ គាត់ក៏សូមយោបល់ពីលោក**អូគូស្តាំង** ។ លោកអូគូស្តាំង ទូន្មានលោកដេអូក្រាស៊ីយ៉ាស ក្នុងអត្ថបទមានចំណងជើងថា *«ដំបូន្មានសម្រាប់អប់រំជំនឿអំពីសេចក្តីសំខាន់ៗជាគ្រឹះ»* ។

*(...) សូមប្អូននឹកគិតថា គេចូលចិត្តស្តាប់យើង លុះត្រាតែយើងសប្បាយរីករាយនឹងការបង្រៀន ។ យើងនិយាយយ៉ាងពិរោះ មកពីយើងសប្បាយចិត្ត ។ បើយើងនិយាយស្រួលយល់ គេមុខជានឹងចាប់អារម្មណ៍នឹងសេចក្តីដែលយើងនិយាយនោះ ។ ហេតុនេះហើយ នៅពេលយើងពន្យល់សេចក្តីពិតអំពីជំនឿ មិនពិបាកបញ្ជាក់ថា ត្រូវចាប់ផ្តើមពីសេចក្តីណា ឬត្រូវចប់សេចក្តីណាដែរ ។ មិនពិបាកដឹងថា ត្រូវផ្លាស់ប្តូររបៀបពន្យល់ ទោះបីខ្លីឬវែងក្តី ដើម្បីឲ្យគ្រប់គ្រាន់ពេញលេញ ។ យើងត្រូវដឹងថា នៅពេលណាត្រូវបំព្រួញសេចក្តីឲ្យបានខ្លី ឬបន្លាយឲ្យវែងដែរ ។ ការសំខាន់ជាងគេ គឺត្រូវរកឃើញនូវវិធីអប់រំយ៉ាងសប្បាយរីករាយ ។ ប្រសិនបើរកឃើញហើយ គេនឹងស្តាប់យើងពុំខាន ។*

*ត្រង់សេចក្តីនេះ យើងមិនបាច់ស្វែងរកមូលហេតុឲ្យវែងឆ្ងាយទេ ។ បើគិតអំពីទ្រព្យសម្បត្តិលោកិយមានចែងថា «ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកដែលចែកទ្រព្យសម្បត្តិដោយសប្បាយរីករាយ» (១ ករ ៩,៧) ។ បើគិតអំពីសម្បត្តិវិញ្ញាណវិញ ក៏យើងត្រូវតែសប្បាយរីករាយដែរ ។ តែត្រូវឲ្យអំណរសប្បាយនោះស្របតាមពេលវេលាជាព្រះអំណោយទានពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដែលសព្វព្រះទ័យឲ្យសប្បាយដូច្នេះដែរ (...) ។*

*និយាយឲ្យចំទៅ ត្រូវចាប់ផ្តើមរៀបរាប់ពី «កាលពីដើមដំបូងបង្អស់ ព្រះជាម្ចាស់បង្កើតមេឃនិងដី» ដូចមានចែងក្នុងគម្ពីរកំណើត ហើយបន្តរហូតមកដល់ព្រះសហគមន៍សព្វថ្ងៃ ។ ពុំមានន័យថា យើងត្រូវសូត្រគម្ពីរបញ្ចកណ្ឌទាំងមូលដោយរត់មាត់ (...) រួចសូត្រពន្យល់គម្ពីរដំណឹងល្អទាំងបួន និងកិច្ចការគ្រីស្តទូតនោះទេ ។ ទេ! យើងត្រូវជ្រើសរើសសេចក្តីសំខាន់ៗដោយលើកព្រឹត្តិការណ៍ដ៏អស្ចារ្យជាងគេខ្លះ ដែលនាំឲ្យគេចាប់អារម្មណ៍យ៉ាងស្រួល ហើយដែលត្រូវចាត់ចែងតាមដំណាក់កាលសំខាន់ៗ (...) ។*

*ខ្ញុំសូមជំរាបប្អូនអំពីរបៀបបង្កើតបរិយាកាសសប្បាយរីករាយ ។ ខ្ញុំទទួលស្គាល់ថា ការនិយាយបន្តបន្ទាប់រហូតធ្វើឲ្យអ្នកស្តាប់ចាប់អារម្មណ៍ ពិតជាការលំបាកមែន គឺយើងត្រូវរកគ្រប់មធ្យោបាយនៃសំនួនវោហារ ដើម្បីធ្វើឲ្យក្រុមអ្នកស្តាប់ហ៊ាននិយាយ លែងអៀនខ្មាស ។ យើងត្រូវនិយាយយ៉ាងទន់ភ្លន់ (...) ទាំងរំលឹកប្រាប់គេថា យើងជាបងប្អូននឹងគ្នា ដើម្បីឲ្យគេលែងអៀន ។ យើងនឹងសួរគេដើម្បីឲ្យដឹងថា គេយល់ឬយ៉ាងណា ។ យើងលើកទឹកចិត្តគេឲ្យប្រាប់អំពីចម្ងល់ ប្រសិនបើគេឆ្ងល់ត្រង់ចំណុចណាមួយ (...) ។ យើងត្រូវនិយាយលេងសើចដើម្បីឲ្យគេចាប់អារម្មណ៍ឡើងវិញ តែកុំនិយាយអ្វីមិនសមគួរ ហើយក៏កុំឲ្យបាកប្រធានឡើយ ។ ត្រូវនិទានរឿងគួរឲ្យរំភើបចិត្តខ្លះ ធ្វើឲ្យគេភ្ញាក់ស្មារតី ឬរឿងព្រួយគួរឲ្យចាប់ចិត្ត ។*

*លោកអូគូស្តាំង «ដំបូន្មានខ្លះៗសម្រាប់អប់រំអំពីសេចក្តីសំខាន់ៗដំបូង»*

# លោកវ៉ាំងសង់នៅឡេរ៉ាំង (សតវត្សទី ៥)

## 72 តើមានវិធីទូទៅណា ដើម្បីសម្គាល់សេចក្តីពិតអំពីសាសនា?

*ខ្ញុំខិតខំខ្នះខ្នែងទាំងប្រុងប្រយ័ត្ន សួរមនុស្សដ៏ឧត្តុង្គឧត្តមជាច្រើនដែលមានចំណេះដឹងខ្ពង់ខ្ពស់ និងរស់នៅយ៉ាងវិសុទ្ធថា៖ «តើវិធីណាមួយដ៏ពិតប្រាកដទូទៅ និងស្ថិតស្ថេរសម្រាប់ឲ្យខ្ញុំវែកញែកជំនឿកាតូលិកដ៏ពិតប្រាកដ ចេញពីពាក្យភូតភរកុហករបស់អ្នកវង្វេងជំនឿ?» ។ ខ្ញុំក៏តែងតែទទួលចម្លើយពីអស់លោកថា៖ «(...) ត្រូវការពារជំនឿនេះដោយដាក់កំផែង*

•••

ពីរ គឺមុនដំបូងមានអំណាចនៃធម្មវិន័យរបស់ព្រះជាម្ចាស់ បន្ទាប់មក ការបញ្ជូនបន្តរបស់ព្រះសហគមន៍កាតូលិក ។

ប្រហែលមានម្នាក់សួរថា៖ «បើមានសាសនបញ្ញត្តិនៃព្រះគម្ពីរគ្រប់គ្រាន់ហើយ និងល្មមសម្រាប់គ្រប់ករណី តើហេតុអ្វីបានជាត្រូវភ្ជាប់ការបកស្រាយអត្ថន័យរបស់ព្រះសហគមន៍ថែមទៀតដូច្នេះ?» ។ មូលហេតុមកពីអត្ថន័យព្រះគម្ពីរស៊ីជម្រៅហេតុនេះហើយ បានជាមនុស្សទាំងអស់មិនយល់តាមអត្ថន័យដដែលដូចគ្នាទេ ។ ម្នាក់បកស្រាយព្រះបន្ទូលតាមរបៀបម៉្យាងម្នាក់ទៀតតាមរបៀបផ្សេងទៀត ។ យើងអាចនិយាយថា មានអ្នកបកស្រាយច្រើនរបៀបយ៉ាងណា ក៏មានយោបល់ច្រើនយ៉ាងនោះដែរ ។

សូម្បីតែក្នុងព្រះសហគមន៍កាតូលិកយើង ក៏ត្រូវយកចិត្តទុកដាក់ប្រកាន់យកតែសេចក្ដីណាដែលគ្រីស្តបរិស័ទជឿនៅគ្រប់កន្លែងជានិច្ច ហើយរួមទាំងអស់គ្នាដែរ ។ ការណ៍នេះ ពិតជាលក្ខណៈ «កាតូលិក» យ៉ាងត្រឹមត្រូវច្បាស់លាស់តាមអត្ថន័យពាក្យ «កាតូលិក» ដែលថែងអំពីអ្វីៗទាំងអស់ជាសកល ។

ប្រសិនបើយើងជឿតាមលក្ខណៈសកល លក្ខណៈបុរាណ និងលក្ខណៈទូទៅ ក៏បានដូច្នេះមែន ។ យើងជឿតាមលក្ខណៈសកល លុះត្រាតែយើងប្រកាសតែជំនឿដ៏ពិតប្រាកដ ដែលព្រះសហគមន៍នៅក្នុងពិភពលោកទាំងមូលប្រកាស ។ យើងជឿតាមលក្ខណៈបុរាណ លុះត្រាតែយើងមិនឃ្លាតឆ្ងាយពីគំនិតបុព្វបុរសដ៏វិសុទ្ធ និងពីគំនិតរបស់គ្រូបាធ្យាយរបស់យើងត្រង់ណាសោះ ។ នៅទីបញ្ចប់ យើងជឿដោយឯកភាពគ្នា លុះត្រាតែយើងសុខចិត្តទទួលសេចក្ដីបញ្ជាក់ និងគោលលទ្ធិរបស់អស់លោកអភិបាល ឬយ៉ាងហោចណាស់របស់អភិបាល និងរបស់បណ្ឌិតស្ទើរតែទាំងអស់ ក្នុងចំណោមអស់លោកពីបុរាណមក ។

បើមានសំណួរថ្មីចោទឡើង ដែលមហាសន្និបាតមិនបានរិះគិតនោះ ត្រូវតែរកយោបល់របស់គ្រូបាធ្យាយដ៏វិសុទ្ធ គឺគ្រូបាធ្យាយដែលរួមរស់តាមឯកភាពនៃជំនឿនៅសម័យអស់លោក និងកន្លែងអស់លោករស់នៅ គឺគ្រូបាធ្យាយណាដែលគ្រីស្តបរិស័ទចាត់ទុកជាគ្រូគួរឲ្យទុកចិត្ត ។ យើងត្រូវចាត់ទុកសេចក្ដីទាំងអស់ដែលអស់លោកកាន់ ជាលទ្ធិកាតូលិកដ៏ពិតប្រាកដរបស់ព្រះសហគមន៍ គ្មានការសង្ស័យ និងមិនល្អៀងឡើយ ។

វ៉ាំងសង់ នៅឡេរ៉ាំង «កំណត់ហេតុការណ៍» ៤៣៤



ចង្កៀងតាមរបៀបអ៊ីស្រាអែលនៅជំនាន់ដើម
«ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់បុព្វបុរសយើង...» (ហប ១,១)



Layout Histor.qxd 2/10/07 10:10 AM Page 129



# មជ្ឈិមសម័យនៅទ្វីបអឺរ៉ុប

## ព្រះសហគមន៍បែកបាក់គ្នា និងបង្កើតពិភពលោកមានលក្ខណៈជាគ្រីស្តបរិស័ទ (សតវត្សទី ៥–១១)

*ព្រះសហគមន៍រស់នៅអស់រយៈពេលបីសតវត្ស ទើបរដ្ឋអំណាចចក្រភពរ៉ូម៉ាំងទទួលស្គាល់គ្រីស្តសាសនា និងអនុញ្ញាតឲ្យគ្រីស្តបរិស័ទមានសិទ្ធិអាចកាន់សាសនារបស់ខ្លួនបាន ។ នៅចុងសតវត្សទី ៤ រចនាសម្ពន្ធព្រះសហគមន៍ ជាប់យ៉ាងជិតស្និទ្ធជាមួយរចនាសម្ពន្ធនៃចក្រភពរ៉ូម៉ាំង បានជាគ្រីស្តបរិស័ទស្មានថា ព្រះសហគមន៍អាចស្ថិតស្ថេរនៅរហូតបាន លុះត្រាតែមានរចនាសម្ពន្ធចក្រភពរ៉ូម៉ាំងនៅស្ថិតស្ថេរដែរ ។ ឧបមាថា គេបាត់បែង ភូមិភាគគ្រីស្តសាសនាតាមភូមិភាគនៃរដ្ឋអំណាច គឺគេបាត់អភិបាលព្រះសហគមន៍ទុកជាមន្ត្រីរាជការជាន់ខ្ពស់ ។ ព្រះចៅអធិរាជកោះហៅអស់លោកអភិបាលមកប្រជុំជាមហាសន្និបាត ក្នុងឋានៈទ្រង់ជាមេដឹកនាំគ្រីស្តសាសនា ។ល ។*

*ប៉ុន្តែ ក្រោយព្រះចៅ**ទេអូដូស** ចូលទិវង្គតទៅ (គ.ស. ៣៩៥) ចក្រភពរ៉ូម៉ាំងបែកជាពីរផ្នែក គឺចក្រភពប៉ែកខាងបស្ចិម និងចក្រភពប៉ែកខាងបូព៌ា ។ សតវត្សទី ៥ ខ្មាំងសត្រូវលុកលុយបំផ្លាញចក្រភពបស្ចិមឲ្យខ្ទេចខ្ទីអស់ ។ រីឯចក្រភពប៉ែកខាងបូព៌ានៅស្ថិតស្ថេរអស់រយៈពេល ១០ សតវត្សតទៅទៀត តែមានទំហំទឹកដីកាន់តែតូចទៅៗ ។ ទោះបីព្រឹត្តិការណ៍ទាំងនោះកើតឡើងយ៉ាងណាក៏ដោយ ក៏ព្រះសហគមន៍នៅតែស្ថិតស្ថេរដែរ ប៉ុន្តែ ព្រះសហគមន៍ប្រែប្រួលយ៉ាងខ្លាំង ។*

*អ្នកស្រាវជ្រាវប្រវត្តិវិទ្យា តែងតែហៅសតវត្សទាំង ១០ ចាប់ពីសតវត្សទី ៥ ដល់សតវត្សទី ១៦ នៅទ្វីបអឺរ៉ុបថា «យុគមជ្ឈិមសម័យ» ។ មានព្រឹត្តិការណ៍សំខាន់ៗកើតឡើងក្នុងរយៈពេលមួយពាន់ឆ្នាំនោះ ។ នៅទ្វីបអឺរ៉ុបមានសាងសង់វិសាលវិហារធំៗរចនាយ៉ាងស្អាត គ្រីស្តបរិស័ទរួមគ្នាទៅច្បាំង ដើម្បីទាមទារផ្នូររបស់ព្រះគ្រីស្ត ។ល ។ អារ្យធម៌អឺរ៉ុបកើតឡើងបន្តិចម្តងៗ ដោយយកគ្រីស្តសាសនាជាគ្រឹះ ។*

# ក. កុលសម្ពន្ធខាងជើងលុកលុយចក្រភពប៉ែកខាងបស្ចិម

### ១- កុលសម្ពន្ធខាងជើងលុកលុយ

នៅដើមសតវត្សទី ៥ កុលសម្ពន្ធរស់នៅខាងជើងទ្វីបអឺរ៉ុបចូលលុកលុយចក្រភពរ៉ូម៉ាំង ។ គ.ស. ៤១០ កុលសម្ពន្ធវិសិកូត (Wisigoth) ដោយមានលោកអាឡារិក (Alaric) ដឹកនាំ វាយដណ្តើមយកក្រុងរ៉ូម បំផ្លាញទីក្រុងឲ្យខ្ទេចខ្ទី

*នំបុ័ងនិងត្រី ជានិមិត្តរូបអំពីព្រះកាយព្រះគ្រីស្ត*
*(ស្រុកប៉ាឡេស្ទីន សតវត្សទី ៥)*

Layout Histor.qxd 2/10/07 10:10 AM Page 130

អស់ ។ កុលសម្ព័ន្ធមួយទៀត គឺពួកវ៉ានដាល (Vandales) វាយដណ្តើមយកស្រុកអាហ្វ្រិកខាងជើង ។ លោក**អូគូស្តាំង** ទទួលមរណភាពនៅ គ.ស. ៤៣០ នៅពេលខ្មាំងសត្រូវទាំងនោះឡោមព័ទ្ធក្រុងហ៊ីប៉ូន ។ នៅ គ.ស. ៤៣៩ ពួកគេដណ្តើមយកក្រុងកាតាស្សបាន ។ កុលសម្ព័ន្ធហឹង (Hun) មានលោក**អាទីឡា** (Attila) ណែនាំក៏លុកលុយបស្ចិមប្រទេសដែរ ។ នៅគ.ស. ៤៥២ លោក**ឡេអូ**ដ៏ប្រសើរឧត្តម ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម ចរចាជាមួយលោកអាទីឡា សូមដកទ័ពចេញពីក្រុងរ៉ូម ។ គ.ស. ៤៥៥ កុលសម្ព័ន្ធវ៉ានដាលវាយឈ្នះក្រុងរ៉ូម ហើយបំផ្លាញក្រុងរ៉ូមម្តងទៀត ។ ទីបញ្ចប់ នៅគ.ស. ៤៧៦ ខ្មាំងម្នាក់ទម្លាក់ព្រះចៅអធិរាជចក្រភពរ៉ូម ។ ចក្រភពរ៉ូមពីបុរាណមកដែលមានលក្ខណៈជាគ្រីស្តបរិស័ទ ផុតទៅហើយ ។ ចក្រភពប៉ែកបស្ចិមបែកបាក់អស់ ក្លាយជារាជាណាចក្រតូចៗតាមកុលសម្ព័ន្ធ ។

### *ក- តើដល់អវសាននៃពិភពលោកឬយ៉ាងណា?*

ដោយព្រះសហគមន៍ជាប់យ៉ាងជិតជិតជាមួយចក្រភពរ៉ូម៉ាំងនោះ គ្រីស្តបរិស័ទយល់ឃើញថា ដល់អវសាននៃពិភពលោកហើយ ។ នៅគ.ស. ៤១០ ពេលខ្មាំងវាយដណ្តើមយកក្រុងរ៉ូម កើតវិបត្តិជំនឿយ៉ាងធ្ងន់ គឺអ្នកកាន់សាសនាដទៃយល់ឃើញថា ព្រះរបស់គេដាក់ទណ្ឌកម្មដល់គេ ពីព្រោះគេឈប់គោរពព្រះទាំងនោះ ។ រីឯគ្រីស្តបរិស័ទវិញគេនឹកឆ្ងល់ថា ហេតុអ្វីបានជាគ្រីស្តទូត**សិលា**និង**ប៉ូល** ព្រមទាំងមរណសាក្សីទាំងប៉ុន្មាន ដែលមានសពកប់នៅក្រុងរ៉ូមនោះ មិនបានជួយការពារដូច្នេះ? គ្រីស្តបរិស័ទខ្លះបោទថា ព្រះជាម្ចាស់ដាក់ទណ្ឌកម្មគេ ព្រោះតែអំពើបាបរបស់គេ ។ ចុះកូនតូចៗដែលមិនបានប្រព្រឹត្តអំពើបាបសោះ ក៏ត្រូវវិនាសដូច្នេះដែរ? លោក**យេរ៉ូម**នៅវត្តអារាមនៅបេថ្លេហិម កើតទុក្ខព្រួយជាខ្លាំង ។ រីឯលោក**អូគូស្តាំង** នៅក្រុងហ៊ីប៉ូន ស្វែងរកអត្ថន័យអំពីព្រឹត្តិការណ៍ទាំង នោះ ហើយនិពន្ធសៀវភៅមួយមានចំណងជើងថា «*ក្រុងរបស់ព្រះជាម្ចាស់*» ។

### *ខ- អភិបាលព្រះសហគមន៍ការពារក្រុងរៀងៗខ្លួន*

នៅក្នុងសភាពការណ៍ដ៏សែនលំបាកនិងស្មុគ្រស្មាញនោះ គ្មានមន្រ្តីរាជការទៀតទេ នៅសល់តែរចនាសម្ព័ន្ធនៃព្រះសហគមន៍ប៉ុណ្ណោះអាចត្រួតត្រាស្រុកទេសបាន ។ ដូច្នេះ អភិបាលព្រះសហគមន៍ជាច្រើន នាំគ្នាបំពេញមុខងារមន្រ្តីរាជការវិញ ។ ឧបមាថា លោកអូគូស្តាំងបាត់បែងជំនួយដល់ជនភៀសខ្លួន លោកសូមអស់លោកអភិបាលនិងបូជាចារ្យ ឲ្យរស់នៅជាមួយប្រជាជនតទៅទៀត ។ នៅតំបន់ជាច្រើន អស់លោកអភិបាលនិងបព្វជិតបព្វជិតាខ្លះ នាំមុខកងទ័ពការពារទីក្រុងរបស់ខ្លួន ឬលើកទឹកចិត្តទាហាន ។ល ។

### *គ- កុលសម្ព័ន្ធហ្វ្រង់នាំគ្នាជឿលើព្រះគ្រីស្ត*

យូរៗទៅ ប្រជាជនសុខចិត្តចរចាជាមួយនឹងកុលសម្ព័ន្ធព្រៃទាំងនោះ ។ កុលសម្ព័ន្ធខ្លះក៏ជាគ្រីស្តបរិស័ទដែរ តែកាន់តាមគោលលទ្ធិលោក**អារីយ៉ូស** ។ ស្តេចនៃកុលសម្ព័ន្ធហ្វ្រង់ (Franc) ឈ្មោះ**ក្លូវិស** (Clovis) ប្រែចិត្តជឿលើព្រះគ្រីស្ត ដូចព្រះចៅកុងស្តង់តាំង កាលពីដើម (ប្រ. គ.ស. ៥០០) ។ គ្រីស្តបរិស័ទនាំគ្នាគាំទ្រលោកក្លូវិស ទុកជាព្រះចៅ**កុងស្តង់តាំង**ថ្មី ។

### *ឃ- ព្រះចៅយូស្ទីញ៉ាំង*

នៅចក្រភពប៉ែកបូព៌ា ព្រះចៅ**យូស្ទីញ៉ាំង** (Justinien គ.ស. ៥២៧-៥៦៥) ខិតខំប្រឹងប្រែងច្បាំងវាយដណ្តើមយកតំបន់ខ្លះមកវិញ ពីកុលសម្ព័ន្ធព្រៃដែលយកបានកាលពីមុន ។ ទ្រង់សាងសង់ព្រះវិហារសន្តី**សូភី** (Sainte Sophie) នៅកុងស្តង់ទីណូប្ល និងរៀបចំ «*ក្បួនច្បាប់*» ជនជាតិរ៉ូម ដោយប្រមែប្រមូលច្បាប់ទាំងប៉ុន្មានពីចក្រភពទាំងមូល ។ ក្បួនច្បាប់នេះក្លាយជាគ្រឹះនៃច្បាប់អឺរ៉ុបទាំងខាងសង្គមស៊ីវិលផង ទាំងខាងសាសនាផងរហូតដល់សព្វថ្ងៃ ។

Layout Histor.qxd 2/10/07 10:10 AM Page 131

## ២- កំណើតនៃសាសនាអ៊ីស្លាម ជនជាតិអារ៉ាប់លុកលុយ

មួយសតវត្សកន្លះក្រោយមក កុលសម្ពន្ធផ្សេងទៀតមកពីស្រុកអារ៉ាប៊ី ចូលលុកលុយពាសពេញទ្វីបអឺរ៉ុប និងបូព៌ាប្រទេស ។ ពួកគេធ្វើឲ្យព្រះសហគមន៍នៅជុំវិញសមុទ្រមេឌីតេរ៉ាណេប្រែប្រួលយ៉ាងខ្លាំង ។

### *ក- ស្រុកអារ៉ាប៊ី*

នៅសតវត្សទី ៧ ប្រជាជនផ្សេងៗដែលមានអារ្យធម៌និងសាសនាផ្សេងៗ រស់នៅជាមួយគ្នា ក្នុងស្រុកអារ៉ាប៊ី ។ អ្នកស្រុកដើមគោរពព្រះតែមួយអង្គគត់ ។ ជនជាតិយូដានិងគ្រីស្តបរិស័ទមកតាំងសហគមន៍នៅស្រុកនោះ តាមឆ្នេរសមុទ្រក្រហម និងភាគខាងត្បូងស្រុកនោះ (*យេម៉ែន Yémen*) ។ ប៉ុន្តែ កុលសម្ពន្ធភាគច្រើនជាជនពនេចរ គោរពព្រះជាច្រើន ហើយតែងតែធ្វើសង្គ្រាមវាយប្រឆាំងគ្នាគ្មានឈប់ឈរ ។ ក្រុងឡាម៉ិក *(La Mecque)* ជាកន្លែងជនជាតិអារ៉ាប់តែងធ្វើបូជនីយេសក៍ ទៅគោរពថ្មខ្មៅ (*Kaaba កាអាបា*) ហើយតែងតែជួបជុំគ្នាធ្វើពាណិជ្ជកម្ម ។

### *ខ- លោកម៉ូហាម៉ាត់ ជាព្យាការីចុងក្រោយបង្អស់*

ប្រហែលនៅ គ.ស. ៦១០ លោក**ម៉ូហាម៉ាត់**ប្រកាសដំណឹងមួយដែលលោកបានទទួលពីទេវទូតកាព្រីអែលថា ព្រះជាម្ចាស់នឹងវិនិច្ឆ័យដាក់ទោសមនុស្សលោកនៅពេលឆាប់ៗខាងមុខនេះ ។ មានព្រះជាម្ចាស់តែមួយអង្គគត់ មនុស្សទាំងអស់ត្រូវតែជឿ ត្រូវតែផ្ញើជីវិតលើព្រះអង្គ ត្រូវតែចុះចូលក្រោមអំណាចព្រះអង្គគ្រប់យ៉ាងជាដាច់ខាត (ពាក្យ «*ម៉ូស្លីម*» មានន័យថា «*អ្នកជឿ*» «*អ៊ីស្លាម*» មានន័យ*ថា* «*សូមចុះចូល*») ។ លោក**ម៉ូហាម៉ាត់**ជាព្យាការីចុងក្រោយបង្អស់ ដែលបន្តពីលោកអប្រាហាំនិងលោក**យេស៊ូ** (*គេហៅព្រះយេស៊ូថា លោកអ៊ីសាកវិញ*) ។

ព្រះជាម្ចាស់ប្រទានឲ្យលោកម៉ូហាម៉ាត់ណែនាំប្រជាជននៅស្រុកអារ៉ាប៊ី ឲ្យ
គោរពព្រះជាម្ចាស់តែមួយព្រះអង្គគត់ ហើយផ្តល់គម្ពីរគូរ៉ាន («*គូរ៉ាន*» មានន័យ
ថា «*អាន*») តាមភាសារបស់គេ ដើម្បីឲ្យប្រជាជនស្មើនឹងប្រជាជនឯទៀតៗ ។ 73
លោកម៉ូហាម៉ាត់ប្រមូលសេចក្តីខ្លះពីគម្ពីរសម្ពន្ធមេត្រីចាស់និងគម្ពីរសម្ពន្ធមេត្រីថ្មី 74
ដែលគ្រីស្តបរិស័ទតាមលោក**ណេស្តូរីយ៉ូស**ផ្សព្វផ្សាយ កត់ត្រាចូលក្នុងគម្ពីរគូរ៉ាន
នោះ ។ លោកក៏បន្ថែមសេចក្តីដែលទេវទូត**កាព្រីអែល**ប្រាប់លោកទៀត ។

នៅគ.ស. ៦២២ លោកម៉ូហាម៉ាត់រត់ចេញពីក្រុងឡាម៉ិកទៅក្រុងមេឌីន (Médine) ពីព្រោះកុលសម្ពន្ធរបស់លោកបដិសេធ មិនព្រមទទួលសេចក្តីលោកបង្រៀននោះទេ ។ អ៊ីស្លាមបរិស័ទហៅដំណើរចេញនេះថា «*អេស៊ីរ*» (Egire) ហើយរាប់ឆ្នាំចាប់តាំងពីពេលនោះមក ជាដើមសករាជរបស់គេ ។ លោកខិតខំណែនាំគ្រីស្តបរិស័ទឲ្យជឿតាមលោក តែគេមិនព្រម បានជាលោកបែរទៅជាច្បាំងប្រឆាំងនឹងពួកគេ ។ លោកម៉ូហាម៉ាត់ប្រកាសថា សាសនាថ្មីរបស់លោកនេះជាសាសនាសកល គឺសម្រាប់មនុស្សទូទៅក្នុងសកលលោក ។

### *គ- សង្គ្រាមដ៏វិសុទ្ធ*

ជនជាតិអារ៉ាប់រួមគ្នាធ្វើកងទ័ពមានកម្លាំងខ្លាំងក្លា អាចប្រឆាំងនឹងចក្រភពនានា មានចក្រភពរ៉ូម៉ាំងនិងចក្រភពពែរ្សជាដើម ដែលអន់ថយយ៉ាងខ្លាំង ។ គេច្បាំងដណ្តើមយកទឹកដីជាច្រើនយ៉ាងឆាប់រហ័ស ។ ពួកគេស៊ូស្លាប់យ៉ាងសប្បាយ «*ដោយពួកគេខំប្រព្រឹត្តតាមមាគ៌ារបស់ព្រះជាម្ចាស់*» (ពាក្យ «*ឌីយ៉ាដ*» Djihad បកប្រែប្រទ្បំថា «*សង្គ្រាមដ៏វិសុទ្ធ*») ។ ប្រជាជនស៊ីរីនិងអេស៊ីបដែលតែងតែមានទំនាស់ជាប្រចាំ ប្រឆាំងអំណាចក្រុងកុងស្តង់ទីណូប្ល ព្រោះរឿងសាសនានិងរឿងប្រកាន់ជាតិ ក៏មិនតយុទ្ធប្រឆាំងនឹងពួកអារ៉ាប់ទេ ដោយយល់ឃើញថា ពួកគេនាំសេរីភាពមក ។ ម្យ៉ាងទៀត អ៊ីស្លាមបរិស័ទក៏ប្រកាសជំនឿចំពោះព្រះជាម្ចាស់

Layout Histor.qxd 2/10/07 10:10 AM Page 132

# គម្ពីរគូរ៉ាន

## (73) អត្ថបទសម្រាំងពីស៊ូរ៉ាតនៃមេគោ (គម្ពីរគូរ៉ាន ជំពូក ២)

គម្ពីរគូរ៉ានចែកជា «ស៊ូរ៉ាត» គឺជំពូកតាមប្រធានបទចែងក្នុងជំពូកនោះ ។ ចំណងជើងស៊ូរ៉ាតទីពីរនេះ មកពី ខ ៦៣ និទានអំពីលោកម៉ូសេ យកមេគោមួយក្បាលធ្វើយញ្ញបូជាថ្វាយព្រះជាម្ចាស់ ។

*អ្នកមានចិត្តអាណិតអាសូរ មិនមែនជាអ្នកបែរមុខទៅទិសខាងកើតឬខាងលិចទេ ។ អ្នកជឿលើព្រះជាម្ចាស់ និងជឿលើពួកទេវទូត ជឿលើគម្ពីរគូរ៉ាន និងជឿលើព្យាការី ថ្ងៃចុងក្រោយបំផុតពិតជាគោរពប្រណិប័តន៍ព្រះជាម្ចាស់ ។ អ្នកនោះតែងយកទ្រព្យរបស់ខ្លួនទៅចែកឲ្យអ្នកដទៃ ក្មេងកំព្រា ជនក្រីក្រ អ្នកធ្វើដំណើរ និងអ្នកដែលសុំ ព្រោះខ្លួនស្រឡាញ់ព្រះជាម្ចាស់ ។ អ្នកនោះលោះមនុស្សជាប់ជាឈ្លើយសង្គ្រាមមកវិញ អធិដ្ឋានយ៉ាងខ្ជាប់ខ្ជួន ធ្វើទាន ធ្វើតាមពាក្យសន្យារបស់ខ្លួន ។ អ្នកនោះមានចិត្តអំណត់ ក្នុងពេលមានឧបសគ្គរារាំងផ្លូវក្នុងគ្រាដ៏លំបាក និងក្នុងគ្រាមនុស្សឃោរឃៅធ្វើបាបគេ ។ អ្នកទាំងនោះពិតជាមនុស្សសុចរិត និងកោតខ្លាចព្រះអម្ចាស់ ។*

*កាលពីដើមដំបូង មនុស្សទាំងអស់ចូលរួមជាប្រជាជាតិតែមួយ ។ ព្រះជាម្ចាស់ចាត់ព្យាការីជាច្រើនឲ្យមកជម្រាប និងទូន្មានពួកគេ ។ ព្រះអង្គប្រទានព្រះគម្ពីរនៃសេចក្ដីពិត (គឺគម្ពីរសម្ពន្ធមេត្រីចាស់និងថ្មី) ដើម្បីដោះស្រាយអំពីការវែកញែកជជែកគ្នា ។ ប៉ុន្តែ ទោះបីព្រះជាម្ចាស់ប្រទានសញ្ញាសម្គាល់យ៉ាងច្បាស់លាស់ ឲ្យមនុស្សទាំងអស់ដឹងអំពីសេចក្ដីពិតក្ដី ក៏មនុស្សនាំគ្នាឈ្លោះគ្នា ប្រណែនឈ្នានីសគ្នា ។ ព្រះជាម្ចាស់ណែនាំមនុស្សលោក គឺណែនាំអ្នកជឿសេចក្ដីពិត តែពួកគេមិនយល់ស្របគ្នាអំពីសេចក្ដីពិតនេះ ព្រះអង្គសព្វព្រះហឫទ័យអនុញ្ញាតឲ្យគេខ្វែងគំនិតគ្នាអំពីសេចក្ដីពិតនេះ ព្រោះព្រះអង្គណែនាំអ្នកដែលទ្រង់សព្វព្រះហឫទ័យទៅតាមមាគ៌ាដ៏ត្រឹមត្រូវ ។*

*ព្រះជាម្ចាស់ជាព្រះតែមួយព្រះអង្គគត់ គ្មានព្រះផ្សេងណាទៀតទេ ព្រះអង្គមានព្រះជន្មគង់នៅមិនប្រែប្រួលឡើយ ។ ព្រះអង្គមិនដែលអន់ស្មារតី ហើយក៏មិនដែលផ្ទុំលក់ដែរ អ្វីៗទាំងអស់ ទាំងលើមេឃ ទាំងលើផែនដី ក៏សុទ្ធតែជាកម្មសិទ្ធិរបស់ព្រះអង្គដែរ ។ តើនរណាអាចអង្វរព្រះអង្គដោយមិនបានទទួលសេចក្ដីអនុញ្ញាតពីព្រះអង្គជាមុនសិន? ព្រះអង្គជ្រាបអ្វីៗដែលនៅខាងមុខ និងនៅខាងក្រោយរបស់ពួកគេ ។ មនុស្សមានចំណេះអំពីព្រះអង្គ តែអំពីសេចក្ដីណាដែលទ្រង់សព្វព្រះហឫទ័យបង្រៀនដល់គេប៉ុណ្ណោះ ។ ព្រះរាជ្យរបស់ព្រះអង្គលាតនៅលើមេឃនិងលើផែនដី ព្រះអង្គមិននឿយហត់ការពារព្រះរាជ្យនោះទេ ។ ព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ជាព្រះដ៏ប្រសើរបំផុត ។*



*ព្រះនាមព្រះជាម្ចាស់តាមអក្សរអារ៉ាប់*

## (74) ពាក្យអធិដ្ឋានដំបូង

*ក្នុងព្រះនាមព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យប្រណីសន្ដោស និងមេត្តាករុណា! សូមលើកតម្កើងព្រះជាម្ចាស់ជាព្រះអម្ចាស់លើពិភពទាំងឡាយ ។*

*ព្រះអង្គមានព្រះហឫទ័យប្រណីសន្ដោសនិងមេត្តាករុណា ព្រះអង្គជាព្រះមហាក្សត្រ វិនិច្ឆ័យកាត់ទោសនៅថ្ងៃចុងក្រោយបង្អស់ យើងខ្ញុំសូមក្រាបថ្វាយបង្គំតែព្រះអង្គមួយគត់ យើងខ្ញុំអង្វរព្រះអង្គមេត្តាសង្គ្រោះយើងខ្ញុំផង ។*

*សូមព្រះអង្គមេត្តាដឹកនាំយើងខ្ញុំតាមមាគ៌ាដ៏ត្រឹមត្រូវ គឺមាគ៌ារបស់អស់អ្នកដែលគាប់ព្រះហឫទ័យព្រះអង្គ មិនមែនជាមាគ៌ារបស់អស់អ្នកបណ្ដាលឲ្យព្រះអង្គទ្រង់ព្រះពិរោធទេ មិនមែនជាមាគ៌ាអស់អ្នកដែលវង្វេងពីសេចក្ដីពិតឡើយ ។*

តែមួយព្រះអង្គគត់ដូចគេដែរ ។ អ៊ីស្លាមបរិស័ទចាត់ព្រះ**យេស៊ូ**ទុកជាមនុស្សដ៏ប្រសើរ ដូចលោក**អេរីយ៉ូស** លោក**ណេស្តូរីយ៉ូស** និងគ្រីស្តបរិស័ទជាច្រើននៅប៉ុព៌ាតែងជឿនោះ ។ ដូច្នេះ មានគ្នាជាច្រើនទទួលជំនឿថ្មីនោះដោយមិនប្រយ័ត្នខ្លួន ។

នៅគ.ស. ៦៣៨ កងទ័ពអារ៉ាប់វាយដណ្តើយកក្រុងយេរូសាឡឹម ។ ក្នុងពេលជាមួយគ្នានោះ គេក៏ដណ្តើមយកស្រុកស៊ីរី និងស្រុកប៉ាលេស្ទីនទៀតដែរ ។ ពួកគេវាយដណ្តើមយកក្រុងអាឡិចសង់ឌ្រី នៅ គ.ស. ៦៤២ ។ ស្រុកពែរ្ស៍នៅ គ.ស. ៦៥១ នៅចុងសតវត្សទី ៧ ពួកគេវាយដណ្តើមយកស្រុកអាហ្វ្រិកខាងជើង ដែលប្រឆាំងនឹងគេយ៉ាងខ្លាំង ។ តាំងពីពេលនោះមក លែងមានព្រះសហគមន៍នៅទឹកដីអាហ្វ្រិកខាងជើង ជាកន្លែងលោកអូគូស្តាំងជាអភិបាលពីដើម ។ តាំងពី គ.ស. ៧១១ កងទ័ពអារ៉ាប់ចាប់ផ្តើមច្បាំងដណ្តើមយកស្រុកអេស្ប៉ាញ រហូតដល់ក្រុងប៉័រជេ (Poitiers ស្រុកបារាំង) នៅ គ.ស. ៧៣២ ។

ចាប់ពីពេលនោះរហូតមក គ្រីស្តបរិស័ទប៉ែកខាងបស្ចិមចាត់អ៊ីស្លាមបរិស័ទទុកជាសត្រូវស្លាប់រស់ ហើយកើតសង្គ្រាមដែលគ្មានទីបញ្ចប់ ។ ចាប់ពីសតវត្សទី ១១ មក គ្រីស្តបរិស័ទប៉ែកបស្ចិមប្រទេសតែងតែលើកទ័ពជាញឹកញាប់ ដើម្បីទៅវាយរំដោះស្រុកព្រះយេស៊ូរស់នៅពីដើម ជាពិសេសរំដោះផ្នូររបស់ព្រះអង្គមកវិញ ។ គេហៅចម្បាំងទាំងនោះថា «*ច្បាំងដើម្បីឈើឆ្កាង*» *(Crusades)* ។ ស្តេចប្រទេសអេស្ប៉ាញច្បាំងដណ្តើមយកស្រុកអេស្ប៉ាញទាំងមូលមកវិញបាននៅ គ.ស. ១៤៩២ ។ ប៉ុន្តែ ជនជាតិអារ៉ាប់ក្រេបជញ្ជក់អារ្យធម៌ក្រិក និងបញ្ជូនវិទ្យាសាស្ត្របុរាណ បញ្ជូនបន្តមកប្រជាជននៅទ្វីបអឺរ៉ុប គេបង្កើតលេខនិងគណនា ។ គ្រីស្តបរិស័ទសាសនិកយូដានិងអ៊ីស្លាមបរិស័ទ តែងតែសន្ទនាជាមួយគ្នា ផ្លាស់ប្តូរយោបល់គ្នាអំពីវប្បធម៌និងសាសនា ជាពិសេសនៅស្រុកអេស្ប៉ាញ និងនៅកោះស៊ីស៊ីល ។ ក្នុងចំណោមទស្សនវិទូអ៊ីស្លាម មានលោក**អាវេរ៉ូអែស** (Averoès) មានឈ្មោះល្បីជាងគេ ។



*ព្រះវិហារអ៊ីស្លាម អាលអាក្សា នៅក្រុងយេរូសាឡឹម*

## ៣- ព្រះសហគមន៍មានរូបរាងថ្មី

ព្រះសហគមន៍បុរាណជាងគេ ទាំងនៅបូព៌ាប្រទេសក្តី អាហ្វ្រិកខាងជើងក្តី ត្រូវធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់ជនជាតិអារ៉ាប់ ។ ទោះបីអ៊ីស្លាមបរិស័ទយោគយល់គ្រីស្តបរិស័ទខ្លះក្តី ក៏ព្រះសហគមន៍ទាំងនេះចេះតែអន់ថយបន្តិចម្តងៗ រហូតមកដល់សព្វថ្ងៃ ។ ក្នុងចំណោមគ្រីស្តបរិស័ទទាំងនោះ មានគ្រីស្តបរិស័ទកុប្ត នៅប្រទេសអេស៊ីប (Coptes) និងគ្រីស្តបរិស័ទម៉ារូនិត (Maronites) នៅប្រទេសលីបង់ ។ ព្រះសហគមន៍ទាំងនោះរក្សារចនាសម្ពន្ធយ៉ាងរឹងមាំ គឺមានបព្វជិតទាំងក្រុមៗជាច្រើន និងធ្វើពិធីបុណ្យនានាតាមភាសា និងតាមវប្បធម៌របស់ខ្លួន ។ ផ្ទុយទៅវិញ ព្រះសហគមន៍នៅអាហ្វ្រិកខាងជើង កាន់តែអន់ទៅៗជាលំដាប់ ។ ឧបមា ពេលកងទ័ពអារ៉ាប់វាយដណ្តើមយកស្រុកអាហ្វ្រិកខាងជើង មានអភិបាលប្រហែល ៤០ នាក់ ។ នៅគ.ស. ១០៥៣ នៅសល់តែ ៥ នាក់ ។ នៅគ.ស. ១០៧៦ នៅសល់តែ ២ នាក់ប៉ុណ្ណោះ ។ នៅដើមសតវត្សទី ១២ គ្មានគ្រីស្តបរិស័ទនៅក្នុងតំបន់នោះទៀតទេ ។

កាលពីមុន គ្រីស្តបរិស័ទភាគច្រើនរស់នៅតាមស្រុកដែលនៅជុំវិញសមុទ្រមេឌីទែរ៉ាណេ និងមានក្រុងរ៉ូមជាមជ្ឈមណ្ឌលដ៏សំខាន់ ។ ចាប់តាំងពីអ៊ីស្លាមត្រួតត្រាស្រុកទាំងនោះ គ្រីស្តបរិស័ទភាគច្រើនរស់នៅប៉ែកខាងជើងនៃទ្វីបអឺរ៉ុប ។ ជនជាតិអារ៉ាប់ដែលនៅតាមឆ្នេរសមុទ្រមេឌីទែរ៉ាណេ ធ្វើឲ្យទំនាក់ទំនងរវាងបស្ចិមនិងបូព៌ាប្រទេសតាមផ្លូវទឹកកាន់តែលំបាកឡើងៗ ។

ម៉្យាងទៀត នាចុងសតវត្សទី ៦ ដើមសតវត្សទី ៧ ជនជាតិស្លាវ (Slaves) មកតាំងទីលំនៅតាមឆ្នេរសមុទ្រដាលម៉ាស៊ី ស្រុកម៉ាសេដូន រហូតដល់ស្រុកក្រិក ។ ពួកគេឃាត់ឃាំងគ្រីស្តបរិស័ទជាតិក្រិកខាងកើត គ្រីស្តបរិស័ទជាតិឡាតាំងខាងលិចមិនឲ្យទាក់ទងគ្នាបាន ។

### *ក- ចក្រភពប៊ីសង់*

ចក្រភពរ៉ូម៉ាំងប៉ែកខាងបូព៌ា បាត់បង់ស្រុកស៊ីរី ស្រុកប៉ាលេស្ទីន និងស្រុកអេស៊ីប ។ ជនជាតិស្លាវចូលលុកលុយភាគខាងជើង និងខាងកើត ។ ប្រជាជនចក្រភពនេះនិយាយភាសាក្រិក យកក្រុងប៊ីសង់ (Byzance) ជាឈ្មោះក្រុងកុងស្តង់ទីណូប្លពីដើម មកធ្វើជារាជធានី ។ ដោយអភិបាលព្រះសហគមន៍អាឡិសង់ឌ្រី យេរូសាឡឹម និងអន់ទីយ៉ូកបាត់អំណាច ព្រោះអស់លោករស់នៅក្នុងចំណោមជនជាតិអារ៉ាប់នោះ អភិបាលព្រះសហគមន៍កុងស្តង់ទីណូប្លមានឥទ្ធិពលកាន់តែខ្លាំងឡើងៗ ទៅជាមេដឹកនាំព្រះសហគមន៍នៅប៉ែកបូព៌ា និងធ្វើជាគូប្រណាំងប្រជែងអភិបាលព្រះសហគមន៍ក្រុងរ៉ូម ។

### *ខ- ព្រះសហគមន៍ប៉ែកបស្ចិមប្រទេស*

ក្រោយពីកុលសម្ពន្ធព្រៃចូលលុកលុយបស្ចិមប្រទេស មិនសូវមានទីក្រុងទេ ហើយក៏មិនសូវមានពាណិជ្ជកម្មដែរ គឺមានតែកសិកម្មប៉ុណ្ណោះ ។ សីលធម៌ចុះអន់ថយយ៉ាងខ្លាំង មនុស្សកាន់តែឃោរឃៅទៅៗ រីឯការសិក្សានិងសិល្បៈធ្លាក់ដុនដាប ។ ព្រះសហគមន៍អន់ថយជាខ្លាំងអស់រយៈពេលជាច្រើនសតវត្ស គឺគ្រីស្តបរិស័ទនាំគ្នាគោរពអារក្ខអ្នកតា ម្ចាស់ទឹកម្ចាស់ដី រួមជាមួយនឹងព្រះគ្រីស្ត គេបង្កើតសាសនាប្រជាប្រិយ គេគោរពសន្តបុគ្គលជាច្រើន និងនាំគ្នាជឿរឿងព្រេងជាច្រើនដែរ ។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី ក៏ក្រុមគ្រួសារបព្វជិតនៅតែធ្វើឲ្យព្រះសហគមន៍មានជីវិតរស់រវើកជាលំដាប់ ។ អស់លោកបន្តការប្រកាសដំណឹងល្អក្នុងជនបទ ។ បព្វជិតជាតិអៀរឡង់បង្កើតពិធីលើកលែងទោស ដោយមានក្បួនកំណត់ទណ្ឌកម្ម លែងធ្វើពិធីលើកលែងទោសរួមទៀតហើយ ។ មានបព្វជិតខ្លះតាមក្រុមគ្រួសារបេណោឌិកតូ នៅតែអធិប្បាយព្រះគម្ពីរ ។

Layout Histor.qxd 2/10/07 10:10 AM Page 135

## *គ- ព្រះសហគមន៍ខាងបូព៌ា*

រដ្ឋអំណាចកើតអសន្តិសុខផ្ទៃក្នុង ។ រីឯគ្រីស្តបរិស័ទវិញក៏ឈ្លោះគ្នាអំពីការគោរពរូបព្រះគ្រីស្ត ។ នៅ គ.ស. ៧២៦ ព្រះចៅ**ឡេអូ**បញ្ជាឲ្យបំបាក់រូបព្រះគ្រីស្តដែលតាំងក្នុងបរមរាជវាំង នាំឲ្យបព្វជិតនិងប្រជាជនបះបោរ ។ ព្រះមហាក្សត្រិយានីព្រះនាម**អ៊ីរ៉ែន** (Irène) កោះហៅមហាសន្និបាតសកលទី ៧ នៅក្រុងនីសេ (គ.ស. ៧៨៧) ដែលអនុញ្ញាតឲ្យគ្រីស្តបរិស័ទគោរពរូប ទុកជាតំណាងរបស់ព្រះគ្រីស្ត ។

ក្រុងប៊ីសង់លូតលាស់ឡើង ។ មានក្រុមបព្វជិតជាច្រើនកើតឡើង ។

## *ឃ- ព្រឹត្តិការណ៍សំខាន់ៗខាងបស្ចិម*

អភិបាលព្រះសហគមន៍ក្រុងរ៉ូមអភិសេកមេដឹកនាំកុលសម្ពន្ធ**ហ្វ្រង់** ទៅជាស្តេច ។ ក្រោយមកស្តេចហ្វ្រង់នេះធ្វើសង្គ្រាមដេញជនជាតិអារ៉ាប់ចេញពីអឺរ៉ុប គឺជួយតែងតាំងអភិបាលក្រុងរ៉ូម ឲ្យត្រួតត្រាស្រុកមួយហៅថា «*រដ្ឋរបស់មហាបូជាចារ្យ*» (Etats pontificaux) នៅ (គ.ស. ៧៥៦ រហូតដល់ គ.ស. ១៨៧០) ។

ស្តេច**ការូលូស-ម៉ាញ៉ូស** (Charlemage ៧៦៨-៨១៤) ប្រមែប្រមូលរដ្ឋនានានៃទ្វីបអឺរ៉ុប បង្កើតចក្រភពឡើងវិញ ។ នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត គ.ស. ៨00 អភិបាលក្រុងរ៉ូមអភិសេកព្រះអង្គជាព្រះចៅ បណ្តាលឲ្យព្រះចៅក្រុងកុងស្តង់ទីណូប្លទ្រង់ព្រះពិរោធ ព្រោះទ្រង់តែងតែឈ្វេងយល់ថា មានព្រះចៅតែមួយគត់ គឺព្រះចៅក្រុងកុងស្តង់ទីណូប្លនោះឯងប៉ុណ្ណោះ ។

ព្រះចៅការូលូស-ម៉ាញ៉ូស ជ្រើសរើសអភិបាលព្រះសហគមន៍ដោយផ្ទាល់ព្រះអង្គ និងបាត់ទុកអស់លោកជាមន្ត្រីជាន់ខ្ពស់ ។ ទ្រង់កែទម្រង់ក្បួនពិធីបុណ្យតាមរបៀបព្រះសហគមន៍ក្រុងរ៉ូម និងគោលគំនិតគម្ពីរសម្ពន្ធមេត្រីចាស់ ។ ពិធីនិងច្បាប់ត្រឡប់ទៅជាមានសារៈសំខាន់ជាងជំនឿ ។ គ្រីស្តបរិស័ទលែងធ្វើពិធីរួមគ្នាទៀតទេ ហើយបែរជាធ្វើពិធីម្នាក់ៗវិញ ។ បូជាចារ្យលែងយកនំប៉័ងធម្មតាមកប្រើក្នុងអភិបូជាទៀត គឺប្រើនំប៉័ងឥតមេវិញ ។ ដោយសារគ្រីស្តបរិស័ទស្តាប់ភាសាឡាតាំងមិនបាន បូជាចារ្យសូត្រធម៌ក្នុងអភិបូជាយ៉ាងស្ងាត់ៗ ទាំងបែរខ្នងដាក់ប្រជាជន បូជាចារ្យថ្វាយអភិបូជាម្នាក់ឯង ។ ប៉ុន្តែ ព្រះចៅបង្កើតមហាវិទ្យាល័យសម្រាប់សិក្សាព្រះគម្ពីរ បញ្ជាឲ្យគេប្រមូលសៀវភៅរបស់គ្រូបាធ្យាយ និងក្បួនពិធីបុណ្យនានា ។ ក្រុមបព្វជិតនាំគ្នាចម្លងគម្ពីរជាច្រើនច្បាប់ ទាំងគូររូបយ៉ាងស្អាត ។ ទេវវិទូដ៏ល្បីឈ្មោះខ្លះរៀននៅមហាវិទ្យាល័យនោះ ។

សន្ត**ស៊ីរីុស**និង**មេថូដ** នាំគ្នាប្រកាសដំណឹងល្អនៅអឺរ៉ុបកណ្តាល ហើយបង្កើតអក្សររុស្ស៊ី (គ.ស. ៨៦៣) ។ លោកទាំងពីរបកប្រែព្រះគម្ពីរ និងពិធីបុណ្យជាភាសាស្លាវ៉ុង ។

ប្រជាជនខ្លះ (*ហុងគ្រី ប៉ូឡូញ*) ចូលគ្រីស្តសាសនាតាមស្តេចរបស់គេ ។

## *ង- របបសក្តិភូមិ*

ទ្វីបអ៊ឺរ៉ុបកើតសង្គ្រាមស៊ីវិលឥតឈប់ឈរអស់រយៈពេលច្រើនសតវត្ស គ្មានរដ្ឋអំណាចត្រួតត្រាស្រុកទៀតទេ ។ ហេតុនេះហើយ បានជាកើតរបបសក្តិភូមិ គឺអ្នកពូកែច្បាំងក្លាយទៅជាម្ចាស់ទឹកដីដែលខ្លួនអាចការពារបាន ។ យូរៗទៅ អភិបាលព្រះសហគមន៍ក៏ក្លាយទៅជាម្ចាស់ទឹកដីជាច្រើនអនេក ។

ស្តេចឬព្រះចៅជ្រើសរើសអភិបាលឬមេវត្ត ហើយក៏តែងតាំងអស់លោកទុកជាស្តេចត្រាញ់ត្រួតត្រាតំបន់ផ្សេងៗនិងមានកងទ័ពថែមទៀតផង ។ ដូច្នេះ អភិបាលនិងបូជាចារ្យជាច្រើនជាគ្រីស្តបរិស័ទមិនសូវល្អ ព្រោះស្តេចតែងជ្រើសរើសអ្នកពូកែច្បាំង ឬអ្នកដែលមានលុយសូកប៉ាន់ ឲ្យបម្រើមុខងារជាអភិបាលសម្រាប់ការពារតំបន់នោះ ជាងជ្រើសរើសអ្នកដែលមានជំនឿមាំមួន ។ សូម្បីតែអភិបាលក្រុងរ៉ូម ក៏នៅក្រោមអំណាចរបស់ស្ត្រីអភិជនក្រុងនោះដែរ ។

Layout Histor.qxd 2/10/07 10:10 AM Page 136

អភិបាល បូជាចារ្យ និងបព្វជិតត្រឡប់ទៅជាវណ្ណៈមួយដ៏សំខាន់ក្នុងសង្គម គឺអស់លោកទទួលមុខងារអធិដ្ឋាន ។ មានវណ្ណៈមួយទៀត គឺអ្នកត្រកូលខ្ពង់ខ្ពស់មានមុខងារច្បាំង និងវណ្ណៈទាសករដែលមានមុខងាររកស្បៀងអាហារសម្រាប់វណ្ណៈទាំងពីរទៀត ។

## ៥- ព្រះសហគមន៍ខាងបស្ចិមនិងខាងបូព៌ា បែកបាក់គ្នា

ចាប់តាំងពីសតវត្សទី ៥ រហូតមក ព្រះសហគមន៍ប៉ែកខាងបស្ចិម និងព្រះសហគមន៍ប៉ែកខាងបូព៌ា បាក់បែកគ្នាកាន់តែខ្លាំងឡើងៗ ដោយមានមូលហេតុខាងនយោបាយ ខាងវប្បធម៌ និងខាងគោលលទ្ធិនៃជំនឿ ។

### *ក- មូលហេតុខាងនយោបាយ*

ព្រះសហគមន៍ប៉ែកខាងបូព៌ានៅជាប់យ៉ាងជិតស្និទ្ធនឹងព្រះចៅអធិរាជដែលតែងតាំង ឬទម្លាក់អភិបាលព្រះសហគមន៍កុងស្តង់ទីណូប្លតាមតែព្រះហឫទ័យ ។ រីឯអភិបាលក្រុងរ៉ូមរំដោះខ្លួនរួចផុតពីអំណាចព្រះចៅក្រុងកុងស្តង់ទីណូប្ល ហើយតែងតាំងអភិសេកព្រះចៅនៅបស្ចិមវិញ បណ្តាលឲ្យព្រះសហគមន៍បស្ចឹមក៏រួចពីការត្រួតត្រារបស់អភិបាលនៅកុងស្តង់ទីណូប្លដែរ ។

### *ខ- មូលហេតុខាងវប្បធម៌*

ព្រះសហគមន៍ទាំងពីរមានអរិយធម៌ប្លែកពីគ្នា និយាយភាសាផ្សេងៗពីគ្នាស្តាប់គ្នាលែងកើត គឺគ្រីស្តបរិស័ទខាងបូព៌ាស្តាប់ភាសាឡាតាំងមិនបាន រីឯគ្រីស្តបរិស័ទខាងបស្ចិម រីតតែស្តាប់ភាសាក្រិកមិនកើត ។ គ្រីស្តបរិស័ទខាងបូព៌ាមានអរិយធម៌ខ្ពង់ខ្ពស់របស់ជនជាតិក្រិក ទាំងខាងអក្សរសាស្ត្រ ទាំងខាងសាសនា ។ ពេលជួបគ្នា គ្រីស្តបរិស័ទឡាតាំងនិងគ្រីស្តបរិស័ទក្រិក មើលងាយគ្នាទៅវិញទៅមក គឺគ្រីស្តបរិស័ទក្រិកចាត់ទុកគ្រីស្តបរិស័ទឡាតាំងជាមនុស្សព្រៃ គ្មានសុជីវធម៌គ្មានដឹងអ្វីសោះ គិតតែពីស៊ីផឹកប៉ុណ្ណោះ ។ ឯគ្រីស្តបរិស័ទឡាតាំងវិញ ប្រកាន់គ្រីស្តបរិស័ទក្រិកទុកជាមនុស្សខ្ជិល បេះតែជជែកវែកញែកមិនចេះអស់ មិនចេះហើយ ។

### *គ- មូលហេតុខាងពិធីបុណ្យ និងខាងគោលលទ្ធិគ្រីស្តសាសនា*

គ្រីស្តបរិស័ទក្រិកតែងតែនឹកគិតថា ពិធីនានាមានគោលដៅបញ្ជាក់ជំនឿ ។ ហេតុដូច្នេះហើយ បានជាអ្នកផ្លាស់ប្តូរពិធីបុណ្យ ក៏ដូចជាផ្លាស់ប្តូរជំនឿដែរ ។ គ្រីស្តបរិស័ទខាងបូព៌ាយល់ឃើញថា ពិធីតមអាហារ នំប៉ុងឥតមេ ប្រទានព្រះសហគមន៍ទុកពុកមាត់សុទ្ធតែមានសារៈសំខាន់ណាស់ ។ នៅបូព៌ាមានតែបព្វជិតប៉ុណ្ណោះជាអ្នកបួស ចំណែកបូជាចារ្យវិញតែងតែមានគ្រួសារ ។ រីឯគ្រីស្តបរិស័ទឡាតាំងវិញ គេបំបែកពិធីនឹងជំនឿយ៉ាងស្រួល គឺបូជាចារ្យត្រូវតែបួស ឬគ្រីស្តបរិស័ទដែលមានគ្រួសារហើយ រួចទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនោះ តែគ្មានសិទ្ធិរួមបវេណីជាមួយភរិយាទៀតឡើយ ។

គ្រីស្តបរិស័ទក្រិកបានចោទគ្រីស្តបរិស័ទឡាតាំងថា គេបន្ថែមពាក្យថា «*ព្រះវិញ្ញាណក៏ហូរចេញពីព្រះបុត្រាដែរ*» ក្នុងធម៌ប្រកាសជំនឿនៃមហាសន្និបាតនីសេ-កុងស្តង់ទីណូប្ល ដែលគ្រាន់តែចែងថា «*ព្រះវិញ្ញាណហូរចេញពីព្រះបិតាមក*» ។ ពាក្យខុសបន្តិចនេះ នាំឲ្យគេយល់អំពីសកម្មភាពនៃព្រះវិញ្ញាណតាមរបៀបប្លែកបន្តិច ។ ឯគ្រីស្តបរិស័ទឡាតាំងដែលមិនស្គាល់ប្រវត្តិសាស្ត្រវិញ ចោទគ្រីស្តបរិស័ទក្រិកថា គេដកឃ្លានោះចេញពីធម៌ប្រកាសជំនឿវិញ ។

### *ឃ- អភិបាលក្រុងរ៉ូម និង អភិបាលក្រុងកុងស្តង់ទីណូប្ល*

គ្រីស្តបរិស័ទជាតិក្រិកយល់ឃើញថា អស់លោកអភិបាលរួបរួមគ្នាក្នុងការណែនាំព្រះសហគមន៍ ។ ប៉ុន្តែ អភិបាលក្រុងរ៉ូមតែងចូលដៃក្នុងរឿងព្រះសហគមន៍នានា ដោយអះអាងថា ខ្លួនបន្តមុខតំណែងពីលោកសិលាមក និងមានមុខងារ

Layout Histor.qxd 2/10/07 10:10 AM Page 137

ណែនាំព្រះសហគមន៍ទាំងមូល ។ រីឯគ្រីស្តបរិស័ទនៅខាងបូព៌ាវិញ គេចាត់ទុកអភិបាលក្រុងរ៉ូមគ្រាន់តែជាប្រធានកិត្តិយសលើអភិបាលឯទៀតៗប៉ុណ្ណោះ ។

ចាប់តាំងពីសតវត្សទី ៥ រហូតដល់សតវត្សទី ១១ គ្រីស្តបរិស័ទខាងបូព៌ា និងខាងបស្ចិមបែកបាក់គ្នាជាញឹកញាប់ ហើយក៏ស្រុះស្រួលគ្នាវិញ ។ នៅគ.ស. ១០៥៤ អភិបាលក្រុងរ៉ូមឈ្មោះលោក**ឡេអូ ទី ៩** មានបំណងរួបរួមជាមួយព្រះចៅកុងស្តង់ទីណូប្លូ ព្រោះលោកទាំងពីរមានសត្រូវតែមួយដូចគ្នា គឺជនជាតិណរ័ម៉ង់ (Normands) ដែលនៅខាងត្បូងស្រុកអ៊ីតាលី ។ លោកមានបំណងចងសម្ពន្ធមេត្រីខាងយោធា តែត្រូវស្រុះស្រួលគ្នាខាងសាសនាជាមុនសិន ។

ទីប្រឹក្សានិងទូតរបស់អភិបាលក្រុងរ៉ូម ឈ្មោះ**ហឹមបែរត៍** (Humbert) មិន
ស្គាល់អរិយធម៌ក្រិកទេ ហើយជាមនុស្សមានចិត្តតឹងរ៉ឹងដែរ ។ អភិបាលក្រុងកុង
ស្តង់ទីណូប្លូ **មីសែល-សេរូឡែរ** (Michel Cérulaire) ក៏មានចិត្តខ្លាំងដែរ ។ លោក
75 សប្បាយចិត្តដោយគ្មានទំនាក់ទំនងជាមួយព្រះសហគមន៍ក្រុងរ៉ូម បើដូច្នេះ លោក
អាចណែនាំព្រះសហគមន៍ក្រិកតាមអំពើចិត្តរបស់លោកបាន ។

## *ង- ការបាក់បែកគ្នា*

ទូតរបស់អភិបាលក្រុងរ៉ូមលើករឿងដែលគេស្គាល់គ្រប់គ្នាជាយូរយារមក
ហើយ មកចោទព្រះសហគមន៍កុងស្តង់ទីណូប្លូ ។ ដោយលោកហឹមបែរត៍ ចរចា
ជាមួយលោកមីសែល-សេរូឡែរ មិនបាន លោកក៏បណ្តេញលោកអភិបាលចេញពី
ព្រះសហគមន៍យ៉ាងឱឡារិក នៅក្នុងព្រះវិហារសន្តិសុភា ។ ពាក្យបណ្តេញ ដែល
ទូតអភិបាលក្រុងរ៉ូមនិពន្ធនោះបង្ហាញឲ្យដឹងច្បាស់ថា លោកជាមនុស្សល្ងង់មិនដឹង
អ្វីសោះ គឺលោកចោទគ្រីស្តបរិស័ទក្រិកថា គេបានដកពាក្យ «*ព្រះវិញ្ញាណក៏ហូរ
ចេញពីព្រះបុត្រាដែរ*» ចោទថាបូជាចារ្យមានគ្រួសារ ។ល។ គាត់ក៏មិនដឹងថា
76 ពាក្យ «*ម៉ារាណាថា*» (*វវ ២២,៣០*) មិនមែនជាពាក្យបណ្តេញគ្រីស្តបរិស័ទម្នាក់
ចេញពីព្រះសហគមន៍ទេ គឺមានន័យថា «*បពិត្រព្រះអម្ចាស់ សូមយាងមក*» ។



*ឈើឆ្កាងតាមរបៀបសែលទិក (Celtique) (ប្រទេសអៀរឡង់ដ៍)*

## 75 ពាក្យស្ដីបន្ទោសបព្វជិតនីសេតាស ស្ដេតាតូសទៅគ្រីស្ដបរិស័ទឡាតាំង

លោក**នីសេតាស ស្ដេតាតូស** (Nicétas Stéthatos ប្រ.គ.ស. ១០០៥-១០៩០) ជាបព្វជិតម្នាក់នៅកុងស្តង់ទីណូប្ល ។ លោកជាអ្នកនិពន្ធសៀវភៅអប់រំខាងវិញ្ញាណ ហើយបង្កើតពាក្យដែលគ្រីស្ដបរិស័ទតែងសូត្រភាវនាឥតឈប់ឈរតាមដំណើរខ្យល់ដង្ហើមចេញចូលថា «*ឱ! ព្រះអម្ចាស់យេស៊ូគ្រីស្ដជាព្រះបុត្រារបស់ព្រះជាម្ចាស់អើយ សូមអាណិតអាសូរខ្ញុំផង!*» ។

*អ្នកដែលចូលរួមពិសានំបុ័ងឥតមេ នៅតែក្រោមម្លប់នៃធម្មវិន័យ និងចូលរួមពិធីជប់លៀងរបស់ជនជាតិយូដានៅឡើយ គេមិនបរិភោគអាហាររបស់ព្រះជាម្ចាស់ ដែលជាអាហារខាងវិញ្ញាណដែលមានព្រះជន្មទេ (...) ។ តើអ្នករាល់គ្នាអាចចូលរួមជាមួយព្រះគ្រីស្ដ ជាព្រះដែលមានព្រះជន្មគង់នៅដូចម្ដេចបាន បើអ្នករាល់គ្នាបរិភោគនំបុ័ងឥតមេ ដែលស្លាប់ក្រោមម្លប់ធម្មវិន័យ តែមិនបរិភោគមេនៃសម្ពន្ធមេត្រីថ្មីដូច្នេះ (...) ។ តើនរណាបង្រៀនអ្នករាល់គ្នា ឲ្យបំបែកគ្រួសាររបស់បូជាចារ្យ (...) ? ។ ហេតុនេះហើយ សូមបងប្អូនពិនិត្យមើលបញ្ហាទាំងនេះឲ្យបានច្បាស់ សូមយល់ថា ជំងឺទាំងបួនដែលខ្ញុំបានរៀបរាប់ខាងលើនេះបណ្ដាលពីសាសនាយូដា គឺបងប្អូនពិសានំបុ័ងឥតមេ ធ្វើពិធីតមអាហារនៅថ្ងៃសៅរ៍ កាន់វិន័យឲ្យបូជាចារ្យបួស និងថ្វាយតង្វាយនៅថ្ងៃតមអាហារ ។*

## 76 ពាក្យបណ្ដេញលោកមីសែល–សេរូឡែរចេញពីព្រះសហគមន៍ (គ.ស. ១០៥៤)

លោក**ហឹមបែរត៍** (Humbert) កើតនៅស្រុកបារាំង ។ លោកយកចិត្តទុកដាក់កែទម្រង់ព្រះសហគមន៍យ៉ាងខ្លាំង ។ អភិបាលក្រុងរ៉ូម**ឡេអូទី ៩** ហៅលោកធ្វើជាស្មៀនរបស់លោកនៅក្រុងរ៉ូម តែងតាំងលោកជាទីប្រឹក្សា និងចាត់លោកឲ្យទៅបំពេញបេសកកម្មផ្សេងៗ ។ លោកមានចិត្តតឹងរ៉ឹង មិនសូវយល់ចិត្តគេទេ គ្មានចិត្តមេត្តាសោះ ។

លោក**មីសែល-សេរូឡែរ** (Michel Cérulaire ១០០០-១០៥៨) កើតក្នុងគ្រួសារអភិជន ក្រុងកុងស្តង់ទីណូប្លូ ។ លោកជាប់ឃុំឃាំង ក្រោយពីបានឃុបឃិតធ្វើគុតព្រះចៅ លោកក៏បួសជាបព្វជិត ។ ព្រះចៅថ្មីស្រឡាញ់លោក ហើយតែងតាំងលោកជាអភិបាលព្រះសហគមន៍កុងស្តង់ទីណូប្លូ ។ លោកជំទាស់នឹងគ្រីស្ដបរិស័ទឡាតាំងយ៉ាងខ្លាំង ។ នៅគ.ស. ១០៥៨ ព្រះចៅថ្មីមួយអង្គទៀតចាប់ចងលោក និងនិរទេសលោកទៀត ។

*(...) លោក**មីសែល**ដែលគេហៅយ៉ាងខុសថា អភិបាល អស់អ្នកដែលកាន់តាមសេចក្ដីលេលារបស់គាត់ តែងតែផ្សព្វផ្សាយការបាក់បែកគ្នា ពាក្យវង្វេងជំនឿក្រុងកុងស្តង់ទីណូប្លូ ។ គេលក់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ គេក្រៀវភ្ញៀវរបស់គេ ដើម្បីតែងតាំងភ្ញៀវទាំងនោះជាបូជាចារ្យ ឬជាអភិបាល (...) ។ គេអនុញ្ញាតឲ្យអ្នកបម្រើអាសនៈរៀបអាពាហ៍ពិពាហ៍ (...) គេប្រឆាំងនឹងព្រះវិញ្ញាណ ដោយដកពាក្យ «ហូរចេញពីព្រះបុត្រា» ពីធម៌ប្រកាសជំនឿ ។ គេតែងប្រកាសថា នំបុ័ងមានមេក៏មានជីវិត (...) ។ ជាងនេះទៅទៀត គេទុកពុកមាត់ និងសក់វែង មិនអនុញ្ញាតឲ្យអ្នកកាត់សក់ខ្លី និងកោរពុកមាត់ទទួលព្រះកាយទេ (...) ។*

*ហេតុដូចនេះហើយ ដោយទ្រាំនឹងពាក្យជេរដ៏ហួសហេតុ និងពាក្យប្រមាថអាសនៈរបស់គ្រីស្ដទូតទី ១ (...) យើងនឹងចុះហត្ថលេខា ក្រោមពាក្យបណ្ដេញរបស់លោកមីសែល-សេរូឡែរ និងអស់អ្នកកាន់ជើងគាត់ឲ្យចេញពីព្រះសហគមន៍ តាមអភិបាលក្រុងរ៉ូមដ៏ជាទីគោរពបំផុតបានប្រកាសថា សូមមីសែលជាពន្លកថ្មី ដែលទទួលឈ្មោះដោយខុសច្បាប់ជាអភិបាល (...) និងអស់អ្នកដែលតាមគាត់ទាំងប្រកាសពាក្យវង្វេងជំនឿ ប្រសិនបើគេមិនប្រែចិត្តគំនិតទេ ត្រូវបណ្ដេញចេញពីព្រះសហគមន៍ តាមពាក្យថា «ម៉ារ៉ាណាថា» (...) រួមជាមួយអ្នកវង្វេងជំនឿទាំងអស់ ជាពិសេសជាមួយមារ និងបរិវារវា ។ អាម៉ែន! អាម៉ែន! អាម៉ែន! ។*

Layout Histor.qxd 2/10/07 10:10 AM Page 139

### *ច- ព្រះសហគមន៍ខិតខំផ្សះផ្សាគ្នាវិញ*

នៅពេលនោះ គ្មាននរណាម្នាក់ចាប់អារម្មណ៍នឹងពាក្យបណ្តេញនោះទេ ។ អភិបាលក្រុងរ៉ូម ទទួលមរណភាពមុនទូតរបស់លោកបណ្តេញអភិបាលកុងស្តង់ទីណូប្លនោះ ដូច្នេះទូតលែងមានអំណាច ហើយការបណ្តេញចេញពីព្រះសហគមន៍ក៏ឥតបានការតាមច្បាប់ដែរ ។ ប៉ុន្តែ គ.ស. ១០៥៤ ជាកាលបរិច្ឆេទមួយដ៏សំខាន់ ព្រោះតាំងពីពេលនោះមក ព្រះសហគមន៍ទាំងពីរផ្សះផ្សាគ្នាមិនសូវបានយូរទេ ។ *"ច្បាំងក្នុងនាមឈើឆ្កាង"* ក៏បណ្តាលឲ្យព្រះសហគមន៍ទាំងពីរកាន់តែបែកគ្នា ។ មហាសន្និបាតក្រុងលីយ៉ុង (១២៧៤) និងក្រុងហ្លូរ៉ង់ (Florence ១៤៣៨) គ្រាន់តែផ្សះផ្សាព្រះសហគមន៍ទាំងពីរមួយរយៈដ៏ខ្លីប៉ុណ្ណោះ ហើយគ្រីស្តបរិស័ទក្រិកមិនយល់ស្របនឹងសេចក្តីសម្រេចក្នុងសន្និបាតទាំងពីរនោះទៀត ។ នៅគ.ស. ១៤៥៣ ជនជាតិទួរគីវាយដណ្តើមយកក្រុងកុងស្តង់ទីណូប្ល តែគ្រីស្តបរិស័ទខាងបស្ចិមមិនអើពើ បណ្តាលឲ្យគ្រីស្តបរិស័ទក្រិកដាច់ពីគ្រីស្តបរិស័ទឡាតាំងថែមទៀត ។

នៅថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ១៩៦៥ អភិបាលព្រះសហគមន៍ក្រុងរ៉ូម **ប៉ូលទី ៦** និងអភិបាលកុងស្តង់ទីណូប្ល **អាថេណាគូរ៉ាស** (Athénagoras) ចុះហត្ថលេខាក្រោម (77)
សេចក្តីប្រកាសមួយថា លោកទាំងពីរនឹកស្តាយ ដោយមានពាក្យបណ្តេញគ្នាពីព្រះសហគមន៍ នៅគ.ស. ១០៥៤ នោះ ។

(77)

## សេចក្តីប្រកាសរួមរបស់អភិបាលព្រះសហគមន៏ក្រុងរ៉ូម ប៉ូលទី ៦ និងអភិបាលព្រះសហគមន៏ក្រុងកុងស្តង់ទីណូប្ល អាថេណាកូរ៉ាស *(ថ្ងៃទី ៧ ធ្នូ ១៩៦៥)*

*(...) ក្នុងចំណោមឧបសគ្គនានាដែលរារាំងព្រះសហគមន៍កាតូលិកនៅក្រុងរ៉ូមនិងព្រះសហគមន៍អ័រតូដុក មិនឲ្យពង្រឹងចំណងមិត្តភាពគ្នា ទុកចិត្តគ្នា និងរាប់រកគ្នា មានកិច្ចការ មានសេចក្តីសម្រេច និងមានគ្រោះកាចដ៏សែនព្រួយ ដែលបណ្តាលឲ្យក្រុមទូតអាសនៈក្រុងរ៉ូម ដឹកនាំដោយទីប្រឹក្សា**ហ៊ីមបែរត៍** បញ្ចេញពាក្យបណ្តេញលោកអភិបាល**មីសែល-សេរូឡែរ** និងជន ២ នាក់ទៀតចេញពីព្រះសហគមន៍ ។ អភិបាលកុងស្តង់ទីណូប្ល និងសន្និបាតកុងស្តង់ទីណូប្ល ក៏បណ្តេញក្រុមទូតនោះចេញពីព្រះសហគមន៍ដែរ (...) ។*

*អភិបាលក្រុងរ៉ូម **ប៉ូលទី ៦** និងអភិបាលកុងស្តង់ទីណូប្ល **អាថេណាគូរ៉ាសទី ១** រួមជាមួយសន្និបាតរបស់លោក ជឿជាក់ថា លោកទាំងពីរបញ្ចេញបំណងរួមចង់រកយុត្តិធម៌ និងសេចក្តីស្រឡាញ់រួមរបស់គ្រីស្តបរិស័ទទាំងសងខាង ទាំងនឹករឭកព្រះបញ្ញារបស់ព្រះអម្ចាស់ថា «ពេលអ្នកយកតង្វាយមកថ្វាយលើអាសនៈ (...)» (មថ ៥,២៣-២៤) ព្រមព្រៀងប្រកាសថា៖*

***១-** ខ្លួននឹកស្តាយក្រោយនូវពាក្យបណ្តាលឲ្យរបួសចិត្ត ពាក្យចោទប្រកាន់ដោយគ្មានមូលហេតុ កាយវិការគួរឲ្យដាក់ទោសដែលជាប់នឹងព្រឹត្តិការណ៍ដ៏សែនព្រួយនៅសម័យនោះ ។*

***២-** ខ្លួននឹកស្តាយក្រោយនូវសេចក្តីបណ្តេញចេញ តាមពាក្យទាំងនោះ ជាឧបសគ្គរារាំងមិនឲ្យព្រះសហគមន៍ទាំងពីររួមគ្នាក្នុងសេចក្តីស្រឡាញ់ ។ ខ្លួនមានបំណងដកសេចក្តីសម្រេចនេះពីចិត្តគំនិត និងពីក្នុងព្រះសហគមន៍ ហើយក៏ចង់បំភ្លេចពាក្យទាំងនោះឲ្យសាបសូន្យផងដែរ ។*

***៣-** ខ្លួនព្រួយចិត្តអំពីរឿងមុនៗ និងព្រឹត្តការណ៍ដែលកើតតាមក្រោយដោយមានមូលហេតុផ្សេងៗ មកពីមិនស្តាប់គ្នា មិនទុកចិត្តគ្នាទៅវិញទៅមក បណ្តាលឲ្យបែកបាក់គ្នា លែងរួបរួមក្នុងព្រះសហគមន៍យ៉ាងពិតប្រាកដ ។*

*ទោះបីកាយវិការនេះជាកាយវិការរកយុត្តិធម៌ និងសូមអភ័យទោសឲ្យគ្នាទៅវិញទៅមកក្តី ក៏អភិបាលក្រុងរ៉ូម ប៉ូល ទី ៦ និងអភិបាលកុងស្តង់ទីណូប្ល អាថេណាកូរ៉ាសទី ១ រួមជាមួយសន្និបាតរបស់លោក ដឹងច្បាស់ថា មិនគ្រប់គ្រាន់ដើម្បីឲ្យព្រះសហគមន៍កាតូលិកក្រុងរ៉ូម និងព្រះសហគមន៍អ័រតូដុកឈប់ខ្វែងគំនិតគ្នា ដូចនៅអតីតកាល និងនៅពេលថ្មីៗនេះបានទេ ។ សូមព្រះវិញ្ញាណជួយព្រះសហគមន៍ទាំងពីរ ឲ្យពុះពារឧបសគ្គទាំងនោះ សូមព្រះអង្គជម្រះចិត្តគំនិតគ្រីស្តបរិស័ទឲ្យនឹកស្តាយអំពីកំហុស ដែលព្រះសហគមន៍ទាំងពីរមានតាមប្រវត្តិសាស្ត្រ និងឲ្យមានបំណងយ៉ាងស័ក្តិសិទ្ធិថា នឹងយល់ព្រមបញ្ចេញធម៌ប្រកាសជំនឿរួមគ្នា ស្របតាមក្រុមគ្រីស្តទូត ព្រមទាំងចង់កាន់តាមសេចក្តីតម្រូវនៃជំនឿនោះផង (...) ។*



Layout Histor.qxd  2/10/07  10:10 AM  Page 141



# សង្គមដែលសុទ្ធតែជាគ្រីស្តបរិស័ទ

## (សតវត្សទី ១១-១៥)

*នៅសតវត្សទី ១១-១៣ នេះ ប្រជាជនទាំងប៉ុន្មាននៅទ្វីបអឺរ៉ុប ហាក់ដូចជាសហគមន៍មួយដ៏ធំ ដែលយកគ្រីស្តសាសនាធ្វើជាគ្រឹះ ។ ព្រះសហគមន៍និងសង្គមមានទំនាក់ទំនងគ្នាម្យ៉ាង គឺព្រះសហគមន៍ជាប់ស្អិតល្មួតនឹងរាជអំណាចនៃព្រះចៅអធិរាជ ។ ប្រជាជនយល់ឃើញថា ព្រះសហគមន៍និងរាជអំណាច ប្រៀបបីដូចជាវិញ្ញាណនិងរូបកាយមនុស្ស គឺលោកិយនៅក្រោមអំណាចនៃវិញ្ញាណយ៉ាងណា អំណាចព្រះចៅត្រូវចុះចូលក្រោមអំណាចព្រះសហគមន៍យ៉ាងនោះដែរ ។*

*ក្នុងសតវត្សទាំងនោះ អភិបាលក្រុងរ៉ូមមានអំណាចនិងមុខងារកាន់តែខ្លាំងឡើងៗ ទាំងនៅក្នុងព្រះសហគមន៍ ទាំងនៅទ្វីបអឺរ៉ុបទាំងមូល ។ ប៉ុន្តែ ជួនកាលអភិបាលក្រុងរ៉ូមនិងព្រះចៅក៏ឈ្លោះប្រកែក ដណ្តើមអំណាចគ្នាយ៉ាងខ្លាំងដែរ ។ នៅដើមសតវត្សទី ១៣ អភិបាលក្រុងរ៉ូមមានអំណាចខ្លាំងជាងនៅសម័យឯទៀតៗទាំងអស់ តែនៅចុងសតវត្សមានគេជំទាស់ ហើយព្រះសហគមន៍ចាប់ផ្តើមបាក់បែកគ្នា ។*

*ជំពូកនេះចែងអំពីលក្ខណៈសំខាន់ៗនៃសម័យនោះ ដែលមានលោក**គ្រេគ័រ ទី ៧** លោក**ប៊ែរណារ** និងក្រុមគ្រួសារបព្វជិតជាច្រើនកើតឡើង ។ ល ។ នៅសម័យនោះ ព្រះសហគមន៍គិតតែពីការពារខ្លួន ច្បាំងនឹងខ្មាំងទាំងខាងក្រៅ ទាំងខាងក្នុង ។ គ្រីស្តបរិស័ទចាប់ផ្តើមចេញទៅប្រកាសដំណឹងល្អនៅស្រុកឆ្ងាយៗ ។ យើងជាគ្រីស្តបរិស័ទសព្វថ្ងៃ ក៏ទទួលលទ្ធិនិងពិធីខ្លះជាកេរអាករពីសម័យនោះដែរ ។ នៅទ្វីបអឺរ៉ុប គេកសាងព្រះវិហារដ៏ប្រសើរជាងគេ ។ តែត្រូវប្រយ័ត្ន នៅសម័យនោះគ្រីស្តបរិស័ទមិនសូវល្អប៉ុន្មានទេ ហើយក៏មិនសូវប្រព្រឹត្តតាមព្រះដំបូន្មានរបស់ព្រះយេស៊ូដែរ ។*

## ក. គ្រីស្តសាសនាជាគ្រឹះនៃសង្គម

### ១- អភិបាលព្រះសហមន៍ក្រុងរ៉ូមទាមទារអំណាចពីព្រះចៅ

ចាប់តាំងពីសតវត្សទី ១១-១៣ អភិបាលព្រះសហគមន៍ក្រុងរ៉ូមទាមទារអំណាចកាន់តែខ្លាំងឡើងៗ ហើយជំទាស់នឹងព្រះចៅអធិរាជជាញឹកញាប់ ។ រីឯព្រះចៅអធិរាជនិងស្តេចនានា ក៏ធ្លាប់តែងតាំងអភិបាលព្រះសហគមន៍ និងមេវត្តជាពិសេសតែងតាំងអភិបាលព្រះសហគមន៍ក្រុងរ៉ូមដែរ ។ ហេតុនេះហើយ បានជាអភិបាលនិងមេវត្តទាំងនោះ មិនសូវល្អប៉ុន្មានទេ ។ អភិបាលក្រុងរ៉ូមខិតខំកែ

*វត្តអារាមនៅគ្លូនី*
*ប្រទេសបារាំង (គ.ស. ៩១០)*

Layout Histor.qxd 2/10/07 10:10 AM Page 142

របៀបជ្រើសរើសអភិបាលទាំងឡាយ បណ្ដាលឲ្យមានជម្លោះ ។

នៅគ.ស. ១០៥៩ អភិបាលក្រុងរ៉ូមឈ្មោះ**នីកូឡាទី ២** (Nicolas 2) បញ្ជាក់អំពីរបៀបបោះឆ្នោតជ្រើសរើសអភិបាលក្រុងរ៉ូម គឺលោកសម្រេចថា តាំងពីពេលនេះតទៅ អស់លោកទីប្រឹក្សា (Cardinal) នឹងជ្រើសរើសលោកអភិបាល រីឯបូជាចារ្យនិងប្រជាជនគ្រីស្ដបរិស័ទ គ្រាន់តែអបអរសាទរលោកអភិបាលដែលអស់លោកទីប្រឹក្សាជ្រើសតាំងថ្មីនោះប៉ុណ្ណោះ ។ តាំងពីពេលនោះមក ទីប្រឹក្សាទាំងឡាយទទួលតួនាទីពិសេសក្នុងព្រះសហគមន៍ ។ អស់លោកជាសមាជិកសំខាន់ក្នុងក្រុមបូជាចារ្យក្រុងរ៉ូម គឺជាអភិបាលព្រះសហគមន៍នៅតំបន់ជាយទីក្រុង និងជាឧបដ្ឋាកចំនួន ៧ នាក់ ដែលទទួលបន្ទុកបាត់បែងព្រះសហគមន៍ទាំងនោះ ។ ព្រះចៅអធិរាជមិនសព្វព្រះទ័យ បាត់អំណាចក្នុងការជ្រើសរើសអភិបាលក្រុងរ៉ូម ។ នៅពេលក្រោយ កាលកើតវិបត្តិណាមួយ ព្រះចៅតែងតាំងអភិបាលក្រុងរ៉ូមតាមព្រះទ័យរបស់ព្រះអង្គវិញ អភិបាលនោះនឹងប្រកួតប្រជែងនឹងអភិបាលដែលក្រុមប្រឹក្សាជ្រើសរើសយ៉ាងត្រឹមត្រូវតាមច្បាប់ ។

78

អភិបាលព្រះសហគមន៍ក្រុងរ៉ូម **គ្រេគ័រទី ៧** (គ.ស. ១០៧៣-១០៨៥) យកចិត្តទុកដាក់កែទម្រង់សីលធម៌ក្នុងព្រះសហគមន៍ ។ លោកជំទាស់នឹងបូជាចារ្យដែលសុំលុយសម្រាប់ធ្វើអគ្គសញ្ញាជូនគ្រីស្ដបរិស័ទ ឬលក់ព្រះវិហារ ។ លោកក៏ជំទាស់នឹងបូជាចារ្យដែលមានគ្រួសារដែរ ។ លោកសុំព្រះមហាក្សត្រនិងអភិបាលព្រះសហគមន៍ជួយសហការជាមួយលោកក្នុងការកែទម្រង់នោះ ។ ប៉ុន្តែ ការកែទម្រង់នោះមិនបានលទ្ធផលតាមបំណងទេ ។

លោកគ្រេគ័រទី ៧ យល់ឃើញថា ការអាក្រក់ទាំងប៉ុន្មានក្នុងព្រះសហគមន៍បណ្ដាលមកពីស្ដេចតែងតាំងអភិបាលទុកជាមន្ត្រីរាជការ ។ នៅគ.ស. ១០៧០ លោកហាមអភិបាល មិនឲ្យទទួលមុខតំណែងពីស្ដេចទៀត ។ ប្រជាជនលែងបោះឆ្នោតជ្រើសរើសអភិបាលតាមប្រពៃណីបុរាណទៀតហើយ ។ លោកក៏បញ្ជាក់ថា លោកមានអំណាចលើព្រះសហគមន៍ទាំងមូល និងលើស្ដេចនានាទៀតផង ។

ចាប់ពីពេលនោះមក អភិបាលក្រុងរ៉ូមតែងកោះហៅអស់លោកអភិបាលទាំងឡាយឲ្យចូលរួមក្នុងមហាសន្និបាត ។ ក្បួនច្បាប់មានសារៈសំខាន់ក្នុងការណែនាំគ្រីស្ដបរិស័ទជាងព្រះគម្ពីរ ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូមទាមទារអំណាចលើព្រះចៅអធិរាជ រហូតដល់ហ៊ានទម្លាក់ព្រះចៅថែមទៀតផង ។



*កងទ័ពច្បាំងដើម្បីព្រះគ្រីស្ដ (Crusade) ដណ្ដើមយកក្រុងយេរូសាឡឹម*

Layout Histor.qxd 2/10/07 10:10 AM Page 143

## ២- ព្រះសហគមន៍លើកបព្វជិតធ្វើជាគំរូ

នៅមជ្ឈិមសម័យ បព្វជិតកើនចំនួនច្រើនអស្ចារ្យ ។ វត្តគ្លូនី (Cluny) សាងសង់នៅ គ.ស. ៩១០ កាន់តាមក្បួនវិន័យលោក**បេណេឌិកតូ** ហើយល្បីឈ្មោះជាងគេ ។ មានបព្វជិត ៥០.០០០ អង្គកាន់តាមវិន័យវត្តនោះ ។ គេជ្រើសរើសអភិបាលព្រះសហគមន៍ជាច្រើន ជាពិសេសអភិបាលក្រុងរ៉ូមពីចំណោមបព្វជិតទាំងនោះ ។ នៅគ.ស. ១១១៥ លោក**ប៊ែរណារ**បង្កើតវត្តអារាមនៅក្លែរវ៉ូ (Bernard de Clairvaux) ។ ក្រុមគ្រួសារលោកក៏ល្បីឈ្មោះយ៉ាងខ្លាំងដែរ គឺលោកកាន់តាមវិន័យតឹងរ៉ឹងជាងបព្វជិតនៅគ្លូនី គេឆ្ការព្រៃអភិវឌ្ឍន៍សង្គម ។ល ។

តាបសឥសីជាច្រើនរស់នៅក្នុងគុហារថ្ម តាមព្រៃ តាមកោះ ធ្វើតបៈធម៌ដើម្បីសូមព្រះជាម្ចាស់លើកលែងទោសឲ្យគេ ។ នៅគ.ស. ១០៨៤ លោក**ប្រ៊ុយណូ** (Bruno) បង្កើតវត្តអារាមមួយនៅភ្នំសារត្រឺស (Chartreuse) ។

នៅក្នុងមជ្ឈិមសម័យនោះ គ្រីស្តបរិស័ទចាត់ទុកបព្វជិតជាគ្រីស្តបរិស័ទគំរូ (ដូចព្រះសង្ឃពុទ្ធសាសនាដែរ) ។ ប៉ុន្តែនៅសម័យនោះ គ្រីស្តបរិស័ទយកទំនៀមទម្លាប់ពីបុរាណមកលាយនឹងលទ្ធិគ្រីស្តសាសនា គឺគោរពឥទ្ធិពលនៃធម្មជាតិផង និងព្រះបន្ទូលរបស់ព្រះយេស៊ូផង ។

## ៣- ទេវវិជ្ជាអំពីអគ្គសញ្ញាកើតបន្តិចម្តងៗ

បាប់តាំងពីសតវត្សទី ១២ មក ព្រះសហគមន៍ចាប់ផ្តើមបញ្ជាក់ទេវវិជ្ជាអំពីអគ្គសញ្ញាទាំង ៧ ។ គេចាប់ផ្តើមធ្វើពិធីប្រូចទឹកលើក្បាល ជំនួសពិធីជ្រមុជក្នុងទឹកដូចពីដើម ។ គេធ្វើអគ្គសញ្ញានេះជូនបេក្ខជនក្រៅពីបុណ្យចម្លង ហើយនាំគ្នាធ្វើអគ្គសញ្ញាឲ្យទារកទៀតដែរ ។

79

ចំពោះអគ្គសញ្ញាលើកលែងទោសវិញ មហាសន្និបាតឡាត្រង់ទី ៤ (គ.ស. ១២១៥) បង្គាប់ឲ្យគ្រីស្តបរិស័ទលន់តួបាបមួយឆ្នាំម្តងក្នុងឱកាសបុណ្យចម្លង ។ គ្រីស្តបរិស័ទដែលគោរពប្រណិប័តន៍ខ្លាំងជាងគេ ទទួលព្រះកាយព្រះគ្រីស្តពីរឬបីដងក្នុងមួយឆ្នាំ ។ គេគោរពព្រះកាយយ៉ាងខ្លាំង ទុកជាវត្ថុសក្ការៈបំផុត ឬទុកជាមន្តអាគមដែរ ។ គេចូលចិត្តធ្វើពិធីលើកតម្កើងព្រះកាយ ពិធីហែព្រះកាយ ។ល ។ ជាជាងនឹកដល់សក្ការបូជារបស់ព្រះយេស៊ូ ដែលជាគ្រឹះនៃការសង្គ្រោះ ។

ចាប់តាំងពីសតវត្សទី ១៣ មក គ្រីស្តបរិស័ទចាត់ទុកអាពាហ៍ពិពាហ៍ជាអគ្គសញ្ញាមួយ ។ ព្រះសហគមន៍បញ្ជាក់លក្ខន្តិកៈអាពាហ៍ពិពាហ៍ ហើយគូសសង្កត់លើការយល់ព្រមរបស់គូស្វាមីភរិយា ទុកជាពិធីសំខាន់ក្នុងអាពាហ៍ពិពាហ៍ ។

### *ជំនឿ និង ប្រាជ្ញា*

នៅពេលនោះ គេមិនសូវយកចិត្តទុកដាក់អប់រំជំនឿគ្រីស្តបរិស័ទទេ ព្រោះប្រជាជនកាន់គ្រីស្តសាសនាគ្រប់ៗគ្នា ។ បូជាចារ្យគ្រាន់តែសម្តែងធម្មទេសនា ធ្វើអត្ថាធិប្បាយព្រះគម្ពីរតាមពិធីបុណ្យប៉ុណ្ណោះ ។ នៅពេលគ្រីស្តបរិស័ទស្តាប់ធម្មទេសនា គេសួរ គេទះដៃ គេជំទាស់នឹងបូជាចារ្យដែលសម្តែងធម្មទេសនានោះ ។ បព្វជិតតែងប្រមូលគម្ពីរ និងសៀវភៅគ្រូបាធ្យាយពីបុរាណមករៀន និងបង្រៀនគ្រីស្តបរិស័ទក្នុងសាលាវត្ត ។ យូរៗទៅ លោកអភិបាលក៏បង្កើតសាលានៅក្បែរវិសាលវិហាររបស់ខ្លួន ។ សាលាទាំងនោះចម្រើនឡើងរហូតដល់ក្លាយជាមហាវិទ្យាល័យ ។ នៅសម័យនោះ គេចាប់ផ្តើមបកប្រែសៀវភៅទស្សនវិទូក្រិក មានស្នាដៃលោក**អរីស្តូត** និងលោក**ប្លាតុង** ជាដើម ។

លោក**ថូម៉ាស**នៅក្រុងអាគីណូ (Thomas d'Aquin ១២២៥-១២៧៤) បង្រៀនទេវវិជ្ជា ដោយពន្យល់លទ្ធិគ្រីស្តសាសនាតាមទស្សនវិជ្ជាលោកអរីស្តូត ហើយបង្កើតសំយោគនៃលទ្ធិគ្រីស្តសាសនា ដែលមានឥទ្ធិពលរហូតដល់សព្វថ្ងៃ ។

នៅមជ្ឈិមសម័យនោះ គេចូលចិត្តសម្តែងរឿងក្នុងព្រះវិហារ គូររូបអំពីប្រវត្តិព្រះគ្រីស្ត ឆ្លាក់រូបផ្សេងៗជាច្រើនដើម្បីអប់រំគ្រីស្តបរិស័ទ ។

78

# អំពីការរស់នៅជាបូជាចារ្យ

## តាមគម្ពីរសម្ពន្ធមេត្រីថ្មី

លោក**ប៉ូល**សម្រេចចិត្តថាមិនយកគ្រួសារ ដើម្បីមានពេលក្នុងការប្រកាសដំណឹងល្អ (១ ករ ៧,៧; ៩,៥) ប៉ុន្តែលោកមិនបង្ខំអ្នកប្រកាសដំណឹងល្អឯទៀតៗឲ្យនៅលីវទេ ។ នៅក្នុងគម្ពីរមានទូន្មានអ្នកណែនាំព្រះសហគមន៍ដែលមានគ្រួសារ (១ ធម ៣,៣; ទត ១,៦) «*អភិបាល... ត្រូវមានភរិយាតែមួយ*» ។ គ្រូបាធ្យាយពីបុរាណតែងបកស្រាយអត្ថន័យពាក្យនេះថា ហាមតែងតាំងបុរសណាដែលរៀបការពីរដង ទៅហើយធ្វើជាបូជាចារ្យ និងហាមបូជាចារ្យពោះម៉ាយឲ្យរៀបការម្តងទៀត ។ លោកខ្លះយល់ឃើញថា លោកអភិបាលត្រូវតែរៀបអាពាហ៍ពិពាហ៍កុំបីខាន ។

## សតវត្សទី ១ ដល់សតវត្សទី ៣

នៅមជ្ឈិមបូព៌ាក៏ដូចបស្ចិមប្រទេសដែរ គ្មានច្បាប់ណាមួយហាមឃាត់ការតែងតាំងបុរសមានគ្រួសារឲ្យទៅជាបូជាចារ្យទេ ហើយក៏គ្មានសុំបូជាចារ្យដែលមានគ្រួសារឲ្យលែងរួមបវេណីជាមួយភរិយាដែរ ។ បូជាចារ្យដែលនៅលីវ ក៏មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ ក្រោយពីបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ។

ប៉ុន្តែ នៅសម័យនោះ គេលើកតម្លៃនៃតបៈធម៌ និងការរស់នៅជាព្រហ្មចារីយ៉ាងខ្លាំង នាំឲ្យគេនឹកគិតថា ការរស់នៅជាលីវ ឬមិនរួមបវេណីជាប្តីប្រពន្ធប្រសើរជាង ។

## សតវត្សទី ៤

ទាំងនៅបស្ចិមប្រទេសនិងបូព៌ាប្រទេស គេហាមឃាត់បូជាចារ្យដែលទទួលអគ្គសញ្ញាតែងតាំងរួចហើយ រៀបអាពាហ៍ពិពាហ៍តាមក្រោយ ប៉ុន្តែ បុរសរៀបការរួចហើយ អាចទៅជាបូជាចារ្យបាន ។ បុរសដែលនៅលីវ នៅពេលទទួលអគ្គសញ្ញាតែងតាំងត្រូវនៅលីវរហូត គឺម្នាក់ៗត្រូវស្មោះត្រង់នឹងបំណងដើមដំបូងរបស់ខ្លួន គឺថា បើរៀបការរួចហើយត្រូវនៅជាមួយគ្រួសារ បើនៅលីវ នៅពេលត្រូវគេតែងតាំងជាបូជាចារ្យ ត្រូវនៅលីវរហូត ។

នៅដើមសតវត្សទី ៤ បូជាចារ្យភាគច្រើនរួមបវេណីជាមួយភរិយា ។ ឯចុងសតវត្សវិញ បូជាចារ្យភាគច្រើនលែងរួមបវេណីជាមួយភរិយាទៀត ។ គេពន្យល់សេចក្តីនេះតាមរបៀបពីរយ៉ាងគឺ អ្នកនៅលីវមានសេរីភាពច្រើនជាងអ្នកមានគ្រួសារ ក្នុងកិច្ចបម្រើព្រះជាម្ចាស់ ។ ម៉្យាងទៀតគេយល់ឃើញថា ការប្រព្រឹត្តខាងផ្លូវភេទជាប់នឹងភាពមិនបរិសុទ្ធ មិនសមនឹងការថ្វាយអភិបូជាប្រចាំថ្ងៃ ។

នៅបស្ចិមប្រទេស (*ជាពិសេសនៅប្រទេសអេស្ប៉ាញនិងក្រុងរ៉ូម*) សន្និបាតសុំលោកអភិបាល បូជាចារ្យ និងឧបដ្ឋាកតមក្នុងការរួមបវេណី ។

## សតវត្សទី ៥

នៅបូព៌ាប្រទេស លោកអភិបាល បូជាចារ្យ និងឧបដ្ឋាករស់នៅជាមួយភរិយាជាធម្មតា ។ នៅបស្ចិមប្រទេស អភិបាលក្រុងរ៉ូមហាមអភិបាល បូជាចារ្យ និងឧបដ្ឋាកក្នុងគ្រប់ព្រះសហគមន៍ឲ្យរួមបវេណីជាមួយភរិយា ប៉ុន្តែ គេអាចរស់នៅជាមួយនាងតទៅទៀតបាន ។

## សតវត្សទី ៦

នៅបូព៌ាប្រទេស ព្រះសហគមន៍កំណត់វិន័យជាស្ថាពរ (គ.ស.៦៩២) ជាវិន័យណែនាំគេរហូតមកដល់សព្វថ្ងៃ គឺថា៖

- ប្រសិនបើគេជ្រើសរើសបុរសម្នាក់ដែលមានគ្រួសារឲ្យទៅជាអភិបាល បុរសនោះត្រូវតែបែកចេញពីភរិយារបស់ខ្លួន ។ នាងត្រូវលែងរស់នៅក្នុងផ្ទះជាមួយស្វាមី ហើយត្រូវចេញទៅរស់នៅក្នុងវត្តអារាមមួយដ៏ឆ្ងាយ ។ លោកអភិបាលត្រូវផ្គត់ផ្គង់ភរិយា ។ តែគ្រីស្តបរិស័ទនាំគ្នាជ្រើសរើសអភិបាលជាច្រើនក្នុងចំណោមបព្វជិត ។
- បុរសដែលមានគ្រួសារនៅពេលតែងតាំងជាបូជាចារ្យ ឬជាឧបដ្ឋាក អាចបន្តការរស់នៅជាមួយភរិយារបស់ខ្លួន ។ អ្នកដែលបែកចេញពីភរិយាត្រូវទទួលទោស ។

នៅបស្ចិមប្រទេស គេបញ្ជាបូជាចារ្យនិងឧបដ្ឋាកឲ្យតមភេទ ។ មហាសន្និបាតមួយចង់ឲ្យមានអ្នកយាមម្នាក់ក្នុងបន្ទប់បូជាចារ្យ ។ ពួកគេផ្តន្ទាទោសបូជាចារ្យណាដែលមានកូនក្រោយពេលត្រូវបានតែងតាំងជាបូជាចារ្យ ។

• • •

Layout Histor.qxd 2/10/07 10:10 AM Page 145

### សតវត្សទី ៩-១១

គេនៅតែតែងតាំងបុរសដែលមានគ្រួសារជាបូជាចារ្យនៅឡើយ ។ បូជាចារ្យទាំងនោះរស់នៅរួមជាគូស្វាមីភរិយា ប៉ុន្តែ ត្រូវតមតាមផ្លូវភេទ ។ គេនាំគ្នាតែងតាំងយុវជននៅលីវ ដែលទទួលការអប់រំក្នុងសាលាឲ្យធ្វើជាបូជាចារ្យ ។ ប៉ុន្តែ ទោះជាគេហាមឃាត់មិនឲ្យបូជាចារ្យរៀបអាពាហ៍ពិពាហ៍ក្តី ក៏មានបូជាចារ្យខ្លះរៀបការ ក្រោយពីត្រូវបានតែងតាំងជាបូជាចារ្យដែរ ។ នេះជាសភាពការណ៍នៅសម័យលោក**គ្រេគ័រ ទី ៧** នៅគ.ស. ១០៧៣ ។

### បញ្ហារបស់លោកគ្រេគ័រ

នៅគ.ស. ១០៧៤ លោក**គ្រេគ័រ ទី ៧** មិនញែកបូជាចារ្យដែលរៀបអាពាហ៍ពិពាហ៍មុនឬក្រោយពេលត្រូវតែងតាំងជាបូជាចារ្យឡើយ ។ លោកហាមគេរស់នៅរួមជាមួយភរិយាតែម្តង ។ អ្នករំលោភវិន័យនោះមិនអាចណែនាំគ្រីស្តបរិស័ទបានទៀតទេ ។

បូជាចារ្យជាច្រើនជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចនេះ គេថា *«វិន័យនេះកាន់មិនបានទេ មិនស្របតាមប្រាជ្ញារបស់មនុស្សទេ»* ។ (...) *«បើគ្មានស្ត្រីនៅជាមួយ យើងមុខជានឹងស្លាប់ដោយនៅខ្លួនទទេ និងរងារ»* ។ បូជាចារ្យជាច្រើនយល់ឃើញថា អភិបាលក្រុងរ៉ូមសម្រេចសេចក្តីថ្មីនេះខុសពីប្រពៃណីបុរាណ ។ ទោះបីបូជាចារ្យគ្មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ក្តី ក៏ព្រះសហគមន៍ទទួលស្គាល់ថា អាពាហ៍ពិពាហ៍របស់គេមានតម្លៃតាមផ្លូវច្បាប់ដែរ ។

### មហាសន្និបាតនៅឡាត្រង់ ទី ២ (គ.ស. ១១៣៩)

អស់លោកអភិបាលសម្រេចថា អាពាហ៍ពិពាហ៍របស់បូជាចារ្យគ្មានតម្លៃតាមផ្លូវច្បាប់ទេ ។ នៅគ.ស. ១១៧០ លោកអភិបាលក្រុងរ៉ូម **អាឡិចសង់ ទី ៣** បញ្ជាភរិយារបស់បុរសដែលត្រូវបានតែងតាំងជាបូជាចារ្យយល់ព្រម និងឲ្យនាងធ្វើពាក្យសច្ចាប្រណិធានថា នឹងរស់នៅជាព្រហ្មចារីតទៅទៀត ។ តាមច្បាប់ បុរសដែលមានគ្រួសារអាចទទួលអគ្គសញ្ញាតែងតាំងខ្លួនជាបូជាចារ្យបាន តែត្រូវបែកចេញពីភរិយា តែការនេះលំបាកពេក ។ ហេតុនេះ មានតែយុវជននៅលីវ និងពោះម៉ាយប៉ុណ្ណោះ ដែលអាចទៅជាបូជាចារ្យបាន ។

គ.ស. ១៩១៧ ក្បួនច្បាប់ព្រះសហគមន៍បញ្ជាក់ថា បុរសដែលរៀបការរួចហើយ មិនអាចទៅជាបូជាចារ្យបានទេ ។ ក្បួនច្បាប់នេះបញ្ជាក់វិន័យយ៉ាងច្បាស់ ឲ្យបូជាចារ្យរស់នៅជាព្រហ្មចារី ។

## (79) អំពីរបៀបធ្វើពិធីលើកលែងទោសក្នុងរយៈពេល ៦ សតវត្ស

កាលពីដើម លោកអភិបាលតែងតែលើកលែងទោសឲ្យអ្នកប្រព្រឹត្តអំពើបាបធ្ងន់ម្តងក្នុងមួយជីវិត *(សូមអានជំពូក ៣ ទំព័រ ៥០-៥១; ជំពូក ៤ ទំព័រ ៧៩-៨០)* ។ បព្វជិតជាតិអៀរឡង់ឲ្យគ្រីស្តបរិស័ទមកក្នុងវត្តអារាមរបស់អស់លោក ទទួលការលើកលែងទោសដោយទទួលទណ្ឌកម្មតាមការកំណត់ជាមុន ។ អ្នកបាបអាចសូមព្រះជាម្ចាស់លើកលែងទោសច្រើនដងក្នុងមួយជីវិត ។

### ទណ្ឌកម្មកំណត់នៅសតវត្សទី ៧-៨

*យើងទូន្មានបូជាចារ្យម្នាក់ៗឲ្យចងចាំអំពីទណ្ឌកម្មកំណត់ ដែលលោកនឹងអាននៅទីនេះ ។ លោកត្រូវចាប់អារម្មណ៍ដោយពិនិត្យពិច័យសភាពការណ៍ក្នុងសង្គម ភេទ អាយុ វណ្ណៈ (នៅលីវ ឬមានគ្រួសារ) បុគ្គលម្នាក់ៗដែលមក ។ បូជាចារ្យត្រូវគិតគូរអំពីចិត្តគំនិតរបស់គេ រួចវិនិច្ឆ័យទោសតាមសេចក្តីទាំងនោះ (...) ។ ទាហានសម្លាប់បព្វជិតម្នាក់ ឬសម្លាប់អ្នកបម្រើព្រះសហគមន៍ ត្រូវឈប់បម្រើកងទ័ព ត្រូវចូលបម្រើព្រះជាម្ចាស់វិញ ឬធ្វើទុក្ករកិរិយាអស់រយៈពេលប្រាំពីរឆ្នាំ ។ អ្នកសម្លាប់មនុស្សដោយស្អប់គេ ឬដោយមានចិត្តលោភលន់ អ្នកនោះត្រូវធ្វើទុក្ករកិរិយារយៈពេល ៤ ឆ្នាំ ។ ទាហានសម្លាប់គេក្នុងពេលសង្គ្រាមត្រូវតមអាហារ ៤០ ថ្ងៃ ។ ម្តាយសម្លាប់កូនក្នុងពោះមុនថ្ងៃទី ៤០ ក្រោយពីកូនចាប់ផ្ទៃ ត្រូវតមអាហារមួយឆ្នាំ ។ ប្រសិនបើនាងសម្លាប់កូនក្រោយ ៤០ ថ្ងៃ ត្រូវតមអាហារ ៣ ឆ្នាំ ។ ប៉ុន្តែ ត្រូវគិតថា ស្ត្រីក្រីក្រម្នាក់ដែលសម្លាប់កូនមកពីនាងគ្មានអ្វីមកចិញ្ចឹម វាប្លែកពីស្ត្រីខិលខូច*

•••

Layout Histor.qxd 2/10/07 10:10 AM Page 146

*វិញ (...) ។ អ្នកដែលដឹកស្រោវហូតដល់ក្ខូត ប្រសិនបើអ្នកនោះជាបូជាចារ្យឬជាឧបដ្ឋាក ត្រូវតមអាហារ ៤០ ថ្ងៃ ប្រសិនបើអ្នកនោះជាបព្វជិតត្រូវតមអាហារ ៣០ ថ្ងៃ បើអ្នកនោះជាគ្រីស្តបរិស័ទធម្មតាត្រូវតមអាហារ ១២ ថ្ងៃ ។*

*(ដកស្រង់ពីក្បួនដាក់ទណ្ឌកម្មកំណត់ស្រុកអង់គ្លេស)*

## កិច្ចធួននឹងអំពើបាប

*អ្នកចូលរួមថ្វាយអភិបូជា ធួននឹងការតមអាហារបីថ្ងៃ (...) អ្នកសូត្រទំនុកតម្កើង ៧៦ បទនៅពេលយប់ និងសុខចិត្តឲ្យគេវាយនឹងរំពាត់ ៣០០ ដង ធួននឹងការតមអាហារ ២ ថ្ងៃ ។ អ្នកចូលរួមថ្វាយអភិបូជា ១២០ ដង និងសូត្រទំនុកតម្កើងគ្រប់មួយកណ្ឌចំនួនបីដង ព្រមទាំងសុខចិត្តឲ្យគេវាយនឹងរំពាត់ ៣០០ ដង ស្មើនឹងមួយរយកាក់មាស (...) ។*

*អ្នកមានអំណាចត្រូវយកមនុស្ស ១២ នាក់ឲ្យតមអាហារជំនួសគាត់អស់រយៈពេលបីថ្ងៃ គឺគេបរិភោគតែនំប៉័ង ទឹក និងបន្លែស្រស់ ។ បន្ទាប់មក លោកនឹងទៅរកមនុស្ស ១២០ នាក់ ៧ ដង អ្នកទាំងនោះនឹងតមអាហារជំនួសគាត់អស់រយៈពេល ៣ ថ្ងៃ ។ ដូច្នេះ គាត់ដូចជាបានតមអាហារចំនួនថ្ងៃស្មើនឹងចំនួនថ្ងៃក្នុងប្រាំពីរឆ្នាំ (...) ។*

*(ដកស្រង់ក្បួនដាក់ទណ្ឌកម្មសតវត្សទី ៧-៨)*

អភិបាលឬបូជាចារ្យតែងតែចូលចិត្តបង្គាប់ឲ្យអ្នកបានធ្វើបូជនិយេសក៍ ទុកជាទុក្ករកិរិយាពិសេស ។ បូជនិយេសក៍ទៅក្រុងយេរូសាឡឹម ក្លាយទៅជាចម្បាំងដើម្បីព្រះគ្រីស្ត ។ ពេលនោះព្រះសហគមន៍អនុគ្រោះយ៉ាងពិសេសដល់អ្នកចេញទៅច្បាំង ឲ្យរួចពីទណ្ឌកម្មដែលត្រូវទទួល ។ ការអនុគ្រោះនេះ ក៏អាចឧទ្ទិសជូនមនុស្សស្លាប់ថែមទៀតផង ។ យូរៗទៅ បូជាចារ្យលែងដាក់ទណ្ឌកម្មកំណត់ជាមុន ហើយគ្រីស្តបរិស័ទធ្វើពិធីលន់តួបាបជំនួស ។

## ពិធីលន់តួផ្សេងៗនៅសតវត្សទី ១១

*ត្រូវលន់តួបាបលាក់កំបាំងទៅអ្នកបម្រើព្រះសហគមន៍គ្រប់ថ្នាក់ ។ រីឯបាបសាធារណៈត្រូវលន់តួទៅបូជាចារ្យ គឺព្រះសហគមន៍មានអំណាចចងនិងស្រាយ អំពើដែលព្រះសហគមន៍ស្គាល់នោះ ព្រោះជាអំពើបាបសាធារណៈ ។ បើអ្នករកអ្នកបម្រើព្រះសហគមន៍មិនបានថ្នាក់ណាក៏ដោយដើម្បីលន់តួបាប ចូរជ្រើសរើសមនុស្សដ៏ត្រឹមត្រូវម្នាក់នៅកន្លែងអ្នករស់នៅ (...) ។ បើគ្មានអ្នកបម្រើព្រះសហគមន៍ទេ មនុស្សបរិសុទ្ធម្នាក់អាចធ្វើឲ្យអ្នកបាបបានវិសុទ្ធ (...) ។ ប្រសិនបើរកនរណាឲ្យលន់តួមិនបានសោះ កុំអស់សង្ឃឹមឡើយ ព្រោះគ្រូបាធ្យាយដូចជាលោក**យ៉ូហានគ្រីសូស្តូម** លោក**កាស៊ីយ៉ាំង** លោក**អំប្រាស៍** (...) ធ្លាប់មានប្រសាសន៍ថា ត្រូវលន់តួបាបទៅព្រះជាម្ចាស់ ប៉ុណ្ណោះបានហើយ! ។*

*(លោកឡង់ហ្វ្រង់ អភិបាលព្រះសហគមន៍កានទ័បេរី ១០០៥-១០៨៩)*

នៅសតវត្សទី ១២ គេភ្ជាប់ពិធីលន់តួ ការនឹកស្តាយ និងពិធីលើកលែងទោសឲ្យជាប់គ្នា ។

*ត្រូវធ្វើពិធីលន់តួបាបធ្ងន់ឲ្យបានល្អិតល្អន់ទៅបូជាចារ្យ ដ្បិតមានតែលោកទេដែលមានអំណាចចងនិងស្រាយ (...) ។ ពិធីលន់តួទៅមនុស្សម្នាក់ មិនធ្វើឲ្យបានរួចពីបាបទេ គឺយើងរួចពីបាបដោយដាក់ខ្លួន និងដោយបងប្អូនឯទៀតជួយអង្វរព្រះជាម្ចាស់ឲ្យយើង ។ ហេតុនេះហើយបានជាយើងមិននិយាយថា "ខ្ញុំលើកលែងទោសឲ្យអ្នក" ទេ គឺយើងគ្រាន់តែនិយាយថា "សូមព្រះជាម្ចាស់ដ៏មានតេជានុភាពសព្វប្រការអាណិតអាសូរដល់អ្នកវិញ ។*

## ត្រូវលន់តួបាបនិងទទួលព្រះកាយព្រះគ្រីស្តមួយឆ្នាំម្តង

*គ្រីស្តបរិស័ទទាំងបុរសទាំងស្ត្រី ដែលមានអាយុដឹងក្តី ត្រូវលន់តួបាបដោយផ្ទាល់ខ្លួន និងដោយចិត្តស្មោះ យ៉ាងហោចណាស់មួយឆ្នាំម្តង ទៅបូជាចារ្យដែលថែរក្សាភូមិ ត្រូវយកចិត្តទុកដាក់បំពេញទណ្ឌកម្មតាមខ្លួនអាចធ្វើទៅបាន ដូចបូជាចារ្យដាក់ឲ្យធ្វើ និងទទួលអគ្គសញ្ញាអរព្រះគុណដោយគោរព យ៉ាងហោចណាស់ក្នុងឱកាសបុណ្យចម្លង លើកលែងតែបូជាចារ្យថែរក្សាភូមិទូន្មានឲ្យខានទទួលមួយរយៈ ដោយមានមូលហេតុដ៏ធ្ងន់ ។ បើគ្រីស្តបរិស័ទមិនលន់តួបាបមួយឆ្នាំម្តងទេ ត្រូវហាមមិនឲ្យចូលព្រះវិហារ ។ ប្រសិនបើគេនៅរស់ ត្រូវហាមគេមិនឲ្យចូលក្នុងព្រះវិហារ ប្រសិនបើគេស្លាប់ កុំធ្វើពិធីបញ្ចុះសពតាមក្បួនពិធីនៃព្រះសហគមន៍ឡើយ ។*

*(មហាសន្និបាតឡាត្រង់ ១២១៥)*

Layout Histor.qxd 2/10/07 10:10 AM Page 147

# ៦- ព្រះសហគមន៍ចម្រើនឡើង

ព្រះសហគមន៍នៅបស្ចិមប្រទេសមានអំណាច និងរួបរួមគ្នាជាឯកភាព ។ ដូច្នេះ ព្រះសហគមន៍ទាមទារទឹកដីដ៏វិសុទ្ធ *«ច្បាំងដើម្បីព្រះគ្រីស្ត»* ចេញទៅប្រកាសដំណឹងល្អនៅប្រទេសចិន ហើយការពារខ្លួនពីអ្នកវង្វេងជំនឿ ។

## ១- សង្គ្រាមប្រឆាំងអ៊ីស្លាម « ដើម្បីព្រះគ្រីស្ត »

គ្រីស្តបរិស័ទតែងធ្វើបូជនីយេសក៍ទៅទីក្រុងយេរូសាឡឹម ដើម្បីបញ្ជាក់
80 បំណងរបស់ខ្លួនចង់រួមស្លាប់រួមរស់ជាមួយព្រះគ្រីស្តដែលបានរស់នៅទីនោះកាលពីដើម ។ ប៉ុន្តែ តាំងពីសតវត្សទី ១១ ជនជាតិទួរគីដែលកាន់សាសនាអ៊ីស្លាមកាន់កាប់ទឹកដីសន្យានោះ ។ ដូច្នេះ អភិបាលក្រុងរ៉ូម ឬឥសី ឬបព្វជិតម្នាក់ដាស់តឿនគ្រីស្តបរិស័ទ ឲ្យលើកគ្នាទៅច្បាំងដណ្តើមយកទឹកដីដ៏វិសុទ្ធនោះវិញ ។ គេបាត់បែង *«ច្បាំងដើម្បីព្រះគ្រីស្ត»* (Crusade) ដោយលើកឈើឆ្កាងរបស់ព្រះគ្រីស្តធ្វើជាទង់ជ័យ (គ.ស. ១០៩៥-១២៩១) ។ សង្គ្រាមទាំងនោះ បណ្តាលឲ្យគេកាប់ចាក់គ្នាយ៉ាងសម្បើម នាំឲ្យគ្រីស្តបរិស័ទនិងអ៊ីស្លាមបរិស័ទស្អប់គ្នារហូត ព្រមទាំងបណ្តាលឲ្យគ្រីស្តបរិស័ទបស្ចិមប្រទេសនិងបូព៌ាប្រទេសកាន់តែបែកបាក់គ្នា ។

## ២- ព្រះសហគមន៍ដើមដំបូងនៅប្រទេសចិន

នៅសតវត្សទី ១២ គ្រីស្តបរិស័ទខ្លះយល់ឃើញថា មិនត្រូវវាយកម្ទេចជនជាតិដទៃដែលមិនកាន់គ្រីស្តសាសនា ជាពិសេសអ៊ីស្លាមបរិស័ទទេ គឺត្រូវចរចារជា
82 មួយគេវិញ ជាការល្អប្រសើរជាង ព្រោះមនុស្សប្រែចិត្តគំនិតជឿលើព្រះគ្រីស្តមកពីយើងស្រឡាញ់គេ ។

នៅសតវត្សទី ១៣ ជនជាតិម៉ុងហ្គោលលុកលុយដែនដីអាស៊ី ។ ពួកគេក៏ដេញកុលសម្ពន្ធសៀមនិងឡាវចូលទឹកដីកម្ពុជាដែរ ។ ជនជាតិអឺរ៉ុបភ័យខ្លាចយ៉ាងខ្លាំង ។ ប៉ុន្តែមានពាក្យចចាមអារាមថា ក្នុងចំណោមពួកម៉ុងហ្គោលនោះមានគ្រីស្តបរិស័ទខ្លះដែរ ជាពិសេសគេដំណាលអំពីបូជាចារ្យម្នាក់ឈ្មោះ**យ៉ូហាន** ។ ស្តេចច្រើនអង្គនៅទ្វីបអឺរ៉ុបជាគ្រីស្តបរិស័ទយល់ឃើញថា គួរព្រួតដៃជាមួយពួកម៉ុងហ្គោលនោះ ដើម្បីឲ្យគេជួយវាយកងទ័ពអ៊ីស្លាមពីក្រោយខ្នង ។ អភិបាលក្រុងរ៉ូមនិងស្តេចបារាំង ចាត់ក្រុមទូតដែលមានបព្វជិតក្រុមគ្រួសារសន្ត**ហ្វ្រង់ស៊ីស្កូ** ជាអ្នកដឹកនាំ ទៅជួបកងទ័ពម៉ុងហ្គោលនោះ ។

បន្ទាប់មក បព្វជិតនៃក្រុមគ្រួសារសន្ត**ហ្វ្រង់ស៊ីស្កូ** និងសន្ត**ដូមីនីកូ** ចាត់បែងដំណើរយ៉ាងពិសេសទៅប្រទេសឆ្ងាយៗ ។ បព្វជិតទាំងនោះទៅដល់អាស៊ីកណ្តាលតាមឈូងសមុទ្រពែរ្ស៍ បន្ទាប់មកទៅប្រទេសឥណ្ឌាហើយរហូតដល់ប្រទេសចិន ។ តាមផ្លូវ អស់លោកតែងតែជួបព្រះសហគមន៍ផ្សេងៗតែងតាំងដោយកូនចៅលោក**ណេស្តូរីយ៉ូស** ដោយមានអ្នកនាំដំណឹងល្អពីស្រុកពែរ្សមក ។ ប៉ុន្តែ បព្វជិតឡាតាំងនិងគ្រីស្តបរិស័ទបូព៌ាប្រទេសមិនសូវយល់ចិត្តគំនិតគ្នាប៉ុន្មានទេ ។

មេដឹកនាំជនជាតិម៉ុងហ្គោល ដែលឡើងជាព្រះចៅអធិរាជប្រទេសចិន សុំអភិបាលក្រុងរ៉ូមចាត់សាសនទូតមកប្រទេសរបស់ព្រះអង្គ ។ នៅគ.ស. ១២៩៤ បព្វជិតនៃក្រុមគ្រួសារសន្ត **ហ្វ្រង់ស៊ីស្កូ** ឈ្មោះ **យ៉ូហាន នៅម៉ុនទេគ័រវីណូ** (Jean de Montecorvino) ទៅដល់ក្រុងខានបាលិក (ប៉េកាំងសព្វថ្ងៃ) ។ លោកផ្ញើលិខិតជូនបងប្អូននៅទ្វីបអឺរ៉ុបមួយច្បាប់គួរឲ្យរំជួលចិត្ត ។ លោកទៅជាអភិបាលព្រះសហគមន៍ដើមដំបូងនៅក្រុងប៉េកាំងមុនគេ ។ ប៉ុន្តែ ដោយចម្ងាយផ្លូវឆ្ងាយពេកនិងដោយនយោបាយចេះតែប្រែប្រួល ព្រះសហគមន៍ដើមដំបូងនៅប្រទេសនោះវិនាសបាត់បង់ទៅវិញ ។

Layout Histor.qxd 2/10/07 10:10 AM Page 148

## ⑧⓪ អភិបាលព្រះសហគមន៍ដំបូងបង្អស់នៅប៉េកាំង

### លិខិតពីក្រុងខានបាលិក (ប៉េកាំង) ចុះថ្ងៃទី ៨ មករា គ.ស. ១៣០៥

*ខ្ញុំ**យ៉ូហាននៅម៉ុនទេគ័រវីណូ** (Jean de Montecorvino) ពីក្រុមគ្រួសារសន្តប្រ៉្វង់ស៊ីស្កូ ។ ខ្ញុំចេញពីក្រុងតូរីសនៅប្រទេសពែរ្ស (គ.ស. ១២៩១) ធ្វើដំណើរទៅប្រទេសឥណ្ឌា ។ ខ្ញុំស្នាក់អាស្រ័យក្នុងព្រះសហគមន៍គ្រីស្តទូត**ថូម៉ាស**រយៈពេល ១៣ ខែ ។ ខ្ញុំធ្វើអគ្គសញ្ញាជ្រមុជទឹកជូនបងប្អូនប្រមាណ ១០០ នាក់ ។ (...) ខ្ញុំក៏ធ្វើដំណើរបន្តមកដល់ស្រុកកាថាយ (Cathay) ជាព្រះរាជាណាចក្រព្រះចៅអធិរាជ**តារតារ** (Tartares) គេហៅថា ព្រះ**មហាខាន** ។ ខ្ញុំក៏ថ្វាយលិខិតរបស់អភិបាលក្រុងរ៉ូមទៅព្រះចៅ ហើយក៏ប្រកាសធម្មវិន័យរបស់ព្រះអម្ចាស់យេស៊ូគ្រីស្តថ្វាយទ្រង់ព្រះសណ្ដាប់ ។*

*ទោះបីព្រះចៅជាប់ព្រះហប្ញទ័យនឹងជំនឿអកុសលក្ដី ក៏ព្រះអង្គពោរពេញដោយព្រះហឫទ័យមេត្តាប្រោសប្រណីចំពោះគ្រីស្តបរិស័ទ ។ ខ្ញុំស្នាក់នៅប្រទេសរបស់ព្រះអង្គអស់រយៈពេលដប់ពីរឆ្នាំហើយ ។ (...)*

*ខ្ញុំនៅម្នាក់ឯងក្នុងប្រទេសដ៏ឆ្ងាយនេះអស់រយៈពេល ១១ ឆ្នាំ ដោយមិនអាចលន់តួបាបបាន រហូតដល់បង**អរ៉ណុល** មកដល់ ។ គាត់ជាជនជាតិអាល្លឺម៉ង់ ពីក្រុងកូឡូញ (Cologne) គាត់នៅ ទីនេះពីរឆ្នាំហើយ ។*

*នៅក្រុងខានបាលិកនេះ ខ្ញុំសាងសង់ព្រះវិហារមួយ ប្រាំមួយឆ្នាំហើយ ។ ខ្ញុំក៏បន្ថែមប្រាសាទ ដាក់ជួងបី ។ នៅទីនេះខ្ញុំធ្វើអគ្គសញ្ញាជ្រមុជទឹកជូនបងប្អូនប្រហែលប្រាំមួយពាន់នាក់ ។ ប្រសិនបើគ្មាននរណាមួលបង្កាច់ខ្ញុំដូចខ្ញុំរៀបរាប់នោះ ខ្ញុំមុខជានឹងធ្វើអគ្គសញ្ញាជ្រមុជទឹកជូនបងប្អូនជាងបីម៉ឺននាក់ពុំខាន ។ ខ្ញុំជាប់ធ្វើអគ្គសញ្ញាជ្រមុជទឹកជាញឹកញាប់ ។ ពួកវាមិនស្គាល់ធម្មវិន័យសោះ ខ្ញុំក៏ធ្វើអគ្គសញ្ញាជ្រមុជទឹកជូនពួកវា ព្រមទាំងអប់រំវាឲ្យស្គាល់អក្សរឡាតាំង និងស្គាល់ពិធី បុណ្យរបស់យើង (...) ។*

*ស្ដេចនៅតំបន់នោះទៅជាគ្រីស្តបរិស័ទ តាមគណៈលោក**ណេស្តូរីយ៉ូស** ជាព្រះរាជវង្សរបស់ព្រះមហាក្សត្រ ហៅថា បូជាចារ្យ**យ៉ូហាន** នៅប្រទេសឥណ្ឌា ទ្រង់ជាប់ព្រះហឫទ័យនឹងសេចក្ដីពិតនៃជំនឿដ៏ពិតប្រាកដដោយសារខ្ញុំ ។ ទ្រង់ទទួលមុខងារបម្រើបន្ទាប់បន្សំក្នុងព្រះសហគមន៍ ហើយបម្រើខ្ញុំនៅពេលថ្វាយអភិបូជា រហូតដល់ពួកណេស្តូរីយ៉ូសចោទប្រកាន់ថា ទ្រង់លះបង់ជំនឿ ។ ប៉ុន្តែ ទ្រង់នាំប្រជាជនភាគច្រើនឲ្យមានជំនឿកាតូលិក ។ ទ្រង់សាងសង់ព្រះវិហារដ៏ល្អប្រណិត សមនឹងសិរីរុងរឿងរបស់ព្រះមហាក្សត្រ (...) ។*

*ខ្ញុំអង្វរបងប្អូនដែលអានលិខិតនេះ សូមឲ្យអភិបាលក្រុងរ៉ូមជ្រាបសេចក្ដីទាំងនេះ ព្រមទាំងឲ្យក្រុមប្រឹក្សា និងអ្នកទទួលខុសត្រូវក្រុមគ្រួសារយើងនៅក្រុងរ៉ូមជ្រាបដែរ ។ ខ្ញុំសូមលោកទទួលខុសត្រូវក្រុមគ្រួសារយើង មេត្តាប្រទានគម្ពីរមួយ មេរៀនអំពីការរស់នៅរបស់សន្តបុគ្គល ព្រមទាំងបទចម្រៀង និងទំនុកតម្កើងសម្រាប់ឲ្យយើងយកធ្វើជាគំរូ ដ្បិតទីនេះខ្ញុំមានតែសៀវភៅទំនុកតម្កើងដ៏តូចមួយនិងសៀវភៅអភិបូជាដ៏តូចមួយដែរ ។ ប្រសិនបើខ្ញុំមានសៀវភៅធ្វើជាគំរូ ក្មេងៗមុខជានឹងសរសេរចម្លងឲ្យបាន ។*

*ពេលនេះ ខ្ញុំកំពុងកសាងព្រះវិហារថ្មីមួយ ខ្ញុំកាន់តែចាស់ទៅៗ ហើយសក់ស្កូវមិនមែនមកពីខ្ញុំចាស់ពេកទេ (ខ្ញុំអាយុតែ ៥៨ ឆ្នាំទេ) គឺមកពីខ្ញុំអស់កម្លាំង និងមានកង្វល់ធ្ងន់ពេក ។ ខ្ញុំរៀនភាសានិងអក្សរ របស់ជនជាតិតារតារយ៉ាងគួរសម គឺជាភាសាធម្មតារបស់ជន ជាតិម៉ុងហ្គោល ។ ខ្ញុំបកប្រែគម្ពីរសម្ពន្ធមេត្រីថ្មី និងទំនុកតម្កើងទាំងអស់ជាភាសានេះ ។ ខ្ញុំឲ្យគេសរសេរគម្ពីរនេះដោយអក្សរស្អាតណាស់ ខ្ញុំក៏បង្ហាញគម្ពីរនេះ ខ្ញុំអាន ហើយបកស្រាយ និងធ្វើឲ្យគេស្គាល់នៅទីសាធារណៈ ដើម្បីថ្វាយសក្ខីភាពអំពីធម្មវិន័យរបស់ព្រះគ្រីស្ត ។*

*ខ្ញុំបានធ្វើកិច្ចព្រមព្រៀងជាមួយព្រះមហាក្សត្រនោះថា ឲ្យលោកបកប្រែគ្រប់ពិធីបុណ្យទៅតាមពេលកំណត់ ដើម្បីឲ្យប្រជាជនច្រៀងនៅគ្រប់ទីកន្លែង នៅលើទឹកដីរបស់ព្រះអង្គ ។ ពេលទ្រង់មានព្រះជន្មរស់នៅ ខ្ញុំថ្វាយអភិបូជាតាមក្បួនពិធីរ៉ូមក្នុងព្រះវិហាររបស់លោកជាភាសានិងអក្សរជាតិរបស់ព្រះអង្គ ទាំងពាក្យអធិដ្ឋាន ទាំងពាក្យលើកតម្កើង (...) ។*

លិខិតនេះមកដល់ទ្វីបអឺរ៉ុបនៅគ.ស. ១៣០៧ ។ អភិបាលក្រុងរ៉ូមឈ្មោះ**ក្លេម៉ង់ទី ៥** ចាត់អភិបាលជាច្រើននាក់ទៅចុងបូព៌ា ។ អស់លោកដែលទៅដល់ក្រុងខានបាលិក តែងតាំងលោក**យ៉ូហាននៅម៉ុងទេក័រវីណូ** ធ្វើជាអភិបាលព្រះសហគមន៍ក្រុងប៉េកាំង ។ អភិបាលម្នាក់តាំងទីលំនៅនៅភាគខាងត្បូងនៃប្រទេសចិន ។ ប៉ុន្តែ ដោយគ្មានអ្នកមកជួយតទៅទៀតនោះ ព្រះសហគមន៍អន់ថយទៅៗ រហូតដល់វិនាសសាបសូន្យនៅពេលមានសន្តតិវង្សចិនថ្មីស្នងរាជ្យព្រះចៅជាតិម៉ុងហ្គោល ។

Layout Histor.qxd 2/10/07 10:10 AM Page 149

# គ- មានគេជំទាស់នឹងព្រះសហគមន៍

នៅសម័យនោះ មនុស្សនៅទ្វីបអឺរ៉ុបស្ទើរតែទាំងអស់កាន់គ្រីស្តសាសនា ។ ជំនឿលើព្រះគ្រីស្តធ្វើជាគ្រឹះនៃសង្គម ។ ហេតុនេះហើយ អ្នកដឹកនាំប្រទេសនិងអ្នកដឹកនាំគ្រីស្តសាសនាយល់ឃើញថា អ្នកដែលមានជំនឿផ្សេងពីគ្រីស្តបរិស័ទ ឬគ្រីស្តបរិស័ទដែលចង់កែទម្រង់ព្រះសហគមន៍ត្រូវតែផ្តន្ទាទោស ព្រោះនាំសង្គមឲ្យបាក់បែក ។

## ១- គ្រីស្តបរិស័ទបៀតបៀនជនជាតិយូដា

គ្រីស្តបរិស័ទបៀតបៀនជនជាតិយូដាទាំងចោទថា គេធ្វើគុតព្រះគ្រីស្ត ។ រដ្ឋអំណាចបង្ខំឲ្យគេពាក់សញ្ញាសម្គាល់បញ្ជាក់ជាតិរបស់គេ ហាមគ្រីស្តបរិស័ទរៀបការជាមួយគេ និងឲ្យពួកគេរស់នៅក្នុងកន្លែងដាច់ចេញពីប្រជាជន ។ល ។ ដោយរដ្ឋមិនឲ្យគេធ្វើកសិកម្មបាន ជនជាតិយូដានាំគ្នាធ្វើជំនួញ និងឲ្យអ្នកស្រុកខ្ចីប្រាក់ទាំងចងការ ។

## ២- គ្រីស្តបរិស័ទខ្លះជំទាស់នឹងព្រះសហគមន៍

គ្រីស្តបរិស័ទខ្លះជំទាស់នឹងព្រះសហគមន៍ ដោយយល់ឃើញថា ព្រះសហគមន៍មានអំណាចខ្លាំងពេកតាមរបៀបលោកិយ និងមានធនធានច្រើនហួស ។ គេចង់ឲ្យព្រះសហគមន៍ត្រឡប់ទៅកាន់តាមសេចក្តីពិតដូចកាលពីដើម គឺអ្នកដឹកនាំត្រូវរស់នៅក្នុងឋានៈជាអ្នកក្រីក្រ និងបម្រើប្រជាជន ។ នៅក្នុងចំណោមអ្នកជំទាស់ទាំងនោះមាន៖

- លោក**វ៉ាលដូ** (Valdo ១១៧៣) លោកលះបង់ទ្រព្យសម្បត្តិទាំងអស់ និងប្រកាសឲ្យគ្រីស្តបរិស័ទរស់នៅតាមភាពក្រីក្រ ។ កូនចៅលោកនាំគ្នាប្រកាសថា «*មនុស្សមិនអាចបម្រើម្ចាស់ពីរបានទេ គឺបម្រើព្រះជាម្ចាស់ផង និងទ្រព្យសម្បត្តិធ្វើជាព្រះផង*» ។ ពួកគេក៏លែងទទួលស្គាល់មុខងារជាបូជាចារ្យ ។

- អ្នកខ្លះនាំគ្នាប្រឆាំងនឹងអយុត្តិធម៌ក្នុងសង្គម ហើយរង់ចាំព្រះវិញ្ញាណយាងមកតែងតាំងព្រះរាជ្យប្រកបដោយយុត្តិធម៌ ។

- «**ពួកបរិសុទ្ធ**» (Cathares) កាន់តាមលោក**ម៉ានី**ពីដើម ។ គេមើលងាយរូបកាយមនុស្ស ហើយបដិសេធថា ព្រះគ្រីស្តមិនបានប្រសូតជាមនុស្សទេ ។ គេមិនព្រមឲ្យមនុស្សរៀបអាពាហ៍ពិពាហ៍ ។ គេក៏ជឿថា មនុស្សស្លាប់ចាប់ជាតិវិញ ។ ព្រះសហគមន៍ធ្វើបាបអ្នកទាំងនោះ រហូតដល់ប្រើទ័ពសម្លាប់ពួកគេជាច្រើន ។

## ៣- កំណើតក្រុមគ្រួសារបព្វជិតសុំទាន

គ្រីស្តបរិស័ទខ្លះក៏ចង់កែទម្រង់របៀបរស់នៅរបស់ព្រះសហគមន៍ ។ ក្នុងចំណោមទាំងនោះ មានលោក**ដូមីនិក្វ** និងលោក**ហ្វ្រង់ស៊ីស្គូ** នៅអាស៊ីស៊ី ។

- លោក**ដូមីនិក្វ** (Dominique) (គ.ស. ១១៧0) កើតនៅស្រុកអេស្ប៉ាញ លោកចង់ប្រកាសដំណឹងល្អដល់ «*ពួកបរិសុទ្ធ*» ដែលរស់នៅយ៉ាងក្រីក្រនិងកាន់វិន័យតឹងរ៉ឹង ។ លោកយល់ឃើញថា បព្វជិតដែលប្រៀនប្រដៅពួកគេឲ្យប្រែចិត្តមកវិញបានបរាជ័យ មកពីអស់លោករស់នៅតាមរបៀបអ្នកមាន ។ ហេតុនេះ លោក «*យកតម្រាប់តាមព្រះគ្រីស្តជាអ្នកក្រីក្រ*» វិញ ហើយកាន់តាមក្បួនវិន័យសន្ត**អូគូស្តាំង** ។ លោកបង្កើតក្រុមគ្រួសារហៅថា «*បងៗដែលសម្តែងធម្មទេសនា*» ដែលមានឥទ្ធិពលយ៉ាងខ្លាំងរហូតមកដល់សព្វថ្ងៃ ។

- លោក**ហ្វ្រង់ស៊ីស្គូ** (François) កើតនៅភូមិអាស៊ីស៊ី (ស្រុកអ៊ីតាលី) ក្នុងគ្រួសារអ្នកឈ្មួញក្រណាត់ម្នាក់ជាអ្នកមាន (គ.ស. ១១៨១) ។ លោកលះបង់អ្វីៗទាំងអស់

Layout Histor.qxd 2/10/07 10:10 AM Page 150

ហើយ «*យកភាពក្រីក្រធ្វើជាភរិយា*» ។ លោករស់នៅក្នុងឋានៈជាឥសី រួចដើរ
81 ជាមួយមិត្តសម្លាញ់ទៅប្រកាសដំណឹងល្អតាមផ្លូវ ។ លោកធ្វើការចិញ្ចឹមជីវិតផង
សុំទានផង ។ លោកបង្កើតក្រុមគ្រួសារ «*ហ្វ្រង់ស៊ីស្កាំង*» ។ នាង**ក្លារ៉ា** (Clara) យកគំរូតាមលោក**ហ្វ្រង់ស៊ីស្គូ** រួចបង្កើតក្រុមគ្រួសារបព្វជិតា «*ក្លារីស*» (Clarisses) ។ ក្រុមគ្រួសារទាំងពីរនោះមានឥទ្ធិពលយ៉ាងខ្លាំងក្នុងព្រះសហគមន៍ រហូតមកសព្វថ្ងៃ ។

81

## ពាក្យផ្តែផ្តាំរបស់សន្តហ្វ្រង់ស៊ីស្គូ (គ.ស. ១២២៦)

ព្រះអម្ចាស់ប្រទានឲ្យខ្ញុំ បង**ហ្វ្រង់ស៊ីស្គូ** ចាប់ផ្តើមធ្វើតបៈធម៌ ។ ពីមុនខ្ញុំរស់នៅជាអ្នកបាប ខ្ញុំខ្ពើមនឹងឃើញមនុស្សឃ្លង់ ។ ប៉ុន្តែ ព្រះអម្ចាស់ផ្ទាល់បាននាំខ្ញុំឲ្យទៅរស់នៅជាមួយពួកគេ ហើយខ្ញុំក៏អាណិតមេត្តាដល់គេដែរ ។ ពេលខ្ញុំទៅជួបគេ អ្វីដែលខ្ញុំឃើញថាជូរចត់ ក៏ក្លាយជាផ្អែមល្ហែមសម្រាប់រូបកាយនិងវិញ្ញាណវិញ ។ បន្ទាប់មក ខ្ញុំនៅជាមួយពួកគេតែរយៈពេលដ៏ខ្លីទេ រួចខ្ញុំលាចាកពីការវឹកវរល់នឹងលោកិយទៅ ។ ពេលនោះ ព្រះអម្ចាស់ប្រទានជំនឿយ៉ាងខ្លាំង ឲ្យខ្ញុំចូលក្នុងព្រះវិហាររហូតដល់ខ្ញុំ អធិដ្ឋានបានយ៉ាងស្រួល ដោយគ្រាន់តែនិយាយថា៖ «បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត យើងខ្ញុំសូមថ្វាយបង្គំព្រះអង្គតាមគ្រប់ព្រះវិហារ ដែលមាននៅក្នុងពិភពលោក ។ យើងខ្ញុំសូមលើកតម្កើងព្រះអង្គ ព្រោះព្រះអង្គបានរំដោះមនុស្សលោកដោយរងទុក្ខលំបាកនៅលើឈើឆ្កាង ។»

ក្រោយមកទៀត ព្រះអម្ចាស់បានប្រទាន ហើយនៅតែប្រទានជំនឿឲ្យខ្ញុំទៅលើអស់បូជាចារ្យ ដែលរស់នៅតាមរបៀបព្រះសហគមន៍ក្រុងរ៉ូម ។ ទោះបីអស់លោកធ្វើទុក្ខបុកម្នេញខ្ញុំក្តី ក៏ខ្ញុំនៅតែពឹងលើអស់លោកឲ្យជួយខ្ញុំដែរ ។ ប្រសិនបើខ្ញុំមានគតិបណ្ឌិតស្មើនឹងព្រះបាទ**សាឡូម៉ូន** ហើយប្រសិនបើខ្ញុំបានជួបបូជាចារ្យល្ងង់ជាងគេ ប្រសិនបើលោកមិនយល់ស្រប ខ្ញុំក៏មិនចង់ទេសនាក្នុងវិហារដែលលោកណែនាំដែរ (...) ។



សន្ត ហ្វ្រង់ស៊ីស្គូ ប្រៀនប្រដៅដល់សត្វ

ក្រោយពីព្រះអម្ចាស់ប្រទានបងប្អូនឲ្យរស់នៅជាមួយខ្ញុំ គ្មាននរណាបង្ហាញអំពីកិច្ចការដែលខ្ញុំត្រូវប្រព្រឹត្តនោះឡើយ ។ ប៉ុន្តែ ព្រះដ៏ខ្ពង់ខ្ពស់បានសម្តែងឲ្យខ្ញុំដឹងថា ខ្ញុំត្រូវរស់នៅតាមដំណឹងល្អដ៏វិសុទ្ធ ។ រីឯខ្ញុំសរសេរសេចក្តីនេះយ៉ាងខ្លី និងយ៉ាងស្រួល ផ្ញើជូនអភិបាលក្រុងរ៉ូម ។ លោកក៏យល់ស្របតាម ។ អស់អ្នកដែលមកទទួលជីវិត គេបរិច្ចាគអ្វីៗទាំងអស់ដែលគេមានឲ្យជនក្រីក្រ ។ ពួកគេពេញចិត្តអោយមានតែអាវវែងមួយប៉ុណ្ណោះ មានបំណះទាំងក្រៅទាំងក្នុង និងយកខ្សែមកក្រវាត់ ។ យើងមិនចង់បានអ្វីលើសពីនេះទៀតទេ ។ យើងជាបូជាចារ្យធ្លាប់សូត្រទំនុកតម្កើង រីឯគ្រីស្តបរិស័ទធម្មតា ធ្លាប់សូត្រធម៌ «ឱ! ព្រះបិតាយើងខ្ញុំ» ។ យើងពេញចិត្តនឹងស្ថិតនៅក្នុងព្រះវិហារ ។ យើងរៀនសូត្រ គឺយើងសុខចិត្តចុះចូលនឹងមនុស្សទាំងអស់ ។ ខ្ញុំធ្វើការចិញ្ចឹមជីវិតដោយខ្លួនឯង ហើយនៅតែធ្វើការតទៅទៀត ។ ខ្ញុំចង់យ៉ាងម៉ឺងម៉ាត់ ឲ្យបងប្អូនឯទៀតៗទាំងអស់ ...

Layout Histor.qxd 2/10/07 10:10 AM Page 151



សន្តហ្វ្រង់ស៊ីស្កូ បើបមនុស្សឃ្លង់

ធ្វើការបំពេញជីវិតយ៉ាងត្រឹមត្រូវតាមយុត្តិធម៌ដែរ ។ សូមឲ្យអស់បងប្អូនដែលមិនចេះធ្វើការ ខិតខំរៀនឲ្យចេះ មិនមែនដោយចិត្តលោភលន់ ចង់បានប្រាក់កម្រៃដោយសារការងារនោះទេ គឺដើម្បីធ្វើជាគំរូ និងដើម្បីកម្ចាត់ភាពខ្ជិលច្រអូសពីខ្លួនចេញ ។ ប្រសិនបើគេមិនឲ្យប្រាក់តម្លៃនៃការងារនោះ ត្រូវពឹងទៅលើតុរបស់ព្រះអម្ចាស់វិញ គឺដើរសុំទានពីផ្ទះមួយទៅផ្ទះមួយ ។ ព្រះអម្ចាស់សម្ដែងឲ្យខ្ញុំដឹងថា ត្រូវជូនពរគេថា «សូមព្រះអម្ចាស់ប្រទានសេចក្ដីសុខសាន្តឲ្យអ្នក» ។

សូមបងប្អូនប្រយ័ត្ន កុំទទួលព្រះវិហារ ទទួលផ្ទះសំបែងសម្រាប់ខ្លួនរស់នៅ និងអ្វីៗទាំងអស់ដែលគេបានកសាងសម្រាប់បងប្អូន គឺយើងត្រូវនឹកថា យើងរស់នៅក្នុងលោកនេះដូចជាជនបរទេស និងដូចជាអ្នកដំណើរ ។ ខ្ញុំហាមយ៉ាងម៉ឺងម៉ាត់ ការសុំលិខិតពីក្រសួងក្រុងរ៉ូមសម្រាប់ប្រយោជន៍ខ្លួនផ្ទាល់ ឬតាមរយៈអ្នកជំទែសម្រាប់សង់ព្រះវិហារ ឬកន្លែងផ្សេងទៀតដោយអះអាងថា ខ្លួនត្រូវការផ្ទះសម្រាប់ទេសនា ឬត្រូវគេបៀតបៀនធ្វើទុក្ខបុកម្នេញលើរូបកាយបងប្អូន ។ ប្រសិនបើមានគេមិនទទួលបងប្អូន សូមបងប្អូនរត់ទៅកន្លែងផ្សេងទៀត ដើម្បីធ្វើតបៈធម៌ ដោយព្រះជាម្ចាស់ប្រទានពរឲ្យ ។

ខ្ញុំចង់យ៉ាងម៉ឺងម៉ាត់ ស្ដាប់បង្គាប់ប្រធាននៃក្រុមគ្រួសារបងប្អូន និងធ្វើតាមអ្នកដែលលោកដាក់ឲ្យថែរក្សាខ្ញុំនេះ (...) ។

សូមបងប្អូនកុំនិយាយថា៖ «នេះជាក្បួនវិន័យមួយផ្សេងប្លែកពីក្បួនវិន័យមុន» ឡើយ ។ ក្បួនវិន័យនេះ ជាពាក្យនឹកគិត ពាក្យព្រមាន ពាក្យដាស់តឿន ពាក្យផ្ដែផ្ដាំ ដែលខ្ញុំ បងហ្វ្រង់ស៊ីស្កូ ជាអ្នកតូចជាងគេ សរសេរសម្រាប់បងប្អូនអនុវត្ត ដើម្បីឲ្យយើងកាន់តាមក្បួនវិន័យ ដូចយើងសន្យាជាមួយព្រះអម្ចាស់ឲ្យកាន់តែប្រសើរឡើង ។ សូមប្រធានទូទៅនៃក្រុមគ្រួសារនិងអ្នកណែនាំឯទៀតៗ កុំបន្ថែមសេចក្ដីអ្វី ឬដកពាក្យណាចេញពីក្បួនវិន័យនេះឡើយដោយនឹកថា ខ្លួនត្រូវធ្វើតាមបង្គាប់ ។ សូមបងប្អូនកាន់សេចក្ដីនេះឲ្យជាប់នឹងខ្លួន រួមជាមួយក្បួនវិន័យដែរ ។

នរណាម្នាក់កាន់តាមសេចក្ដីនេះ ទទួលពរយ៉ាងបរិបូរណ៍ពីព្រះបិតាដ៏ខ្ពង់ខ្ពស់បំផុតនៅស្ថានបរមសុខ ពីព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គនៅលើផែនដី និងពីព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះដែលជួយការពារ ។ រីឯខ្ញុំ បង**ហ្វ្រង់ស៊ីស្កូ**ជាអ្នកតូចជាងគេ ជាអ្នកបម្រើរបស់បងប្អូន សូមបញ្ជាក់ពរជីវិសុទ្ធនេះតាមតែខ្ញុំអាចបញ្ជាក់បាន ។

ហ្វ្រង់ស៊ីស្កូនៅអាស៊ីស៊ី សំណេរ

Layout Histor.qxd 2/10/07 10:10 AM Page 152

# ឃ. ការបង្ក្រាបអ្នកវង្វេងជំនឿ (Inquisition)

តាំងពីកើតចក្រភពគ្រីស្តបរិស័ទ រដ្ឋអំណាចតែងតែចេញច្បាប់ផ្តន្ទាទោសអ្នកវង្វេងជំនឿ ឬអ្នកកាន់ជំនឿផ្សេងពីគ្រីស្តសាសនា ។ គេចាប់អ្នកទាំងនោះទៅដាក់គុក តែមិនសម្លាប់ទេ ។ ចាប់តាំងពីសតវត្សទី ១១ ជាពិសេសសតវត្សទី ១៣ មានអ្នកបែកចេញពីព្រះសហគមន៍កាន់តែច្រើនឡើងៗ ។ រដ្ឋអំណាចយល់ឃើញថា អ្នកបែកចេញពីព្រះសហគមន៍ក៏បែកចេញពីសង្គមដែរ ហេតុដូចនេះហើយបានជារដ្ឋអំណាចចាប់ផ្តើមស្វែងរកគេយកទៅធ្វើទារុណកម្ម ដោយដុតទាំងរស់ជាដើម ។ អភិបាលព្រះសហគមន៍ខ្លះមិនព្រមឲ្យរដ្ឋអំណាចប្រព្រឹត្តដូច្នេះហើយយល់ឃើញថា ត្រូវតែដេញគេចេញពីព្រះសហគមន៍ប៉ុណ្ណោះគ្រប់គ្រាន់ហើយ ។

ប៉ុន្តែ ចាប់តាំងពីសតវត្សទី ១៣ រដ្ឋអំណាចនិងព្រះសហគមន៍ ដោយមានអភិបាលក្រុងរ៉ូមណែនាំជាដើម រួមគ្នាស្វែងរក ជួនកាលអធិរាជស្វែងរកអ្នកវង្វេងជំនឿមកធ្វើទារុណកម្ម ជួនកាលអភិបាលព្រះសហគមន៍នីមួយៗកាត់ក្តីដាក់ទណ្ឌកម្មអ្នកទាំងនោះ ជួនកាលអភិបាលក្រុងរ៉ូមផ្ទាល់បង្កើតតុលាការកាត់ទោសអ្នកវង្វេងជំនឿ ។ ឧប. នៅ គ.ស. ១២៣៣ លោក**គ្រេគ័រទី ៩** ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម បង្កើតតុលាការពិសេស ផ្ញើសារឲ្យបព្វជិតក្រុមគ្រួសារដូមីនិកូនិងប្រាំង់ស៊ីស្កូ បញ្ជាឲ្យស្វែងរកនិងចាប់ចងអ្នកវង្វេងជំនឿ ។ លោកអនុញ្ញាតឲ្យអស់លោកធ្វើទារុណកម្មគេថែមទៀត ។ តុលាការព្រះសហគមន៍កាត់ទោស រីឯរដ្ឋអំណាចធ្វើទោសគេតាមសេចក្តីកាត់ក្តីនោះ ។ ទេវវិទូ**សន្តថូម៉ាស**ពន្យល់ថា ធ្វើដូច្នេះត្រឹមត្រូវហើយ!

គួរឲ្យឆ្ងល់ណាស់! ព្រះសហគមន៍ដែលអួតអាងថា ប្រព្រឹត្តតាមព្រះដំបូន្មានរបស់ព្រះយេស៊ូដែលស្រឡាញ់អ្នកបាប បែរជាទៅដាក់ទោសអ្នកមិនព្រមទទួលការប្រៀនប្រដៅរបស់ខ្លួន និងដុតគេទាំងរស់ ។ ព្រះសហគមន៍នៅសម័យនោះកាន់អំណាចតាមរបបលទ្ធិផ្តាច់ការគួរឲ្យខ្លាស មកពីព្រះសហគមន៍ខ្លាចអ្នកវង្វេងជំនឿប្រឆាំង និងធ្វើឲ្យព្រះសហគមន៍វិនាសបាត់បង់ ។ ព្រះសហគមន៍ស្មានថាអាចការពារខ្លួនតាមរបៀបនោះបាន ។



*គេធ្វើទារុណកម្មគ្រីស្តបរិស័ទដែលគេចោទថា វង្វេងជំនឿ*

Layout Histor.qxd 2/10/07 10:10 AM Page 153

# ៤_ រដ្ឋអំណាចរកគេចខ្លួនចេញពីអំណាចរបស់អភិបាលក្រុងរ៉ូម

នៅសតវត្សទី ១៣ អំណាចព្រះចៅអាល្លឺម៉ង់ចុះអន់ថយ ទើបស្ដេចឯទៀតៗនៅទ្វីបអឺរ៉ុបចម្រើនអំណាចឡើងវិញ មានស្ដេចបារាំង ស្ដេចអង់គ្លេស និងស្ដេចអេស្ប៉ាញជាដើម ។ ស្ដេចទាំងនោះមិនព្រមទទួលស្គាល់អំណាចអភិបាលក្រុងរ៉ូមលើព្រះអង្គទៀតទេ អស់លោកទាមទារអំណាចខាងផ្លូវលោក ចង់បានអំណាចលើព្រះសហគមន៍ក្នុងប្រទេសរបស់ព្រះអង្គថែមទៀតផង ។ រីឯអភិបាលក្រុងរ៉ូមវិញនៅតែប្រកាសថា «អំណាចខាងលោកិយស្ថិតនៅក្រោមអំណាចខាងវិញ្ញាណ» (*ក្រិត្យ "ព្រះសហគមន៍តែមួយដ៏វិសុទ្ធ" របស់អភិបាលបូនីហ្វាស ៨ គ.ស. ១៣០២*) ។

តាំងពីពេលនោះមក គ្រីស្តបរិស័ទនាំគ្នាមានគំនិតថ្មីថា រដ្ឋអំណាចត្រួតត្រាលើលោកិយ រីឯព្រះសហគមន៍វិញ គ្រាន់តែជាក្រុមអ្នកជឿ គ្មានអំណាចលើលោកិយទេ ។ ម្យ៉ាងទៀត ព្រះសហគមន៍មិនគ្រាន់តែអភិបាល បូជាចារ្យ និងឧបដ្ឋាកប៉ុណ្ណោះទេ គឺជាក្រុមអ្នកជឿទាំងអស់ ។

## ១- អភិបាលព្រះសហគមន៍ក្រុងរ៉ូមមានដល់បីនាក់

គ.ស. ១៣០៥ ក្រុមទីប្រឹក្សាអភិបាលក្រុងរ៉ូមបោះឆ្នោតជ្រើសរើសជនជាតិបារាំងធ្វើជាអភិបាលព្រះសហគមន៍ក្រុងរ៉ូមថ្មី ព្រោះលោកពូកែដោះស្រាយជម្លោះរវាងស្ដេចបារាំងនិងអភិបាលក្រុងរ៉ូមពីមុនៗមក ។ ពេលនោះ ស្ដេចបារាំងសុំឲ្យលោកមកជួយដោះស្រាយជម្លោះរវាងប្រទេសបារាំងនិងប្រទេសអង់គ្លេស ។ ដោយហេតុនេះ និងដោយ «*រដ្ឋរបស់មហាបូជាចារ្យ*» (គឺរដ្ឋលោកផ្ទាល់) ជួបអសន្តិសុខ អភិបាលព្រះសហគមន៍ក្រុងរ៉ូមក៏មកតាំងទីលំនៅនៅក្រុងអាវីញ៉ុង (Avignon ខាងត្បូងប្រទេសបារាំង) ។ អស់លោកដែលបន្តមុខតំណែងរបស់លោកក៏នៅក្រុងអាវីញ៉ុងនេះអស់ ៧០ ឆ្នាំ ។ អស់លោកប្រមែប្រមូលប្រាក់ជាច្រើនពីគ្រីស្តបរិស័ទ ដើម្បីសង់វាំងធំៗនៅក្រុងនោះ និងសម្រាប់ផ្គត់ផ្គង់មន្ត្រីរាជការប្រហែល ៤000 នាក់ ដែលជួយលោកក្នុងកិច្ចត្រួតត្រាព្រះសហគមន៍ ។ លោកជ្រើសរើសនិងតែងតាំងអភិបាលទាំងអស់ដោយផ្ទាល់ មិនឲ្យគ្រីស្តបរិស័ទបោះឆ្នោតជ្រើសរើសអស់លោកដូចពីមុនទៀតឡើយ ។

ប៉ុន្តែ គ្រីស្តបរិស័ទក្រុងរ៉ូមបន់ឲ្យអភិបាលក្រុងរ៉ូមវិលត្រឡប់ទៅនៅក្រុងរ៉ូមវិញដោយយល់ឃើញថា ប្រសិនបើលោកស្ថិតនៅជាប់ក្រុងអាវីញ៉ុងដូច្នេះ លោកបម្រើព្រះមហាក្សត្របារាំងខ្លាំងពេក ។ ក្នុងចំណោមគ្រីស្តបរិស័ទទាំងនោះ សន្តី **កាតារីណា នៅស៊ីយ៉េណា** អង្វរអភិបាលក្រុងរ៉ូមឲ្យត្រឡប់មកវិញខ្លាំងជាងគេ ។ 82
លោក**គ្រេគ័រ ទី ១១** វិលត្រឡប់ទៅក្រុងរ៉ូមវិញនៅ គ.ស. ១៣៧៧ ។ ប៉ុន្តែ ដោយលោកដែលបន្តមុខតំណែងធ្វើបាបក្រុមប្រឹក្សាជាតិបារាំងខ្លាំងពេក អស់លោកបោះឆ្នោតរើសអភិបាលថ្មី ។ អភិបាលទាំងពីរបណ្ដេញគ្នាពីព្រះសហគមន៍ទៅវិញទៅមក ។ ក្រោយមក ក្រុមប្រឹក្សាប្រជុំជាសន្និបាតទម្លាក់អភិបាលព្រះសហគមន៍រ៉ូមទាំងពីរនាក់ និងបោះឆ្នោតជ្រើសរើសអភិបាលម្នាក់ផ្សេងទៀត ។ ពេលនោះមានអភិបាលព្រះសហគមន៍ក្រុងរ៉ូមដល់ទៅបីនាក់ដែលដណ្ដើមអំណាចគ្នា ។

មហាសន្និបាតសកលនៅក្រុងហ្លូរ៉ង់ (Florence គ.ស. ១៤៣៩) បញ្ចប់ការបែកបាក់នេះ ដោយអភិបាលពីរនាក់លាលែងមុខតំណែង ។ មហាសន្និបាតនេះខិតខំធ្វើឲ្យគ្រីស្តបរិស័ទបូព៌ាប្រទេសនិងបស្ចិមប្រទេស រួបរួមគ្នាជាធ្លុងតែមួយ ។ តែអភិបាលទាំងសងខាង មិនសូវយកចិត្តទុកដាក់អនុវត្តតាមសេចក្ដីសម្រេចនៃមហាសន្និបាតទេ បានជាសេចក្ដីសម្រេចនោះគ្មានលទ្ធផល ។ គ្រីស្តបរិស័ទបស្ចិមប្រទេសមិនចាប់អារម្មណ៍នឹងគ្រីស្តបរិស័ទបូព៌ា ជាពិសេសនៅពេលកងទ័ពទួរគី 83
វាយដណ្ដើមយកក្រុងកុងស្តង់ទីណូប្លនៅគ.ស. ១៤៥៣ គេមិនជួយការពារសោះ ។

Layout Histor.qxd 2/10/07 10:10 AM Page 154

## ⑧② សន្តីកាតារីណា នៅក្រុងស៊ីយ៉ែណា សុំអភិបាលក្រុងរ៉ូម គ្រេគ័រទី ១១ ត្រឡប់មកក្រុងរ៉ូមវិញ

នាង**កាតារីណា បិននីនកាសា** (Catarina Benincasa ១៣៤៧-១៣៨០) ជាកូនទី ២៣ ក្នុងក្រុមគ្រួសារមួយដែលមានកូន ២៥ នាក់ ។ តាំងពីក្មេងមក នាងមានបទពិសោធន៍ដ៏អស្ចារ្យអំពីព្រះជាម្ចាស់គង់នៅជាមួយនាង ។ ទោះបីនាងសម្រេចចិត្តថានឹងរស់នៅជាបព្វជិតាក្តី ក៏នាងចូលរួមយ៉ាងសកម្មក្នុងព្រះសហគមន៍នៅក្រុងស៊ីយ៉ែណានៅសម័យនោះ ។ នាងមានគោលជំហរបីគឺ៖

- នាំឲ្យអ្នកបាបប្រែចិត្តគំនិត
- ឲ្យគ្រីស្តបរិស័ទចេញច្បាំងសាជាថ្មីដើម្បីរំដោះផ្នូររបស់ព្រះគ្រីស្ត
- ឲ្យអភិបាលក្រុងរ៉ូមត្រឡប់មកក្រុងរ៉ូមវិញ ។

*សូមលោកបន្តមុខងាររបស់សន្ត**គ្រេគ័រ**ឲ្យពិតប្រាកដ ។ ចូរស្រឡាញ់ព្រះជាម្ចាស់ ។ កុំភ្ជាប់ចិត្តនឹងឪពុកម្ដាយ មិត្តភ័ក្តិ ឬសេចក្តីត្រូវការក្នុងលោកនេះឡើយ ។ កុំខ្លាចនឹងការជ្រួលច្របល់សម័យនេះឲ្យសោះ ក៏កុំខ្លាចអ្នកដែលបះបោរប្រឆាំងអំណាចរបស់លោកដែរ ។ ព្រះជាម្ចាស់ជិតយាងមកជួយហើយ ព្រះអង្គគង់នៅជិតបង្កើយហើយ ។ ចូរភ្ជាប់ចិត្តតែនឹងអស់គង្វាលដ៏ល្អប៉ុណ្ណោះ ដ្បិតមានតែគង្វាលអាក្រក់ទេដែលបង្កើតការបះបោរនោះ ។ ចូរយកថ្នាំមកថែទាំរោគអាក្រក់ទាំងនេះទៅ ចូរប្រព្រឹត្តតាមព្រះយេស៊ូគ្រីស្ត ។ ចូរទៅមុខទៅ ។ ចូរបង្ហើយនូវអ្វីដែលលោកបានចាប់ផ្ដើមនឹងធ្វើ ។ ចូរកុំបង្អង់ឡើយ ព្រោះការយឺតយ៉ាវបណ្តាលឲ្យកើតអន្តរាយជាច្រើន ហើយមារក៏ខិតខំបង្កើតឧបសគ្គជាច្រើន មករារាំងផ្លូវលោក ។ ចូរលើកទង់ចម្បាំងនៃឈើឆ្កាងដ៏ពិតប្រាកដ ព្រោះទង់ចម្បាំងនេះនឹងផ្តល់សេចក្តីសុខសាន្តឲ្យលោក ។ ធ្វើដូច្នេះ លោកមុខជានឹងសម្រាលទុក្ខជនក្រីក្ររបស់ព្រះយេស៊ូ ដែលទន្ទឹងរង់ចាំលោក ។ សូមអញ្ជើញមក លោកមុខជានឹងឃើញសត្វចចកក្លាយទៅជាកូនចៀមវិញ ។*

*សូមនាំសន្តិភាព ឲ្យសង្គ្រាមចប់ ។ កុំរួញរានឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទៀត ព្រោះមេចៀមនៅតែឃ្លាន រង់ចាំលោកវិលត្រឡប់មកអាសនៈរបស់សន្តសិលាវិញ ។ លោកត្រូវមកកាន់អាសនៈរបស់លោកវិញ ក្នុងឋានៈជាតំណាងរបស់ព្រះយេស៊ូ ។ សូមមក កុំភ័យខ្លាចអ្វីឡើយ ដ្បិតព្រះជាម្ចាស់នឹងគង់នៅជាមួយលោក ។ កុំរង់ចាំពេលវេលាល្អ ពីព្រោះពេលវេលាមិនរង់ចាំលោកទេ ។ ចូរឆ្លើយតបនឹងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ចូរត្រឡប់មកទាំងមានចិត្តដូចជាកូនចៀម ដែលគ្មានអាវុធដែលបង្ក្រាបសត្រូវដោយព្រះហឫទ័យស្រឡាញ់ ។ ចូរក្លាហានឡើង! ចូរសង្គ្រោះព្រះសហគមន៍កុំឲ្យបែកបាក់ និងកុំប្រព្រឹត្តអំពើអាក្រក់ ។ សត្វចចកមុខជានឹងមករកលោក ហើយអង្វរលោកមេត្តាដល់គេពុំខាន (...) ។ សូមលោកមានចិត្តក្លាហាន និងមកដោយមិនភ័យខ្លាចអ្វីសោះឡើយ ។ ជាពិសេស លោកស្រឡាញ់ជីវិត សូមកុំយកកងទ័ពមកជាមួយឡើយ សូមកាន់តែឈើឆ្កាងដូចកូនចៀមដ៏សុភាពរាបសា ។*

## ⑧③ មហាសន្និបាតនៅហ្លូរ៉ង់ ស្តីអំពីការរួបរួមជាមួយគ្រីស្តបរិស័ទក្រិក (៦ កក្កដា ១៤៣៩)

*ខ្ញុំ**អឺសែន** (Eugène) ជាអភិបាល និងជាអ្នកបម្រើអស់អ្នកបម្រើព្រះជាម្ចាស់ សូមប្រកាសសេចក្តីនេះដើម្បីឲ្យគ្រីស្តបរិស័ទចងចាំជានិច្ចនិរន្តរ៍តរៀងទៅ ។*

*ខ្ញុំសូមរួមជាមួយព្រះចៅអធិរាជដ៏ប្រសើរបំផុតនៃជនជាតិរ៉ូម៉ាំង ព្រះនាម**យ៉ូហាន ប៉ាឡេអូឡូហ្គ**ដែលជាបុត្រដ៏ជាទីស្រឡាញ់របស់យើង សូមរួមជាមួយតំណាងអស់លោកអភិបាលដ៏ជាទីគោរពសក្ការៈ ជាបងប្អូន ព្រមទាំងសូមរួមជាមួយតំណាងឯទៀតៗនៃព្រះសហគមន៍ខាងបូព៌ា ។*

*«ចូរឲ្យផ្ទៃមេឃមានអំណរសប្បាយ ចូរឲ្យផែនដីរីករាយឡើង» (ទំន ៩៦, ១១) ។ ជញ្ជាំងដែលធ្វើឲ្យព្រះសហគមន៍ខាងបស្ចិមនិងព្រះសហគមន៍ខាងបូព៌ាដាច់ពីគ្នានោះ រលំហើយ ។ សន្តិភាពនិងឯកភាពមកវិញហើយ គឺដោយសារ «ព្រះគ្រីស្តជាថ្មដ៏សំខាន់ ប្រមូលព្រះសហគមន៍ទាំងពីរឲ្យរួបរួមគ្នា ធ្វើជាប្រជារាស្ត្រតែមួយ» (អភ ២, ២០.១៤) ។ ព្រះសហគមន៍ទាំងពីរបានផ្សាភ្ជាប់គ្នាដោយចំណងដ៏ខ្លាំងក្លានៃសន្តិភាព និងសេចក្តី*

•••

Layout Histor.qxd 2/10/07 10:10 AM Page 155

*ស្រឡាញ់ ហើយចុះសន្និសញ្ញាបង្រួបបង្រួមគ្នាជានិច្ចនិរន្តរ៍វៀង រហូត ។ ក្រោយពីមានពពកខ្មៅនៃទុក្ខព្រួយ និងមានភាពងងឹតគួរឲ្យស្អប់បាំងយើងយ៉ាងយូរ រស្មីនៃការរួបរួមគ្នាដែលយើងរង់ចាំជាយូរមកហើយ បានបំភ្លឺយើងទាំងអស់គ្នា (...) ។*

*ក្រោយពីអភិបាលនៅបស្ចិមប្រទេស និងនៅប៉ែកបូព៌ាប្រទេសបាក់បែកគ្នា ខ្វែងគំនិតគ្នាជាយូរអង្វែងមក អស់លោកចូលមករួមមហាសន្និបាតសកលនេះដោយចិត្តសប្បាយរីករាយ ទាំងហ៊ានពុះពារឧបសគ្គគ្រប់យ៉ាង ទាំងនៅតាមផ្លូវសមុទ្រ ទាំងនៅតាមផ្លូវដីគោក ។ ដោយអស់លោកមានបំណងឲ្យព្រះសហគមន៍រួបរួមគ្នាយ៉ាងវិសុទ្ធ និងតែងតាំងសេចក្ដីស្រឡាញ់ឡើងវិញ ដែលមានតាំងពីដើមរៀងមក អស់លោកមិនខ្វល់ចិត្តទេ គឺបានសម្រេចតាមបំណង ។ ក្រោយពីអស់លោករិះគិតយ៉ាងហ្មត់ចត់និងយ៉ាងយូរ អស់លោកក៏រួបរួមគ្នាតាមបំណង ដោយព្រះវិញ្ញាណដ៏វិសុទ្ធមេត្តាដល់អស់លោកដែរ (...) ។*

*អស់លោកអភិបាលនិយាយភាសាឡាតាំងនិងអស់លោកនិយាយភាសាក្រិក ដែលជួបជុំគ្នាក្នុងមហាសន្និបាតសកលនេះ ខំប្រឹងខ្នះខ្នែងបង្ហាញចិត្តស្រឡាញ់គ្នាទៅវិញទៅមក ហេតុនេះ អស់លោកជជែកវែកញែកដោយយកចិត្តទុកដាក់ជាទីបំផុតនិងដោយពិនិត្យពិច័យយ៉ាងយូរ អំពីប្រការចែងពីព្រះវិញ្ញាណដ៏វិសុទ្ធហូរចេញមកពីព្រះជាម្ចាស់ (..) ។*

*យើងសូមប្រកាសយ៉ាងឱឡារិកថា បូជាចារ្យប្រសិទ្ធិពរលើនំបុ័ងធ្វើអំពីម្សៅសាឡី ជានំបុ័ងឥតមេក្ដី ឬមានមេក្ដី ពិតជាព្រះកាយព្រះគ្រីស្ដ ។ អស់លោកបូជាចារ្យត្រូវប្រសិទ្ធិពរលើនំបុ័ងដែលមានមេឬឥតមេ ឲ្យស្របតាមទំនៀមទម្លាប់ព្រះសហគមន៍របស់ខ្លួននៅបស្ចិមប្រទេសក្ដី ឬនៅបូព៌ាប្រទេសក្ដី ឲ្យទៅជាព្រះកាយព្រះគ្រីស្ដតែមួយដដែល (...) ។*

*យើងសូមប្រកាសយ៉ាងឱឡារិកថា អាសនៈដ៏វិសុទ្ធរបស់គ្រីស្ដទូត និងមហាបូជាចារ្យនៅក្រុងរ៉ូម ពិតជាប្រធានលើព្រះសហគមន៍ក្នុងពិភពលោកទាំងមូល ។ មហាបូជាចារ្យនេះ ក៏បន្តមុខងារពីសន្ត* ***សិលា*** *មកដែរ (...) ។*

*យើងក៏ត្រូវបញ្ជាសាជាថ្មីថា ត្រូវរក្សាឋានន្តរស័ក្ដិនៃអភិបាលខាងបូព៌ាដ៏ជាទីគោរពតាមលំដាប់លំដោយ ដូចមានចែងទុកក្នុងក្បួនមាត្រាតមក គឺលោកអភិបាលព្រះសហគមន៍ក្រុងកុងស្តង់ទីណូប្លមានឋានន្តរស័ក្ដិទី ២ បន្ទាប់ពីមហាបូជាចារ្យដ៏វិសុទ្ធបំផុតនៃក្រុងរ៉ូម លោកអភិបាលព្រះសហគមន៍ក្រុងអាឡិចសង់ឌ្រីមានឋានន្តរស័ក្ដិទី ៣ លោកអភិបាលព្រះសហគមន៍ក្រុងអន់ទីយ៉ូកមានឋានន្តរស័ក្ដិទី ៤ លោកអភិបាលព្រះសហគមន៍យេរូសាឡឹមមានឋានន្តរស័ក្ដិទី ៥ ។ ប៉ុន្តែ អស់លោករក្សាទុកឯកសិទ្ធិ និងសិទ្ធិរបស់អស់លោក ។*

## ២- ប្រជារាស្ត្ររបស់ព្រះជាម្ចាស់

នៅពេលអស់លោកដណ្ដើមអំណាចដូច្នេះ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ជួបប្រទះនឹងទុក្ខវេទនាយ៉ាងសែនជូរចត់ ។

- កងទ័ពអង់គ្លេស និងកងទ័ពបារាំងវាយគ្នា អស់រយៈពេលមួយរយឆ្នាំ (គ.ស. ១៣៣៧-១៤៥៣) បណ្ដាលឲ្យកើតទុរ្ភិក្ស និងអសន្តិសុខ បំផ្លាញព្រះវិហារ និងវត្តអារាមជាច្រើន ។
- តាំងពី គ.ស. ១៣៤៧ មក មានជំងឺប៉េស្តរាតត្បាតទ្វីបអឺរ៉ុប ស្លាប់ប្រជាជនមួយភាគបី ។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទនាំគ្នានឹកដល់សេចក្ដីស្លាប់ជានិច្ច ។ គេចោទជនជាតិយូដាថា ជាអ្នកបង្កជំងឺប៉េស្តនោះ ដោយដាក់ថ្នាំពុល គេចោទមារសាតាំងនិងបរិវា គឺគ្រូធ្មប់ទាំងប៉ុន្មាន គេនាំគ្នាចាប់គ្រូមន្តអាគមរាប់ពាន់នាក់ធ្វើទារុណកម្ម ដុតសម្លាប់ចោលទាំងរស់ ។ គេនៅតែនឹកគិតអំពីបាបជានិច្ចអំពីការធ្វើទារុណកម្មលើខ្លួន ដើម្បីឲ្យបានរួចពីបាបនិងសេចក្ដីស្លាប់ ។ គ្រីស្តបរិស័ទនឹកតែអំពីបាប និងមាសាតាំងមិនសូវគិតគូរដល់ព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតាចំពោះគេ ។ ព្រឹត្តិការណ៍នេះមានឥទ្ធិពលរហូតដល់សព្វថ្ងៃ ។
- គ្រីស្តបរិស័ទខ្លះមានបំណងចង់កែទម្រង់ព្រះសហគមន៍ ដោយចោទថា អភិបាលក្រុងរ៉ូមមិនសូវល្អ បណ្ដាលឲ្យប្រជាជនកើតទុក្ខវេទនា ។

## ៣- អ្នកប្រាជ្ញជំទាស់នឹងព្រះសហគមន៍

នៅពេលប្រជាជនកើតទុក្ខវេទនាដូច្នេះ មានអ្នកប្រាជ្ញចាប់ផ្ដើមរិះគិតទាស់ទែងនឹងទេវវិជ្ជារបស់ព្រះសហគមន៍ ។

Layout Histor.qxd 2/10/07 10:10 AM Page 156

លោក**អូកាម** (Occam គ.ស. ១២៩០-១៣៥០) យល់ឃើញថា មនុស្ស មិនអាចស្គាល់ព្រះជាម្ចាស់ដោយសារប្រាជ្ញារបស់ខ្លួនបានទេ ។ ហេតុដូច្នេះហើយ គ្រីស្តបរិស័ទត្រូវតែអានព្រះគម្ពីរ និងយកតម្រាប់តាមសន្តបុគ្គល ។

លោក**យ៉ូហានវិគ្លីហ្វ** (John Wiclif គ.ស. ១៣២៤-១៣៨៤) លើកតម្កើង ព្រះគម្ពីរឲ្យខ្ពស់ជាងសេចក្តីដែលព្រះសហគមន៍បញ្ជូនបន្តមក ។ ដោយអភិបាល ក្រុងរ៉ូមពីរនាក់ដណ្តើមអំណាចគ្នា «*ដូចឆ្កែដណ្តើមសាច់*» លោកយល់ឃើញថា ក្នុងព្រះសហគមន៍មានតែអ្នកដែលព្រះគ្រីស្តបានជ្រើសរើសទុកជាមុនទេ ហើយ មានតែព្រះគ្រីស្តណែនាំគេប៉ុណ្ណោះ ។

លោក**យ៉ូហាន ហ៊ូស** (Jean Hus គ.ស. ១៣៦៩-១៤១៥) បន្តការរិះគិត
84 របស់លោក**វិគ្លីហ្វ** សូមឲ្យព្រះសហគមន៍រស់នៅតាមភាពក្រីក្រ ស្របតាមដំណឹងល្អ របស់ព្រះគ្រីស្ត ។ តែមហាសន្និបាតនៅកុងស្តង់ទីណូប្ល (គ.ស. ១៤១៥) ចាប់លោក ដុតបោលទាំងរស់ បណ្តាលឲ្យគ្រីស្តបរិស័ទនៅបូអែម (Bohème ឆែកូសព្វថ្ងៃ) បះបោរប្រឆាំងព្រះសហគមន៍អស់ជាច្រើនឆ្នាំ ។

## ៤- ការប្រែរបៀបរស់នៅតាមគ្រីស្តសាសនា

គ្រីស្តបរិស័ទតប់ប្រមល់អំពីសេចក្តីស្លាប់ និងអំពីការសង្គ្រោះ ។ គេលែង ទុកចិត្តលើអ្នកដឹកនាំព្រះសហគមន៍ ។

គ្រីស្តបរិស័ទនាំគ្នាយកចិត្តទុកដាក់នឹងបទពិសោធន៍ផ្ទាល់ខ្លួនតាមផ្លូវវិញ្ញាណ ជាជាងស្តាប់អស់លោកអភិបាលបង្រៀន ។ គេចូលចិត្តស្តាប់ព្រះសូរសៀងដែលឮ នៅក្នុងចិត្ត ជាជាងពាក្យទូន្មានរបស់លោកអភិបាល គេនាំគ្នាជឿជំនឿអកុសល គោរពសន្តបុគ្គលហួសហេតុ ធ្វើបុណ្យទានជាច្រើន មានអភិបូជាជាដើម ដើម្បី សន្សំបុណ្យ ។ គេបង្កើតពិធីផ្សេងៗមានសូត្រធម៌ជាដើម ដើម្បីឲ្យរួចពីទណ្ឌកម្ម
85 ដែលព្រះសហគមន៍បញ្ជាឲ្យអ្នកបាបប្រព្រឹត្ត (Indulgences) ។ គ្រីស្តបរិស័ទជា ច្រើននាំគ្នាសូត្រផ្គាំ ធ្វើបូជនីយសក៍ និងខិតខំសន្សំបុណ្យសន្សំកុសល ដើម្បីបាន រួចពីបាប ។

តាំងពីពេលនោះមក គ្រីស្តបរិស័ទតែងឆ្លាក់រូបព្រះយេស៊ូកំពុងរកទុក្ខភ្ជាប់ នៅលើឈើឆ្កាង ហើយយកចិត្តទុកដាក់សញ្ជឹងគិតពីទុកលំបាករបស់ខ្លួននៅរួមជា មួយព្រះយេស៊ូ ។ គ្រីស្តបរិស័ទចូលចិត្តគម្ពីរវិវរណៈព្រោះគេយល់ថា នៅក្នុងគម្ពីរ នោះមានទស្សន៍ទាយអំពីព្រឹត្តិការណ៍ដែលកើតនៅសម័យរបស់គេ ជាអវសាន កាលនៃពិភពលោក ។



*គេធ្វើទារុណកម្មលោកយ៉ូហាន ហ៊ូស*

Layout Histor.qxd 2/10/07 10:10 AM Page 157

ទោះជាយ៉ាងណាក៏ដោយ ក៏គ្រីស្តបរិស័ទជាច្រើនយកចិត្តទុកដាក់គោរពប្រណិប័តន៍ព្រះគ្រីស្ត ចង់រួមទុក្ខជាមួយព្រះអង្គដោយចិត្តស្មោះ ។ លោក**អេកខរ** (Eckhart គ.ស. ១២៦០-១៣២៧) រិះគិតយ៉ាងជ្រៅអំពីព្រះជាម្ចាស់ដែលមនុស្សមិនអាចស្រមៃឃើញ ។ គ្រីស្តបរិស័ទតែងតែជួបជុំគ្នាជាក្រុមតូចៗដើម្បីអធិដ្ឋានមានបព្វជិតនិងបូជាចារ្យខ្លះ យកចិត្តទុកដាក់បង្ហាត់គ្រីស្តបរិស័ទឲ្យចម្រើនឡើងខាងវិញ្ញាណ ។ លោក**ថូម៉ាស អាកែមពិស** (Thomas a Kempis គ.ស. ១៣៨០- (86)
១៤៧១) និពន្ធសៀវភៅមានចំណងជើងថា «*ការយកតម្រាប់តាមព្រះយេស៊ូគ្រីស្ត*» (87)
ដែលមានឥទ្ធិពលយ៉ាងខ្លាំងរហូតមកដល់សព្វថ្ងៃ ។

## (84) ចម្លើយរបស់លោកយ៉ូហាន ហ៊ូស នៅមហាសន្និបាតក្រុងប្រាក (គ.ស. ១៩១៣)

ត្រូវនឹកថា ចាប់ពីគ.ស. ១៤០៩ មក មានអភិបាលព្រះសហគមន៍ក្រុងរ៉ូម បីនាក់ ប្រកួតប្រជែងក្នុងការណែនាំព្រះសហគមន៍កាតូលិក ។ ក្នុងអត្ថបទខាងក្រោមនេះ លោក**យ៉ូហាន ហ៊ូស** ស្ដីបន្ទោសលោក**យ៉ូហាន ទី ២៣** ជាអភិបាលក្រុងរ៉ូមនៅក្រុងពីសា ។

ខ្ញុំសូមបួងសួង ឲ្យសាវ័ករបស់មេប្រឆាំងនឹងព្រះគ្រីស្តប្រកាសថា គេយល់ស្របអំពីព្រះសហគមន៍ដ៏វិសុទ្ធ និងដ៏ពិតប្រាកដនៅក្រុងរ៉ូម គឺថានឹកគិតអំពីគ្រីស្តបរិស័ទដែលស្មោះត្រង់នឹងព្រះគ្រីស្ត ហើយដែលកំពុងតយុទ្ធសម្រាប់ជំនឿ ជាអ្នកសុខចិត្តទទួលការអប់រំរបស់លោក**សិលា**ជាអភិបាលក្រុងរ៉ូម ហើយពិសេសទៅទៀត ទទួលការអប់រំរបស់ព្រះគ្រីស្ត ។ ប្រសិនបើក្រុងរ៉ូម ទាំងលោកអភិបាលនិងក្រុមទីប្រឹក្សារបស់លោកត្រូវវិនាសអន្តរាយដូចក្រុងសូដុំពីដើម (ការណ៍នេះអាចកើតឡើងបាន) ក៏ព្រះសហគមន៍ដ៏វិសុទ្ធនៅស្ថិតស្ថេរជាដរាបតរៀងទៅទៀតដែរ ។

ខ្ញុំសូមកាន់ជាប់នូវសេចក្តីដូចតទៅ៖ ខ្ញុំរាប់អភិបាលក្រុងរ៉ូមទុកជាតំណាងរបស់ព្រះគ្រីស្តក្នុងព្រះសហគមន៍ក្រុងរ៉ូម ។ តែខ្ញុំមិនចាត់ប្រការនេះ ទុកជាប្រការដែលត្រូវតែជឿទេ (...) ។ ខ្ញុំយល់ឃើញថា ប្រសិនបើព្រះជាម្ចាស់ជ្រើសរើសអភិបាលក្រុងរ៉ូមជាមុន ហើយប្រសិនបើលោកបំពេញមុខងារជាអ្នកណែនាំហ្វូងចៀម ដោយយកតម្រាប់តាមព្រះយេស៊ូគ្រីស្តមែន លោកនោះពិតជាប្រមុខនៃព្រះសហគមន៍ ដែលកំពុងតយុទ្ធដើម្បីជំនឿ ហើយលោកក៏គ្រងលើគេមែន ។ បើលោកគ្រប់គ្រងរបៀបនេះ ក្នុងឋានៈជាមេដឹកនាំព្រះសហគមន៍ទាំងមូល ដែលកំពុងតយុទ្ធតាមធម្មវិន័យរបស់ព្រះយេស៊ូគ្រីស្តនោះ លោកក៏ពិតជាប្រមុខដឹកនាំមែនក្រោមអំណាចព្រះសិរសា គឺព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើង ។ ប៉ុន្តែ ប្រសិនបើលោករស់នៅផ្ទុយពីព្រះគ្រីស្ត លោកដូចជាចោរលួចចោរប្លន់ដែលចូលមក ជាចចក ជាមនុស្សលាក់ពុតក្នុងចំណោមមនុស្សទាំងអស់ លោកជាមេប្រឆាំងព្រះគ្រីស្តលើសគេ ។ ព្រះអម្ចាស់ព្រមានយើងជាច្រើនឲ្យប្រយ័ត្នខ្លួនកុំបាញ់បោកព្រះគ្រីស្តក្លែងក្លាយ និងកុំបាញ់បោកការអស្ចារ្យរបស់ពួកគេ ។ ខ្ញុំក៏កាន់សេចក្តីនេះដូចគ្រីស្តបរិស័ទឯទៀតៗដែលស្មោះត្រង់នោះថា ខ្ញុំសុខចិត្តទទួលយកដោយគោរព និងដោយប្រណិប័តន៍នូវសេចក្តីទាំងប៉ុន្មាន ដែលព្រះសហគមន៍ក្រុងរ៉ូម ឬអភិបាលក្រុងរ៉ូម ឬក្រុមទីប្រឹក្សាប្រកាសយ៉ាងឱឡារិក បញ្ជាឲ្យជឿ និងឲ្យអនុវត្តតាម ស្របតាមធម្មវិន័យរបស់ព្រះគ្រីស្ត ។ តែខ្ញុំមិនព្រមទទួលស្គាល់នូវសេចក្តីទាំងអស់ដែលអភិបាលក្រុងរ៉ូម និងក្រុមប្រឹក្សាប្រកាសយ៉ាងឱឡារិក និងបញ្ជាជាទូទៅនោះទេ ព្រោះថា ទាំងអភិបាលក្រុងរ៉ូម ទាំងក្រសួងនានាអាចយល់ច្រឡំអំពីសេចក្តីពិត និងអំពីសីលធម៌បាន ។

### ពាក្យចុងក្រោយរបស់លោកយ៉ូហាន ហ៊ូស លើភ្នក់ភ្លើង

ព្រះជាម្ចាស់ជាសាក្សីថា ខ្ញុំមិនដែលបង្រៀន ឬទេសនាសេចក្តីដែលសាក្សីក្លែងក្លាយបញ្ជាក់ថា ខ្ញុំនិយាយនោះទេ ។ ពេលខ្ញុំទេសនា និងក្នុងគ្រប់កិច្ចការដែលខ្ញុំបានធ្វើ ខ្ញុំមានបំណងចម្បងតែមួយ គឺដកមនុស្សឲ្យបានរួចពីបាប ។ ខ្ញុំប្រុងស្លាប់ដោយអំណរ ទាំងកាន់តាមសេចក្តីពិតនៃដំណឹងល្អ ដូចដែលខ្ញុំបានសរសេរ បង្រៀន និងទេសនានោះ ត្រូវតាមគ្រូបាធ្យាយដ៏វិសុទ្ធបានបញ្ជូនបន្តមក ។

៦ ខែ កក្កដា គ.ស. ១៤១៥

Layout Histor.qxd 2/10/07 10:10 AM Page 158

## 85 គ្រូអេកខរ

លោកគ្រូ**អេកខរ** (Maître Eckhart ១២៦០-១៣២៧) កើតនៅស្រុកអាល្លឺមង់ លោកជាបព្វជិតក្នុងក្រុមគ្រួសារដូមីនិកូ ស្នាក់អាស្រ័យនៅទីក្រុងប៉ារីស និងនៅក្រុងកូឡូញ (Cologne) ។ លោកចូលក្នុងចលនារបស់គ្រីស្តបរិស័ទអាល្លឺមង់ ដែលមានបទពិសោធន៍រួមរស់យ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ ។ គេចោទលោកថា លោកបង្រៀនលទ្ធិក្លែងក្លាយអំពីព្រះជាម្ចាស់ ។

នៅគ.ស. ១៣២០ អភិបាលក្រុងរ៉ូមឈ្មោះ**យ៉ូហាន ទី ២២** ប្រកាសថា សេចក្តីដែលលោកបង្រៀនមួយចំនួន ខុសពីលទ្ធិគ្រីស្តសាសនា ។ តាមពិត លោកបង្រៀនត្រឹមត្រូវតាមព្រះវិញ្ញាណ តែអស់លោកអភិបាលមិនយល់គំនិតដ៏ជ្រៅរបស់លោក ។ របៀបលោករិះគិតអំពីព្រះជាម្ចាស់ ប្រហែលនឹងរបៀបពុទ្ធបរិស័ទរិះគិតអំពីបរិនិព្វាន ។

*ព្រះជាម្ចាស់គ្មានព្រះនាមទេ ពីព្រោះគ្មាននរណាម្នាក់អាចនិយាយនិងយល់អ្វីអំពីព្រះអង្គសោះ (..) ។ ដូច្នេះ ប្រសិនបើខ្ញុំពោលថា ព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរស សេចក្តីនេះមិនពិតប្រាកដទេ ខ្ញុំមានចិត្តសប្បុរស តែព្រះអង្គគ្មានព្រះហឫទ័យសប្បុរសតាមរបៀបខ្ញុំទេ (..) ។ ប្រសិនបើខ្ញុំនិយាយទៀតថា ព្រះជាម្ចាស់ប្រកបដោយគតិបណ្ឌិត សេចក្តីនេះមិនពិតប្រាកដទេ ខ្ញុំប្រកបទៅដោយគតិបណ្ឌិតជាងព្រះអង្គ ។ ប្រសិនបើខ្ញុំនិយាយថា ព្រះជាម្ចាស់ជាព្រះមួយអង្គ សេចក្តីនេះមិនពិតប្រាកដទេ ព្រោះព្រះអង្គលើសព្រះទាំងអស់ (..) ។ គ្រូម្នាក់និយាយថា «បើខ្ញុំគោរពព្រះមួយអង្គ ដែលខ្ញុំអាចស្គាល់បាន ខ្ញុំមិនចាត់ព្រះនោះទុកជាព្រះជាម្ចាស់ទេ (..) ។ អ្នកត្រូវស្រឡាញ់ព្រះជាម្ចាស់ក្នុងឋានៈជាព្រះជាម្ចាស់ គឺមិនមែនជាព្រះ គឺមិនមែនជាវិញ្ញាណ មិនមែនជាបុគ្គល មិនមែនជារូបឡើយ ។ លើសពីនេះទៅទៀត ព្រះអង្គវិសុទ្ធមិនលាយនឹងអ្វីសោះ ព្រះអង្គបរិសុទ្ធ ព្រះអង្គបញ្ចេញពន្លឺដ៏ចិញ្ចែងចិញ្ចាច (..) ។*

## 86 វិធីគោរពព្រះជាម្ចាស់តាមរបៀបទំនើប គឺយកតម្រាប់តាមព្រះយេស៊ូគ្រីស្ត

*អ្នកណាចង់ភ្លក្សឱជារសដ៏ឆ្ងាញ់នៃព្រះបន្ទូលព្រះយេស៊ូគ្រីស្ត ត្រូវយកចិត្តទុកដាក់រស់នៅតាមព្រះអង្គនូវគ្រប់កិច្ចការប្រចាំជីវិត ។ បើអ្នកជជែកវែកញែកអំពីព្រះត្រៃឯក តើមានប្រយោជន៍អ្វី បើអ្នកគ្មានចិត្តសុភាពរាបសា ធ្វើឲ្យព្រះត្រៃឯកមិនសព្វព្រះហឫទ័យនឹងអ្នក ។ តាមពិតពាក្យសំដីដែលមានអត្ថន័យជ្រៅ មិនធ្វើឲ្យមនុស្សបានវិសុទ្ធ និងបានសុចរិតទេ គឺមានតែការរស់នៅប្រកបដោយព្រហ្មវិហារធម៌ប៉ុណ្ណោះ ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់វិញ (...) ។*

*ទោះបីជាអ្នកចងចាំគម្ពីរទាំងមូលរត់មាត់ក្តី និងស្គាល់សេចក្តីទាំងប៉ុន្មានដែលទស្សនវិទូថ្លែងក្តី តើមានប្រយោជន៍អ្វី បើអ្នកគ្មានចិត្តស្រឡាញ់ព្រះជាម្ចាស់ និងព្រះជាម្ចាស់មិនប្រណីសន្តោសដល់អ្នក? អ្វីៗទាំងអស់សុទ្ធតែគ្មានន័យ ឥតខ្លឹមសារ និងឥតបានការទាំងអស់ ក្រៅពីការស្រឡាញ់ព្រះជាម្ចាស់ និងបម្រើព្រះជាម្ចាស់តែមួយព្រះអង្គគត់ ។ប្រាជ្ញាដ៏ខ្ពង់ខ្ពស់បំផុតមានដូចតទៅ គឺត្រូវមើលងាយអ្វីៗទាំងអស់ក្នុងពិភពលោក និងឈានទៅកាន់ព្រះរាជ្យនៃស្ថានបរមសុខវិញ (១, ១) ។*

*អ្នកស្រែដ៏ទន់ទាបដែលបម្រើព្រះជាម្ចាស់ ប្រសើរជាងទស្សនវិទូដែលមានចិត្តក្រអឺតក្រទម ដែលចេះពិនិត្យចលនាតារានៅលើមេឃ តែមិនរវីរវល់នឹងខ្លួនឯង (...) ។ ចូរជៀសផុតពីបំណងចង់ចេះដឹងខ្លាំងពេក ដ្បិតបំណងនេះបណ្តាលឲ្យវិញ្ញាណមិននឹងនរទេ និងបណ្តាលឲ្យខកចិត្ត (...) ។ ប្រសិនបើអ្នកស្មានថា អ្នកស្គាល់សេចក្តីជាច្រើន ហើយយល់សេចក្តីទាំងនោះគ្រាន់បើ សូមឲ្យដឹងថា មានសេចក្តីជាច្រើនទៀតដែលអ្នកមិនស្គាល់ (...) ។ ការស្គាល់ខ្លួនយ៉ាងពិតប្រាកដ និងបន្ទាបខ្លួន ពិតជាចំណេះដឹងដ៏ខ្ពង់ខ្ពស់បំផុត និងមានប្រយោជន៍ខ្លាំងជាងគេ (១, ២) ។*

*គ្មានមូលហេតុណាមួយក្នុងពិភពលោក អាចអនុញ្ញាតឲ្យអ្នកប្រព្រឹត្តអំពើអាក្រក់ ទោះបីមូលហេតុនៃការស្រឡាញ់មនុស្សម្នាក់ក្តី ។ ប៉ុន្តែ នៅពេលខ្លះត្រូវសុខចិត្តពន្យារពេលប្រព្រឹត្តអំពើល្អមួយ ឬត្រូវធ្វើអំពើរឹតតែល្អប្រសើរជំនួសទៅទៀត ដើម្បីជួយអ្នកខ្វះខាត (...) ១, ១៥ ។*

*ព្រះអម្ចាស់មានព្រះបន្ទូលថា «ព្រះរាជ្យរបស់ព្រះអង្គនៅកណ្តាលចំណោមអ្នករាល់គ្នា» ។ ហេតុនេះ ចូរបែរទៅរកព្រះអម្ចាស់ឲ្យអស់ពីដួងចិត្ត ចូរលះបង់ពិភពលោកដ៏ថោកទាបនេះ នោះវិញ្ញាណរបស់អ្នកនឹងបានស្ងប់ ។ ចូរបង្ហាត់ខ្លួនឲ្យមើលងាយអ្វីៗដែលនៅខាងក្រៅ និងយកចិត្តទុកដាក់នឹងសេចក្តី*

•••

Layout Histor.qxd 2/10/07 10:10 AM Page 159

*ដែលនៅខាងក្នុងវិញ អ្នកមុខជានឹងឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់មកដល់ក្នុងអ្នកពុំខាន (៣,១) ។*

*ម្នាលកូនអើយ! កូនមិនអាចមានបំណងយ៉ាងខ្លាំង ចង់ប្រព្រឹត្តតាមព្រហ្មវិហាធម៌ជានិច្ចបានទេ កូនក៏មិនអាចរស់នៅដោយស្មឹងស្មាធិ៍យ៉ាងជ្រៅរហូតដែរ ។ តែកូនត្រូវទៅបំពេញកិច្ចការដ៏ថោកទាបវិញ ហើយត្រូវលីទម្ងន់ប្រចាំជីវិត ដែលតែងតែរលួយនេះ ទោះបីកូនមិនពេញចិត្ត និងស្អប់ខ្ពើមកិច្ចការនោះក្តី (៣,៥១) ។*

*ថូម៉ាសអាកែមពិស*

87

# ពាក្យអធិដ្ឋានទៅកាន់ព្រះយេស៊ូ

លោក**នីសេហ្វ័រ** ដែលរស់នៅម្នាក់ឯង (Nicéphore le Solitaire) កើតខាងត្បូងស្រុកអ៊ីតាលី នៅពាក់កណ្តាលសតវត្សទី ១៣ ។ លោកជាបព្វជិតរស់នៅក្រុងកុងស្តង់ទីណូប្ល បន្ទាប់មកលោករស់ជាឥសីនៅលើភ្នំអាថូស (Mont Athos) ។ លោកនិពន្ធសៀវភៅមួយមានចំណងជើងថា «*អំពីការតាំងចិត្តអធិដ្ឋាន*» ។ លោកពន្យល់វិធីអធិដ្ឋានមួយតាមបច្ចេកទេសខាងចិត្តវិទ្យា និងរូបវិទ្យា ។ លោកពន្យល់ប្រហែលនឹងគ្រូខាងពុទ្ធសាសនាដែរ ។

*មុនដំបូង សូមប្អូនរស់នៅយ៉ាងសុខសាន្ត កុំទាស់ទែងជាមួយនរណាឲ្យសោះ ។ សូមចូលក្នុងបន្ទប់ស្ងាត់ អង្គុយនៅកៀនមួយ ហើយសូមធ្វើតាមខ្ញុំប្រាប់ខាងក្រោមនេះ៖*

*ប្អូនដឹងហើយថា ខ្យល់យើងគឺជាខ្យល់ដង្ហើមរបស់យើង យើងបញ្ចេញព្រោះតែបេះដូងរបស់យើង (...) ។ សូមអង្គុយចុះ ប្រមូលអារម្មណ៍បញ្ចូលវិញ្ញាណទៅក្នុងរន្ធច្រមុះ ។ នេះគឺជាផ្លូវខ្យល់ដង្ហើមចូលទៅកាន់បេះដូង ។ ចូរជំរុញវិញ្ញាណបង្ខំឲ្យចូលក្នុងបេះដូងរួមជាមួយខ្យល់ដង្ហើមចូល ។ ពេលវិញ្ញាណចូលហើយ អ្នកនឹងសប្បាយរីករាយ មិននឹកស្តាយអ្វីសោះ ។ បុរសម្នាក់ត្រឡប់មកផ្ទះ ក្រោយពីឃ្លាតចាកឆ្ងាយពីផ្ទះយ៉ាងយូរ មិនអាចទប់ទល់អំណរសប្បាយរបស់ខ្លួនបាន នៅពេលជួបប្រពន្ធកូនវិញយ៉ាងណា ពេលវិញ្ញាណជួបនឹងបេះដូងក៏សប្បាយរីករាយយ៉ាងខ្លាំង រកថ្លែងពុំបានយ៉ាងនោះដែរ ។ ដូច្នេះ សូមប្អូនបង្ខាត់វិញ្ញាណ កុំប្រញាប់ចេញពីបេះដូងវិញ (...) ។*

*ពេលវិញ្ញាណនៅក្នុងបេះដូង ប្អូនមិនត្រូវនៅស្ងៀមទេ ហើយក៏មិនត្រូវខ្ជិលដែរ ។ សូមកុំធ្វើអ្វី កុំនឹកគិតអំពីអ្វី ក្រៅពីពោលថា៖ «បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្តជាព្រះបុត្រារបស់ព្រះជាម្ចាស់ សូមអាណិតអាសូរខ្ញុំផង!» ។ សូមកុំសម្រាកជាដាច់ខាត ។ ការប្រព្រឹត្តដូច្នេះ ធ្វើឲ្យវិញ្ញាណនៅជាប់នឹងនរមិនរវើរវាយ ខ្មាំងសត្រូវមិនអាចលួងលោមដណ្តើមយកវិញ្ញាណប្អូនបានទេ ។ ប្រព្រឹត្តដូច្នេះ ក៏ធ្វើឲ្យបងប្អូនស្រឡាញ់ព្រះជាម្ចាស់ នឹងប្រាថ្នាចង់ជួបព្រះអង្គកាន់តែខ្លាំងឡើងៗដែរ ។*

***« បពិត្រព្រះអម្ចាស់យេស៊ូគ្រីស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ សូមអាណិតអាសូរខ្ញុំផង! »***



*រូបព្រះយេស៊ូតាមប្រពៃណីមជ្ឈិមបូព៌ា*

Layout Histor.qxd 2/10/07 10:10 AM Page 160



Layout Histor.qxd 2/10/07 10:10 AM Page 161



# ការកែទម្រង់ព្រះសហគមន៍

## សតវត្សទី ១៥-១៦

*នៅទ្វីបអឺរ៉ុប នាចុងសតវត្សទី ១៥ មានប្រទេសខ្លះលូតលាស់ ចង់បម្រះចេញពីអំណាចនៃអភិបាលព្រះសហគមន៍ក្រុងរ៉ូម និងពីអំណាចព្រះចៅនៃ «ចក្រភពអាល្លឺម៉ង់ដ៏វិសុទ្ធ» ដែរ ។ ប្រជាជនទ្វីបអឺរ៉ុបប្រែវប្បធម៌របស់ខ្លួនយ៉ាងជ្រៅ ហាក់បីដូចជាវប្បធម៌កើតឡើងវិញ ។ លោកហ្គូតំបែរ បង្កើតឧបករណ៍បោះពុម្ពអក្សរ នាំឲ្យគេបោះពុម្ពផ្សាយព្រះគម្ពីរ និងសៀវភៅរបស់ទស្សនវិទូបុរាណ ។ គ្រីស្តបរិស័ទនាំគ្នារិះគិតតាមប្រភពនៃជំនឿរបស់ខ្លួន គឺតាមព្រះគម្ពីរ និងសំណេររបស់គ្រូបាធ្យាយនៃព្រះសហគមន៍ ។ គ្រីស្តបរិស័ទជាច្រើនមានបំណងជម្រះព្រះសហគមន៍អំពីសេចក្ដីដែលគេបន្ថែមបណ្ដើរៗតាមសតវត្សតៗមក ។ គេចង់កែទម្រង់ព្រះសហគមន៍ ប៉ុន្តែ គួរឲ្យស្ដាយណាស់ដោយស្ដាប់គ្នាមិនបាន និងប្រើហឹង្សាទាំងសងខាង ព្រះសហគមន៍នៅបស្ចិមប្រទេសបាក់បែកគ្នារហូតមកដល់សព្វថ្ងៃ ។ (សូមអានប្រវត្តិព្រះសហគមន៍កម្ពុជា ទំព័រ ២៣-៤៥)*

### ១- វប្បធម៌ទ្វីបអឺរ៉ុបលូតលាស់ឡើង

គ.ស.១៤៥៣ ចប់ *«សង្គ្រាម ១០០ ឆ្នាំ»* រវាងកងទ័ពបារាំងនិងអង់គ្លេស ។ ប្រទេសបារាំង ប្រទេសអង់គ្លេស និងប្រទេសអេស្ប៉ាញរីកចម្រើនឡើង កងទ័ពអេស្ប៉ាញដេញអ្នកកាន់សាសនាអ៊ីស្លាមចេញពីស្រុកគេ (១៤៩២) ។ ព្រះចៅអធិរាជអាល្លឺម៉ង់ **សាលកិង** (Charles-Quint) ក៏លាតអំណាចកាន់តែខ្លាំងឡើងៗ ត្រួតត្រាទាំងអឺរ៉ុបកណ្ដាល ទាំងស្រុកហូឡង់ ទាំងស្រុកអេស្ប៉ាញផង ។

នៅគ.ស.១៤៥៦ លោក**ហ្គូតំបែរ** (Guttemberg) បង្កើតឧបករណ៍បោះពុម្ពអក្សរ ។ លោកបោះពុម្ពព្រះគម្ពីរមុនសៀវភៅឯទៀតៗទាំងអស់ ។ បន្ទាប់មកលោកនិងអ្នកដទៃ បោះពុម្ពសៀវភៅជាច្រើនខាងសាសនា ។ ពីមុនៗមក បព្វជិតធ្លាប់ចម្លងសៀវភៅដោយផ្ទាល់ដៃនៅក្នុងវត្តអារាម ។ ដូច្នេះ មានតែបព្វជិតក្នុងវត្ត អភិជន ឬអ្នកមានទេ ដែលអានព្រះគម្ពីរ និងសៀវភៅឯទៀតៗបាន រីឯអ្នកតូចតាច ត្រូវតែស្ដាប់បូជាចារ្យពន្យល់គម្ពីរប៉ុណ្ណោះ ។ តាំងពីពេលនោះមក

*លោកហ្គូតំបែរបង្កើតឧបករណ៍បោះពុម្ពអក្សរ (១៤៥៦)*

គេនាំគ្នាបោះពុម្ពផ្សាយសៀវភៅជាស្នាដៃគ្រូបាធ្យាយនៃព្រះសហគមន៍ និងស្នាដៃអ្នកនិពន្ធពីបុរាណ ។ ហេតុនេះហើយ ទើបកើតអរិយធម៌ថ្មី គឺមនុស្សជាច្រើន 88
ចង់ចេះចង់ដឹង ខិតខំរិះគិត ។ លោក**អេរ៉ាស្ម** (Erasme គ.ស. ១៤៦៩-១៥៣៦) បោះពុម្ពផ្សាយសៀវភៅជាច្រើន ជាពិសេសគម្ពីរសម្ពន្ធមេត្រីថ្មីជាភាសាក្រិក (១៥១៦) ។ លោកមានបំណងចង់កែទម្រង់ព្រះសហគមន៍ ។

សម័យនោះ អភិបាលក្រុងរ៉ូមកាន់តែខិលខូចអាក្រក់ទៅៗ អស់លោកបែកទ្រព្យសម្បត្តិព្រះសហគមន៍ឲ្យកូនក្មួយ កូនក្រៅខោ ឬកូនខ្លួនផ្ទាល់ ។ លោក**អាឡិចសង់ ទី ៦** (Alexandre Borgia គ.ស.១៤៩២-១៥០៣) ខូចជាងគេ ហើយក៏មានកូនស្រីពីរនាក់មានឈ្មោះល្បីខាងអាក្រក់ដែរ ។ លោកអភិបាលព្រះសហគមន៍ក្រុងរ៉ូមឈ្មោះ**យូលីយូស ទី ២** (Jules II គ.ស. ១៥០៣-១៥១៣) ក៏តែងនាំកងទ័ពដោយផ្ទាល់ទៅតយុទ្ធនឹងខ្មាំងលើសមរភូមិ ។ អស់លោកចាយវាយប្រាក់ជាច្រើនដើម្បីសាងសង់គេហដ្ឋានដ៏ល្អប្រណិតនៅក្រុងរ៉ូម ដូចស្ដេចតាមរបៀបលោកិយ ។

Layout Histor.qxd 2/10/07 10:10 AM Page 162

## ២- អ្នកកែទម្រង់ព្រះសហគន៍

គ្រីស្តបរិស័ទខ្លះស្វែងរកព្រះគ្រីស្តយ៉ាងខ្លាំង ដោយអានគម្ពីរដំណឹងល្អ ។ លោក**ម៉ារតាំង-លូធែរ** (Martin Luther) កើតនៅស្រុកអាល្លឺម៉ង់ គ.ស. ១៤៨៣ ក្នុងគ្រួសារអ្នកមានគ្រប់គ្រាន់ ។ ពេលនៅក្មេង លោកព្រឺសាច់ដោយឮនិទានរឿងអស្ចារ្យស្ដីអំពីមារនិងរឿងគ្រូធ្មប់ ។ នៅគ.ស. ១៥០៥ លោកឈឺបិះស្លាប់ រួចចូលធ្វើជាបព្វជិតនៅវត្តសន្ដអូគូស្ដាំង ។ លោកកាន់វិន័យយ៉ាងតឹងរ៉ឹង និងទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ។ បន្ទាប់មក លោកបង្រៀនព្រះគម្ពីរនៅមហាវិទ្យាល័យវិតែមបែរ (Wittemberg) ។ តែលោកនៅតែព្រួយបារម្ភ ដោយដឹងថាខ្លួនជាអ្នកបាប មានចិត្តលោភលន់ មានសភាវគតិទាក់ទាញឲ្យប្រព្រឹត្តអំពើបាប ។ លោកខ្លាចព្រះជាម្ចាស់ដាក់ទណ្ឌកម្មទម្លាក់ទៅស្ថាននរក ។ ថ្ងៃមួយ លោកអាន

89 លិខិតរបស់គ្រីស្តទូត**ប៉ូល**ផ្ញើជូនគ្រីស្តបរិស័ទក្រុងរ៉ូម ដែលចែងថា «*មនុស្សបានសុចរិតដោយសារជំនឿ មិនមែនដោយកុសលផលបុណ្យតាមធម្មវិន័យឡើយ*» (រ៉ូម ១,១៧; ៣,២៨) ។ អត្ថបទនោះនាំឲ្យលោកភ្ញាក់ស្មារតី និងបានអំណរសប្បាយជាខ្លាំង ធ្វើឲ្យលោករួចពីការតប់ប្រមល់ ។ លោកយល់ឃើញថា មនុស្សមិនអាចសង្គ្រោះខ្លួនឯងដោយអំពើល្អដែលខ្លួនបានប្រព្រឹត្តនោះទេ គឺមានតែព្រះជាម្ចាស់មួយព្រះអង្គគត់ អាចប្រោសមនុស្សឲ្យសុចរិត ដោយព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គប៉ុណ្ណោះ ។ មនុស្សនៅតែជាប់បាប ប៉ុន្តែព្រះជាម្ចាស់យាងមកសង្គ្រោះគេ ។



*លោកម៉ារតាំង-លូធែរ*

88

### សាសនារបស់លោកអេរ៉ាស្ម

លោក**អេរ៉ាស្ម**សង្ឃឹមថា គ្រីស្តបរិស័ទកែទម្រង់ព្រះសហគមន៍បាន ដោយស្គាល់ព្រះគម្ពីរឲ្យបានច្បាស់ជាងពីមុន ។ ហេតុនេះលោកយល់ឃើញថា មិនគ្រាន់តែត្រូវស្វែងរកគម្ពីរដើមជាភាសាហេប្រឺ ក្រិក និងឡាតាំងប៉ុណ្ណោះទេ គឺត្រូវបកប្រែព្រះគម្ពីរតាមគ្រប់ភាសាថែមទៀតផង ។ លោកយល់ឃើញថា គតិបណ្ឌិតដ៏ពិតប្រាកដសម្រាប់មនុស្សរស់នៅ ស្ថិតនៅក្នុងព្រះគម្ពីរ មនុស្សលោកក៏អាចស្គាល់ទស្សនវិជ្ជារបស់ព្រះគ្រីស្តបាន ក៏ដោយសារព្រះគម្ពីរដែរ ។

*កាលព្រះគ្រីស្តរស់នៅក្នុងលោកនេះ តើនរណាមកស្ដាប់ព្រះអង្គ? គឺមានបណ្ដាជនចម្រុះមកស្ដាប់ មានទាំងមនុស្សខ្វាក់ មនុស្សពិការជើង អ្នកសុំទាន អ្នកទារពន្ធ នាយទាហានរ៉ូម៉ាំង ស្ត្រីៗ និងក្មេងៗ ។ល ។ បើព្រះអង្គសព្វព្រះហឫទ័យឲ្យអ្នកទាំងនោះស្ដាប់ព្រះបន្ទូល ទ្រង់មុខជាមិនទាស់ព្រះហឫទ័យឲ្យគេអានព្រះបន្ទូលទេ ។ តាមពិត ទាំងកសិករ ទាំងជាង ទាំងចោរ ទាំងស្រីពេស្យា ទាំងពួកជើងកាង និងពួកបារ៉ាំបន នឹងអានព្រះគម្ពីរបាន សូម្បីតែជនជាតិទួរគីក៏អានបានដែរ ។ បើព្រះគ្រីស្តមិនដេញពួកគេកុំឲ្យមកស្ដាប់ព្រះបន្ទូល ខ្ញុំក៏មិនដេញគេ និងឃាត់គេមិនឲ្យអានព្រះគម្ពីរដែរ (...) ។*

*ព្រះគ្រីស្តសព្វព្រះហឫទ័យផ្សព្វផ្សាយទស្សនវិជ្ជារបស់ព្រះអង្គយ៉ាងឆ្ងាយ ។ ព្រះអង្គសោយទិវង្គតដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់ ព្រះអង្គក៏សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ស្គាល់ព្រះអង្គដែរ ។ គោលដៅរបស់ព្រះអង្គសម្រេចបាន* ●●●

Layout Histor.qxd 2/10/07 10:10 AM Page 163

*លុះត្រាតែគេបកប្រែសៀវភៅរបស់ព្រះអង្គក្នុងគ្រប់ភាសានៅគ្រប់ប្រទេសទាំងអស់ ឬដោយអ្នកដឹកនាំប្រទេសចាត់ចែងឲ្យគេបង្រៀនភាសាទាំងបី គឺភាសាហេប្រឺ ក្រិក ឡាតាំងឲ្យប្រជាជនទាំងអស់ ពីព្រោះជាភាសាគ្រឹះនៃទស្សនវិជ្ជានេះ ។*

*តើមានអ្វីជំទាស់មិនឲ្យគេសូត្រគម្ពីរដំណឹងល្អតាម ភាសាកំណើតរបស់ខ្លួន តាមតែខ្លួនអាចស្តាប់បាន? ជនជាតិបារាំងសូត្រជាភាសាបារាំង ជនជាតិអង់គ្លេសសូត្រជាភាសាអង់គ្លេស ជនជាតិអាល្លឺម៉ង់សូត្រជាភាសាអាល្លឺម៉ង់ ជនជាតិឥណ្ឌាសូត្រជាភាសាឥណ្ឌា ។ ខ្ញុំយល់ឃើញថា មនុស្សមិនបានរៀន ហើយស្រីៗស្មូតទំនុកតម្កើងដូចសត្វសេក និងសូត្រពាក្យអធិដ្ឋានរបស់ព្រះអម្ចាស់ជាភាសាឡាតាំង ទាំងមិនយល់អ្វីសោះឡើយ ពិតជាមិនសមរម្យ និងគួរឲ្យអស់សំណើចដែរ ។*

*លោកអេរ៉ាស្មុ*

*«សេចក្តីប្រៀនប្រដៅមកអ្នកអានគម្ពីរម៉ាថាយ» (១៥២២)*

## (89) លោកលូធែរយល់ឃើញថា ព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណា

ពេលលោក**លូធែរ**ចាស់ទៅ លោករៀបរាប់អំពីបទពិសោធន៍របស់ខ្លួនខាងវិញ្ញាណ គឺព្រះជាម្ចាស់សង្គ្រោះមនុស្សដោយសារតែជំនឿប៉ុណ្ណោះ ។ ប្រហែលលោកមានបទពិសោធន៍នេះនៅគ.ស. ១៥១៤ ។

*ខ្ញុំមានបំណងយ៉ាងខ្លាំងជាយូរមកហើយ ចង់យល់ច្បាស់អំពីពាក្យមួយ ចែងក្នុងលិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងរ៉ូម នៅជំពូកទី ១ ថា «ព្រះជាម្ចាស់សម្តែងព្រះហឫទ័យសុចរិតរបស់ព្រះអង្គដោយសារដំណឹងល្អ»* (ពាក្យ «សុចរិត» អាចប្រែថា «យុត្តិធម៌» ក៏បានដែរ) ។ *តាំងពីពេលនោះមក ខ្ញុំតែងតែនឹកដល់ពាក្យនោះទាំងភ័យខ្លាច ។ ខ្ញុំតែងស្អប់ពាក្យ «ព្រះហឫទ័យសុចរិត» ព្រោះធម្មតា គ្រូបានបង្រៀនខ្ញុំឲ្យយល់ពាក្យនេះតាមរបៀបទស្សនវិជ្ជា គឺខ្ញុំយល់ថា ព្រះជាម្ចាស់ប្រកបដោយយុត្តិធម៌ តែងតែផ្តន្ទាទោសអ្នកបាប ។*

*ទោះបីខ្ញុំរស់នៅយ៉ាងត្រឹមត្រូវគ្មានកំហុស ក្នុងឋានៈជាបព្វជិតក្តី ក៏ខ្ញុំដឹងខ្លួនថា ខ្ញុំជាអ្នកបាបនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ដែរ ។ មនសិការរបស់ខ្ញុំនៅតែបារម្ភជាពន់ពេក ខ្ញុំគ្មានភស្តុតាងថា ព្រះជាម្ចាស់ធូរព្រះហឫទ័យដោយអំពើល្អរបស់ខ្ញុំទេ ។ ហេតុដូចនេះ ខ្ញុំមិនស្រឡាញ់ព្រះជាម្ចាស់ប្រកបដោយយុត្តិធម៌បែបនេះទេ គឺព្រះដែលរកតែសងសឹកមនុស្ស ។ ខ្ញុំស្អប់ព្រះអង្គ ។ ទោះបីខ្ញុំមិនប្រមាថព្រះអង្គនៅទីស្ងាត់ក្តី ក៏ខ្ញុំពិតជាមួរម៉ៅដាក់ព្រះអង្គ ហើយរអ៊ូរទាំយ៉ាងខ្លាំងប្រឆាំងព្រះអង្គថា «ព្រះអង្គមិនគ្រាន់តែផ្តន្ទាទោសយើង ឲ្យស្លាប់អស់កល្បជានិច្ច ព្រោះតែអំពើបាបដូនតារបស់យើងប៉ុណ្ណោះទេ ព្រះអង្គក៏នឹងដាក់ទោសមកយើង ទៅតាមធម្មវិន័យដ៏តឹងរ៉ឹងរបស់ព្រះអង្គទៀត ។ ព្រះអង្គនឹងបន្ថែមទារុណកម្មលើយើងដោយដំណឹងល្អសូម្បីនៅពេលនោះ ក៏ព្រះអង្គឲ្យយើងប្រកាសយុត្តិធម៌ និងព្រះពិរោធរបស់ព្រះអង្គទៀត ។ ខ្ញុំហួសចិត្ត ជ្រួលច្របល់ក្នុងចិត្ត ខ្ញុំចេះតែរិះគិតអំពីអត្ថបទរបស់គ្រីស្តទូត**ប៉ូល**នេះ ដោយមានបំណងយ៉ាងខ្លាំង ចង់ដឹងថា លោកមានបំណងពន្យល់អ្វីខ្លះ ។*

*ពេលនោះ ព្រះជាម្ចាស់អាណិតអាសូរខ្ញុំ ។ ពេលខ្ញុំនឹកសញ្ជឹងគិតទាំងថ្ងៃទាំងយប់ ខ្ញុំពិនិត្យមើលពាក្យដែលភ្ជាប់ជាមួយគ្នានោះថា «ព្រះជាម្ចាស់សម្តែងព្រះហឫទ័យសុចរិតរបស់ព្រះអង្គដោយសារដំណឹងល្អ ដូចមានចែងទុកមកថា «មនុស្សសុចរិតមានជីវិតដោយសារជំនឿ» ។ ខ្ញុំចាប់ផ្តើមយល់ឃើញថា «ព្រះហឫទ័យសុចរិត» មានន័យថា គឺជាសេចក្តីសុចរិតដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យ គឺព្រះអង្គប្រោសឲ្យមនុស្សសុចរិតរស់នៅ លុះត្រាតែគេមានជំនឿ ។ ហេតុនេះហើយ បានជាឃ្លានេះមានអត្ថន័យថា ដំណឹងល្អសម្តែងព្រះហឫទ័យសុចរិតរបស់ព្រះជាម្ចាស់ គឺព្រះអង្គអាណិតអាសូរយើង ព្រះអង្គប្រោសយើងឲ្យបានសុចរិត ដោយយើងមានជំនឿ ដូចមានចែងទុកមកថា «មនុស្សសុចរិតមានជីវិតដោយសារជំនឿ» ។ នៅពេលនោះខ្ញុំដឹងថា ខ្ញុំកើតសាជាថ្មីហើយ ខ្ញុំដូចជាចូលស្ថានបរមសុខហើយតាមទ្វារបើកចំហ ។ តាំងពីពេលនោះមក ខ្ញុំយល់ព្រះគម្ពីរទាំងមូលតាមរបៀបថ្មី ខ្ញុំនឹកអត្ថបទតាមខ្ញុំនឹកចាំ ហើយកំណត់ពាក្យឯទៀតៗ គឺត្រូវពន្យល់ពាក្យទាំងនោះតាមរបៀបដដែល គឺថាព្រះរាជកិច្ចរបស់ព្រះជាម្ចាស់មានន័យថា ព្រះរាជកិច្ចដែលព្រះអង្គប្រព្រឹត្តក្នុងខ្លួនយើង ។ «ឫទ្ធានុភាពរបស់ព្រះជាម្ចាស់» ជាឫទ្ធានុភាពដែលផ្តល់កម្លាំងឲ្យយើង ។ «ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់» គឺព្រះអង្គប្រោសឲ្យយើងមានប្រាជ្ញា ។ «ការសង្គ្រោះ» «សិរីរុងរឿងរបស់ព្រះជាម្ចាស់» មានអត្ថន័យដូចគ្នានោះ ។ ពេលមុនខ្ញុំស្អប់ពាក្យ «ព្រះហឫទ័យសុចរិតរបស់ព្រះជាម្ចាស់» នេះខ្លាំងយ៉ាងណា ឥឡូវខ្ញុំស្រឡាញ់ពាក្យនេះខ្លាំងយ៉ាងនោះវិញ ជាពាក្យដ៏ផ្អែមល្ហែម (..) ។*

*លោកលូធែរ «អារម្ភកថានៃស្នាដៃ» គ.ស. ១៥៤៥*

Layout Histor.qxd 2/10/07 10:10 AM Page 164

## ៣- បុណ្យកុសលសម្រាប់អនុគ្រោះ *(Indulgences)*

នៅសម័យនោះ ព្រះសហគមន៍តែងតែធ្វើអគ្គសញ្ញាលើកលែងទោសជូនគ្រីស្តបរិស័ទ គឺព្រះសហគមន៍អត់ទោសឲ្យអ្នកបាបក្នុងនាមព្រះជាម្ចាស់ តែព្រះសហគមន៍តែងបញ្ជាឲ្យអ្នកបាបទទួលទណ្ឌកម្មម្យ៉ាង ដើម្បីឲ្យរួចពីទោស ។ ឧប. ឲ្យគេតមអាហារមួយរយៈ ឲ្យគេធ្វើបុណ្យទានដល់អ្នកក្រីក្រមួយចំនួន ។ល ។

បព្វជិតក្រុមគ្រួសារដូមីនិកូតែងតែប្រកាសថា ប្រសិនបើអ្នកបាបចូលបច្ច័យសម្រាប់សាងសង់ព្រះវិហារសន្តសិលានៅក្រុងរ៉ូម គេនឹងបានរួចពីទណ្ឌកម្មនោះ គឺព្រះសហគមន៍អនុគ្រោះដល់គេ ។ គ្រីស្តបរិស័ទជាច្រើនយល់ឃើញថា ប្រសិនបើគេបង់ប្រាក់ គេបានរួចពីបាប ។ មនុស្សស្លាប់ក៏អាចរួចពីបាបនោះបានដែរ ។ មានបព្វជិតម្នាក់ប្រកាសថា «*ពេលមានកាក់មួយធ្លាក់ក្នុងហិប វិញ្ញាណក្ខន្ធមនុស្សស្លាប់ម្នាក់ឡើងស្ថានបរមសុខហើយ*» ។

លោក**លូធែរ**ញជួច្ចេះ ក៏ហួសចិត្ត ហើយសរសេរ «*ប្រជានបទ ៩៥ ខ*» បិទនៅមុខព្រះវិហារនៅវិតែមបែរនោះ ។ លោកប្រឆាំងគេផង និងអញ្ជើញសាស្ត្រាចារ្យមហាវិទ្យាល័យឲ្យវែកញែកអំពីរឿងនោះជាមួយលោក ។ លោកលូធែរមិនព្រមឲ្យមនុស្សបាបស្មានថា បានរួចខ្លួនយ៉ាងស្រួលដោយគ្រាន់តែបង់ប្រាក់របៀបនោះទេ គ្រីស្តបរិស័ទមិនអាចសូកព្រះជាម្ចាស់ ឬទិញការប្រណីសន្តោសរបស់ព្រះអង្គបានឡើយ ព្រោះព្រះអង្គប្រោសប្រណីមនុស្សតាមតែព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គប៉ុណ្ណោះ ។ នៅពេលនោះ លោកលូធែរមិនទាន់ជំទាស់ប្រឆាំងអភិបាលក្រុងរ៉ូមនៅឡើយទេ ហើយក៏មិនគិតនឹងបែកបាក់ពីលោកដែរ ។ នៅប្រទេសអាល្លឺម៉ង់ និងនៅទ្វីបអឺរ៉ុបទាំងមូល គ្រីស្តបរិស័ទជាច្រើនចូលចិត្តអាន (90) «*ប្រជានបទទាំង ៩៥ ខ*» នោះដោយរីករាយ ។ លោក**អេរ៉ាស្ម**យល់ស្របទាំងស្រុងតាមលោកលូធែរ ។

---

(90) **ប្រធានបទ ៩៥ ប្រការ (៣១ តុលា គ.ស. ១៥១៧)**

លោក**លូធែរ**បិទប្រជានបទទាំង ៩៥ ប្រការនៅថ្ងៃមុនព្រះសហគមន៍ធ្វើបុណ្យគោរពសន្តបុគ្គល និងថ្ងៃអង្វរព្រះជាម្ចាស់ឲ្យមរណបុគ្គល ព្រោះនៅថ្ងៃទាំងពីរនោះគ្រីស្តបរិស័ទជាច្រើនចង់បានការអនុគ្រោះ សម្រាប់អ្នកដែលលាចាកលោកនេះទៅហើយ ។

*១- ព្រះយេស៊ូមានព្រះបន្ទូលថា «ចូរប្រែចិត្តគំនិត» គឺព្រះអម្ចាស់យេស៊ូគ្រីស្តសព្វព្រះហឫទ័យឲ្យអ្នកជឿលើព្រះអង្គប្រែចិត្តគំនិតអស់មួយជីវិត ដោយមិនឈប់ឈរ ។*

*៤- យើងរងទារុណកម្មគ្រប់ពេលដែលយើងនៅតែស្អប់ខ្លួនឯង (នេះហើយជាការប្រែចិត្តដ៏ពិតប្រាកដ) គឺរហូតដល់ពេលចូលក្នុងព្រះរាជ្យនៃស្ថានបរមសុខ ។*

*៨- មាត្រាបញ្ជាឲ្យប្រែចិត្តគំនិតមានប្រយោជន៍សម្រាប់តែមនុស្សដែលនៅរស់ប៉ុណ្ណោះ ។ តាមមាត្រាទាំងនោះ មិនត្រូវបង្ខំដល់អ្នកហៀបនឹងស្លាប់ទេ ។*

*២៧- អ្នកខ្លះអះអាងថា ពេលណាស្គរប្រាក់កាក់ធ្លាក់ក្នុងហិបរបស់គេលាន់ឮឡើង ពេលនោះវិញ្ញាណក្ខន្ធបុគ្គលដែលស្លាប់ហោះចេញពីស្ថានភ្លើងសម្រាំងបាប ។ អ្នកទាំងនោះប្រកាសតែសេចក្ដីដែលមនុស្សប្រឌិតឡើងប៉ុណ្ណោះ ។*

*៥០- ត្រូវបង្រៀនគ្រីស្តបរិស័ទថា ប្រសិនបើអភិបាលព្រះសហគមន៍ក្រុងរ៉ូមដឹងអំពីការឆបោករបស់អ្នកប្រកាសអំពីការអនុគ្រោះនោះ លោកមុខជានឹងសុខចិត្តឲ្យវិសាលវិហារសន្តសិលាទៅជាផេះ ជាជាងដឹងថាគេកសាងវិហារនោះដោយសារស្បែក ដោយសារសាច់ និងដោយសារឆ្អឹងរបស់ហ្វូងចៀមរបស់លោក ។*

*៥១- កំណប់ថ្លៃថ្នូរដ៏ពិតប្រាកដរបស់ព្រះសហគមន៍ គឺគម្ពីរដំណឹងល្អដ៏វិសុទ្ធបំផុតដែលសម្ដែងសិរីរុងរឿង និងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ។*

ទេវវិទូខ្លះចោទប្រកាន់លោកលូធែរ ។ បព្វជិតក្រុមគ្រួសារលោកនិងទូតអភិបាលក្រុងរ៉ូមខិតខំអស់បីឆ្នាំ ដើម្បីឲ្យលោកលូធែរកែសេចក្តីដែលលោកប្រកាសនោះ ។ ក៏ប៉ុន្តែ អ្នកជាតិនិយមអាល្លឺម៉ង់ ដែលមានបំណងចង់រើបម្រះខ្លួនចេញពីការកៀបសង្កត់របស់អភិបាលក្រុងរ៉ូម នាំគ្នាលើកតម្កើងលោកលូធែរ ទុកជាជើងឯកទាមទារឯករាជ្យស្រុកគេ ។ សម័យនោះ អភិបាលក្រុងរ៉ូមទារពន្ធដារពីគេច្រើនពេក ហើយព្រះសហគមន៍តែងប្រមែប្រមូលទ្រព្យសម្បត្តិយ៉ាងសម្បូណ៌ហួសហេតុ ។ ហេតុនេះហើយ បានជាលោកលូធែរ បញ្ជាក់គំនិតរបស់លោកដោយសរសេរឯកសារថ្មីបី មានចំណងជើងថា៖ «*សេចក្តីអំពាវនាវដល់អភិជនគ្រីស្តបរិស័ទអាល្លឺម៉ង់*» «*ព្រះសហគមន៍ជាប់ជាឈ្លើយនៅបាប៊ីឡូន*» និង «*សេរីភាពរបស់គ្រីស្តបរិស័ទ*» ។ លោកសូមឲ្យអភិបាលក្រុងរ៉ូមត្រាស់ហៅមហាសន្និបាតមួយ
(91) ដើម្បីរិះគិតអំពីបញ្ហាទាំងនោះ ប៉ុន្តែលោកបញ្ជាក់ថា មហាសន្និបាតក៏អាចយល់ច្រឡំបានដែរ ។

នៅគ.ស. ១៥១៩ លោកមានប្រសាសន៍កាន់តែខ្លាំងឡើងៗ ប្រឆាំងនឹងអភិបាលក្រុងរ៉ូមថា «*ខ្ញុំដូចជាលែងសង្ស័យទៀតហើយ! អភិបាលក្រុងរ៉ូមពិតជាអ្នកប្រឆាំងនឹងព្រះគ្រីស្តមែន*» ។ នៅគ.ស. ១៥២០ អភិបាលក្រុងរ៉ូមបញ្ចេញក្រិត្យមួយប្រកាសថា ប្រធានបទ ៤១ របស់លោកលូធែរ ខុសនឹងជំនឿនៃព្រះសហគមន៍



*លោកលូធែរ
បកប្រែគម្ពីរ
ជាភាសាអាល្លឺមង់*

ហើយសូមឲ្យលោកចុះចូលនឹងអភិបាលក្នុងរយៈពេលពីរខែ ។ ថ្ងៃទី ១០ ធ្នូ គ.ស. ១៥២០ លោកលូធែរដុតក្រិត្យរបស់អភិបាលចោល ។ ខែមករា គ.ស. ១៥២១ គេបណ្តេញលោកលូធែរចេញពីព្រះសហគមន៍ ។ គេកោះហៅលោកឲ្យមកដោះសាខ្លួននៅចំពោះមុខសភាមេដឹកនាំចក្រភពអាល្លឺម៉ង់ និងនៅចំពោះព្រះភ័ក្ត្រព្រះចៅផ្ទាល់ ។ លោកលូធែរនៅតែកាន់ជាប់តាមគំនិតរបស់លោក ដោយសំអាងលើព្រះគម្ពីរ និងមនសិការរបស់ខ្លួន ។ នៅខែឧសភា ១៥២១ គេបណ្តេញលោកចេញពីចក្រភពអាល្លឺម៉ង់ ។ លោកលាក់ខ្លួនកុំឲ្យនគរបាលចាប់ ។ នៅពេលនោះ លោកបកប្រែព្រះគម្ពីរជាភាសាអាល្លឺម៉ង់ ។

## (91) លោកលូធែរនៅចំពោះមុខសភាមេដឹកនាំចក្រភពអាល្លឺម៉ង់ (១៨ មេសា គ.ស. ១៥២១)

ទោះបីគេគំរាមកំហែងលោក**លូធែរ**យ៉ាងណា រហូតដល់គំរាមសម្លាប់គាត់ក្តី ក៏លោកនៅតែជឿសង្ឃឹមលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ជានិច្ច ។

*ខ្ញុំមិនជឿអភិបាលក្រុងរ៉ូមទាំងនោះទេ ខ្ញុំក៏មិនជឿមហាសន្និបាតដែរ ព្រោះគេច្រឡំជាញឹកញាប់ ហើយថ្លែងសេចក្តីផ្ទុយគ្នា ។ ប្រសិនបើគ្មានភស្តុតាងចេញមកពីព្រះគម្ពីរ និងគ្មានមូលហេតុច្បាស់លាស់ទេ ខ្ញុំនៅតែជាប់ចំណងដោយអត្ថបទព្រះគម្ពីរដែលខ្ញុំយកមកនេះ ។ មនសិការរបស់ខ្ញុំក៏ជាប់ចំណងដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ ។ ខ្ញុំពុំអាច ហើយក៏ពុំចង់បដិសេធនូវសេចក្តីដែលខ្ញុំបានប្រកាសនេះ ព្រោះអ្នកនិយាយផ្ទុយនឹងមនសិការរបស់ខ្លួន មិនប្រាប់សេចក្តីពិតទេ ហើយក៏ប្រព្រឹត្តខុសនឹងសេចក្តីសុចរិតដែរ ។ សូមព្រះជាម្ចាស់ជួយខ្ញុំផង! ។*

Layout Histor.qxd 2/10/07 10:10 AM Page 166

## ៤- ចលាចល

អ្នកស្រុកអាល្លឺម៉ង់បែកបាក់គ្នា ខ្លះកាន់ជើងលោក**លូធែរ** ខ្លះប្រឆាំងនឹងលោក ។ អ្នកកាន់តាមលោកមានមូលហេតុផ្សេងៗពីគ្នា គឺពួកអភិជនចង់វាយដណ្ដើមយកស្រែចម្ការរបស់ព្រះសហគមន៍ រីឯកសិករយល់ឃើញថា មនុស្សទាំងអស់មានឋានៈស្មើគ្នានៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ គេលើកគ្នាប្រឆាំងនឹងពួកសក្ដិភូមិ ដែលជិះជាន់សង្កត់សង្កិនពួកគេ ។ ហេតុនេះ បានជាកើតសង្គ្រាមដ៏សាហាវ (១៥២៤-១៥២៥) ។ លោកលូធែរព្រួយបារម្ភព្រោះគូបដិបក្ខទាំងសងខាងអះអាងថា ខ្លួនប្រព្រឹត្តតាមព្រះបន្ទូលព្រះជាម្ចាស់គ្រប់ៗគ្នា ។ ដោយលោកឲ្យពួកកសិករនៅស្ងៀមមិនកើត លោកបែរជាសុខចិត្តឲ្យពួកអភិជនសម្លាប់អស់អ្នកបះបោរដោយគ្មានត្រាប្រណី ។

លោក**ថូម៉ាស-មីងស៊ែរ** (Thomas-Müntzer) ជាបូជាចារ្យដែលគាំទ្រកសិករក្រីក្រ លោកប្រឆាំងនឹងលោកលូធែរយ៉ាងខ្លាំង ។ លោកលូធែរក៏ដាច់ពីលោក**អេរ៉ាស្ម** ដែលមិនយល់ស្របនឹងគំនិតរបស់លោក អំពីសភាពខិលខូច និងអំពីសេរីភាពរបស់មនុស្ស ។ ទីបញ្ចប់ គឺគ.ស. ១៥២៥ លោកលូធែរបានរៀបអាពាហ៍ពិពាហ៍ជាមួយបព្វជិតាម្នាក់ ឈ្មោះ**កាតារិណា បូរ៉ា** (Catharina Bora) «*ដើម្បីចំអកអោយពួកមារ.. និងចំអកដាក់អស់ពួកមនុស្សលេលា ដែលហាមបូជាចារ្យរៀបការ*» ។

## ៥- លទ្ធិលោកលូធែរ

លោកលូធែរ គ្មានបំណងបង្កើតព្រះសហគមន៍ថ្មីទេ គឺលោកយល់ឃើញថា ព្រះសហគមន៍ត្រូវតែកែទម្រង់ខ្លួនឯង ដោយត្រឡប់ទៅកាន់តាមព្រះគម្ពីរដំណឹងល្អវិញ ។ ប៉ុន្តែ ដោយមានអ្នកបកស្រាយព្រះគម្ពីរតាមរបៀបផ្សេងៗពីគ្នា មានអ្នកខ្លះនិយមជ្រុល នាំឲ្យលោកលូធែរ បញ្ជាក់គោលលទ្ធិរបស់លោកឲ្យច្បាស់ និងបាត់បែងគ្រីស្តបរិស័ទឲ្យមានរបៀបរៀបរយ ។ នៅគ.ស. ១៥២៩ លោកបោះពុម្ពផ្សាយសៀវភៅពីរច្បាប់ទៀតគឺ «*សេចក្ដីសង្ខេបយ៉ាងខ្លីនៃលទ្ធិគ្រីស្តសាសនា*» និង «*សេចក្ដីបរិយាយយ៉ាងវែងនៃលទ្ធិគ្រីស្តសាសនា*» ។ លោកសំអាងលើបទពិសោធន៍ផ្ទាល់ គឺលោកយល់ឃើញថា មនុស្សខិលខូចទាំងស្រុង ប៉ុន្តែ ព្រះជាម្ចាស់សង្គ្រោះគេ គឺគេមានជំនឿ គឺគេផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្ត ។



*ព្រះវិហារសន្តសិលា*

Layout Histor.qxd 2/10/07 10:10 AM Page 167

ក្នុងកិច្ចសង្គ្រោះ ព្រះជាម្ចាស់ប្រព្រឹត្តកិច្ចការទាំងអស់ មនុស្សមិនអាចធ្វើអ្វីបានសោះឡើយ ។ អំពើល្អមិនអាចធ្វើឲ្យមនុស្សបានល្អទេ តែមនុស្សដែលព្រះជាម្ចាស់ប្រោសឲ្យសុចរិតវិញ អាចប្រព្រឹត្តអំពើល្អបាន ។ ហេតុនេះ ក្នុងសេចក្ដីទាំងប៉ុន្មានដែលព្រះសហគមន៍បញ្ជូនបន្តមក លោកលះបង់បោលសេចក្ដីទាំងអស់ដែលមិនមកពីព្រះគម្ពីរ ។ គាត់ក៏មិនព្រមទទួលស្គាល់ការគោរពសន្តបុគ្គល មិនទទួលស្គាល់បុណ្យកុសលដើម្បីអនុគ្រោះ មិនទទួលស្គាល់ពាក្យសច្ចាប្រណិធានរបស់បព្វជិត ។ តាមគំនិតលោក ក្នុងគម្ពីរគ្មានចែងអំពីអគ្គសញ្ញាទេ ។ លោកយល់ឃើញថា កិច្ចទាំងនោះសុទ្ធតែជាការខិតខំ និងការអួតអាងរបស់មនុស្សដែលចង់សង្គ្រោះខ្លួនឯង ដោយពឹងលើខ្លួនប៉ុណ្ណោះ ។ អ្វីៗដែលគ្មានបញ្ជាក់យ៉ាងច្បាស់ក្នុងព្រះគម្ពីរ ក៏គ្មានបានការទាល់តែសោះ ។ លោកទទួលស្គាល់ថា គ្រីស្តបរិស័ទទាំងអស់ជា «*ក្រុមបូជាចារ្យពូជស្ដេច*» តែគ្មានគ្រីស្តបរិស័ទទទួលមុខងារបម្រើជាបូជាចារ្យទេ ។ លោកយល់ឃើញថា ព្រះសហគមន៍ជាក្រុមអ្នកជឿដែលភ្នែកមនុស្សមើលមិនឃើញ មិនបាច់ចាត់ចែងក្រុមអ្នកជឿនោះទេ ហើយព្រះសហគមន៍ក៏មិនត្រូវកាន់កាប់ទ្រព្យសម្បត្តិទៀតដែរ ។

លោក**លូធែរ**ទទួលស្គាល់អគ្គសញ្ញាតែពីរប៉ុណ្ណោះ គឺអគ្គសញ្ញាជ្រមុជទឹកនិងអគ្គសញ្ញាអរព្រះគុណ ។ តែលោកទទួលស្គាល់ថា អ្នកជឿអាចលន់តួបាបបាន ។ លោកធ្វើពីធី «*លៀងព្រះអម្ចាស់*» ជាភាសាអាល្លឺម៉ង់ ។ លោកមិនទទួលស្គាល់ថាពិធីលៀងព្រះអម្ចាស់នេះជាសក្ការបូជារបស់ព្រះគ្រីស្តទេ តែលោកជឿជាក់ថាព្រះគ្រីស្តគង់នៅយ៉ាងពិតប្រាកដនៅក្នុងនំប៉័ង ។ លោកចង់ឲ្យគ្រីស្តបរិស័ទរួមគ្នាច្រៀងបទជាច្រើនសំឡេង ។ លោកចាត់ចែងគ្រីស្តបរិស័ទ ដើម្បីឲ្យស្រួលក្នុងការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងពេលធ្វើអគ្គសញ្ញាជូនគេ ។ តាមគំនិតលោក មេដឹកនាំប្រទេសនានាមានភារកិច្ចចាត់ចែងព្រះសហគមន៍ក្នុងស្រុករបស់អស់លោក ព្រោះអស់លោកទទួលអំណាចនេះពីព្រះជាម្ចាស់មក ។ លោកមិនព្រមទទួលស្គាល់អំណាចរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូមជាដាច់ខាត តែលោកពង្រឹងអំណាចមេដឹកនាំប្រទេសឲ្យត្រួតត្រាលើព្រះសហគមន៍តាមប្រទេស ។ តាមលោកលូធែរ ព្រះសហគមន៍ក្នុងប្រទេសមួយ ត្រឡប់ទៅជាព្រះសហគមន៍សម្រាប់តែប្រទេសនោះ ដែលចាត់ចែងតាមរបៀបផ្សេងពីគ្នា តាមរដ្ឋនីមួយៗ ។

## ៦- អ្នកកែទម្រង់ជាច្រើននាក់

បូជាចារ្យនិងបព្វជិតជាច្រើន នាំគ្នាកាន់តាមលោកលូធែរ តែមានអ្នកខ្លះខ្វែងគំនិតនឹងលោកដែរ ។ ក្នុងចំណោមអ្នកតាមលោកលូធែរ មានលោក**អ៊ូលរិជ ហ្វិងគ្លី** (Ulrich Zwingli គ.ស.១៤៨៤-១៥៣១) នៅស្រុកស្វីស្ស (Suisse) និងលោក**យ៉ូហាន កាល់វ៉ាំង** (Jean Calvin គ.ស. ១៥០៩-១៥៦៤) នៅប្រទេសបារាំង និងក្រុងសឺណែវ (Genève) ដែលមានឈ្មោះល្បីជាងគេ ។

លោកកាលវ៉ាំង រៀនខាងអក្សរសាស្ត្រនិងខាងច្បាប់ ។ នៅឆ្នាំ ១៥៣៦ លោកនិពន្ធសៀវភៅមួយមានចំណងជើងថា «*ការចាត់ចែងគ្រីស្តសាសនា*» បោះពុម្ពផ្សាយជាច្រើនលើកច្រើនសារ ។ ក្រោយមក លោកតាំងទីលំនៅនៅទីក្រុងសឺណែវ (*ប្រទេសស្វីស្វ*) ។ លោកចាត់ចែងព្រះសហគមន៍នៅក្រុងសឺណែវនោះទុកជាព្រះសហគមន៍គំរូ ដែលគេយកទៅអនុវត្តតាមនៅទ្វីបអឺរ៉ុប និងក្នុងពិភពលោកទាំងមូល ។

ត្រូវចាត់ចែងព្រះសហគមន៍នេះអោយមានរបៀបរៀបរយ ព្រោះលោកចាត់ទុកថា អនាធិបតេយ្យជាការមើលងាយព្រះជាម្ចាស់ ។ ក្នុងព្រះសហគមន៍មានមុខងារបម្រើបួនយ៉ាង គឺគ្រូគង្វាល គ្រូបង្រៀន ក្រុមចាស់ទុំ និងឧបដ្ឋាក ។ ក្នុងក្រុមចាត់ចែងព្រះសហគមន៍នីមួយៗ (Consistoire) មានគ្រូគង្វាលនិងចាស់ទុំ ១២ នាក់ ដែលរដ្ឋអំណាចជ្រើសរើស ។ ក្រុមនេះត្រួតកិច្ចការទាំងអស់ក្នុងព្រះសហគមន៍ រីឯរដ្ឋអំណាចមានមុខងារបង្ខំអោយអ្នកជឿអនុវត្តតាម ។

Layout Histor.qxd 2/10/07 10:10 AM Page 168

ដូច្នេះ លោកកាល់វ៉ាំងធ្វើអោយការកែទម្រង់របស់លោកលូថែរផ្សព្វផ្សាយជាទូទៅ និងមានការរឹងប៉ឹង ។ ព្រះសហគមន៍ជាច្រើន (ឬក្រុមជំនុំ) យកតម្រាប់តាមព្រះសហគមន៍ក្រុងសឺណែវនេះមកបាត់បែងខ្លួន ជាពិសេសព្រះសហគមន៍នៃក្រុមព្រឹទ្ធាចារ្យ (Presbytériens) ដែលមានក្រុមចាស់ទុំណែនាំ ។

ចំពោះទេវវិជ្ជា លោកយោងគោលគំនិតតាមលោកលូថែរ គឺព្រះគម្ពីរនិងជំនឿមានសារៈសំខាន់ជាទីបំផុត ។ ប៉ុន្តែ លោកគូសសង្កត់ទៅលើការថ្វាយបង្គំព្រះអម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតលើពិភពលោក ។ លោកយល់ឃើញថា ក្រោយពីលោកអដាំនិងនាងអេវ៉ាប្រព្រឹត្តអំពើបាប មនុស្សយើងខូចទាំងស្រុង ត្រូវតែធ្លាក់ស្ថាននរកគ្រប់គ្នាមិនខាន ។ ប៉ុន្តែ ព្រះជាម្ចាស់បានជ្រើសរើសមនុស្សខ្លះទុកជាមុនឲ្យទទួលការសង្គ្រោះ ។ ហេតុនេះហើយ បានជាលោកប្រៀនប្រដៅអំពីសីលធម៌ជារបៀបមនុស្សសុខចិត្តទទួលស្គាល់ព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ដែលទទួលមនុស្សទុកជាបុត្រធីតារបស់ព្រះអង្គ ។

## ៧- សហគមន៍តាមរដ្ឋផ្សេងៗ

**ក្នុងចក្រភពអាល្លឺម៉ង់** ស្ដេចត្រាញ់ឬមេដឹកនាំស្រុកនីមួយៗជ្រើសរើសនិកាយរបស់ខ្លួន គឺលោកខ្លះកាន់តាមកាតូលិក លោកខ្លះតាមលោកលូថែរ ឯប្រជាពលរដ្ឋទូទៅត្រូវកាន់តាមមេដឹកនាំ ឬត្រូវរត់បោលស្រុក តាមពាក្យស្លោកថា *«ស្រុកស្ដេចណា ត្រូវកាន់សាសនាស្ដេចនោះ»* ។ ព្រះបោសព្វព្រះហឫទ័យដកសិទ្ធិមេដឹកនាំមិនឲ្យជ្រើសរើសនិកាយសាសនាទេ តែមេដឹកនាំដែលកាន់តាមលោកលូថែរនាំគ្នាតវ៉ា ហើយទទួលឈ្មោះថា *«ប្រូតេស្តង់» (Protestants គឺអ្នកតវ៉ា)* ។ គ្រីស្តបរិស័ទក្រីក្រខ្លះសំអាងលើព្រះគម្ពីរ នាំគ្នាបះបោរទាមទាយុត្តិធម៌ ។

**នៅប្រទេសអង់គ្លេស** ព្រះមហាក្សត្រព្រះនាម**ហង់រី ទី ៨** (Henri VIII) ចង់លែងលះភរិយាដែលបង្កើតតែកូនស្រីម្នាក់ប៉ុណ្ណោះ ។ តែអភិបាលក្រុងរ៉ូមមិនយល់ព្រមទេ ។ ហេតុនេះហើយ ស្ដេចប្រកាសខ្លួនឯងថា ជាមេដឹកនាំព្រះសហគមន៍នៅស្រុកអង់គ្លេស ។ អស់លោកដែលជំទាស់នឹងស្ដេច ត្រូវទ្រង់សម្លាប់ មានលោក**ថូម៉ាស ម៉ូរ** (Thomas More) និងអភិបាល**ហ្វីសែរ** (Fischer) ជាដើម ។ ស្ដេចស្នងរាជ្យបោះពុម្ពសៀវភៅ “Book of Common Prayer” *(សៀវភៅធម៌រួម)* និង *៣៩ ប្រធានបទ* ដែលយោងគោលៗតាមលោកកាល់វ៉ាំង ។ សៀវភៅទាំងពីរនោះត្រឡប់ជាគ្រឹះនៃសាសនាអង់គ្លីកង់ ។ តែប្រជាជននៅកោះអៀរឡង់ដ៍ (Irlande) មិនព្រមតាមគេទេ ហើយកាន់តាមកាតូលិកយ៉ាងដាច់អហង្ការ ។ 92

**ប្រទេសបារាំង** រដ្ឋអំណាចដេញតាមគ្រីស្តបរិស័ទប្រូតេស្តង់ ធ្វើបាបគេនិងសម្លាប់គេជាច្រើនអនេកដោយចោទគេថា ពួកគេបំបែករាជអំណាចនិងឯកភាពនៅក្នុងសង្គម ។ គ្រីស្តបរិស័ទប្រូតេស្តង់នាំគ្នាបះបោរ ហើយកើតសង្គ្រាមសាសនាអស់ជាងសាមសិបឆ្នាំ (រហូតដល់ គ.ស. ១៥៩៨) ។ កងទ័ពព្រះមហាក្សត្រសម្លាប់គ្រីស្តបរិស័ទប្រូតេស្តង់រាប់ពាន់នាក់ ។ នៅសតវត្សក្រោយ ព្រះមហាក្សត្របារាំងធ្វើបាបគ្រីស្តបរិស័ទប្រូតេស្តង់ម្ដងទៀត បង្ខំពួកគេឲ្យកាន់តាមព្រះសហគមន៍កាតូលិក ដាក់ទាហានម្នាក់ឲ្យនៅយាមក្នុងផ្ទះប្រូតេស្តង់នីមួយៗ ។ល។ មានប្រូតេស្តង់ប្រហែល ២00 000 នាក់ ភៀសខ្លួនទៅប្រទេសក្រៅ ។ ព្រឹត្តិការណ៍ទាំងនោះបណ្ដាលឲ្យគ្រីស្តបរិស័ទប្រូតេស្តង់ នាំគ្នាស្អប់គ្រីស្តបរិស័ទកាតូលិករហូតដល់សព្វថ្ងៃ ។

**ព្រះមហាក្សត្រអេស្ប៉ាញ** កាន់កាប់តំបន់ខាងជើងទ្វីបអឺរ៉ុប នៅគ.ស. ១៥៥៥ ហើយសម្លាប់គ្រីស្តបរិស័ទកាន់តាមលោកកាល់វ៉ាំង ដែលរស់នៅក្នុងស្រុកនោះ ។ តែនៅគ.ស. ១៥៨0 គ្រីស្តបរិស័ទប្រូតេស្តង់បម្រះខ្លួនចេញពីអំណាចរបស់ជនជាតិអេស្ប៉ាញ ហើយបង្កើតស្រុកហូឡង់ (Hollande) រីឯគ្រីស្តបរិស័ទកាតូលិកបង្កើតប្រទេសបែលស៊ិក (Belgique) វិញ ។ ព្រឹត្តិការណ៍នោះមានឥទ្ធិពលដល់ប្រវត្តិសាស្ត្រព្រះសហគមន៍នៅប្រទេសកម្ពុជាយើង ។

# 92 លោកថូម៉ាស–ម៉ូរ ទទួលទារុណកម្មរហូតដល់ស្លាប់

ទោះបីមិត្តសំឡាញ់ទទួចអង្វរ ក៏លោក**ថូម៉ាស-ម៉ូរ**មិនព្រមទទួលស្គាល់ព្រះបាទ**ហង់រីទី ៨** ទុកជាមេដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះសហគមន៍នៅប្រទេសអង់គ្លេសដែរ ។ គេធ្វើទារុណកម្មលោកនៅថ្ងៃ ៦ កក្កដា ១៥៣៥ ។

*ថ្ងៃនោះ លោកថូម៉ាស-ម៉ូរ ស្លៀកពាក់ល្អប្រណិតជាងគេហាក់បីដូចជាលោកទៅចូលរួមក្នុងពិធីបុណ្យដ៏ឱឡារិកមួយ ។ នាយទាហានឃើញដូច្នេះ ក៏ទូន្មានលោកឲ្យផ្លាស់សម្លៀកបំពាក់ចេញដោយប្រាប់ថា ក្រោយពេលដែលលោកទទួលមរណភាព គឺមនុស្សជោកទាបទេដែលនឹងទទួលសម្លៀកបំពាក់ទាំងនោះ ។*

*លោកថូម៉ាសថា៖ «ម្ដេចក៏លោកនាយទាហាននិយាយដូច្នេះ! តើខ្ញុំត្រូវរាប់អ្នកដែលជួយបម្រើខ្ញុំយ៉ាងអស្ចារ្យនៅថ្ងៃនេះទុកជាមនុស្សជោកទាបឬ? ប្រសិនបើសម្លៀកបំពាក់នេះធ្វើអំពីមាស ក៏ខ្ញុំនៅតែជឿថា គួរឲ្យគាត់មែន ដូចសន្ត**ស៊ីព្រីយ៉ាំង**បែកកាក់មាសដល់អ្នកធ្វើឃាតលោក» ។*

*ដោយនាយទាហានទទូចសុំខ្លាំងពេក លោកក៏សុខចិត្តផ្លាស់សម្លៀកបំពាក់ តែលោកយកតម្រាប់តាមសន្តស៊ីព្រីយ៉ាំង គឺលោកយកមាសដ៏តិចតួចដែលលោកនៅសល់ និងយករូបទេវទូតតូចមួយធ្វើពីមាស ផ្ញើទៅពេជ្ឈឃាតដែលធ្វើឃាតលោក ។*

*នាយទាហាននាំលោកទៅខាងក្រៅប៉ម រួចទៅកន្លែងធ្វើឃាត ។ លោកត្រូវឡើងលើវេទិកាជាកន្លែងកាត់កលោក តែវេទិកានោះញ័រជិតរលំ ។ លោកប្រាប់នាយទាហានទាំងសើចថា៖ «សូមលោកជួយយកខ្ញុំឡើង ។ ឯពេលចុះទៅក្រោមវិញនោះ ខ្ញុំនឹងចុះដោយខ្លួនឯងបាន» ។*

*ពេលនោះ លោកថូម៉ាសសូមបណ្ដាជនអង្វរព្រះជាម្ចាស់សម្រាប់គាត់ និងឲ្យគេផ្ដល់សក្ខីភាពថា លោកនឹងរងទុក្ខ ហើយទទួលមរណភាពនេះ ព្រោះតែជំនឿនៃព្រះសហគមន៍កាតូលិកដែលលោកនៅតែកាន់រហូត ។ ពេលលោកលុតជង្គង់អធិដ្ឋានរួចហើយ លោកបែរទៅពេជ្ឈឃាតដោយទឹកមុខរីករាយ និងមានប្រសាសន៍ថា៖ «ក្លាហានឡើង! កុំខ្លាចនឹងបំពេញមុខងាររបស់អ្នក! តែសូមប្រយ័ត្ន ខ្ញុំមានកខ្លីណាស់ បើកាត់ខុសក្រែងខ្មាសគេ» ។*

*លោកថូម៉ាស-ម៉ូរឆ្លងពីលោកនេះ ទៅកាន់ព្រះជាម្ចាស់ដូច្នេះឯង ។*

*ជីវិតលោកថូម៉ាស-ម៉ូរ*



*លោកថូម៉ាស-ម៉ូរ*



Layout Histor.qxd 2/10/07 10:10 AM Page 171



# ព្រះសហគមន៍កាតូលិកកែទម្រង់ខ្លួនឯង

## សតវត្សទី ១៦-១៧

*ក្នុងព្រះសហគមន៍នានាដែលនៅភ្ជាប់ទៅនឹងព្រះសហគមន៍ក្រុងរ៉ូម មានគ្រីស្តបរិស័ទជាច្រើនមានបំណងចង់កែទម្រង់ព្រះសហគមន៍របស់ខ្លួន ដោយបង្កើតក្រុមគ្រួសារបព្វជិតជាដើម ។ អស់លោកអភិបាលជួបជុំគ្នាជាមហាសន្និបាតនៅត្រែនតូ គ.ស. ១៥៤៥-១៥៦៣ ។ មហាសន្និបាតនេះ បញ្ជាក់ជំនឿ និងវិន័យព្រះសហគមន៍យ៉ាងតឹងរ៉ឹង ហើយមានឥទ្ធិពលយ៉ាងខ្លាំងលើព្រះសហគមន៍នានារហូតមកដល់សព្វថ្ងៃ ។*

### ១- មហាសន្និបាតនៅក្រុងត្រែនតូ (១៥៤៥-១៥៦៣)

ពេលគេកោះហៅលោក**លូធែរ**មកកាត់ទោស នៅចំពោះព្រះភ័ក្ត្រព្រះចៅ ទូតអភិបាលក្រុងរ៉ូមរាយការណ៍ថា៖ *ប្រជាជននាំគ្នាស្រែកថា «សូមកោះហៅមហាសន្និបាតទៅ! កោះហៅមហាសន្និបាតទៅ!»* ។ ប៉ុន្តែ អភិបាលក្រុងរ៉ូមមិនយល់ព្រមកោះហៅមហាសន្និបាតភ្លាមៗទេ ។ ម្យ៉ាងទៀត ទ្វីបអឺរ៉ុបកើតសង្គ្រាមញឹកញាប់ ដែលបណ្តាលឲ្យអស់លោកអភិបាលពិបាកប្រជុំគ្នា ។ លោក**ប៉ូល ទី ៣** (គ.ស. ១៥៣៤-១៥៤៩) សម្រេចកោះហៅមហាសន្និបាតនៅត្រែនតូ (Trento) ថ្ងៃទី ១៣ ធ្នូ ឆ្នាំ ១៥៤៥ ។ ព្រះចៅអធិរាជបង្ខំអភិបាលក្រុងរ៉ូមឲ្យជ្រើសរើសក្រុងនោះ ដែលនៅខាងជើងស្រុកអ៊ីតាលី (តែអ្នកស្រុកនិយាយភាសាអាល្លឺម៉ង់) ដោយសង្ឃឹមថា អភិបាលព្រះសហគមន៍ជាតិអាល្លឺម៉ង់ជាច្រើនចូលរួមដែរ ។ មុនដំបូងមានអភិបាលតែ ៣៤ នាក់ប៉ុណ្ណោះមកប្រជុំគ្នា (សម័យនោះមានអភិបាលតែ ៥០០ នាក់ ក្នុងសកលលោកទាំងមូល) ។ យូរៗទៅមានអភិបាល ២៣៧ នាក់ចូលរួម ។ ក្នុងចំណោមអស់លោក ពីរភាគបីជាអភិបាលជាតិអ៊ីតាលី គឺអភិបាលតំបន់ខាងត្បូងទ្វីបអឺរ៉ុប មានបំណងចង់ដោះស្រាយបញ្ហាព្រះសហគមន៍តំបន់ខាងជើង មានតំណាងប្រូតេស្តង់ខ្លះចូលរួមដែរ ។ មហាសន្និបាតត្រូវផ្អាកបីដង ។ ពេលផ្អាកម្តងៗមានរយៈពេលយូរឆ្នាំ លោកប៉ូលទី ៤ (Paul IV ១៥៥៥-១៥៥៩) ជាអភិបាលក្រុងរ៉ូម ចង់កែទម្រង់ព្រះសហគមន៍ដោយខ្លួនលោក ដោយប្រើមធ្យោបាយពីបុរាណ គឺលោកពង្រឹងការស្វែងរកអ្នកវង្វេងជំនឿ បញ្ជូនឲ្យគេធ្វើទារុណកម្ម ដុតសៀវភៅដែលលោកយល់ថា នាំឲ្យឃ្លាតចាកពីគ្រីស្តសាសនាចោល (*ចំណងជើងសៀវភៅទាំងនោះត្រូវកត់ទុកចូលក្នុងបញ្ជីស្បែកខ្មៅ Index*) ហាមប្រែគម្ពីរជាភាសាប្រជាជនជាដាច់ខាត ។ល។ លោក**ពីយ៉ូទី ៤** (Pio IV) បង្ហើយមហាសន្និបាតនៅគ.ស. ១៥៦៣ ។

មហាសន្និបាតត្រែនតូ បញ្ជាក់សេចក្តីជាច្រើនខាងលទ្ធិគ្រីស្តសាសនា គឺអំពីសេចក្តីដែលព្រះសហគមន៍មិនបានបញ្ជាក់កាលពីមុនៗ មានបញ្ជីក័ណ្ឌគម្ពីរ ចំនួនអគ្គសញ្ញា អំពីព្រះជាម្ចាស់ប្រោសមនុស្សឲ្យបានសុចរិត និងអំពីព្រះជាម្ចាស់និងមនុស្សរួមសហការគ្នាក្នុងកិច្ចសង្គ្រោះជាដើម ។ អស់លោករិះគិតយ៉ាងជ្រៅអំពី

*មហាសន្និបាត*
*នៅត្រែនតូ (១៥៤៥-១៥៦៣)*

ទេវវិជ្ជា ហើយមានបំណងកែទម្រង់ព្រះសហគមន៍គ្រប់វិស័យដែរ ។ ប៉ុន្តែ អស់លោកគិតអំពីប្រឆាំងនឹងគ្រីស្តបរិស័ទប្រូតេស្តង់ខ្លាំងពេក ជួនកាលគ្មានមូលហេតុពិតប្រាកដ ។ ឧ. មហាសន្និបាតមិនអនុញ្ញាតឲ្យគ្រីស្តបរិស័ទធ្វើពិធីបុណ្យជារៀងរាល់ថ្ងៃតាមភាសារបស់ខ្លួន ព្រោះបងប្អូនប្រូតេស្តង់ធ្លាប់ធ្វើពិធីតាមភាសាប្រជាជននោះ ។ មហាសន្និបាតបង្កើតទេវវិជ្ជាតឹងរ៉ឹងបន្តិច ដោយយោងតាមប្រពៃណីព្រះសហគមន៍ ជាជាងសំអាងលើព្រះគម្ពីរ ។ អស់លោកសម្រេចបង្កើតទេវវិទ្យាល័យ ជាកិច្ចសម្រេចដែលមានសារៈសំខាន់នៅពេលអនាគតរហូតដល់សព្វថ្ងៃ ។

អស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតត្រេនតូនេះ ទុកឲ្យអភិបាលក្រុងរ៉ូមបញ្ជាឲ្យគ្រីស្តបរិស័ទអនុវត្តតាមសេចក្តីសម្រេចទាំងនោះ ។ អភិបាលក្រុងរ៉ូម **ពីយ៉ូ ទី ៥** (Pio V គ.ស. ១៥៦៦-១៥៧២) បានបោះពុម្ពផ្សាយ «*សេចក្តីសង្ខេបនៃលទ្ធិគ្រីស្តសាសនានៃព្រះសហគមន៍ក្រុងរ៉ូម*» «*ធម៌តាមពេលកំណត់*» និង «*សៀវភៅអភិបូជា*» ។ លោកសូមឲ្យគ្រប់ព្រះសហគមន៍ថ្វាយអភិបូជាតាមរបៀបតែមួយដូចគ្នានៅគ្រប់ទីកន្លែង ។ លោក**គ្រេគ័រ ទី ១៣** (គ.ស. ១៥៧២-១៥៩៣) កែសម្រួលប្រតិទិន បង្កើតទេវវិទ្យាល័យជាច្រើន បង្កើតមហាវិទ្យាល័យមួយនៅក្រុងរ៉ូម និងតែងតាំងអគ្គរាជទូតជាតំណាងរបស់លោក ឲ្យមានទំនាក់ទំនងជាមួយស្តេចនានា ។ លោក**ស៊ីស្ទ ទី ៥** (Sixte Quint ១៥៨៥-១៥៩0) ចាត់ចែងក្រសួង ១៥ នៅក្រុងរ៉ូម សម្រាប់ជួយលោកក្នុងការណែនាំព្រះសហគមន៍ទូទៅ លោកក៏តែងតាំងទីប្រឹក្សា ៧0 នាក់ ដែលមានមុខងារណែនាំក្រសួងទាំងនោះ ។ លោក**ប៉ូល ទី ៥** (គ.ស. ១៦0៥-១៦២១) បានបោះពុម្ពផ្សាយ «*ក្បួនពិធីបុណ្យនៅក្រុងរ៉ូម*» ។ ដោយសារព្រះមហាក្សត្រប្រទេសជាច្រើន មិនសូវយល់ព្រមផ្សព្វផ្សាយសេចក្តីសម្រេចរបស់មហាសន្និបាត ទើបអស់លោកអភិបាលយកចិត្តទុកដាក់ផ្សាយជំនួសវិញ ។

មហាសន្និបាតត្រេនតូ តែងតាំងព្រះសហគមន៍ឲ្យមានរចនាសម្ពន្ធមាំមួន (93)
ដោយមានអភិបាលក្រុងរ៉ូមណែនាំដូចជាព្រះចៅមួយព្រះអង្គ ។ ព្រះសហគមន៍សំអាងលើច្បាប់ លើទេវវិជ្ជារបស់សន្តថូម៉ាសនៅអគីណូ (Scolastique) ជាជាងសំអាងលើព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ព្រះសហគមន៍ចាប់អារម្មណ៍យ៉ាងខ្លាំងនឹងឯកភាព បណ្តេញគ្រីស្តបរិស័ទដែលមានជំនឿប្លែកពីជំនឿទូទៅចេញពីព្រះសហគមន៍ តែព្រះសហគមន៍មិនសូវចាប់អារម្មណ៍នឹងសភាពការណ៍មនុស្សលោក ជាពិសេសមិនចាប់អារម្មណ៍នឹងការវិវឌ្ឍន៍ខាងសេដ្ឋកិច្ច និងខាងសង្គមដែលចម្រើនយ៉ាងខ្លាំងនៅសម័យនោះ ។

## (93) សេចក្តីសម្រេច និងសេចក្តីបញ្ជាក់នៃមហាសន្និបាតត្រេនតូ

អស់លោកអភិបាលដែលបានជួបជុំគ្នាជាមហាសន្និបាតត្រេនតូ ធ្លាប់សរសេរសេចក្តីអត្ថាធិប្បាយអំពីគោលជំហរនៃលទ្ធិគ្រីស្តសាសនានីមួយៗតាមលំដាប់លំដោយ រួចអស់លោកចែងពាក្យដាក់ទោសអ្នកមានយោបល់ផ្ទុយពីគោលជំហរទាំងនេះ ។ តាមធម្មតាយោបល់ផ្ទុយនោះជាពាក្យប្រកាសរបស់គ្រីស្តបរិស័ទប្រូតេស្តង់ ។

### អំពីព្រះគម្ពីរ និងការបញ្ជូនបន្តជំនឿ

*មហាសន្និបាតទទួលកណ្ឌទាំងប៉ុន្មាននៃសម្ពន្ធមេត្រីចាស់ និងសម្ពន្ធមេត្រីថ្មីដូចគ្នា ដោយគោរពតាមអស់លោកអភិបាលអ័រតូដុកដែរ ពីព្រោះថា ព្រះជាម្ចាស់តែមួយព្រះអង្គនិពន្ធគម្ពីរសម្ពន្ធមេត្រីទាំងពីរនោះ ។ មហាសន្និបាតក៏ទទួលទំនៀមទម្លាប់ផ្សេងៗអំពីជំនឿ និងសីលធម៌ដែលព្រះសហគមន៍បញ្ជូនបន្តមកទុកដូចជាហូរចេញមកពីព្រះឱស្ឋព្រះគ្រីស្តផ្ទាល់ ឬទុកជាព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូល ហើយព្រះសហគមន៍កាតូលិកបានរក្សាទុកដោយមានអភិបាលបន្តមុខតំណែងរហូតមកឥតដាច់ ។*

*(អង្គប្រជុំទី ៤ ថ្ងៃទី ៨ មេសា ១៥៤៦ ៦១ សំឡេងឆ្នោត)*

• • •

Layout Histor.qxd 2/10/07 10:10 AM Page 173

## អំពីព្រះជាម្ចាស់ប្រោសឱ្យមនុស្សបានសុចរិត

ប្រសិនបើមាននរណាម្នាក់អះអាងថា មនុស្សអាចទៅជាមនុស្សសុចរិតនៅចំពោះព្រះជាម្ចាស់បាន ដោយសារកុសលផលបុណ្យរបស់ខ្លួន មិនបាច់ព្រះជាម្ចាស់ប្រណីសន្ដោសតាមព្រះយេស៊ូគ្រីស្ដទេ សូមបណ្ដេញអ្នកនោះចេញពីព្រះសហគមន៍ទៅ ។

ប្រសិនបើនរណាម្នាក់និយាយថា នៅពេលព្រះជាម្ចាស់ទាក់ទាញចិត្ដមនុស្សម្នាក់ ឬជំរុញគេ ពេលនោះ គេគ្មានសេរីភាពទេ គឺត្រូវតែសហការជាមួយព្រះអង្គពុំខាន ពីព្រោះព្រះជាម្ចាស់ជំរុញ ឬត្រាស់ហៅគេឲ្យរៀបចំខ្លួនទៅជាសុចរិតតាមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ គឺគេត្រូវតែសហការជាមួយព្រះអង្គ មិនអាចបដិសេធព្រះអង្គបានទេ គឺគេដូចជាវត្ថុគ្មានវិញ្ញាណមិនអាចធ្វើអ្វីបានសោះ សូមបណ្ដេញអ្នកនោះចេញពីព្រះសហគមន៍ ។

*(អង្គប្រជុំទី ៦ ថ្ងៃទី ១៣ មករា ១៥៤៧ ៧០ សំឡេងឆ្នោត)*

## អំពីអគ្គសញ្ញា

ប្រសិនបើនរណាម្នាក់និយាយថា ព្រះយេស៊ូគ្រីស្ដមិនបានបង្កើតអគ្គសញ្ញាទាំងប៉ុន្មាននៃធម្មវិន័យថ្មី ឬថា ចំនួនអគ្គសញ្ញាមានលើសឬតិចជាង ៧ ឬថា អគ្គសញ្ញាក្នុងចំណោមអគ្គសញ្ញាទាំង ៧ នោះមិនមែនជាអគ្គសញ្ញាយ៉ាងពិតប្រាកដ សូមបណ្ដេញអ្នកនោះចេញពីព្រះសហគមន៍ទៅ ។

*(អង្គប្រជុំទី ៧ ថ្ងៃទី ៣ មីនា ១៥៤៧ ៧២ សំឡេងឆ្នោត)*

## អំពីអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធ

ប្រសិនបើនរណាម្នាក់មិនទទួលស្គាល់ថា ក្នុងអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធបំផុត ព្រះកាយនិងព្រះលោហិតរួមជាមួយព្រះវិញ្ញាណ និងសភាពជាព្រះជាម្ចាស់របស់ព្រះយេស៊ូគ្រីស្ដ ជាព្រះអម្ចាស់មិនស្ថិតនៅយ៉ាងពិតប្រាកដក្នុងនំប៉័ងនិងស្រា គឺនំប៉័ងនិងស្រាគ្រាន់តែជាសញ្ញាសម្គាល់អំពីព្រះកាយនិងព្រះលោហិតព្រះគ្រីស្ដ ឬគ្រាន់តែជានិមិត្ដរូប ឬគ្រាន់តែបង្ហាញឫទ្ធានុភាពប៉ុណ្ណោះ សូមបណ្ដេញអ្នកនោះចេញពីព្រះសហគមន៍ទៅ ។

*(អង្គប្រជុំទី ១៣ ថ្ងៃទី ១១ តុលា ១៥៥១ ៥៤ សំឡេងឆ្នោត)*

## អំពីអភិបូជា

ប្រសិនបើនរណាម្នាក់និយាយថា ត្រូវប្រឆាំងនឹងរបៀបថ្វាយអភិបូជាតាមព្រះសហគមន៍ក្រុងរ៉ូម គឺបូជាចារ្យសូត្រធម៌អរព្រះគុណមួយផ្នែក និងសូត្រធម៌ប្រសិទ្ធិព្រះកាយតាមសំឡេងខ្សាវៗ សូមបណ្ដេញអ្នកនោះចេញពីព្រះសហគមន៍ទៅ ។ បើនរណាម្នាក់និយាយថា ត្រូវថ្វាយអភិបូជាតែតាមភាសាប្រជាជនប៉ុណ្ណោះ សូមបណ្ដេញអ្នកនោះចេញពីព្រះសហគមន៍ទៅ ។

*(អង្គប្រជុំទី ២២ ថ្ងៃទី ១៧ កញ្ញា ១៥៦២ ១៨៣ សំឡេងឆ្នោត)*

## អំពីបូជាចារ្យ

ប្រសិនបើនរណាម្នាក់និយាយថា ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មីគ្មានចែងអំពីមុខងារជាបូជាចារ្យទេ ឬថាគ្មាននរណាម្នាក់មានអំណាចប្រសិទ្ធិព្រះកាយ ថ្វាយព្រះកាយនិងព្រះលោហិតដ៏ពិតប្រាកដរបស់ព្រះអម្ចាស់ បូជាចារ្យក៏គ្មានអំណាចលើកលែងទោសឲ្យរួចពីបាប ឬប្រកាន់ទោសដែរ គឺគ្រាន់តែមានមុខងារឬនាទីបម្រើធម្មតានៅពេលពន្យល់ដំណឹងល្អប៉ុណ្ណោះ ឬថាអស់បូជាចារ្យណាដែលមិនទេសនា មិនមែនជាបូជាចារ្យទៀតទេ សូមបណ្ដេញអ្នកនោះចេញពីព្រះសហគមន៍ទៅ ។

*(អង្គប្រជុំទី ២៣ ថ្ងៃទី ១៥ កក្កដា ១៥៦៣ ២៣៧ សំឡេងឆ្នោត)*

## អំពីកំណើតទេវវិទ្យាល័យ

យុវជនមិនទទួលការអប់រំត្រឹមត្រូវ តែងតែបណ្ដោយខ្លួនយ៉ាងស្រួលទៅតាមការស្រើបស្រាលរបស់លោកិយ ។ ហេតុនេះ បើយុវជនមិនទទួលការអប់រំឲ្យគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងកាន់សាសនាតាំងពីតូចមក គឺនៅវ័យដែលទម្លាប់អាក្រក់តាមតណ្ហាមិនទាន់កាន់កាប់មនុស្សទាំងមូលទេ នោះគេមិនអាចកាន់តាមវិន័យរបស់ព្រះសហគមន៍តទៅទៀតយ៉ាងពេញលេញបានសោះ លើកលែងតែព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការការពារគេយ៉ាងខ្លាំង និងយ៉ាងពិសេសនោះ ។ ហេតុនេះ មហាសន្និបាតដ៏វិសុទ្ធ បញ្ជាឲ្យគ្រប់វិសាលវិហារនិងវិហារដែលប្រសើរជាងវិសាលវិហារទៅទៀត មានភារកិច្ចចិញ្ចឹមនិងអប់រំក្មេងមួយចំនួន ឲ្យគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងអប់រំគេតាមវិន័យព្រះសហគមន៍នៅក្រុង ឬនៅក្នុងភូមិភាគ ឬប្រសិនបើចំនួនគេមិនគ្រប់គ្រាន់ ឲ្យក្មេងក្នុងតំបន់មួយចូលរួមក្នុងវិទ្យាល័យដែលលោកអភិបាលនឹងជ្រើសរើសនៅជិតព្រះវិហារទាំងនោះ ឬនៅកន្លែងផ្សេងទៀតដ៏សមគួរ ។

*(អង្គប្រជុំទី ២៣ ថ្ងៃទី ១៥ កក្កដា ១៥៦៣ ២៣៧ សំឡេងឆ្នោត)*

## អំពីអាពាហ៍ពិពាហ៍

អស់គ្រីស្ដបរិស័ទដែលរៀបអាពាហ៍ពិពាហ៍ ដោយគ្មានបូជាចារ្យថែរក្សាព្រះសហគមន៍ក្នុងភូមិធ្វើជាសាក្សី ឬបូជាចារ្យដែលទទួលច្បាប់អនុញ្ញាតពីបូជាចារ្យក្នុងភូមិ ឬពីអភិបាលធ្វើជាសាក្សី ឬនៅមុខសាក្សីពីរឬបីនាក់ទៀត មហាសន្និបាតដ៏វិសុទ្ធប្រកាសថា គេមិនអាចរៀបអាពាហ៍ពិពាហ៍ដូច្នេះបានសោះ ហើយប្រកាសថា ការព្រមព្រៀងរបស់គេគ្មានតម្លៃ ហើយមិនបានការតាមច្បាប់ ។

*(អង្គប្រជុំទី ២៤ ថ្ងៃ ១១ កញ្ញា ១៥៦៣ ២៣១ សំឡេងឆ្នោត)*

Layout Histor.qxd 2/10/07 10:10 AM Page 174

## ២- គ្រីស្តបរិស័ទកែទម្រង់ព្រះសហគមន៍ពីខាងក្នុង

### ***លោកអ៊ីញ៉ាស នៅ ឡូយ៉ូឡា***



(*Ignace de Loyola គ.ស. ១៤៩១-១៥៥៦*)

94 មុនពេលមហាសន្និបាតត្រេនតូ មាន
95 បូជាចារ្យជាច្រើនតែងតាំងក្រុមគ្រួសារជា
បូជាចារ្យ និងជាបព្វជិត ។ ក្នុងចំណោម លោកទាំងនោះ មានលោក**អ៊ីញ៉ាស នៅ ឡូយ៉ូឡា**ជាជនជាតិអេស្ប៉ាញម្នាក់ ។ លោកជាទាហានត្រូវរបួសនៅលើសមរភូមិ ហើយប្រែចិត្តជឿលើព្រះយេស៊ូ ។ លោករៀបរាប់បទពិសោធន៍ក្នុងសៀវភៅមួយ មានចំណងជើងថា «*ការហ្វឹកហ្វឺនខាងវិញ្ញាណ*» ។ គ.ស. ១៥៤០ លោកបង្កើតក្រុមគ្រួសារ «*សហជីវិនព្រះយេស៊ូ*» ។ អស់លោកដែលចូលក្នុងសមាគមនេះ ប្រកាសពាក្យសច្ចាប្រណិធានដូចបព្វជិតឯទៀតៗ (*រស់នៅជាព្រហ្មចារី ជាអ្នកក្រីក្រ ស្ដាប់តាមបង្គាប់*) ហើយក៏ប្រកាសពាក្យសច្ចាប្រណិធានមួយទៀត គឺស្ដាប់បង្គាប់អភិបាលក្រុងរ៉ូមជានិច្ច ។ អស់លោកយកចិត្តទុកដាក់បង្រៀនយុវជន ណែនាំមនុស្សជាច្រើនខាងវិញ្ញាណ និងទៅប្រកាសដំណឹងល្អនៅស្រុកឆ្ងាយៗ ។ នៅគ.ស. ១៦៥០ មានសមាជិកក្រុមសហជីវិនព្រះយេស៊ូ ១៥.000 នាក់ ។

### ***សន្តីតេរ៉េសា នៅ អាវីឡា*** (*Thérèse d'Avila គ.ស. ១៥១៥-១៥៨២*)



នាង**តេរ៉េសា** កើតនៅក្រុងអាវីឡា 96
ប្រទេសអេស្ប៉ាញ ។ កាលអាយុ ១៨ ឆ្នាំ នាងបួសនៅអារាមការមែល នៅទីក្រុងអាវីឡា ។ ម្ភៃប្រាំពីរឆ្នាំក្រោយមក នាងស្ម័គ្រចិត្ត «*ឬរងទុក្ខ ឬក៏ស្លាប់*» ថ្វាយព្រះយេស៊ូ ។ គាត់បានកែទម្រង់វិន័យក្រុមគ្រួសារការមែល ឲ្យស្របតាមក្បួនដើម ហើយបង្កើតអារាមជាច្រើនផង ។ សន្តី**តេរ៉េសា**និពន្ធសៀវភៅមួយតំណាលអំពីដំណើរជីវិតថ្វាយខ្លួនទៅព្រះជាម្ចាស់ ជាពិសេសអប់រំអំពីការអធិដ្ឋាន ។

94

### ការហ្វឹកហ្វឺនតាមវិញ្ញាណ

*ពាក្យ «ការហ្វឹកហ្វឺនតាមវិញ្ញាណ» សំដៅលើគ្រប់របៀបពិនិត្យមើលមនសិការរបស់ខ្លួន របៀបសញ្ជឹងគិត ស្មឹងស្មាធិ៍ អធិដ្ឋាន សូត្រធម៌ និងគ្រប់កិច្ចខាងវិញ្ញាណ ។ ការដើរលេង ការហាត់ធ្វើដំណើរយ៉ាងឆ្ងាយ ការហាត់រត់ប្រណាំង សុទ្ធតែជាការហ្វឹកហ្វឺនរូបកាយយ៉ាងណា ក៏គ្រប់របៀបរៀបចំចិត្តគំនិតលះបង់ចំណង់នានាដែលខុសទំនង ការលះបង់ចំណង់ទាំងនោះរួចហើយ ការស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់ដោយចាត់ចែងការរស់នៅរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់វិញ្ញាណរបស់ខ្លួន សុទ្ធតែហៅថា «ការហ្វឹកហ្វឺនតាមវិញ្ញាណ» ។*

***៣៦៥ :*** *វិន័យទី ១៣ ដែលត្រូវអនុវត្តតាមដើម្បីទទួលមុខនាទីដ៏ពិតប្រាកដរបស់ខ្លួនក្នុងព្រះសហគមន៍បច្ចុប្បន្ន មានដូចតទៅ៖ ត្រូវប្រុងប្រៀបខ្លួនជានិច្ច បើអស់លោកអភិបាលសម្រេចអ្វីដែលខ្ញុំឃើញ ស ថាជាខ្មៅវិញ ខ្ញុំត្រូវតែជឿតាម ទើបខ្លួនអាចទៅកាន់ទីដៅក្នុងគ្រប់កិច្ចការបាន ដ្បិតយើងជឿថា ព្រះវិញ្ញាណតែមួយដែលភ្ជាប់នឹងព្រះគ្រីស្តជាព្រះអម្ចាស់នៃយើង និងជាព្រះស្វាមី ឲ្យជាប់នឹងព្រះសហគមន៍ជាព្រះមហេសី ក៏ព្រះវិញ្ញាណដដែលនោះគ្រប់គ្រងយើង និងណែនាំយើងទៅរកប្រយោជន៍ខាងវិញ្ញាណ ។*

Layout Histor.qxd 2/10/07 10:10 AM Page 175

95

## វិន័យជាគ្រឹះនៃសមាគមសហជីវិនព្រះយេស៊ូ

នរណាក៏ដោយក្នុងសមាគមយើងដែលយើងចង់ហៅថា «សមាគមសហជីវិនព្រះយេស៊ូ» មានបំណងកាន់អាវុធសម្រាប់តយុទ្ធថ្វាយព្រះជាម្ចាស់ និងចង់បម្រើតែព្រះយេស៊ូគ្រីស្តជាអម្ចាស់តែមួយព្រះអង្គគត់ ព្រមទាំងបម្រើអភិបាលក្រុងរ៉ូមជាតំណាងព្រះគ្រីស្តនៅលើផែនដី អ្នកនោះត្រូវតែធ្វើពាក្យសច្ចាប្រណិធានថា នឹងរស់ជាព្រហ្មចារីអស់មួយជីវិតសិន រួចសូមចូលរួមជាសមាជិកនៃសមាគមយើង ។ សមាគមយើងចាត់ចែងជាអាទិ៍ ដើម្បីជួយឲ្យវិញ្ញាណមនុស្សចម្រើនឡើង ក្នុងការរស់នៅរបស់គេតាមលទ្ធិគ្រីស្តសាសនា ព្រមទាំងឲ្យប្រកាសផ្សាយជំនឿ ដោយសម្តែងធម្មទេសនាជាសាធារណៈ ដោយបម្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយធ្វើការហ្វឹកហ្វឺនខាងវិញ្ញាណ ដោយធ្វើអំពើល្អ សម្តែងមេត្តាករុណា ជាពិសេសអប់រំជំនឿរបស់ក្មេងៗ និងរបស់អ្នកដែលមិនបានទទួលការអប់រំអំពីលទ្ធិគ្រីស្តសាសនា ព្រមទាំងដោយធ្វើអគ្គសញ្ញាលើកលែងទោសឲ្យគ្រីស្តបរិស័ទ ដើម្បីឲ្យគេធូរស្រាលក្នុងចិត្ត (...) ។

មានតែលោកប្រធានទូទៅប៉ុណ្ណោះ ដែលមានសិទ្ធិបញ្ជាសមាជិកនៃសមាគមសហជីវិនព្រះយេស៊ូ (...) ។ ទោះបីយើងរៀនអ្វីអំពីព្រះគម្ពីរដំណឹងល្អក្តី និងអំពីជំនឿដ៏ត្រឹមត្រូវក្តី ទោះបីយើងប្រកាសយ៉ាងម៉ឺងហ្មាត់ និងជឿថា គ្រីស្តបរិស័ទទាំងអស់ត្រូវតែចុះចូលក្រោមអំណាចអភិបាលក្រុងរ៉ូម ទុកជាមេដឹកនាំរបស់ខ្លួន និងចាត់លោកទុកជាតំណាងរបស់ព្រះគ្រីស្តក្តី ក៏យើងយល់ឃើញថា ត្រូវតែធ្វើពាក្យសច្ចាប្រណិធានយ៉ាងពិសេសថា នឹងបម្រើអភិបាលក្រុងរ៉ូមនាបច្ចុប្បន្ន និងអស់លោកដែលបន្តមុខងារពីលោក ដើម្បីឲ្យសមាជិកសមាគមយើងមានចិត្តកាន់តែសុភាពរាបសាទៅទៀត (...) ។ អស់លោកបញ្ជាធ្វើអ្វីដើម្បីជាប្រយោជន៍ដល់វិញ្ញាណរបស់មនុស្សលោក និងដើម្បីផ្សព្វផ្សាយជំនឿ ក៏យើងត្រូវតែធ្វើតាមភ្លាមដោយមិនរួញរា ឬដកខ្លួនចេញឡើយ ។ ប្រសិនបើលោកចាត់យើងឲ្យទៅប្រទេសណាក្តី ទៅកាន់ជនជាតិទួរគីក្តី ឬទៅកាន់អ្នកឯទៀតដែលគ្មានជំនឿណាក្តី សូម្បីតែទៅនៅស្រុកឥណ្ឌាក្តី ទៅកាន់អ្នកបែកចេញពីជំនឿក្តី បែកចេញពីព្រះសហគមន៍ក្តី ឬចំពោះអ្នកជឿក្តីក៏យើងទៅភ្លាមដែរ (...) ។

អ៊ីញ៉ាស់ នៅ ឡូយ៉ូឡា

96

## សន្តិតេរ៉េសា នៅ អាវីឡា (១៥១៥–១៥៨២) : សម្ផស្សរបស់ព្រះគ្រីស្ត

កាលខ្ញុំឃើញព្រះគ្រីស្ត ព្រះអង្គបារសម្ផស្សដ៏ល្អបំផុតរបស់ព្រះអង្គក្នុងចិត្តខ្ញុំ សម្ផស្សនោះក៏នៅ ស្ថិតស្ថេរក្នុងចិត្តខ្ញុំនៅឡើយរហូតមកសព្វថ្ងៃដែរ ។ ព្រះអង្គបារសម្ផស្សនៅក្នុងចិត្តខ្ញុំតែម្តងគត់ ។ តែព្រះអម្ចាស់ប្រណីសន្តោសមកខ្ញុំដូច្នេះជាញឹកញយ ។ ខ្ញុំចម្រើនយ៉ាងអស្ចារ្យដូចតទៅ៖ កាលពីមុនខ្ញុំមានចិត្តវៀចវេរយ៉ាងខ្លាំង បណ្តាលឲ្យខ្ញុំខាតប្រយោជន៍យ៉ាងធ្ងន់ គឺពេលខ្ញុំយល់ឃើញថា មានមនុស្សម្នាក់ស្រឡាញ់ខ្ញុំ គាប់ចិត្តខ្ញុំ ខ្ញុំវក់ចិត្តនឹងគេ នឹកគិតគេជានិច្ច ។ ទោះបីខ្ញុំគ្មានបំណងធ្វើខុសនឹងវិន័យព្រះជាម្ចាស់ក្តី ក៏ខ្ញុំសប្បាយចិត្តដោយឃើញគេ ដោយនឹកដល់គេ និងនឹកអំពីគុណសម្បត្តិដែលគេមាននោះ ។ ចិត្តវៀចវេរនោះ បណ្តាលឲ្យចិត្តគំនិតខ្ញុំវិលវល់ទាំងស្រុង ។ ក្រោយមក ខ្ញុំឃើញសម្ផស្សដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ខ្ញុំយល់ឃើញថា បើប្រៀបធៀបនឹងព្រះអង្គ គ្មាននរណាម្នាក់ល្អ គ្មាននរណាម្នាក់គួរឲ្យខ្ញុំចាប់អារម្មណ៍ឡើយ តាំងពីពេលនោះមក ខ្ញុំគ្រាន់តែក្រឡេកភ្នែកមើលរូបភាពដែលស្ថិតក្នុងចិត្តខ្ញុំប៉ុណ្ណោះ ។ ខ្ញុំមានសេរីភាពដល់កម្រិតអស្ចារ្យបំផុត គឺខ្ញុំខ្ពើមនឹងអ្វីៗដែលខ្ញុំឃើញ ដោយប្រៀបធៀបនឹងការដ៏ប្រសើរអស្ចារ្យនេះ និងការប្រណីសន្តោសដែលខ្ញុំឃើញក្នុងព្រះអម្ចាស់ ។ យើងរាប់ចំណេះនិងអំណរសប្បាយណាក៏ដោយទុកជាឥតបានការ ដោយគ្រាន់តែឮព្រះសូរសៀងមួយព្រះឱស្ឋ ដែលព្រះអង្គមានព្រះបន្ទូលមកខ្ញុំជាញឹកញយ ។ ប្រសិនបើព្រះអម្ចាស់មិន អនុញ្ញាតឲ្យខ្ញុំភ្លេចព្រះសូរសៀងនេះទេ គ្មាននណាអាចធ្វើជាម្ចាស់ដួងចិត្តខ្ញុំបានទេ ខ្ញុំគ្រាន់តែនឹកបន្តិចដល់ព្រះអម្ចាស់ នោះខ្ញុំមានសេរីភាពពេញទីទៅហើយ ។

តេរ៉េសានៅអាវីឡា «ជីវិតសរសេរដោយខ្លួនឯងផ្ទាល់»

Layout Histor.qxd 2/10/07 10:10 AM Page 176

### *លោកយ៉ូហាន ស្រឡាញ់ឈើឆ្កាង*



*(Jean de la Croix គ.ស. ១៥៤២-១៥៩១)*

លោក**យ៉ូហាន**កើតនៅក្នុងប្រទេសអេស្ប៉ាញ ។ ពេលអាយុ ២៥ ឆ្នាំ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុងក្រុមគ្រួសារបព្វជិតការមែល ។ លោកជួយណែនាំជូនជី**តេរ៉េសា** ខាងផ្លូវវិញ្ញាណ ។

អ្នកទាំងពីរខិតខំកែទម្រង់ក្រុមគ្រួសារការមែល ទាំងខាងបុរសទាំងខាងស្ត្រី ។ តែពួកអ្នកប្រឆាំងនាំគ្នាចាប់លោកយ៉ូហានឃុំឃាំងធ្វើបាប ។ នៅក្នុងមន្ទីរឃុំឃាំង លោកនិពន្ធសៀវភៅបរិយាយអំពីជីវិតរួមរស់ជាមួយព្រះយេស៊ូ ក្រោមការណែនាំនៃព្រះវិញ្ញាណ ។ លោកតែងតែពោលថា៖ «*កាលយើងផុតជីវិតទៅ ព្រះជាម្ចាស់វិនិច្ឆ័យទោសយើង ដោយឈ្វេងយល់តែសេចក្តីស្រឡាញ់របស់យើងប៉ុណ្ណោះ*» ។ ដូច្នេះ ត្រូវតែលះបង់អ្វីៗទាំងអស់ ដើម្បីស្រឡាញ់ព្រះជាម្ចាស់តែមួយព្រះអង្គគត់ ។

### *លោកហ្វ្រង់សរ័ នៅ សាល* (François de Sales *គ.ស. ១៥៦៧-១៦២២*)



97 លោក**ហ្វ្រង់សរ័**កើតនៅក្នុងគ្រួសារត្រកូលខ្ពស់មួយ នៅភូមិសាល ស្រុកសាវ័រ (*ប្រទេសបារាំងសព្វថ្ងៃ*) ។ លោកយកចិត្តទុកដាក់បង្រួបបង្រួមគ្រីស្តបរិស័ទកាតូលិកនិងប្រូតេស្តង់ដែលបាក់បែកគ្នា ។ កាលពីលោកអាយុ ៣៥ ឆ្នាំ លោកទទួលបន្ទុកជាអភិបាលព្រះសហគមន៍ក្រុងសឺណែវ ។

លោកតែងធ្វើដំណើរទៅសួរសុខទុក្ខគ្រីស្តបរិស័ទអប់រំក្មេងៗ ខាងគ្រីស្តសាសនា អប់រំក្រុមបូជាចារ្យ ។ នៅគ.ស. ១៦១០ លោកបង្កើតក្រុមគ្រួសារបព្វជិតាមួយគឺ «*ក្រុមគ្រួសាររបស់ព្រះនាងម៉ារីទៅសួរសុខទុក្ខនាងអេលីសាបិត*» ។ ក្រោយមកក្រុមគ្រួសារបព្វជិតាជាច្រើន ក្រេបជញ្ជក់គោលគំនិតរបស់លោកក្នុងការបង្ហាត់បង្រៀនក្មេងៗ ។ លោកនិពន្ធសៀវភៅនិងលិខិតដែលមានខ្លឹមសារខាងគ្រីស្តសាសនាជាច្រើន ។ លោកមានឥទ្ធិពលយ៉ាងខ្លាំងក្នុងកិច្ចអប់រំខាងព្រះវិញ្ញាណ ។

### *លោកវ៉ាំងសង់ នៅ ប៉ូល* (Vincent de Paul *គ.ស. ១៥៨១-១៦៦០*) 98



កាលពីកុមារ លោក**វ៉ាំងសង់**ឃ្វាលសត្វ តែលោកមានបំណងទៅជាបូជាចារ្យ ។ លុះលោកទទួលមុខងារជាបូជាចារ្យហើយ លោកភ្ញាក់ស្មារតី ដោយឃើញទុក្ខវេទនាគ្រប់យ៉ាងនៃប្រជាជនក្រីក្រ ។

ហេតុនេះហើយ បានជាលោកបង្កើតក្រុមគ្រួសារបព្វជិតពីរ ដោយមានគោលបំណងជួយអ្នកក្រីក្រ នាំដំណឹងល្អជូនអ្នកស្រែ ណែនាំទេវវិទ្យាល័យ ឲ្យអប់រំអស់អ្នកដែលមានបំណងទៅជាបូជាចារ្យ ។ លោកឧស្សាហ៍អធិដ្ឋាន ។ លោកតែងតែពោលថា៖ «*ព្រះជាម្ចាស់នឹងប្រទានអ្វីៗទាំងអស់ដល់អ្នកអធិដ្ឋាន*» ។

## 97 ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទទាំងអស់ឱ្យបានវិសុទ្ធនៅកន្លែងគេរស់នៅ

លោក**ហ្វ្រង់ស័រនៅសាល**ជាអភិបាលដើមដំបូង ដែលយកចិត្តទុកដាក់ទូន្មានគ្រីស្តបរិស័ទធម្មតាឲ្យរស់នៅខាងវិញ្ញាណតាមការរស់នៅរបស់គេ ។

*ខ្ញុំមានបំណងបង្រៀនគូស្វាមីភរិយាដែលរស់នៅទីក្រុង ឬនៅក្នុងវាំងស្តេច ដែលត្រូវតែរស់នៅតាមរបៀបសាធារណៈ ហើយដែលមិនចង់គិតអំពីការគោរពប្រណិប័តន៍ព្រះជាម្ចាស់ ដោយអះអាងថា ធ្វើមិនកើតនោះទេ (..) ។*

*នាង**ភីឡូទេ**អើយ! ការគោរពប្រណិប័តន៍ពិតប្រាកដ និងដែលមានជីវិតរស់រវើក មកពីយើងស្រឡាញ់ព្រះជាម្ចាស់ ។ គ្មានអ្វីក្រៅពីការស្រឡាញ់ព្រះអង្គយ៉ាងពិតប្រាកដទេ (...) ។ ព្រះអង្គប្រទានឲ្យយើងមានកម្លាំងនឹងប្រព្រឹត្តអំពើល្អ គេហៅការនោះថា "សេចក្តីស្រឡាញ់" ។ កាលសេចក្តីស្រឡាញ់នោះចម្រើនឡើងយ៉ាងពេញលក្ខណៈ យើងមិនគ្រាន់តែធ្វើអំពើល្អប៉ុណ្ណោះទេ គឺសេចក្តីស្រឡាញ់នោះជំរុញឲ្យយើងធ្វើអំពើល្អជាញឹកញយ ដោយយកចិត្តទុកដាក់ភ្លាម ។ គេហៅរបៀបរស់បែបនេះថា "ការគោរពប្រណិប័តន៍" (...) ។*

*អភិជន ជាង អ្នកបម្រើ ព្រះអង្គម្ចាស់ ស្ត្រីមេម៉ាយ នាងក្រមុំ ស្ត្រីមានស្វាមី ត្រូវគោរពប្រណិប័តន៍តាមរបៀបផ្សេងៗពីគ្នា មិនគ្រាន់តែប៉ុណ្ណោះសោត ត្រូវសម្រួលការគោរពតាមកម្លាំង តាមអាជីវកម្ម តាមភារកិច្ចមនុស្សម្នាក់ៗ (...) ។ អ្នកដែលនិយាយថា ទាហាន អ្នករកស៊ី ជាងនៅរោងចក្រ ស្តេចនៅវាំង គូស្វាមីក្នុងគ្រួសារ មិនអាចគោរពនោះ អ្នកនោះពិតជាវង្វេងគំនិត ហើយក៏វង្វេងជំនឿទៀតផងដែរ! ។*

*ហ្វ្រង់ស័រនៅសាល "ការណែនាំក្នុងជីវិតគោរពប្រណិប័តន៍"*

## 98 សេចក្តីស្រឡាញ់ដ៏ពិតប្រាកដបញ្ចេញសកម្មភាព

*បងប្អូនអើយ! យើងត្រូវស្រឡាញ់ព្រះជាម្ចាស់! យើងត្រូវស្រឡាញ់ព្រះជាម្ចាស់! តែត្រូវស្រឡាញ់ដោយប្រើកម្លាំងដៃរបស់យើងដោយបែកញើសហូរញើស ។ មានកិច្ចស្រឡាញ់ព្រះជាម្ចាស់ច្រើនយ៉ាង ដូចជាអាណិតគេ មានចិត្តសប្បុរស ចិត្តមេត្តាករុណា គ្រាន់តែក្នុងចិត្តគំនិតប៉ុណ្ណោះទេ ។ អ្នកគិតដូច្នេះពិតជាមានគំនិតល្អណាស់ គួរឲ្យចង់បានចិត្តបែបនេះមែន ។ ប៉ុន្តែ ប្រសិនបើគំនិតទាំងនោះមិននាំឲ្យប្រព្រឹត្តអំពើដែលប្រកបដោយសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដ គួរឲ្យសង្ស័យអំពីចិត្តគំនិតទាំងនោះវិញ ។ ព្រះអម្ចាស់មានព្រះបន្ទូលថា ព្រះបិតាទទួលសិរីរុងរឿង ដោយអ្នករាល់គ្នាបង្កើតផលជាច្រើន (...) ។*

*អ្នកខ្លះអួតខ្លួនដោយគ្រាន់តែស្រមៃឃើញយ៉ាងអស្ចារ្យប៉ុណ្ណោះ ហើយគ្រាន់តែនិយាយស្និទ្ធស្នាលជាមួយព្រះជាម្ចាស់នៅពេលគេស្មិងស្មាធិ៍ធ្វើសមាធិ ។ គេចេះនិយាយយ៉ាងល្អអំពីព្រះជាម្ចាស់ ដូចដែលទេវទូតធ្លាប់និយាយនោះ តែក្រៅពីនោះគេមិនធ្វើការអ្វីថ្វាយព្រះជាម្ចាស់ទេ មិនរងទុក្ខ មិនធ្វើតបៈធម៌ មិនបង្រៀនអ្នកក្រីក្រ មិនទៅរកកូនចៀមដែលវង្វេង មិនចូលចិត្តឲ្យខ្លួនខ្វះខាត មិនចូលចិត្តឲ្យខ្លួនមានជំងឺ មិនចូលចិត្តឲ្យខ្លួនរងទុក្ខលំបាកផ្សេងៗឡើយ ។ បើកើតទុក្ខទាំងនោះ គេអស់ក្លាហានហើយ ។ ទេ! ទេ! កុំប្រទ្បាំឡើយ! «គំនិតដ៏ល្អទាំងអស់របស់យើងត្រូវក្លាយជាការប្រព្រឹត្តវិញ» ។*

*វាំងសង់នៅប៉ូល*

Layout Histor.qxd 2/10/07 10:10 AM Page 178

***លោកយ៉ូហានបាទីស្ត នៅ ឡាសាល*** *(Jean Baptiste de la Salle គ.ស. ១៦៥១-១៧១៩)*



លោក**យ៉ូហានបាទីស្ត នៅឡាសាល** ជាបូជាចារ្យសញ្ជាតិបារាំង ។ លោកបង្កើតក្រុមគ្រួសារបព្វជិតដែលមានឈ្មោះថា «*បងៗគ្រូបង្រៀនក្នុងសាលាគ្រីស្តបរិស័ទ*» មានគោលដៅអប់រំកូនអ្នកក្រីក្រ ។ ក្រោយមក មានសមាជិកក្រុមគ្រួសារនេះមកបង្រៀនក្មេងៗនៅប្រទេសកម្ពុជា អស់រយៈពេល ៨០ ឆ្នាំ នៅសាលាមីស្សជាដើម ។

## ៣- អំពីទេវវិទ្យាល័យ

តាំងពីដើមព្រះសហគមន៍រៀងមក គ្មានទេវវិទ្យាល័យសម្រាប់អប់រំគ្រីស្តបរិស័ទដែលចង់ទៅជាបូជាចារ្យទេ ។ តាមធម្មតា អ្នកទាំងនោះរស់នៅជាមួយបូជាចារ្យម្នាក់អស់រយៈពេលយូរបន្តិចមុនទៅជាបូជាចារ្យ ។ គេចាប់ផ្តើមបាត់តាំងទេវវិទ្យាល័យនៅពាក់កណ្តាលសតវត្សទី ១៦ ។ នៅចុងសតវត្សទី ១៧ និងនៅដើមសតវត្សទី ១៨ អស់លោកអភិបាលតែងតាំងទេវវិទ្យាល័យមួយនៅភូមិភាគរៀងៗខ្លួន ។ និស្សិតរៀនតែសីលធម៌និងសាសនា ។ ចាប់តាំងពីមានទេវវិទ្យាល័យមក បូជាចារ្យបែរជារស់នៅតាមរបៀបប្លែកពីប្រជាជន គឺពាក់អាវខ្មៅវែង រស់នៅដាច់ឡែកពីមនុស្សធម្មតា ថ្វាយអភិបូជារៀងរាល់ព្រឹក សូត្រធម៌តាមពេលកំណត់ដូចក្រុមបព្វជិត និងយកចិត្តទុកដាក់ណែនាំគ្រីស្តបរិស័ទ ។

## ៤- ជំនឿ និង វិទ្យាសាស្ត្រ

មហាសន្និបាតត្រេនតូ មិនបានដោះស្រាយបញ្ហាទាំងប៉ុន្មានដែលហូរចេញមកពីការកែទម្រង់ទេ ។ នៅសម័យនោះ អ្នកស្រាវជ្រាវវត្ថុបុរាណនិងអ្នកប្រាជ្ញខាងវិទ្យាសាស្ត្រ ចាប់ផ្តើមចោទសួរសំណួរខ្លះអំពីគម្ពីរ ។ ឧប.ថា ក្នុងគម្ពីរមានចែងថា ព្រះអាទិត្យវិលជុំវិញផែនដី ។ នៅគ.ស. ១៥៤៣ លោក**កូពែរនិក**
(Copernic) ជាបូជាចារ្យជាតិប៉ូឡូញម្នាក់រកឃើញថា ផែនដីវិលខ្លួនឯងមួយថ្ងៃ 99
មួយជុំ ហើយវិលជុំវិញព្រះអាទិត្យមួយឆ្នាំមួយជុំ ។

នៅសតវត្សក្រោយ ទេវវិទូទាំងប្រូតេស្តង់ ទាំងកាតូលិក នាំគ្នាជំទាស់នឹងទ្រឹស្តីលោកកូពែរនិក ដែលផ្ទុយពីព្រះគម្ពីរ ហើយដាក់សៀវភៅលោកទៅក្នុង «*បញ្ជីស្បែកឆ្កែ*» ដែរ ។ គេដុតលោក**យ័រដាណូ ប្រុយណូ** (Giordano Bruno) ទាំងរស់ នៅគ.ស. ១៦០០ នៅក្រុងរ៉ូម ព្រោះលោកប្រកាសទ្រឹស្តីលោកកូពែរនិកនិងជំទាស់ព្រះសហគមន៍ ។

គ.ស. ១៦១៦ លោក**កាលីឡេអូ-កាលីឡេអ៊ី** (Galileo Galilei) ប្រកាសទ្រឹស្តីដដែល ហើយត្រូវទទួលទោសដែរ ។ លោកពន្យល់ថា «*ក្នុងព្រះគម្ពីរព្រះវិញ្ញាណដ៏វិសុទ្ធ គ្មានបំណងសម្តែងឲ្យយើងស្គាល់អំពីរបៀបមេឃធ្វើដំណើរទេ គឺព្រះអង្គណែនាំយើងឲ្យស្គាល់មាគ៌ាទៅស្ថានបរមសុខវិញ*» ។ លោកក៏ត្រូវព្រះសហគមន៍បង្ខំឲ្យលះបង់ទ្រឹស្តីដ៏ត្រឹមត្រូវរបស់លោកចោល ។

## ៥- ការបកស្រាយព្រះគម្ពីរតាមរបៀបថ្មី

លោក**រីសា-ស៊ីម៉ុង** (Rihard Simon គ.ស. ១៦៣៨-១៧១២) ជាបូជា 100
ចារ្យស្ទាត់ជំនាញខាងភាសាហេប្រឺ ក្រិក និងភាសាបុរាណផ្សេងៗទៀត ។ លោកបានប្រៀបធៀបគម្ពីរសរសេរតាមភាសាបុរាណផ្សេងៗ ហើយរិះគិតអំពីរបៀបព្រះវិញ្ញាណបំភ្លឺអ្នកនិពន្ធគម្ពីរ ។ លោកប្រមូលភស្តុតាងបញ្ជាក់ថា លោក**ម៉ូសេមិន**បាននិពន្ធគម្ពីរបញ្ចក័ណ្ឌទាំងមូលដូចមានចែងក្នុងគម្ពីរទេ ។ តែលោកត្រូវទទួលទោស ហើយត្រូវគេដេញចេញពីក្រុមគ្រួសារបព្វជិតរបស់លោក ។

Layout Histor.qxd  2/10/07  10:10 AM  Page 179

99

## អំពីការអប់រំបូជាចារ្យ

លោក**វ៉ាំងសង់ នៅ ប៉ូល**ធ្លាប់អប់រំបូជាចារ្យ ដោយណែនាំគ្រីស្តបរិស័ទដែលចង់ទៅជាបូជាចារ្យធ្វើសំណាក់ធម៌រយៈពេល ១១ ថ្ងៃ ។ យូរៗទៅព្រះសហគមន៍បង្កើតវិន័យកាន់តែតឹងឡើងៗ ។ អភិបាលនានាបង្កើតទេវវិទ្យាល័យក្នុងភូមិភាគរបស់ខ្លួន ហើយបង្កើតវិន័យថ្មី ។ ឧប. លោកអភិបាលព្រះសហគមន៍ក្រុងលីយ៉ុង (ប្រទេសបារាំង) បញ្ជាក់សេចក្តីដូចតទៅ៖

***គ.ស. ១៦៥៧ :*** *យើងបញ្ជាអស់អ្នកដែលចង់ទទួលមុខដំណែងដ៏វិសុទ្ធផ្សេងៗ ត្រូវមកស្នាក់នៅក្រុងនេះឲ្យយូរបន្តិច ដើម្បីទទួលការអប់រំក្នុងទេវវិទ្យាល័យរបស់លោកអភិបាល និងរស់នៅទីនោះគ្រប់ចំនួនថ្ងៃដែលលោកបានសម្រេចនោះសម្រាប់ទទួលមុខនាទីនីមួយៗ គឺថា ១២ ថ្ងៃ សម្រាប់អ្នកទទួលមុខនាទីអនុឧបដ្ឋាក ។ ១០ ថ្ងៃសម្រាប់អ្នកទទួលមុខនាទីជាឧបដ្ឋាក ។ ១៥ ថ្ងៃ សម្រាប់អ្នកទទួលមុខនាទីជាបូជាចារ្យ ។*

***គ.ស. ១៦៦៣ :*** *យើងសម្រេចចិត្តបង្កើតទេវវិទ្យាល័យ ដើម្បីអប់រំអ្នកបំពេញមុខនាទីពិសេសក្នុងភូមិភាគយើង គឺអស់លោកដែលមានបំណងបំពេញមុខនាទីនោះ ត្រូវទទួលការអប់រំឲ្យចេះគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងមានសមត្ថភាព ស្របតាមមុខនាទីដ៏ថ្លៃថ្នូរ និងដ៏សំខាន់នោះ ។ ត្រូវបន្ថែមការអប់រំដល់អស់អ្នកដែលកំពុងបំពេញមុខនាទីនេះ ដោយបាត់បែងសំណាក់ធម៌ សិក្ខាសាលាបង្រៀនគេ លើកទឹកចិត្តគេ (...) ។ ជាពិសេសទេវវិទ្យាល័យ ត្រូវទៅជាសាលាដ៏វិសុទ្ធ ជាកន្លែងអប់រំគ្រីស្តបរិស័ទឲ្យកាន់តាមព្រហ្មវិហារធម៌ ឲ្យគេទទួលអគ្គសញ្ញានិងធ្វើពិធីផ្សេងៗ ព្រមទាំងប្រព្រឹត្តអ្វីៗដែលគ្រីស្តបរិស័ទមានបំណងណែនាំប្រជាជនឲ្យបានវិសុទ្ធ (...) ។*

***គ.ស. ១៦៩៤ :*** *អ្នកដែលចង់ទទួលមុខងាជាអនុឧបដ្ឋាក ត្រូវរស់នៅក្នុងទេវវិទ្យាល័យ ៦ ខែ ។ អ្នកដែលចង់ទទួលមុខងារជាឧបដ្ឋាក ត្រូវរស់នៅក្នុងទេវវិទ្យាល័យ ៣ ខែទៀត ។ រីឯអ្នកចង់ទទួលមុខនាទីជាបូជាចារ្យបន្ថែមបីខែទៀត (...) ។*

100

## ការបកស្រាយអត្ថន័យព្រះគម្ពីរតាមវិទ្យាសាស្ត្រ

***លោកម៉ូសេមិនមែនជាអ្នកនិពន្ធគម្ពីរបញ្ចកណ្ឌទាំងមូលទេ***

*(..) យើងមិនលំបាកបង្ហាញភស្តុតាងបញ្ជាក់ថា លោកម៉ូសេមិនមែនជាអ្នកនិពន្ធគម្ពីរបញ្ចកណ្ឌទាំងមូល ដូចយើងអានសព្វថ្ងៃ (..) ឧបមាថា នរណាហ៊ាននិយាយថា លោកម៉ូសេនិពន្ធជំពូកចុងក្រោយនៃទុតិយកថា ព្រោះក្នុងជំពូកនោះមានរៀបរាប់អំពីលោកទទួលមរណភាព ។ ខ្ញុំដឹងថា លោក**ហ្វ្លាវីយ៉ុស-យ៉ូសែប** និងលោក**ភីឡូន** ធ្លាប់និយាយថា លោកម៉ូសេទស្សន៍ទាយខ្លួនឯង អំពីលោកទទួលមរណភាពនោះ ។ ប៉ុន្តែយើងមិនត្រូវជឿគេអំពីរឿងនេះទេ ហើយក៏មិនត្រូវជឿជនជាតិយូដាឯទៀតៗ ដែលតែងតែនិយាយថា លោកម៉ូសេនិពន្ធធម្មវិន័យទាំងមូលដែរ ។ គេតែងនិយាយដូច្នេះ ដើម្បីឲ្យជនជាតិយូដាមានចិត្តចង់អនុវត្តតាម (..) ។ ក្នុងគម្ពីរបញ្ចកណ្ឌមានសេចក្តីជាច្រើនអនេកបែងពីរឬបីដង គឺច្បាស់ថា មិនមែនមកពីលោកម៉ូសេនិពន្ធទេ គឺមកពីអស់អ្នកដែលប្រមូលអត្ថបទពេលចងក្រងព្រះគម្ពីរ យកអត្ថបទជាច្រើន និងសេចក្តីពន្យល់ពាក្យដដែលជាច្រើនមកដាក់ចូលភ្ជាប់គ្នា (..) ។ យើងក៏អាចនឹកគិតដល់រឿងរៀបរាប់អំពីទឹកជំនន់ធំ ដែលមានបែងជាច្រើនដងដូច្នេះដែរ (..) ។ នៅក្នុងគម្ពីរដំណើរឆ្ពោះទៅកាន់សេរីភាព និងគម្ពីរលេវីវិន័យ គេក៏បែងសេចក្តីជាពីរឬបីដងច្រើនជាងគម្ពីរកំណើតទៅទៀត (..) ។ របនាបទក៏ប្លែកៗពីគ្នានៅក្នុងគម្ពីរបញ្ចកណ្ឌ ដែលគេហៅថា «គម្ពីរលោកម៉ូសេ» ក៏ជាភស្តុតាងមួយទៀតបញ្ជាក់ថា មិនមានអ្នកនិពន្ធតែម្នាក់ទេ (..) ។*

*លោករីសា-ស៊ីម៉ុង «ប្រវត្តិសម្ពន្ធមេត្រីចាស់តាមវិទ្យាសាស្ត្រ» ១៦៧៨*

## ៦- វិបត្តិរបស់លោកយ៉ង់សេន *(Jansen)*

101 ពេលដែលគ្រីស្តបរិស័ទកាតូលិករិះគិតតាមរបៀបអ្នកកែទម្រង់ព្រះសហគមន៍ អំពីព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្តោសសង្គ្រោះមនុស្សបាប មានគេចោទសំណួរមួយថា តើមនុស្សមានសេរីភាពប្រព្រឹត្តផ្ទុយនឹងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់បានឬមិនបាន? គ្រីស្តបរិស័ទមួយចំនួនធំដែលតែងតែរិះគិតតាមលោក**អូគូស្តាំង**នាំគ្នាប្រកាសថា ព្រះជាម្ចាស់តម្រូវមនុស្សដែលព្រះអង្គសព្វព្រះហឫទ័យសង្គ្រោះនោះមុនកាលសម័យទាំងអស់ ហេតុដូចនេះហើយ បានជាមនុស្សគ្មានសេរីភាព មិនអាចជំទាស់នឹងព្រះហឫទ័យព្រះអង្គបានទេ ។

គ្មាននរណាអាចដោះស្រាយបញ្ហានេះបានទេ ។ ទេវវិទូទ្វីបអឺរ៉ុបខ្វែងគំនិតគ្នាអស់មួយសតវត្សកន្លះ (១៥៦៧-១៧១៣) សព្វថ្ងៃ ក៏មិនទាន់ផុតនៅឡើយ ។ លោកអភិបាល**យ៉ង់សេន** (១៦៤០) មានឈ្មោះល្បីជាងគេក្នុងចំណោមទេវវិទូទាំងនោះ លោកយល់ឃើញថា អំពើបាបរបស់លោកអដាំ បណ្តាលឲ្យមនុស្សខូចទាំងស្រុង គ្មានសេរីភាព គ្មានអ្វីដ៏ល្អក្នុងខ្លួនទាល់តែសោះ ហើយត្រូវតែប្រព្រឹត្តអំពើបាបជានិច្ច ។ រីឯលោក**ម៉ូលីណា** (Molina) ខិតខំពន្យល់វិញថា ទោះបីមនុស្សជាប់បាបតាំងពីកំណើតមកមែនក្តី ក៏គេមានសេរីភាពដែរ ដោយសារព្រះជាម្ចាស់បង្ហាញព្រះទ័យប្រណីសន្តោសដល់គេគ្រប់គ្រាន់ហើយ ។ លោក**ប៉ាស្កាល់** (Pascal ១៦៧០) កាន់ជើងគ្រីស្តបរិស័ទរិះដែលគិតតាមលោកយ៉ង់សេន ។ អភិបាលក្រុងរ៉ូមដាក់ទោសពួកគេ (ក្រិត្យ «*ព្រះបុត្រាតែមួយព្រះអង្គ*» ១៧១៣) ។

ពួកគេកាន់គ្រីស្តសាសនាយ៉ាងតឹងរ៉ឹង បេះតែខ្លាចបាបជានិច្ច (ដូចគ្រីស្តបរិស័ទខ្លះសព្វថ្ងៃ) តែពួកគេយកចិត្តទុកដាក់ធ្វើពិធីបុណ្យតាមភាសាប្រជាជនដើម្បីឲ្យប្រជាជនស្តាប់បាន ។ ពួកគេក៏លើកកិត្តិយសរបស់ក្រុមបូជាចារ្យ និងគ្រីស្តបរិស័ទឲ្យហ៊ានតវ៉ានឹងអភិបាលព្រះសហគមន៍ ។ គេក៏ទាមទារសិទ្ធិសេរីភាពខាងមនសិការ កុំឲ្យរដ្ឋអំណាចបញ្ជាមនុស្សខាងជំនឿ ។



*លោក កាលីឡេអូ កាលីឡេអ៊ី*

## (101) អភិបាលព្រះសហគមន៍ក្រុងរ៉ូមដាក់ទោសលោកយ៉ង់សេន

អភិបាលក្រុងរ៉ូម**ក្លេម៉ង់ ទី ១១** ដាក់ទោសគ្រីស្តបរិស័ទដែលកាន់តាមលោកយ៉ង់សេន (ក្រិត្យ «*ព្រះបុត្រាតែមួយព្រះអង្គ*» នៅ ១៧១៣) ។ លោកក៏ដាក់ទោសគ្រីស្តបរិស័ទដែលចង់កែទម្រង់ព្រះសហគមន៍ ដោយហុចឱកាសឲ្យគ្រីស្តបរិស័ទអានគម្ពីរគ្រប់ៗគ្នា ។ គួរឲ្យឆ្ងល់ ព្រោះសព្វថ្ងៃយើងកាន់តាមសេចក្តីដែលអភិបាលក្រុងរ៉ូមបានបដិសេធយ៉ាងឱឡារិក ។ តែត្រូវគិតថា អភិបាលក្រុងរ៉ូមបញ្ចេញយោបល់របស់ខ្លួនសម្រាប់ដោះស្រាយវិបត្តិមួយ តាមកាលៈទេសៈនោះប៉ុណ្ណោះ ។
ខាងក្រោមនេះ ជាសេចក្តីបដិសេធរបស់លោកអភិបាលព្រះសហគមន៍ក្រុងរ៉ូម៖

***៨០-*** *គ្រីស្តបរិស័ទទាំងអស់ត្រូវអានព្រះគម្ពីរ ។*

***៨១-*** *ទោះបីព្រះបន្ទូលព្រះជាម្ចាស់លំបាកស្តាប់ក្តី ក៏មិនត្រូវអនុញ្ញាតឲ្យគ្រីស្តបរិស័ទលែងអានព្រះគម្ពីរដែរ ។*

***៨២-*** *គ្រីស្តបរិស័ទត្រូវតែគោរពថ្ងៃរបស់ព្រះអម្ចាស់ ដោយអានសេចក្តីអំពីធម៌ ជាពិសេសដោយអានព្រះគម្ពីរ ។ អ្នកដែលចង់ឃាត់គ្រីស្តបរិស័ទមិនឲ្យអានគម្ពីរត្រូវទទួលទោស ។*

***៨៣-*** *អ្នកដែលស្មានថា ស្ត្រីៗមិនត្រូវស្គាល់គម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ គឺមិនត្រូវអានព្រះគម្ពីរទេ អ្នកនោះយល់ច្រឡំហើយ ។ គ្រីស្តបរិស័ទវង្វេងជំនឿ មិនមែនមកពីស្ត្រីៗឆាប់ជឿទេ គឺមកពីបុរសមានចំណេះអួតបំប៉ោងវិញ ។*

***៨៥-*** *អ្នកដកគម្ពីរសម្ពន្ធមេត្រីថ្មីពីដៃរបស់គ្រីស្តបរិស័ទ ឬបិទគម្ពីរនោះមិនឲ្យគេអាន គឺមិនបណ្តោយឲ្យគេមានមធ្យោបាយយល់គម្ពីរនោះ អ្នកនោះពិតជាបិទព្រះឱស្ឋរបស់ព្រះគ្រីស្ត មិនឲ្យគេអាចស្តាប់ឮ ។*

*ក្រិត្យ «ព្រះបុត្រាតែមួយព្រះអង្គ»*

Layout Histor.qxd 2/10/07 10:10 AM Page 182



# គ្រីស្តសាសនា ឈានសន្ទឹងលើពិភពលោកទាំងមូល

*សតវត្សទី ១៥-១៦ វិទ្យាសាស្ត្រនៅទ្វីបអឺរ៉ុបចម្រើនឡើង ។ អ្នកប្រាជ្ញរកឃើញថា ផែនដីមានរាងមូលដូចផ្លែក្រូច គេបង្កើតចង្កូតសម្រាប់ដឹកនាំសំពៅកាន់តែធំឡើងៗ បង្កើតត្រីវិស័យ (តាមពិតចិនរកឃើញមុនគេ យូរសតវត្សមកហើយ) គេបង្កើតកាណូតមានក្តោងធំៗជាច្រើន នាំឲ្យជនជាតិព័រទុយហ្គាល និងអេស្ប៉ាញដែលជាមហាអំណាចនាសម័យនោះ ហ៊ានធ្វើដំណើរតាមមហាសមុទ្រ ។ ពួកគេមានបំណងចង់រកមាស គ្រឿងទេស ដីចម្ការដាំដំណាំ ចាប់ទាសករសម្រាប់ធ្វើការនៅចម្ការទាំងនោះ ។ល ។ រីឯគ្រីស្តបរិស័ទយល់ឃើញថា ត្រូវតែនាំដំណឹងល្អអំពីព្រះយេស៊ូប្រាប់អ្នកស្រុកទាំងនោះ កុំឲ្យគេធ្លាក់ស្ថាននរក ។ ដោយប្រូតេស្តង់ធ្វើឲ្យចំនួនគ្រីស្តបរិស័ទកាតូលិកនៅទ្វីបអឺរ៉ុបថយចុះ ការប្រកាសដំណឹងល្អដល់ប្រជាជនថ្មី ជាឱកាសល្អឲ្យព្រះសហគមន៍កាតូលិកចម្រើនឡើងវិញ ។*

## ១- ប្រទេសព័រទុយហ្គាល់ និងអេស្ប៉ាញល្បួតលាស់

នៅគ.ស. ១៤៩២ ជនជាតិអ៊ីតាលីម្នាក់ មានដើមកំណើតនៅទីក្រុងហ្សែន (Gênes) ឈ្មោះ**គ្រីស្តូហ្វ កូឡុំ** (Christoforo Colombo) ដែលបម្រើព្រះមហាក្សត្រអេស្ប៉ាញ ជិះសំពៅដល់ទ្វីបអាមេរិក (Amérique) មុនគេ ។ គាត់ស្មានថាទៅដល់ប្រទេសឥណ្ឌា ។ គ.ស. ១៤៩៧-១៤៩៩ លោក**វ៉ាសកូ ដា ហ្គាម៉ា** (Vasco da Gama) ចេញពីប្រទេសព័រទុយហ្គាល់ បើកសំពៅសៀវតាមចុងទ្វីបអាហ្វ្រិកទៅដល់ប្រទេសឥណ្ឌា ។ នៅគ.ស. ១៥១០ ជនជាតិព័រទុយហ្គាល់ម្នាក់ទៀតឈ្មោះ**អាល់ប៊ូកែក** (Albuquerque) វាយយកក្រុងហ្គោអា (Goa) ដែលស្ថិតតាមឆ្នេរសមុទ្រខាងលិចនៃប្រទេសឥណ្ឌាបាន រួចវាយយកក្រុងម៉ាឡាកា (Malacca) នៅឆ្នេរសមុទ្រខាងលិចប្រទេសម៉ាឡេស៊ី (Malaisie) សព្វថ្ងៃ ។ នៅអំឡុងគ.ស. ១៥១៩-១៥២២ លោក**ម៉ាសេឡង់** (Magellan) ជនជាតិព័រទុយហ្គាល់ម្នាក់បម្រើព្រះមហាក្សត្រអេស្ប៉ាញ ធ្វើដំណើរជុំវិញពិភពលោកមុនគេ ។ លោកបើកសំពៅតម្រង់ទៅទិសខាងលិចជានិច្ច វាងទ្វីបអាមេរិកខាងត្បូង ហើយចូលមកប្រទេសរបស់លោកវិញ កាត់តាមប្រជុំកោះដែលសព្វថ្ងៃហៅថា ហ្វីលីពីន (Philippines) និងកាត់តាមប្រទេសឥណ្ឌា (Inde) ។ គ.ស. ១៥៦៥ ប្រទេសអេស្ប៉ាញវាយយកកោះហ្វីលីពីនបាន ។

Layout Histor.qxd 2/10/07 10:10 AM Page 184

នៅសម័យនោះ ប្រទេសអេស្ប៉ាញនិងប្រទេសព័រទុយហ្គាល់ជាមហាអំណាចខាងសមុទ្រ ហើយក៏ជាប្រទេសកាតូលិកដែរ ។ ហេតុនេះហើយ នៅគ.ស.១៤៩៤ អភិបាលក្រុងរ៉ូមឈ្មោះ**អាឡិចសង់ ទី ៦** (Alexandre VI) ក្នុងឋានៈជាអធិរាជលើស្តេចនានា ចែកពិភពលោកជាពីរផ្នែក ប្រគល់ឲ្យមហាអំណាចទាំងពីរ ។ ស្រុកទាំងប៉ុន្មានដែលស្ថិតនៅប៉ែកខាងលិចខ្សែបន្ទាត់ចម្ងាយ ៣២០ គ.ម. ពីទ្វីបអាហ្វ្រិក ពោលគឺខ្សែបន្ទាត់ចំកណ្តាលមហាសមុទ្រអាត្លង់ទិក (Atlantique) ត្រូវធ្លាក់នៅក្រោមអំណាចរបស់ប្រទេសអេស្ប៉ាញ ។ រីឯស្រុកទាំងប៉ុន្មានដែលនៅខាងកើតខ្សែបន្ទាត់ដដែលនេះ ត្រូវធ្លាក់នៅក្រោមអំណាចរបស់ប្រទេសព័រទុយហ្គាល់វិញ ។ លោកសម្រេចដូច្នេះ ដោយមានបំណងចៀសវាងកុំឲ្យប្រទេសដែលកាន់សាសនាកាតូលិកដូចគ្នាច្បាំងគ្នា ។ លោកក៏ប្រគល់ឲ្យមហាអំណាចទាំងពីរនូវបន្ទុកផ្សព្វផ្សាយគ្រីស្តសាសនា ក្នុងដែនដីថ្មីទាំងនោះថែមទៀតផង ។

អាស្រ័យហេតុនេះហើយ បានជាគេហៅទ្វីបអាមេរិកថា «*ឥណ្ឌាប៉ែកខាងលិច*» ធ្លាក់ក្រោមអំណាចរបស់ប្រទេសអេស្ប៉ាញ ។ ដោយពួកអ្នកផ្សងព្រេងជាតិអេស្ប៉ាញ រកឃើញកោះមួយចំនួនក្នុងមហាសមុទ្រប៉ាស៊ីហ្វិកមុនគេ កោះទាំងនោះក៏ធ្លាក់ក្រោមអំណាចស្តេចអេស្ប៉ាញដែរ រួចទទួលឈ្មោះថា «*ហ្វីលីពីន*» តាមព្រះនាមព្រះមហាក្សត្រអេស្ប៉ាញ (Philippe) ដែរ ។ ចំណែកឯ «*ឥណ្ឌាប៉ែកខាងកើត*» ពោលគឺចុងបូព៌ាប្រទេស ត្រូវធ្លាក់ក្រោមអំណាចរបស់ប្រទេសព័រទុយហ្គាល់វិញ ។

នៅគ្រានោះ ប្រទេសព័រទុយហ្គាល់មានប្រជាជនមិនលើសពីមួយលានកន្លះផង ។ ទោះបីប្រជាជនព័រទុយហ្គាល់មានជំនឿខាងគ្រីស្តសាសនាមាំមួនក៏ដោយ ក៏ប្រជាជនប្រទេសនេះពុំអាចនឹងរកបូជាចារ្យឲ្យគ្រប់ចំនួន ដើម្បីតែងតាំងគ្រីស្តសាសនា ក្នុងដែនដីដែលពួកគេវាយដណ្តើមយកបាននោះឡើយ ។ ហេតុនេះហើយ បានជាព្រះមហាក្សត្រអំពាវនាវសុំឲ្យក្រុមគ្រួសារបព្វជិតស្ម័គ្រចិត្តចាត់បព្វជិតទៅប្រកាសដំណឹងល្អនៅលើទឹកដីទាំងនោះ ។ បព្វជិតទាំងអស់នោះពុំនៅក្រោមការចាត់ចែងរបស់អភិបាលព្រះសហគមន៍ ដូចបូជាចារ្យឯទៀតៗទេ គឺគេនៅក្រោមអំណាចនាយកក្រុមគ្រួសាររបស់គេតែមួយគត់វិញ ។

ដោយព្រះចៅប្រទេសព័រទុយហ្គាល់អំពាវនាវរកក្រុមគ្រួសារបព្វជិតដូច្នេះ ទ្រង់ត្រួតត្រាលើបុគ្គលិកទាំងប៉ុន្មាន ដែលទ្រង់ចាត់បញ្ជូនទៅដែនដីថ្មីទាំងនោះ ។ បព្វជិតទាំងអស់ដែលមានមុខងារចេញទៅទ្វីបអាស៊ី ទោះជាសញ្ជាតិណាក៏ដោយ ក៏ត្រូវតែគាល់ព្រះមហាក្សត្រព័រទុយហ្គាល់ជាដាច់ខាត ដើម្បីឲ្យរាជការប្រទេសព័រទុយហ្គាល់ត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ។ បព្វជិតទាំងនោះដូចជាទទួលសញ្ជាតិព័រទុយហ្គាល់ ។ ព្រះមហាក្សត្ររ៉ាប់រងឲ្យបព្វជិតទាំងនោះធ្វើដំណើរតាមសំពៅរបស់ព្រះអង្គ ហើយទ្រង់ធានាផ្គត់ផ្គង់សោហ៊ុយថែមទៀតផង ។ ម្យ៉ាងទៀត ព្រះមហាក្សត្រសន្យាថា នឹងចេញប្រាក់សាងវិហារ និងគ្រឹះស្ថានផ្សេងៗសម្រាប់គ្រីស្តសាសនានៅដែនដីថ្មីៗទាំងនោះ ។ នៅពេលបព្វជិតទៅដល់ទីក្រុងហ្គោអា (Goa) អស់លោកត្រូវព្រះឧបរាជនៃប្រទេសព័រទុយហ្គាល់ត្រួតពិនិត្យម្តងទៀត មុននឹងបន្តដំណើរទៅកាន់ប្រទេសជប៉ុនឬប្រទេសចិន ។ លក្ខន្តិកៈនេះធ្វើឲ្យបព្វជិតទាំងនោះមិនចាំបាច់គោរពតាមបញ្ជារបស់អភិបាលព្រះសហគមន៍ ដែលពុំមែនជាជនជាតិព័រទុយហ្គាល់ ។

ចំពោះស្រុកទាំងប៉ុន្មានដែលធ្លាក់ក្រោមអំណាចប្រទេសអេស្ប៉ាញក៏ដូច្នោះដែរ គឺបព្វជិតទាំងប៉ុន្មានត្រូវចូលក្រុងម៉ាឌ្រីដ (Madrid) ជាមុនសិន ហើយបែរក្លាយជាទីភ្នាក់ងារបម្រើព្រះមហាក្សត្រអេស្ប៉ាញ ។ គេហៅរបបនោះថា «*របបស្តេចត្រួតត្រា*» (Patroado) ។

ព្រះមហាក្សត្រប្រទេសទាំងពីរ ហាក់ដូចជាមេដឹកនាំព្រះសហគមន៍នានា អភិបាលក្រុងរ៉ូមគ្រាន់តែទទួលស្គាល់អភិបាលដែលស្តេចទាំងពីរតែងតាំងប៉ុណ្ណោះ សភាពការណ៍នេះ ធ្វើឲ្យគ្រីស្តសាសនាភ្ជាប់នឹងរដ្ឋអំណាចអណានិគមនិយម ។

Layout Histor.qxd 2/10/07 10:10 AM Page 185

## ២- ទ្វីបអាហ្វ្រិក

កងទ័ពព័រទុយហ្គាល់នៅតែវាយអ៊ីស្លាមតទៅទៀត នៅអាហ្វ្រិកខាងជើង
102 រួចទៅដល់ចុងខាងត្បូងទ្វីបអាហ្វ្រិក តាំងពី គ.ស.១៤៨៦ ។ សាសនទូតចាប់ផ្ដើម
ប្រកាសដំណឹងល្អ ។ នៅពេលនោះ ស្ដេចស្រុកកុងហ្គោ (Congo) ទទួលអគ្គសញ្ញា
ជ្រមុជទឹក ។ មានព្រះសហគមន៍ជាតិកុងហ្គោកើតឡើង គេតែងតាំងបុត្រស្ដេច
103 ទៅជាអភិបាលទៀតផង ។ ស្ដេចបាត់បែងព្រះរាជាណាចក្រតាមរបៀបស្រុក
ព័រទុយហ្គាល់ តែទ្រង់មានបំណងការពារឯករាជ្យខាងនយោបាយនិងខាងសេដ្ឋ
កិច្ច ។ ស្ដេចស្រុកនោះមិនអនុញ្ញាតឲ្យជនជាតិព័រទុយហ្គាល់ជីករ៉ែត្បូងនៅស្រុកគេទេ ។ ពីពេលនោះមក កងទ័ពព័រទុយហ្គាល់ធ្វើសឹកសង្គ្រាម ហើយធ្វើគុតស្ដេចនោះ រួចលះបង់ស្រុកកុងហ្គោបោល ។ ពេលក្រោយ ជំនឿគ្រីស្ដបរិស័ទកុងហ្គោលាយឡំនឹងប្រពៃណីជាតិ ។ កងទ័ពព័រទុយហ្គាល់នាំគ្នាវាយសម្លាប់គ្រីស្ដបរិស័ទទាំងនោះ ។ ក្រោយមកទៀត ពួកព័រទុយហ្គាល់អាណានិគមនិយមចាប់ផ្ដើមចាប់ជនជាតិអាហ្វ្រិកធ្វើជាទាសករ ជាកិច្ចអាក្រក់បំផុត បណ្ដាលឲ្យអ្នកស្រុកស្អប់ខ្ពើមអ្នកកាន់គ្រីស្ដសាសនាទាំងនោះ ។

នៅសតវត្សទី ១៧ និង ១៨ សាសនទូតបារាំងទៅកាន់ទ្វីបអាហ្វ្រិក តែមិនសូវទទួលបានលទ្ធផលតាមបំណងទេ ។

### 102 លិខិតព្រះមហាក្សត្រស្រុកកុងហ្គោថ្វាយព្រះមហាក្សត្រប្រទេសព័រទុយហ្គាល់

*យើងខ្ញុំសូមទូលសុំព្រះករុណា កុំជឿពាក្យមួលបង្កាច់ឈ្មោះយើងខ្ញុំ អ្នកទាំងនោះមានបំណងតែមួយ គឺធ្វើពាណិជ្ជកម្ម ។ គេយកអ្វីៗដែលគេបានរឹបអូសមកដោយអយុត្តិធម៌ទៅលក់ឲ្យអ្នកដទៃ ។ ពួកគេបំផ្លាញព្រះសហគមន៍នៅក្នុងស្រុកយើងខ្ញុំជាយូរឆ្នាំមកហើយ ។ សាសនទូតដែលមកមុនៗបានរងទុក្ខយ៉ាងខ្លាំង ដើម្បីសាងសង់ព្រះសហគមន៍នោះ ។ (...) យើងខ្ញុំត្រូវតែរក្សាជំនឿទុក គឺជំនឿជាព្រះអំណោយទានដ៏ប្រសើរបំផុតនោះសម្រាប់អ្នកដែលជឿ ។ ប៉ុន្តែ យើងខ្ញុំលំបាករក្សាជំនឿទុកណាស់ ព្រោះមនុស្សល្ងង់ជក់ចិត្តនឹងទំនិញមកពីអឺរ៉ុបយ៉ាងខ្លាំង ហេតុនេះ គេលះបង់ព្រះជាម្ចាស់បោល ដើម្បីបានទំនិញទាំងនោះ ។ មានថ្នាំតែមួយគត់អាចកែសភាពការណ៍នេះបាន គឺបំបាត់ទំនិញទាំងនោះដែលជាអន្ទាក់ បង្អាក់ទាំងអ្នកទិញ ទាំងអ្នកលក់ ។ ដោយគេចង់បានចំណេញខ្លាំងពេក និងមានចិត្តលោភលន់ហួសហេតុ អ្នកស្រុកនាំគ្នាចាប់ជនរួមជាតិយកទៅលក់ជាទាសករ សូម្បីតែសាច់ញាតិរបស់គេ និងរបស់យើងខ្ញុំក៏គេលក់ដែរ ដោយមិនគិតថា អ្នកដែលគេចាប់យកទៅលក់នោះជាគ្រីស្ដបរិស័ទឬក៏អត់ គេយកទៅលក់ឬទៅដូរនឹងទំនិញផ្សេងៗ ។ យើងខ្ញុំមិនអាចកែការអាក្រក់ដ៏ធ្ងន់នេះបានទេ ត្រូវតែវាយនិងវាយយ៉ាងខ្លាំងថែមទៀតផង ។*

### 103 សេចក្ដីរាយការណ៍ពីសាសនទូតម្នាក់ (គ.ស. ១៦៩៦) សាសនទូតមិនចាប់អារម្មណ៍នឹងចិត្តគំនិតអ្នកស្រុក

*ខ្ញុំរំលំអាសនៈបូជាចារ្យរបស់គេ ។ មានលលាដ៍ក្បាលសត្វដោតលើបង្គោលជុំវិញអាសនៈនោះ គឺលលាដ៏ក្បាលធំមួយនិងតូចបួន ។ ស្ត្រីៗខ្លះឃើញខ្ញុំរំលំអាសនៈរបស់គេដូច្នេះ ត្អូញត្អែរថា «ពេលលោកថ្វាយអភិបូជា លោកក៏ធ្វើពិធីផ្សេងៗរបស់លោក ។ យើងក៏ចង់រក្សាទុកពិធីរបស់យើងដែរ (..) ។*

Layout Histor.qxd 2/10/07 10:10 AM Page 186

## ៣- ទ្វីបអាមេរិក

ជនជាតិអេស្ប៉ាញយកចិត្តទុកដាក់តែងតាំងព្រះសហគមន៍យ៉ាងមាំមួននៅ
ទ្វីបអាមេរិក គឺពួកគេបង្កើតទីស្ទងការជាអសនៈលោកអភិបាលចំនួន ៣៤ កន្លែង
ក្នុងអំឡុងឆ្នាំ ១៥១១-១៦២០ ។ អភិបាលភាគច្រើនជាគ្រីស្តបរិស័ទល្អ ហើយបាត់
បែងព្រះសហគមន៍ដោយយកចិត្តទុកដាក់ ។ ប៉ុន្តែ សាសនទូតជាច្រើនសម័យ
នោះចូលចិត្តសម្តែងឫទ្ធិអំណាចនៃគ្រីស្តសាសនា គេនាំគ្នាធ្វើពិធីបុណ្យយ៉ាងអធឹក
105 អធម បំផ្លាញរូបបដិមាព្រះនៃជនជាតិទាំងនោះ តំឡើងឈើឆ្កាងជំនួស ។ល ។
សាសនទូតភាគច្រើនមានបំណងបំផ្លាញសាសនា និងអរិយធម៌របស់អ្នកស្រុក
106 មានសាសនាជនជាតិអ៊ីនកា (Inca) ជាដើម ។ ប៉ុន្តែ មានសាសនទូតខ្លះសរសេរ
សៀវភៅប្រៀនប្រដៅគ្រីស្តសាសនា តែងធម្មទេសនា និងនិពន្ធល្ខោនតាមភាសា
របស់គេ ហើយនាំគ្នាសិក្សាអរិយធម៌បុរាណរបស់ជនជាតិទាំងនោះ ។ ស្តេចស្រុក
អេស្ប៉ាញខ្ចាល់នឹងសាសនទូតដែលសិក្សាអរិយធម៌ស្រុកគេ ហើយដុតសៀវភៅ
របស់លោកនោះចោល ។

នៅស្រុកខ្លះ បព្វជិតក្រុមគ្រួសារសហជីវិនព្រះយេស៊ូបង្កើតភូមិ ដែលមាន
សុទ្ធតែជនជាតិដើមរស់នៅ ដើម្បីការពារពួកគេមិនឲ្យអាណានិគមនិយមធ្វើបាប
គេបង្កើតភូមិទាំងស្រុងតាមលទ្ធិគ្រីស្តសាសនា គឺអ្នកភូមិដាក់ទ្រព្យសម្បត្តិរួមទាំង
អស់ ដូចមានចែងក្នុងកិច្ចការគ្រីស្តទូត ។

## ៤- អាមេរិកខាងជើង

បព្វជិតនៃក្រុមគ្រួសារសហជីវិនព្រះយេស៊ូ ចាប់ផ្តើមប្រកាសដំណឹងល្អ តែ
មិនសូវបានលទ្ធផលប៉ុន្មានទេ ។ សាសនទូតខ្លះបូជាជីវិតជាមរណសាក្សី ។

ដោយជនជាតិអឺរ៉ុបបង្កើតបច្ចេកទេសពូកែជាងគេ គេស្មានថា អរិយធម៌
និងសាសនារបស់គេប្រសើរជាងគេដែរ ។



*រូបព្រះរបស់ជនជាតិអ៊ីនកា (អាមេរិកខាងត្បូង)*

## 104 លោកបារថូឡូមេ ដេ ឡាស កាសាស្ស ទាមទារយុត្តិធម៌ក្នុងអាណានិគមអេស្ប៉ាញ

### ធម្មទេសនាបព្វជិតម៉ុនតេស៊ីណូស (Montesinos)

លោក**បារថូឡូមេ ដេ ឡាស កាសាស្ស** ការពារជនជាតិអ៊ីនកា *(Inca)* នៅអាមេរិកខាងត្បូងអស់មួយជីវិត (លោកទទួលមរណភាពនៅគ.ស. ១៥៦៦) ។ លោករៀបរាប់អំពីធម្មទេសនារបស់បព្វជិតដូមីនិកូម្នាក់ ដែលជំទាស់នឹងទាហានអេស្បាញ នៅគ.ស. ១៥១១ ។

*(..) អស់លោករស់នៅដោយជាប់អំពើបាបយ៉ាងធ្ងន់ ហើយក៏រស់និងស្លាប់ដោយជាប់អំពើបាបធ្ងន់នោះដែរ ព្រោះអស់លោកឃោរឃៅពេក តែងតែជិះជាន់សង្កត់សង្កិនប្រជាជនទាំងប៉ុន្មានដែលគ្មានទោសសោះ ។ សូមប្រាប់មក! តើអស់លោកអះអាងលើសិទ្ធិអ្វី លើយុត្តិធម៌ណាមកបង្ក្រាប ជនជាតិអ៊ីនកាយ៉ាងព្រៃផ្សៃបែបអាក្រក់បំផុតនេះ? តើនរណាអនុញ្ញាតឲ្យអស់លោកធ្វើសឹកសង្គ្រាមគួរឲ្យស្អប់ខ្ពើមទាំងនោះ ប្រឆាំងនឹងប្រជាជនដែលរស់នៅយ៉ាងស្រួល ប្រកបដោយសន្តិភាពកាលពីមុននោះ? តើនរណាអនុញ្ញាតឲ្យសម្លាប់ប្រជាជនរង្គាលយ៉ាងច្រើនអនេកដូច្នេះ? អស់លោកអាចជិះជាន់សង្កត់សង្កិនគេបែបនេះ ដោយគ្មានចែកអាហារឲ្យគេពិសា មិនមើលជំងឺរបស់គេ ។ ប៉ុន្តែ គេធ្លាក់ខ្លួនឈឺដូច្នេះ ព្រោះអស់លោកបង្ខំគេឲ្យធ្វើការហួសហេតុ ។ បើនិយាយត្រង់ អស់លោកសម្លាប់ពួកគេដើម្បីឲ្យគេរែរអង្គាសមាសយកមកសម្រាប់អស់លោកជារៀងរាល់ថ្ងៃ ។ តើអស់លោកមានបារម្ភថា ត្រូវធ្វើយ៉ាងណាឲ្យគេប្រែចិត្តជឿលើព្រះយេស៊ូដែរឬទេ? (...) អ្នកទាំងនោះក៏ជាមនុស្សដូចអស់លោកដែរ គេមានចិត្ត មានវិញ្ញាណ ចេះគិតចេះគូ ចេះស្រឡាញ់ដូចអស់លោក ។ ព្រះយេស៊ូបានបញ្ជាអស់លោកឲ្យស្រឡាញ់គេ ដូចស្រឡាញ់ខ្លួនឯងពិតឬមិនពិត? ។*

## 105 យើងមិនអាចធ្វើឱ្យគេលែងគោរពព្រះក្លែងក្លាយតែក្នុងមួយថ្ងៃប៉ុណ្ណោះទេ

*អស់លោកតម្លើងឈើឆ្កាង និងអញ្ជើញជនជាតិអ៊ីនកាឲ្យគោរពឈើឆ្កាងទាំងនោះ ពិតជាការល្អមែន លុះត្រាតែអស់លោកណែនាំគេឲ្យយល់អំពីអត្ថន័យនៃការគោរពនេះ ។ ផ្ទុយទៅវិញ បើអស់លោកគ្មានពេលគ្រប់គ្រាន់ទេ បើអស់លោកមិនចេះភាសារបស់គេ ការតម្លើងឈើឆ្កាងគ្មានប្រយោជន៍សោះ គ្មានបានការអ្វីឡើយ នាំឲ្យជនជាតិអ៊ីនកាស្មានថា អស់លោកនាំរូបព្រះមួយអង្គថ្មីទៀត ជារូបព្រះរបស់គ្រីស្តបរិស័ទ ។ ដូច្នេះ អស់លោកជាស់តឿនគេឲ្យថ្វាយបង្គំដុំឈើទុកជាព្រះ គឺពិតជានាំគេឲ្យគោរពរូបព្រះក្លែងក្លាយមែន ។*

*សេចក្តីដែលត្រូវធ្វើ គឺវិន័យដែលគ្រីស្តបរិស័ទត្រូវតែអនុវត្តតាម នៅពេលខ្លួននៅក្នុងតំបន់សាសន៍ដទៃរស់នៅ គឺធ្វើអំពើល្អទុកជាគំរូដល់គេ តាមព្រះបន្ទូលព្រះសង្គ្រោះរបស់យើងថា «គេឃើញអំពើល្អដែលអ្នករាល់គ្នាធ្វើ ហើយនាំគ្នាលើកតម្កើងសិរីរុងរឿងព្រះបិតារបស់អ្នករាល់គ្នា» ហើយនាំឲ្យគេរាប់ថា ព្រះដែលមានមនុស្សគោរពយ៉ាងល្អបែបនេះ ពិតជាមានព្រះហឫទ័យល្អ និងជាព្រះដ៏ពិតប្រាកដដែរ ។*

*ឡាស កាសាស្ស ប្រវត្តិសាស្ត្រស្រុកឥណ្ឌា*

Layout Histor.qxd 2/10/07 10:10 AM Page 188

## ៥- ទ្វីបអាស៊ី

### *លោកហ្វ្រង់ស្វ័រសាវីយេ នៅស្រុកឥណ្ឌានិងនៅស្រុកជប៉ុន*

លោក**ហ្វ្រង់ស្វ័រសាវីយេ** (François Xavier) កើតនៅស្រុកអេស្ប៉ាញ នៅ គ.ស. ១៥០៦ ។ លោកចូលក្នុងក្រុមសហជីវិនព្រះយេស៊ូ ដែលចាត់លោកឲ្យ
107 ទៅប្រទេសឥណ្ឌា នៅគ.ស. ១៦៤២ ។ ទោះបីលោកមិនស្គាល់ភាសានិងអរិយធម៌របស់អ្នកស្រុកក្ដី ក៏លោកធ្វើអគ្គសញ្ញាជ្រមុជទឹកជូនមនុស្សរាប់ពាន់នាក់ នៅស្រុកឥណ្ឌា នៅជ្រោយម៉ាឡាកា និងនៅកោះឥណ្ឌូណេស៊ីដែរ ។

ក្រោយមក លោកទៅដល់ស្រុកជប៉ុនជាមួយមិត្តសំឡាញ់ខ្លះ (គ.ស. ១៥៤៩) ពេលនោះ លោកយល់ឃើញថា លោកត្រូវរៀនភាសាជប៉ុនជាចាំបាច់ និងត្រូវស្គាល់ទស្សនវិជ្ជារបស់អ្នកស្រុកយ៉ាងជ្រៅ ទើបលោកអាចប្រកាសដំណឹងល្អឲ្យគេបាន ។ ម៉្យាងទៀត លោកយល់ឃើញថា ត្រូវចំណាយពេលវេលាយ៉ាងយូរ ទើបមនុស្សប្រែចិត្តគំនិតយ៉ាងពិតប្រាកដបាន ។ ក្រោយមក លោកធ្វើដំណើរទៅស្រុកចិន ហើយទទួលមរណភាពមុននឹងចូលស្រុកចិន (នៅគ.ស. ១៥៥២) ។ ក្រុមគ្រួសារសហជីវិនព្រះយេស៊ូ ផ្សព្វផ្សាយលិខិតលោកសរសេរ និងរឿងដំណើរជីវិតរបស់លោក ឲ្យគ្រីស្ដបរិស័ទជាតិអឺរ៉ុបអាន បានជាលោកជាសាសនទូតមានឈ្មោះល្បីជាងគេ ។

107

### លោកហ្វ្រង់ស្វ័រ សាវីយេ ប្រកាសដំណឹងល្អនៅប្រទេសឥណ្ឌា

លោក**ហ្វ្រង់ស្វ័រ សាវីយេ** សរសេរលិខិតនេះនៅគ.ស. ១៥៥៤ បង្ហាញអំពីរបៀបលោកប្រកាសដំណឹងល្អនៅប្រទេសឥណ្ឌា ។ លោកមិនសូវរវីរវល់នឹងវប្បធម៌អ្នកស្រុកទេ ។ គ្រីស្ដបរិស័ទដើមដំបូងនៅប្រទេសកម្ពុជាទទួលការអប់រំតាមបែបនោះដែរ ។

*«(...) ខ្ញុំធ្វើអគ្គសញ្ញាជ្រមុជទឹកជូនមនុស្សមួយម៉ឺននាក់ ក្នុងរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ ។ ខ្ញុំធ្លាប់ធ្វើដូចតទៅ៖ ពេលខ្ញុំមកដល់ភូមិមួយ ដែលអ្នកភូមិហៅខ្ញុំមកដោយប្រាប់ថា មានបំណងចូលគ្រីស្ដសាសនា ខ្ញុំប្រមូលបុរសនិងក្មេងៗទាំងអស់នៅកន្លែងមួយ ។ ខ្ញុំចាប់ផ្ដើមប្រកាសថា មានព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ខ្ញុំបង្ហាត់គេឲ្យធ្វើសញ្ញាឈើឆ្កាងបីដង និងឲ្យគេអង្វរព្រះត្រៃឯក ដោយប្រកាសជំនឿលើព្រះជាម្ចាស់តែមួយព្រះអង្គ ។ ក្រោយមក ខ្ញុំសូត្រធម៌ «ខ្ញុំសូមទទួលសារភាព» «វិន័យទាំង ១០ ប្រការ» «ឱ! ព្រះបិតា» «បពិត្រព្រះនាងម៉ារី» និង «សម្ដេចក្សត្រី» ។ ខ្ញុំបកប្រែធម៌ទាំងនោះតាមភាសារបស់គេពីរឆ្នាំហើយ ខ្ញុំក៏ចងចាំធម៌ទាំងនោះរត់មាត់ដែរ (...) ។ ពួកគេទាំងចាស់ទាំងក្មេងសូត្រតាមទាំងអស់គ្នា (...) ។*

*ពេលសូត្រធម៌រួចហើយ ខ្ញុំពន្យល់ប្រការជំនឿនីមួយៗ និងវិន័យជាភាសារបស់គេ ។ បន្ទាប់មក ខ្ញុំឲ្យគេសូមព្រះជាម្ចាស់ជាព្រះអម្ចាស់នៃយើង លើកលែងទោសជាសាធារណៈ (...) ។ កាលខ្ញុំបញ្ចប់ធម្មទេសនា ខ្ញុំសួរមនុស្សទាំងអស់ ទាំងបុរស ទាំងក្មេងៗ តើគេជឿប្រការជំនឿយ៉ាងពិតប្រាកដ ឬយ៉ាងណា? គេតបឆ្លើយទាំងអស់គ្នាថា «ខ្ញុំជឿ» ។ ខ្ញុំសូត្រប្រការជំនឿទាំងនោះដោយសំឡេងខ្លាំងហើយសួរថា តើគេជឿប្រការនីមួយៗ ឬយ៉ាងណាដែរ ។ រីឯពួកគេបត់ដៃលើដើមទ្រូង ឆ្លើយមកខ្ញុំថា «ខ្ញុំជឿ» ។ ក្រោយមក ខ្ញុំធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ ហើយឲ្យឈ្មោះថ្មីគេជាលាយលក្ខអក្សរ ។ បុរសៗត្រឡប់ទៅផ្ទះវិញ ហើយចាត់ប្រពន្ធនិងកូនគេមក ។ ខ្ញុំធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យគេ ដូចខ្ញុំបានធ្វើពិធីជ្រមុជទឹកឲ្យបុរស ។ កាលខ្ញុំធ្វើពិធីជ្រមុជទឹករួចហើយ ខ្ញុំចាត់គេឲ្យទៅរំលំកន្លែងតម្កល់ព្រះក្លែងក្លាយរបស់គេ ។ នៅពេលគេជាគ្រីស្ដបរិស័ទរួចហើយ ខ្ញុំឲ្យគេកម្ទេចរូបបដិមាព្រះទាំងនោះ ។*

Layout Histor.qxd 2/10/07 10:10 AM Page 189

## *នៅប្រទេសកម្ពុជា*

សម័យនោះ ប្រទេសកម្ពុជានៅតែកើតសង្គ្រាមជាមួយស្រុកសៀមឥតឈប់ឈរ ។ គ.ស. ១៥១៥ ស្ដេចកម្ពុជាព្រះនាមព្រះបាទ**អង្គច័ន្ទទី ១** (១៥១៥-១៥៦៦) ទាក់ទងជាមួយឈ្មួញជាតិព័រទុយហ្គាល់ ដែលទើបមកដល់កោះជ្វា (Java) សុំទិញកាំភ្លើងធំចំនួន ១៥០ គ្រឿង និងស្នាពិសេស ២០០០ ដើម ។ នៅគ.ស. ១៥២៥ ទ្រង់វាយបង្ក្រាបកងទ័ពសៀមឲ្យបរាជ័យនៅក្នុងតំបន់អង្គរ ។ ដូច្នេះហើយ បានជាទ្រង់ដាក់ឈ្មោះទីនោះថា «សៀមរាប» គឺសៀមបាញ់រាបដូចកន្ទេល ។ ព្រះអង្គក៏តាំងរាជធានីនៅលង្វែកវិញ ដើម្បីឲ្យបានសន្តិសុខរឹងមាំល្អ ។

គ.ស. ១៥៥៥ ពួកព័រទុយហ្គាល់ដែលរស់នៅក្រុងលង្វែក អញ្ជើញសាសនទូតម្នាក់ឲ្យមកប្រកាសជំណឿងល្អនៅក្រុងនោះ ដោយប្រាប់លោកថា ស្ដេចនិងប្រជាជនខ្មែរចង់ទៅជាគ្រីស្ដបរិស័ទ ។ ដូច្នេះ លោក**កាសប៉ារដាគ្រូស** (Gaspar da Cruz) មករស់នៅក្រុងលង្វែកអស់មួយឆ្នាំ ។ មានសាសនទូតឯទៀតៗមកបន្តបន្ទាប់ លទ្ធផលមិនសូវបានតាមបំណង ព្រោះតែសង្គ្រាមនៅក្នុងស្រុកកើតជាញយផង ។ *(សូមអាន «ប្រវត្តិព្រះសហគមន៍នៅប្រទេសកម្ពុជា» ទំព័រ ២៧-៣៨)*

នៅឆ្នាំ ១៧៦៨ លោក**ឡឺ វ៉ាវ៉ាស័រ** (Le Vavasseur) ជាជនជាតិបារាំងចាប់ផ្ដើមប្រកាសដំណឹងល្អនៅប្រទេសកម្ពុជា ។ មុនដំបូងលោកទៅកំពង់ស្វាយរួចលោកទៅភូមិប្រាំបីឆោម ។ លោកតែងតាំងក្រុមគ្រួសារបព្វជិតាស្រឡាញ់ឈើឆ្កាង ផ្ដាច់ឈើឆ្កាងព្រះយេស៊ូ ដែលមានរហូតមកសព្វថ្ងៃ ។ លោកបានបង្កើតទេវវិទ្យាល័យសម្រាប់អប់រំគ្រីស្ដបរិស័ទឲ្យទៅជាបូជាចារ្យ ហើយក៏និពន្ធសៀវភៅជាភាសាខ្មែរជាច្រើនដែរ ។ ប៉ុន្តែ ឆ្នាំ ១៧៨៤ កងទ័ពរបស់ពួកតៃសុន (ជាចោរព្រៃពួកអាណ្ណាម) ចូលលុកលុយស្រុកខ្មែរ ដុតបំផ្លាញព្រះវិហារចោល កៀរទាំងគ្រីស្ដបរិស័ទ ទាំងបូជាចារ្យទៅផ្សារដែក ។ ឆ្នាំក្រោយ កងទ័ពសៀមកៀរគ្រីស្ដបរិស័ទទាំង ៩០០ នាក់ទៅបាងកក (ស្រុកសៀម) ។



*ជនជាតិព័រទុយហ្គាល់នាំយកបដិមានាងម៉ារីមកស្រុកខ្មែរ*

Layout Histor.qxd 2/10/07 10:10 AM Page 190

## ប្រទេសជប៉ុន

សម័យនោះ ជនជាតិជប៉ុនចូលចិត្តបច្ចេកទេសអឺរ៉ុប ជាបច្ចេកទេសទំនើប កំពុងល្បួតលាស់ ។ ម្យ៉ាងទៀត ជប៉ុនមានរបបសក្តិភូមិ ហើយស្តេចត្រាញ់ចូលចិត្តកាន់គ្រីស្តសាសនា ដើម្បីបម្រះខ្លួនចេញពីអំណាចព្រះចៅអធិរាជ ដែលគេគោរពថ្វាយបង្គំទុកជាព្រះរបស់ប្រជាជាតិទាំងមូល ។ មិនយូរប៉ុន្មាន ជនជាតិជប៉ុនប្រមាណ ៣00.000 នាក់ រស់នៅប៉ែកខាងត្បូងស្រុកជប៉ុនបែរជាគ្រីស្តបរិស័ទ ។ ប៉ុន្តែ ព្រះចៅនិងពួកមន្ត្រីចង់បង្ក្រាបស្តេចត្រាញ់ ហើយនាំគ្នាធ្វើទុក្ខបុកម្នេញដល់គ្រីស្តបរិស័ទ ។ នៅគ.ស. ១៥៩៧ រដ្ឋអំណាចឆ្កាងសាសនទូតនិងគ្រីស្តបរិស័ទ ២៦ នាក់នៅលើភ្នំតូចក្បែរក្រុងណាកាសាគី ។ គ.ស. ១៦១៤ រដ្ឋអំណាចមិនឲ្យមានគ្រីស្តសាសនានៅប្រទេសជប៉ុនដាច់ខាត ។ គេធ្វើទារុណកម្មគ្រីស្តបរិស័ទយ៉ាងឃោរឃៅបំផុត ។ គ.ស. ១៦៣៥ គេសម្លាប់គ្រីស្តបរិស័ទ ៣៥.000 នាក់ រួចហាមសាសនទូតបរទេសចូលស្រុកជប៉ុនទៀតរហូតដល់សតវត្សទី ១៩ ។

នៅពេលរដ្ឋអំណាចធ្វើទុក្ខបុកម្នេញគ្រីស្តបរិស័ទដូច្នេះ គ្រីស្តបរិស័ទខ្លះភៀសខ្លួនមករស់នៅប្រទេសកម្ពុជា ខាងត្បូងពញាឮ ។ *(ប្រវត្តិព្រះសហគមន៍ ទំព័រ ៤៤)*

សាសនទូតបរទេសយកចិត្តទុកដាក់រៀនភាសាជប៉ុន សិក្សាអំពីអរិយធម៌ស្រុកគេ ។ គេអប់រំបូជាចារ្យជាតិជប៉ុន (នៅគ.ស. ១៦១៤ មានបូជាចារ្យ ចំនួន ១៤ នាក់) ហើយចាត់ចែងព្រះសហគមន៍ឲ្យរស់នៅដោយគ្មានបូជាចារ្យបាន ។ ប៉ុន្តែ ព្រះសហគមន៍នៅតែរស់ដោយទទួលជំនួយពីទ្វីបអឺរ៉ុប ។ ការនេះបណ្តាលឲ្យមានការលំបាកដល់ការប្រកាសដំណឹងល្អ ។



*រដ្ឋអំណាចជប៉ុនឆ្កាងគ្រីស្តបរិស័ទនៅណាកាសាគី (១៥៩៧)*

Layout Histor.qxd 2/10/07 10:10 AM Page 191

## *ប្រទេសឥណ្ឌា*

គ្រីស្តបរិស័ទជាតិឥណ្ឌាតែងតែតំណាលថា គ្រីស្តទូត**ថូម៉ាស**មកប្រកាសដំណឹងល្អឲ្យជូនតារបស់គេតាំងពីដើមរៀងមក ។ តាមពិត មានគ្រីស្តបរិស័ទនៅខាងត្បូងទ្វីបឥណ្ឌា តាំងពីសតវត្សទី ៥ តែប៉ុណ្ណោះ ។ ពួកគេនិយាយភាសាស៊ីរី ហើយជាប់ទាក់ទិនជាមួយព្រះសហគមន៍ តាមលោក**ណេស្តូរីយ៉ូស** ។ នៅពេលជនជាតិព័រទុយហ្គាល់មកដល់ក្រុងហ្គោអា (Goa) គេចង់បង្ខំគ្រីស្តបរិស័ទឥណ្ឌាទាំងនោះ ឲ្យចុះចូលក្រោមអំណាចអភិបាលក្រុងរ៉ូម ។ គ្រីស្តបរិស័ទឥណ្ឌាឈ្លោះប្រកែក និងបែកចេញពីពួកគេ ។

ជនជាតិព័រទុយហ្គាល់តែងតាំងអសនៈរបស់លោកអភិបាលមួយនៅក្រុងហ្គោអានោះ (គ.ស. ១៥៣៣) ។ អភិបាលនោះត្រួតតំបន់បូព៌ាទាំងមូល គឺចាប់ពីចុងទ្វីបអាហ្វ្រិករហូតដល់ស្រុកចិន ។ ជនជាតិព័រទុយហ្គាល់ខិតខំប្រកាសដំណឹងល្អ ដោយមិនគិតអំពីអរិយធម៌ប្រជាជនឥណ្ឌាទេ ។ ពួកគេធ្វើអគ្គសញ្ញាជ្រមុជទឹកជូនមនុស្សជាច្រើន តែមិនតាំងព្រះសហគមន៍ពិតប្រាកដទេ ។

លោក**រ៉ូបែរត៍ នៅណូប៊ីលី** (Robert de Nobili) ជាជនជាតិអ៊ីតាលីម្នាក់ និងជាសមាជិកនៃក្រុមគ្រួសារសហជីវិនព្រះយេស៊ូ (១៥៧៧-១៦៥៦) ។ លោកមកដល់ប្រទេសឥណ្ឌានៅគ.ស. ១៦០៥ ។ លោករស់នៅ ៥០ ឆ្នាំ នៅក្រុងម៉ាឌូរេខាងត្បូងស្រុកឥណ្ឌា ។ លោករៀនភាសាជនជាតិទមិឡ (Tamul) និងសំស្ក្រិត ។ លោកមិនព្រមឲ្យអ្នកស្រុករាប់លោកទុកជាអាណានិគម ដូចជនជាតិបរទេសឯទៀតៗទេ គឺលោកចង់ឲ្យអ្នកស្រុករាប់លោក ជាអ្នកកាន់សីលតាមសាសនាហិណ្ឌូ ។ គាត់រស់នៅដូចព្រាហ្មណ៍ម្នាក់ ហើយសុខចិត្តឲ្យអ្នកជឿលើព្រះគ្រីស្ត កាន់តាមប្រពៃណីវណ្ណៈរបស់ខ្លួន គឺឲ្យគេចងបួងសក់ ទុកខ្សែ ។ល។ នៅក្នុងពិធីអគ្គសញ្ញាជ្រមុជទឹក លោកមិនព្រមធ្វើពិធីដែលជនជាតិឥណ្ឌាខ្ពើម មានពិធីផ្លុំខ្យល់ និងពិធីដាក់ទឹកមាត់នៅអណ្តាតគេ តាមរបៀបគ្រីស្តបរិស័ទអឺរ៉ុបជាដើម ។ តែរបៀបលោកណូប៊ីលី ប្រព្រឹត្តនោះ នាំឲ្យសាសនទូតខ្លះខឹងក្តៅក្រហាយ ប្តឹងទៅលោកអភិបាលព្រះសហគមន៍ក្រុងរ៉ូម ។ តែអភិបាលក្រុងរ៉ូមយល់ស្របនឹងសេចក្តីខ្លះដែលលោកកែសម្រួលនោះ (គ.ស. ១៦២៣) ។

គ្រីស្តបរិស័ទខាងលោក**លូធែរ**មករស់នៅប្រទេសឥណ្ឌា នៅគ.ស. ១៧០៦ ។ បងប្អូនប្រូតេស្តង់ ចាត់សាសនទូតទៅក្រៅប្រទេសអាល្លឺមង់ដូច្នេះជាលើកដំបូង ។ នៅគ.ស. ១៧៣៣ គេតែងតាំងគ្រូគង្វាលជាតិឥណ្ឌាមុនគេ ។



*រូបសាសនាឥណ្ឌា*

Layout Histor.qxd 2/10/07 10:10 AM Page 192

## ប្រទេសចិន

គ.ស. ១៥៥៧ ជនជាតិព័រទុយហ្គាល់តាំងទីលំនៅក្រុងម៉ាកាវ (Macao) ។ ក្រុមគ្រួសារសហជីវិនព្រះយេស៊ូកសាងជំណាក់នៅក្រុងនោះ (គ.ស. ១៥៦៥) ។ មិនសូវយូរប៉ុន្មាន ពួកគេក៏តែងតាំងអភិបាលម្នាក់នៅក្រុងនោះដែរ ។ ពួកគេបង្ខំឲ្យគ្រីស្តបរិស័ទចិនកាត់សក់ និងរស់នៅតាមរបៀបអឺរ៉ុប ។ នៅគ.ស. ១៥៧៨ គេចាត់សហជីវិនព្រះយេស៊ូពីរនាក់ឲ្យទៅរស់នៅក្នុងប្រទេសចិន អ្នកទាំងពីរនោះគឺ
107 លោក**រូស៊ីយេរី** (Ruggiéri) និងលោក**ម៉ាថេអូ រីជី** (Mateo Ricci) ។ លោករីជីធ្វើដំណើរទៅដល់ក្រុងប៉េកាំង ហើយលោករស់នៅទីនោះរហូតដល់ពេលទទួលមរណភាពនៅ គ.ស. ១៦១០ ។

ដំបូងលោករីជី ចង់រស់ដូចលោកសង្ឃខាងពុទ្ធសាសនាមួយអង្គ ។ លោករៀនភាសាចិននិងអរិយធម៌ចិនយ៉ាងជ្រៅជ្រះ ទើបលោកយល់អំពីឋានៈដ៏ខ្ពង់ខ្ពស់របស់អ្នកចេះដឹងជាកូនសិស្សលោក**ខុងជឺ** ។ លោកយល់ឃើញថា លទ្ធិលោកខុងជឺមិនសូវប្លែកពីលទ្ធិគ្រីស្តសាសនាទេ រីឯលទ្ធិតៅនិងលទ្ធិព្រះពុទ្ធប្លែកខុសឆ្ងាយវិញ ។ ហេតុនេះហើយ បានជាលោកបែរមកពាក់អាវរបស់អ្នករៀនសូត្រខ្ពស់ រស់នៅដូចគេដែរ ។ លោកនាំឲ្យជនជាតិចិនស្គាល់វិទ្យាសាស្ត្របស្ចិមប្រទេស មានតារាសាស្ត្រនិងគណិតវិទ្យាជាដើម ។ លោករៀបរាប់អំពីលទ្ធិគ្រីស្តសាសនានៅក្នុង
108 សៀវភៅជាភាសាចិន មានចំណងជើងថា «*សេចក្តីរៀបរាប់ដ៏ពិតប្រាកដអំពីលទ្ធិទៅកាន់ស្ថានបរមសុខ*» ។ តែគ្រីស្តបរិស័ទចិនជួបប្រទះបញ្ហាជាច្រើន ឧប.

- តើគ្រីស្តបរិស័ទចិនមានសិទ្ធិគោរពដូនតានិងលោកខុងជឺដូចគេដូចឯងបានទេ?
- តើត្រូវជ្រើសរើសពាក្យពេចន៍ណាដើម្បីពន្យល់លទ្ធិគ្រីស្តសាសនា ដោយមិនបណ្តាលឲ្យជនជាតិចិនយល់ច្រឡំ?
- តើត្រូវធ្វើដូចម្តេច ដើម្បីបង្កើតក្រុមបូជាចារ្យចិន? តើត្រូវអប់រំបូជាចារ្យចិននៅកន្លែងណា? តើចាំបាច់ឲ្យគេរៀនភាសាឡាតាំងឬយ៉ាងណា?

នៅគ.ស. ១៦១៥ អភិបាលក្រុងរ៉ូម **ប៉ូលទី ៥** អនុញ្ញាតឲ្យគេបកប្រែគម្ពីរនិងអត្ថបទសម្រាប់សូត្រក្នុងពិធីនានាជាភាសាចិន តែមិនឲ្យគ្រីស្តបរិស័ទចិនធ្វើពិធីបុណ្យតាមរបៀបចិនទេ ។ ព្រះចៅអធិរាជចិនសព្វព្រះទ័យនឹងសហជីវិនព្រះយេស៊ូជាអ្នកប្រាជ្ញ ដែលនាំប្រតិទិន បច្ចេកទេសផលិតកាំភ្លើងជាដើម ។ នៅគ.ស. ១៦៨៨ ស្តេចប្រទេសបារាំងចាត់សហជីវិនព្រះយេស៊ូ ជាអ្នកបច្ចេកទេសខាងគណិតវិទ្យាទៅស្រុកចិន ។

នៅចុងសតវត្សទី ១៧ មានគ្រីស្តបរិស័ទចិនប្រហែល ៣00.000 នាក់ និងសាសនទូត ១២០ នាក់ ។ ប៉ុន្តែ កើតជម្លោះក្នុងព្រះសហគមន៍អំពីរបៀបធ្វើពិធី



*លោករូស៊ីយេរី និងលោកម៉ាថេអូរីជី នៅស្រុកចិន*

នានា នឹងអំពីអំណាចស្ដេចព័រទុយហ្គាល់ដែលទាស់ទែងនឹងអំណាចអភិបាលក្រុងរ៉ូម បណ្ដាលឲ្យព្រះចៅអធិរាជចិនខ្វាល់ ហើយបែរទៅជាបៀតបៀនធ្វើបាបគ្រីស្ដបរិស័ទវិញ ។ ទ្រង់សព្វព្រះហឫទ័យតែនឹងសហជីវិនព្រះយេស៊ូជាអ្នកប្រាជ្ញប៉ុណ្ណោះ ។ តែមិនយូរប៉ុន្មាន អភិបាលក្រុងរ៉ូមបិទក្រុមគ្រួសារសហជីវិនព្រះយេស៊ូ (នៅឆ្នាំ ១៧៦២) បញ្ហានេះ បណ្ដាលឲ្យព្រះសហគមន៍កាតូលិកនៅស្រុកចិនកាន់តែលំបាកឡើងៗ ។

## 107 លោកម៉ាថេអូរីជីបង្កើតរបៀបថ្មីសម្រាប់ប្រកាសដំណឹងល្អ

*លោក**ម៉ាថេអូ**ស្លៀកពាក់សម្លៀកបំពាក់របស់អ្នកចេះដឹង ជាពិសេសសម្លៀកបំពាក់របស់អ្នកប្រកាសធម្មវិន័យរបស់គេ ។ សម្លៀកបំពាក់នេះមិនអស្ចារ្យទេ ហើយមួកគេក៏មិនសូវ ប្លែកពីមួករបស់យើងដែរ គឺមានរាងដូចឈើឆ្កាង ។ លោកតែងតែបង្ហាញខ្លួនថា ជាអ្នកប្រកាសធម្មវិន័យរបស់ព្រះជាម្ចាស់ មិនគ្រាន់តែដោយពាក់សម្លៀកបំពាក់ប៉ុណ្ណោះទេ ជាពិសេសទៅទៀតដោយថ្លែងសេចក្ដី ។ លោកឧស្សាហ៍ជជែកវែកញែកសាសនាពីររបស់ព្រះក្លែងក្លាយ គឺសាសនាតៅនិងពុទ្ធសាសនា ។ រីឯសាសនារបស់អ្នកចេះដឹង លោកមិនស្ដីបន្ទោសទេ ។ តែផ្ទុយទៅវិញ លោកសរសើរជាខ្លាំង សូមឲ្យគេទុកចិត្តលោក**ខុងជឺ**ជាម្ចាស់សាសនានោះ ។ លោកខុងជឺចូលចិត្តនៅស្ងៀមជាជាងតំណាលរឿងព្រេងអំពីជីវិតនៅលោកខាងមុខដែលលោកមិនស្គាល់ ។ លោកយកចិត្តទុកដាក់រស់នៅស្របតាមធម្មវិន័យរបស់លោក អប់រំមនុស្សឲ្យត្រួតត្រាទាំងក្រុមគ្រួសារទាំងស្រុកទេស តាមច្បាប់ និងតាមយុត្តិធម៌ ។*

*របៀបស្លៀកសម្លៀកបំពាក់ និងរបៀបដើរនៅទីសាធារណៈដូចជារបៀបថ្មី តែអ្នកចេះដឹងពេញចិត្ត និងយល់ស្របយ៉ាងខ្លាំង (..) ។ លោកម៉ាថេអូ និពន្ធសេចក្ដីសង្ខេបនៃលទ្ធិគ្រីស្ដសាសនាជាភាសាចិន តាមរបៀបអ្នកកាន់សាសនាដទៃពេញចិត្ត ។*

## 108 អគ្គសញ្ញាជ្រមុជទឹកជូនដល់ក្មេងហៀបនឹងស្លាប់នៅស្រុកចិន

នៅសម័យនោះ សាសនទូតបារម្ភអំពីការសង្គ្រោះរបស់ក្មេងៗដែលស្លាប់ដោយមិនបានទទួលអគ្គសញ្ញាជ្រមុជទឹក ។ ហេតុនេះ សាសនទូតនាំគ្នាធ្វើពិធីជ្រមុជទឹកឲ្យក្មេងៗជាច្រើនអនេក ដូចសហជីវិនព្រះយេស៊ូរៀបរាប់ខាងក្រោមនេះ ។

*រៀងរាល់ឆ្នាំ មានក្មេងៗប្រមាណ ៥០០០ ឬ ៦០០០ នាក់ទទួលពិធីជ្រមុជទឹក ដែលជម្រះខ្លួនវាក្នុងព្រះវិហារនីមួយៗនៅក្រុងប៉េកាំង ។ យើងប្រួចទឹកលើក្មេងច្រើនឬតិច តាមចំនួនគ្រូដែលយើងអាចចិញ្ចឹមបាន ។ ប្រសិនបើយើងមានចំនួនគ្រូគ្រប់គ្រាន់ យើងមិនគ្រាន់តែធ្វើពិធីជ្រមុជទឹកដល់ក្មេងៗហៀបនឹងស្លាប់ ដែលគេបោះបង់បោលប៉ុណ្ណោះទេ គឺយើងមានឱកាសជាច្រើន ជាពិសេសក្នុងខែដែលមានជំងឺរាតត្បាត បណ្ដាលឲ្យក្មេងរាប់មិនអស់ត្រូវស្លាប់ (...) ។ ជាញឹកញាប់ ជនជាតិចិនដែលគ្មានលទ្ធភាពចិញ្ចឹមកូនច្រើន បង្គាប់ឲ្យឆ្មបយកកូនស្រីទើបកើត សង្គ្រុបក្នុងផើងទឹកសម្លាប់ ។ ប្រសិនបើយើងមានឆ្មបជាគ្រីស្ដបរិស័ទ កូនស្រីដែលរងគ្រោះដោយឪពុកម្ដាយវាក្រពេក នឹងបានជីវិតអស់កល្បជានិច្ច ក្នុងទឹកដដែលដែលដកជីវិតដ៏ខ្លីរបស់វានោះ ។*

*លោកអនត្រកូល ប៉េកាំង ថ្ងៃទី ១៩ តុលា ឆ្នាំ ១៧២០*

Layout Histor.qxd 2/10/07 10:10 AM Page 194

## ២- ឥណ្ឌូចិន

ពេលព្រះចៅជប៉ុនបៀតបៀនធ្វើបាបគ្រីស្តបរិស័ទជប៉ុន គ្រីស្តបរិស័ទជប៉ុនមួយចំនួនភៀសខ្លួនទៅស្រុកកូសាំងស៊ីន (ហ្វៃហ្វឺ) ស្រុកខ្មែរ (ពញាឮ) និងស្រុកសៀម (អយុធ្យា) ។ ចាប់ពីគ.ស. ១៦១៥ មក ក្រុមគ្រួសារសហជីវិនព្រះយេស៊ូចាប់អារម្មណ៍នឹងប្រទេសទាំងនោះ ។ អស់លោកយកអក្សរឡាតាំងមកសរសេរភាសាវៀតណាម ។ លោក**អាឡិចសង់ នៅរ៉ូដ៍** (Alexandre de Rhodes) ជាប់ចិត្តរស់នៅស្រុកវៀតណាមយ៉ាងខ្លាំងអស់រយៈពេល ២០ ឆ្នាំ (១៦២៥-១៦៤៥) ។ លោកយកចិត្តទុកដាក់រៀនភាសាវៀតណាម អប់រំអ្នកណែនាំ ព្រមទាំងគោរពអរិយធម៌វៀតណាម និងខិតខំយល់អត្ថន័យប្រពៃណីរបស់គេ ។ គាត់មានបំណងចង់បង្កើតក្រុមបូជាចារ្យជាតិវៀតណាមទៀតផង ។

## ៣- អភិបាលព្រះសហគមន៍តំណាងលោកអភិបាលក្រុងរ៉ូម


*លោកឡាំបែរត៍ នៅឡាមុត*

អភិបាលក្រុងរ៉ូមតែងតាំងអភិបាលតំណាងរបស់លោក ដើម្បីបម្រើព្រះសហគមន៍ប្រទេសមានគ្រីស្តបរិស័ទចំនួនតិច ។ ដូច្នេះ ព្រះសហគមន៍រើបម្រះពីអំណាចមហាក្សត្រព័រទុយហ្គាល់និងអេស្ប៉ាញ ដែលត្រួតត្រាអភិបាល បូជាចារ្យ និងបព្វជិតទាំងអស់ ។ លោក**អាឡិចសង់ ទី ៧** ជាអភិបាលក្រុងរ៉ូម តែងតាំង
109 លោក**ឡាំបែរត៍ នៅឡាមុត** (Lambert de La Motte) និងលោក**ហ្វ្រង់ស្វ័រ ប៉ាល្លឺ** (François Pallu) ជាអភិបាលតំណាងរបស់លោក (Vicaire Apostolique) ។ អស់លោកមកដល់ប្រទេសសៀមនៅ គ.ស. ១៦៦៤ ហើយតែងតាំងបូជាចារ្យជាតិវៀតណាមមុនគេ រួចបង្កើតទេវវិទ្យាល័យនៅប្រទេសសៀមសម្រាប់ចុងបូព៌ាទាំងមូល ។

*(សូមអានប្រវត្តិព្រះសហគមន៍នៅប្រទេសកម្ពុជា ទំព័រ ៤៩-៦៦)*

## ៤- កំណើតព្រះសហគមន៍នៅស្រុកកូរ៉េ

នៅសតវត្សទី ១៧ និង ១៨ អ្នករៀនសូត្រជាតិកូរ៉េ ទទួលសៀវភៅខាងគ្រីស្តសាសនាមកពីស្រុកចិន ។ នៅគ.ស. ១៧៨៤ ជនជាតិកូរ៉េម្នាក់ធ្វើដំណើរទៅក្រុងប៉េកាំង ហើយទទួលអគ្គសញ្ញាជ្រមុជទឹកនៅទីនោះ ។ នៅពេលត្រឡប់មក
ស្រុកកូរ៉េវិញ គាត់និងអ្នករៀនសូត្រឯទៀតៗបង្កើតទេវវិទ្យាម៉្យាងតាមលទ្ធិ**ខុងជឺ** 110
ហើយតែងតាំងព្រះសហគមន៍មួយ ទាំងធ្វើអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលើកលែងទោស និងអភិបូជា ។ល។ តែគាត់មានមន្ទិលសង្ស័យខ្លះមិនដឹងថា គាត់ធ្វើដូច្នេះត្រឹមត្រូវឬយ៉ាងណា សូមឲ្យព្រះសហគមន៍នៅប៉េកាំងចាត់បូជាចារ្យម្នាក់ទៅស្រុកកូរ៉េ ។ តែនៅពេលនោះ រដ្ឋអំណាចបៀតបៀនធ្វើបាបព្រះសហគមន៍ថ្មី ហើយគ្មានបូជាចារ្យបរទេសណាអាចចូលប្រទេសកូរ៉េបានទេ ។

## ៥- វិបត្តិអំពីពិធីបុណ្យនៅប្រទេសឥណ្ឌានិងចិន

នៅប្រទេសឥណ្ឌានិងប្រទេសចិន សាសនទូតខ្វែងគំនិតគ្នាអំពីពាក្យដែលត្រូវយកមកប្រើសម្រាប់ហៅព្រះជាម្ចាស់តាមភាសារបស់អ្នកស្រុក ព្រមទាំងអំពីពិធីបុណ្យនានា និងពិធីតាមប្រពៃណីប្រជាជាតិទាំងនោះ ។ សហជីវិនព្រះយេស៊ូសុខចិត្តសម្របសម្រួលពិធីនៃគ្រីស្តសាសនាទៅតាមទម្លាប់អ្នកស្រុក រីឯសាសនទូតឯទៀតៗស្មានថា ធ្វើដូច្នេះនាំឲ្យគេច្រឡំ និងគោរពព្រះក្លែងក្លាយ ។ ជម្លោះអំពីពិធីបុណ្យក៏មានជាប់ទាក់ទងនឹងជម្លោះស្តេចព័រទុយហ្គាល់និងអេស្ប៉ាញ ដណ្តើមអំណាច ប្រឆាំងនឹងអភិបាលក្រុងរ៉ូមដែរ ។ នៅទ្វីបអឺរ៉ុបក៏មានជម្លោះខាងទេវវិទ្យាដែរ គឺមានគ្រីស្តបរិស័ទកាន់តាមរបៀបតឹងរ៉ឹង (កាន់តាមលោកយ៉ង់សេន) និងគ្រីស្តបរិស័ទខ្លះធូរវិញ (កាន់តាមលោកម៉ូលីណា) ។

គ.ស. ១៦៩៣ អភិបាលតំណាងអភិបាលក្រុងរ៉ូមនៅប្រទេសចិន ហាមគ្រីស្តបរិស័ទប្រើពាក្យរបស់ក្រុមគ្រួសារសហជីវិនព្រះយេស៊ូ សម្រាប់ហៅព្រះជាម្ចាស់

Layout Histor.qxd 2/10/07 10:10 AM Page 195

## 109 លិខិតប្រៀនប្រដៅនៅ គ.ស. ១៦៥៩

អភិបាលក្រុងរ៉ូម **អាឡិចសង់ ទី ៧** តែងតាំងនិងចាត់អភិបាលជាតំណាងរបស់លោក ដើម្បីរំដោះសាសនទូតឲ្យរួចពីអំណាចស្ដេចព័រទុយហ្គាល់និងស្ដេចអេស្ប៉ាញ ។ លោកផ្ដល់ដំបូន្មានយ៉ាងល្អប្រសើរដល់អភិបាលតំណាងរបស់លោក ។

សូមកុំខ្នះខ្នែង កុំជជែកដេញដោល បញ្ចុះបញ្ចូលប្រជាជនទាំងនោះ ឲ្យដូរពិធីដូរទំនៀមទម្លាប់ ឬប្រពៃណីរបស់ពួកគេសោះឡើយ លើកលែងតែទំនៀមទម្លាប់ណា ឬប្រពៃណីណាដែលមានលក្ខណៈផ្ទុយនឹងសាសនា ផ្ទុយសីលធម៌យ៉ាងច្បាស់ ។ អ្នកណាយកប្រពៃណីនិងទំនៀមទម្លាប់របស់ប្រជាជន បារាំង ប្រជាជនអេស្ប៉ាញ ប្រជាជនអ៊ីតាលី ឬប្រជាជាតិដទៃទៀតនៅទ្វីបអឺរ៉ុប មកបង្ខំឲ្យជនជាតិចិនគោរពតាម គឺពិតជាលេលាមែន ។ សូមកុំនាំប្រពៃណីរបស់យើងទៅបញ្ចូលក្នុងស្រុកទាំងនោះឡើយ សូមនាំជំនឿលើព្រះជាម្ចាស់វិញ ។ ជំនឿនេះមិនប្រកាន់ ឬប្រមាថបោលពិធីនិងទំនៀមទម្លាប់របស់ប្រជាជនទាំងនោះទេ ឲ្យតែទំនៀមទម្លាប់នោះមិនមានលក្ខណៈ គួរឲ្យស្អប់ខ្ពើម ។ ជំនឿនេះរឹតតែនាំឲ្យពួកគេខំថែរក្សា ការពារពិធី និងប្រពៃណីប្រជាជាតិទាំងអស់នោះ ។ មនុស្សទាំងអស់តែងតែស្រឡាញ់ តែងតែគោរពប្រពៃណីប្រទេសរបស់ខ្លួន និងតែងតែលើកតម្កើងប្រទេសរបស់ខ្លួនឲ្យលើសអ្វីៗទាំងអស់ក្នុងលោកនេះ ។ ដូច្នេះ គ្មានមូលហេតុណាបណ្ដាលឲ្យមនុស្សឃ្លាតឆ្ងាយពីជំនឿ ឬស្អប់ខ្ពើមគ្រីស្ដសាសនាខ្លាំង ជាងការផ្លាស់ប្ដូរទំនៀមទម្លាប់ផ្ទាល់របស់ប្រជាជនណាមួយឡើយ ជាពិសេសការផ្លាស់ប្ដូរប្រពៃណី ដែលពួកគេធ្លាប់គោរពតាំងពីបុព្វបុរសមកនោះ ។

ប្រវត្តិព្រះសហគមន៍នៅប្រទេសកម្ពុជា ទំព័រ ៥២-៥៥

## 110 ដើមកំណើតនៃគ្រីស្ដសាសនានៅស្រុកកូរ៉េ

ព្រះសហគមន៍ស្រុកកូរ៉េមានដើមកំណើតប្លែកពីព្រះសហគមន៍ឯទៀតៗទាំងអស់ ។ កំណើតបែបនេះ បណ្ដាលឲ្យកើតការលំបាកខ្លះៗនៅពេលក្រោយ ។ លោក**សិលាលី**សរសេរលិខិតខាងក្រោមនេះ ផ្ញើជូនសាសនទូតបារាំងដែលនៅក្រុងប៉េកាំង ។ លោកបារម្ភព្រោះមានគេប្រាប់គាត់ថា គាត់បានប្រព្រឹត្តខុសវិន័យនៃព្រះសហគមន៍ ។

ពេលខ្ញុំទទួលអគ្គសញ្ញាជ្រមុជទឹកនៅប៉េកាំង ខ្ញុំស្គាល់តែសេចក្ដីខ្លះ ហើយមិនសូវជ្រៅអំពីសេចក្ដីដែលខ្ញុំត្រូវស្គាល់នោះទេ (...) ។ នៅពេលខ្ញុំមកដល់មាតុភូមិរបស់ខ្ញុំវិញ ខ្ញុំប្រញាប់ប្រញាល់រៀនសាសនារបស់ខ្ញុំ ដោយអានសៀវភៅដែលខ្ញុំយកពីប៉េកាំងមក ហើយក៏ប្រកាសឲ្យក្រុមគ្រួសារ និងមិត្តភក្តិដឹង ។ ពេលខ្ញុំធ្វើកិច្ចការនេះ ខ្ញុំជួបបណ្ឌិតម្នាក់ដែលរកឃើញសៀវភៅមួយអំពីគ្រីស្ដសាសនាយើង លោកបានអាននិងរិះគិតជាច្រើនឆ្នាំហើយ (...) ។ គាត់បង្រៀនខ្ញុំ ហើយយើងទាំងពីរនាក់បានជួយគ្នាទៅវិញទៅមក ឲ្យបម្រើព្រះជាម្ចាស់ និងអ្នកឯទៀតៗគឺមួយពាន់នាក់ទទូចសុំទទួលអគ្គសញ្ញាជ្រមុជទឹកយ៉ាងខ្លាំង ។ ដោយមានគេសុំគ្រប់គ្នា ខ្ញុំធ្វើពិធីជ្រមុជទឹកជូនគេជាច្រើន ។ ខ្ញុំធ្វើតាមពិធីដែលខ្ញុំសង្កេតឃើញនៅពេលខ្ញុំទទួលអគ្គសញ្ញាជ្រមុជទឹកនៅប៉េកាំង ។ ពេលនោះ ស្រាប់តែរដ្ឋអំណាចបៀតបៀនធ្វើបាបមកលើគ្រីស្ដបរិស័ទ ។ ក្រុមគ្រួសារខ្ញុំរងទុក្ខខ្លាំងជាងអ្នកឯទៀតៗទាំងអស់ បណ្ដាលឲ្យខ្ញុំត្រូវឃ្លាតពីបងប្អូនរួមក្នុងអង្គព្រះយេស៊ូគ្រីស្ដ ។ តែខ្ញុំឲ្យពីរនាក់ធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេជំនួស គឺបណ្ឌិតដែលខ្ញុំសរសេរខាងលើ ។ ម្នាក់ទៀតជាអ្នករងទុក្ខលំបាកយ៉ាងច្រើន ដោយរដ្ឋអំណាចបៀតបៀនតែគាត់ទទួលមរណភាពនៅចុងឆ្នាំ ១៧៨៥ គឺមួយឆ្នាំក្រោយគេចាប់ខ្លួន ។

នៅដើមគ.ស. ១៧៨៦ គ្រីស្ដបរិស័ទជួបជុំគ្នា រិះគិតអំពីរបៀបលន់តួបាបគ្នាទៅវិញទៅមក ។ គេសម្រេចថា ឈ្មោះ "គា" ត្រូវលន់តួឲ្យឈ្មោះ "ហ៊ី" និងឲ្យឈ្មោះ "ពីន" តែឈ្មោះ "គា" "ហ៊ី" និង "ពិន" មិនអាចលន់តួគ្នាទៅវិញទៅមកបានទេ ។ នៅដាច់ឆ្នាំដដែលនោះ គ្រីស្ដបរិស័ទជួបជុំគ្នាម្ដងទៀត រួចសម្រេចថា ខ្ញុំនឹងថ្វាយអភិបូជា និងធ្វើអគ្គសញ្ញាលាបថ្វាសដល់គេ ។ ខ្ញុំមិនគ្រាន់តែធ្វើតាមពាក្យទទូចរបស់គេប៉ុណ្ណោះទេ គឺខ្ញុំឲ្យដប់នាក់ទៀតមានអំណាចថ្វាយអភិបូជាដែរ ។ ខ្ញុំធ្វើពិធីបុណ្យដូចមានចែងក្នុងសៀវភៅទាំងប៉ុន្មាន និងតាមសៀវភៅធម៌តាមពេលកំណត់ ដោយដកធម៌ខ្លះបន្ថែមខ្លះ ។



ជនជាតិ តុងកឹង (ជនជាតិវៀតណាមពីដើម)

ហាមគោរពជូនតាតាមប្រពៃណីចិន ព្រមទាំងហាមគ្រីស្តបរិស័ទចិនគោរពលោក **ខុងជឺ** ។ ទោះបីព្រះចៅអធិរាជចិនបកស្រាយអត្ថន័យថា ពិធីទាំងនោះជាពិធីតាមប្រពៃណីរដ្ឋក្តី ក៏លោកអភិបាលក្រុងរ៉ូមហាមដែរ ។ គ.ស. ១៧០៤ ក្រសួងរក្សាទុកជំនឿនៅក្រុងរ៉ូម យល់ស្របតាមអភិបាលតំណាងស្រុកចិន ។ អភិបាលក្រុងរ៉ូមបាត់ទូតម្នាក់ដើម្បីដោះស្រាយបញ្ហានេះ ។ នៅស្រុកឥណ្ឌាវិញ ទូតនោះហាមសម្របសម្រួលតាមអរិយធម៌ម៉ាឡាប័រ ។ នៅស្រុកចិន លោកក៏មិនយល់ស្របឲ្យគ្រីស្តបរិស័ទប្រព្រឹត្តពិធីជាប្រពៃណីដែរ ។ ទូតនោះទទួលមរណភាពនៅម៉ាកាវ (គ.ស. ១៧១០) ។ នៅគ.ស. ១៧១៥ អភិបាលក្រុងរ៉ូម ហាមយ៉ាងឱឡារិកធ្វើពិធីបុណ្យតាមប្រពៃណីម៉ាឡាប័រ និងចិនជាដាច់ខាត ។ ទូតម្នាក់ទៀតជួយសម្រួលខ្លះ ។ គេហាមធ្វើពិធីទាំងនោះពីរដងទៀត នៅគ.ស. ១៧៤២ និង ១៧៤៤ ។ 111
បញ្ហានេះនៅតែបោទរហូតដល់ គ.ស. ១៩៣៩ ទើបអភិបាលក្រុងរ៉ូមអនុញ្ញាត ។

## ៦- វិបត្តិអន្តរជាតិ

នៅសតវត្សទី ១៧-១៨ ប្រទេសបារាំងនិងប្រទេសអេស្ប៉ាញចុះអន់ថយលែងជាមហាអំណាចខាងសមុទ្រ ។ រីឯប្រទេសអង់គ្លេសឡើងជាមហាអំណាចវិញ ទៅត្រួតត្រាប្រទេសអាមេរិកនិងប្រទេសឥណ្ឌា ។ អភិបាលក្រុងរ៉ូមរំលាយក្រុមគ្រួសារសហជីវិនព្រះយេស៊ូ (គ.ស. ១៧៧៣) ដែលមានសាសនទូត ៣.០០០ នាក់ ក្នុងសកលលោក ។ ដូច្នេះ គ្រីស្តបរិស័ទជាច្រើនគ្មាននរណាណែនាំទៀត ។

បដិវត្តន៍ប្រទេសបារាំង (១៧៨៩-១៨១៥) ក៏បណ្តាលឲ្យចំនួនសាសនទូតចុះអន់ថយដែរ ។ មហាអំណាចអង់គ្លេសជានិកាយប្រូតេស្តង់ ធ្វើឲ្យសាសនទូតកាតូលិកដែលធ្វើដំណើរតាមផ្លូវទឹកកាន់តែលំបាកឡើងៗ ។ នៅប្រទេសអង់គ្លេសក៏កើតសមាគមប្រូតេស្តង់ ដែលចេញទៅប្រកាសដំណឹងល្អដែរ ។

ព្រះសហគមន៍លែងនឹងគិតថា មនុស្សលោកទាំងអស់គង់តែទៅជាគ្រីស្តបរិស័ទនៅពេលណាមួយមិនខាន ។ ប៉ុន្តែ នៅសតវត្សទាំងប៉ុន្មានកន្លងមក គ្រីស្តបរិស័ទចាប់ផ្តើម រិះគិតអំពីទំនាក់ទំនងរវាងគ្រីស្តសាសនានិងសាសនាដទៃឲ្យកាន់តែច្បាស់ ។

## (111) អភិបាលក្រុងរ៉ូមក្លេម៉ង់ ទី១២ ជំទាស់នឹងក្បួនពិធីតាមប្រពៃណីចិន (គ.ស. ១៧០៤)

*៣- ដោយមូលហេតុណាក៏ដោយ គឺមិនត្រូវអនុញ្ញាតឲ្យគ្រីស្តបរិស័ទចិនធ្វើប្រធាន ឬបម្រើ ឬចូលរួមក្នុងសក្ការបូជាយ៉ាងឱឡារិក ឬក្នុងពិធីថ្វាយតង្វាយដែលជនជាតិចិនធ្លាប់ថ្វាយទៅខុងជឺ ឬនៅថ្ងៃ ២១ មិនា ឬនៅថ្ងៃ ២១ កញ្ញា ជាថ្ងៃឧទ្ទិសជូនដល់ដូនតាដែលលាចាកលោកនេះទៅ ។ ត្រូវរាប់ពិធីទាំងនោះទុកជាពិធីនៃជំនឿអកុសល ( .. ) ។*

*៧- មិនត្រូវអនុញ្ញាតឲ្យគ្រីស្តបរិស័ទចិនទុករូប ឬអក្សរនៅផ្ទះផ្ទាល់សម្រាប់គោរពកុងម៉ាតាមប្រពៃណីចិនដែលមានចែងថា «បល្ល័ង្ក» ឬទីស្នាក់នៅរបស់វិញ្ញាណក្ខន្ធ ឬវិញ្ញាណក្ខន្ធអ្នកនេះ អ្នកនោះ ព្រោះពាក្យនេះបញ្ជាក់ថា វិញ្ញាណក្ខន្ធមរណបុគ្គលមកស្នាក់នៅ ឬមកសម្រាកនៅទីនោះយូរៗម្តង ។*



*ព្រះវិហារថ្វាយស្ថានបរមសុខ (សតវត្សទី ១៥)*



Layout Histor.qxd 2/10/07 10:10 AM Page 199



# បដិវត្តនៅទ្វីបអឺរ៉ុប និង ឧស្សាហូបនីយកម្ម

## សតវត្សទី ១៨-១៩

*នៅសតវត្សទី ១៨ នៅទ្វីបអឺរ៉ុបមានទស្សនវិទូជាច្រើនចាប់ផ្ដើមបែកចេញពីព្រះសហគមន៍ នឹងបង្កើតទ្រឹស្ដីជំទាស់នឹងគ្រឹស្ដសាសនា ។ អស់លោកចង់រិះគិតអំពីគ្រប់សេចក្ដីស្របទៅតាមកម្លាំងប្រាជ្ញាមនុស្សសុទ្ធសាធ មិនមែនស្របតាមគម្ពីរឬតាមជំនឿទៀតទេ ។ អ្នកប្រវត្តិវិទ្យាតែងហៅសម័យនោះថា «សតវត្សនៃពន្លឺ» ។ ទស្សនវិទូជាច្រើនជំទាស់ប្រឆាំងនឹងគ្រឹស្ដសាសនា ។ ក្នុងចំណោមទស្សនវិទូទាំងនោះ មានលោក**វ៉ុលទែរ** (Voltaire) និងលោក**រ៉ូស្សូ** (Rousseau) ដែលមានឥទ្ធិពលរហូតមកដល់អ្នកដឹកនាំបដិវត្តន៍នៅប្រទេសកម្ពុជាយើង ។*

*ព្រះសហគមន៍ខិតខំរិះគិតតាមរបៀបថ្មីអំពីទ្រឹស្ដីទាំងនោះ ។ នៅប្រទេសអាល្លឺម៉ង់ គ្រឹស្ដបរិស័ទយកចិត្តទុកដាក់សិក្សាព្រះគម្ពីរ ខិតខំកែសម្រួលពីធីបុណ្យនានា មិនឲ្យលាយឡំនឹងប្រពៃណីប្រជាប្រិយ ដែលជ្រួតជ្រាបដោយជំនឿអកុសល ។ គេយកចិត្តទុកដាក់បង្កើតទេវវិទ្យាថ្មី និងខិតខំរួបរួមជាមួយបងប្អូនប្រូតេស្ដង់ ។ គ្រឹស្ដបរិស័ទទាំងកាតូលិក ទាំងប្រូតេស្ដង់ ប្រើសៀវភៅអប់រំជំនឿតែមួយដូចគ្នា ។*

*នៅសតវត្សទី ១៨ អភិបាលក្រុងរ៉ូមសុទ្ធតែចាស់ៗមិនសូវមានគំនិតក្នុងការណែនាំព្រះសហគមន៍ប៉ុន្មានទេ ។ អស់លោករវីរវល់តែនឹងត្រួតត្រា «រដ្ឋមហាបូជាចារ្យ» ដូចស្ដេចឯទៀតៗប៉ុណ្ណោះ ។ គេជ្រើសរើសអភិបាលព្រះសហគមន៍ឯទៀតៗ ភាគច្រើនក្នុងចំណោមគ្រឹស្ដបរិស័ទវណ្ណៈអភិជន ហើយអភិបាលជាច្រើនមិនសូវរស់នៅក្នុងភូមិភាគរបស់ខ្លួនទៀត ។ ទាំងនៅប្រទេសបារាំង ទាំងនៅប្រទេសអាល្លឺម៉ង់ចំនួនបព្វជិតក៏ចុះអន់ថយដែរ ។*

*គ្រឹស្ដបរិស័ទមួយចំនួនធំនាំគ្នាជំទាស់ប្រឆាំងនឹងអភិបាលក្រុងរ៉ូម ហើយចង់បង្កើតព្រះសហគមន៍ជាតិ ។*

*អភិបាលក្រុងរ៉ូមទន់ខ្សោយពេក ។ រីឯស្ដេចជាច្រើននៅទ្វីបអឺរ៉ុបសុំរំលាយក្រុមគ្រួសារសហជីវិនព្រះយេស៊ូ ។ ស្ដេចទាំងនោះច្រើនកាន់អំណាចលទ្ធិផ្ដាច់ការ ហើយមានបំណងត្រួតលើព្រះសហគមន៍ជាតិរបស់អស់លោក ។ ដូច្នេះ អស់លោកចោទថា ក្រុមគ្រួសារសហជីវិនព្រះយេស៊ូបម្រើអភិបាលក្រុងរ៉ូម និងមានឥទ្ធិពលខាងនយោបាយ ។ អភិបាលក្រុងរ៉ូមក៏យល់ស្របតាមស្ដេចទាំងនោះដែរ ហើយចាប់ប្រជានក្រុមគ្រួសារសហជីវិនព្រះយេស៊ូទៅឃុំឃាំង (គ.ស. ១៧៧៣) ថែមទៀតផង ។ នៅប្រទេសព័រទុយហ្គាល់គេសម្លាប់សហជីវិនព្រះយេស៊ូជាង ៨០ នាក់ ។*

*រោងចក្រត្បាញ*
*នៅប្រទេសអង់គ្លេស នាសតវត្សទី ១៩*

Layout Histor.qxd 2/10/07 10:10 AM Page 200

## ១- ចលនាភ្ញាក់ស្មារតី

យូរៗទៅនៅប្រទេសអាល្លឺម៉ង់ ក្រុមជំនុំប្រូតេស្តង់ក្លាយទៅជាសាសនាជាតិ ហើយទស្សនវិជ្ជាបណ្ដាលឲ្យគ្រីស្តសាសនាក្លាយទៅជាទ្រឹស្ដីតាមប្រាជ្ញាមនុស្ស ។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទខ្លះចូលចិត្តបញ្ចូលមនោសញ្ចេតនាក្នុងពេលអធិដ្ឋាន និងក្នុងពេលធ្វើពិធីបុណ្យនានា (Piétisme) ។ គេចូលចិត្តបទពិសោធន៍អំពីជំនឿ និងអំពើសេចក្ដីស្រឡាញ់ ចូលចិត្តការរំភើបចិត្តជាងរិះគិតអំពីជំនឿ ។

## ២- លោកយ៉ូហាន វ៉ែស្លេ បង្កើតក្រុមមេថូឌីស្ត

នៅប្រទេសអង់គ្លេស ព្រះសហគមន៍អង់គ្លីកង់មិនសូវទាក់ទងជាមួយនឹងប្រជាជនក្រីក្រទេ ជាពិសេសជាមួយពួកកម្មកររស់នៅក្នុងក្រុង មានឧស្សាហកម្ម ឬមានរ៉ែធ្យូង ។ ដូច្នេះ មានគ្រីស្តបរិស័ទខ្លះនាំគ្នាតវ៉ា ទាមទាររកយុត្តិធម៌ឲ្យកម្មករក្រីក្រ ។ ក្នុងចំណោមនោះមាន៖

- លោក**ហ្សក-ហ្វូស** (Georges-Fox ១៦២៤-១៦៩១) លោកប្រៀនប្រដៅគ្រីស្តបរិស័ទឲ្យទទួលពន្លឺដែលគេមានក្នុងចិត្ត ដោយមិនសូវចាប់អារម្មណ៍នឹងលទ្ធិគ្រីស្តសាសនា និងរចនាសម្ពន្ធនៃព្រះសហគមន៍ ។ លោកជាស់តឿនអ្នកស្ដាប់លោកឲ្យ «*ញ័រ*» នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ។ គេហៅក្រុមលោកបង្កើតនោះថា «*ក្រុមក្វាគ័រ*» (Quakers) គឺជាក្រុមអ្នកញ័រ ។
- លោក**យ៉ូហាន-វែស្លេ** (John Wesley ១៧០៣-១៧៩១) លោកបង្កើតក្រុមគ្រីស្តបរិស័ទដែលជួបជុំគ្នាអានព្រះគម្ពីរ អធិដ្ឋាន ប្រព្រឹត្តអំពើល្អ ។ លោកចាត់ចែងក្រុមទាំងនោះឲ្យមានរបៀបរៀបរយយ៉ាងតឹងរ៉ឹងល្អ បានជាគេហៅក្រុមគេថា «*អ្នកមានវិធី*» (Méthodistes មេថូឌិស្ត) ដែលនៅពេលក្រោយត្រឡប់ទៅជាក្រុមជំនុំធំជាងគេនៅសហរដ្ឋអាមេរិក ។

# ក. បដិវត្តន៍នៅប្រទេសបារាំង (១៧៨៩_១៨១៥)

មុនដំបូង អ្នកធ្វើបដិវត្តន៍នៅប្រទេសបារាំងមិនប្រឆាំងនឹងគ្រីស្តសាសនាទេ ។ តែយូរៗទៅដោយត្រូវការថវិកាសម្រាប់ធ្វើសង្គ្រាម គេរឹបអូសយកទ្រព្យសម្បត្តិទាំងអស់របស់ព្រះសហគមន៍ (នៅសម័យនោះ ១ ភាគ ៦ នៃទឹកដីបារាំងជាកម្មសិទ្ធិព្រះសហគមន៍) ។ គេលក់ព្រះវិហារនិងវត្តអារាមឲ្យអ្នកមាន ។ បន្ទាប់មក គេហាមគ្រីស្តបរិស័ទធ្វើពាក្យសច្ចាប្រណិធានរស់នៅជាបព្វជិត ។ គេបង្គាប់ឲ្យគ្រីស្តបរិស័ទបោះឆ្នោតជ្រើសរើសអភិបាលនិងបូជាចារ្យ ។ អភិបាលព្រះសហគមន៍និងបូជាចារ្យត្រូវធ្វើពាក្យសន្យាថា ស្មោះនឹងរដ្ឋអំណាច ។ ប៉ុន្តែ អភិបាលព្រះសហគមន៍ក្រុងរ៉ូម **ពីយ៉ូទី ៦** ដាក់ទោសអភិបាលនិងបូជាចារ្យទាំងប៉ុន្មានដែលធ្វើពាក្យសន្យានោះ (គ.ស. ១៧៩១) ។ ហេតុនេះហើយ បានជាព្រះសហគមន៍បែកជាពីរ គឺមួយស្មោះនឹងរដ្ឋអំណាច និងមួយទៀតស្មោះនឹងអភិបាលក្រុងរ៉ូម ។ បូជាចារ្យប្រហែល ៤០.០០០ នាក់ ភៀសខ្លួនទៅក្រៅប្រទេសបារាំង ទៅរស់នៅពាសពេញទ្វីបអឺរ៉ុប ។

នៅគ.ស. ១៧៩២ រដ្ឋអំណាចបារាំងសម្លាប់បូជាចារ្យជាង ៣០០ នាក់ ។ (112)

នៅគ.ស. ១៧៩៣-១៧៩៤ រដ្ឋអំណាចរុះរើព្រះវិហារ និងវត្តអារាមបោលសម្លាប់បូជាចារ្យ បព្វជិតបព្វជិតា និងគ្រីស្តបរិស័ទច្រើនអនេកដោយចោទគេថាជាអ្នកក្បត់ជាតិ ។ រដ្ឋអំណាចដូរប្រតិទិន បង្កើតពិធីបុណ្យផ្សេងៗជំនួសពិធីបុណ្យគ្រីស្តសាសនា ដើម្បីចំអកមើលងាយគ្រីស្តបរិស័ទ បង្ខំបូជាចារ្យដែលនៅសេសសល់ឲ្យយកគ្រួសារ ។ល។

Layout Histor.qxd 2/10/07 10:10 AM Page 201

## 114 ពាក្យទូន្មានសម្រាប់អ្នកអប់រំជំនឿ និងអ្នកណែនាំព្រះសហគមន៏តាមភូមិភាគនានា (៨ កុម្ភៈ ឆ្នាំ ១៧៩៦)

តំណាងពេញសិទ្ធិរបស់អភិបាលក្រុងលីយ៉ុង ចាត់ចែងព្រះសហគមន៍ភូមិភាគរបស់លោក ទៅតាមសេចក្ដីដែលលោកបានឮពីព្រះសហគមន៍នៅស្រុកតុងកឹង *(វៀតណាម)* ជាស្រុករដ្ឋអំណាចបៀតបៀនធ្វើបាបគ្រីស្តបរិស័ទដែរ ។ លោកយល់ឃើញថា ត្រូវចាត់ចែងគ្រីស្តបរិស័ទឲ្យមានមុខងារបម្រើយ៉ាងពិតប្រាកដក្នុងព្រះសហគមន៍និមួយៗ ។ រីឯបូជាចារ្យវិញ មានមុខងារចល័តពីភូមិមួយទៅភូមិមួយ ។

*សាសនទូតជួយព្រះសហគមន៍ស្រុកចិននិងស្រុកតុងកឹងដោយអ្នកណែនាំមានជំនឿ និងមានចិត្តឧស្សាហ៍ជាខ្លាំង ។ នៅស្រុកនោះគ្រីស្តបរិស័ទជួបឧបសគ្គរារាំងជារៀងរាល់ថ្ងៃ ហើយរដ្ឋអំណាចបៀតបៀនធ្វើបាបដូចនៅស្រុកយើងដែរ ។ មារកំពុងតែរារាំងមិនឲ្យព្រះសហគមន៍រីកចំរើនឡើងបាន (...) ។ ប្រទេសដ៏អភ័ព្វរបស់យើង ក៏ជួបប្រទះឧបសគ្គដូចស្រុកសាសន៍ដទៃទាំងនោះដែរ ។ ដូច្នេះ ត្រូវតែតែងតាំងប្រធានព្រះសហគមន៍និងអ្នកអប់រំជំនឿ ។ ការនេះមុខជានឹងបានលទ្ធផលល្អដូចនៅស្រុកគេ ដើម្បីលើកតម្កើងជំនឿឲ្យបានខ្ពស់ និងនាំទៅប្រទេសដទៃទៀត (...) ។ អភិបាលព្រះសហគមន៍ភូមិភាគតែងតាំងប្រធានស្របតាមយោបល់សាសនទូរ ។ គាត់ធ្វើការក្រោមការដឹកនាំរបស់សាសនទូត ។*

*ប្រធានព្រះសហគមន៍មានមុខងារដូចតទៅ៖*

*ក- ធ្វើប្រធានអង្គប្រជុំគ្រីស្តបរិស័ទក្នុងគ្រប់ពិធី ដើម្បីឲ្យមានរបៀបរៀបរយ ។*

*ខ- ណែនាំការអធិដ្ឋាន សូត្រធម៌ ថ្លែងអត្ថបទព្រះគម្ពីរដែលសាសនទូតបង្គាប់តាមថ្ងៃបុណ្យ ។*

*គ- យកចិត្តទុកដាក់ធ្វើឲ្យគ្រីស្តបរិស័ទប្រុងប្រយ័ត្នយ៉ាងខ្លាំង និងឲ្យបេះលាក់ការ (...) ។*

*ឃ- ធ្វើឲ្យគ្រីស្តបរិស័ទក្នុងភូមិរស់នៅប្រកបដោយសេចក្ដីសុខសាន្ត កុំឲ្យឈ្លោះប្រកែកគ្នាឡើយ ។*

*ង- ឲ្យគ្រីស្តបរិស័ទដឹងអំពីសេចក្ដីដែលអភិបាល ឬសាសនទូតចង់ឲ្យគេដឹងអំពីសាសនា ។*

*ច- ធ្វើបញ្ជីគ្រីស្តបរិស័ទដែលស្លាប់ក្នុងភូមិ បញ្ជីទារកដែលកើតក្នុងភូមិ ហើយធ្វើពិធីចាក់ទឹកលើវានៅផ្ទះ ធ្វើបញ្ជីអ្នកជំងឺ និងជនពិការ (..) ។*

### មានអ្នកណែនាំបីក្រុម

*ក្នុងប្រទេសក្រៅមានអ្នកអប់រំបីក្រុម គឺក្រុមទីមួយជាអ្នកអប់រំដែលនៅស្ថិតស្ថេរក្នុងភូមិ ។ ក្រុមទីពីរជាអ្នកអប់រំដែលដើរជាមួយសាសនទូត ។ ក្រុមទីបីជាអ្នកអប់រំដែលទៅភូមិផ្សេងៗ មុនសាសនទូតទៅទាំងនាំជំនួយផ្សេងៗខាងផ្លូវធម៌អាថ៌ ។ យើងនឹងពន្យល់ភារកិច្ចអ្នកទាំងបីក្រុមនោះ (..) ។*

### ក្រុមអ្នកអប់រំដែលនៅស្ថិតស្ថេរក្នុងភូមិ

*ប្រធានព្រះសហគមន៍នឹងបង្ហាញបញ្ជីគ្រីស្តបរិស័ទដែលស្មោះត្រង់នឹងជំនឿខ្លាំងជាងគេ ដើម្បីឲ្យសាសនទូតស្គាល់ ឬប្រសិនបើអាចធ្វើបានឲ្យអភិបាលស្គាល់ (...) ។ ប្រធានព្រះសហគមន៍ត្រួតពិនិត្យអ្នកអប់រំទាំងនោះ ហើយអ្នកអប់រំជំនឿត្រូវតែសួរយោបល់គាត់មុនធ្វើអ្វីៗទាំងអស់ ។ ក្រុមអ្នកអប់រំនៅស្ថិតស្ថេរក្នុងភូមិ ពិតជាអ្នកថែរក្សាការពារព្រះសហគមន៍តាមភូមិ (..) ។*

*១- ត្រូវតែមានចិត្តមេត្តាករុណាយ៉ាងស្និទ្ធស្នាលចំពោះអ្នកក្រីក្រដូចគ្រីស្តបរិស័ទដើមដំបូង (..) ។ គេសូមឲ្យគ្រីស្តបរិស័ទចូលបច្ច័យ និងប្រមូលបច្ច័យទាំងនោះ (..) យកទៅជូនប្រធានព្រះសហគមន៍ដែលនឹងជួយអ្នកខ្វះខាត (..) ។*

*២- អ្នកណែនាំផ្ទាល់ ឬអ្នកអប់រំចាក់ទឹកលើទារកដែលទើបនឹងកើត ។ គេនឹងធ្វើបញ្ជីទារកទាំងនោះ ជូនដល់ប្រធានព្រះសហគមន៍ ។ ពេលសាសនទូតមកដល់ លោកធ្វើអគ្គសញ្ញាជ្រមុជទឹកបន្ថែម (..) ។*

*៣- អ្នកអប់រំទៅសួរសុខទុក្ខអ្នកជំងឺ ដើម្បីជួយគេខាងផ្លូវវិញ្ញាណនៅពេលហៀបនឹងទទួលមរណភាព (..) ។*

*៦- អ្នកអប់រំត្រូវរាយការណ៍ដល់ប្រធានព្រះសហគមន៍អំពីព្រឹត្តិការណ៍ដែលកើតឡើង យ៉ាងហោចណាស់ពីរអាទិត្យម្ដងៗ (...) ។*

ដោយកងទ័ពបារាំងលុកលុយចូលទ្វីបអឺរ៉ុបមួយភាគធំ រដ្ឋអំណាចក៏ធ្វើបាបគ្រីស្តបរិស័ទក្នុងទ្វីបអឺរ៉ុបទាំងមូល វាយដណ្តើមយក *«រដ្ឋមហាបូជាចារ្យ»* ចាប់អភិបាលក្រុងរ៉ូម **ប៉ូល ទី ៦** នាំជាឈ្លើយនៅប្រទេសបារាំង ។ លោកទទួលមរណភាពនៅក្នុងស្រុកនោះ (១៧៩៩) ។

នៅឆ្នាំ ១៨00 ក្រុមទីប្រឹក្សាររបស់អភិបាលក្រុងរ៉ូម បោះឆ្នោតជ្រើសរើសអភិបាលថ្មី គឺលោក **ពីយ៉ូ ទី ៧** ។ លោកចចារជាមួយលោក**ណាប៉ូឡេអុង** (Napoléon) ជាអ្នកធ្វើរដ្ឋប្រហារដណ្តើមអំណាច មកត្រួតត្រានៅក្នុងប្រទេសបារាំង ។ លោកសុខចិត្តចុះហត្ថលេខាក្រោមការព្រមព្រៀង គឺអភិបាលក្រុងរ៉ូមសូមឲ្យអស់លោកអភិបាលដែលទទួលមុខតំណែងក្នុងរបបរាជានិយម លាលែងមុខតំណែង ។ រដ្ឋាភិបាលជ្រើសរើសអភិបាលថ្មី ហើយអភិបាលក្រុងរ៉ូមផ្តល់សិទ្ធិឲ្យអស់លោកដែលរដ្ឋអំណាចជ្រើសរើសនោះ អាចណែនាំព្រះសហគមន៍បាន ។ លោកមិនទាមទារអតីតទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់ព្រះសហគមន៍ឲ្យរដ្ឋអំណាចសងវិញទេ ។

ដូច្នេះ អភិបាលព្រះសហគមន៍ក្រុងរ៉ូមទទួលអំណាចយ៉ាងទូលំទូលាយ ដែលមិនដែលមានតាំងពីដើមព្រះសហគមន៍រៀងមក គឺលោកទទួលអំណាចផ្លាស់ប្តូរអភិបាលព្រះសហគមន៍ទាំងអស់ក្នុងប្រទេសមួយ និងផ្តល់អំណាចឲ្យអភិបាលទាំងនោះអាចណែនាំព្រះសហគមន៍បាន ។ ប៉ុន្តែ លោកណាប៉ូឡេអុងបន្ថែមល័ក្ខខ័ណ្ឌ ៧៧ ខ ដើម្បីគ្រប់គ្រងព្រះសហគមន៍ក្នុងគ្រប់វិស័យ ។

នៅគ.ស. ១៨0៦ ព្រះចៅអធិរាជណាប៉ូឡេអុងដណ្តើមយក *«រដ្ឋមហាបូជាចារ្យ»* ពីអភិបាលក្រុងរ៉ូម ហើយភ្ជាប់រដ្ឋនោះនឹងស្រុកបារាំង ។ ទ្រង់ចាប់អភិបាលព្រះសហគមន៍ក្រុងរ៉ូមដាក់ឃុំឃាំង តែលោកអភិបាលមិនព្រមអនុញ្ញាតឲ្យអភិបាលថ្មី ១៧ នាក់ ណែនាំភូមិភាគរបស់ខ្លួនបាន ។ ក្រោយមក ដោយព្រះចៅអធិរាជណាប៉ូឡេអុង បាញ់សង្គ្រាម បានជាទ្រង់អនុញ្ញាតឲ្យអភិបាលក្រុងរ៉ូមវិលត្រឡប់ទៅក្រុងរ៉ូមវិញ នៅគ.ស. ១៨១៤ ដើម្បីគាប់ចិត្តគ្រីស្តបរិស័ទ ។

ក្រោយបដិវត្តន៍ ព្រះសហគមន៍ស្រុកបារាំងខុសប្លែកពីមុន គឺបាត់បង់ទ្រព្យសម្បត្តិដ៏ច្រើនហួសហេតុរបស់ខ្លួន ។ មានតែអភិបាលក្រុងរ៉ូមម្នាក់ប៉ុណ្ណោះដែលត្រួតត្រាទឹកដីមួយ គឺត្រួតត្រា *«រដ្ឋរបស់មហាបូជាចារ្យ»* ។

រដ្ឋធម្មនុញ្ញថ្មីប្រទេសបារាំងចែងអំពីសិទ្ធិខាងជំនឿ គឺប្រជាជនមានសិទ្ធិប្រកាសថាខ្លួនជាគ្រីស្តបរិស័ទ ហើយក៏មានសិទ្ធិមិនមែនជាគ្រីស្តបរិស័ទផងដែរ ។ រដ្ឋអំណាចដកបញ្ជីអត្រានុកូល *(កំណើត អាពាហ៍ពិពាហ៍ ស្លាប់)* ពីព្រះសហគមន៍ផ្ទេរឲ្យទៅរាជការកាន់ជំនួសវិញ ។ មុខងារអប់រំប្រជាជនក៏ផ្ទេរពីព្រះសហគមន៍ទៅដល់រដ្ឋដែរ ។ ដូច្នេះ ព្រះសហគមន៍វិលទៅបំពេញមុខងារពិសេសរបស់ខ្លួនផ្ទាល់ គឺប្រកាសដំណឹងល្អ ។



*លោកណាប៉ូឡេអុង បំពាក់មកុដខ្លួនឯងនៅចំពោះមុខអភិបាលក្រុងរូម (១៨0៤)*

Layout Histor.qxd 2/10/07 10:10 AM Page 203

# ២. សង្គមថ្មីនៅសតវត្សទី ១៩ (១៨១៥_១៨៧០)

## ១- ការខិតខំតែងតាំងសភាពការណ៍នយោបាយឲ្យបានដូចពីមុន

### *ក- នៅទ្វីបអឺរ៉ុប*

ឆ្នាំ ១៨១៥ ព្រះចៅ**ណាប៉ូឡេអុង**បរាជ័យ បដិវត្តន៍នៅទ្វីបអឺរ៉ុបក៏បរាជ័យដែរ ។ អភិបាលក្រុងរ៉ូមត្រួតត្រារដ្ឋមហាបូជាចារ្យឡើងវិញ ព្រះចៅអធិរាជប្រទេសរុស្ស៊ី (Russie) ព្រះចៅអធិរាជប្រទេសអូទ្រីស (Autriche) និងស្ដេចស្រុកប្រ៊ូស (Prusse) ចុះហត្ថលេខាក្រោមសន្ធិសញ្ញា «*សម្ពន្ធមេត្រីដ៏វិសុទ្ធ*» គឺស្ដេចទាំងបីព្រះអង្គជាតំណាងគណៈគ្រីស្ដសាសនាទាំងបី (កាតូលិក ប្រូតេស្ដង់ និងអ័រតូដុក) សន្យាថា «*ក្នុងនាមព្រះត្រៃឯកដ៏វិសុទ្ធដែលមិនអាចបំបែកបាន*» នឹងយកគោលលទ្ធិគ្រីស្ដសាសនាមកអនុវត្ត និងជួយគ្នាទៅវិញទៅមកផង ។

វណ្ណៈសក្ដិភូមិទ្វីបអឺរ៉ុប មានបំណងលប់បំបាត់ឥទ្ធិពលរបស់បដិវត្តន៍ ជាពិសេសលប់បំបាត់សេរីភាពរបស់ប្រជាជន ដើម្បីរក្សាទុកឯកសិទ្ធិរបស់ខ្លួនឲ្យបានដូចពីមុន ។ ប្រជាជនគ្មានសិទ្ធិទេ មានតែភារកិច្ចដែលត្រូវតែបំពេញប៉ុណ្ណោះ ។ អ្នកណែនាំគ្រីស្ដសាសនាភាគច្រើនជាវណ្ណៈអភិជន ក៏ចង់រក្សាសិទ្ធិវណ្ណៈរបស់ខ្លួនដែរ គេតែងតែចូលរួមជាមួយរដ្ឋអំណាច ឬគាំទ្ររដ្ឋនានា ។ តែប្រជាជនជាច្រើននាំគ្នាបះបោរប្រឆាំងនឹងរាជអំណាចផង និងអំណាចព្រះសហគមន៍ផង ។ ព្រះសហគមន៍នៅតែប្រឆាំងនឹងប្រជាជនដែលទាមទាររកសេរីភាព ដោយយល់ឃើញថា សេរីភាពនោះអាចបំបាត់លទ្ធិជំនឿនៃគ្រីស្ដសាសនាបាន ។

នៅគ.ស. ១៨១៤ លោកអភិបាលក្រុងរ៉ូមអនុញ្ញាតឲ្យក្រុមគ្រួសារសហជីវិនព្រះយេស៊ូកើតឡើងវិញ ។ នៅសម័យនោះ ក្រុមគ្រួសារបព្វជិតបព្វជិតាជាច្រើនអនេកកើតឡើង ដើម្បីបម្រើអ្នកក្រីក្រ ។ ក្រុមគ្រួសារជាច្រើនគោរពនាងម៉ារី (គ្រាន់តែនៅប្រទេសបារាំងមានក្រុមគ្រួសារ ៧០០ មានឈ្មោះតាមព្រះនាងម៉ារី) គោរពព្រះបេះដូង គោរពព្រះកាយព្រះគ្រីស្ដ ។

នៅទ្វីបអឺរ៉ុបទាំងមូល គ្រីស្ដបរិស័ទកាតូលិកនិងប្រូតេស្ដង់ ហាត់ខ្លួនឲ្យរស់នៅជាមួយគ្នាដោយសន្តិភាព ។ មានចលនាប្រូតេស្ដង់ម៉្យាងប្រកាន់ថា ជំនឿគ្រាន់តែជាមនោសញ្ចេតនាម៉្យាង គឺជាទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដោយមិនចាំបាច់ឲ្យមានគោលលទ្ធិអ្វីសោះ ។

ប្រជាជនទ្វីបអឺរ៉ុបស្ទើរតែគ្រប់ប្រទេស លើកគ្នាប្រឆាំងនឹងស្ដេចនានាផង ហើយក៏ប្រឆាំងគ្រីស្ដសាសនាដែលភ្ជាប់នឹងស្ដេចទាំងនោះផង គឺនៅគ.ស. ១៨៣០ ម្ដង និងឆ្នាំ ១៨៤៨ ម្ដងទៀត ។ សូម្បីតែប្រជាជននៅ «រដ្ឋមហាបូជាចារ្យ» (ដែលស្ថិតក្រោមអំណាចអភិបាលព្រះសហគមន៍ក្រុងរ៉ូមផ្ទាល់) ក៏លើកគ្នាប្រឆាំងនឹងអភិបាលក្រុងរ៉ូមដែរ ។ អភិបាលព្រះសហគមន៍ក៏ហៅកងទ័ពបរទេសមកបង្ក្រាបពួកគេ ។ អភិបាលក្រុងរ៉ូម **គ្រេគ័រទី ១៦** ដាក់ទោសគ្រីស្ដបរិស័ទដែលទាមទារសិទ្ធិសេរីភាពអំពីជំនឿ និងអំពីរបៀបធ្វើពិធីបុណ្យ ព្រមទាំងអស់គ្រីស្ដបរិស័ទដែលមានបំណងបំបែកព្រះសហគមន៍ពីរដ្ឋអំណាច ។ លោកអាក់អន់ចិត្ត 113
ដោយឃើញថា គ្រីស្ដបរិស័ទជាច្រើនទាមទារសិទ្ធិសេរីភាព ព្រោះលោកយល់ឃើញថា សេរីភាពបានបណ្ដាលឲ្យព្រះសហគមន៍វេទនានិងអន់ថយ ។

នៅឆ្នាំ ១៨៣០ ប្រជាជននៅស្រុកប៉ូឡូញបះបោរចង់បំរះចេញពីប្រទេសរុស្ស៊ីដែលត្រួតត្រាស្រុកគេ ។ កងទ័ពរុស្ស៊ីបង្ក្រាបជនជាតិប៉ូឡូញ ទាំងសម្លាប់មនុស្សជាច្រើនអនេក ។ លោកគ្រេគ័រទី ១៦ ទូន្មានគ្រីស្ដបរិស័ទប៉ូឡូញឲ្យចុះចូលក្រោមអំណាចប្រទេសរុស្ស៊ីវិញ ។

Layout Histor.qxd 2/10/07 10:10 AM Page 204

## 113 លិខិតអភិបាលក្រុងរ៉ូមដាក់ទោសគ្រីស្តបរិស័ទដែលទាមទារសិទ្ធិសេរីភាពខាងជំនឿ

*មនុស្សសម័យឥឡូវមិនចាប់អារម្មណ៍អំពីសាសនា មកពីគំនិតដ៏លេលាផ្តេសផ្តាសនោះថា យើងត្រូវផ្តល់និងធានាឲ្យមនុស្សម្នាក់ៗមានសិទ្ធិសេរីភាពខាងជំនឿ (...) យើងឮថា មានអ្នកនិពន្ធខ្លះបានផ្សព្វផ្សាយគោលលទ្ធិខ្លះ ក្នុងចំណោមគ្រីស្តបរិស័ទ បណ្តាលឲ្យពួកគេលែងចុះចូលក្រោមអំណាចអ្នកដឹកនាំប្រទេស គឺគេបង្កើតភ្លើងឲ្យបះបោរនៅគ្រប់កន្លែង ។ ត្រូវប្រុងប្រយ័ត្ន ឃាត់ប្រជាជននានាដែលចាញ់បោកគេដូច្នេះ កុំឃ្លាតឆ្ងាយពីភារកិច្ចរបស់ខ្លួន ។ សូមឲ្យប្រជាជនទាំងនោះយល់ឃើញថា «អំណាចទាំងឡាយសុទ្ធតែមកពីព្រះជាម្ចាស់ គឺព្រះអង្គបានតែងតាំងឲ្យមានអំណាចទាំងនោះឡើង ។ ដូច្នេះ អ្នកដែលប្រឆាំងនឹងអាជ្ញាធរ ក៏ដូចជាប្រឆាំងនឹងរបៀបរៀបរយដែលព្រះជាម្ចាស់បានចាត់ចែងនោះដែរ ។ អ្នកដែលប្រឆាំងមុខជាធ្វើឲ្យខ្លួនមានទោសមិនខាន» (រម ១៣, ១-២) ។*

*សារលិខិត«យើងនឹកឆ្ងល់» របស់អភិបាលក្រុងរ៉ូម គ្រេគ័រ ទី ១៦*
*ថ្ងៃទី ១៥ សីហា ១៨៣២*

### *ខ- ឧស្សាហូបនីយកម្ម និង កំណើតវណ្ណៈអធន*

នៅសតវត្សទី ១៩ ឧស្សាហកម្មនៅទ្វីបអឺរ៉ុបរីកចម្រើនឡើង ជាពិសេសនៅប្រទេសអង់គ្លេសនិងប្រទេសបារាំង ។ រោងចក្រតម្បាញនិងរ៉ែជាច្រើនលូតលាស់ឡើងយ៉ាងលឿន បណ្តាលឲ្យអ្នកស្រែចម្ការទៅរស់នៅទីក្រុងយ៉ាងសែនវេទនាជាទីបំផុត ។ ថៅកែជាច្រើនជិះជាន់កម្មករ គិតតែពីចង់បានចំណេញយ៉ាងអយុត្តិធម៌តាមលទ្ធិសេរីនិយមឥតព្រំដែន ។

គ្រីស្តបរិស័ទមិនទាន់ធ្លាប់រិះគិតអំពីយុត្តិធម៌ក្នុងសង្គមទេ ពីព្រោះសភាពការណ៍សង្គមឧស្សាកម្មនៅថ្មីពេក គេធ្លាប់គិតគូរតាមសភាពការណ៍សង្គមពីមុន គឺសង្គមបាត់បែងក្រុមតាមអាជីវកម្ម ដែលមានទាំងថៅកែនិងកម្មកររួមគ្នាក្នុងក្រុមសាជីវកម្មនោះ (Corporations) ។ ថៅកែគ្រីស្តបរិស័ទខ្លះមានចិត្តមេត្តាហើយបង្កើតក្រុមមនុស្សធម៌ ដើម្បីជួយកម្មករ ។ រីឯព្រះសហគមន៍ធ្លាប់ប្រៀន
114 ប្រដៅកម្មករជាគ្រីស្តបរិស័ទ ឲ្យធ្វើពិធីបុណ្យតាមគ្រីស្តសាសនា ឲ្យទ្រាំទ្រសភាពការណ៍ដ៏វេទនារបស់ខ្លួន ព្រមទាំងគោរពរបៀបរៀបរយក្នុងសង្គម ។ គ្រីស្តបរិស័ទមួយចំនួនទៀតចាប់ផ្តើមទាមទារយុត្តិធម៌ សូមឲ្យរដ្ឋអំណាចចាត់ចែងឧស្សាហកម្មតាមរបៀបប្រជាធិបតេយ្យ ។ ពួកគេមិនគ្រាន់តែចង់បានទានតាមមនុស្សធម៌ប៉ុណ្ណោះទេ គឺទាមទារយុត្តិធម៌វិញ ។ ចំណោមគ្រីស្តបរិស័ទទាំងនោះ មានលោក
**ហ្វ្រេដេរីក-អូសាណាម** (Frédéric Ozanam) ជាដើម ។ គ្រីស្តបរិស័ទមិនទាន់ 115
យល់អំពីមុខងាររបស់ខ្លួនក្នុងសង្គម និងក្នុងនយោបាយនៅឡើយ ។ 116

គ្រីស្តបរិស័ទជាច្រើនភ័យខ្លាចនៅពេលជួបសភាពការណ៍ថ្មីនោះ និងខ្លាចលទ្ធិសង្គមនិយម ។ គេនៅអាឡោះអាល័យរបបរាជានិយមកាលពីមុន ដែលមានរបៀបរៀបរយ ។ អ្នកខ្លះយល់ឃើញថា មានតែអភិបាលក្រុងរ៉ូមប៉ុណ្ណោះ ដែលអាចសង្គ្រោះសង្គមគេបាន ។ គេរាប់លោកដូចជាអាទិទេពមួយអង្គ ។

### ***គ- ប្រទេសកម្ពុជា*** *("ប្រវត្តិព្រះសហគមន៍នៅប្រទេសកម្ពុជា" ទំព័រ ៩៣-១២៤)*

- កងទ័ពសៀមនិងអាណ្ណាមលេបទឹកដីកម្ពុជា ។
- ឆ្នាំ ១៨៤៥ ព្រះបាទ**អង្គឌួង**ឡើងសោយរាជ្យនៅព្រះរាជធានីឧត្តុង្គ ។
- លោក**មីស្ស**ជាអភិបាលព្រះសហគមន៍កាតូលិក ។
- ជនជាតិវៀតណាមជាច្រើនភៀសខ្លួនមកប្រទេសកម្ពុជា ។
- ឆ្នាំ ១៨៦៣ បារាំងតែងតាំងអាណានិគមនៅលើប្រទេសកម្ពុជា ។
- ព្រះបាទ**មុនីវង្ស**យាងមកគង់នៅព្រះរាជធានីភ្នំពេញ ។
- ឆ្នាំ ១៨៦៤ អាចារ្យ**ស្វាបះបោរ**ប្រឆាំងនឹងកងទ័ពបារាំង ។

Layout Histor.qxd 2/10/07 10:10 AM Page 205

## 114 មនុស្សក្លាយទៅជាគ្រឿងម៉ាស៊ីន

លោក**បូណាលដ៍** (Bonald) ជាអភិបាលព្រះសហគមន៍លីយ៉ុង *(បារាំង)* ទាស់ចិត្តដោយឃើញថា ថៅកែតែងជិះជាន់កម្មករ ប្រើគេដូចជាគ្រឿងម៉ាស៊ីនម៉្យាង ។ ប៉ុន្តែ លោកមិនទាន់យល់ឃើញថា ត្រូវប្រែរចនាសម្ព័ន្ធខាងសេដ្ឋកិច្ចនៅឡើយ ។

*អ្នកមានចិត្តលោភលន់យល់ឃើញថា មនុស្សជាអ្វី? ចំពោះគេ មនុស្សគ្រាន់តែជាគ្រឿងម៉ាស៊ីនដែលអាចធ្វើការបាន គ្រាន់តែជាកង់ដែលមានចលនាកាន់តែលឿនឡើងៗ ឬគ្រាន់តែជាដងគំនាស់សម្រាប់គាស់ ឬជាញញួរបំបែកដុំថ្ម ជាដាងសម្រាប់ដំដែកប៉ុណ្ណោះឬអ្វី? តើកូនក្មេងជាអ្វី? គេយល់ឃើញថា កូនក្មេងគ្រាន់តែជាផ្នែកមួយក្នុងស្ពឺនៃគ្រឿងចក្រដែលមិនទាន់មានកម្លាំងពេញលេញប៉ុណ្ណោះឬ? គេយល់ឃើញថា កិត្តិយសរបស់មនុស្សមានតែប៉ុណ្ណឹងឬ? ប្រសិនបើអ្នកសួរគេថា ឯណាការសង្គ្រោះនៃសង្គម? គេមុខជាបង្ហាញចលនាគ្រឿងម៉ាស៊ីន ដែលវិលមិនចេះឈប់ឈរ ឬសកម្មភាពរបស់កម្មករដែលកំពុងផលិតរបភ្លើងដែលរត់លឿន ។*

*រដូវអប់រំពិសេស ឆ្នាំ ១៨៤២*

## 115 លោកហ្វ្រេដេរិក អូសាណាម

កម្មកររោងចក្រសូត្រនៅលីយ៉ុង នាំគ្នាបះបោរប្រឆាំងថៅកែ *(១៨៣១-១៨៣៤)* មនុស្សជាច្រើននិយាយថា កម្មករជាពួកព្រៃថ្មី ដែលគំរាមកំហែងក្រុងនានា ។ លោក**អូសាណាម** (Ozanam) និយាយថា *«ហេតុនេះហើយ បានជាយើងត្រូវតែទៅកាន់ពួកព្រៃ»* ។ ដល់ពេលផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ច និងនយោបាយសង្គមកិច្ចហើយ!

*នៅពេលខ្ញុំនិយាយថា «យើងត្រូវតែទៅកាន់ពួកព្រៃដូច្នេះ» ខ្ញុំមិនចង់និយាយថា យើងត្រូវធ្វើតាមអ្នកជ្រុលនិយមទេ (..) គឺមានន័យថា យើងត្រូវលែងកាន់ជើងព្រះមហាក្សត្រ និងមេដឹកនាំប្រទេស ហើយទៅរកប្រជាជនវិញ ។ (..) ខ្ញុំសុំឲ្យយើងយកចិត្តទុកដាក់នឹងប្រជាជនកំពុងជួបសេចក្តីត្រូវការជាច្រើន និងគ្មានសិទ្ធិគ្រប់គ្រាន់ ។ ប្រជាជនទាមទារឲ្យរួមចំណែកក្នុងការណែនាំរដ្ឋ ឲ្យមានច្បាប់ធានារ៉ាប់រងលើការងារ កុំឲ្យគេក្រីក្រតោកយ៉ាករហូត កុំឲ្យប្រជាជនចាញ់ថៅកែដ៏អាក្រក់ណែនាំ ។*

*លិខិតលោកអូសាណាម ២២ កុម្ភៈ ឆ្នាំ ១៨៤៨*



*លោក ហ្វ្រេដេរិក អូសាណាម*

Layout Histor.qxd 2/10/07 10:11 AM Page 206

## ២- មហាសន្និបាតវ៉ាទីកង់ ទី ១ (១៨៦៩-១៨៧០)

នៅគ.ស. ១៨៦១ ស្តេច **វិកទ័រ-អេម៉ានូអែល** (Victor-Emmanuel) ប្រមែប្រមូលក្រុងនិងរដ្ឋផ្សេងៗនៃប្រទេសអ៊ីតាលី ចូលរួមធ្វើជាព្រះរាជាណាចក្រតែមួយ ។ ទ្រង់រឹបអូសយកតំបន់ជាច្រើននៃព្រះរាជាណាចក្ររបស់អភិបាលក្រុងរ៉ូម *(រដ្ឋរបស់មហាបូជាចារ្យ)* ។ ប៉ុន្តែ គ្រីស្តបរិស័ទស្ទើរតែទាំងអស់ក្នុងពិភពលោកសុខចិត្តការពាររដ្ឋអំណាចអភិបាលក្រុងរ៉ូមនោះ គឺឲ្យលោកត្រួតត្រាលើរដ្ឋមហាបូជាចារ្យវិញ ដើម្បីឲ្យលោកមានសេរីភាព ។ គ្រីស្តបរិស័ទជាច្រើនក៏ប្រឆាំងនឹងលទ្ធិសង្គមនិយមដែរ ហើយក៏ទាមទារឯកសិទ្ធិសម្រាប់ព្រះសហគមន៍ឲ្យបានដូចកាលពីពេលមុនៗមក ។

ពេលនោះ ក៏មានបញ្ញវ័ន្តអឺរ៉ុបចាប់ផ្តើមជំទាស់នឹងគ្រីស្តសាសនា ដោយអះអាងលើប្រាជ្ញារបស់មនុស្ស ។

ពេលជាមួយគ្នានោះ មានគ្រីស្តបរិស័ទខ្លះគោរពអភិបាលក្រុមរ៉ូមហួសហេតុទុកជាព្រះមួយអង្គគង់នៅលើផែនដី ដែលមិនអាចភ័ន្តច្រឡំអំពីជំនឿបានឡើយ ។ ហេតុនេះហើយ បានជាឆ្នាំ ១៨៦៤ អភិបាលក្រុងរ៉ូម **ពីយ៉ូទី ៩** សរសេរឯកសារពីរច្បាប់គឺ មួយជាសារលិខិតដាក់ទោសអ្នកប្រើប្រាជ្ញាមករិះគន់គ្រីស្តសាសនា ដាក់ទោសគ្រីស្តបរិស័ទបារាំងដែលចង់បង្កើតសាសនាជាតិ ដាក់ទោសលទ្ធិសង្គមនិយម ដាក់ទោសអ្នកទាមទារសេរីភាព ។ល។ ឯកសារទីពីរហៅថា *«បញ្ជីប្រធានបទ»* (Syllabus) លោកដាក់ទោសប្រធានបទ ៨៤ ឃ្លា ដែលលោកយល់ឃើញថាខុសនឹងជំនឿ ។ (សព្វថ្ងៃ ព្រះសហគមន៍កាន់តាមសេចក្តីជាច្រើនដែលអភិបាលព្រះសហគមន៍ក្រុងរ៉ូមដាក់ទោសនៅពេលនោះវិញ) ។

គ្រីស្តបរិស័ទដែលអះអាងតាមប្រពៃណីមានអំណរសប្បាយយ៉ាងខ្លាំង ផ្ទុយទៅវិញ គ្រីស្តបរិស័ទដែលយកចិត្តទុកដាក់ធ្វើឲ្យជំនឿសម្របតាមសម័យ មិនដឹងថា ត្រូវគិតយ៉ាងណាទេ ។

ក្នុងបរិយាកាសដ៏សែនស្មុគស្មាញនោះ ព្រះសហគមន៍និងសង្គមមនុស្ស មិនសូវមានទំនាក់ទំនងជាមួយគ្នាទេ សូម្បីតែក្នុងផ្ទៃព្រះសហគមន៍ក៏មានការជជែកវែកញែកខ្វែងគំនិតគ្នាដែរ ។ ដូច្នេះហើយ ទើបអភិបាលក្រុងរ៉ូម **ពីយ៉ូទី ៩** សម្រេចចិត្តកោះហៅអស់លោកអភិបាល ឲ្យចូលរួមក្នុងមហាសន្និបាតនៅបូរីវ៉ាទីកង់ ។

អភិបាលព្រះសហគមន៍ជាង ៧០០ នាក់ ក្នុងចំណោមអភិបាល ១.០០០ នាក់ក្នុងពិភពលោកទាំងមូលចូលរួមប្រជុំថ្ងៃទី ៨ ធ្នូ ១៨៦៩ ។ ប៉ុន្តែ អភិបាលទាំងនោះសុទ្ធតែជនជាតិអឺរ៉ុបទាំងអស់ ។ គណៈកម្មាធិការផ្សេងៗរៀបចំឯកសារស្តីអំពីប្រធានបទផ្សេងៗជាច្រើនរួចហើយ ។ ថ្ងៃ ២៤ ខែមេសា ១៨៧០ មហាសន្និបាតប្រកាសគោលលទ្ធិជំនឿ បញ្ជាក់អំពីទំនាក់ទំនងរវាងប្រាជ្ញានិងជំនឿ គឺមហាសន្និបាតប្រកាសថា ទោះបីមនុស្សត្រូវការពន្លឺ និងព្រះទ័យប្រណីសណ្តោសរបស់ព្រះ 117
ជាម្ចាស់ ដើម្បីឲ្យស្គាល់ព្រះអង្គក្តី ក៏មនុស្សអាចស្គាល់ព្រះអង្គដោយប្រាជ្ញារបស់ខ្លួនបាន ប្រាជ្ញាមិនជំទាស់នឹងជំនឿទេ ។

អភិបាលជាច្រើនក្នុងមហាសន្និបាត សុំពិភាក្សាគ្នាអំពីឯកសិទ្ធិអភិបាលក្រុងរ៉ូម ក្នុងឋានៈជាមេដឹកនាំទីមួយនៃព្រះសហគមន៍ ដែលមិនអាចភ័ន្តច្រឡំបាននៅពេលលោកប្រកាសសេចក្តីពិតអំពីជំនឿរបស់ព្រះសហគមន៍ ។ អភិបាលមួយចំនួនមិនយល់ស្របនឹងសេចក្តីប្រកាសនេះ ហើយចាកចេញទៅ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មហាសន្និបាតប្រកាសសេចក្តីនេះថ្ងៃទី ១៨ កក្កដា ឆ្នាំ ១៨៧០ ។

ប៉ុន្តែថ្ងៃទី ១៩ កក្កដា ប្រទេសបារាំងនិងអាល្លឺម៉ង់ ចាប់ផ្តើមច្បាំងគ្នា ។ ថ្ងៃ ២០ កញ្ញា កងទ័ពអ៊ីតាលីវាយដណ្តើមយកក្រុងរ៉ូម ហើយលើកក្រុងរ៉ូមនេះធ្វើជាព្រះរាជធានីប្រទេសអ៊ីតាលីទាំងមូល ។ មហាសន្និបាតចប់ត្រឹមនេះ ។

ចាប់តាំងពីពេលនោះមក អភិបាលក្រុងរ៉ូមបាត់អំណាចលើ «រដ្ឋមហាបូជាចារ្យ» តែលោកទទួលអំណាចណែនាំព្រះសហគមន៍ ក្នុងឋានៈជាអភិបាលព្រះសហគមន៍ទាំងមូលវិញ ។

Layout Histor.qxd 2/10/07 10:11 AM Page 207

## 116 ប្រជាជនមិនសុំទានទេ គឺសុំយុត្តិធម៌វិញ

កម្មករខ្លះជាគ្រីស្តបរិស័ទកាន់តាមលទ្ធិសង្គមនិយម គេនាំគ្នាប្រឆាំងនឹងការផ្តល់អំណោយ និងកិច្ចការផ្សេងៗតាមមនុស្សធម៌ដែលព្រះសហគមន៍ធ្វើដើម្បីជួយគេ គឺគេចង់បានយុត្តិធម៌វិញ ។

*ប្រជាជនមិនសុំឲ្យគេធ្វើទានដល់ខ្លួនទេ និងមិនសុំឲ្យគេអាណិតតាមមនុស្សធម៌ ឬតាមសាសនាទេ ប្រជាជនក៏មិនសុំទានដែរ បើត្រូវជាប់ជាខ្ញុំគេដើម្បីបានអាហារនោះ ។ ប្រជាជនសុំឲ្យខ្លួនមានកន្លែងមួយ នៅក្នុងមហាគ្រួសាររបស់មនុស្ស ឲ្យគេទទួលស្គាល់សិទ្ធិរបស់ខ្លួន ឲ្យចូលរួមក្នុងការណែនាំរដ្ឋ ។ ប្រជាជនសុំឲ្យមានសិទ្ធិសេរីភាពប្រមូលផលដែលខ្លួនបានសាបព្រោះដោយកិច្ចការរបស់ខ្លួន គឺសុំរំលាយឯកសិទ្ធិទាំងប៉ុន្មានរបស់អ្នកមានធនធាន សូមមនុស្សមួយចំនួនតូចលែងយកទ្រព្យសម្បត្តិទូទៅមកចាយយ៉ាងខ្ជះខ្ជាយ (...) ។ យើងចង់ឲ្យបូជាចារ្យចូលរួមជាមួយប្រជាជន ក្នុងកិច្ចទាមទារសេរីភាពនោះ ។ ប៉ុន្តែ អន្តរាគមន៍របស់បូជាចារ្យនោះត្រូវស្របតាមគំនិតជាគ្រីស្តបរិស័ទសុទ្ធសាធ ។*

*ប្រ៉ូវដេរីក អូសាណាម "សារព័ត៌មានរោងចក្រ" ឆ្នាំ ១៨៤៥*

## 117 អភិបាលក្រុងរ៉ូម មានឋានៈប្រសើរជាងអភិបាលឯទៀតៗ និងមិនអាចភ័ន្តច្រឡំអំពីជំនឿ

*គោលលទ្ធិ «គង្វាលដែលស្ថិតស្ថេរអស់កល្បជានិច្ច» របស់មហាសន្និបាតវ៉ាទីកង់ទី ១*

*(..) យើងបង្រៀននិងប្រកាសថា ព្រះសហគមន៍ក្រុងរ៉ូមមានអំណាចជាធម្មតា នាំមុខព្រះសហគមន៍ឯទៀតទាំងអស់តាមព្រះអម្ចាស់បានចាត់ចែងឲ្យ ។ មហាបូជាចារ្យក្រុងរ៉ូមមានអំណាចណែនាំយ៉ាងពិតប្រាកដដោយផ្ទាល់ នេះត្រូវតាមឋានៈលោកជាអភិបាល ។ អភិបាលគ្រីស្តបរិស័ទទាំងអស់ ម្នាក់ៗក្តី ដោយឡែកក្តី រួមគ្នាក្តី ក៏ត្រូវតែចុះចូលក្រោមអំណាចដ៏វិសុទ្ធនេះ និងត្រូវស្តាប់យ៉ាងពិតប្រាកដ មិនគ្រាន់តែអំពីសេចក្តីដែលទាក់ទិននឹងជំនឿ ហើយនឹងសីលធម៌ប៉ុណ្ណោះទេ គឺអំពីសេចក្តីដែលទាក់ទិននឹងវិន័យ និងអំពីការចាត់ចែងរបស់ព្រះសហគមន៍ ដែលផ្សព្វផ្សាយក្នុងពិភពលោកទាំងមូល (..) ។*

*អំណាចនៃមហាបូជាចារ្យនេះ មិនជំទាស់នឹងអំណាចរបស់អស់លោកអភិបាល ក្នុងការណែនាំផ្ទាល់ធម្មតា គឺអភិបាលដែលព្រះវិញ្ញាណបានតែងតាំង (កក ២០,២៨) ទុកជាអ្នកបន្តមុខនាទីពីក្រុមគ្រីស្តទូតមក មានអំណាចថែទាំ ណែនាំ នៅក្នុងឋានៈលោកជាគង្វាលដ៏ពិតប្រាកដ ម្នាក់ៗថែរក្សាហ្វូងដែលព្រះជាម្ចាស់បានផ្ញើឲ្យខ្លួន (..) ។*

*យើងបង្រៀននិងប្រកាសគោលលទ្ធិដែលព្រះជាម្ចាស់បានសម្តែងនេះថា ជាពិតប្រាកដគឺថា៖ ពេលមហាបូជាចារ្យក្រុងរ៉ូមប្រកាសសេចក្តីក្នុងឋានៈលោកបន្តមុខតំណែងពីគ្រីស្តទូតសិលាមក គឺនៅពេលលោកបំពេញមុខតំណែងជាគង្វាល និងបង្រៀនគ្រីស្តបរិស័ទទាំងអស់ លោកបញ្ជាក់អំពីគោលលទ្ធិម៉្យាងអំពីជំនឿក្តី អំពីសីលធម៌ក្តី ពេលនោះ ព្រះសហគមន៍ទាំងមូលត្រូវតែទទួល ព្រោះពេលនោះលោកទទួលអំណាចដ៏ខ្ពង់ខ្ពស់ជាអ្នកបន្តមុខតំណែងពីគ្រីស្តទូត**សិលា**មក ហើយព្រះជាម្ចាស់គាំទ្រលោក ដូចព្រះអង្គសន្យាគាំទ្រគ្រីស្តទូតសិលាថា លោកមិនអាចភ័ន្តច្រឡំបានទេ ដូចព្រះសង្គ្រោះយើងសព្វព្រះហឫទ័យឲ្យព្រះសហគមន៍មិនអាចភ័ន្តច្រឡំបាន នៅពេលព្រះសហគមន៍បញ្ជាក់គោលលទ្ធិអំពីជំនឿ និងអំពីសីលធម៌ ។ ហេតុនេះហើយ បានជាសេចក្តីដែលមហាបូជាចារ្យក្រុងរ៉ូមបញ្ជាក់នោះ មិនអាចប្រែប្រួលបាន ព្រោះមិនមែនមកពីព្រះសហគមន៍យល់ព្រមទេ ។*

*១៨ កក្កដា ១៨៧០*





Layout Histor.qxd 2/10/07 10:11 AM Page 209



# ព្រះសហគមន៍ និង សង្គមថ្មី

## (ឆ្នាំ ១៨៧០-១៩៣៩)

### *ក- នៅទ្វីបអឺរ៉ុប*

*នៅសម័យនោះ រដ្ឋអំណាចគ្រប់ប្រទេសនៅទ្វីបអឺរ៉ុបទាមទារសេរីភាព ចង់រួចផុតពីអំណាចព្រះសហគមន៍ ។ ស្ទើរតែនៅគ្រប់ប្រទេសរដ្ឋអំណាចបៀតបៀនគ្រីស្តបរិស័ទដោយចោទថា គ្រីស្តបរិស័ទជាអ្នកប្រឆាំងនឹងរដ្ឋ ព្រោះគ្រីស្តបរិស័ទជាច្រើនភ្ជាប់ចិត្តនឹងរបបរាជានិយមជារបបចាស់ ។ កាលពីដើម ព្រះសហគមន៍កាន់កាប់អ្វីៗទាំងអស់ក្នុងសង្គម គឺកាន់កាប់អគ្រានុកូលដ្ឋាន ការអប់រំជាតិ មន្ទីរពេទ្យ សង្គមកិច្ច ។ល ។ នៅសម័យថ្មីនោះ គ្រីស្តបរិស័ទយកចិត្តទុកដាក់បង្កើតស្ថាប័នដោយឡែកពីស្ថាប័នរដ្ឋ ដោយស្មានថា ធ្វើដូច្នេះគេអាចការពារខ្លួនបាន ។ យូរៗទៅរដ្ឋនិងព្រះសហគមន៍ទទួលស្គាល់ព្រំដែនរៀងៗខ្លួន ហើយមានទំនាក់ទំនងជាមួយគ្នាតាមរបៀបថ្មី ។*

### *ខ- នៅប្រទេសកម្ពុជា*

*(សូមអាន "ប្រវត្តិព្រះសហគមន៍" ទំព័រ ១២៥-១៥៧)*

- *ប្រទេសកម្ពុជានៅក្រោមអាណានិគមបារាំង ។*
- *១៨៨៤-១៨៨៧ ការបះបោរប្រឆាំងកងទ័ពបារាំង ។*
- *១៩០៧ សន្ធិសញ្ញាជាមួយស្រុកសៀមយកខេត្តម្លូរព្រៃ ទន្លេរពៅ បាត់ដំបង អង្គរ ភ្ជាប់នឹងក្នុងព្រះរាជាណាចក្រកម្ពុជាឡើងវិញ ។*
- *ព្រះសហគមន៍ចម្រើនឡើង តែភាគច្រើនជាជនបរទេស ។*
- *បូជាចារ្យនិពន្ធវចនានុក្រមដ៏មានឈ្មោះល្បី ។*

## ១- នៅប្រទេសអ៊ីតាលី និងនៅបូរីវ៉ាទីកង់

នៅឆ្នាំ ១៨៧០ កងទ័ពនៃព្រះរាជាណាចក្រអ៊ីតាលី ដណ្តើមយកក្រុងរ៉ូមពីអំណាចអភិបាលព្រះសហគមន៍ ហើយលើកក្រុងរ៉ូមនោះធ្វើជារាជធានីប្រទេសទាំងមូល ។ តាំងពីពេលនោះមក អភិបាលព្រះសហគមន៍ក្រុងរ៉ូមចាត់ខ្លួនទុកជាជាប់ឃុំឃាំងនៅបូរីវ៉ាទីកង់ ។ លោកហាមគ្រីស្តបរិស័ទជាតិអ៊ីតាលី រួមចំណែក

*លោក កាល់ម៉ាក្ស*
*លោក ឡេនីន*

Layout Histor.qxd 2/10/07 10:11 AM Page 210

ក្នុងនយោបាយស្រុក គឺហាមបោះឆ្នោតតំណាងរាស្ត្រ និងមិនឲ្យចុះឈ្មោះជាបេក្ខជនតំណាងរាស្ត្រដែរ ។ ពាក្យហាមឃាត់នោះ បណ្តាលឲ្យរដ្ឋាភិបាលប្រឆាំងនឹងព្រះសហគមន៍ ។ ប៉ុន្តែ គ្រីស្តបរិស័ទខ្លះបែកចិត្ត គឺគេស្រឡាញ់អភិបាលក្រុងរ៉ូមផង និងស្រឡាញ់ជាតិផង ។ គេយកចិត្តទុកដាក់បង្កើតក្រុមផ្សេងៗជាច្រើន ។ គ្រីស្តបរិស័ទនិងបូជាចារ្យខ្លះសុំសិទ្ធិចូលរួមនយោបាយ និងក្នុងការណែនាំស្រុក ។ បញ្ហានេះត្រូវបានគេដោះស្រាយនៅឆ្នាំ ១៩២៩ ដោយលោកអភិបាលក្រុងរ៉ូម និងប្រធានាធិបតីអ៊ីតាលី ឈ្មោះ **មូស្សូលីនី** (Mussolini) ធ្វើការព្រមព្រៀងគ្នានៅឡាត្រង់ ។

នៅឆ្នាំ ១៨៧៨ អភិបាលព្រះសហគមន៍ក្រុងរ៉ូម**លេអូ ទី ១៣** បន្តមុខតំណែងពីលោក **ពីយ៉ូ ទី ៩** ។ លោកយកចិត្តទុកដាក់នឹងបញ្ហាសំខាន់ៗក្នុងសង្គមមនុស្សនៅសម័យលោក ជាពិសេសលោកទាមទារយុត្តិធម៌ឲ្យកម្មករដែលត្រូវគេជិះជាន់សង្កត់សង្កិន ។ លោកនិពន្ធលិខិតដ៏ល្បីមានចំណងជើងថា *«សភាពការណ៍ថ្មីៗ»* (Rerum Novarum ១៨៩១) ។

នៅឆ្នាំ ១៩០៣ លោក **ពីយ៉ូទី ១០** បន្តមុខតំណែនពីលោកលេអូ ទី ១៣ ។ លោកយកចិត្តទុកដាក់ណែនាំគ្រីស្តបរិស័ទ ប្រៀនប្រដៅអំពីពិធីបុណ្យ តែលោកមិនចូលចិត្តរឿងនយោបាយទេ ។

## ២- ប្រទេសអាល្លឺម៉ង់រួមគ្នាជាចក្រភពមួយ

នៅឆ្នាំ ១៨៧១ ខេត្តនិងរដ្ឋផ្សេងៗដែលនៅស្រុកអាល្លឺម៉ង់ រួបរួមគ្នាធ្វើជាចក្រភពមួយ គឺចក្រភពអាល្លឺម៉ង់ ។ គ្រីស្តបរិស័ទកាតូលិកមិនសូវសប្បាយចិត្តទេ ព្រោះគេត្រូវរស់នៅជាមួយប្រូតេស្តង់ ។ គេនាំគ្នាបង្កើតសមាគម និងគណបក្សនយោបាយដើម្បីការពារសិទ្ធិរបស់ខ្លួន ហើយយកចិត្តទុកដាក់នឹងសង្គមកិច្ច ។ រដ្ឋអំណាចតែងតែជំទាស់នឹងគ្រីស្តបរិស័ទកាតូលិកជាញឹកញាប់ ។

## ៣- សាសនា និង នយោបាយនៅប្រទេសបារាំង

នៅឆ្នាំ ១៨៧០ កងទ័ពបារាំងចាញ់កងទ័ពអាល្លឺម៉ង ។ ប្រជាជននៅក្រុងប៉ារីស នាំគ្នាបះបោរ ហើយបង្កើតជារដ្ឋតូចមួយដែលប្រឆាំងព្រះសហគមន៍ ។ តែរដ្ឋាភិបាលដណ្តើមយកក្រុងប៉ារីសវិញ ហើយសម្លាប់មនុស្សជាច្រើនអនេក ។ បូជាចារ្យនិងអភិបាលជាច្រើនក៏ត្រូវពួកបះបោរសម្លាប់ដែរ ។ គ្រីស្តបរិស័ទកាតូលិកជាច្រើននៅតែជាប់ចិត្តនឹងរបបរាជានិយម រីឯរដ្ឋាភិបាលកាន់តាមសាធារណរដ្ឋនិយម ។ យូរៗទៅ រដ្ឋាភិបាលនិងព្រះសហគមន៍ទាស់ទែងគ្នា រដ្ឋាភិបាលក៏បង្កើតច្បាប់ប្រឆាំងព្រះសហគមន៍ ហើយដកសិទ្ធិអប់រំយុវជនចេញពីព្រះសហគមន៍ ។ អស់លោកអភិបាលសុំឲ្យឪពុកម្តាយអប់រំជំនឿកូន ហើយបង្កើតគ្រូអប់រំជំនឿ ។ ព្រះសហគមន៍បង្កើតស្ថាប័នដោយឡែកពីស្ថាប័នរដ្ឋ ។

លោក **ឡេអូ ទី ១៣** (១៨៧៨-១៩០៣) ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម សរសេរសារលិខិតសុំឲ្យគ្រីស្តបរិស័ទបារាំង សុខចិត្តទទួលយករបបសាធារណរដ្ឋនិយម (១៨៩២) ។ ប៉ុន្តែ គ្រីស្តបរិស័ទបារាំងមិនសូវពេញចិត្តទេ ។ ដូច្នេះ រដ្ឋាភិបាលទាស់ទែងកាន់តែខ្លាំងឡើងៗប្រឆាំងនឹងគ្រីស្តបរិស័ទ គឺរដ្ឋាភិបាលបញ្ជាឲ្យបិទក្រុមគ្រួសារបព្វជិតទាំងអស់ និងបៀតបៀនធ្វើបាបគ្រីស្តបរិស័ទទៀតផង ។

នៅឆ្នាំ ១៩០៥ រដ្ឋាភិបាលចេញច្បាប់មួយ បំបែករដ្ឋអំណាចចេញពីព្រះសហគមន៍ និងទទួលស្គាល់ថា មនុស្សទាំងអស់មានសិទ្ធិសេរីភាពខាងសាសនា ។ រដ្ឋលែងផ្តល់ថវិកាឲ្យព្រះសហគមន៍ទៀត ។ តាំងពីពេលនេះតទៅ សមាគមគ្រីស្តបរិស័ទផ្សេងៗគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់ព្រះសហគមន៍ ។

លោក**ពីយ៉ូ ទី ១០** (១៩០៣-១៩១៤) មិនយល់ស្របនឹងច្បាប់នេះទេ ហើយដាក់ទោសគ្រីស្តបរិស័ទដែលចូលរួមក្នុងសមាគមទាំងនោះ ។ តែតាមពិត ច្បាប់នេះផ្តល់សិទ្ធិសេរីភាពថ្មីដល់ព្រះសហគមន៍នៅប្រទេសបារាំង ។ នៅពេលក្រោយប្រទេសជាច្រើនយកតម្រាប់តាមប្រទេសបារាំង ។

## ៤- ព្រះសហគមន៍ និង យុត្តិធម៌ក្នុងសង្គម

នៅស្រុកអាល្លឺម៉ង់និងអាមេរិក សេដ្ឋកិច្ចលូតលាស់ជាខ្លាំង ។ គ្រីស្តបរិស័ទស្រុកទាំងពីរនោះយកចិត្តទុកដាក់នឹងវណ្ណៈអធនដែលកំពុងកើតឡើង តែពួកគេមិនទាន់ចេះវិភាគអំពីមូលហេតុនៃអយុត្តិធម៌ក្នុងសង្គមឲ្យបានច្បាស់នៅឡើយទេ ។ នៅឆ្នាំ ១៨៤៨ ប្រទេសបារាំងកើតវិបត្តិសង្គម គឺប្រជាជនកម្មករបះបោរប្រឆាំងនឹងអ្នកមាន នាំឲ្យអភិបាលព្រះសហគមន៍មួយចំនួនធំភ័យខ្លាច ។

ដើមដំបូង អ្នកប្រកាន់លទ្ធិសង្គមនិយម មានបំណងចង់កែទម្រង់សេដ្ឋកិច្ច និងសង្គមឲ្យត្រូវតាមគោលជំហរនៃគ្រីស្តសាសនា ។ ប៉ុន្តែ នៅក្រោយឆ្នាំ ១៨៤៨ គេបែរជាប្រឆាំងនឹងគ្រីស្តសាសនាយ៉ាងខ្លាំងទៅវិញ ដោយយល់ឃើញថា ព្រះសហគមន៍កាន់ជើងអ្នកមានអំណាចខាងនយោបាយ និងអំណាចខាងសេដ្ឋកិច្ច ។ លោក**ព្រូដុំ** (Proudhom ១៨០៩-១៨៦៥) សរសេរថា *«អ្នកមានកម្មសិទ្ធឯកជនសុទ្ធតែជាចោរ ។ ព្រះជាម្ចាស់គឺជាសេចក្ដីអាក្រក់តែម្ដង! ត្រូវតែផ្លាស់ប្ដូរសាសនាដោយប្រកាន់យកយុត្តិធម៌ជំនួសវិញ»* ។ នៅឆ្នាំ ១៨៤៨ លោក**កាល ម៉ាក្ស** (Karl Marx) សរសេរនិងបោះពុម្ពផ្សាយសៀវភៅមានចំណងជើងថា *«សេចក្ដីប្រកាសកុម្មុយនីស្ត»* ហើយនៅឆ្នាំ ១៨៦៩ សៀវភៅ *«មូលធន»* (Le Capital) ដែលជាគ្រឹះនៃលទ្ធិម៉ាឡេនីន ជាវិធីវិភាគទំនាស់ក្នុងសង្គម ហើយដែលមានឥទ្ធិពលក្នុងពិភពលោកទាំងមូលរហូតមកសព្វថ្ងៃ ។ លោកបង្កើតលទ្ធិសង្គមនិយមវិទ្យាសាស្ត្រ គឺថាការតស៊ូវណ្ណៈធ្វើឲ្យប្រវត្តិសាស្ត្រចម្រើនឡើង ។ សាសនាជាថ្នាំញៀន បំភាន់ប្រជាជន ព្រោះសាសនាតែងប្រៀនប្រដៅឲ្យអ្នកក្រីក្រខិតខំស៊ូទ្រាំក្នុងលោកនេះ ដោយសង្ឃឹមថា នឹងបានសុភមង្គលនៅលោកខាងមុខ ។ នៅឆ្នាំ ១៨៦៤ កើតសមាគមពលករអន្តរជាតិ ដែលប្រៀបដូចជាអង្គការមួយជំនួសព្រះសហគមន៍ ។ អភិបាលព្រះសហគមន៍ទាំងប៉ុន្មាន នាំគ្នាជំទាស់ប្រឆាំងនឹងលទ្ធិសង្គមនិយមបែបនេះដែលតែងប្រកាសថា គ្មានព្រះជាម្ចាស់ឡើយ ។ ម្យ៉ាងទៀត លទ្ធិសង្គមនិយមមានគោលដៅកែប្រែរចនាសម្ពន្ធសង្គមទាំងមូល ដែលអស់លោកស្មានថា ព្រះជាម្ចាស់សព្វព្រះហឫទ័យបង្កើតនោះ ។ អស់លោកចេះតែដាស់តឿនគ្រីស្តបរិស័ទឲ្យស៊ូទ្រាំ និងបង្កើតអង្គការមនុស្សធម៌សម្រាប់ជួយអ្នកក្រីក្រ ។

គ្រីស្តបរិស័ទខ្លះយកចិត្តទុកដាក់នឹងការងារសង្គម តែគេមិនកាន់តាមលទ្ធិសេរីនិយមទេ ភាគច្រើនយល់ឃើញថា លទ្ធិសេរីនិយមបណ្ដាលឲ្យកើតសភាពដ៏លំបាកនេះ ព្រោះលទ្ធិនេះ បានរំលាយក្រុមសាជីវកម្ម (corporations) ដែលតែងតែជួយការពារកម្មករនៅសម័យមុនៗទៅហើយ ។ ហេតុនេះ ហើយបានជាគេយល់ឃើញថា ត្រូវតែបង្កើតសង្គមដូចដើមឡើងវិញដើម្បីឲ្យបានស្រួល ។ ពួកគេបង្កើតសមាគមមនុស្សធម៌ជាច្រើន ចៅកែជាគ្រីស្តបរិស័ទក៏យកចិត្តទុកដាក់នឹងជីវភាពកម្មករ ទុកជាអំណោយមកពីមេត្តាករុណារបស់គេ ។ រីឯកម្មករវិញ គេមិនពេញចិត្តទេ ព្រោះគេទាមទារតែយុត្តិធម៌ក្នុងសង្គមប៉ុណ្ណោះ ។

### *ក- កំណើតលទ្ធិកាតូលិកអំពីសង្គមកិច្ច*

លោក**លេអូទី ១៣** ជាអភិបាលក្រុងរ៉ូមបារម្ភយ៉ាងខ្លាំង ដោយឃើញលទ្ធិសង្គមនិយម និងអនាធិបតេយ្យក្នុងសង្គមរីកចម្រើននៅទ្វីបអឺរ៉ុប ។ ឆ្នាំ ១៨៩០ កម្មករនាំគ្នាធ្វើកូដកម្ម ហើយត្រូវរដ្ឋអំណាចនានាសម្លាប់កម្មករជាច្រើន ។

លោកអភិបាលក្រុងរ៉ូមសង្កេតឃើញថា សភាពការណ៍ក្នុងសង្គមប្លែកពីមុន គឺមូលធននិយមប្រមូលធនធានកាន់តែច្រើនឡើងៗ កម្មករក៏រស់នៅក្នុងសភាពក្រីក្រតោកយ៉ាក ទ្រាំមិនកើត ។ លោកដាក់ទោសលទ្ធិសង្គមនិយម ដោយយល់ឃើញថា លទ្ធិនោះលប់បំបាត់កម្មសិទ្ធិឯកជន ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យបង្កើត ។ លោករំឭកគោលការណ៍សំខាន់ៗរបស់ព្រះសហគមន៍ គឺតាមធម្មជាតិមនុស្សមិនស្មើគ្នាទេ តែមនុស្សទាំងអស់ត្រូវរួមរស់ជាមួយគ្នា ។ លោកមិនសុខចិត្តឲ្យកើតការតស៊ូវណ្ណៈក្នុងសង្គម ។ រដ្ឋត្រូវចែកធនធានជាតិឲ្យបានសមរម្យ តាម

Layout Histor.qxd 2/10/07 10:11 AM Page 212

រយៈពេលម្នាក់ៗធ្វើការ ឲ្យមានច្បាប់សម្រាករាល់អាទិត្យ និងមានប្រាក់ខែល្មម
សម្រាប់ចិញ្ចឹមគ្រួសារ ។ល។ គឺលោកសូមឲ្យបង្កើតច្បាប់ការងារ ។ លោកដាក់
ទោសចំពោះលទ្ធិសេរីនិយមខាងសេដ្ឋកិច្ច ដែលបណ្ដាលឲ្យអ្នកកាន់អំណាច និង
អ្នកមាន ជិះជាន់អ្នកក្រីក្រតាមចិត្ត ។ លោកដាស់តឿនដល់កម្មករ ឲ្យរួមគ្នាជា
សមាគម គឺលោកសូមឲ្យបង្កើតក្រុមសាជីវកម្ម ដូចកាលពីដើម *(ថៅកែរួមនិង
កម្មករ)* តែលោកមិនជំទាស់ឲ្យមានសហជីពឡើយ ។

លិខិតនេះនាំឲ្យគ្រីស្តបរិស័ទភ្ញាក់ផ្អើល លិខិតនេះបញ្ជាក់ពីគោលជំហរខាង
118 សង្គមកិច្ចរបស់ព្រះសហគមន៍នៅសម័យនោះ គឺជាជំហ៊ានដើមដំបូងសម្រាប់គ្រីស្ត
បរិស័ទរិះគិតតទៅទៀត ។ លិខិតនេះ នាំឲ្យគ្រីស្តបរិស័ទជាច្រើនចាប់អារម្មណ៍
នឹងយុត្តិធម៌ក្នុងសង្គម ។ ថៅកែជាគ្រីស្តបរិស័ទ មិនព្រមឲ្យកម្មកររួមគ្នាបង្កើត
សហជីព ហើយក៏មិនព្រមឲ្យរដ្ឋបញ្ចេញច្បាប់តាមសង្គមកិច្ច ។ ទោះជាយ៉ាងណា
ក្ដី ក៏នៅឆ្នាំ ១៨៨៧ កម្មករគ្រីស្តបរិស័ទបង្កើតសហជីព ។ គ្រីស្តបរិស័ទបង្កើត
ក្រុមនិងសមាគមផ្សេងៗ ហើយនាំគ្នាវិភាគសភាពការណ៍ក្នុងសង្គមតាមគម្ពីរ និង
តាមសេចក្ដីប្រៀនប្រដៅរបស់អភិបាលក្រុងរ៉ូម ។

ប៉ុន្តែយូរៗទៅ ក្រុមទាំងនោះទំនាស់នឹងក្រុមអភិបាលដែលខ្លាចគ្រីស្តបរិស័ទ
រួចផុតពីអំណាចរបស់ខ្លួនទៅរួមជាមួយអ្នកផ្សេង មានអ្នកសង្គមនិយមជាដើម ។

នៅឆ្នាំ ១៩២៩ អភិបាលព្រះសហគមន៍ក្រុងរ៉ូម **ពីយ៉ូទី ១១** អនុញ្ញាតឲ្យ
គ្រីស្តបរិស័ទបង្កើតសហជីព ។ អភិបាលព្រះសហគមន៍នៅលិល *(ស្រុកបារាំង)*
កាន់ជើងកម្មករដែលប្រឆាំងនឹងថៅកែ ។ ឆ្នាំនោះកើតវិបត្តិសេដ្ឋកិច្ចសកល ។ 119
អភិបាលព្រះសហគមន៍ក្រុងរ៉ូម សរសេរសារលិខិតមួយច្បាប់ទៀតបញ្ជាក់គោល
ជំហរព្រះសហគមន៍ គឺលោកនៅតែស្ដីបន្ទោសលទ្ធិសង្គមនិយម តែលោកសុំឲ្យ
រដ្ឋាភិបាលនានាចាត់ចែងសេដ្ឋកិច្ចសកល និងរបៀបរៀបរយសង្គមសារជាថ្មី ។

## *ខ- កំណើតនៃចលនាជាគ្រីស្តទូតក្នុងសង្គម*

គ្រីស្តបរិស័ទដែលទទួលអគ្គសញ្ញាជ្រមុជទឹក មានភារកិច្ចទៅជាគ្រីស្តទូត
ប្រកាសដំណឹងល្អ ។ ឆ្នាំ ១៩២៥ លោក**ការឌីន** (Cardijn) បង្កើតក្រុម *«យុវជន
កម្មករគ្រីស្តបរិស័ទ»* (Jeunesse Ouvrière Chrétienne) ។ យុវជននោះធ្វើ 120
ជាសាក្សីអំពីព្រះយេស៊ូនៅកន្លែងដែលខ្លួនរស់នៅ តាមគោលជំហរបីយ៉ាងគឺ
*«ពិនិត្យសភាពការណ៍ រិះគិតពិចារណាអំពីសភាពការណ៍នោះ សម្រេចបំពេញ
សកម្មភាពដើម្បីបំប្រែសភាពការណ៍នោះ»* ។ គេយកសភាពការណ៍មករិះគិត
និងអប់រំយុវជន មិនគ្រាន់តែយកលទ្ធិគ្រីស្តសាសនាមកប្រៀនប្រដៅគេទេ ។ 121
គេយកចិត្តទុកដាក់ប្រែសង្គមមនុស្សឲ្យបានស្របតាមយុត្តិធម៌ ។

118 **សភាពការណ៍ថ្មីៗ** *១៥ ខែ ឧសភា ១៨៩១ (Rerum Novarum)*

*យើងជឿជាក់ថា ត្រូវចាត់ចែងវិធានការយ៉ាងស័ក្ដិសិទ្ធិភ្លាមៗដើម្បីជួយមនុស្សវណ្ណៈទាប ព្រោះគេរស់នៅសែនវេទនាតោកយ៉ាកមិនសមរម្យសោះ ដោយគ្មានកំហុសអ្វីឡើយ ។*

*សតវត្សមុននេះ ក្រុមសាជីវកម្ម (corporations) ដែលការពារកម្មករត្រូវរលាយ ហើយគ្មានបង្កើតអ្វីជំនួសទៀតទេ ។ ស្ថាប័នសាធារណៈលែងប្រកបដោយគំនិតខាងសាសនាទៀតហើយ ។ ដូច្នេះ យូរៗទៅកម្មករឯកោគ្មានទីពឹង ត្រូវគេបញ្ជូនក្នុងកណ្ដាប់ដៃរបស់ថៅកែអមនុស្សធម៌ដែលមានចិត្តលោភលន់ប្រណាំងប្រជែងគ្នា ។ អ្នកចងការហួសហេតុ បន្ថែមទុក្ខលំបាកលើគេទៀត ។ ពេលមុនព្រះសហគមន៍ហាមជាច្រើនដង មិនឲ្យចងការហួសកម្រិត តែចិត្តមនុស្សលោភលន់មិនចេះឆ្អែតឆ្អន់ នៅតែចងការប្រាក់តាមរបៀបផ្សេងៗ ។ លើសពីនេះទៅទៀត អ្នកមាននិងអ្នកកាន់អំណាចមួយចំនួនតូចកាន់កាប់ឧស្សាហកម្ម និងពាណិជ្ជកម្មទាំងមូល ។ ពួកគេដាក់នឹមដ៏ធ្ងន់ធ្ងរនៅលើស្មាមនុស្សអធនជាច្រើនអនេក ដែលរស់នៅតាមរបៀបទាសករ ។*

Layout Histor.qxd 2/10/07 10:11 AM Page 213

119

## ឆ្នាំខួបទី ៩០ *(ស្ដីអំពីការកែទម្រង់ក្នុងសង្គមឲ្យត្រឹមត្រូវតាមការប្រៀនប្រដៅរបស់ព្រះគម្ពីរដំណឹងល្អ ។ ១៥ ខែ ឧសភា ១៩៣១)*

លោក**ពីយ៉ូទី ១១** សរសេរលិខិតនេះនៅពេលកើតវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ។ លោកពង្រីកគំនិតលោក**លេអូ ទី ១៣** ។

*(...) សភាពការណ៍សេដ្ឋកិច្ច និងសហព័ន្ធពិភពលោក បេះតែប្រែប្រួល ជំរុញឲ្យអស់អ្នកដែលចូលរួមចំណែកសេដ្ឋកិច្ច និងសហព័ន្ធពិភពលោកធ្វើសកម្មភាពដោយពេញទំហឹង ។ អ្នកខ្លះមានសតិសម្បជញ្ញៈស្ពឹកស្រពន់រឹងរូស យល់ឃើញថា គេមានសិទ្ធិប្រើគ្រប់មធ្យោបាយដើម្បីឲ្យបានចំណេញ និងការពារទ្រព្យសម្បត្តិរបស់ខ្លួន ដែលគេរកបានយ៉ាងលំបាកឲ្យបានគង់វង្ស ។ ភាពអនាធិបតេយ្យទីផ្សារ បណ្ដាលឲ្យមនុស្សខ្លះបានចំណេញយ៉ាងស្រួល ធ្វើឲ្យមនុស្សខ្លះចង់បានប្រាក់ចំណេញយ៉ាងឆាប់ ដោយគ្រាន់តែធ្វើការបន្តិចបន្តួច ឬមិនធ្វើការអ្វីឡើយ (...) ។*

*របបសេដ្ឋកិច្ចថ្មីកើតឡើងនេះ នៅសម័យដែលមនុស្សសំអាងតែលើប្រាជ្ញារបស់ខ្លួន ។ ហេតុនេះហើយ ទើបកើតវិជ្ជាសង្គមម៉្យាងដាច់ដោយឡែកពីវិន័យសីលធម៌ ហើយបើកសេរីភាពដល់តណ្ហារបស់មនុស្ស (...) ។ វត្ថុធាតុដែលគ្មានវិញ្ញាណចេញពីរោងចក្រ បានទទួលកិត្តិយសពីមនុស្ស រីឯមនុស្សដែលធ្វើការក្នុងរោងចក្រនោះវិញ ត្រូវអាប់កិត្តិយស (...)*

*អ្នកជំនាញសេដ្ឋកិច្ច តែងតែស្រែកសូមឲ្យបាត់វិជានការដោយតែងតាំងសេដ្ឋកិច្ចឲ្យមានរបៀបរៀបរយតាមប្រាជ្ញារបស់មនុស្ស ។ (...) ព្រះសហគមន៍នៅតែប្រកាសអំពីរបៀបដ៏ពេញលក្ខណៈតាមប្រាជ្ញារបស់មនុស្សដែលរិះគិតយ៉ាងត្រឹមត្រូវ ។*

120

## យុវជនកម្មករគ្រីស្ដបរិស័ទ

ព្រឹត្តិប័ត្រស្ដីអំពីចលនា «*យុវជនកម្មករគ្រីស្ដបរិស័ទ*» តែងបោះពុម្ពផ្សាយចេញពីរអាទិត្យម្ដងៗ ដើម្បីអប់រំយុវជនឲ្យស្គាល់បច្ចេកទេសទំនើប ឲ្យជៀសវាងគ្រោះថ្នាក់នៅពេលធ្វើការ ឲ្យស្គាល់ច្បាប់ ។ល។

*សភាពការណ៍កម្មករបណ្ដាលឲ្យយុវជនកម្មករបែកឆ្ងាយពីគ្រីស្ដសាសនា ឲ្យទៅជាមនុស្សខិលខូច ត្រូវគេជិះជាន់សង្កត់សង្កិន ។ គេលែងរិះគិតដោយខ្លួនឯងទៀតហើយ ។ បើសភាពការណ៍ការងារនៅតែដូច្នេះ យើងមិនបានលទ្ធផលតាមបំណងទេ ហើយក៏មិនបានបំពេញមុខងាររបស់យើងនៅឡើយដែរ (...) ។ យើងម្នាក់ៗមិនអាចប្រែសង្គមបានទេ គឺត្រូវប្រែសភាពការណ៍នៃការងាររបស់វណ្ណៈកម្មករអធនទាំងស្រុង ដែលមានច្រើនឥតគណនា និងមានកម្លាំងពលំយ៉ាងខ្លាំង ។*

*ចលនា «យុវជនកម្មករគ្រីស្ដបរិស័ទ» មានអនាគត និងចម្រើនឡើងធម្មតា ដោយសារយើងបំពេញកិច្ចការយ៉ាងជ្រៅ ដើម្បីលើកវណ្ណៈកម្មករឡើង គឺធ្វើឲ្យការរស់នៅ វប្បធម៌ និងសិល្បៈរបស់កម្មករលេចឡើង (...) ។ «យុវជនកម្មករគ្រីស្ដបរិស័ទ» នឹងមានអនាគត នៅពេលអរិយធម៌កម្មករក្លាយជាអរិយធម៌គ្រីស្ដបរិស័ទ ដូចកាលពីមុន អរិយធម៌សក្តិភូមិទៅជាគ្រីស្ដបរិស័ទដែរ ។ «យុវជនកម្មករគ្រីស្ដបរិស័ទ» មានអនាគតនៅពេលវណ្ណៈកម្មករអាចរស់នៅក្នុងសភាពការណ៍មួយ ដែលនាំឲ្យគេរស់នៅតាមរបៀបដ៏វិសុទ្ធ ការពាររូបកាយរបស់ខ្លួន គាំទ្របុគ្គលនីមួយៗ និងការពារក្រុមគ្រួសារ (...) ។ «យុវជនកម្មករគ្រីស្ដបរិស័ទ» មានអនាគតនៅពេលវណ្ណៈកម្មករទាំងអស់ទៅជាកម្មសិទ្ធិរបស់ព្រះគ្រីស្ដ (...) ។ (១៥ វិច្ឆិកា ១៩២៩)*

*ខ្ញុំមានឧត្ដមគតិតែមួយ និងបំណងយ៉ាងខ្លាំង គឺបានដូចព្រះគ្រីស្ដសុខចិត្តបូជាជីវិតដើម្បីបងប្អូន ខ្ញុំស្រឡាញ់ពួកគេដូចព្រះអង្គស្រឡាញ់គេដែរ (...) ។ បើសិនបងប្អូនយល់ឃើញថាពាក្យនេះជាប់នឹងសាសនាខ្លាំងពេក សូមនឹកគិតដល់មិត្តកុម្មុយនីស្ដដែលអះអាងថា ខ្លួនជាតំណាងវណ្ណៈកម្មករនៅពេលអនាគត គេនាំមនុស្សលោកទៅកាន់ពន្លឺនិងភាតរភាព ។ ប៉ុន្តែគួរឲ្យស្ដាយណាស់! ពួកគេមានចិត្តស្អប់វណ្ណៈឯទៀតៗ (...) ។*

*យើងរួមជាមួយពួកគេ ចាប់ដៃគេ រួមគ្នាទៅកាន់យុវកម្មករទាំងអស់ដែលនៅតែឯងឯកា ឬដែលចាញ់បោកគេ ជាពិសេសទៅកាន់កម្មករដែលអស់សង្ឃឹម ដែលខ្ពើមនឹងការរស់នៅ ហើយធ្លាក់ក្នុងអសីលធម៌ (...) ។ ជាទីបញ្ចប់ យើងនឹងសង្គ្រោះវណ្ណៈកម្មកររបស់យើង ។ (១ ធ្នូ ១៩២៩)*

Layout Histor.qxd 2/10/07 10:11 AM Page 214

### (121) អភិបាលព្រះសហគមន៍ក្រុងរ៉ូមគាំទ្រចលនា "យុវជនកម្មករគ្រីស្តបរិស័ទ" *(Quadragesimo Anno)*

*សម័យឥឡូវ ក៏ដូចកាលពីសម័យមុនៗដែរ តាមប្រវត្តិព្រះសហគមន៍ យើងប្រឈមមុខនឹងមនុស្សលោកដែលធ្លាក់ខ្លួនរហូតដល់បោលសាសនាទាំងអស់ ។ ប្រសិនបើយើងចង់ណែនាំវណ្ណៈផ្សេងៗរបស់មនុស្សដែលលះបង់បោលព្រះគ្រីស្ត ឲ្យវិលមករកព្រះគ្រីស្តវិញ យើងត្រូវជ្រើសរើសអ្នកជួយចេញពីវណ្ណៈទាំងនោះ និងអប់រំគេ ដើម្បីរួមជួយសហការក្នុងកិច្ចប្រកាសដំណឹងល្អឲ្យវណ្ណៈនោះ ព្រោះគេស្គាល់និងយល់ចិត្តអ្នកក្នុងវណ្ណៈនេះ ស្គាល់បំណងប្រាថ្នារបស់គេ និងចេះនិយាយតាមរបៀបដែលគេអាចយល់បានដោយមានចិត្តស្រឡាញ់គេដូចបងប្អូន ។ ត្រូវឲ្យកម្មករប្រកាសដំណឹងល្អដល់កម្មករ ។ អ្នកនាំដំណឹងល្អដល់សង្គមឧស្សាហកម្ម ត្រូវជាមនុស្សដែលកើតពីឧស្សាហកម្មតែម្តង ។*

*អភិបាលពីយ៉ូទី ១១ សារលិខិត "ខួបឆ្នាំទី ៤០" (១៩៣១)*

## ៥- ព្រះសហគមន៍ និង វិទ្យាសាស្រ្តទំនើប

នៅសតវត្សទី ១៧ និង ១៨ វិទ្យាសាស្រ្តបានបណ្តាលឲ្យគ្រីស្តបរិស័ទសង្ស័យអំពីសេចក្តីខ្លះដែលមានចែងក្នុងគម្ពីរ *(សូមអានទំព័រ ១៥៧, ១៧៤-១៧៥)* ។

នៅសតវត្សទី ១៩ ទស្សនវិទូជំទាស់នឹងសាសនាដោយប្រកាសថា មនុស្សជាតិដល់យុគសម័យនៃវិទ្យាសាស្រ្តហើយ ត្រូវចម្រើនឡើងជាលំដាប់ រីឯសាសនាឥតបានការទៀតឡើយ ។

អ្នកប្រាជ្ញស្រាវជ្រាវអំពីដើមកំណើតមនុស្សសន្និដ្ឋានថា មនុស្សកើតមកពីសត្វដែលតែងតែចម្រើនឡើងជាលំដាប់ តាមសេចក្តីត្រូវការ និងតាមពលកម្ម ។ លោក**ដារវិន** (Darwin) សរសេរសៀវភៅមួយមានចំណងជើងថា *"កំណើតជាតិទាំងឡាយ"* (១៨៥៩) ។ បើមនុស្សកើតមកពីសត្វមែន តើការប្រៀនប្រដៅក្នុងគម្ពីរ អំពីព្រះជាម្ចាស់បង្កើតមនុស្ស អំពីបាបឪពុកម្តាយដើមទៅជាយ៉ាងណា?

សតវត្សទី ១៩ អ្នកប្រាជ្ញខាងប្រវត្តិវិទ្យាស្រាវជ្រាវអក្សរសាស្រ្តបុរាណនិងប្រវត្តិសាស្រ្តមជ្ឈិមបូព៌ា ។ ដូច្នេះ កើតមានវិទ្យាសាស្រ្តម៉្យាង ជាវិទ្យាសាស្រ្តខាងសាសនា ។ គេយកចិត្តទុកដាក់អានអក្សរសាស្រ្តបុរាណខាងមជ្ឈិមបូព៌ា មកប្រៀបធៀបនឹងអត្ថបទគម្ពីរ ។ អ្នកប្រាជ្ញខ្លះសន្និដ្ឋានថា ក្នុងគម្ពីរមានចែងរឿងព្រេងជាច្រើន ដូចក្នុងអក្សរសាស្រ្តស្រុកឯទៀតៗ រហូតមានអ្នកខ្លះសរសេរថា សូម្បីតែគម្ពីរដំណឹងល្អ ក៏ជារឿងដែលគ្រីស្តបរិស័ទដើមដំបូងប្រឌិតឡើងដែរ ។ លោក**វេឡៅសិន** (Welhausen) បង្កើតទ្រឹស្តីអំពីឯកសារបួនក្នុងគម្ពីរបញ្ចកណ្ឌ ។ បើពិតដូចលោករកឃើញនោះ តើព្រះគម្ពីរជាព្រះបន្ទូលព្រះជាម្ចាស់មែនឬ? ព្រះជាម្ចាស់បានបំភ្លឺអ្នកនិពន្ធមែនឬ? វិទ្យាសាស្រ្តបណ្តាលឲ្យគ្រីស្តបរិស័ទនាំគ្នាសង្ស័យអំពីជំនឿរបស់ខ្លួន ។

មុនដំបូងព្រះសហគមន៍ជំទាស់ប្រឆាំងនឹងទ្រឹស្តីទំនើបទាំងនោះ គឺអភិបាលព្រះសហគមន៍ក្រុងរ៉ូមប្រកាសថា វិទ្យាសាស្រ្តទាំងប៉ុន្មានដែលជំទាស់នឹងគម្ពីរសុទ្ធតែខុស ហើយកើតមកពីមារ ។ លោក**ពីយ៉ូទី ៩** យកចំណងជើងសៀវភៅទាំងប៉ុន្មានដែលចែងអំពីទ្រឹស្តីទាំងនោះ ទៅដាក់ក្នុងបញ្ជីស្បែកឆ្កែ ហាមគ្រីស្តបរិស័ទអាន ។ នៅឆ្នាំ ១៨៦៤ លោកពីយ៉ូទី ៩ និពន្ធ **"បញ្ជីប្រកាស"** (Syllabus) គឺហាមគ្រីស្តបរិស័ទកាន់តាមលទ្ធិមួយចំនួននោះ ។ មហាសន្និបាតវ៉ាទីកង់ទី ១ (១៨៧០) ចាប់ផ្តើមរកប្រកបញ្ហាក់អំពីទំនាក់ទំនងរវាងសាសនានិងវិទ្យាសាស្រ្ត តែគ្មានសម្រេចសេចក្តីបាន ដោយកើតសង្គ្រាមប្រទេសបារាំងនិងអាល្លឺម៉ង់ ។

នៅប្រទេសអាល្លឺម៉ង់ លោក**ឌឹលិងកែរ** (Dölinger) នៅប្រទេសអង់គ្លេស លោក**ញ៉ូម៉ាន់** (Newman) និងនៅប្រទេសបារាំង លោក**មិញ ឌឹកែណ ឡាក្រង្ស** (Migne, Duchesne, Lagrange) ជាគ្រីស្តបរិស័ទអ្នកប្រាជ្ញ នាំគ្នាស្រាវជ្រាវ

វិទ្យាសាស្ត្រទំនើបទាំងនោះ និងតាមជំនឿ ស្វែងរកផ្លូវដោះស្រាយបញ្ហាទាំងនេះ ។ ឆ្នាំ ១៨៩០ លោក**ឡាក្រង់**បង្កើត *"សាលាព្រះគម្ពីរនៅយេរូសាឡឹម"* ដែលប្រមូលសុទ្ធតែអ្នកប្រាជ្ញដែលរិះគិតតាមរបៀបទំនើបនេះ ។ ទេវវិទូខ្លះរិះគិតអំពីលទ្ធិគ្រីស្តសាសនាតាមទស្សនវិជ្ជាទំនើប ដោយលះបង់ទេវវិជ្ជារបស់សន្តថូ**ម៉ាស**នៅអាគីណូ ដោយយល់ឃើញថា ហួសសម័យហើយ (គ.ស.១២៥០) ។

ឆ្នាំ ១៩០៧ លោក**ពីយ៉ូ ទី ១០** ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម បញ្ចេញក្រិត្យមួយបដិសេធសេចក្តី ៦៥ ដកស្រង់ពីការប្រៀនប្រដៅរបស់ពួក *"ទំនើបនិយម"* (Modernistes) ដែលលោកយល់ឃើញថា វង្វេងឆ្ងាយពីជំនឿដ៏ពិតប្រាកដនៃព្រះសហគមន៍កាតូលិក ។ លោកបង្គាប់សាស្ត្រាចារ្យក្នុងទេវវិទ្យាល័យនានា ឲ្យអប់រំបូជាចារ្យតាមរបៀបសន្តថូម៉ាសនៅអាគីណូវិញ ។ នៅឆ្នាំ ១៩០៩ មានកើត *"គ្រឹះស្ថានព្រះគម្ពីររបស់អភិបាលក្រុងរ៉ូម"* ។

អស់លោកអភិបាល បូជាចារ្យ ឧបដ្ឋាក ត្រូវតែស្បថបដិសេធមិនកាន់តាមលទ្ធិទំនើបនិយមរហូតដល់សព្វថ្ងៃ ។ នេះជាដើមកំណើតរបស់ចលនា *"ប្រពៃណីនិយម"* ។ ពាក្យស្តីបន្ទោសរបស់លោកពីយ៉ូទី ១០ បណ្តាលឲ្យគ្រីស្តបរិស័ទជាអ្នកប្រាជ្ញ មិនហ៊ានរិះគិតដោយសេរី ខ្លាចទទួលទោស ។

នៅឆ្នាំ ១៩៤៣ លោក**ពីយ៉ូ ទី ១២** ជាអភិបាលក្រុងរ៉ូម សរសេរសារលិខិតមួយក្រោមចំណងជើងថា *"ដោយព្រះវិញ្ញាណដ្ឋំពីលើ"* អនុញ្ញាតឲ្យអ្នកប្រាជ្ញគ្រីស្តបរិស័ទអាចរិះគិតដោយសេរីបាន ។ លោក**ស៊ីនី** (Chenu) លោក**កង់ករ** (Congar) លោក**ឌឺលូបាក** (De Lubac) រិះគិតយ៉ាងជ្រៅអំពីប្រវត្តិព្រះសហគមន៍ អំពីទំនាក់ទំនងព្រះសហគមន៍ និងមនុស្សលោកបច្ចុប្បន្ន ។ មហាសន្និបាតវ៉ាទីកង់ទី ២ (១៩៦២-១៩៦៥) នឹងបញ្ជាក់សេចក្តីជាច្រើនតាមអស់លោក ។ បន្តិចម្តងៗ គ្រីស្តបរិស័ទកាតូលិកទាមទារសេរីភាពឲ្យមានសិទ្ធិរិះគិត និងសម្រេចធ្វើអ្វីតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់និងតាមមនសិការរបស់ខ្លួន ។

## ៦- សង្គ្រាមលោកលើកទី ១ (១៩១៤-១៩១៨)

ប្រទេសបារាំងនិងប្រទេសអាល្លឺម៉ង់ធ្វើសង្គ្រាមនឹងគ្នា ។ គ្រីស្តបរិស័ទទាំងសងខាងមានបំណងការពារជាតិរបស់ខ្លួន មនោសញ្ចេតនាជាតិនិយមមានឥទ្ធិពលខ្លាំងជាងជំនឿរបស់គេ អ្នកជាតិនិយមទាំងសងខាងហាក់ដូចជាបំភ្លេចសាសនា ។ រីឯពួកសង្គមនិយមខិតខំទាមទារសន្តិភាពវិញ តែទៅមិនរួច ។

នៅប្រទេសបារាំង បូជាចារ្យក៏ត្រូវបម្រើកងទ័ពរួមជាមួយប្រជាជនដែរ ទើបព្រះសហគមន៍លែងជាសត្រូវរបស់រដ្ឋទៀត ។ អភិបាលក្រុងរ៉ូម **បេណេឌិកតូទី ១៥** (១៩១៤-១៩២២) យកចិត្តទុកដាក់ធ្វើអន្តរាគមន៍ នាំគូបដិបក្ខចរចារកសន្តិភាព ។ តែអ្នកជាតិនិយមបារាំងមិនព្រមជាដាច់ខាត ព្រោះគេចង់កម្ទេចខ្មាំងសត្រូវឲ្យអស់ជាមុនសិន ។ លោកក៏មិនពេញចិត្តនឹងការព្រមព្រៀងនៅវែរសៃ (Versailles ១៩១៨) ដែលបញ្ចប់សង្គ្រាមនេះ មកពីពួកឈ្នះមានបំណងសងសឹកអ្នកចាញ់សង្គ្រាម ជាមូលហេតុកើតសង្គ្រាមសកលលើកទី ២ ។ ធ្វើសង្គ្រាមដូច្នេះ ប្រទេសបារាំងនិងអល្លឺម៉ង់ ហាក់ដូចជាធ្វើអត្តឃាតកម្មម្យ៉ាង ។

## ៧- អំណាចលទ្ធិផ្តាច់ការកើតឡើងនៅទ្វីបអឺរ៉ុប

### *ក- របបហ្វាស៊ីស្ត នៅប្រទេសអ៊ីតាលី (Fascisme)*

ក្រោយពីសង្គ្រាមលោកលើកទី ១ គ្រីស្តបរិស័ទជាតិអ៊ីតាលីទាមទារសិទ្ធិធ្វើនយោបាយ ។ លោក**មូសូលីនី** (Mussolini) ឡើងកាន់អំណាចនៅខែតុលា ១៩២២ ហើយបង្កើតលទ្ធិហ្វាស៊ីស្ត *(ពាក្យ "ហ្វាស៊ីយ៉ូ" មកពី fascio ជាសមាគមអតីតទាហាន)* ។ អ្នកជាតិនិយមរបួសចិត្តដោយសង្គ្រាមលោកលើកទី ១ បណ្តាលឲ្យកើតជនក្រីក្រជាច្រើន ។ សង្គមមានចលាចល ឃាតកម្មជាច្រើនកើតឡើង និងសេដ្ឋកិច្ចអន់ថយ ។ ប្រជាជនតូចតាចដែលតែងតែប្រឆាំងនឹងព្រះសហគមន៍បានចូលរួមជាមួយក្រុមកាតូលិកប្រពៃណីនិយម ដែលខ្លាចពួកកុម្មុយនីស្ត ។ លោក

122 មូស្សូលីនីរំលាយបក្សនយោបាយទាំងអស់នៅឆ្នាំ ១៩២៦ ។ តាំងពីឆ្នាំ ១៩៣១ មក លោកជំទាស់នឹងព្រះសហគមន៍ ដែលមិនព្រមឲ្យរដ្ឋត្រួតត្រាអ្វីៗទាំងអស់ប្រចាំជីវិតមនុស្ស ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូមសរសេរលិខិតជំទាស់លទ្ធិនោះ ។

### *ខ- លទ្ធិជាតិសង្គមនិយមអាល្លឺម៉ង់ (Nazisme)*

លោក **អ៊ីត្លែរ** (Hitler) ប្រមែប្រមូលអស់អ្នកដែលអៀនខ្មាស់ដោយចាញ់សង្គ្រាមលោកលើកទី ១ ថា បរាជ័យនេះមកពីជនជាតិយូដា និងអ្នកកាន់តាម



*កងទ័ពអាល្លឺមង់ ជាតិសង្គមនិយមរបស់លោកអ៊ីត្លែរ*

Layout Histor.qxd  2/10/07  10:11 AM  Page 217

សង្គមនិយម និងពួកកុម្មុយនីស្ត ។ លោកកាន់លទ្ធិប្រកាន់ពូជសាសន៍ ប្រកាន់ជាតិសែ៊ម ហើយក៏ប្រឆាំងនឹងគ្រីស្តសាសនាដែរ ។ អភិបាលព្រះសហគមន៍ប្រទេសអាល្លឺម៉ង់ ដាក់ទោសលទ្ធិនេះជាញឹកញាប់ គឺហាមគ្រីស្តបរិស័ទមិនអាចកាន់តាមលទ្ធិជាតិសង្គមនិយមបានជាដាច់ខាត ។

ឆ្នាំ ១៩៣៣ លោក**អ៊ីត្លែរ**ឡើងកាន់អំណាចនៅប្រទេសអាល្លឺម៉ង់ ។ ប្រជាជនរាប់លោកទុកជាអ្នកសង្គ្រោះជាតិគេ ។ គ្រីស្តបរិស័ទប្រពៃណីនិយមក៏កាន់ជើងលោកដែរ ដោយសារពួកគេខ្លាចពួកកុម្មុយនីស្ត ។ លោកទទួលអំណាចពេញទី ។ អភិបាលព្រះសហគមន៍ក៏លែងបោទទោសគណបក្សជាតិសង្គមនិយមទៀតដែរ ។ លោកអ៊ីត្លែរ ចង់យកចិត្តគ្រីស្តបរិស័ទកាតូលិក ដោយធ្វើការព្រមព្រៀងជាមួយអភិបាលក្រុងរ៉ូម នៅថ្ងៃទី ២០ កក្កដា ១៩៣៣ គឺលោកធ្វើដូចជាគាំទ្រសាសនាកាតូលិក ។ តែតាមពិត លោកមានបំណងឲ្យគ្រីស្តបរិស័ទកាតូលិកមិនចាប់អារម្មណ៍នឹងលទ្ធិសង្គមនិយម ។ មិនយូរប៉ុន្មាន លោកអ៊ីត្លែរ រំលាយចលនាកាតូលិកទាំងប៉ុន្មាន មួលបង្កាច់បូជាចារ្យ ហើយបែរទៅកាន់លទ្ធិប្រកាន់ពូជសាសន៍ ។

មុនដំបូង ក្រុមគ្រីស្តបរិស័ទខ្លះគាំទ្រគណបក្សជាតិសង្គមនិយម ។ តែតាំងពីឆ្នាំ ១៩៣៤ មក គ្រីស្តបរិស័ទប្រូតេស្តង់នាំគ្នាប្រឆាំងគណបក្សជាតិសង្គមនិយម 123
នោះ ។ រដ្ឋអំណាចសម្លាប់ពួកគេជាច្រើននាក់ ជាពិសេសលោក**ឌីត្រីស បុនហុហ្វេរ** (Dietrich Bonhoeffer) ។ នៅឆ្នាំ ១៩៣៧ អភិបាលព្រះសហគមន៍ក្រុមរ៉ូម**ពីយ៉ូទី ១១** សរសេរសារលិខិតដាក់ទោសលទ្ធិជាតិសង្គមនិយម និងលទ្ធិកុម្មុយនីស្ត ។

## 122 អភិបាលព្រះសហគមន៏ក្រុងរ៉ូមដាក់ទោសលទ្ធិហ្វាស៊ីស្តនិយម *(Non abbiamo bisogno)*

*យើងយល់ឃើញថា មានសេចក្តីនិងព្រឹត្តិការណ៍ជាច្រើនបញ្ជាក់ថា រដ្ឋអំណាចមានគោលដៅប្រមែប្រមូលយុវជនតាំងពីក្មេងខ្ចីមក រហូតដល់មនុស្សពេញវ័យក្នុងគ្រប់វិស័យ ដើម្បីបម្រើគណបក្សតែមួយគត់ និងប្រើប្រាស់គេសម្រាប់បម្រើរបបមួយ ។ សេចក្តីនិងព្រឹត្តិការណ៍ទាំងនោះមានពិតមែនហើយ រដ្ឋក៏បានសម្រេចតាមសេចក្តីនេះរួចហើយដែរ ។ មនោគមវិជ្ជាដែលជាគ្រឹះចលនានេះ នាំឲ្យគោរពថ្វាយបង្គំរដ្ឋអំណាចទុកជាព្រះតាមពួកទមិឡឥតសាសនា ។ មនោគមវិជ្ជានេះ បង្កើតជម្លោះប្រឆាំងសិទ្ធិធម្មតារបស់ក្រុមគ្រួសារ និងប្រឆាំងសិទ្ធិខាងវិញ្ញាណរបស់ព្រះសហគមន៍ (..) ។ គ្រីស្តបរិស័ទកាតូលិកមិនត្រូវយល់ថា ព្រះសហគមន៍និងអភិបាលក្រុងរ៉ូម គ្រាន់តែចាប់អារម្មណ៍នឹងពិធីបុណ្យប៉ុណ្ណោះ មានអភិបូជា និងអគ្គសញ្ញាជាដើម ។ រីឯរដ្ឋអំណាចវិញ ត្រូវតែទទួលខុសត្រូវលើការអប់រំទាំងមូល ។ (..)*

*លោកពីយ៉ូទី ១១ នៅថ្ងៃ ២៩ មិថុនា ១៩៣១*

## 123 ជាតិសង្គមនិយមអាល្លឺម៉ង់ *(Mit brenneder sorge)*

*នរណាក៏ដោយដែលលើកពូជសាសន៍មួយ ឬលើកប្រជាជនមួយ ឬលើករដ្ឋអំណាច ឬលើកអ្នកកាន់អំណាច ឬលើកអ្វីៗផ្សេងទៀតដែលជាគ្រឹះនៃសហគមន៍មនុស្សលោក មកគោរពថ្វាយបង្គំទុកជាព្រះ ដោយធ្វើពិធីផ្សេងៗ អ្នកនោះជំទាស់នឹងរបៀបរៀបរយ ដែលព្រះជាម្ចាស់បាត់ចែងមកហើយ (..) ។ អ្វីៗទាំងអស់នោះក៏មនុស្សត្រូវគោរពពិតមែន និងត្រូវការជាចាំបាច់ផង ។ តែអ្នកលើកអ្វីៗទាំងនោះស្មើនឹងព្រះនោះ ក៏ផ្ទុយពីព្រះហឫទ័យព្រះជាម្ចាស់ ។*

*មនុស្សមានសិទ្ធិផ្សេងៗមកពីព្រះជាម្ចាស់ សិទ្ធិទាំងនោះត្រូវស្ថិតនៅរហូត មិនត្រូវបំបាត់សិទ្ធិនោះសម្រាប់សម្ហូហភាព គ្មាននរណាអាចបំបាត់សិទ្ធិទាំងនោះ ឬមើលងាយបានឡើយ ។*

*លោកពីយ៉ូ ទី ១១ នៅថ្ងៃ ១៤ មិនា ១៩៣៧*

Layout Histor.qxd 2/10/07 10:11 AM Page 218

## *គ- លទ្ធិកុម្មុយនីស្ត*

នៅឆ្នាំ ១៩១៧ ប្រជាជនរុស្ស៊ីធ្វើបដិវត្តកុម្មុយនីស្ត ដែលមានឥទ្ធិពលយ៉ាង
126 ខ្លាំងនៅទ្វីបអឺរ៉ុប និងនៅលើពិភពលោកទាំងមូល ។ លោក**ឡេនីន**កាន់អំណាចនៅប្រទេសរុស្ស៊ី ហើយបង្កើតសហភាពសូវៀត (ពាក្យ «សូវៀត» មានន័យថា «ក្រុមប្រឹក្សាបដិវត្តន៍» ។ លោក**ស្តាលីន**ដែលកាន់អំណាចបន្ទាប់ពីលោកឡេនីន (១៩២៤-១៩៥៣) សម្លាប់អ្នកប្រឆាំងនយោបាយជាច្រើនអនេក និងធ្វើបាបគ្រីស្តបរិស័ទអ័រតូដុកដែរ ។

នៅឆ្នាំ ១៩៣១ សាធារណរដ្ឋអេស្ប៉ាញប្រឆាំងនឹងក្រុមបូជាចារ្យ ពីព្រោះព្រះសហគមន៍នៅមានទ្រព្យសម្បត្តិច្រើនហួស ។ នៅឆ្នាំ ១៩៣៦ រណសិរ្សប្រជាជនអេស្ប៉ាញបំផ្លាញព្រះវិហារនិងវត្តអារាមជាច្រើន ។ តែលោក**ហ្វ្រង់កូ** (Franco) ប្រឆាំងពួកសាធារណរដ្ឋនិយម ហើយលើកទ័ពមកច្បាំងគេអស់រយៈពេលបីឆ្នាំ ។ ប្រជាជនស្លាប់ជាងមួយលាននាក់ ។ ពួកសាធារណរដ្ឋនិយមនិងពួកកុម្មុយនីស្តដុតព្រះវិហារ ២000 និងសម្លាប់បូជាចារ្យអស់ជាង ៧000 នាក់ ។ អស់លោកអភិបាលអេស្ប៉ាញបែរទៅគាំទ្រលោកហ្វ្រង់កូ ។ ប៉ុន្តែ ក្រុមកាតូលិកខ្លះនៅតែទាមទារយុត្តិធម៌ក្នុងសង្គម ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូមក៏ទទួលស្គាល់លោកហ្វ្រង់កូដែរ ។ គណបក្សជាតិសង្គមនិយមនៅប្រទេសអាល្លឺម៉ង់ និងពួកហ្វាស៊ីស្តប្រទេសអ៊ីតាលីគាំទ្រលោកហ្វ្រង់កូ រីឯពួកកុម្មុយនីស្តអន្តរជាតិគាំទ្រសាធារណរដ្ឋអេស្ប៉ាញវិញ ។

## *ឃ- នៅប្រទេសបារាំង*

ឆ្នាំ ១៩៣៦ រណសិរ្សប្រជាជនឈ្នះឆ្នោត ។ គ្រីស្តបរិស័ទខ្វែងគំនិតគ្នា គឺអ្នកខ្លះគាំទ្រ ភាគច្រើនជំទាស់រណសិរ្សនោះ តែដោយគេធ្លាប់វែកញែកអំពីលទ្ធិនិងបុគ្គល គេសុខចិត្តគាំទ្រអ្នកដែលកាន់លទ្ធិប្លែកពីខ្លួន ។



*លោកពីយ៉ូ ទី ១២*

### *ង- អភិបាលព្រះសហគមន៍ពីយ៉ូទី ១១ ដាក់ទោសអំណាចលទ្ធិផ្តាច់ការ*

នៅឆ្នាំ ១៩៣១ អភិបាលព្រះសហគមន៍ក្រុងរ៉ូម **ពីយ៉ូទី ១១** ហាមគ្រីស្តបរិស័ទកាន់តាមលទ្ធិហ្វាស៊ីស្តនិយមនៅស្រុកអ៊ីតាលី ដែលលោកចោទថា រំលោភសិទ្ធិមនុស្ស (No abbiamo bisogno) ។

នៅឆ្នាំ ១៩៣៧ លោកជិទាស់លទ្ធិជាតិសង្គមនិយមរបស់លោកអ៊ីត្លែរ ហាមប្រាមការប្រកាន់ពូជសាសន៍ ការប្រឆាំងជាតិសែម និងការគោរពរដ្ឋទុកជាព្រះមួយអង្គ (Mit brennender sorge) ។ បូជាចារ្យលួចអានលិខិតនេះនៅគ្រប់ព្រះវិហារនៅប្រទេសអល្លឺម៉ង់ បណ្តាលឲ្យលោកអ៊ីត្លែខឹងសម្បារនិងគ្រីស្តបរិស័ទ ។

បួនថ្ងៃក្រោយ លោកជិទាស់នឹងលទ្ធិកុម្មុយនីស្ត (Divini Redemptoris) លោកចាត់ទុកថា «*ទមិឡទាំងស្រុង*» ហើយហាមគ្រីស្តបរិស័ទចូលរួមសហការជាមួយពួកកុម្មុយនីស្តជាដាច់ខាត ។ លោករំឭកអំពីលទ្ធិព្រះសហគមន៍ស្តីអំពីយុត្តិធម៌ក្នុងសង្គម ។

នៅពេលនោះ គ្រីស្តបរិស័ទខ្លាចលទ្ធិកុម្មុយនីស្ត ជាងលទ្ធិសង្គមនិយមរបស់អ៊ីត្លែ ។ ៤-៥ ខែក្រោយមក អស់លោកដែលកាន់អំណាចបែបលទ្ធិផ្តាច់ការបង្កើតសង្គ្រាមសកលលើកទី ២ (១៩៣៩-១៩៤៥) ។

(126)

**អភិបាលក្រុងរ៉ូមដាក់ទោសលទ្ធិកុម្មុយនីស្ត**

*(Divini Redemptoris)*

*សេចក្តីល្អនិងអាក្រក់នៅតែប្រឆាំងគ្នា ជាកេរមត៌កអភ័ព្វពីអំពើបាបដើម ។ ការប្រឆាំងនេះនៅតែបន្តនៅលើពិភពលោកសព្វថ្ងៃ (...) ។ ប្រជាជនជាច្រើនមុខជាធ្លាក់ទាំងស្រុងក្នុងភាពសាហាវឃោរឃៅជាទីបំផុត អាក្រក់ជាងភាពឃោរឃៅដែលមនុស្សធ្លាប់ជួបប្រទះនៅសម័យព្រះយេស៊ូប្រសូត ។ អស់លោកយល់ស្រាប់ហើយថា (...) គ្រោះកាចនេះគឺជាលទ្ធិកុម្មុយនីស្តទមិឡឥតសាសនា ។*

*លទ្ធិកុម្មុយនីស្តអាក្រក់ទាំងស្រុង អ្នកដែលចង់សង្គ្រោះអរិយធម៌គ្រីស្តបរិស័ទ មិនអាចសហការជាមួយលទ្ធិកុម្មុយនីស្តនេះបានឡើយ ។ ប្រសិនបើនរណាម្នាក់បាញ់បោកគេ ហើយជួយឲ្យលទ្ធិកុម្មុយនីស្តមានជ័យជំនះនៅក្នុងប្រទេសរបស់ខ្លួននោះ គេមុខជានឹងត្រូវទទួលទោសដល់ជីវិតមុនគេ ដោយបាញ់បោកគេ ។ នៅក្នុងតំបន់ដែលលទ្ធិកុម្មុយនីស្តចូលគ្រប់គ្រងនោះ ប្រសិនបើតំបន់ណាមានអរិយធម៌គ្រីស្តបរិស័ទយ៉ាងយូរ និងយ៉ាងប្រសើរ ពួកទមិឡឥតសាសនានឹងបំផ្លាញតំបន់ទាំងនោះកាន់តែខ្លាំងឡើងៗ ។*

*លោកពីយ៉ូ ទី ១១ ថ្ងៃ ១៩ មិនា ១៩៣៧*

Layout Histor.qxd 2/10/07 10:11 AM Page 220
























# គ្រីស្តសាសនា សម្របតាមអរិយធម៌ប្រទេសនីមួយៗ

ចាប់តាំងពីកើតបដិវត្តន៍នៅទ្វីបអឺរ៉ុបមក មិនសូវមានគ្រីស្តបរិស័ទចេញទៅប្រកាសដំណឹងល្អក្រៅប្រទេសទេ ។ ប៉ុន្តែ តាំងពីបដិវត្តន៍បរាជ័យ (គ.ស.១៨១៥) នៅតែមានបូជាចារ្យឬបព្វជិតអឺរ៉ុបជាច្រើនចេញទៅប្រកាសដំណឹងល្អវិញ ។ រហូតដល់ ឆ្នាំ ១៨៧០ អស់លោកចេញទៅដោយគ្មានជំនួយពីរដ្ឋាភិបាលរបស់គេដូចកាលពីមុនទៀតឡើយ ។ ប៉ុន្តែពេលក្រោយ ដោយរដ្ឋអំណាចអឺរ៉ុបរីកចម្រើនឡើង និងវាតទីលើពិភពលោកទាំងរកស្រុកឈរបធ្វើជាអាណានិគមនោះ ។ ទោះបីរដ្ឋាភិបាលប្រទេសទាំងនោះប្រឆាំងនឹងគ្រីស្តសាសនាក្តី ក៏រដ្ឋាភិបាលទាំងនោះរាប់សាសនទូតជាតិរបស់គេ ទុកជាជំនួយផ្សព្វផ្សាយអរិយធម៌របស់គេ ក្នុងប្រទេសជាអាណានិគមដែរ ។

អភិបាលព្រះសហគមន៍ក្រុងរ៉ូម នៅតែបារម្ភអំពីសភាពការណ៍នេះ ហើយមានបំណងឲ្យព្រះសហគមន៍កើតតាមប្រទេសនីមួយៗ ដោយមានក្រុមបូជាចារ្យ និងអភិបាលព្រះសហគមន៍ជាតិនោះ ព្រមទាំងឲ្យមានរបៀបបញ្ចេញជំនឿតាមអរិយធម៌របស់ជាតិនីមួយៗផងដែរ ។

- នៅសតវត្សទី ១៩ ប្រទេសព័រទុយហ្កាល់ និង ប្រទេសអេស្ប៉ាញចុះអន់ថយ លែងទៅជាមហាអំណាចខាងផ្លូវសមុទ្រទៀតហើយ ។ ផ្ទុយទៅវិញ ប្រទេសបារាំងនិងប្រទេសអង់គ្លេសរីកចម្រើនឡើងខាងផ្លូវសេដ្ឋកិច្ច ហើយវាតទឹកដីអាហ្វ្រិក និងអាស៊ីធ្វើជាអាណានិគម ។
- នៅសតវត្សទី ១៩ នោះ អ្នកធ្វើពាណិជ្ជកម្មតាមផ្លូវសមុទ្រលែងប្រើទូកក្តោង ហើយនាំគ្នាធ្វើដំណើរតាមកប៉ាល់ភ្លើង ។
- នៅឆ្នាំ ១៨៦៩ គេជីកព្រែកជីកស៊ុយអេ (Suez) ធ្វើឲ្យទ្វីបអាស៊ីនិងទ្វីបអឺរ៉ុបទាក់ទងគ្នារហ័សជាងពីមុន ។
- សាសនទូតនិងអ្នកស្រាវជ្រាវអរិយធម៌ តែងតែចូលក្នុងប្រទេសក្រោមអាណានិគមប្រទេសរបស់ខ្លួន ។ បើនិយាយឲ្យខ្លី ប្រទេសអង់គ្លេស គាំទ្រក្រុមជំនុំប្រូតេស្តង់ រីឯប្រទេសបារាំងគាំទ្រព្រះសហគមន៍កាតូលិកវិញ ។

**នៅប្រទេសកម្ពុជា** (សូមអានប្រវត្តិព្រះសហគមន៍ ទំព័រ ១៤៦-១៥៧) ។

- អាណានិគមបារាំងត្រួតត្រាលើប្រទេសកម្ពុជា តាំងពីឆ្នាំ ១៨៦៣ មក ។
- ព្រះសហគមន៍រីកចម្រើនឡើង ដោយតែងតាំងស្ថាប័នដូចនៅប្រទេសអឺរ៉ុប ។

**១. ២. ៣.** ព្រះវិហារនៅប្រទេសភូមា កម្ពុជា វៀតណាម ។
**៤. ៥. ៦.** គ្រីស្តបរិស័ទនៅប្រទេសប៉ាឡេស្ទីន អេស៊ីប អូសេអានី ។

Layout Histor.qxd 2/10/07 10:11 AM Page 222

## ១- គ្រីស្ដបរិស័ទប្រូតេស្តង់

នៅឆ្នាំ ១៧៩២ លោក**វិលីយ៉ាំ ការៃ** (William Carey) ជាជនជាតិអង់គ្លេសបង្កើត «*សមាគមសាសនទូតបាទីស្ត*» (Baptist Missionary Society) ។ នៅ ១៧៩៥ កើត «*សមាគមសាសនទូតក្រុងឡុងដុង*» (London Missionary Society) ។ មានសមាគមគម្ពីរជាច្រើនកើតឡើង ហើយគេចាប់ផ្ដើមបោះពុម្ពផ្សាយគម្ពីរតាមភាសាផ្សេងៗក្នុងពិភពលោកទាំងមូល ។ នៅឆ្នាំ ១៩00 មានសមាគមសាសនទូតប្រូតេស្តង់ជាង ៣00 សមាគម ពីគ្រប់ប្រទេស ជាពិសេសពីប្រទេសអង់គ្លេស និងពីសហរដ្ឋអាមេរិកចេញទៅប្រកាសដំណឹងល្អ ។

## ២- ក្រុមផ្សព្វផ្សាយជំនឿ

125 គ្រីស្ដបរិស័ទកាតូលិកខ្លះបង្កើតសមាគមសម្រាប់ប្រមែប្រមូលធនធានដើម្បីជួយសាសនទូត គេបង្កើតព្រឹត្តិបត្រដើម្បីផ្សព្វផ្សាយអំពីកិច្ចការរបស់សាសនទូត (ពីឆ្នាំ ១៨២៣ ដល់ឆ្នាំ ១៩១៩ គេបង្កើត ៣៨0 ព្រឹត្តិបត្រ) ។

នៅសតវត្សទី ១៩ សមាគមសាសនទូតពីបុរាណមានជីវិតរស់រវើកឡើងវិញ (មានសមាគមសាសនទូតក្រុងប៉ារីសជាដើម) ។

ឆ្នាំ ១៨១៧ អភិបាលក្រុងរ៉ូមបាត់បែងក្រសួងផ្សព្វផ្សាយជំនឿ ។ លោក
**គ្រេគ័រទី ១៦** ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម (១៨៣១-១៨៤៦) ដាក់ទោសអ្នក
ដែលចាប់ជនជាតិស្បែកខ្មៅធ្វើជាទាសករ (១៨៣៩) ហើយប្រៀនប្រដៅព្រះ
សហគមន៍យ៉ាងច្បាស់ គឺលោកសុំបាត់បែងព្រះសហគមន៍តាមស្រុកទេស ដោយ
មានក្រុមបូជាចារ្យកើតក្នុងស្រុកនោះណែនាំ ។ ប៉ុន្តែ ជនជាតិអឺរ៉ុបនៅតែប្រកាន់
126 ថា ខ្លួនឯងពូកែជាងគេខាងសេដ្ឋកិច្ចនិងចំណេះវិជ្ជា ។ គ្រីស្ដបរិស័ទខ្លះប្រកាន់ពូជ
សាសន៍ រហូតដល់យល់ឃើញថា ជនជាតិខ្លះមិនអាចទៅជាបូជាចារ្យបានទេ
មានតែជនជាតិគេផ្ទាល់អាចណែនាំព្រះសហគមន៍បាន ។

## ៣- សាសនទូត និង អាណានិគម

សតវត្សទី ១៩ មហាអំណាចនៅទ្វីបអឺរ៉ុបវាតទីយកទឹកដីនៃទ្វីបឯទៀតៗធ្វើជាអាណានិគម ។ ក្នុងប្រទេសជាច្រើន មានប្រទេសកម្ពុជាជាដើម សាសនទូតប្រកាសដំណឹងល្អមុនកងទ័ព ប្រទេសរបស់គេមកធ្វើអាណានិគមម្ល៉េះ ។ សាសនទូតធ្លាប់ជំទាស់ជាញឹកញាប់ ប្រឆាំងនឹងពួកអាណានិគមទាំងនោះ ដែលមិនគោរពអ្នកស្រុក និងជិះជាន់គេ ។ ធម្មតា សាសនទូតទាំងនោះស្គាល់ភាសា និងអរិយធម៌ស្រុកច្បាស់ជាងអ្នករាជការអាណានិគមនោះថែមទៀត ។ អស់លោកនៅតែជួយការពារអ្នកស្រុកពីរដ្ឋការអាណានិគម ។



*រូបបដិមានាងម៉ារី និងព្រះកុមារយេស៊ូ នៅវត្តសាគរារាម (នៅក្រុងកែប)*

## 125 ក្រុមផ្សព្វផ្សាយជំនឿ កើតនៅឆ្នាំ ១៨២២

សុន្ទរកថាក្នុងឱកាសបុណ្យសន្ត**ហ្វ្រង់ស្វ័រសាវីយេ** ថ្ងៃទី ៣ ធ្នូ ១៨២៣ នៅក្រុងលីយ៉ុង (ស្រុកបារាំង) ។ ជនជាតិអឺរ៉ុបតែងប្រកាន់ ហើយមើលងាយអរិយធម៌ស្រុកដទៃ ។

*(...) យើងមានភារកិច្ចដកមនុស្សជាច្រើនឥតគណនាចេញពីភាពងងឹតស្លុង ពួកគេក៏ជាមនុស្សដូចយើងដែរ ពួកគេលំបាកចិត្ត ហើយនៅតែលំបាកក្នុងចិត្តរហូតសព្វថ្ងៃ គេកប់ក្នុងភាពងងឹតអន្ធការ ដោយគេប្រព្រឹត្តតាមជំនឿផ្សេងៗ ។ ពួកគេក៏នឹងត្រូវស្លាប់អស់កល្បជានិច្ចដែរ ។ មនុស្សអភ័ព្វទាំងនោះគឺជាមនុស្សដ៏កាចសាហាវទាំងឡាយ ដែលគ្មានអរិយធម៌ គ្មានវិន័យនិងសណ្ដាប់ធ្នាប់ ក្រៅពីប្រព្រឹត្តតាមសភាវគតិប៉ុណ្ណោះ ។ អ្នកទាំងនោះ ដូចជាញែកខ្លួនដាច់ពីមនុស្សជាតិដោយសារទំនៀមទម្លាប់របស់គេ ។ ពួកគេដូចជាមានលក្ខណៈជាមនុស្សតែរូបរាងខាងក្រៅប៉ុណ្ណោះ (...) ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក្តី ក៏សូមកុំឲ្យអ្នករាល់គ្នារបួសចិត្តឡើយ គឺមនុស្សទាំងនោះសុទ្ធតែជាបងប្អូនយើង ដែលព្រះជាម្ចាស់បានបង្កើតមកឲ្យបានដូចព្រះអង្គ ពួកគេក៏ដូចយើងដែរ ពួកគេកើតពីព្រះបិតាតែមួយព្រះអង្គដូចយើង ព្រះលោហិតរបស់ព្រះយេស៊ូគ្រីស្តក៏បានលោះគេដូចព្រះអង្គលោះយើងដែរ (...) ។*

*ព្រះសហគមន៍មានធម៌មេត្តាករុណាដ៏លើសលប់ ចង់ប្រមែប្រមូលមនុស្សលោកទាំងអស់ក្នុងមហាគ្រួសារតែមួយ ។ រីឯបងប្អូនវិញ ដោយបងប្អូនចូលរួមក្នុងក្រុមផ្សព្វផ្សាយជំនឿ ព្រះជាម្ចាស់ត្រាស់ហៅបងប្អូន ឲ្យសម្រាលទុក្ខព្រះសហគមន៍តាមកម្លាំងរបស់បងប្អូន ។*

*របាក្យត្រអំពីការផ្សព្វផ្សាយជំនឿ ជំពូក ១,២*

## 126 គោលលទ្ធិរបស់លោកអភិបាលគ្រេគ័រទី ១៦ អំពីការប្រកាសដំណឹងល្អ

មុនលោក**គ្រេគ័រ**ទៅជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម លោកជាប្រធានក្រសួងផ្សព្វផ្សាយជំនឿ ។ ពីរបីខែមុនលោកទទួលមរណភាព គឺនៅថ្ងៃទី ២៣ វិច្ឆិកា ១៨៤៥ លោកគ្រេគ័រ សរសេរគោលលទ្ធិសម្រាប់ណែនាំសាសនទូត ក្នុងការផ្សព្វផ្សាយជំនឿ ។ តែគួរឲ្យស្ដាយណាស់ សាសនទូតមិនបានអនុវត្តតាមពាក្យបណ្តាំដ៏ឈ្លាសវៃរបស់លោក អំពីការបង្កើតក្រុមបូជាចារ្យនៅតាមស្រុកនីមួយៗទេ ។

*(...) អស់លោកណែនាំភូមិភាគ និងអស់លោកឯទៀតៗ ទោះជាបំពេញមុខតំណែងណាក្តី ត្រូវតែធ្វើតាមសំណូមពររបស់អស់លោកអភិបាលតាំងពីដើមរៀងមក គឺត្រូវផ្តល់ឈ្មោះបេក្ខជនជាច្រើនតាមដែលអាចធ្វើបាន ឲ្យទៅជាអភិបាល ដើម្បីពង្រីកនិងពង្រឹងជំនឿកាតូលិក ។ ត្រូវឲ្យចំនួនអភិបាលកាន់តែច្រើនឡើងៗ និងតែងតាំងអ្នកដឹកនាំព្រះសហគមន៍នៅស្រុកនីមួយៗផង (...) ។*

*(...) យ៉ាងណាមិញ អស់លោកត្រូវខិតខំឲ្យអស់ពីសមត្ថភាព ទុកជាបន្ទុកដ៏សំខាន់របស់អស់លោក គឺត្រូវណែនាំគ្រីស្តបរិស័ទនៅក្នុងប្រទេសនោះឲ្យទៅជាបូជាចារ្យ (...) ។ ការនេះប្រញាប់ជាទីបំផុត គឺត្រូវតែបង្កើតទេវវិទ្យាល័យ ដើម្បីអប់រំបូជាចារ្យឲ្យបានល្អ គឺឲ្យយុវជនទាំងអស់ដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាបូជាចារ្យ អាចរៀនវិជ្ជាផ្សេងៗខាងគ្រីស្តសាសនា (...) ។ ដូច្នេះនឹងមានបូជាចារ្យសមនឹងបំពេញមុខងារដ៏សក្ការៈតាមសំណូមពរសន្តអាសនៈជាយូរមកហើយ (...) និងបូជាចារ្យខ្លះក៏អាចទៅជាអភិបាលផងដែរ (...) ។*

*អស់លោកត្រូវលះបង់ទម្លាប់ដែលចាត់ទុកបូជាចារ្យកើតក្នុងស្រុកថា គ្រាន់តែជាបូជាចារ្យជំនួយប៉ុណ្ណោះ ។ យើងមិនយល់ស្របសោះ អ្នកដែលប្រកាសដំណឹងល្អ ទោះជាជនជាតិអឺរ៉ុបក្តី កើតក្នុងស្រុកក្តី គឺស្មើគ្នាទាំងអស់ (...) ។*

*សាសនទូតណាដែលរស់នៅជាមួយមនុស្សមានយោបល់ផ្សេងៗខាងនយោបាយ កុំលូកដៃផ្ទាល់នឹងរឿងនយោបាយ ឬក្នុងរឿងលោកិយឡើយ ។ កុំឲ្យសាសនទូតភ្ជាប់នឹងគណបក្សនយោបាយឲ្យសោះ ហើយក៏កុំនាំឲ្យជាតិបាក់បែកដែរ (...) ។*

*សាសនទូតត្រូវយកចិត្តទុកដាក់ខិតខំឲ្យយល់អំពីការរស់នៅក្នុងសង្គមប្រជាជនទាំងនោះ ។ នៅពេលនាំលទ្ធិនៃដំណឹងល្អទៅកន្លែងណា សាសនទូតត្រូវសុខចិត្តទទួលស្គាល់តម្លៃនៃការងារ និងការប៉ិនប្រសប់របស់អ្នកជឿនៅកន្លែងនោះ ។*

Layout Histor.qxd 2/10/07 10:11 AM Page 224

# ក_ នៅទ្វីបអាស៊ី

## ១- ប្រទេសចិន

តាំងពីដើមសតវត្សទី ១៩ រដ្ឋអំណាចចិនតែងតែបៀតបៀនធ្វើបាបគ្រីស្ដបរិស័ទរហូត មិនព្រមឲ្យសាសនទូតនិងឈ្មួញបរទេសចូលប្រទេសចិនសោះ ។ នៅឆ្នាំ ១៨៤២ ប្រទេសនៅទ្វីបអឺរ៉ុបបង្ខំរដ្ឋអំណាចចិនឲ្យចុះសន្ធិសញ្ញា «*មិនស្មើភាព*» ជាមួយពួកគេ គឺផ្ដល់ច្បាប់អនុញ្ញាតឲ្យនាវាអឺរ៉ុបចូលកំពង់ផែចិន និងឲ្យជនជាតិអឺរ៉ុបបង្កើតស្ថានប័នខាងគ្រីស្ដសាសនាតាមតែគេត្រូវការ ។ ឯប្រទេសបារាំងវិញចាត់ខ្លួនឯងថា ជាប្រទេសការពារសាសនទូតនៅប្រទេសចិន ។ សន្តអាសនៈ ចង់ភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋអំណាចចិន តែរដ្ឋអំណាចបារាំងមិនព្រមឲ្យអភិបាលព្រះសហគមន៍ក្រុងរ៉ូម **ឡេអូ ទី ១៣** ចាត់ប្រតិភូទៅជួបរដ្ឋាភិបាលប្រទេសចិនទេ (១៨៨៥) ។

ទោះបីសាសនទូតបរទេសមិនដឹងខ្លួនក្ដី ក៏អស់លោកតែងតែរួមគំនិតជាមួយមហាអំណាចអឺរ៉ុប ដែលលួចដណ្ដើមយកធនធានសេដ្ឋកិច្ចរបស់ស្រុកចិន ។ ប្រជាជនចិនមួយចំនួនដែលប្រកាន់ពូជសាសន៍ ស្អប់ជនជាតិបរទេស រួមគ្នាធ្វើជាសមាគមសម្ងាត់ ។ ឆ្នាំ ១៩00 នៅប៉េកាំង គេចាប់សាសនទូត បព្វជិតា អភិបាលព្រះសហគមន៍ គ្រីស្ដបរិស័ទរាប់ពាន់នាក់ យកទៅសម្លាប់ជាមួយជនជាតិអឺរ៉ុបឯទៀតៗមួយចំនួនធំ ។ កងទ័ពអឺរ៉ុបឆ្លៀតឱកាសនេះចូលមកវាយក្រុងប៉េកាំងវិញ និងទារប្រាក់ពិន័យជាទម្ងន់ ។

ចាប់ពីឆ្នាំ ១៩0១ មក លោក**លែប** (Lebbe) ជាបូជាចារ្យជនជាតិបែលស៊ិក ម្នាក់ទាស់ចិត្ត ដោយឃើញសាសនទូតអឺរ៉ុបខ្លះប្រកាន់ពូជសាសន៍ និងមើលងាយប្រជាជនចិន ។ សូម្បីតែបូជាចារ្យចិន ក៏បូជាចារ្យអឺរ៉ុបមើលងាយដែរ ។

សាសនទូតចំនួនតិចតួចយកចិត្តទុកដាក់រៀនអរិយធម៌ចិន ។ សាសនទូតជាច្រើនបង្រៀនប្រជាជនតាមរបៀបអឺរ៉ុប គឺវិទ្យាសាស្ត្រ និងភាសាបរទេស ។ គេអប់រំបូជាចារ្យតាមរបៀបអឺរ៉ុប ដោយមិនយកចិត្តទុកដាក់នឹងទំនៀមទម្លាប់គ្រួសារ និងវប្បធម៌របស់ចិនទេ ។

នៅឆ្នាំ ១៩៤៩ នៅប្រទេសចិនទាំងមូលមានគ្រីស្ដបរិស័ទទាំងកាតូលិក ទាំងប្រូតេស្ដង់ ចំនួន ៥ លាននាក់ គឺ ១% នៃប្រជាជនចិនទាំងមូល ។



*លោកលែប ជាបូជាចារ្យជនជាតិបែលស៊ិក ឆ្នាំ ១៩0១*

Layout Histor.qxd 2/10/07 10:11 AM Page 225

127

## ២- នៅប្រទេសជប៉ុន និង កូរ៉េ

ចាប់តាំងពីសតវត្សទី ១៧ មក ប្រទេសជប៉ុនមិនព្រមឲ្យជនជាតិអឺរ៉ុបស្នាក់អាស្រ័យនៅលើទឹកដីរបស់ខ្លួនទេ ។ នៅសតវត្សទី ១៩ ប្រទេសអឺរ៉ុបដែលមានអំណាចខាងសេដ្ឋកិច្ចកាន់តែខ្លាំងឡើងៗ ចង់បង្ខំជនជាតិស្រុកជប៉ុនឲ្យទទួលជនជាតិអ៊ឺរុប ។ នៅឆ្នាំ ១៨៥៣ សហរដ្ឋអាមេរិកទទួលសេចក្តីអនុញ្ញាតឲ្យចតនាវារបស់គេនៅកំពង់ផែប្រទេសជប៉ុនបាន និងមានសិទ្ធិសាងសង់ព្រះវិហារសម្រាប់ជនជាតិអាមេរិក ។ បន្ទាប់មក ប្រទេសអឺរ៉ុបក៏ទទួលសេចក្តីអនុញ្ញាតនេះដែរ ។

នៅឆ្នាំ ១៨៦៥ សាសនទូតម្នាក់រកឃើញពូជពង្សគ្រីស្តបរិស័ទជប៉ុនកាលពីសតវត្ស ទី ១៧ ។ ទោះបីគ្មានបូជាចារ្យណែនាំក្តី ក៏គេនៅតែរក្សាជំនឿពីដូនតាដែរ ។ តាំងពីឆ្នាំ ១៨៧៣ (សម័យម៉ីស៊ី Meiji គឺមានន័យថា "ការចម្រើន") ស្រុកជប៉ុនបើកទ្វារឲ្យអរិយធម៌បស្ចិមប្រទេសចូលបាន គេអនុញ្ញាតឲ្យមានសេរីភាពខាងការគោរពបូជាសាសនា ។ សាសនទូតនិងបព្វជិតាជាច្រើន តាំងទីលំនៅនៅប្រទេសជប៉ុន ហើយសាងសង់សាលារៀន ដ្បិតជនជាតិជប៉ុនចង់ស្គាល់ចំណេះខាងបស្ចិមប្រទេសយ៉ាងខ្លាំង ។ ឆ្នាំ ១៨៩១ អភិបាលក្រុងរ៉ូម**ឡេអូទី ១៣** តែងតាំងអភិបាលជាតិជប៉ុនមួយចំនួន ។ ជនជាតិជប៉ុនចូលចិត្តទទួលចំណេះវិជ្ជា និងបច្ចេកទេសពីទ្វីបអឺរ៉ុប តែមិនព្រមទទួលគ្រីស្តសាសនាទេ គេបំបែកចំណេះទាំងនោះពីគ្រីស្តសាសនាឲ្យដាច់ពីគ្នា ។ ម្យ៉ាងទៀត គំនិតរបស់អ្នកជាតិនិយមបេះតែចម្រើនឡើងៗ តាំងពីពេលកងទ័ពជប៉ុនមានជ័យជំនះលើកងទ័ពចិននិងរុស្សី (១៩០៥) ព្រមទាំងលើកងទ័ពកូរ៉េ បណ្តាលឲ្យគេមានចិត្តសង្ស័យទៅលើគ្រីស្តបរិស័ទស្រុកគេដែលមានទំនាក់ទំនងនឹងជនជាតិបរទេស ។

ឆ្នាំ ១៨៣១ អភិបាលក្រុងរ៉ូមបាត់អភិបាលម្នាក់ទៅស្រុកកូរ៉េ តែរដ្ឋអំណាចប្រទេសនោះនៅតែហាមមិនឲ្យមានគ្រីស្តសាសនាក្នុងស្រុក ។ ទោះបីគេបៀតបៀនគ្រីស្តបរិស័ទរហូតដល់ឆ្នាំ ១៨៨៥ ក្តី ក៏ចំនួនគ្រីស្តបរិស័ទស្រុកកូរ៉េនៅតែចម្រើនឡើងជាលំដាប់នៅប្រទេសនោះ ។

## ៣- ប្រទេសវៀតណាម

លោក**ពិញ្ញូដឺបេហែន** (Pigneau de Béhaine) ជួយព្រះចៅ**យ៉ាឡុង** (Gia Long) ឲ្យឡើងគ្រងរាជ្យនៅលើទឹកដីវៀតណាមទាំងមូល ។ ហេតុនេះហើយបានជាព្រះអង្គប្រទានឲ្យគ្រីស្តបរិស័ទរស់នៅដោយសេចក្តីសុខសាន្ត ។ ប៉ុន្តែចាប់តាំងពីឆ្នាំ ១៨២៥ មក ព្រះចៅដែលស្នងរាជ្យបន្តពីព្រះចៅយ៉ាឡុងគ្រប់អង្គនាំគ្នាបៀតបៀនធ្វើបាបគ្រីស្តបរិស័ទអស់រយៈពេលហាសិបឆ្នាំ ។ ដោយប្រជាជនវៀតណាមចាត់ទុកព្រះចៅជាព្រះរបស់គេ ព្រះចៅតែងតែចោទថា គ្រីស្តបរិស័ទគេចចេញពីរាជអំណាចរបស់ព្រះអង្គ គឺអ្នកក្បត់ជាតិ ។

ព្រះចៅ**ទុយ ឌុក** (Tu-Duc 1847-1882) សម្លាប់គ្រីស្តបរិស័ទជាច្រើន ។ គ្រីស្តបរិស័ទវៀតណាមមួយចំនួនធំភៀសខ្លួនមកប្រទេសកម្ពុជា ។ កងទ័ពបារាំងដណ្តើមយកក្រុងព្រៃនគរនៅឆ្នាំ ១៨៥៩ ។ ព្រះចៅទុយ ឌុក ផ្តល់ស្រុកកូសាំងស៊ីន (Cochinchine) ជូនប្រទេសបារាំង ដើម្បីឲ្យបានសន្តិភាព ។ កងទ័ពបារាំងយកលេសថា មកការពារគ្រីស្តបរិស័ទហើយបែរជាតែងតាំងអាណានិគមវិញ ។ នៅឆ្នាំ ១៨៨៥ កងទ័ពបារាំងត្រួតត្រាស្រុកវៀតណាមទាំងមូល ។

ពេលក្រោយ ព្រះសហគមន៍លូតលាស់នៅស្រុកវៀតណាមទាំងមូលរហូតដល់មានគ្រីស្តបរិស័ទ ៧% នៃប្រជាជនវៀតណាមសព្វថ្ងៃ ។ តាំងពីដើមរៀងមកគេតែងតាំងគ្រីស្តបរិស័ទវៀតណាមឲ្យទៅជាបូជាចារ្យ និងជាគ្រូអប់រំជំនឿ ។ នៅពេលរដ្ឋអំណាចធ្វើទុកបុកម្នេញគ្រីស្តបរិស័ទ គឺគ្រូទាំងនោះបានជួយព្រះសហគមន៍យ៉ាងសកម្មឲ្យស្ថិតស្ថេរនឹងនរបាន ។

Layout Histor.qxd 2/10/07 10:11 AM Page 226

# ១_ ក្រោយសង្គ្រាមលោកលើកទី ១

128 ក្នុងអំឡុងឆ្នាំ ១៩១៤-១៩១៨ លែងមានសាសនទូតទៀតហើយ ពីព្រោះរដ្ឋអំណាចរបស់គេកេណ្ឌពួកគេឲ្យបម្រើកងទ័ព ។ លោក**បេណេឌិកតូ ទី ១៥** ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម សរសេរលិខិតស្ដីបន្ទោសសាសនទូត ដែលមិនទាន់បង្កើតក្រុមបូជាចារ្យ និងអភិបាលក្នុងព្រះសហគមន៍ដែលគេបម្រើ (១៩១៩) ។

លោកអភិបាលក្រុងរ៉ូម **ពីយ៉ូ ទី ១១** ប្រមូលសកម្មភាពទាំងអស់នៃកិច្ចប្រកាសដំណឹងល្អ មកក្រោមការណែនាំរបស់ក្រសួងតែមួយ (Congrégation de la Propagande) ដើម្បីឲ្យសាសនទូតរួចផុតពីរដ្ឋអំណាចរៀងៗខ្លួន ។ លោកក៏យកចិត្តទុកដាក់តែងតាំងអភិបាលព្រះសហគមន៍តាមស្រុក ។ នៅឆ្នាំ ១៩២៦ លោកតែងតាំងសហជីវិនព្រះយេស៊ូជាតិឥណ្ឌាជាអភិបាល ។ ឆ្នាំ ១៩២៦ លោកធ្វើអគ្គសញ្ញាតែងតាំងអភិបាលព្រះសហគមន៍ចិន ៦ នាក់យ៉ាងឱឡារិកដោយខ្លួនលោកផ្ទាល់ ។ ឆ្នាំ ១៩២៧ លោកតែងតាំងអភិបាលជាតិជប៉ុនមុនគេ ឲ្យណែនាំព្រះសហគមន៍នៅណាកាសាគី ។ នៅឆ្នាំ ១៩៣៣ លោកតែងតាំងអភិបាលជាតិវៀតណាមមុនគេ ។ នៅឆ្នាំ ១៩៣៩ មានអភិបាល ៤៨ នាក់ ណែនាំភូមិភាគជាស្រុកកំណើតរបស់ខ្លួន ។ លោកក៏តែងតាំងអភិបាលជាច្រើននៅទ្វីបអាហ្វ្រិកដែរ ។

## 127 នៅឆ្នាំ ១៨៦៥ បូជាចារ្យម្នាក់រកឃើញគ្រីស្តបរិស័ទជប៉ុនពីដើម នៅក្រុងណាហ្គាសាគី

នៅឆ្នាំ ១៨៦៥ សាសនទូតសាងសង់ព្រះវិហារតូចមួយនៅណាហ្គាសាគី ។ ហេតុនេះហើយ គ្រីស្តបរិស័ទដែលលាក់ខ្លួនតាំងពីសតវត្សទី ១៧ មក អាចចេញមុខមកបង្ហាញខ្លួនបាន ។ ពួកគេយល់ឃើញថា សាសនាកាតូលិកមានលក្ខណៈដូចតទៅ គឺកាតូលិកគោរពនាងព្រហ្មចារិនីម៉ារី គោរពលោកអភិបាលក្រុងរ៉ូម ហើយបូជាចារ្យជាអ្នកបួស ។ សាសនទូតម្នាក់នោះរៀបរាប់រឿងដូចតទៅ៖

*នៅថ្ងៃសុក្រទី ១៧ មិនា ប្រហែលនៅម៉ោង ១២ កន្លះ មានមនុស្សមួយក្រុមប្រមាណ ១៥ នាក់ មកដល់មាត់ទ្វារព្រះវិហារ (...) ។ ស្ត្រីបីនាក់ដាក់ដៃម្ខាងលេដើមទ្រូងគាត់ ហើយនិយាយតិចៗមកខ្ញុំថា៖ «ជំនឿយើងទាំងអស់គ្នាដែលនៅទីនេះ មិនខុសពីជំនឿរបស់លោកទេ» (...) ។*

*ស្ត្រីសួរថា៖ «តើឯណារូបព្រះនាងម៉ារី ?» (...) កាលគេឃើញរូបព្រះនាងម៉ារីពរព្រះកុមារយេស៊ូ គេប្រាប់ខ្ញុំថា គេនឹកដល់បុណ្យព្រះយេស៊ូប្រសូត ដែលគេធ្លាប់ប្រារព្ធនៅខែទី ១១ (...) ។*

*មានគ្រីស្តបរិស័ទតែមួយចំនួនតិចទេ ដែលចងចាំពាក្យក្នុងអគ្គសញ្ញាជ្រមុជទឹក (...) ។ ពួកគេនៅតែគោរពថ្ងៃអាទិត្យ និងថ្ងៃបុណ្យ ។ ឥឡូវនេះ ពួកគេក៏នាំគ្នាគោរពរដូវអប់រំពិសេសដែរ (...) ។ ម្នាក់ឈ្មោះ **សិលា** ជាអ្នកធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ និងផ្ដល់ព័ត៌មានជាក់លាក់ដល់យើង ។ យើងសូមបញ្ជាក់មុនដំបូងថា ពាក្យធ្វើអគ្គសញ្ញាជ្រមុជទឹកហាក់ដូចជាត្រឹមត្រូវមែន (...) ។ គាត់ក៏និយាយប្រាប់យើងអំពីផ្កាំដែលគ្រីស្តបរិស័ទតែងតែសូត្រដូចយើង (...) ។ ទីបញ្ចប់គាត់សួរយើងអំពីព្រះចៅនៃព្រះរាជអាណាចក្រក្រុងរ៉ូម គឺគាត់ចង់ស្គាល់ឈ្មោះលោក ។ យើងនិយាយថាលោកជាតំណាងដ៏ប្រសើររបស់ព្រះយេស៊ូគ្រីស្ត លោកឈ្មោះអភិបាល**ពីយ៉ូ ទី ៩** លោកមុខជានឹងមានអំណរសប្បាយក្រៃលែង ដោយទទួលដំណឹងអំពីបងប្អូននៅទីនេះ និងបងប្អូនគ្រីស្តបរិស័ទឯទៀតៗដែលយើងទើបតែនឹងដឹងនៅពេលនេះ ។ ពេលនោះប្អូន**សិលា**សម្ដែង*

●●●

*អំណរសប្បាយជាខ្លាំង ។ ប៉ុន្តែ មុននឹងលាយើង គាត់ចង់បញ្ជាក់ម្តងទៀតឲ្យបានច្បាស់លាស់ថា យើងពិតជាអ្នកបន្តមុខងារពីសាសនទូតរបស់គេពីដើម ពិតមែនឬយ៉ាងណា?*

*គាត់សួរយើងដោយទឹកមុខអៀនប្រៀនថា៖ «តើលោកមានកូនទេ?»*

*«បងប្អូននិងគ្រីស្តបរិស័ទឯទៀតៗ ព្រមទាំងជនជាតិជប៉ុនទាំងមូល ជាកូនៗដែលព្រះជាម្ចាស់បានប្រទានឲ្យយើង ។ យើងមិនអាចមានកូនផ្សេងៗទៀតបានទេ ។ ឯបូជាចារ្យក៏ដូចសាសនទូតពីដើមដែរ ត្រូវតែបួសអស់មួយជីវិត ។»*

*ពេលឮចម្លើយនេះ ប្អូនសិលានិងគ្រីស្តបរិស័ទទាំងអស់អោនក្បាលដល់ដី និយាយខ្លាំងៗថា៖ «អស់លោកនៅព្រហ្មចារី សូមអរព្រះគុណព្រះជាម្ចាស់! សូមអរព្រះគុណព្រះជាម្ចាស់!» ។*

*គ្រីស្តបរិស័ទស្ទើរតែទាំងអស់ ចាត់ចែងក្រុមរបស់គេតាមរបៀបដូចៗគ្នា គឺនៅតាមភូមិមានមេដឹកនាំពីរនាក់ដ៏សំខាន់គឺ អ្នកទី ១ គេហៅថា «មេដឹកនាំការអធិដ្ឋាន»* (...) *។ មេដឹកនាំទី ២ គេហៅថា «អ្នកធ្វើអគ្គសញ្ញាជ្រមុជទឹក»* (...) *។*

## 128 លិខិតលោកអភិបាលក្រុងរ៉ូម បេណេឌីកតូ ទី ១៥ (១៩១៩) *(Maximum illud)*

ពេលសង្គ្រាមលោកលើកទី ១ សាសនទូតអឺរ៉ុបត្រូវវិលត្រឡប់ទៅស្រុករបស់ខ្លួនវិញ ។ ព្រះសហគមន៍ជាច្រើនគ្មានក្រុមបូជាចារ្យកើតក្នុងស្រុកទេ ។ ជួនកាលសាសនទូតបរទេសជាអ្នកជាតិនិយមហួស ខុសនឹងដំណឹងល្អ ។

(...) *មានសេចក្តីដ៏សំខាន់មួយ ដែលអស់លោកដឹកនាំភូមិភាគត្រូវចាប់អារម្មណ៍យ៉ាងពិសេស គឺត្រូវស្វែងរកនិងអប់រំ ក្រុមបូជាចារ្យកើតក្នុងស្រុក* (...) *។ ទោះបីអស់លោកអភិបាលក្រុងរ៉ូមតែងតែទទួចសុំជាយូរមកហើយក្តី ក៏នៅតែមានសភាពការណ៍គួរឲ្យនឹកស្តាយជាខ្លាំងដែរ ។ តំបន់ខ្លះ សាសនាកាតូលិកចូលជាយូរសតវត្សមកហើយ តែក្រុមបូជាចារ្យកើតក្នុងស្រុកនៅតែអន់ជាងបូជាចារ្យឯទៀតៗ ។ ក្នុងប្រជាជនជាច្រើនដែលលូតលាស់ មានមនុស្សគួរឲ្យសរសើរគ្រប់វិស័យ ប៉ុន្តែយូរសតវត្សក្រោយដែលដំណឹងល្អបានទៅដល់នោះ នៅតែមិនទាន់មានអភិបាលណែនាំ ហើយក៏គ្មានក្រុមបូជាចារ្យដែលអ្នកស្រុកពេញចិត្តបានសោះ ។ យើងត្រូវទទួលស្គាល់ថា យើងធ្វើមិនត្រឹមត្រូវនៅក្នុងការអប់រំបូជាចារ្យរហូតមកដល់សព្វថ្ងៃ* (...) *។*

*តាំងពីប៉ុន្មានឆ្នាំកន្លងមក យើងកើតទុក្ខជាខ្លាំង ដោយឃើញព្រឹត្តិបត្រខ្លះរបស់សាសនទូតយកចិត្តទុកដាក់នឹងអត្ថប្រយោជន៍នៃប្រទេសរបស់ខ្លួនជាជាងរកអត្ថប្រយោជន៍ព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ ។ យើងសែនឆ្ងល់ ដោយគ្មាននរណានឹកឃើញថា របៀបគិតបែបនេះអាចបង្វែរអស់អ្នកមិនជឿ កុំឲ្យចាប់អារម្មណ៍នឹងសាសនាយើង* (...) *។ សាសនទូតមិនមែនជាទូតប្រទេសរបស់ខ្លួនទេ គឺជាទូតរបស់ព្រះគ្រីស្តវិញ ។ គាត់ ត្រូវរស់នៅតាមរបៀបដែលមនុស្សណា ក៏អាចទទួលស្គាល់ថា គាត់ជាអ្នកបម្រើសាសនា និងមិនមែនជាសាសនាបរទេសទេ ។ ក្នុងស្រុកណាក៏ដោយ ត្រូវតែគោរពថ្វាយបង្គំព្រះជាម្ចាស់ តាមសេចក្តីពិតនិងតាមព្រះវិញ្ញាណ «គ្មានជនជាតិក្រិក គ្មានជនជាតិយូដា គ្មានអ្នកងារ គ្មានអ្នកជាទៀតទេ គឺមានតែព្រះគ្រីស្តបំពេញអ្វីទាំងអស់ក្នុងមនុស្សទាំងអស់» ។* (កូឡ ៣,១១)

Layout Histor.qxd 2/10/07 10:11 AM Page 228

លោកដាស់តឿនសាសនទូតឲ្យអប់រំបូជាចារ្យដែលកើតក្នុងស្រុក ឲ្យមានសកម្មភាពស្មើនឹងបូជាចារ្យឯទៀតៗក្នុងពិភពលោក ហើយដាស់តឿនអភិបាលឲ្យបង្កើតទេវវិទ្យាល័យតាមតំបន់រៀងៗខ្លួន ។ លោកក៏បង្កើតមហាវិទ្យាល័យនៅក្រុងរ៉ូម ដើម្បីជួយបូជាចារ្យកើតក្នុងស្រុកកុំឲ្យជាតិនិយមជ្រុល ។ នៅពេលនោះ គ្រីស្តបរិស័ទចាប់ផ្តើមសម្របទៅតាមអរិយធម៌ស្រុករបស់ខ្លួន ។ ក្នុងចំណោមអ្នកយកចិត្តទុកដាក់ធ្វើឲ្យគ្រីស្តសាសនាបានស្របតាមអរិយធម៌ស្រុកទេសនោះ មានពីរនាក់ដ៏ល្បីគឺ៖

129 - លោក**វិនសង់-លែប** (Vincent Lebbe ១៨៧៧-១៩៤០) យកចិត្តទុកដាក់គោរពអរិយធម៌ចិន ។ លោកបង្កើតកាសែតកាតូលិកជាភាសាចិនមុនគេ ។ នៅឆ្នាំ ១៩២៧ លោកបង្កើត «*សមាគមជំនួយអភិបាលកើតក្នុងស្រុក*» (Société Auxilliaire des Missions) ប្រមូលបូជាចារ្យដែលសុខចិត្តជួយបម្រើអភិបាលកើតក្នុងស្រុកនានា ។ នៅស្រុកចិនលោកបង្កើតក្រុមគ្រួសារបព្វជិតបព្វជិតាជាតិចិនពីរក្រុម ។ លោកយកចិត្តទុកដាក់ឲ្យជនជាតិចិនយល់ឃើញថា សាសនទូតមិនមែនជាឧបករណ៍ជួយជនបស្ចិមឲ្យចូលមកប្រទេសចិនទេ ។

- លោក**យូលីយ៉ូ ដឺមុងសានាំង** (Jules de Monchanin ១៨៩៥-១៩៥៧) ជាបូជាចារ្យជាតិបារាំងម្នាក់ពីភូមិភាគលីយ៉ុង ។ លោកចូលចិត្តស្វែងរកចំណេះគ្រប់យ៉ាង ។ គាត់ចាប់ចិត្តនឹងសាសនាហិណ្ឌូ ហើយចេញទៅប្រទេសឥណ្ឌានៅឆ្នាំ 130
១៩៣៩ ក្នុងឋានៈជាសមាជិកនៃសមាគមជំនួយលោកអភិបាលកើតនៅក្នុងស្រុក (SAM) ។ លោកបង្កើតវត្តអារាមមួយ ហើយយកចិត្តទុកដាក់ឲ្យសម្របតាមប្រពៃណីបព្វជិតឥណ្ឌា និងការរស់នៅជាឥសីនៅប្រទេសឥណ្ឌាផង ។

129

## គ្រីស្តបរិស័ទចិនមានសិទ្ធិជាអ្នកជាតិនិយមបាន

លោក**លែប** សរសេរលិខិតផ្ញើជូនលោកអភិបាលព្រះសហគមន៍រ៉េណូ (Reynaud) នៅថ្ងៃទី ១៨ វិច្ឆិកា ១៩១៧ មានសេចក្តីដូចតទៅ៖

*(...) គ្រីស្តបរិស័ទចិនមានសិទ្ធិស្រឡាញ់មាតុភូមិរបស់ខ្លួន ។ គេមានភារកិច្ចទៅជាអ្នកជាតិនិយម ដូចគ្រីស្តបរិស័ទអឺរ៉ុបឬអាមេរិកដែរ ។ ខ្ញុំប្រកាសដំណឹងល្អអស់រយៈពេល ១៧ ឆ្នាំមកហើយ ខ្ញុំយល់ឃើញថា ឧបសគ្គធ្ងន់ជាងគេដែលរារាំងបណ្តាជនមិនឲ្យទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺបញ្ហាជាតិ (ខ្ញុំមិននិយាយថាមានឧបសគ្គតែមួយនេះទេ) ។ ប្រសិនបើនិយាយតាមប្រាជ្ញារបស់មនុស្ស ព្រះជាម្ចាស់មិនប្រព្រឹត្តបាដិហារិយ៍ ពួកគេមិនអាចចូលព្រះសហគមន៍បានសោះ គឺមានតែយើងទេ ដែលអាចរំលំជញ្ជាំងដែលឃាំងគេមិនឲ្យចូលនោះ ។ នៅក្នុងព្រះសហគមន៍ទ្វីបអឺរ៉ុប គេលើកតម្កើងអ្នកជាតិនិយមយ៉ាងពិតប្រាកដ ។ យ៉ាងណាមិញ ព្រះសហគមន៍នៅស្រុកចិនក៏ត្រូវលើកតម្កើងអ្នកជាតិនិយមរបស់គេដែរ ។ សេចក្តីនេះជាលក្ខណៈចៀសមិនផុតតាមផ្លូវលោក ដើម្បីសាសនាកាតូលិកចាក់ឫសក្នុងប្រជាជន និងទាក់ទាញចិត្តគេបាន (...) ។*

*លោកអភិបាល! លោកណែនាំព្រះសហគមន៍អស់រយៈពេល ៣៣ ឆ្នាំហើយ! លោកអប់រំបូជាចារ្យល្អៗជាច្រើនឲ្យចេះដឹង បូជាចារ្យខ្លះទៀតខ្ពង់ខ្ពស់ឧត្តុង្គឧត្តម ដូចគេប្រាប់មកខ្ញុំ ។ ហេតុអ្វីបានជាលោកមិនដែលគិតតែងតាំងលោកដ៏ប្រសើរលើសគេទាំងអស់នោះឲ្យទៅជាអភិបាល (...) ។ ប្រហែលលោកខ្លាចបូជាចារ្យជាតិអឺរ៉ុបអាក់អន់ចិត្ត មិនយល់ព្រមចុះចូលក្រោមអំណាចអភិបាលដែលមានជាតិប្លែកពីខ្លួនទេដឹង? បើពិតដូច្នោះមែន លោកមើលងាយអស់លោកទាំងនោះហើយ ។ យើងជាបូជាចារ្យ ត្រូវធ្វើដូចជនស៊ីវិលអឺរ៉ុបដែលធ្វើការតាមផ្លូវដែកនៅគយ ឬនៅក្នុងសាលារៀន គឺពួកគេសុខចិត្តចុះចូលអ្នកដឹកនាំដែលមានសញ្ជាតិប្លែកពីខ្លួន ។ ពួកគេស្រឡាញ់ប្រាក់ រីឯយើងវិញ ប្រកាសថា ស្រឡាញ់ព្រះយេស៊ូគ្រីស្ត ។ ហេតុនេះហើយ បានជាការអប់រំបូជាចារ្យកើតក្នុងស្រុកឃឺតបំផុត គឺគ្រាន់តែអប់រំគេឲ្យក្លាយជាក្រុមបូជាចារ្យជំនួយប៉ុណ្ណោះ ។*

*លិខិតលោកលែប*

Layout Histor.qxd 2/10/07 10:11 AM Page 229

(130)

# មានព្រះសហគមន៏តែមួយ តែមានរូបរាងផ្សេងៗជាច្រើន

*ខ្ញុំស្នាក់អាស្រ័យនៅប្រទេសឥណ្ឌាអស់រយៈពេល ១២ ឆ្នាំហើយ ។ មិត្តសំឡាញ់ដែលកាន់សាសនាហិណ្ឌូ ណែនាំខ្ញុំឲ្យយល់កាន់តែច្បាស់ថា ព្រះគ្រីស្តតែមួយព្រះអង្គ បានសង្គ្រោះមនុស្សទាំងអស់ហើយ (...) គឺសង្គ្រោះពិភពលោកទាំងមូលរួចហើយ ។*

*គ្រីស្តបរិស័ទខ្លះស្មានថា វាសនាពិភពលោកនឹងវាសនាគ្រីស្តសាសនាជាប់គ្នា ដូចគ្រីស្តសាសនាមានរូបរាងនៅក្នុង ១០ ឬ ២០ សតវត្ស ដើមដំបូងនៃប្រវត្តិសាស្ត្ររបស់ខ្លួនប៉ុណ្ណោះ ។ គ្រីស្តបរិស័ទទាំងនោះយល់ឃើញថា ប្រជាជនជឿលើព្រះគ្រីស្តកាន់តែច្រើនឡើងៗ ហើយស្មានថា ធ្វើឲ្យព្រះសហគមន៍លាតសន្ធឹងកាន់តែឆ្ងាយទៅៗ ។ គេនឹកស្មានថា បន្ទាប់ពីសន្តិ**ថូម៉ាស នៅអាគីណូ** និងបន្ទាប់ពីមហាសន្និបាតនៅត្រេនតូ ព្រះសហគមន៍គ្មានអ្វីដែលខ្លួនត្រូវរៀនទៀតនោះទេ មិនត្រូវកែទម្រង់អ្វីសោះឡើយ ។ ព្រះសហគមន៍ដូចជាដល់ឋានៈជាមនុស្សពេញវ័យ ហើយអ្នកចូលព្រះសហគមន៍ ដូចជាចូលក្នុងព្រះវិហារមួយដែលមិនខ្វះដុំថ្មណាមួយសោះ (..) ។*

*បើសិនយើងគិតអំពីសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់ យើងយល់ឃើញថា ព្រះសហគមន៍ទទួលយកសេចក្ដីទាំងអស់តាំងពីដើមរៀងមកមែន មិនខ្វះអ្វីឡើយ ។ ប៉ុន្តែ ប្រសិនបើយើងគិតអំពីការលាតត្រដាងអត្ថន័យអំពីព្រះគ្រីស្តដែលមានលក្ខណៈជាមនុស្ស និងបំប្រែអ្វីៗទាំងនោះឲ្យបានប្រសើរក្នុងអង្គព្រះគ្រីស្តវិញ គ្មានទីបញ្ចប់ទេ ។ នៅសតវត្សណាក៏ដោយ សេចក្ដីពិតមិនដែលលាតត្រដាងជាស្ថាពរទេ ។ សម័យនេះ ព្រះសហគមន៍មិនគ្រាន់តែប្រកាសដូចសម័យសន្ត**អូគូស្តាំង**ថា៖ «ភាសាឡាតាំង ក្រិក និងស៊ីរី ជាភាសារបស់ខ្ញុំដែរ» គឺព្រះសហគមន៍ត្រូវបន្ថែមភាសាសំស្ក្រិត ភាសាទមិឡ និងភាសាចិនថែមទៀត ទោះបីភាសានេះលំបាកយល់ដល់អស់អ្នករស់នៅជុំវិញសមុទ្រមេឌីទែរ៉ាណេ អាល្លឺម៉ង់ និងនៅស្លាវក៏ដោយ ក៏ព្រះសហគមន៍ត្រូវប្រកាសជំនឿតាមភាសា និងតាមអរិយធម៌ទាំងនោះ ។*



*លោក ដឺមុងសានាំង រស់នៅតាមរបៀបបព្វជិតឥណ្ឌា*

*មនុស្សនឹងរិះគិតតាមវិញ្ញាណ តាមរបៀបថ្មី ដែលមិនទាន់ចេញពន្លកទេ មានរបៀបថ្មីៗអំពីការស្មឹងស្មាធិ៍ របៀបថ្មីអំពីការថ្លែងគម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ របៀបថ្មីអំពីការថ្វាយបង្គំ របៀបថ្មីអំពីការថ្វាយខ្លួនជាបព្វជិត ។ ព្រះសហគមន៍រង់ចាំរបៀបថ្មីនេះយូរសតវត្សទៀត ប្រហែលរហូតដល់អរិយធម៌ឥណ្ឌា ចិន ចូលមកយ៉ាងរុងរឿងក្នុងព្រះសហគមន៍តែមួយ ដែលមានរូបរាងផ្សេងៗគ្នា ។ គ្រីស្តសាសនាមានកាលពីដើម មាននៅសព្វថ្ងៃ និងមានជាដរាបតរៀងទៅ ។ ព្រះវិញ្ញាណដែលមានព្រះជន្មអស់កល្បជានិច្ច ព្រះអង្គនឹងគង់នៅជាមួយអ្វីៗ ដែលព្រះអង្គធ្វើឲ្យពេញលក្ខណៈឡើង ។*

*យូលីយ៉ូ ដឺមុងសានាំង*

# គ- ក្រោយសង្គ្រាមលោកលើកទី ២

តាមការព្រមព្រៀងនៅយ៉ាលថា (Yalta) នាឆ្នាំ ១៩៤៤ ពិភពលោកចែកជាពីរផ្នែក គឺមួយខាងសេរី មួយផ្នែកទៀតខាងកុម្មុយនីស្ត ។ ចាប់តាំងពីពេលនោះមក ផ្នែកទាំងពីរកើតសង្គ្រាមត្រជាក់ ។ គ្រីស្តបរិស័ទមួយចំនួនធំស្លាប់ក្នុងសង្គ្រាមលោកលើកទី ២ រួមជាមួយប្រជាជនប្រទេសរបស់ខ្លួន ។ សភាពការណ៍ព្រះសហគមន៍ប្រែប្រួលជាខ្លាំងនៅគ្រប់ប្រទេស ។

## ១- នៅទ្វីបអាស៊ី

### *ប្រទេសចិន*



*លោកម៉ៅសេទុង*

ឆ្នាំ ១៩៤៩ លោក**ម៉ៅ សេទុង** (Mao Tse Toung) ឡើងកាន់អំណាចលើប្រទេសចិនទាំងមូល ។ លោកសូមឲ្យគ្រីស្តបរិស័ទ «*ស្វយ័តបីយ៉ាង*» គឺឲ្យត្រួតត្រាព្រះសហគមន៍របស់ខ្លួនដោយខ្លួនឯង (*មិនទទួលស្គាល់អំណាចសន្តអាសនៈក្នុងការដឹកនាំ មានការតែងតាំងអភិបាលជាដើម*) ឲ្យរកនិងកាន់កាប់កម្រៃដោយខ្លួនឯង (*មិនទទួលធនធានពីបរទេសទៀតទេ*) ឲ្យប្រកាសដំណឹងល្អដោយគ្មានជនជាតិបរទេសចូលលាយឡំជាមួយ (*ដេញសាសនទូតបរទេសទាំងអស់ចេញពីស្រុក*) ។ លោកខិតខំបង្កើតព្រះសហគមន៍ជាតិនិយមដាច់ពីសន្តអាសនៈ តែងតាំងអភិបាលដែលគាំទ្ររដ្ឋ ហើយបៀតបៀនធ្វើបាបគ្រីស្តបរិស័ទដែលនៅតែភ្ជាប់ចិត្តនឹងសន្តអាសនៈ ។ រដ្ឋអំណាចបៀតបៀនធ្វើបាបអភិបាលព្រះសហគមន៍ បូជាចារ្យ និងគ្រីស្តបរិស័ទជាច្រើន ឲ្យជាប់ឃុំឃាំងជាយូរឆ្នាំ បង្ខំឲ្យធ្វើការជាទម្ងន់ សម្លាប់ខ្លះជាពិសេសនៅសម័យ «*បដិវត្តន៍វប្បធម៌*» (១៩៦៦-១៩៦៨) ។ នៅដើមសតវត្សទី ២១ សភាពការណ៍ព្រះសហគមន៍នៅប្រទេសចិនធូរស្រាលបន្តិច តែនៅមិនទាន់ស្រួលបួលប៉ុន្មានទេ ។ គ្រីស្តបរិស័ទប្រូតេស្តង់នៅស្រុកចិន សុខចិត្តអនុវត្តតាមគោលការណ៍ «*ស្វយ័តបីយ៉ាង*» មិនសូវជួបឧបសគ្គប៉ុន្មានទេ ។

## ***ប្រទេសកូរ៉េ***

ប្រទេសកូរ៉េកើតសង្គ្រាមរវាងកុម្មុយនីស្តកូរ៉េជាមួយនឹងកងទ័ពអាមេរិកាំង (១៩៥០-១៩៥៥) ។ នៅឆ្នាំ ១៩៥៥ ប្រទេសកូរ៉េបែកចែញជាពីរ គឺកូរ៉េខាងជើងជាកុម្មុយនីស្ត និងកូរ៉េខាងត្បូងនៅសេរី ។ នៅកូរ៉េខាងជើងគ្មានសេរីភាពសោះរហូតមកដល់សព្វថ្ងៃ ។ រីឯនៅកូរ៉េខាងត្បូងវិញ គ្រីស្តបរិស័ទកាន់តែកើនចំនួនឡើង ។ នៅឆ្នាំ ២០០៥ មានគ្រីស្តបរិស័ទកូរ៉េខាងត្បូងជាង ៤ លាននាក់ (*៩% នៃប្រជាជនទាំងអស់*) អភិបាល ២០ នាក់ បូជាចារ្យ ៤០០០ នាក់ ។

## ***ប្រទេសវៀតណាម***

នៅឆ្នាំ ១៩៥៤ ពួកអ្នកជាតិនិយមវៀតមិញវាយឈ្នះកងទ័ពអាណានិគមបារាំង ហើយកាន់អំណាចនៅវៀតណាមភាគខាងជើង ។ គ្រីស្តបរិស័ទកាតូលិកជាងពីរលាននាក់ ភៀសខ្លួនមករស់នៅវៀតណាមភាគខាងត្បូង ។ រដ្ឋអំណាចភាគខាងជើងបៀតបៀនធ្វើបាបគ្រីស្តបរិស័ទ ដោយចោទថា គេកាន់ជើងអាណានិគមបារាំង និងកាន់តាមសេរី ។ ទោះជាយ៉ាងណាក៏ដោយ ក៏គ្រីស្តបរិស័ទវៀតណាមខាងជើងនៅតែកាន់ជំនឿមាំមួនរ៉ឹងប៉ឹងដដែល ។

ពីឆ្នាំ ១៩៦៥-១៩៧៥ វៀតណាមកើតចម្បាំងម្តងទៀត គឺច្បាំងជាមួយសហរដ្ឋអាមេរិក គ្រីស្តបរិស័ទនៅភាគខាងជើងប្រឆាំងយ៉ាងសកម្មនឹងកងទ័ពបរទេស ហើយសម្តែងថា គេក៏ជាអ្នកជាតិនិយមដែរ ។ រីឯគ្រីស្តបរិស័ទវៀតណាមខាងត្បូងវិញ ភាគច្រើនកាន់ជើងរដ្ឋអំណាចខាងសេរី ។ លោកអភិបាល **ង៉ោ ឌីន ធុក** (Ngo Dinh Thuc) ជាបងរបស់លោកប្រធានាធិបតី **ង៉ោ ឌីន យៀម** (Ngo Dinh Diem) ចង់លើកគ្រីស្តសាសនាទៅជាសាសនារដ្ឋ ។ ប៉ុន្តែបូជាចារ្យខ្លះ គាំទ្ររបបកុម្មុយនីស្ត ដោយយល់ឃើញថា កងទ័ពអាមេរិកាំងធ្វើបាបប្រជាជនខ្លាំងពេក និងមានអយុត្តិធម៌ក្នុងស្រុក ។ គេរួមជាមួយពួកកុម្មុយនីស្តដែលទាមទារយុត្តិធម៌ក្នុងសង្គមវិញ ។ ក្រោយពីកុម្មុយនីស្តបានជ័យជំនះហើយ (៣០ មេសា ១៩៧៥) លោកអភិបាលព្រះសហគមន៍ព្រៃនគរ **ង្វៀង វ៉ាន ប៊ិន** (Nguyen van Binh) សុខចិត្តរួមសហការខ្លះៗជាមួយរបបកុម្មុយនីស្ត ។ ប៉ុន្តែ របបនោះបៀតបៀនព្រះសហគមន៍ មិនអនុញ្ញាតឲ្យបើកទេវវិទ្យាល័យ និងមិនឲ្យបព្វជិតបព្វជិតាធ្វើការខាងសង្គមកិច្ចដូចពីមុនទេ ហើយចាប់គ្រីស្តបរិស័ទនិងបូជាចារ្យមួយចំនួនដាក់ឃុំឃាំង ។ មានបូជាចារ្យខ្លះខិតខំបង្កើតព្រះសហគមន៍ជាតិនិយម (Công giao va tan tok) តែទៅមិនរួច ។

ឆ្នាំ ២០០៦ មានគ្រីស្តបរិស័ទវៀតណាម ៥ លាននាក់ (៦,៩% នៃប្រជាជនទាំងអស់) អភិបាល ៣៩ នាក់ បូជាចារ្យ ២៥០០ នាក់ បព្វជិត ១១០០០ នាក់ ។ សភាពការណ៍គ្រីស្តបរិស័ទធូរស្រាលច្រើន ។

## ***ប្រទេសលាវ***

ប្រទេសលាវកើតសង្គ្រាមតាំងពីឆ្នាំ ១៩៤៥ មក ។ នៅឆ្នាំ ១៩៥៤ ប្រទេសនេះចែកជាពីរដោយគណបក្ស «*បថេតឡាវ*» កាន់ផ្នែកខាងកើត និងរដ្ឋាភិបាលសេរីកាន់កាប់ខាងលិច ។ តាំងពីឆ្នាំ ១៩៦២ មក សង្គ្រាមកើតម្តងទៀត យន្តហោះអាមេរិកទម្លាក់គ្រាប់បែកលើផ្លូវលំហូជីមិញ ដែលកាត់ភ្នំខាងកើតស្រុកឡាវ ។ ដល់ឆ្នាំ ១៩៧៣ រដ្ឋអំណាចកុម្មុយនីស្តកាន់កាប់ស្រុកទាំងមូល គេបណ្តេញសាសនទូតបរទេសទាំងអស់ ចាប់អភិបាលខ្លះទៅឃុំឃាំង ។ សព្វថ្ងៃ សភាពការណ៍គ្រីស្តបរិស័ទនៅតែតឹងតែង ។ ឆ្នាំ ១៩៩៩ ទូទាំងស្រុកមានគ្រីស្តបរិស័ទ ៤២០០០ នាក់ អភិបាល ៤ នាក់ បូជាចារ្យ ១៧ នាក់ បព្វជិតា ៩៧ នាក់ ។ ឆ្នាំ ២០០៧ ជនជាតិឡាវ ៤ នាក់ ទទួលអគ្គសញ្ញាតែងតាំងបូជាចារ្យ ។

Layout Histor.qxd 2/10/07 10:11 AM Page 232

ក្រោយសង្គ្រាមលោកលើកទី ២ ប្រទេសអាស៊ីជាច្រើនបែរទៅជាមានគំនិតនយោបាយជាអ្នកជាតិនិយម រដ្ឋមានបំណងការពារសាសនានិងអរិយធម៌របស់ខ្លួនហើយនាំគ្នា បិទព្រំដែនមិនឲ្យសាសនទូតបរទេសចូលមកបាន ។ ក្នុងចំណោមប្រទេសទាំង នោះមានប្រទេសម៉ាឡេស៊ី សឹង្ហបុរី ឥណ្ឌា ភូមាជាដើម ។

## ២- គំនិតថ្មីក្នុងការណែនាំព្រះសហគមន៍

### *ក- គ្រីស្តបរិស័ទ និង នយោបាយ*

គ្រីស្តបរិស័ទយកចិត្តទុកដាក់នឹងរឿងនយោបាយ ដើម្បីកសាងសង្គមឲ្យប្រកបដោយយុត្តិធម៌ ហើយបង្កើតគណបក្សនយោបាយកាតូលិក *(ស្រុកអ៊ីតាលី ស្រុកអាល្លឺម៉ង់ ស្រុកបារាំង)* ។ ជួនកាលគេដណ្តើមអំណាចពីគណបក្សកុម្មុយនីស្តនិងគណបក្សសង្គមនិយមបាន ។ យូរៗទៅ គ្រីស្តបរិស័ទឯទៀតៗដែលតែងនឹកនាពីរបបរាជានិយម ប្រែខ្លួនសុខចិត្តទទួលយករបបសាធារណរដ្ឋនិយម និងសុខចិត្តទទួលស្គាល់ថា គ្រីស្តសាសនាលែងទៅជាសាសនារដ្ឋហើយ ។ គណបក្សកាតូលិកទាំងនោះជួយយ៉ាងសកម្ម ក្នុងការបង្កើតច្បាប់ជាច្រើន ជាពិសេសច្បាប់ចាត់ចែងយុត្តិធម៌ក្នុងសង្គម ។

ក្រោយពីសង្គ្រាមលោកលើកទី ២ សហភាពសូវៀតលេបទឹកដីទ្វីបអឺរ៉ុបខាងកើត ។ រដ្ឋអំណាចសូវៀតនិងរដ្ឋអំណាចប្រទេសនីមួយៗ នាំគ្នាបៀតបៀនធ្វើបាបគ្រីស្តបរិស័ទ ព្រោះគ្រីស្តបរិស័ទមានគំនិតសេរីនិយម ផ្សេងពីគំនិតរដ្ឋកុម្មុយនីស្ត ។ រដ្ឋអំណាចប្រទេសនីមួយៗចាប់ចងអភិបាលព្រះសហគមន៍ខ្លះដាក់ឃុំឃាំង និងយកទៅផ្តន្ទាទោស ចាប់គ្រីស្តបរិស័ទជម្លៀសទៅកន្លែងផ្សេងៗបង្ខំឲ្យធ្វើការជាទម្ងន់ ។

នៅឆ្នាំ ១៩៤៩ សន្តអាសនៈ ហាមគ្រីស្តបរិស័ទនៅប្រទេសសេរី សហការជាមួយពួកកុម្មុយនីស្ត ។ ក៏ប៉ុន្តែ មានគ្រីស្តបរិស័ទខ្លះបែកចិត្តដោយឃើញថា មានតែគណៈបក្សកុម្មុយនីស្តទេ ដែលយកចិត្តទុកដាក់បង្កើតសង្គមប្រកបដោយយុត្តិធម៌ ។ គេយល់ឃើញថា ព្រះសហគមន៍នៅតែណែនាំអ្នកមាន តែមិនសូវរវីរវល់នឹងវណ្ណៈអធនដែលមិនអាចចូលគ្រីស្តសាសនាបានទេ សូម្បីតែចូលក្នុងវិហារក៏មិនបានដែរ ព្រោះវណ្ណៈអធនមានអរិយធម៌ប្លែកពីគ្រីស្តបរិស័ទធម្មតា ។

### *ខ- បូជាចារ្យកម្មករ*

បូជាចារ្យបារាំងខ្លះយល់ឃើញថា អ្នកស្រុកទូទាំងប្រទេសភាគច្រើនលះបង់ជំនឿ ជាពិសេសកម្មករធ្វើការនៅរោងចក្រ ។ គេអាចទៅជាគ្រីស្តបរិស័ទវិញបាន លុះត្រាតែព្រះសហគមន៍កែសម្រួលខ្លួន ជាពិសេសបូជាចារ្យផ្លាស់ប្តូររបៀបរស់នៅឲ្យស្របតាមកាលៈទេសៈ គឺប្លែកពីរបៀបចាត់ចែងតាមមហាសន្និបាតត្រេនតូ ។ អស់លោកលែងពាក់អាវវែងខ្មៅដូចពីមុន ត្រូវរស់នៅជាមួយប្រជាជនរស់នៅតាមផ្ទះធម្មតា ។ អស់លោកបូជាចារ្យទាក់ទងជាមួយអ្នកដែលមិនកាន់សាសនា និងពួកកុម្មុយនីស្តដែរ ព្រោះពួកកុម្មុយនីស្តទាំងនោះយកចិត្តទុកដាក់នឹងអ្នកក្រីក្រ ចង់បង្កើតសង្គមថ្មីប្រកបដោយយុត្តិធម៌ សមភាព និងភាតរភាព ។ ម៉្យាងទៀត កម្មករនិងអ្នកក្រីក្រស្ទើរតែទាំងអស់ចូលបក្សកុម្មុយនីស្ត ហើយកាន់អរិយធម៌ម៉្យាង ដែលហូរពីគោលលទ្ធិកុម្មុយនីស្តនោះ ។ ដូច្នេះហើយ បើចង់នាំដំណឹងល្អឲ្យគេ ត្រូវមានគំនិតដូចគេខ្លះ គឺត្រូវធ្វើជាកម្មកររោងចក្រដូចគេដែរ ។ អភិបាលព្រះសហគមន៍ខ្លះយល់ស្រប និងអនុញ្ញាតឲ្យបូជាចារ្យខ្លះទៅរស់នៅ និងធ្វើការនៅរោងចក្រជាកម្មករដូចគេដូចឯង ។ ស្រុកបារាំង មានបូជាចារ្យកម្មករប្រហែល ១០០ នាក់ ។

ប៉ុន្តែ នៅឆ្នាំ ១៩៤៩ អភិបាលក្រុងរ៉ូម**ពីយ៉ូ ទី ១២** ហាមគ្រីស្តបរិស័ទសហការជាមួយពួកកុម្មុយនីស្តជាដាច់ខាត ។ លោកបារម្ភថា បូជាចារ្យកម្មករទាំងនោះលែងរស់នៅតាមព្រះវិញ្ញាណ ហើយគិតតែពីទាមទារយុត្តិធម៌តាម

Layout Histor.qxd 2/10/07 10:11 AM Page 233

របៀបលោកិយ ។ នៅឆ្នាំ ១៩៥៤ លោកបញ្ឈប់អស់លោកជាបូជាចារ្យកម្មករឲ្យឈប់ធ្វើការនៅរោងចក្រទៀត ។ ក្នុងចំណោមពួកគេ ពាក់កណ្ដាលអនុវត្តតាមបញ្ជា និងពាក់កណ្ដាលទៀតមិនព្រមអនុវត្តតាមទេ ហើយនៅតែរស់នៅដូចកម្មករដដែល ។

ក្រោយមហាសន្និបាតវ៉ាទីកង់ទី ២ (១៩៦២-១៩៦៥) មានបូជាចារ្យជាច្រើនក្នុងពិភពលោកទាំងមូល រស់នៅតាមរបៀបថ្មីនោះ ។

## *គ- ការអប់រំជំនឿ*

ក្រោយសង្គ្រាមលោកលើកទី ២ បូជាចារ្យបារាំងខ្លះយល់ឃើញថា ការអប់រំតាមរបៀបមហាសន្និបាតត្រេនតូ មិនស៊ីជម្រៅជាមួយមតិប្រជាជនទេ ។ តាមរបៀបបុរាណនោះ អភិបាល បូជាចារ្យ និងអ្នកអប់រំជំនឿស្មានថា ក្មេងទាំងអស់ជាគ្រីស្ដបរិស័ទ គឺមានជំនឿតពីឪពុកម្ដាយមក ហេតុនេះអ្នកអប់រំគ្រាន់តែឲ្យបង្រៀនលទ្ធិគ្រីស្ដសាសនា ឲ្យពួកវាដឹងប៉ុណ្ណោះបានហើយ ។ តែតាមពិតក្មេងៗ យុវជន និងមនុស្សពេញវ័យមួយចំនួនធំក្រៃលែង គ្មានជំនឿលើព្រះគ្រីស្ដសោះ គឺពួកគេគ្រាន់តែកាន់តាមប្រពៃណីគ្រីស្ដសាសនាប៉ុណ្ណោះ ។ ដូច្នេះត្រូវអប់រំដោយសំអាងលើបទពិសោធន៍របស់គេ និងនាំគេឲ្យជួបព្រះគ្រីស្ដដោយផ្ទាល់ ។ ត្រូវអប់រំតាមតែគេអាចទទួលបាន ដោយមានដំណាក់កាលផ្សេងៗតាមដំណើរនៃការរស់នៅរបស់គេ ត្រូវនិយាយតាមពាក្យដែលគេធ្លាប់និយាយនោះ កុំប្រើពាក្យបច្ចេកទេសខាងសាសនាឲ្យសោះ ។ មិនត្រូវចាប់ផ្ដើមបង្ហាត់បង្រៀនទេវវិទ្យាឲ្យគេទេ គឺត្រូវចាប់ផ្ដើមអប់រំគេតាមបទពិសោធន៍នៃប្រជាជនអ៊ីស្រាអែល និងចាប់ផ្ដើមពីគម្ពីរជាគ្រឹះ ។ ហេតុនេះហើយ បានជាអស់លោកអភិបាលបង្កើតគ្រឹះស្ថានផ្សេងៗ ដើម្បីបង្ហាត់គ្រូអប់រំអាជីពនិងគ្រូស្ម័គ្រចិត្ត ។

ប៉ុន្ដែ នៅឆ្នាំ ១៩៥៧ អភិបាលក្រុងរ៉ូម **ពីយ៉ូ ទី ១២** បាញ់បោកពួកប្រពៃណីនិយមដែលចោទថា របៀបអប់រំជំនឿនេះមិនល្អ ព្រោះគ្មានបង្រៀនទេវវិទ្យាឲ្យក្មេងៗ គឺមិនបង្រៀនអំពីព្រះជាម្ចាស់បង្កើតពិភពលោកជាមុន មិនបង្រៀនអំពីបាបឪពុកម្ដាយដើម អំពីព្រះត្រៃឯក ។ល ។ អភិបាលក្រុងរ៉ូម សូមដកបូជាចារ្យបីនាក់នៅប្រទេសបារាំងដែលណែនាំការអប់រំជំនឿតាមរបៀបថ្មីនោះចេញ ។

ក្រោយមហាសន្និបាតវ៉ាទីកង់ទី ២ (១៩៦២-១៩៦៥) ព្រះសហគមន៍ជាច្រើនមានប្រទេសកម្ពុជាជាដើម បែរជាអប់រំជំនឿតាមរបៀបថ្មីនេះ គឺយកព្រះគម្ពីរ និងបទពិសោទរបស់ក្មេងមកអប់រំ ។

Layout Histor.qxd 2/10/07 10:11 AM Page 234



# ព្រះសហគមន៍ តាមមហាសន្និបាតវ៉ាទីកង់ទី ២

## ១- លោកយ៉ូហានទី ២៣

ក្រុមទីប្រឹក្សាអភិបាលក្រុងរ៉ូម បោះឆ្នោតជ្រើសរើសលោក**រ៉ុងកាល្លី** (Roncalli) ធ្វើជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម តពីលោក**ពីយ៉ូទី ១២** (ឆ្នាំ ១៩៥៨) ។ ពេលនោះលោកអាយុ ៧៧ ឆ្នាំហើយ ។ លោកដាក់ឈ្មោះខ្លួនឯងថា **យ៉ូហាន ទី ២៣** ។ មុនជាអភិបាលក្រុងរ៉ូម លោកបំពេញមុខងារជាអគ្គរាជទូតនៅប្រទេសជាច្រើន ហេតុនេះហើយ បានជាលោកសង្កេតឃើញថា មនុស្សជាច្រើនមិនវើរវល់នឹងព្រះសហគមន៍ ត្រង់វិស័យជាច្រើនក្នុងការរស់នៅរបស់គេ ។ លោកមានបំណងធ្វើឲ្យព្រះសហគមន៍ «*រលាស់ធូលីដែលជាប់ពីចក្រភពមក ចេញពីព្រះសហគមន៍*» គឺធ្វើឲ្យព្រះសហគមន៍តបឆ្លើយនឹងសេចក្ដីរងចាំរបស់មនុស្ស ។

## ២- មហាសន្និបាតវ៉ាទីកង់ ទី ២

ថ្ងៃ ២៥ មករា ១៩៥៩ លោកយ៉ូហានទី ២៣ កោះហៅអស់លោកអភិបាលក្នុងពិភពលោកទាំងមូលមកជួបជុំគ្នាជាមហាសន្និបាតសកល ។ លោកមានគោលបំណងណែនាំព្រះសហគមន៍ឲ្យស្របតាមសម័យ ឲ្យគិតគូរអំពីការប្រកាសដំណឹងល្អក្នុងពិភពលោកដែលតែងតែប្រែប្រួលនាបច្ចុប្បន្នកាល ព្រមទាំងណែនាំគ្រីស្តបរិស័ទគ្រប់និកាយឲ្យរួបរួមគ្នាជាធ្លុងតែមួយនៅពេលឆាប់ៗ ។ លោកគ្មានបំណងដាក់ទោសលើនរណាសោះ គឺលោកគ្រាន់តែចង់ឲ្យព្រះសហគមន៍រិះរករបៀបប្រកាសដំណឹងល្អស្របតាមអរិយធម៌បច្ចុប្បន្នប៉ុណ្ណោះ ។

លោកស្នើសុំយោបល់ពីអភិបាលព្រះសហគមន៍ និងពីមហាវិទ្យាល័យនានា ហើយបង្កើតគណៈកម្មាធិការ ១២ ដែលមានមុខងាររៀបចំឯកសារ ៧០ ច្បាប់ ទុកជាសេចក្ដីដែលត្រូវពិនិត្យមើលនិងរិះគិត ។



លោកយ៉ូហានទី ២៣ (ឆ្នាំ ១៩៥៨ - ១៩៦៣)

Layout Histor.qxd 2/10/07 10:11 AM Page 236

## ៣- ប្រជុំទី ១ (១៩៦២)

អភិបាល ២.៤០០ នាក់ចូលរួម អស់លោកមកពីគ្រប់ទ្វីបទាំងអស់ ។ លោក **យ៉ូហាន ទី ២៣** ក៏អញ្ជើញតំណាង ៣១ នាក់របស់និកាយផ្សេងៗ *(ប្រជុំចុងក្រោយចំនួនឡើងដល់ ៩៣)* ឲ្យចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍ គឺមានអភិបាលអ័រតូដុក និងអង់គ្លីកង់ ព្រមទាំងគ្រូគង្វាលប្រូតេស្តង់ដែរ ។ នៅពេលប្រជុំ មានគ្រីស្តបរិស័ទធម្មតា ៣៦ នាក់ទៀតចូលរួម ក្នុងនោះមានស្ត្រី ៧ នាក់ ។

ពេលអស់លោកអភិបាលប្រជុំគ្នាលើកដំបូង អង្គប្រជុំបែកគំនិតពីរយ៉ាងគឺ ក្នុងក្រុមមួយមានអភិបាលភាគច្រើនដែលមានបំណងតាមលោកយ៉ូហាន ទី ២៣ ចង់សម្របសម្រួលព្រះសហគមន៍តាមអរិយធម៌នាបច្ចុប្បន្នកាល ចង់សន្ទនាជាមួយនិកាយផ្សេងៗទៀត និងចង់ឲ្យព្រះសហគមន៍យោងកម្លាំងថ្មីពីព្រះគម្ពីរវិញ ។ មួយក្រុមទៀត គឺអភិបាលភាគតិចមានបំណងឲ្យព្រះសហគមន៍ស្ថិតនៅមាំមួនដូចពីដើម ចង់រក្សាការពារពាក្យខ្លួនដដែល មិនប្រែប្រួលអ្វីឡើយ ។

ឆ្នាំ ១៩៦៣ លោកយ៉ូហានទី ២៣ សរសេរសារលិខិតមួយច្បាប់មានចំណងជើងថា «*សេចក្តីសុខសាន្តនៅលើផែនដី*» (Pacem in Terris) ។ មានមនុស្ស (131) ជាច្រើនពេញចិត្តនឹងលិខិតនេះ ពីព្រោះលោកមិនសរសេរសំដៅតែគ្រីស្តបរិស័ទប៉ុណ្ណោះទេ គឺលោកផ្ញើជូនមក «*អស់មនុស្សដែលមានឆន្ទៈល្អ*» ផងដែរ ។ លោកទទួលមរណភាពពីរខែក្រោយមក ។

(131) **សារលិខិត "សេចក្តីសុខសាន្តនៅលើផែនដី" របស់លោកយ៉ូហាន ទី ២៣ (ខែមេសា ១៩៦៣)**

*ជម្រាបមកអស់បងប្អូនជាអភិបាលព្រះសហគមន៍មជ្ឈិមបូព៌ា អស់លោកអភិបាលព្រះសហគមន៍ (...) ក្រុមបូជាចារ្យ និងគ្រីស្តបរិស័ទទាំងអស់ក្នុងពិភពលោក ព្រមទាំងមនុស្សទាំងប៉ុន្មានដែលមានឆន្ទៈល្អ (...) ។*

*វិទ្យាសាស្ត្រចម្រើនឡើងជាលំដាប់ អ្វីដែលបច្ចេកទេសបង្កើតនាំឲ្យយើងដឹងច្បាស់ថា សត្វលោកទាំងអស់ និងឥទ្ធិពលធម្មជាតិ ត្រូវបាត់បែងតាមរបៀបរៀបរយល្អហើយ ។ មនុស្សមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយអាចរកឃើញរបៀបរៀបរយនេះ និងផលិតគ្រឿងផ្សេងៗ ដើម្បីយកថាមពលធម្មជាតិទាំងនោះមកប្រើប្រាស់បម្រើខ្លួន (...) ។*

*មនុស្សគ្រប់រូបមានសិទ្ធិមានជីវិត ឲ្យគេគោរពរូបកាយ និងមានអ្វីៗទាំងអស់ដែលខ្លួនត្រូវការឲ្យបានគ្រប់គ្រាន់ ដើម្បីរស់នៅយ៉ាងសមរម្យ ជាពិសេសមានម្ហូបអាហារ មានសម្លៀកបំពាក់ មានទីលំនៅ មានពេលសម្រាកកាយ សិទ្ធិព្យាបាលជំងឺ និងអាចពឹងលើការបម្រើតាមសង្គមកិច្ច (...) ។*

*មនុស្សគ្រប់ៗរូបមានសិទ្ធិសេរីភាពគោរពព្រះជាម្ចាស់តាមច្បាប់ដ៏ត្រឹមត្រូវនៃមនសិការរបស់ខ្លួន អាចកាន់សាសនាតាមរបៀបជាឯកជនក្តី ជាសាធារណៈក្តី (...) ។ មនុស្សគ្រប់ៗរូបមានសិទ្ធិសេរីភាពអាចនៅលីវក៏បាន ឬរៀបអាពាហ៍ពិពាហ៍ក៏បានដែរ (...) ។ មនុស្សគ្រប់ៗរូបមានសិទ្ធិមានការងារធ្វើ និងទទួលខុសត្រូវលើសេដ្ឋកិច្ចក្នុងប្រទេស (...) ។*

*យើងយល់ឃើញថា សេចក្តីប្រកាសទូទៅនៃសិទ្ធិមនុស្សរបស់សហប្រជាជាតិ (១០ ធ្នូ ១៩៤៨) ពិតជាជំហានមួយសម្រាប់បាត់បែងសហគមន៍មនុស្សក្នុងលោក ឲ្យមានរបៀបរៀបរយ (...) ។ ហេតុដូច្នេះហើយ បានជាយើងសង្ឃឹមយ៉ាងមុតមាំថា អង្គការសហប្រជាជាតិ អាចសម្របរចនាសម្ពន្ធ និងមធ្យោបាយបំពេញមុខងាររបស់ខ្លួនឲ្យ បានស្របទៅតាមបេសកកម្មដ៏ធំទូលាយដ៏ មានតម្លៃបំផុតរបស់ខ្លួននោះ ។ សូមឲ្យអង្គការសហប្រជាជាតិ ជានាយ៉ាងស័ក្តិសិទ្ធិនូវសិទ្ធិសេរីភាពរបស់មនុស្សគ្រប់ៗរូបនាពេលឆាប់ៗខាងមុខនេះផង (...) ។*

*មនុស្សទាំងប៉ុន្មានដែលមានឆន្ទៈល្អ មានភារកិច្ចដ៏ទូលំទូលាយមួយ នឹងតែងតាំងទំនាក់ទំនងនៃការរស់នៅក្នុងសង្គម ដោយយកសេចក្តីពិត យុត្តិធម៌ សេចក្តីស្រឡាញ់ និងសេរីភាពធ្វើជាគ្រឹះឡើងវិញ គឺថា ទំនាក់ទំនងមនុស្សនិងមនុស្ស ទំនាក់ទំនងប្រជាពលរដ្ឋនិងរដ្ឋអំណាច ទំនាក់ទំនងរដ្ឋនិងរដ្ឋ ហើយនៅទីបញ្ចប់ ទំនាក់ទំនងបុគ្គលម្នាក់និងបុគ្គលម្នាក់ទៀត ទំនាក់ទំនងក្រុមគ្រួសារនិងក្រុមគ្រួសារ ទំនាក់ទំនងអង្គការផ្សេងៗជាមួយនិងរដ្ឋផង ហើយជាមួយសហគមន៍មនុស្សលោកផង ។ ភារកិច្ចនេះល្អប្រសើរហើយ ព្រោះមានគោលដៅធ្វើឲ្យសេចក្តីសុខសាន្តដ៏ពិតប្រាកដគ្រងរាជ្យក្នុងលោកនេះ តាមរបៀបរៀបរយដែលព្រះជាម្ចាស់បានតែងតាំងស្រាប់ ។*

Layout Histor.qxd 2/10/07 10:11 AM Page 237



*លោកអភិបាលក្រុងរ៉ូម ប៉ូល ទី ៦ ជួបលោកអភិបាលអ័រតូដុក ជាប្រធានព្រះសហគមន៍នៅក្រុងកុងស្តង់ទីណូប្ល ឈ្មោះលោក អាថេណាកូរ៉ាស*

## ៤- លោកប៉ូលទី ៦

ក្រុមប្រឹក្សាអភិបាលក្រុងរ៉ូមបោះឆ្នោតជ្រើសរើសលោក**ម៉ុនទីនី** (Montini) នៅថ្ងៃទី ២១ មិថុនា ១៩៦៣ ធ្វើជាអភិបាលក្រុងរ៉ូម បន្តមុខងារពីលោកយ៉ូហាន ទី ២៣ ។ លោកដាក់ឈ្មោះខ្លួនឯងថា « **ប៉ូល ទី ៦** » លោកសម្រេចថា បន្តមហាសន្និបាតតទៅទៀត ។

នៅពេលប្រជុំលើកទីពីរ (ចុងឆ្នាំ ១៩៦៣) អស់លោកអភិបាលរិះគិតអំពីមុខងាររួមរបស់អស់លោក អំពីគ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ និងអំពីសេរីភាពខាងសាសនា ។ លោកអភិបាលក្រុងរ៉ូមប្រកាសគោលលទ្ធិស្ដីអំពីពិធីបុណ្យ និងក្រិត្យស្ដីអំពីទំនាក់ទំនងក្នុងសង្គម ។

នៅខែឧសភា ១៩៦៤ លោកតែងតាំងការិយាល័យមួយសម្រាប់គិតគូរដល់អ្នកកាន់សាសនាផ្សេងៗក្រៅពីគ្រីស្តសាសនា ។

នៅប្រជុំលើកទី ៣ (ចុងឆ្នាំ ១៩៦៤) អស់លោកអភិបាលបោះឆ្នោត និងប្រកាសគោលលទ្ធិស្ដីអំពីព្រះសហគមន៍ «*ពន្លឺបំភ្លឺមនុស្សគ្រប់ជាតិសាសន៍*» អំពីចលនាបង្រួបបង្រួមគ្រីស្តបរិស័ទជាធ្លុងតែមួយ និងអំពីព្រះសហគមន៍នានានៅមជ្ឈិមបូព៌ា ។

នៅប្រជុំលើកទី ៤ (១៩៦៥) អស់លោកប្រកាសអត្ថបទទាំងអស់ដែលអស់លោកបានពិនិត្យមើលកាលពីប្រជុំមុនៗមក ។

នៅថ្ងៃទី ៤ ធ្នូ លោក**ប៉ូល ទី ៦** ជូនពរអ្នកសង្កេតការណ៍ជាតំណាងនិកាយផ្សេងៗ ដែលចូលមករួមក្នុងមហាសន្និបាត ។

នៅថ្ងៃ ៧ ធ្នូ នៅព្រះវិហារសន្តសិលានៅក្រុងរ៉ូម លោក**ប៉ូល ទី ៦** និងលោក**អាថេណាគូរ៉ាស** (Athénagoras) ប្រធានព្រះសហគមន៍ក្រុងកុងស្តង់ទីណូប្ល ដកពាក្យបណ្ដេញគ្នាពីព្រះសហគមន៍របស់ខ្លួន ដែលចាស់បុរាណចែងនៅឆ្នាំ ១០៥៤ ។

នៅថ្ងៃទី ៨ ធ្នូ លោកបិទមហាសន្និបាត ។ គ្រីស្តបរិស័ទមានសង្ឃឹមយ៉ាងខ្លាំងថា ព្រះសហគមន៍នឹងប្រែតាមបំណងរបស់គេ ។

## ៤- មហាសន្និបាតវ៉ាទីកង់ទី ២ បើកផ្លូវថ្មីឲ្យព្រះសហគមន៍

### *ក- ទេវវិជ្ជា និង គម្ពីរ*

*«គោលលទ្ធិស្តីអំពីព្រះជាម្ចាស់សម្តែងព្រះអង្គ»* គូសសង្កត់ថា មានព្រះជាម្ចាស់តែមួយព្រះអង្គគត់ ដែលសម្តែងព្រះអង្គតាំងពីដើមរៀងមក ។ ហេតុនេះហើយ បានជាមិនត្រូវបំបែកព្រះគម្ពីរ ពីព្រះសហគមន៍ដែលបញ្ជូនបន្តព្រះគម្ពីរមក ហើយពីការបកស្រាយអត្ថន័យឲ្យអ្នកជឿតាមកាលៈទេសៈ ។ ព្រះអង្គមិនបានកំណត់នូវសេចក្តីដែលព្រះអង្គសម្តែងម្តងជាស្រេច ដែលចែងជាលាយល័ក្ខអក្សរនៅក្នុងគម្ពីរនោះទេ គឺប្រជាជនរបស់អ្នកជឿរកឃើញសេចក្តីថ្មីជានិច្ចស្របទៅតាមគម្ពីរនោះ ។ ដោយព្រះសហគមន៍កាតូលិកត្រឡប់ទៅរកគម្ពីរវិញ ព្រះសហគមន៍ចាប់អារម្មណ៍នឹងសេចក្តីខ្លះ ដែលខ្លួនបានបំភ្លេចនៅសតវត្សមុនៗ ដោយនៅជាប់ជជែកជំទាស់នឹងគ្រីស្តបរិស័ទអ័រតូដុក និងប្រូតេស្តង់ ។ ឧបមាថា ព្រះសហគមន៍នឹកឡើងវិញថា៖

- *គ្រីស្តបរិស័ទទាំងអស់ជាក្រុមបូជាចារ្យ ។*
- *ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ មិនគ្រាន់តែជាអង្គការដែលមានរបៀបរៀបរយតាមច្បាប់ប៉ុណ្ណោះទេ ។*
- *អភិបាលទាំងអស់រួបរួមគ្នា ក្នុងការណែនាំព្រះសហគមន៍ គឺរួមជាមួយអភិបាលក្រុងរ៉ូម ។*

### *ខ- ការប្រែសម្រួលពិធីបុណ្យឲ្យបានស្របតាមសម័យ*

អស់លោកអភិបាលប្រកាស *«គោលលទ្ធិស្តីអំពីពិធីបុណ្យ»* មុនគេ ទុកជាសញ្ញាសម្គាល់បញ្ជាក់ថា អស់លោកមានបំណងប្រែសម្រួលព្រះសហគមន៍ឲ្យបានស្របតាមសភាពការណ៍បច្ចុប្បន្ន ជាពិសេសអស់លោកអនុញ្ញាតឲ្យគ្រីស្តបរិស័ទប្រើភាសាប្រជាជនមកសូត្រក្នុងពិធីបុណ្យនានា ។ ភាសាជាតិនីមួយៗ ទទួលតម្លៃជាភាសាសក្ការៈ សម្រាប់ថ្វាយបង្គំព្រះអម្ចាស់តែមួយព្រះអង្គ ។ (132)

**(132) គោលលទ្ធិអំពីពិធីបុណ្យ ជំពូក ២ "អំពីគម្រោងការណ៍ដ៏អស្ចារ្យនៃអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធ"**

*ព្រះសហគមន៍យកចិត្តទុកដាក់ឲ្យគ្រីស្តបរិស័ទចូលរួមក្នុងអភិបូជាជាកិច្ចដ៏សក្ការៈយ៉ាងសកម្ម ដោយដឹងខ្លួន និងដោយគោរព ពុំមែនដូចជាទស្សនិកជននៅស្ងៀមដូចមនុស្សគ មិនយល់អត្ថន័យឡើយ ព្រោះថា អគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធលើកតម្កើងគម្រោងការណ៍ដ៏អស្ចារ្យនៃជំនឿរបស់យើង ។ សូមឲ្យគ្រីស្តបរិស័ទយល់អំពីអត្ថន័យនៃគម្រោងការណ៍នេះយ៉ាងច្បាស់តាមគ្រប់ពិធី និងគ្រប់ពាក្យអធិដ្ឋានផ្សេងៗផង ។ សូមយកព្រះបន្ទូលរបស់ព្រះជាម្ចាស់មកអប់រំគ្រីស្តបរិស័ទ និងឲ្យគេទទួលព្រះកាយព្រះអម្ចាស់ជាអាហារ ទាំងអរព្រះគុណព្រះជាម្ចាស់ផង (...) ។ ត្រូវកែសម្រួលក្បួនពិធីអភិបូជា ដើម្បីបង្ហាញឲ្យបានច្បាស់ថា មុខងារពិសេសនៃភាគនីមួយៗ និងទំនាក់ទំនងរវាងភាគទាំងនោះដែលជាប់គ្នា ដើម្បីជួយគ្រីស្តបរិស័ទឲ្យចូលរួមយ៉ាងសកម្មនិងដោយគោរព ។ ហេតុដូច្នេះ ត្រូវកែសម្រួលពិធី ទាំងរក្សាអត្ថន័យមិនឲ្យប្រែប្រួលដែរ ។ ត្រូវលុបបំបាត់អ្វីៗដែលមានចែងពីរដង ឬដែលគេបន្ថែមតៗមកតាមប្រវត្តិសាស្ត្រ ហើយដែលមិនសូវមានប្រយោជន៍ ។ ត្រូវតែងតាំងឡើងវិញនូវពិធីខ្លះដែលបាត់តាមប្រវត្តិសាស្ត្រ ឲ្យស្របតាមក្បួនច្បាប់របស់បុព្វបុរសដ៏វិសុទ្ធ ប្រសិនបើលោកអភិបាលយល់ឃើញថា គួរឲ្យតែងតាំងឡើងវិញ ឬមានការចាំបាច់ ។ ត្រូវបើកសម្បត្តិដ៏ថ្លៃថ្នូរនៃព្រះគម្ពីរឲ្យបានទូលំទូលាយ ដើម្បីឲ្យគ្រីស្តបរិស័ទទទួលអាហារពីតុនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ដូច្នេះ ក្នុងឆ្នាំមួយចំនួន ត្រូវអានភាគសំខាន់ៗនៃព្រះគម្ពីរឲ្យគ្រីស្តបរិស័ទស្តាប់ ។*

Layout Histor.qxd 2/10/07 10:11 AM Page 239

## *ឃ- ទំនាក់ទំនងជាមួយសាសនាដទៃ*

133 លោកអភិបាលលំបាកចុះសម្រុងគ្នាក្នុងការនិពន្ធ *«សេចក្តីប្រកាសអំពីសេរីភាពខាងសាសនា»* ពីព្រោះមានតែអភិបាលមួយចំនួនតូច មានបំណងការពារសិទ្ធិនៃសេចក្តីពិត គឺលោកយល់ឃើញថា មានតែសាសនាកាតូលិកមួយប៉ុណ្ណោះ ជាសាសនាដ៏ពិតប្រាកដ ។ អស់លោកគិតតាមរបៀបបុរាណ គឺដូចលោក**គ្រេគ័រ ទី ១៦** ជាអភិបាលក្រុងរ៉ូម ។ អភិបាលភាគច្រើនមិនស្របតាមយោបល់នេះ ហើយយល់ឃើញថា មនុស្សគ្រប់ៗរូបមានសិទ្ធិសេរីភាពដែលបំបាត់មិនបាន គឺម្នាក់ៗមានសិទ្ធិសេរីភាពអាចទៅកាន់សេចក្តីពិត ដែលខ្លួនទទួលស្គាល់ទៅតាមមនសិការរបស់ខ្លួន ។ មិនត្រូវទាមទារសេរីភាពសម្រាប់គ្រីស្តបរិស័ទកាតូលិកនៅស្រុកណាមានគ្នាតិច ឬនៅពេលរដ្ឋអំណាចបៀតបៀនធ្វើបាបគេប៉ុណ្ណោះទេ គឺត្រូវទាមទារសេរីភាពសម្រាប់មនុស្សទាំងអស់ ។ អ្នកមិនកាន់សាសនាកាតូលិកដែលរស់នៅក្នុងស្រុកដែលមានកាតូលិកច្រើន ក៏មានសិទ្ធិសេរីភាពខាងសាសនាផងដែរ ។

ក្រិត្យស្តីអំពី *«គ្រីស្តបរិស័ទរួបរួមគ្នាជាផ្លូងតែមួយ»* ជាស់តឿនគ្រីស្តបរិស័ទគ្រប់និកាយឲ្យរិះគិតអំពីសម្បត្តិរួមដ៏ថ្លៃប្រសើរ ពោលគឺព្រះគ្រីស្តនិងដំណឹងល្អ ។ កុំចោទនិកាយឯទៀតៗថា គេបែកចេញពីឯកភាពឡើយ សូមព្រះសហគមន៍កាតូលិកទទួលសារភាពកំហុសរបស់ខ្លួនតាមប្រវត្តិសាស្ត្រ ដែលនាំឲ្យគ្រីស្តបរិស័ទបាក់បែកគ្នា ។

134 សេចក្តីប្រកាសអំពី *«ទំនាក់ទំនងព្រះសហគមន៍និងសាសនាដទៃ»* បញ្ចេញគំនិតថ្មីក្នុងព្រះសហគមន៍ ។ អស់លោកអភិបាលយល់ឃើញថា គ្រប់សាសនាទាំងអស់ជាពិសេសសាសនាយូដា និងសាសនាអ៊ីស្លាម សុទ្ធតែបញ្ចេញរស្មីពន្លឺនៃសេចក្តីពិត គឺជួយមនុស្សឲ្យស្គាល់ព្រះជាម្ចាស់ ។ *«ព្រះសហគមន៍នឹកស្តាយដោយគ្រីស្តបរិស័ទខ្លះស្អប់ បៀតបៀន និងជិទាស់គ្រប់បែបយ៉ាង ប្រឆាំងនឹងជាតិសេមទោះជានៅសម័យណាក្តី ឬជាជនណាប្រព្រឹត្តជិទាស់ និងជនជាតិយូដាក្តី»* ។

## ៥- ព្រះសហគមន៍ទាក់ទងជាមួយមនុស្សលោកនាបច្ចុប្បន្នកាល

គោលលទ្ធិ *«ព្រះសហគមន៍ជាពន្លឺបំភ្លឺជាតិសាសន៍ទាំងឡាយ»* ពន្យល់នូវ
គម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ គឺព្រះអង្គត្រាស់ហៅព្រះសហគមន៍ធ្វើ
ជាប្រជារាស្ត្ររបស់ព្រះអង្គឲ្យបានវិសុទ្ធ ។ អភិបាលនិងបូជាចារ្យបំពេញមុខងារ
ពិសេសនៅក្នុងការណែនាំព្រះសហគមន៍ ប៉ុន្តែ គ្មានឋានៈលើគេទេ ។ អស់លោក 135
ពន្យល់អំពីនាងម៉ារី ដោយភ្ជាប់នាងនឹងគម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់
អំពីព្រះសហគមន៍ គឺនាងជាតំណាងព្រះសហគមន៍ ជាគ្រីស្តបរិស័ទមុនគេ ដោយ
នាងជឿលើព្រះជាម្ចាស់មុនគេ និងជាគ្រីស្តបរិស័ទគំរូ ។

គោលលទ្ធិ *«អំណរសប្បាយនិងសេចក្តីសង្ឃឹម»* ជាឯកសារវែងជាងគេ
គឺមហាសន្និបាតជាស់តឿនគ្រីស្តបរិស័ទ ឲ្យមានទំនាក់ទំនងជាមួយមនុស្សលោក 136
ទូទៅ ។ ព្រះសហគមន៍ត្រូវគិតគូរអំពីសភាពការណ៍ពិភពលោក ដែលតែងតែ
ប្រែប្រួលជាលំដាប់ ។ កាលពីសម័យមុន ព្រះសហគមន៍និងមនុស្សលោកទាស់ទែង
គ្នាជាញឹកញាប់ មនុស្សខ្លះក៏វង្វេងឆ្ងាយពីព្រះជាម្ចាស់ មកពីព្រះសហគមន៍មិន
បានរិះគិតអំពីមនុស្សលោកប្រែប្រួលទេ ។ ព្រះសហគមន៍ហាក់ដូចជារករបៀប
រិះគិតថ្មី អំពីទំនាក់ទំនងជាមួយមនុស្សលោក គឺព្រះសហគមន៍នៅក្នុងមនុស្ស
លោកតែម្តង ។ ត្រូវរិះគិតអំពីលទ្ធិរបស់មនុស្សដែលប្រកាន់ថា គ្មានព្រះជាម្ចាស់
សោះ ដោយខិតខំស្វែងរកមូលហេតុ ដែលនាំឲ្យពួកគេប្រកាន់ដូច្នេះ ។ ឯកសារ
នេះ មហាសន្និបាតក៏រិះគិតយ៉ាងល្អិតល្អន់អំពីបញ្ហាខ្លះ មានអាពាហ៍ពិពាហ៍ ក្រុម
គ្រួសារ វប្បធម៌ សេដ្ឋកិច្ច នយោបាយសង្គម និងការកសាងសន្តិភាពជាដើម ។
គ្រីស្តបរិស័ទត្រូវយល់ឃើញថា ព្រះសហគមន៍គឺខ្លួនគេតែម្តង មានភារៈកិច្ចបំរើ
មនុស្សលោកទូទៅឲ្យបានសេចក្តីសុខតាមព្រះទ័យព្រះជាម្ចាស់ ។

នៅឆ្នាំ ១៩៦៥ លោក**ប៉ូល ទី ៦** បង្កើតការិយាល័យសម្រាប់ទាក់ទងជាមួយមនុស្សដែលមិនជឿ ដើម្បីរិះគិតសេចក្តីទាំងនោះតទៅទៀត ។

Layout Histor.qxd 2/10/07 10:11 AM Page 240

133

## សេចក្តីប្រកាសអំពីសេរីភាពខាងសាសនា

(...) មហាសន្និបាតវ៉ាទីកង់ប្រកាសថា មនុស្សម្នាក់ៗមានសិទ្ធិសេរីភាពខាងសាសនា ។ សិទ្ធិសេរីភាពនេះមានន័យថា មនុស្សគ្រប់ៗរូបត្រូវរួចផុតពីការបង្ខិតបង្ខំពីសំណាក់បុគ្គល ឬពីក្រុមណាមួយក្នុងសង្គម ឬពីអំណាចមនុស្សណាក្តី កុំឲ្យនរណាម្នាក់ត្រូវគេបង្ខំខាងជំនឿសាសនា ឲ្យប្រព្រឹត្តខុសនឹងមនសិការរបស់ខ្លួន ឬត្រូវគេឃាត់មិនឲ្យប្រព្រឹត្តតាម មនសិការរបស់ខ្លួនទាំងឯកជនក្តី សាធារណៈក្តី ម្នាក់ឯងក្តី រួមជាមួយអ្នកផ្សេងទៀតក្តី ។ មហាសន្និបាតប្រកាសទៀតថា តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់បានសម្តែងឲ្យស្គាល់ផង និងតាមប្រាជ្ញារបស់មនុស្សផ្ទាល់ផង កិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សជាគ្រឹះនៃសិទ្ធិសេរីភាពខាងសាសនានេះ ។ ត្រូវទទួលស្គាល់សិទ្ធិមនុស្សឲ្យមានសេរីភាពខាងសាសនាតាមផ្លូវច្បាប់នៃសង្គមឲ្យបានច្បាស់ ធ្វើជាសិទ្ធិសេរីភាពតាមច្បាប់ប្រជាពលរដ្ឋ ។

134

## សេចក្តីប្រកាសអំពីទំនាក់ទំនងព្រះសហគមន៍និងសាសនាដទៃ

(...) ប្រជាជាតិទាំងអស់ចូលរួមជាសហគមន៍តែមួយ ។ ប្រជាជាតិទាំងអស់មានប្រភពតែមួយ ព្រោះព្រះជាម្ចាស់បានប្រោសប្រទានឲ្យមនុស្សរស់នៅពាសពេញលើផែនដី ។ ជីវិតមនុស្សគ្រប់ៗរូបក៏មានទីដៅតែមួយដែរ គឺរួមរស់ជាមួយព្រះជាម្ចាស់ ដែលទ្រង់មានព្រះហឫទ័យមេត្តាករុណា សប្បុរស ថែរក្សាមនុស្សទាំងអស់ ព្រះអង្គក៏មានគម្រោងការណ៍សង្គ្រោះមនុស្សទាំងអស់ដែរ រហូតដល់ពេលមនុស្សទាំងអស់ដែលទ្រង់បានជ្រើសរើស បានរួមគ្នានៅក្នុងបុរីរបស់ព្រះអង្គ គឺនៅពេលសិរីរុងរឿងរបស់ព្រះអង្គនឹងបំភ្លឺបុរីនោះ ហើយប្រជាជនទាំងអស់នឹងដើរក្រោមពន្លឺបុរីនោះផង ។

មនុស្សទាំងប៉ុន្មានទន្ទឹងរង់ចាំឲ្យសាសនានីមួយៗជួយដោះស្រាយប្រស្នាដ៏លាក់កំបាំងនៃវាសនារបស់ខ្លួន គឺតាំងតែពីសម័យមុនៗមក ក៏ដូចក្នុងសម័យបច្ចុប្បន្ននេះដែរ មនុស្សផងទាំងពួងបេះតែបារម្ភក្នុងចិត្ត និងសួរខ្លួនឯងថា តើមនុស្សយើងជាអ្វី? តើជីវិតមនុស្សយើងមានអត្ថន័យយ៉ាងណា? តើជីវិតមានទិសដៅទៅណា? តើឯណាបុណ្យ ឯណាបាប? ទុក្ខវេទនាកើតពីប្រភពណាមក ហើយមានមូលហេតុយ៉ាងណា? តើផ្លូវណានាំមនុស្សយើងឲ្យបានសុភមង្គលដ៏ពិតប្រាកដ? តើអ្វីទៅសេចក្តីស្លាប់? ក្រោយពីស្លាប់ តើមានការកាត់ក្តីដាក់ទោស ឬទទួលរង្វាន់ តើមានស្ថាននរក ស្ថានសួគ៌ ឬយ៉ាងណា? តើមនុស្សយើងកើតពីណា ហើយទៅណា? តើនរណាអាចដោះស្រាយការអាថ៌កំបាំងដ៏អស្ចារ្យនៃជីវិតមនុស្សយើងបាន? (...)

ព្រះសហគមន៍កាតូលិកមិនទាត់ចោលអ្វីៗដ៏ពិតប្រាកដ និងអ្វីៗដ៏វិសុទ្ធដែលស្ថិតនៅក្នុងសាសនាទាំងអស់ទេ ។

135

## គោលលទ្ធិព្រះសហគមន៍ជាពន្លឺបំភ្លឺជាតិសាសន៍ទាំងឡាយ

(...) ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យឲ្យមនុស្សទៅជាវិសុទ្ធ និងទទួលការសង្គ្រោះដោយឡែកពីគ្នា ដោយគ្មានចំណងទាក់ទងគ្នាទៅវិញទៅមកទេ ។ ផ្ទុយទៅវិញ ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទៅជាប្រជាជនមួយ ដែលស្គាល់ព្រះអង្គតាមសេចក្តីពិត និងបម្រើព្រះអង្គដោយរស់នៅយ៉ាងវិសុទ្ធ (...) ។ ព្រះគ្រីស្តក៏ត្រាស់ហៅមហាជនពីចំណោមជនជាតិយូដា និងសាសន៍ដទៃ ដើម្បីឲ្យរួមគ្នាជាធ្លុងតែមួយ មិនមែនតាមរបៀបលោកិយទេ គឺតាមរបៀបព្រះវិញ្ញាណវិញ និងដើម្បីឲ្យគេក្លាយទៅជាប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់ ។ អស់អ្នក

●●●

Layout Histor.qxd 2/10/07 10:11 AM Page 241

ដែលជឿលើព្រះគ្រីស្ដ ហើយកើតជាថ្មី ពុំមែនដោយពូជមនុស្សដែលតែងតែរលួយ គឺកើតជាថ្មីដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅវិញ ជាពូជដែលមិនចេះរលួយ ។ នៅទីបញ្ចប់ អ្នកទាំងនោះក៏ទៅជា «ពូជសាសន៍ដែលព្រះអង្គបានជ្រើសរើសជាក្រុមបូជាចារ្យពូជស្ដេច ជាជាតិដ៏វិសុទ្ធ ជាប្រជារាស្ដ្រ ដែលព្រះជាម្ចាស់យកធ្វើជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ ។ ពីមុន បងប្អូនមិនមែនជាប្រជារាស្ដ្រទេ តែឥឡូវនេះបងប្អូនជាប្រជារាស្ដ្ររបស់ព្រះជាម្ចាស់ហើយ» (...) ។

ទោះបីមនុស្សលោកទាំងអស់មិនចូលរួមយ៉ាងពិតប្រាកដក្នុងប្រជារាស្ដ្ររបស់ព្រះគ្រីស្ដក្ដី ទោះបីជាព្រះសហគមន៍មានរូបរាងជាក្រុមមួយដ៏តូចក្ដី ក៏ប៉ុន្ដែ ប្រជារាស្ដ្រនេះជាពូជមួយយ៉ាងមាំ ធ្វើឲ្យមនុស្សទាំងអស់រួបរួមគ្នាជាធ្លុងតែមួយ នាំឲ្យគេមានសេចក្ដីសង្ឃឹម និងទទួលការសង្គ្រោះ ។ ព្រះគ្រីស្ដតែងតាំងប្រជារាស្ដ្រនេះ ដើម្បីឲ្យគេទទួលព្រះជន្មរបស់ព្រះអង្គ ទទួលព្រះហឫទ័យស្រឡាញ់និងសេចក្ដីពិតពីព្រះអង្គ ។ ព្រះអង្គក៏ប្រើប្រជារាស្ដ្រនេះ ដើម្បីលោះមនុស្សលោកទាំងអស់ ព្រះអង្គក៏ចាត់គេឲ្យទៅកាន់មនុស្សលោកទាំងអស់ ទុកជាពន្លឺបំភ្លឺមនុស្សលោក និងជាអំបិលសម្រាប់ផែនដី (...) ។

ព្រះជាម្ចាស់ចាត់ចែងឲ្យព្រះសហគមន៍លាតត្រដាងក្នុងពិភពលោកទាំងមូល ។ ទោះបីព្រះសហគមន៍ដ៏វិសុទ្ធ ប្លែកពីមនុស្សលោក និងមិនជាប់ប្រពៃណីណាមួយ ឬសម័យកាលណាមួយក្ដី ក៏ព្រះសហគមន៍ចូលក្នុងប្រវត្តិសាស្ដ្ររបស់មនុស្សលោកដែរ ។ ព្រះសហគមន៍ធ្វើដំណើរទាំងជួបការល្បួងនិងទុក្ខវេទនា តែព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ គាំទ្រព្រះសហគមន៍ដែរ ។ ព្រះអម្ចាស់មានព្រះបន្ទូលសន្យាថា ទោះបីព្រះសហគមន៍មានសុទ្ធតែជាមនុស្សទន់ខ្សោយក្ដី ក៏ព្រះសហគមន៍មានឋានៈជាព្រះមហេសីរបស់ព្រះអម្ចាស់ដែរ និងបានពេញលក្ខណៈដោយសេចក្ដីស្មោះត្រង់ ព្រះវិញ្ញាណដ៏វិសុទ្ធក៏ប្រោសព្រះសហគមន៍ឲ្យប្រែជាថ្មីជានិច្ច រហូតទៅដល់ពន្លឺដែលមិនចេះលិច ដោយឆ្លងកាត់តាមឈើឆ្កាងផង ។

## 136 គោលលទ្ធិព្រះសហគមន៍ អំពីទំនាក់ទំនងជាមួយមនុស្សលោកនាបច្ចុប្បន្ន

មនុស្សសម័យឥឡូវនេះ ជាពិសេសជនក្រីក្រកំសត់ទុគ៌តដែលរងទុក្ខវេទនា មានអំណរសប្បាយ សេចក្ដីសង្ឃឹម ព្រមទាំងមានទុក្ខព្រួយ កង្វល់ និងបារម្ភយ៉ាងណា សាវ័ករបស់ព្រះគ្រីស្ដក៏មានអំណរសប្បាយ មានសេចក្ដីសង្ឃឹម កង្វល់និងបារម្ភយ៉ាងនោះដែរ ។ អ្វីៗទាំងប៉ុន្មានដែលទាក់ទិនយ៉ាងពិតប្រាកដជាមួយនឹងមនុស្សជាតិ ក៏សាវ័ករបស់ព្រះគ្រីស្ដចាប់អារម្មណ៍ទាំងអស់ដែរ (...) ។

មហាសន្និបាតគោរពយ៉ាងខ្លាំងនូវអ្វីៗដ៏ពិតប្រាកដ ដ៏ល្អត្រឹមត្រូវក្នុងរចនាសម្ពន្ធផ្សេងៗដែលមនុស្សបានបង្កើតមក និងបង្កើតតទៅទៀត ។ មហាសន្និបាតប្រកាសថា ព្រះសហគមន៍មានបំណងជួយនឹងពង្រឹងរចនាសម្ពន្ធទាំងនោះ តាមតែខ្លួនអាចធ្វើបាន ទាល់តែស្របតាមបេសកកម្មរបស់ខ្លួន (...) ។

មហាសន្និបាតដាស់តឿនគ្រីស្ដបរិស័ទជាប្រជាពលរដ្ឋនៃបុរីទាំងពីរ ឲ្យយកចិត្តទុកដាក់ខ្នះខ្នែងបំពេញការងាររបស់ខ្លួននៅលើផែនដីនេះដោយចិត្តឧស្សាហ៍ និងដោយចិត្តស្មោះទាំងបណ្ដោយខ្លួនតាមគោលជំហរនៃដំណឹងល្អ ។ យើងដឹងថា យើងមិនមានទីក្រុងដ៏ស្ថិតស្ថេររហូតនៅលើលោកនេះទេ គឺយើងធ្វើដំណើរទៅកាន់ទីក្រុងនៃអនាគត ។ អ្នកដែលស្មានថា ដោយមូលហេតុនោះ គេមិនបាច់ប្រព្រឹត្តកិច្ចការរបស់ខ្លួន ក្នុងឋានៈជាមនុស្ស គឺពិតជាវង្វេងគំនិតហើយ ពីព្រោះគេមិនយល់ថាជំនឿជំរុញគេឲ្យបំពេញភារកិច្ចនោះយ៉ាងសកម្ម ស្របតាមព្រះជាម្ចាស់ត្រាស់ហៅឲ្យបំពេញនោះ ។ ផ្ទុយទៅវិញ អស់អ្នកដែលស្មានថា គេអាចបណ្ដោយខ្លួនទាំងស្រុង ឲ្យបំពេញសកម្មភាពក្នុងលោកនេះ ហាក់បីដូចជាសកម្មភាពរបស់គេគ្មានទំនាក់ទំនងនឹងជីវិតខាងសាសនាសោះក៏វង្វេងដែរ ។ គេស្មានថា សាសនាគ្រាន់តែអាស្រ័យលើពិធីបុណ្យនិងវិន័យសីលធម៌ប៉ុណ្ណោះ មនុស្សជាច្រើនបំបែកជំនឿដែលគេកាន់នោះដាច់ពីកិរិយាមារយាទជារៀងរាល់ថ្ងៃ ។ ត្រូវរាប់បញ្ចូលការបំបែកជំនឿពីកិរិយានេះក្នុងចំណោមការវង្វេងដ៏ធ្ងន់ជាងគេនាសម័យបច្ចុប្បន្ន ។

Layout Histor.qxd 2/10/07 10:11 AM Page 242

## ៦- សម័យថ្មីកើតឡើង

គ្រីស្តបរិស័ទជាច្រើនស្មានថា ព្រះសហគមន៍ទាំងស្រុងនឹងចាប់ផ្តើមរស់នៅតាមរបៀបថ្មីភ្លាម គឺព្រះសហគមន៍ផុតពីសម័យតឹងរ៉ឹងនៃមហាសន្និបាតត្រេនតូហើយ ។ មហាសន្និបាតវ៉ាទីកង់ទី ២ នាំឲ្យគ្រីស្តបរិស័ទមានសិទ្ធិសេរីភាពក្នុងការរិះគិតមែន ប៉ុន្តែសេដ្ឋកិច្ចជឿនលឿនយ៉ាងខ្លាំង អរិយធម៌ក៏ប្រែប្រួលយ៉ាងលឿនដែរ ។ ដូច្នេះ ព្រះសហគមន៍លំបាកបំពេញតាមសេចក្តីរង់ចាំរបស់គ្រីស្តបរិស័ទ ។ គ្រីស្តបរិស័ទខ្លះគិតថា សូម្បីតែមហាសន្និបាតវ៉ាទីកង់ទី ២ ក៏ហួសសម័យហើយ ។

## ៧- លទ្ធផលនៃមហាសន្និបាតវ៉ាទីកង់ទី ២

អស់លោកអភិបាលតែងតាំងស្ថាប័នតាមសំណូមពររបស់មហាសន្និបាត គឺបង្កើតក្រុមអភិបាលតាមប្រទេស ជាសញ្ញាសម្គាល់បញ្ជាក់ថា អស់លោកទទួលភារកិច្ចរួមក្នុងការណែនាំព្រះសហគមន៍ ។ នៅឆ្នាំ ១៩៦៧ លោក**ប៉ូល ទី ៦** បើកសន្និបាតអភិបាលនៅក្រុងរ៉ូម ដើម្បីជួយលោកក្នុងការណែនាំព្រះសហគមន៍ទាំងមូល ។ អភិបាល ១៩៧ នាក់ ជួបជុំគ្នាក្នុងសន្និបាតនេះ គឺអភិបាលពីរភាគបីក្នុងចំនួននោះ ត្រូវក្រុមអភិបាលតាមប្រទេសនានាបោះឆ្នោតជ្រើសរើស ។ ក្នុងភូមិភាគនីមួយៗ ក្រុមប្រឹក្សាបូជាចារ្យក៏កើតឡើងដែរ ដោយជួបការលំបាកបន្តិច ។ បព្វជិតបព្វជិតាកែសម្រួលធម្មនុញ្ញក្រុមគ្រួសាររបស់ខ្លួន តាម «*ក្រឹត្យស្តីអំពីការប្រែសម្រួល ការរស់នៅជាបព្វជិតតាមសម័យ*» ។

អស់លោកក៏កែសម្រួលពិធីបុណ្យតាម «*គោលលទ្ធិអំពីពិធីបុណ្យ*» គឺគ្រីស្តបរិស័ទអាចប្រើភាសាជាតិក្នុងពិធីនានា អាចទទួលព្រះកាយនិងព្រះលោហិតបានមានចែងពិធីលើកតម្កើងព្រះបន្ទូលឲ្យបានល្អប្រសើរជាងពីមុន បូជាចារ្យរួមគ្នាថ្វាយអភិបូជា ។ល។ ប៉ុន្តែ គ្រីស្តបរិស័ទខ្លះនៅតែអាឡោះអាល័យភាសាឡាតាំងដែលគេបាត់ទុកថា ជាភាសាសក្ការៈតែមួយគត់នោះ ។

## ៨- ព្រះសហគមន៍មានទំនាក់ទំនងជាមួយមនុស្សលោក

លោកអភិបាលក្រុងរ៉ូម **ប៉ូល ទី ៦** ចេញដំណើរក្នុងពិភពលោកជាញឹកញាប់ធ្វើឲ្យទាំងគ្រីស្តបរិស័ទ ទាំងអ្នកកាន់សាសនាដទៃចាប់អារម្មណ៍ជាខ្លាំងគឺ៖

**- ខែមករា ១៩៦៤** លោកធ្វើដំណើរទៅក្រុងយេរូសាឡឹម ដែលជាកន្លែងប្រភពនៃជំនឿ ។ តាំងពីរាប់សតវត្សមក គ្មានអភិបាលក្រុងរ៉ូមណាម្នាក់ ចេញពីប្រទេសអ៊ីតាលីសោះ ។ នៅក្រុងយេរូសាឡឹមនោះ លោកជួបអភិបាលអ័រតូដុកជាប្រធានព្រះសហគមន៍នៅក្រុងកុងស្តង់ទីណូប្ល ឈ្មោះលោក **អាថេណាគូរាស** (Athénagoras) ។ នៅខែធ្នូ ឆ្នាំ ១៩៦៤ ដដែលនោះ លោកធ្វើដំណើរទៅប៊ុំបៃ (Bombay) ប្រទេសឥណ្ឌា គឺចេញពីទ្វីបអឺរ៉ុបជាលើកដំបូង ។

**- ថ្ងៃទី ៤ តុលា ១៩៦៥** លោកទៅទីចាត់ការនៃអង្គការសហប្រជាជាតិហើយថ្លែងសុន្ទរកថាដែលមានឈ្មោះល្បី លោកប្រកាសឃ្លាចុងក្រោយថា «*កុំឲ្យមានសង្គ្រាមទៀតជាដាច់ខាត!*» ។

**- នៅឆ្នាំ ១៩៦៦** លោកជួបនិងអភិបាលអង់គ្លីកង់ នៅទីក្រុងកនទ័របេរី (Canterbury) ។

**- នៅឆ្នាំ ១៩៦៨** លោកធ្វើដំណើរទៅទ្វីបអាមេរិកឡាទីន និងទៅទីក្រុងហ្សឺណែវ (Genève) រួចទៅទ្វីបអាហ្វ្រិក (១៩៦៩) និងទៅទ្វីបអាស៊ី (១៩៧0) ។ លោកហៅអភិបាលមកពីគ្រប់ប្រទេសចូលមកកាន់កាប់ក្រសួងនានានៅក្រុងរ៉ូម ។



- **នៅឆ្នាំ ១៩៦៧** លោកសរសេរលិខិត «*ប្រជាជាតិចម្រើនឡើង*»(Populorum Progressio) ។ លោកបញ្ជាក់ថា «*សភាពការណ៍ដ៏លំបាកក្នុងសង្គមបោទឡើងក្នុងពិភពលោកទាំងមូល*» ។ ប្រទេសត្រូវជឿនលឿនទៅមុខសម្រាប់មនុស្សជឿនលឿនទាំងអស់ គឺជឿនលឿនក្នុងគ្រប់វិស័យ មានវិស័យសេដ្ឋកិច្ចវិស័យវប្បធម៌ វិស័យជីវិតខាងវិញ្ញាណជាដើម ។ ហេតុដូចនេះ ត្រូវមានច្បាប់ការពារទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ដើម្បីការពារប្រទេសដែលទន់ខ្សោយ

កុំឲ្យបាញ់ប្រទេសអ្នកមាន ដែលធ្លាប់ធ្វើពាណិជ្ជកម្មដោយអយុត្តិធម៌ ។ សារលិខិតនេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើក្រុមអភិបាលតាមប្រទេសនានា ។ គ្រីស្តបរិស័ទទ្វីបខាងជើងចាប់ផ្តើមរិះគន់សង្គមរបស់ខ្លួន ដែលប្រើប្រាស់ទ្រព្យសម្បត្តិជាច្រើន ដោយរឹបអូសធនធានពីសកលលោកទាំងមូល ។

## ៨- សារលិខិតអំពីជីវិតមនុស្ស (១៩៦៨) (Humani Generis)

មហាសន្និបាតមិនបានរិះគិតអំពីការពន្យាកំណើតកូនទេ ។ អភិបាលក្រុងរ៉ូមទុកសេចក្តីនេះឲ្យលោកផ្ទាល់សម្រេច ។ លោកផ្ញើឲ្យគណៈកម្មាធិការមួយរិះគិតអំពីបញ្ហានេះ ។ ពួកគេសុខចិត្តកែប្រែគោលជំហរខ្លះៗ ដែលជាប្រពៃណីក្នុងព្រះសហគមន៍តាំងពីដើមរៀងមក ។ តែលោកមិនយល់ស្របតាមគណៈកម្មាធិការនេះ ហើយសរសេរសារលិខិតមួយក្រោមចំណងជើងថា «*ជីវិតមនុស្ស*» ដែលមិនអនុញ្ញាតឲ្យគ្រីស្តបរិស័ទប្រើវិធីមួយណាផ្សេង ក្រៅពីវិធីតាមធម្មជាតិដើម្បីពន្យាកំណើតកូន ។ ទាំងគ្រីស្តបរិស័ទ ទាំងអ្នកកាន់សាសនាដទៃទៀតរស់នៅតាមប្រទេសជឿនលឿន មិនសូវសប្បាយចិត្តនឹងលិខិតនេះទេ ។ គេយល់ឃើញថា ពេលណាមានបញ្ហាពិសេស (*ការតែងតាំងអ្នកមានគ្រួសារឲ្យទៅបូជាចារ្យ ការអនុញ្ញាតឲ្យអ្នកលះលែងគ្រួសាររៀបអាពាហ៍ពិពាហ៍ជាថ្មី ។ល។*) អភិបាលក្រុងរ៉ូមសម្រេចដោយខ្លួនលោកផ្ទាល់ គឺខុសនឹងមហាសន្និបាតដែលថែងថា អស់លោកអភិបាលរួមគ្នាក្នុងការណែនាំព្រះសហគមន៍ទាំងមូល ។ ម៉្យាងគេចោទថា លោកយកវិជ្ជាជីវៈមករិះគិត តែមិនសំអាងលើបុគ្គលដែលទទួលការខុសត្រូវនៅក្នុងការសម្រេចពន្យាកំណើតកូននោះទេ ។ មនុស្សតែងធ្វើជាម្ចាស់លើធម្មជាតិក្នុងបញ្ហាជាច្រើន (*គ្រោះកាចធម្មជាតិ ជំងឺ សេចក្តីស្លាប់*) ចុះហេតុអ្វីបានជាអំពីការពន្យាកំណើតកូន មនុស្សប្រើវិទ្យាសាស្ត្រមិនបាន? ចាប់តាំងពីពេលនោះមក មនុស្សជាច្រើន ទាំងគ្រីស្តបរិស័ទ ទាំងអ្នកកាន់សាសនាដទៃ លែងទុកចិត្តអភិបាលក្រុងរ៉ូមទៀតហើយ ។

137

### លោកប៉ូលទី ៦ “ប្រជាជាតិចម្រើនឡើង” *(២៦ មេសា ១៩៦៧)*

*សព្វថ្ងៃ យើងត្រូវភ្ញាក់ស្មារតីថា សភាពការណ៍ដ៏លំបាកក្នុងសង្គមបោទឡើងក្នុងពិភពលោកទាំងមូល (...) ។*

*មានសភាពការណ៍អយុត្តិធម៌ខ្លាំងពេក «ស្រែកទៅដល់ព្រះជាម្ចាស់» ។ ប្រជាជនខ្លះគ្មានអ្វីដែលមនុស្សត្រូវការចាំបាច់ គឺរស់នៅរណបប្រជាជនផ្សេងទៀត មិនអាចធ្វើអ្វីដោយខ្លួនឯងបាន និងមិនអាចទទួលខុសត្រូវលើខ្លួនដោយខ្លួនឯងបានឡើយ (...) ។ ពេលនោះ មនុស្សមានការល្បួងនិងប្រើហិង្សា ដើម្បីបំបាត់អ្វីៗដែលជំទាស់នឹងកិត្តិយសរបស់មនុស្ស (...) ។*

*ការជឿនលឿនបែបនេះ មិនគ្រាន់តែជាការជឿនលឿនតាមសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺត្រូវធ្វើឲ្យមនុស្សទាំងស្រុងជឿនលឿនទៅមុខដោយត្រឹមត្រូវ គឺត្រូវឲ្យអ្វីៗទាំងអស់ដែលមានក្នុងមនុស្ស និងធ្វើឲ្យមនុស្សទាំងអស់ជឿនលឿនដែរ (...) ។ ត្រូវតែកសាងពិភពលោកមួយដែលមិនប្រកាន់ជាតិ មិនប្រកាន់សាសនា សញ្ជាតិ គឺមនុស្សអាចរស់នៅក្នុងឋានៈជាមនុស្សដ៏ពេញលេញ ដោយរួចផុតពីធ្វើទាសកររបស់មនុស្សផ្សេងទៀត ឬជាទាសករនៃធម្មជាតិ ដោយមិនទាន់ម្ចាស់ការនៅឡើយទេ (...) ។ ប្រសិនបើការអភិវឌ្ឍន៍ជាឈ្មោះថ្មីរបស់សេចក្តីសុខសាន្តនោះគ្រប់គ្នាត្រូវតែយល់ព្រមអភិវឌ្ឍន៍ដោយអស់សមត្ថភាព ។*

Layout Histor.qxd 2/10/07 10:11 AM Page 244

## ៩- ទេវវិជ្ជាអំពីការរំដោះមនុស្ស

138 នៅខែតុលា ឆ្នាំ ១៩៦៨ លោក**ប៉ូលទី ៦**ទៅប្រទេសកូឡុំប៊ី លោកប្រកាស
ថា«*មានតែវឌ្ឍនភាពទេ ដែលអាចបង្កើតសន្តិភាពបាន*» ។ លោកមិនយល់ស្រប
139 នឹងចលនារំដោះទាំងប៉ុន្មាន ដែលប្រើហិង្សាដើម្បីទាមទារយុត្តិធម៌ឲ្យអ្នកក្រីក្រ
140 ទេ ។ ប៉ុន្តែ គ្រីស្តបរិស័ទជាច្រើន ជាពិសេសបូជាចារ្យយល់ឃើញថា វឌ្ឍនភាព
ជួយតែពួកនាយទុនមូលធននិយមប៉ុណ្ណោះ ព្រោះពួកគេមានសហគ្រាសក្នុងពិភពលោកទាំងមូល និងមានទីបាត់ការនៅសហរដ្ឋអាមេរិក ។ ពួកមូលធននោះបេះតែគាំទ្ររបបយោធានិយម ដែលកៀបសង្កត់ប្រជាជននៅអាមេរិកខាងត្បូង ។ គេបោទថា ព្រះសហគមន៍មិនព្រមកែប្រែអ្វីសោះ ហើយសេពគប់ជាមួយពួកមូលធននិយមទាំងនោះ ។ ទេវវិទូខ្លះយល់ឃើញថា គ្រីស្តបរិស័ទត្រូវតែចូលរួមប្រយុទ្ធដើម្បីទាមទារយុត្តិធម៌សម្រាប់អ្នកក្រជាងគេ ។ បូជាចារ្យខ្លះស្លាប់នៅសមរភូមិ មានលោក**សេកេវ៉ារ៉ា** ជាដើម (Che Guévara) ។

ពួកប្រពៃណីនិយមបោទថា មហាសន្និបាតវ៉ាទីកង់ទី ២ បានបង្កើតបញ្ហាទាំងនោះ ។ លោក**ប៉ូលទី ៦** ព្រួយចិត្តជាខ្លាំង ដោយយល់ឃើញថា គ្រីស្តបរិស័ទក្នុងព្រះសហគមន៍ទាស់ទែងគ្នា ។

## ១០- សេចក្តីសង្ឃឹម

លោកអភិបាលដែលប្រជុំគ្នាក្នុងមហាសន្និបាតវ៉ាទីកង់ទីពីរ ស្មានថា អស់លោកប្រែសម្រួលទ្រង់ទ្រាយព្រះសហគមន៍ឲ្យមនុស្សលោកបច្ចុប្បន្នពេញចិត្តតែតាមពិតនៅទ្វីបអឺរ៉ុប មនុស្សកាន់តែច្រើនឡើងៗបែរខ្នងដាក់ព្រះសហគមន៍ទៅវិញ ។ អ្នកស្រាវជ្រាវខ្លះពន្យល់ថា ព្រះសហគមន៍មិនបានយល់ឲ្យទាន់ពេលថា សង្គមថ្មីកើតឡើងជាយូរមកហើយ ហើយសង្គមនោះមិនរវីរវល់នឹងព្រះសហគមន៍ទៀតទេ ។ តែផ្ទុយទៅវិញ អ្នកខ្លះពន្យល់ថា ព្រះសហគមន៍អន់ថយដូច្នេះ មកពីមហាសន្និបាតវ៉ាទីកង់ទី ២ បណ្តោយឲ្យមនុស្សមានសេរីភាពខ្លាំងពេក ។

ត្រូវយល់ឃើញថា តាំងពីឆ្នាំ ១៩៦៨ មក គ្រប់សាសនាធំៗ និងក្រុម 141
មនោគមវិជ្ជាសំខាន់ៗ គឺទាំងវិទ្យាសាស្ត្រ ទាំងទស្សនវិជ្ជា ជាពិសេសលទ្ធិម៉ាកឡេនីនក៏អន់ថយដែរ ។ ទាំងនយោបាយ ទាំងព្រះសហគមន៍ ទាំងនិកាយធំៗនានា មិនគាប់ចិត្តមនុស្សទៀតទេ ។ ហេតុនេះហើយ បានជាមនុស្សបែរទៅពេញចិត្តនឹងក្រុមផ្សេងៗដែលមិនពឹងលើប្រាជ្ញា គឺពឹងលើមនោសញ្ចេតនាវិញ ដូចជាគណៈប៉ង់តេកុស្ទីស (Pentecostistes) ជាដើម គឺគេចូលចិត្តការអស្ចារ្យ ការនិយាយភាសាចម្លែក ការព្យាបាលអ្នកជំងឺយ៉ាងអស្ចារ្យ ការទស្សន៍ទាយ ។ល។

---

138

### គ្រីស្តបរិស័ទដែលចូលចិត្តបដិវត្តន៍ (១៩៦៨)

*(...) យើងយល់ឃើញថា មានផ្លូវតែមួយគឺធ្វើបដិវត្តន៍ប៉ុណ្ណោះ មានន័យថា ត្រូវកែប្រែរចនាសម្ពន្ធសេដ្ឋកិច្ចនិងនយោបាយ ។ ប៉ុន្តែ ត្រូវមានបដិវត្តន៍វប្បធម៌ជាមុនសិន ទើបអាចមានបដិវត្តន៍សេដ្ឋកិច្ចខាងក្រោយបាន ។*

*(...) បដិវត្តន៍នេះ នឹងជំទាស់ប្រឆាំងនឹងរបៀបគ្រីស្តសាសនាធ្លាប់រិះគិត ធ្លាប់និយាយ និងធ្លាប់បំពេញសកម្មភាពតាំងពីដើមរៀងមក ។ យើងជឿជាក់ថា យើងត្រូវយកចិត្តទុកដាក់ចូលក្នុងការតស៊ូវណ្ណៈរបស់មនុស្សជាច្រើនក្នុងពិភពលោកទាំងមូល ដែលត្រូវគេជិះជាន់ ដើម្បីជួយរំដោះគេ ។ ការតស៊ូបដិវត្តន៍ចូលក្នុងគោលដៅនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ តែខុសពីព្រះរាជ្យនោះ ។ យើងទទួលស្គាល់ថា គ្រីស្តបរិស័ទគ្រប់រូបក៏ដូចមនុស្សឯទៀតទាំងអស់ មានសិទ្ធិសេរីភាពចូលរួមនៅក្នុងដំណើរនៃបដិវត្តន៍នេះ សូម្បីតែការតយុទ្ធដោយអាវុធក៏គេមានសិទ្ធិសេរីភាពចូលរួមដែរ ។*

*(អង្គការគ្រីស្តបរិស័ទបារាំងមួយចំនួន ២៤ មេសា ១៩៦៨)*

## (139) លោកប៉ូល ទី ៦ មានប្រសាសន៍ទៅកសិករជាតិកូឡុំប៊ី *(២០ សីហា ១៩៦៨)*

*យើងនៅតែបោទប្រកាន់ទោសអំពីអយុត្តិធម៌ខាងសេដ្ឋកិច្ច អំពីរដ្ឋអំណាចជិះជាន់អ្នកក្រដោយឥតអើពើ ធ្វើបាបបងប្អូន ប្រជាជនទាំងមូល ។ យើងនៅតែជួយសេចក្តីសម្រេច និងកម្មវិធីសម្រាប់ជួយប្រជាជនដែលកំពុងជឿនលឿន (...) ។*

*យើងដាស់តឿនបងប្អូន កុំពឹងផ្អែកលើហឹង្សា និងលើបដិវត្តន៍ ដែលផ្ទុយនឹងគំនិតជាគ្រីស្តបរិស័ទ ។ ហិង្សានិងបដិវត្តន៍ មុខជានឹងពន្យាការចម្រើនក្នុងសង្គម ដែលបងប្អូនសង្វាតចង់បាននោះ ។*

## (140) ឯកសារបញ្ចប់ការប្រជុំក្រុមអភិបាលកូឡុំប៊ី *(ខែកញ្ញា ១៩៦៨)*

*យើងចូលក្នុងសម័យថ្មីនៃប្រវត្តិសាស្ត្រទ្វីបរបស់យើង គឺជាសម័យមនុស្សចង់បានសេរីភាពទាំងស្រុង ចង់រំដោះខ្លួនពីអ្វីៗដែលធ្វើឲ្យជាប់ជាទាសករ ចង់ឲ្យខ្លួនទៅជាមនុស្សពេញវ័យ និងចូលរួមក្នុងសង្គមគ្រប់ៗគ្នា (...) ។ កាលពីដើមប្រជាជនអ៊ីស្រាអែលជាប្រជាជននៃសម្ពន្ធមេត្រីបាស់យល់ឃើញថា ព្រះជាម្ចាស់គង់នៅជាមួយគេ និងសង្គ្រោះគេ ពេលព្រះអង្គរំដោះគេឲ្យរួចពីធ្វើទាសករនៅប្រទេសអេស៊ីបយ៉ាងណា យើងជាប្រជាជននៃសម្ពន្ធមេត្រីថ្មីក៏ដូច្នេះដែរ គឺយើងដឹងថាព្រះអង្គយាងមកសង្គ្រោះយើង ពេលយើងអភិវឌ្ឍន៍យ៉ាងពិតប្រាកដ ដែលចម្លងយើងម្នាក់ៗ និងមនុស្សទាំងអស់ពីសភាពការណ៍មិនល្អ ឲ្យទៅកាន់សភាពការណ៍ដ៏ប្រសើរ និងឋានៈជាមនុស្ស ។*

## (141) វិបត្តិដែលថ្មីប្លែក

*បើយើងប្រៀបព្រះសហគមន៍សព្វថ្ងៃនិងព្រះសហគមន៍ពីអតីតកាល យើងសង្កេតឃើញថា គ្រីស្តសាសនាជួបវិបត្តិសព្វថ្ងៃ ជាវិបត្តិដែលព្រះសហគមន៍មិនដែលជួបប្រទះតាំងពីដើមរៀងមក ។ ហេតុនេះហើយ បានជាត្រូវខិតខំស្រមៃឃើញនឹងបង្កើតការបាត់បែងព្រះសហគមន៍តាមរបៀបថ្មី អំពីរបៀបកាន់អំណាចនៅក្នុងព្រះសហគមន៍ និងសុខចិត្តឲ្យអំណាចអភិបាលក្រុងរ៉ូមប្រែជាថ្មីទាំងស្រុង ។ ត្រូវបង្កើតមុខងារបម្រើព្រះសហគមន៍ថ្មីៗ និងលើកតម្កើងឋានៈស្ត្រីៗឲ្យបានសមរម្យវិញ ។*

*ខ្ញុំហ៊ានប្រកាសថា សព្វថ្ងៃយើងជាគ្រីស្តបរិស័ទ កុំថាយើងជាសមាជិកនៃព្រះសហគមន៍កាតូលិក ឬប្រូតេស្តង់ ឬខាងអ័រតូដុក ។ល ។ ខ្ញុំយល់ឃើញថា អនាគតនៃគ្រីស្តសាសនាអាស្រ័យលើចលនាបង្រួបបង្រួមគ្រីស្តបរិស័ទគ្រប់និកាយឲ្យបានជោគជ័យ ។ បើនិកាយទាំងអស់មិនរួបរួមគ្នាទេ គ្មាននរណាអាចជឿគ្រីស្តសាសនាទៀតបានឡើយ (...) ។ តាមយោបល់ខ្ញុំត្រូវរំដោះព្រះសហគមន៍នីមួយៗពីនឹមនៃអាណានិគមអភិបាលក្រុងរ៉ូម ឲ្យបានឆាប់រហ័ស ។ ការរំដោះនេះ អាចធ្វើបានដោយទទួលស្គាល់ថា គ្រីស្តបរិស័ទអាចថ្លែងជំនឿតែមួយជាគ្រឹះ តាមរបៀបផ្សេងៗពីគ្នាជាច្រើនអនេក ។*

*យ៉ូហានដឺលីម៉ូ «វិបត្តិដែលថ្មីប្លែក»*
*កាសែត «ពិភពលោក» ថ្ងៃទី ៥ មិថុនា ១៩៧៩*

Layout Histor.qxd 2/10/07 10:11 AM Page 246

## ១១- លោកយ៉ូហានប៉ូលទី ២

លោកប៉ូល ទី ៦ ទទួលមរណភាពនៅថ្ងៃទី ៣ សីហា ១៩៧៨ ។ ក្រុមប្រឹក្សាអភិបាលក្រុងរ៉ូម ជ្រើសរើសលោក**លូស៊ីយ៉ានី** (Luciani) ជាអភិបាលក្រុងវេនីស (Venise) ឲ្យបន្តមុខងារជាអភិបាលក្រុងរ៉ូម ។ លោកដាក់ឈ្មោះខ្លួនឯងថា **យ៉ូហាន-ប៉ូល ទី ១** ដោយសម្តែងបំណងថា លោកចង់បន្តកិច្ចការរបស់លោកទាំងពីរដែលកាន់មុខងារនេះមុនលោក ។ ប៉ុន្តែ លោកទទួលមរណភាពមួយខែក្រោយពីទទួលមុខតំណែងនេះ ។

ក្រុមប្រឹក្សាអភិបាលក្រុងរ៉ូមជ្រើសរើសលោក **ការូល-វ៉ុយទីឡា** (Karol Wojtyla) ជាអភិបាលព្រះសហគមន៍ក្រុងក្រាកូវី (Cracovie) នៅប្រទេសប៉ូឡូញ (Pologne) ឲ្យបន្តមុខងារជាអភិបាលក្រុងរ៉ូម ។ លោកដាក់ឈ្មោះខ្លួនឯងថា
142 **យ៉ូហាន-ប៉ូល ទី ២** ដើម្បីគោរពលោកទាំងបី ដែលបំពេញមុខងារនេះមុនលោក ព្រមទាំងបញ្ជាក់ថា លោកក៏ចង់អនុវត្តតាមមហាសន្និបាតវ៉ាទីកង់ទី ២ ដែរ ។

លោក**យ៉ូហាន-ប៉ូលទី ២** ធ្វើដំណើរក្នុងពិភពលោកទាំងមូលចំនួន ១៧៨ លើក ទៅសួរសុខទុក្ខក្រុមអភិបាល ព្រះសហគមន៍ និងគ្រីស្តបរិស័ទតាមប្រទេសនានា ជាពិសេសទៅជួបយុវជនយុវនារី ។ លោកទាមទារសេរីភាពសម្រាប់
ប្រទេសនានា ដែលស្ថិតនៅក្រោមអំណាចសហភាពសូវៀត ។ ហេតុនេះហើយ 142
បានជានៅថ្ងៃទី ១៣ ឧសភា ១៩៨១ រដ្ឋអំណាចសូវៀតលបធ្វើឃាតលោក ។ ប៉ុន្តែ សហភាពសូវៀតបែកបាក់នៅឆ្នាំ ១៩៨៩ ។

លោកយកចិត្តទុកដាក់ឲ្យព្រះសហគមន៍អនុវត្តតាមមហាសន្និបាតវ៉ាទីកង់ ទី ២ គឺលោកប្រជុំសន្និបាតអភិបាលតាមប្រទេស តាមទ្វីប តាមប្រធានបទមួយ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ក្រសួងក្រុងរ៉ូមនៅតែមានឥទ្ធិពលយ៉ាងខ្លាំងលើអភិបាលនានា ។

លោកយ៉ូហានប៉ូល ទី ២ យកចិត្តទុកដាក់ទាក់ទងជាមួយអ្នកដឹកនាំនិកាយនីមួយៗ តែបញ្ហាកើតឡើង គឺមាននិកាយតូចៗថ្មីៗ មិនសូវវិវរវល់នឹងគោលលទ្ធិ

142 **ធម្មទេសនាដើមដំបូងរបស់លោកយ៉ូហាន–ប៉ូលទី ២** *(២២ តុលា ១៩៧៨)*

*បងប្អូនជាទីស្រឡាញ់! កុំខ្លាចនឹងទទួលព្រះគ្រីស្ត និងទទួលអំណាចរបស់ព្រះអង្គឡើយ! ចូរជួយអភិបាលក្រុងរ៉ូម និងអស់អ្នកដែលមានបំណងចង់បម្រើព្រះគ្រីស្ត ហើយចង់បម្រើមនុស្ស និងពិភពលោកទាំងមូល ដោយទទួលអំណាចនៃព្រះវិញ្ញាណ ។ កុំខ្លាចឡើយ! ចូរបើកទ្វារចំហចាំទទួលព្រះគ្រីស្ត ។ ចូរបើកព្រំដែនរដ្ឋនានាឲ្យប្រទ្ធានុភាពរបស់ព្រះអង្គអាចសង្គ្រោះមនុស្សលោក ។ ចូរបើករចនាសម្ពន្ធសេដ្ឋកិច្ច និងនយោបាយ ចូរបើកផ្លូវវប្បធម៌ អរិយធម៌ ការអភិវឌ្ឍន៍ឲ្យបានទូលំទូលាយ កុំខ្លាចអ្វីឡើយ ។ ព្រះគ្រីស្តដឹងអ្វីៗដែលកប់ទុកក្នុងចិត្តមនុស្ស មានតែព្រះអង្គទេទ្រង់ជ្រាប ។ សព្វថ្ងៃ មនុស្សជាច្រើនមិនដឹងអំពីសេចក្តីដែលមានកប់ទុកក្នុងខ្លួន គឺកប់ក្នុងជម្រៅនៃវិញ្ញាណ និងក្នុងចិត្តគំនិត ។ មនុស្សមិនសូវយល់ដឹងច្បាស់អំពីអត្ថន័យជីវិតរបស់ខ្លួនលើផែនដីនេះទេ ។ គេមានចិត្តសង្ស័យ ហើយក្លាយទៅជាអស់សង្ឃឹម ។ ហេតុនេះហើយ សូមអនុញ្ញាតឲ្យខ្ញុំអង្វរដោយចិត្តសុភាព ដោយសេចក្តីទុកចិត្ត សូមអនុញ្ញាតឲ្យព្រះគ្រីស្តមានព្រះបន្ទូលមកមនុស្សគ្រប់ៗរូប ។ មានតែព្រះអង្គទេ ដែលមានព្រះបន្ទូលផ្តល់ជីវិតអស់កល្បជានិច្ច ។*

Layout Histor.qxd 2/10/07 10:11 AM Page 247

នៃជំនឿទេ ហើយក៏មិនសូវចង់រួបរួមគ្នាដែរ ។ គ្រីស្តបរិស័ទជាច្រើននាំគ្នាយល់ថា និកាយនីមួយៗត្រូវតែរក្សាទុកលក្ខណៈរបស់ខ្លួនផ្ទាល់ និងមានទំនាក់ទំនងជាមួយនិកាយឯទៀត ដោយស្រួលអធិដ្ឋានជាមួយគ្នា ធ្វើការជាមួយគ្នា ទោះបីគេមិនចូលរួមខាងគោលលទ្ធិនៃជំនឿក្តី ។

លោកយ៉ូហានប៉ូល ទី ២ យកចិត្តទុកដាក់ប្រជុំសន្ទនាជាមួយអស់លោកណែនាំសាសនាដទៃ ទាំងពុទ្ធបរិស័ទ ទាំងអ៊ីស្លាមបរិស័ទ ។ នៅឆ្នាំ ១៩៨៦ មានប្រជុំពិសេសនៅក្រុងអាស៊ីស៊ី (Assise) នាប្រទេសអ៊ីតាលី ។ នៅឆ្នាំ ១៩៨៨ លោកបង្កើតក្រុមប្រឹក្សាអន្តរសាសនា និងសរសេរឯកសារជាច្រើនអំពីការសន្ទនាសាសនានិងសាសនា ។

លោកសរសេរសារលិខិតមួយអំពី «*បេសកកម្មរបស់ព្រះសង្គ្រោះ* »(១៩៩០) គឺលោកបញ្ជាក់ថា ព្រះគ្រីស្តជាព្រះសង្គ្រោះតែមួយព្រះអង្គគត់ គឺលោកមិនយល់ស្របនឹងទេវវិទូខ្លះដែលអះអាងថា ព្រះបន្ទូលគង់នៅជាមួយអ្នកបង្កើតសាសនាដ៏ប្រសើរៗ ។ លោកថែងអំពីការប្រកាសដំណឹងល្អសារជាថ្មី គឺថា៖ «*វប្បធម៌ នយោបាយ សីលធម៌ ការរស់នៅតាមវិញ្ញាណតែងតែប្រែប្រួលយ៉ាងខ្លាំងទៅៗ បណ្តាលឲ្យសង្គមទ្វីបអឺរ៉ុបមានទ្រង់ទ្រាយថ្មី ។ ហេតុនេះហើយ ត្រូវតែប្រកាសដំណឹងល្អឲ្យមានគុណភាពថ្មី គឺត្រូវថ្លែងអំពីដំណឹងល្អនៃការសង្គ្រោះដែលមិនចេះសាបសូន្យ សម្រាប់មនុស្សនាបច្ចុប្បន្នកាល ដើម្បីឲ្យគេចាប់ចិត្តនិងជឿបាន*» ។

លោកយ៉ូហាន-ប៉ូល ទី ២ យកចិត្តទុកដាក់នឹងរំឭកសិទ្ធិនិងកិត្តិយសរបស់មនុស្ស គឺដំណឹងល្អត្រូវតែជួយមនុស្សឲ្យបានសេចក្តីសុខសាន្តគ្រប់ជំពូក ។ លោកការពារសិទ្ធិមនុស្ស សិទ្ធិអ្នកក្រីក្រ ដែលត្រូវគោរពទុកជារូបតំណាងរបស់ព្រះជាម្ចាស់ ។ លោកខិតខំកសាងសន្តិភាព សុំឲ្យមហាអំណាចដាក់អាវុធ ជាពិសេសនៅពេលមុនកើតសង្គ្រាមនៅប្រទេសអ៊ីរ៉ាក់ (២០០៣) ។

លោកចេះតែដាស់តឿនគ្រីស្តបរិស័ទឲ្យទៅជាជនដ៏វិសុទ្ធ រួមរស់ជាមួយព្រះយេស៊ូជានិច្ច ។ ហេតុនេះហើយ បានជាលោកប្រកាសថា គ្រីស្តបរិស័ទជាងមួយពាន់នាក់ទៅជាសន្តបុគ្គល ។ លោកទទួលមរណភាពថ្ងៃ ២ មេសា ២០០៥ ។



*លោកយ៉ូហានប៉ូលទី ២ (ឆ្នាំ ១៩៧៨ - ២០០៥)*

Layout Histor.qxd 2/10/07 10:11 AM Page 248

## ១២- លោកបេណេឌិកតូ ទី ១៦

ក្រុមទីប្រឹក្សាអភិបាលក្រុងរ៉ូម ជ្រើសរើសលោក**រ៉ាតស៊ីនកែរ** (Ratzinger) ជាជនជាតិអាល្លឺម៉ង់ អាយុ ៧៨ ឆ្នាំ ឲ្យបន្តមុខងារជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម នៅថ្ងៃ ១៩ មេសា ២០០៥ ។ កាលពីមុន លោកជាប្រធានក្រសួងរក្សាការពារជំនឿឲ្យគង់វង្ស និងជាសហការីជិតស្និទ្ធិរបស់លោក**យ៉ូហានប៉ូល ទី ២** ។ លោកដាក់ឈ្មោះខ្លួនឯងថា « **បេណេឌិកតូ ទី ១៦** » ដោយនឹកដល់សន្តបេណេឌីកតូ ជាបព្វជិតមួយអង្គ ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្នុងកំណើតព្រះសហគមន៍នៅទ្វីបអឺរ៉ុប និងនឹកដល់អភិបាលក្រុងរ៉ូម បេណេឌីកតូ ទី ១៥ ដែលយកចិត្តទុកដាក់រកផ្លូវសន្តិភាពនៅពេលកើតសង្គ្រាមលោកលើកទី ១ ។



*លោកបេណេឌីកតូ ទី ១៦ (ឆ្នាំ ២០០៥)*

*ប្រវត្តិព្រះសហគមន៍មិនចប់ទេ គឺនៅតែបន្តទៅទៀត ។ យើងម្នាក់ៗបន្តប្រវត្តិនេះតាមចំណែករៀងៗខ្លួន តពីគ្រីស្តបរិស័ទជំនាន់មុនៗ ។ ក្នុងសៀវភៅនេះ ប្រហែលបងប្អូនបានស្ងើចសរសើរគ្រីស្តបរិស័ទដែលមានជំនឿ មានប្រាជ្ញា មានសេចក្តីក្លាហាន ។ល ។ បងប្អូនក៏ប្រហែលព្រួយចិត្តដោយឃើញថា គ្រីស្តបរិស័ទខ្លះកំសាក ឬនាំព្រះសហគមន៍ឲ្យបាក់បែក ឬឲ្យវង្វេង ។ល ។ ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត ហើយនាំដំណឹងល្អរហូតមកយើង ឲ្យមនុស្សលោកសព្វថ្ងៃ និងនៅពេលក្រោយទៀត ដោយមានព្រះវិញ្ញាណណែនាំផង ។ សូមព្រះវិញ្ញាណបំភ្លឺចិត្តគំនិតយើងទាំងអស់គ្នា ឲ្យបញ្ជូនកេរអាករដែលយើងបានទទួលពីដូនតាមកបន្តឲ្យកូន ឲ្យចៅ ដូចអ្នកនិពន្ធគម្ពីរដំណឹងល្អពីដើមថែងថា សូម «យកទ្រព្យទាំងចាស់ (គឺព្រះបន្ទូលរបស់ព្រះយេស៊ូ) ទាំងថ្មី (គឺព្រះបន្ទូលនេះបកស្រាយតាមសភាពការណ៍ថ្មី) ចេញពីឃ្លាំងរបស់គាត់» (មថ ១៣,៥២) ។*

| ព្រឹត្តិការណ៍នយោបាយ ព្រះចៅអធិរាជ និង ស្តេច | កាលបរិច្ឆេទ | ព្រឹត្តិការណ៍សាសនា | អភិបាលព្រះសហគមន៍ក្រុងរ៉ូម | អ្នកនិពន្ធ |
|---|---|---|---|---|
| ព្រះចៅទីបែរ (១៤-៣៧) | ៣០ | ព្រះយេស៊ូសោយទិវង្គត | | |
| | ៣៦ | លោក**ស្ទេផាន**បូជាជីវិតជាមរណសាក្សី | | |
| ព្រះចៅកាលីគូឡា (៣៧-៤១) | ៣៧ | លោក**ប៉ូល**ប្រែចិត្តគំនិតជឿ | លោក**សិលា** ? | |
| ព្រះចៅក្លូដ (៤១-៥៤) | ៤៥ | លោក**ប៉ូល**ធ្វើដំណើរប្រកាសដំណឹងល្អលើកដំបូង (កក ១៣-១៤) | | |
| | ៤៩ | «មហាមហាសន្និបាតនៅយេរូសាឡឹម» (កក ១៥) | | |
| | ៥០ | ព្រះរាជក្រឹត្យបណ្តេញជនជាតិយូដាចេញពីក្រុងរ៉ូម (កក ១៨,២) | | |
| | ៥១ | លោក**ប៉ូល**នៅក្រុងកូរិនថូស | | ថេស្សាឡូនិក |
| ព្រះចៅណេរ៉ុង(៥៤-៦៨) | ៥៨ | គេចាប់លោក**ប៉ូល**នៅក្រុងយេរូសាឡឹម | | រ៉ូម |
| | ៦០ | លោក**ប៉ូល**ទៅដល់ក្រុងរ៉ូម | | |
| | ៦២ | លោក**យ៉ាកុប**ជាបងប្អូនរបស់ព្រះអម្ចាស់បូជាជីវិត | | |
| អគ្គីភ័យនៅក្រុងរ៉ូម | ៦៤ | ទុក្ខបុកម្នេញ- លោក**សិលា**បូជាជីវិត (?) | | |
| ព្រះចៅវេសប៉ាស៊ីយ៉ាំង (៦៧-៧៩) | ៦៧ | លោក**ប៉ូល**បូជាជីវិតនៅក្រុងរ៉ូម (?ឬ ៦៣) | លោក**លីណូ** (៦៤-៧៦) | ដំណឹងល្អសហចក្ខុ (៦៥-៨០) |
| កងទ័ពរ៉ូម៉ាំងបំផ្លាញក្រុងយេរូសាឡឹម | ៧០ | | លោក**អាណាក្លេ** (៧៦-៩៨) | |
| | ៩៥ | លោក**យ៉ូហាន**នៅប៉ាតម៉ូស | លោក**ក្លេម៉ង់** (៩៨-៩៧) | លោកយ៉ូហាន វិវរណៈ |
| ព្រះចៅត្រាយ៉ាណូ (៩៨-១១៧) | | | | ឌីដាខែ |
| | ១១០ | លោក**អ៊ីញ៉ាស**ជាអភិបាលក្រុងអន់ទីយ៉ូកបូជាជីវិត(?) | | គង្វាលរបស់លោក**ហែរម៉ាស** |
| | ១១១ | ទុក្ខបុកម្នេញនៅតំបន់ប៊ីធីនី | | លិខិតលោកព្លីន |
| ព្រះចៅអន់ទូណាំង (១៣៨-១៦២) | ១៦១ | លោក**ប៉ូលីកាប**ជាអភិបាលក្រុងស្មៀរណាបូជាជីវិត | | |
| ព្រះចៅម៉ាក់-អូរែល (១៦២-១៨០) | ១៦៣ | លោក**យូស្ទាំង**បូជាជីវិតនៅក្រុងរ៉ូម | | សេចក្តីដោះសារ (លោក**យូស្ទាំង**) |
| | ១៧៧ | មរណសាក្សីនៅក្រុងលីយ៉ុង ។ លោក**អ៊ីរេណេ**ជាអភិបាលក្រុងលីយ៉ុង | លោក**អេឡឺថែរ** (១៧៥-១៨៩) | ល.**ទែរទូលីយ៉ាំង** (១៦០-២២០) |
| | ២០២ | ទុក្ខបុកម្នេញគ្រីស្តបរិស័ទ | លោក**វិកទ័រ** (១៨៩-១៩៩) | លិខិតផ្ញើជូនលោកឌីយ៉ូញែត |
| ព្រះចៅសែបទីមសេវែរ (១៩៣-២១១) | ២៤២ | លោក**ម៉ានី** សម្តែងធម្មទេសនាមុនដំបូង | លោក**កាលីស្ត** (២១៧-២២២) | |
| ព្រះចៅម៉ាក់ស៊ីម៉ាំង (២៣៥-២៣៩) | ២៤៩ | លោក**ស៊ីព្រីយ៉ាំង** ជាអភិបាលព្រះសហគមន៍កាតាស្ស | លោក**ក័រណេល្យូស** (២៥១) | លោក**អូរីសែន** (១៨៥-២៥៣) |
| ព្រះចៅដែស្ស (២៤៩-២៥១) | ២៥០ | ទុក្ខបុកម្នេញទូទៅ | លោក**ស្ទេផាន** (២៥៤-២៥៧) | |
| | ២៥៨ | លោក**ស៊ីព្រីយ៉ាំង**បូជាជីវិត | | |
| ព្រះចៅវ៉ាលេរីយ៉ាំង (២៥៣-២៦០) | ២៧០ | លោក**អន់ទន**នៅវាលរហោស្ថាន (?) | | |
| ព្រះចៅឌីយ៉ូក្លេស៊ីយ៉ាំង (២៨៤-៣០៥) | ២៩៣ | | | |
| ព្រះចៅ ៤អង្គ | ៣០៣ | ព្រះរាជក្រឹត្យធ្វើទុក្ខបុកម្នេញ | លោក**ស៊ីលវេស្ត្រ** (៣១៤-៣៣៥) | លោក**អេប្រ្ហែម**នៅនីស៊ីប |
| | | | | លោក**អឺសែប**នៅសេសារ៉េ |
| | ៣១២ | | | |
| ព្រះចៅអធិរាជកុងស្តង់តាំងមានជ័យជម្នះ | ៣១៣ | ព្រះរាជក្រឹត្យនៅមីឡង់ ព្រះសហគមន៍បានសេចក្តីសុខសាន្ត | | |
| | ៣១៤ | មហាសន្និបាតនៅអារល្លឺ (រឿងលោកដូណាត) | | |

Layout Histor.qxd 2/10/07 10:11 AM Page 250

| | | | | |
|---|---|---|---|---|
| | ៣១៨ | លោក**អារីយ៉ូស**ទទួលទោស | | |
| | ៣២៥ | មហាសន្និបាតសកលនៅនីសេ (ទី ១) | | លោក**អាថាណាស្ស**នៅអាឡិចសង់ឌ្រី |
| កំណើតក្រុងកុងស្តង់ទីណូប្ល | ៣៣០ | | លោក**យូលីយូស** (៣៣៧-៣៥២) | លោក**ហ៊ីឡែរ**នៅព័រជេ |
| ព្រះចៅកុងស្តង់ (៣៣៧-៣៦១) | ៣៤០ | លោក**វុលហ្វីឡា**ជាអភិបាលកុលសម្ពន្ធហ្គោត | លោក**លីបែរ** (៣៥២-៣៦៦) | លោក**ស៊ីរិល**នៅយេរូសាឡឹម |
| ព្រះចៅយូលីយាំងក្បត់គ្រីស្តសាសនា | | | លោក**ដាម៉ាស** (៣៦៦-៣៨៤) | លោក**បាស៊ីល**នៅសេសារ៉េ |
| | ៣៧០ | លោក**ម៉ារតាំង**ជាអភិបាលព្រះសហគមន៍ ទួរ | | លោក**គ្រេគ័រ**នៅណាស៊ីយ៉ង្ស |
| ព្រះចៅទេអូដូស (៣៧៨-៣៩៥) | ៣៨០ | សាសនាកាតូលិកជាសាសនារបស់រដ្ឋ | | លោក**គ្រេគ័រ**នៅនីស្ស |
| | ៣៨១ | មហាសន្និបាតកុងស្តង់ទីណូប្ល (ទី ២) | | |
| | ៣៨៦ | លោក**អូគូស្តាំង**ប្រែចិត្តគំនិត | លោក**ស៊ីរិល** (៣៨៤-៣៩៩) | លោក**យេរ៉ូម** (៣៤៧-៣៩៧) |
| | ៣៩៥ | ចក្រភពរ៉ូម៉ាំងបែងចែកជាពីរផ្នែក | | |
| | ៣៩៦ | លោក**អូគូស្តាំង**ជាអភិបាលព្រះសហគមន៍ក្រុងហ៊ីប៉ុន | | គម្ពីរប្រជាជន (Vulgate) |
| កុលសម្ពន្ធអាល្លឺម៉ង់លុកលុយ | ៣៩៨ | លោក**យ៉ូហានគ្រីសូស្តូម**ជាអភិបាលក្រុងកុងស្តង់ទីណូប្ល | | |
| | | លោក**អំប្រាស៍**ជាអភិបាលក្រុងមីឡង់ | | លោក**ស៊ីរិល**នៅអាឡិចសង់ឌ្រី |
| | ៤០៧ | លោក**យ៉ូហានគ្រីសូស្តូម**បូជាជីវិត | | លោក**ទេអូដូរែត** |
| កុលសម្ពន្ធមនុស្សព្រៃវាយយកក្រុងរ៉ូម | ៤១០ | | លោក**សេឡេស្តាំង** (៤២២-៤៣២) | *ទីក្រុងរបស់ព្រះជាម្ចាស់* |
| | ៤៣១ | មហាសន្និបាតនៅអេភេសូ (ទី ៣) | | |
| | ៤៣២ | សន្ត **ប៉ាទ្រិក** ប្រកាសដំណឹងល្អនៅស្រុកអៀរឡង់ | | |
| | ៤៥១ | មហាសន្និបាតនៅកាល់សេដូន (ទី ៤) | លោក**ឡេអូ** (៤៤០-៤៦១) | លោក**វ៉ាំងសង់**នៅឡេរាំង |
| | ៤៧៦ | ចក្រភពរ៉ូម៉ាំងនៅបស្ចឹមប្រទេសរលំ | | |
| ព្រះបាទក្លូវីស (ជាតិហ្វ្រង់) (៤៨២-៥១១) | ៤៨៦ | | | |
| ព្រះចៅយូស្ទីញ៉ាំង(៥២៧-៥៦៥) | ៥៣៧ | ការសាងសង់ព្រះវិហារសន្តី**សូភី**នៅកុងស្តង់ទីណូប | លោក**វីស៊ីល**(៥៣៧-៥៥៥) | *ក្បួនច្បាប់ព្រះចៅយូស្ទីញ៉ាំង (៥៤០)* |
| | ៥៤០ | | | *ធម្មវិន័យរបស់សន្ត* **បេណេឌិកតូ** |
| | ៥៥៣ | មហាសន្និបាតនៅកុងស្តង់ទីណូប្ល ២ (ទី ៥) | | |
| កុលសម្ពន្ធស្លាវលុកលុយអឺរុបខាងកើត | ៥៩៦ | លោក**អូគូស្តាំង** នៅកង់តូបេរី | | លោក**គ្រេគ័រ**នៅទួរ |
| ព្រះចៅហេរាក្លីយូស (៦១០-៦៤១) | ៦២២ | លោក**មហាម៉ាត់** (អេសៀវ) កំណើត**អ៊ីស្លាម** | | |
| | ៧៥៦ | កំណើតរដ្ឋរបស់មហាបូជាចារ្យ | | |
| ព្រះចៅការូឡូម៉ាញ៉ូស | ៨០០ | | លោក**ឡេអូ**ទី ៣ (៧៩៥-៨១៦) | |
| | ៨៦៤ | លោក**ស៊ីរិល**និង**មេថូដ**ប្រកាសដំណឹងល្អដល់ជនជាតិស្លាវ | | |
| | ៩០៩ | ការសាងសង់វត្តគ្លូនី | | |
| | ៩៦៣ | កំណើតវត្តអារាមនៅភ្នំអាថូស | លោក**ឡេអូ**ទី ៩ (១០៤៩-១០៥៤) | |
| | ១០៥៤ | ព្រះសហគមន៍នៅបូព៌ា និងនៅបស្ចឹមបែកបាក់គ្នា | | |
| | ១០៥៩ | ទីប្រឹក្សាបោះឆ្នោតជ្រើសរើសអភិបាលក្រុងរ៉ូម | លោក**គ្រេគ័រ**ទី ៧ (១០៧៣-១០៨៥) | |
| | ១០៧៥ | លោក**គ្រេគ័រ**ទី ៧ កែទម្រង់ព្រះសហគមន៍ | | |
| | ១០៨៤ | លោក**ប្រ៊ុយណូ**តាំងវត្តអារាមនៅភ្នំសារត្រឺស | | |
| ច្បាំងដើម្បីព្រះគ្រីស្តដណ្តើមយកក្រុងយេរូសាឡឹម | ១០៩៩ | | | លោក**ប៊ែរណារ** (១០៩០-១១៥៣) |

Layout Histor.qxd 2/10/07 10:11 AM Page 251

| | | | | |
|---|---|---|---|---|
| | ១១២៣ | មហាសន្និបាតនៅឡាត្រង់ (ទី ៩) | | |
| | | | | លោក**ដូមីនិកូ** (១១៧០-១២២១) |
| | ១១៧៣ | លោក**វ៉ាលដូ**ទេសនានៅលីយ៉ុង | | លោក**ប្រាំងស្វ័រ** នៅអាស៊ីស៊ី |
| | ១២៣២ | អភិបាលព្រះសហគមន៍ស្វែងរកអ្នកវង្វេងជំនឿ | | (១១៨១-១២២៦) |
| | ១២៩១ | | | លោក**ថូម៉ាស**នៅអាគីណូ |
| | ១៣០៧ | លោក**យ៉ូហាន** នៅម៉ុងទេក័រវីនូ | | (១២២៧-១២៧៤) |
| | | អភិបាលព្រះសហគមន៍ នៅប៉េកាំង | អភិបាលក្រុងរ៉ូមនៅអាវីញ៉ុង | លោកគ្រូ**អេកខរ** (១២៦០-១៣២៧) |
| | ១៤៣៩ | មហាសន្និបាតនៅហ្លូរង់ (ទី ១៧) | (១៣០៥-១៣៧៧) | នាង**កាតារីណា**នៅស៊ីយ៉ែណា |
| | ១៤៥៥ | លោក**ហ្គោតំបែរ**បោះពុម្ពព្រះគម្ពីរ | | (១៣៤៧-១៣៨០) |
| លោកគ្រីស្តូស្ត កូឡុំ | ១៤៩២ | | លោក**អាឡិចសង់**ទី ៦ (១៤៩២-១៥០៣) | លោក**អេរ៉ាស្ម** (១៤៦៩-១៥៣៦) |
| | ១៤៩៣ | ការចែកពិភពលោកជាពីរ | លោក**យូលីយូស**ទី ២ (១៥០៣-១៥១៣) | លោក**ថូម៉ាស់ ម៉ូរ** (១៤៧៨-១៥៣៥) |
| ព្រះបាទហង់រីទី ៨ (១៥០៩-១៥៤៧) | ១៥១៧ | លោក**លូធែរ**បិទប្រជានបទ ៩៥ ប្រការ | | |
| ព្រះចៅសាលកិង(១៥១៩-១៥៥៦) | | | | លោក**អុីញ៉ាស់** នៅឡូយ៉ូឡា (១៤៩១-១៥៥៦) |
| | ១៥២១ | គេដេញលោក**លូធែរ**ចេញពីព្រះសហគមន៍ | | |
| លោកម៉ាសេឡង់ | ១៥២៤ | | | នាង**ថេរេសា** នៅអាវីឡា (១៥១៥-១៥៨២) |
| | ១៥២៦ | លោក**រ៉ូបែរនៅណូប៊ីស៊ី** ទៅប្រទេសឥណ្ឌា | | |
| សង្គ្រាមស៊ីវិល (ថូម៉ាស មីងសែរ) | | សេចក្ដីប្រកាសជំនឿនៅក្រុងអូសបួរ | លោក**ប៉ូល**ទី ៣ (១៥៣៤-១៥៤៩) | |
| | ១៥៣០ | លោក**កាលវ៉ាំង**នៅហ្សឺណែវ | | |
| | ១៥៤១ | មហាសន្និបាតនៅត្រេន្ត (ទី ១៩) (១៥៤១-១៥៦៣) | | លោក**យ៉ូហាន**ដែលស្រឡាញ់ឈើឆ្កាង |
| | ១៥៤៥ | លោក**ហ្វ្រង់ស្វ័រសាវីយេ**នៅប្រទេសជប៉ុន | | (១៥៤២-១៥៩១) |
| | ១៥៤៩ | | លោក**ប៉ូល**ទី ៤ (១៥៥៥-១៥៥៩) | |
| ព្រះបាទភីលីពទី ២ (១៥៥៦-១៥៩៨) | ១៥៥៥ | លោក**ហ្គាសប៉ារដាគ្រូស**មកដល់ប្រទេសកម្ពុជា | លោក**ពីយ៉ូ**ទី ៤ (១៥៥៩-១៥៦៥) | |
| | ១៥៧១ | ចម្បាំងនៅឡេប៉ង់ | លោក**ពីយ៉ូ**ទី ៥ (១៥៦៦-១៥៧២) | |
| | ១៥៨២ | លោក**ម៉ាថេអូ-រីជី** នៅប្រទេសចិន | | លោក**ហ្វ្រង់ស្វ័រ** នៅសាល (១៥៦៧-១៦២២) |
| | ១៦៣៣ | គេដាក់ទោសលោកកាលីឡេអុី | លោក**អាឡិចសង់**ទី ៧ (១៦៥៥-១៦៦៧) | |
| | ១៦៤០ | លោក**យ៉ង់សែន** | | លោក**វ៉ាំងសង់** នៅប៉ូល (១៥៨១-១៦៦០) |
| | ១៦៥៩ | អភិបាលតំណាងអភិបាលក្រុងរ៉ូមចេញទៅទ្វីបអាស៊ី | | |
| | ១៦៧៨ | | លោក**ក្លេម៉ង់** ទី ១១ (១៧០០-១៧២១) | លោក**ប៉ាស្កាល់** (១៦២៣-១៦៦២) |
| | ១៧៣៨ | លោក**យ៉ូហានវ៉េស្លេ** ប្រែចិត្តគំនិត | | លោក**រីសា ស៊ីម៉ុង** (១៦៣៨-១៧១២) |
| | ១៧៤២ | ការហាមធ្វើពិធីតាមអរិយធម៌ចិន | លោក**បេណេឌិកតូ**ទី ១៤ | |
| | | | (១៧៤០-១៧៥៨) | |
| | ១៧៧៣ | ការបិទក្រុមគ្រួសារសហជីវិនព្រះយេស៊ូ | លោក**ក្លេម៉ង់** ទី ១៤ (១៧៦៩-១៧៧៤) | |
| សហរដ្ឋអាមេរិក ឯករាជ្យ | ១៧៧៦ | | | |
| បដិវត្តន៍បារាំង | ១៧៨៩ | | | |

Layout Histor.qxd 2/10/07 10:11 AM Page 252

| | | | | |
|---|---|---|---|---|
| ព្រះចៅណាប៉ូឡេអុងទី ១ (១៨០៤-១៨១៤) | ១៨០៤ | | លោក**ពីយ៉ូ**ទី ៧ (១៨០០-១៨២៣) | |
| | ១៨៣២ | | លោក**គ្រេគ័រ**ទី ១៦ (១៨៣១-១៨៤៦) | *"យើងនឹកឆ្ងល់"* |
| | ១៨៥៩ | | | *"កំណើតជាតិទាំងឡាយ"* លោក**ដាវិន** |
| សហពន្ធកម្មករអន្តជាតិដំបូង | ១៨៦៤ | *"បញ្ជីប្រកាស"* | | លោក**កាល់-ម៉ាក់** (១៨១៨-១៨៨៣) |
| សម័យម៉ៃជិ នៅប្រទេសជប៉ុន | ១៨៦៨ | | លោក**ពីយ៉ូ**ទី ៩ (១៨៤៦-១៨៧៨) | *មូលធន* |
| | ១៨៦៩ | មហាសន្និបាតនៅវ៉ាទីកង់ទី ១ (ទី ២០) | | |
| សង្គ្រាមបារាំងនិងអាល្លឺម៉ង់ | ១៨៧០ | | | |
| ទ័ពអ៊ីតាលីលេបយករដ្ឋមហាបូជាចារ្យ | ១៨៧១ | | | |
| | | | លោក**ឡេអូ**ទី ១៣ (១៨៧៨-១៩០៣) | |
| | ១៨៩០ | កំណើតគ្រីស្ថានព្រះគម្ពីរ នៅយេរូសាឡឹម | | *"សភាពការណ៍ថ្មីទាំងអស់ "* |
| | | | លោក**ពីយ៉ូ**ទី ១០ (១៩០៣-១៩១៤) | នាង**ថេរេសា**នៃកុមារយេស៊ូ |
| សង្គ្រាមលោកលើកទី ១ (១៩១៤-១៩១៨) | | | ល.**បេណេឌិកតូ**ទី ១៥ (១៩១៤-១៩២២) | (១៨៧៣-១៨៩៧) |
| | ១៩២៤ | កំណើតយុវជនកម្មករគ្រីស្តបរិស័ទ | លោក**ពីយ៉ូ**ទី ១១ (១៩២២-១៩៣៩) | លោក**កាឌីន** (១៨៨២-១៩៦៧) |
| | ១៩៣១ | | | *"ឆ្នាំទីសែសិប"* |
| លោកអ៊ីត្លែរកាន់អំណាច | ១៩៣៣ | ការដាក់ទោសលទ្ធិហ្វាស៊ីស្តនិយម | | |
| | ១៩៣៧ | ការដាក់ទោសលទ្ធិជាតិសង្គមនិយម | លោក**ពីយ៉ូ**ទី ១២ (១៩៣៩-១៩៥៨) | |
| សង្គ្រាមលោកលើកទី ២ (១៩៣៩-១៩៤៥) | ១៩៤៣ | | | *"ព្រះវិញ្ញាណបំភ្លឺ "* |
| សហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកបរមាណូ<br>នៅអ៊ីរ៉ូស៊ីម៉ា | ១៩៤៥ | | | |
| | ១៩៤៨ | ក្រុមប្រឹក្សាជំនុំនិងព្រះសហគមន៍នៅហ្សឺណែវ | | |
| | ១៩៥៤ | ការហាមបូជាចារ្យជាកម្មករ | លោក**យ៉ូហាន**ទី ២៣ (១៩៥៣-១៩៦៣) | |
| | ១៩៦១ | | | *"ព្រះសហគន៍ជាព្រះមាតា និងព្រះគ្រូ"* |
| | ១៩៦២ | មហាសន្និបាតនៅវ៉ាទីកង់ទី ២ (ទី ២១)(១៩៦២-១៩៦៥) | | |
| | ១៩៦៣ | | លោក**ប៉ូល** ៦ (១៩៦៣-១៩៧៨) | *"សន្តិភាពនៅលើផែនដី "* |
| | ១៩៦៥ | ព្រះសហគមន៍រ៉ូម និង កុងស្តង់ទីណូប្លរួបរួមគ្នា | | |
| មនុស្សជាន់ឋានព្រះច័ន្ទ | ១៩៦៦ | | | |
| | ១៩៦៨ | | | |
| | ១៩៨៦ | ប្រជុំអធិដ្ឋានអន្តរសាសនានៅអាស៊ីស៊ី | លោក**យ៉ូហាន-ប៉ូល** ទី ១ (១៩៧៨) | លោក**ម៉ារតាំងលូថៃរគីញ** (១៩២៩- |
| | ១៩៩៩ | កាតូលិក និង លូថៃរីយ៉ាំងព្រមព្រៀងអំពីលទ្ធិជំនឿ | លោក**យ៉ូហាន-ប៉ូល** ទី ២ | ១៩៦៨) |
| | | | (១៩៧៨-២០០៥) | *"ជីវិតមនុស្ស"* |
| | | | លោក**បេណេឌិកតូ**ទី ១៦ (២០០៥) | |